ហាមលក់

ក្រសួងអប់រំ យុវជន និងកីឡា

# វិទ្យាសាស្ត្រ

# ជីវវិទ្យា

១១



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

ព្រះវិហារផ្លូវនៃព្រះគុណ
THE WAY OF GRACE CHURCH

# ជីវវិទ្យា

## ថ្នាក់ទី ១១

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៥៧ មហាវិថី ព្រះនរោត្តម ភ្នំពេញ

**គណៈកម្មការនិពន្ធ** អ្នកស្រី យិម យីហ៊ុប អ្នកស្រី ហែម វ៉ាន់នី
អ្នកស្រី ស្រី សុម៉ាលី អ្នកស្រី វ៉ាល់ សោរ

**អ្នកខាយអត្ថបទ** អ្នកស្រី ហាក់ ផាន្នី

**វិចិត្រករ** លោក តន់ ជាតិ

**អ្នករៀបរៀង** លោក វ៉ា វុទ្ធី

**អ្នករចនាទំព័រ** លោក ហាក់ វណ្ណថា

**គណៈកម្មការពិនិត្យ** លោក ម៉ម ចាន់សៀន លោកស្រី ហ៊ុយ ចន្ទូ
លោកស្រី ចក់ ហ៊ីម លោកស្រី ឈី រូប៊ីយ៍

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ២២៩២ អយក.ប្រក. ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៨ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ព ( ឆ្នាំ២០១២ )

ISBN 9-789-995-000-707

# អារម្ភកថា

សៀវភៅជីវវិទ្យាថ្នាក់ទី 11 បានចងក្រងឡើងជាជំនួយដល់ប្អូនសិស្សានុសិស្ស ក្នុងការសិក្សាមុខវិជ្ជានេះ ។

ដើម្បីឆ្លើយតបនិងកម្មវិធីសិក្សាថ្មីសម្រាប់មធ្យមសិក្សាទុតិយភូមិឆ្នាំ 2005-2009 គណៈកម្មការនិពន្ធយើងខ្ញុំបានខិតខំជ្រើសរើសសម្រិតសម្រាំងនូវខ្លឹមសារមេរៀនទាំងនេះប្រកបដោយអត្ថន័យសំខាន់ៗស្របទៅនឹងកម្រិតយល់ដឹងរបស់សិស្ស ។

ដោយនៅថ្នាក់ទី 11 នេះ សិស្សត្រូវជ្រើសរើសមុខវិជ្ជាសម្រាប់រៀនបន្តទៀត ហើយជីវវិទ្យាជាមុខវិជ្ជាជម្រើសមួយក្នុងចំណោមមុខវិជ្ជាវិទ្យាសាស្ត្រ ។ ដូចនេះខ្លឹមសារនៃមេរៀននីមួយៗមានលក្ខណៈទូលំទូលាយនិងស៊ីជម្រៅថែមទៀត ដើម្បីឱ្យសិស្សយល់កាន់តែច្បាស់នូវអត្ថប្រយោជន៍នៃមុខវិជ្ជានេះ ដែលផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅរបស់ប្រជាជនយើង ។

តែទោះជាយ៉ាងនេះក្តី គណៈកម្មការនិពន្ធយើងខ្ញុំយល់ថាសៀវភៅនេះនៅមានកង្វះខាតខ្លះៗជាមិនខាន ។

គណៈកម្មការនិពន្ធយើងខ្ញុំ សូមថ្លែងអំណរគុណព្រមទាំងរង់ចាំទទួលដោយរីករាយជានិច្ចនូវការរិះគន់ កែតម្រូវគ្រប់យ៉ាងពីសំណាក់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមិត្តអ្នកអានទាំងអស់ដើម្បីធ្វើឱ្យសៀវភៅនេះកាន់តែមានគុណភាពល្អប្រសើរឡើង ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ


ទំព័រ

**ជំពូក1 : កោសិកា** ............ 1

1. សមាសធាតុគីមីក្នុងកោសិកា ............ 2

2. រូបផ្គុំនិងនាទីកោសិកា ............ 10

3. ដំណុះដំណាលកោសិកានិងរូបផ្គុំសារពាង្គកាយរស់ ............ 24

**ជំពូក2 : ការបន្តពូជនិងការលូតលាស់** ............ 37

1. កំណកោសិកាបន្តពូជ ............ 38

2. ការលូតលាស់របស់អំប្រីយ៉ុង ............ 54

**ជំពូក3 : តំណពូជ** ............ 73

1. ច្បាប់តំណពូជ ............ 74

2. ក្រូម៉ូសូម ............ 92

**ជំពូក4 : អាហារនិងការរំលាយអាហាររបស់មនុស្ស** ............ 115

1. អាហារ ............ 116

2. ការរំលាយអាហារ ............ 124

**ជំពូក5 : បណ្ដូរឧស្ម័ននិងការបញ្ចេញចោលរបស់សត្វ** ............ 137

1. បណ្ដូរឧស្ម័នរបស់សត្វ ............ 138

2. ការបញ្ចេញចោល ............ 150

**ជំពូក6 : ប្រតិកម្មរវាងសត្វនិងមជ្ឈដ្ឋាន** ............ 163

1. របត់ឈាមនិងភាពស៊ាំ ............ 164

2. ថេរលំនឹង ............ 186

**ជំពូក7 : រូបផ្គុំរុក្ខជាតិមានសរសៃនាំ** ............ 195

1. ជាលិការុក្ខជាតិ ............ 196

2. ឫស ............ 204

3. ដើមនិងស្លឹក ............ 212

**ជំពូក8 : ជីវវិទ្យានិងសុខភាព** ............ 225

1. ការប្រយុទ្ធប្រឆាំងនិងជំងឺ ............ 226

2. អាហារនិងសុខភាព ............ 238

**បទានុក្រម** ............ 248

# ជំពូក 1 កោសិកា



ជីវវិទ្យា គឺជាការសិក្សាពីជីវិតនៅលើផែនដី ។ ភាវៈរស់នៅលើផែនដីមានរាប់លានប្រភេទខុសៗគ្នា។ ភាវៈរស់ខ្លះមានរូបរាងតូចៗក្រៃលែងដែលយើងមិនអាចមើលឃើញបានដូចជា អាមីប វីរុស បាក់តេរី ហើយភាវៈរស់ខ្លះទៀតមានរូបរាងធំខ្ពស់ មានទម្ងន់រាប់រយតោនដូចជា មនុស្ស ត្រីបាឡែន ដំរី ដើមឈើ ។

តើភាវៈរស់ទាំងអស់នេះបង្កឡើងពីធាតុបង្កដូចគ្នាឬខុសគ្នា?

តើសារពាង្គកាយទាំងនោះផ្គុំឡើងពីអ្វី?

ហេតុអ្វីបានជាភាវៈរស់ខ្លះមានមាឌតូច ខ្លះមានមាឌធំ?

មេរៀនទី

# 1 សមាសធាតុគីមីក្នុងកោសិកា

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីទម្រង់គ្លុយស៊ីត លីពីត ប្រូទីត និងអាស៊ីតនុយក្លេអ៊ិច ។
- ❑ ប្រៀបធៀបសមាសធាតុសរីរាង្គនិងសមាសធាតុអសរីរាង្គ ។
- ❑ បង្ហាញពីសារៈសំខាន់របស់អង់ស៊ីម ។

ភាវៈរស់ទាំងអស់សុទ្ធតែផ្គុំឡើងដោយធាតុបង្កដូចៗគ្នា ។ តើធាតុបង្កអ្វីខ្លះដែលគេប្រទះឃើញក្នុងកោសិកាភាវៈរស់?

## 1. សមាសធាតុអសរីរាង្គ

យើងចង់ដឹងថា តើសារពាង្គកាយផ្គុំឡើងដោយធាតុអ្វីខ្លះ? ចូរសាកល្បងធ្វើការពិនិត្យតាមដានពិសោធន៍ដូចខាងក្រោម ។




*រូបទី 1.1 ៈពិសោធន៍រកសមាសធាតុគីមីក្នុងស្លឹក*

យើងដាក់ស្លឹករុក្ខជាតិទៅក្នុងបំពង់សាក (ឬស្លាបព្រាហើយគ្របបន្ទះកញ្ចក់ពីលើ)រួចដាក់វាលើភ្លើង ។ ស្លឹកពណ៌បៃតងប្រែពណ៌ជាខ្មៅ បង្ហាញថាក្នុងស្លឹកផ្ទុកសមាសធាតុ កាបូន ។ នៅជាប់ផ្ទៃខាងក្នុងបំពង់សាកឬក្រោមកញ្ចក់មានតំណក់ទឹកតូចៗ ។ បើយើងដុតបន្តទៀត ស្លឹកដែលមានពណ៌ខ្មៅប្រែពណ៌បន្តិចម្តងៗទៅជាពណ៌ប្រផេះដែលបញ្ជាក់ថា សារធាតុកាបូនត្រូវបានឆេះអស់ ។ សារធាតុពណ៌ប្រផេះនៅសល់ គឺជាផេះដែលបង្ហាញវត្តមានសមាសធាតុខនិជ ។ ក្រោយពិសោធន៍យើងសន្និដ្ឋានថា ភាវៈរស់ទាំងអស់(សត្វនិងរុក្ខជាតិ) បង្កឡើងដោយសមាសធាតុ**សរីរាង្គ**(កាបូន)និងសមាសធាតុ**អសរីរាង្គ**(ទឹក អំបិលខនិជ) ។

កោសិកានីមួយៗមានធាតុគីមីចំនួនជាង 60 ។ សារធាតុដែលបង្កឡើងដោយអាតូមតែមួយហើយមិនអាចបំបែកជាសារធាតុងាយបានហៅថាអង្គធាតុទោល ។ ***ឧទាហរណ៍*** កាបូន អ៊ីដ្រូសែន អាសូត... ។ កាលណាធាតុពីរឬច្រើនចងភ្ជាប់គ្នាដោយសម្ព័ន្ធគីមីបង្កើតបានជាម៉ូលេគុលឬសមាសធាតុ ។ ***ឧទាហរណ៍*** ម៉ូលេគុលទឹកផ្សំឡើងដោយអាតូមអ៊ីដ្រូសែន2ភ្ជាប់និងអាតូមអុកស៊ីសែន1 ។ សមាសធាតុខ្លះមានម៉ូលេគុលតូចៗដែលហៅថា ម៉ូណូមែ ។ ម៉ូណូមែច្រើនភ្ជាប់គ្នាជាច្រវាក់បង្កើតជាប៉ូលីមែ ។

***ឧទាហរណ៍*** អាស៊ីតអាមីនេឬអាមីណូអាស៊ីតជាធាតុបង្ករបស់ប្រូតេអ៊ីន ។ គេអាចនិយាយថា អាស៊ីតអាមីនេជាម៉ូណូមែ ដែលប៉ូលីមែជាប្រូតេអ៊ីន ។ កាលណាម៉ូលេគុលមួយមានម៉ូណូមែច្រើនពីរាប់រយដល់រាប់ពាន់ គេហៅម៉ូលេគុលនោះ ថាជា **ម៉ាក្រូម៉ូលេគុល** ។

សមាសធាតុអសរីរាង្គ ជាសមាសធាតុមិនផ្ទុកធាតុកាបូនទេ លើកលែងកាបូនឌីអុកស៊ីត $CO_2$ ។ សមាសធាតុអសរីរាង្គសំខាន់ៗដែលច្រើនជួបប្រទះក្នុងសារពាង្គកាយមាន **ទឹក អំបិលខនិជ** កាបូនឌីអុកស៊ីត បាស អាស៊ីត ។ ទឹកមាននាទីសំខាន់ណាស់ក្នុងកោសិកា ។ សារពាង្គកាយផ្ទុកទឹកប្រហែល 65% នៃទម្ងន់ខ្លួន ។ វារំលាយសារធាតុផ្សេងៗឱ្យទៅជាសូលុយស្យុង ទើបអាចមានបន្សាយចូលក្នុងកោសិកាបាន ។ ទឹកជួយរក្សារាង ទំហំ សីតុណ្ហភាព និងធ្វើឱ្យប្រតិកម្មគីមីផ្សេងៗក្នុងសារពាង្គកាយប្រព្រឹត្តទៅបានល្អ ។ នៅពេលគ្មានទឹកជីវិតកោសិកានិងសារពាង្គកាយទាំងអស់មិនអាចដំណើរការបានទេ ។ ក្រៅពីទឹក **អំបិលសំខាន់ៗ**មានអំបិលសូដ្យូម ប៉ូតាស្យូម កាល់ស្យូម ដែក ... ។ **អំបិលខនិជ**មានបរិមាណតិចតួចតែវាក៏ចាំបាច់ណាស់ដែរ ។

## 2. សមាសធាតុសរីរាង្គ

សមាសធាតុសរីរាង្គ ជាសមាសធាតុដែលផ្សំឡើងដោយធាតុកាបូន ។ សមាសធាតុសរីរាង្គសំខាន់ៗមានគ្លុយស៊ីត លីពីត ប្រូទីត និងអាស៊ីតនុយក្លេអ៊ិច ។ វាបង្កឡើងដោយកាបូន អ៊ីដ្រូសែន អុកស៊ីសែន និងអាសូតដែលមាន 96% នៃម៉ាសស្ងួតរបស់សារពាង្គកាយ ។ ក្នុងចំណោមធាតុទាំង4នេះកាបូនមាននាទីសំខាន់ជាងគេ ។ ដូចនេះគេហៅវាថា **ជាសមាសធាតុសរីរាង្គឬសមាសធាតុកាបូន** ។

### 2.1. គ្លុយស៊ីត

គ្លុយស៊ីត ជាសមាសធាតុសរីរាង្គដែលបង្កឡើងដោយអាតូមកាបូន អ៊ីដ្រូសែន និងអុកស៊ីសែន តាមសមាមាត្រប្រហែលៈ 1 : 2 : 1 ($CH_2O$) ។ គ្លុយស៊ីតងាយមានឈ្មោះថា **ម៉ូណូសាកាវីត**ឬហៅថា **ស្ករងាយ**(គ្លុយកូស ព្រុចតូស កាឡាក់តូស) ។ ស្ករងាយទាំង3នេះមានរូបមន្ត ដូចគ្នាគឺ $C_6H_{12}O_6$ ។ រូបខាងស្តាំបង្ហាញពីភាពខុសគ្នារវាងស្ករងាយទាំង3 ប្រភេទនេះ ។




គ្លុយកូស ព្រុចតូស កាឡាក់តូស

*ភាពខុសគ្នារវាងស្ករងាយ 3 ប្រភេទ*

សមាសធាតុដែលកើតពីការភ្ជាប់គ្នារវាងម៉ូណូសាការីត 2 ឬស្ករងាយ 2 ហៅថា **ឌីសាការីត** ដែលមានរូបមន្ត $C_{12}H_{22}O_{11}$ ។ ឌីសាការីតមាន ម៉ាល់តូស ស៊ុចក្រូស(សាការ៉ូស) និងឡាក់តូស

ម៉ូណូសាការីត + ម៉ូណូសាការីត ⟶ ឌីសាការីត + ទឹក

គ្លុយកូស + គ្លុយកូស ⟶ ម៉ាល់តូស + $H_2O$

$$C_6H_{12}O_6 + C_6H_{12}O_6 \longrightarrow C_{12}H_{22}O_{11} + H_2O$$

ការភ្ជាប់នេះធ្វើតាមលំនាំមួយហៅថាប្រតិកម្មសំយោគដោយផ្តាច់ម៉ូលេគុលទឹក ។

ឌីសាការីតអាចបំបែកតាមលំនាំមួយដោយការបញ្ចូលទឹកហៅថាប្រតិកម្មអ៊ីដ្រូលីស ។

ម៉ាល់តូស + $H_2O$ ⟶ គ្លុយកូស + គ្លុយកូស

$$C_{12}H_{22}O_{11} + H_2O \longrightarrow C_6H_{12}O_6 + C_6H_{12}O_6$$

ម៉ូណូសាការីតច្រើនភ្ជាប់គ្នាបង្កើតបានជា **ប៉ូលីសាការីត** ដូចជា អាមីដុង គ្លីកូសែន សែលុយឡូសជាដើម ។ រុក្ខជាតិស្តុកស្ករលើសក្រោមទម្រង់ជាអាមីដុង ។ អាមីដុងជាម៉ាក្រូម៉ូលេគុលដែលបានមកពីការភ្ជាប់គ្លុយកូសរាប់រយម៉ូលេគុល ។ សត្វស្តុកគ្លុយកូស ក្រោមទម្រង់ជាគ្លីកូសែននៅក្នុងថ្លើមនិងក្នុងកោសិកាសាច់ដុំ ។ ប៉ូលីសាការីតក៏អាចបំបែកជាគ្លុយកូសវិញ នៅពេលកោសិកាត្រូវការថាមពល ។ គ្លុយកូស ជាប្រភពថាមពលដ៏សំខាន់សម្រាប់ប្រើប្រាស់ក្នុងគ្រប់សកម្មភាពទាំងអស់របស់កោសិកា ។ ថាមពលត្រូវបានស្តុកទុកនៅក្នុងសម្ព័ន្ធគីមីដែលបង្កើតម៉ូលេគុលគ្លុយស៊ីត ។ កាលណាសម្ព័ន្ធគីមីត្រូវបានផ្តាច់ ថាមពលក៏ត្រូវបានបញ្ចេញ ។ ប៉ូលីសាការីតមួយទៀតដែលមានតែនៅលើរុក្ខជាតិគឺ សែលុយឡូស ។ សែលុយឡូសចូលរួមបង្កើតភ្នាសកោសិកា ទ្រទ្រង់រុក្ខជាតិឱ្យមានភាពរឹងមាំ និងដើបត្រង់ឡើងលើ ។

## 2.2. លីពីត

លីពីតក៏ដូចជាគ្លុយស៊ីតដែរ ។ វាជាសមាសធាតុសរីរាង្គបង្កឡើងដោយ អាតូមកាបូន អ៊ីដ្រូសែន និងអុកស៊ីសែន ប៉ុន្តែវាខុសពីគ្លុយស៊ីតដោយមានអាតូមអុកស៊ីសែនតិច តែមានអាតូមអ៊ីដ្រូសែនច្រើន ។

***ឧទាហរណ៍ :*** ខ្លាញ់គោជាលីពីតមានរូបមន្ត $C_{57}H_{110}O_6$ ។

លីពីតដែលយើងធ្លាប់ស្គាល់មានខ្លាញ់ ប្រេង និងក្រមួន(ទៀន) ។ ខ្លាញ់និងក្រមួនមានសភាពរឹង ឯប្រេងមានសភាពរាវ ។ លីពីតកើតពីបណ្តុំរវាងគ្លីសេរ៉ុលនិងអាស៊ីតខ្លាញ់ ។ គ្លីសេរ៉ុលជាអាល់កុលសរីរាង្គដែលមានកាបូន 3 អាតូម ហើយអាតូមនីមួយៗភ្ជាប់ទៅនឹងអ៊ីដ្រុកស៊ីល(–OH )មួយ ។ អាស៊ីតខ្លាញ់នីមួយៗ គឺជាច្រវាក់វែងនៃកាបូននិងអ៊ីដ្រូសែន ដែលខាងចុងមានបណ្តុំកាបុកស៊ីល(–COOH ) ។

គ្លីសេរ៉ុល + អាស៊ីតខ្លាញ់ ⟶ ទឹក + លីពីត

$$\begin{array}{l} CH_2OH \\ | \\ CHOH \\ | \\ CH_2OH \end{array} + 3[COOH-(CH_2)_{16}-CH_3] \longrightarrow 3H_2O + \begin{array}{l} CH_2-O-CO-C_{17}H_{35} \\ | \\ CH-O-CO-C_{17}H_{35} \\ | \\ CH_2-O-CO-C_{17}H_{35} \end{array}$$




កាបូននីមួយៗនៃអាស៊ីតខ្លាញ់ភ្ជាប់គ្នាទៅវិញទៅមកដោយសម្ព័ន្ធទោល ។ គេហៅថា **អាស៊ីតខ្លាញ់ឆ្អែត** ព្រោះវាមានអាតូមអ៊ីដ្រូសែនគ្រប់គ្រាន់ ។ តែបើអាតូមកាបូនភ្ជាប់គ្នាដោយសម្ព័ន្ធទ្វេ គេហៅថា **អាស៊ីតខ្លាញ់មិនឆ្អែត** ព្រោះវាមានអាតូមអ៊ីដ្រូសែនមិនគ្រប់គ្រាន់ ។ ដូចនេះបើលីពីតកើតពីអាស៊ីតខ្លាញ់ឆ្អែត គេហៅថា **លីពីតឆ្អែត** ។ លីពីតឆ្អែតមាននៅក្នុងសាច់ឬខ្លាញ់ ហើយកកជានិច្ចនៅក្នុងសីតុណ្ហភាពធម្មតា ។ លីពីតបែបនេះអាចបង្កជាជំងឺបេះដូង កាលណាវាមានបរិមាណច្រើនក្នុងសរសៃឈាម ។ តែបើលីពីតកើតពីអាស៊ីតខ្លាញ់មិនឆ្អែតគេហៅថា **លីពីតមិនឆ្អែត** ។ លីពីតប្រភេទនេះមាននៅក្នុងប្រេង វាមិនកកហើយមិនបង្កជាជំងឺទេ ។

លីពីតផ្តល់ថាមពលច្រើនជាងគ្លុយស៊ីត ។ មនុស្សនិងថនិកសត្វខ្លះអាចសំយោគខ្លាញ់ចាំបាច់បានដោយខ្លួនឯង ។ ដូចនេះខ្លាញ់មិនសូវសំខាន់ទេក្នុងរបបអាហារប្រចាំថ្ងៃ ។

លីពីតក៏មានសារៈសំខាន់ដែរ ដោយសារវាផ្តល់ថាមពលនិងស្តុកថាមពលសម្រាប់ប្រើប្រាស់នៅពេលត្រូវការ ។ ***ឧទាហរណ៍*** ខ្លាឃ្មុំនៅសិសិររដូវរស់បានដោយសារថាមពលស្តុកទុកក្នុងលីពីត ។ លីពីតត្រូវបានប្រើប្រាស់សម្រាប់បង្កើតភ្នាសកោសិកា រំលាយវីតាមីនមួយចំនួន និងការពារស្បែកបន្ថយរំហួតនៃទឹក ។

## 2.3. ប្រូទីត

ប្រូទីត ជាសមាសធាតុសរីរាង្គផ្គុំឡើងដោយអាតូមកាបូន អ៊ីដ្រូសែន អុកស៊ីសែន និងអាសូត ។ ក្នុងករណីខ្លះមានបន្ថែមផូស្វ័រនិងស្ពាន់ធ័រទៀតផង ។ ប្រូទីតជាសមាសធាតុសំខាន់សម្រាប់ជីវិត ព្រោះវាមាននាទីបង្កើតទម្រង់កោសិកា ជួយក្នុងការកន្ត្រាក់សាច់ដុំ ដឹកនាំអុកស៊ីសែន ផ្តល់ភាពស៊ាំសម្រាប់ការលូតលាស់ និងជួសជុលកោសិកាចាស់ៗព្រមទាំងជួយជំរុញប្រតិកម្មគីមីផ្សេងៗ ។ គេចែកប្រូទីតជាបីក្រុមគឺ

### ក. អាស៊ីតអាមីនេ(ឬអាមីណូអាស៊ីត )

| | |
|---|---|
| រូបមន្តទូទៅ | $R-\underset{NH_2}{\underset{\vert}{CH}}-COOH$ |
| អាឡានីន | $CH_3-\underset{NH_2}{\underset{\vert}{CH}}-COOH$ |
| សេរីន | $CH_2OH-\underset{NH_2}{\underset{\vert}{CH}}-COOH$ |

អាមីណូអាស៊ីត ជាធាតុបង្កតូចៗរបស់ប្រូតេអ៊ីនឬជាម៉ូណូមែររបស់ប្រូតេអ៊ីន ។ ប្រូតេអ៊ីន ជាប៉ូលីមែររបស់អាមីណូអាស៊ីត ។ អាមីណូអាស៊ីតមួយមានបណ្តុំកាបុកស៊ីល($-COOH$ ) រ៉ាឌីកាល់R និងបណ្តុំអាមីន($-NH_2$ )នៅលើអាតូមកាបូនតែ

មួយ ។ អាមីណូអាស៊ីតមានជាង 20 ប្រភេទខុសៗគ្នា ។ រូបមន្តទូទៅរបស់អាមីណូអាស៊ីតគឺ

$NH_2-\underset{R}{\underset{|}{CH}}-COOH$ អាមីណូអាស៊ីតទាំងនោះខុសគ្នាដោយរ៉ាឌីកាល់ R ។

### ខ. ប៉ិបទីត

សម្ព័ន្ធកូវ៉ាឡង់ដែលភ្ជាប់អាមីណូអាស៊ីតពីរហៅថា ចំណងប៉ិបទីត ។ អាមីណូអាស៊ីតពីរ ភ្ជាប់គ្នាដោយចំណងប៉ិបទីតមួយបង្កើតបានជាឌីប៉ិបទីត ដោយផ្ដាច់បណ្ដុំ(OH) និង(H) បង្កើតបានមួយម៉ូលេគុលទឹក ។ កាលណាអាមីណូអាស៊ីតបីភ្ជាប់គ្នាបង្កើតបានជាទ្រីប៉ិបទីត ។ ប៉ូលីប៉ិបទីតបង្កើតឡើងដោយអាមីណូអាស៊ីតច្រើន (រាប់រយ) ភ្ជាប់គ្នាដោយសម្ព័ន្ធប៉ិបទីត ។




### គ. ប្រូតេអ៊ីន

ប្រូតេអ៊ីនកើតពីប៉ូលីប៉ិបទីតមួយឬប៉ូលីប៉ិបទីតច្រើន ។ តំណលំដាប់អាមីណូអាស៊ីតកំណត់យថាប្រភេទនៃប្រូតេអ៊ីន(ចំនួន ទីតាំង និងប្រភេទអាមីណូអាស៊ីត) ។ អាមីណូអាស៊ីតទាំង20 ប្រៀប ដូចជាព្យញ្ជនៈ 33 តួដែលបង្កើតបានជាពាក្យច្រើនរាប់មិនអស់ ។ កាលណាអ្នកដូរព្យញ្ជនៈមួយតួនៅក្នុងពាក្យមួយឬឃ្លាមួយន័យពាក្យឬឃ្លានោះក៏ដូរដែរ ។

- **អង់ស៊ីម**

អង់ស៊ីមជាប្រូតេអ៊ីនមួយប្រភេទនៅក្នុងកោសិកាសារពាង្គកាយ ។ អង់ស៊ីមមាននាទីជំរុញល្បឿនប្រតិកម្មគីមីផ្សេងៗ រួមមានប្រតិកម្មសំយោគនិងប្រតិកម្មបំបែកនៅក្នុងកោសិកា ។ បើគ្មានអង់ស៊ីមនោះទេ ប្រតិកម្មគីមីសំខាន់ៗប្រព្រឹត្តទៅយ៉ាងយឺតឬមិនដំណើរការ ឬប្រព្រឹត្តទៅលុះត្រាមានសីតុណ្ហភាពខ្ពស់ឬក្នុងមជ្ឈដ្ឋានអាស៊ីតឬបាសខ្លាំង ។ អង់ស៊ីមបង្កើនល្បឿនប្រតិកម្មរំលាយអាហារសំយោគម៉ូលេគុលផ្សេងៗ ស្តុកនិងបញ្ចេញថាមពល ។ យថាប្រភេទនៃអង់ស៊ីមមានដូចខាងក្រោម




*អំពើនៃសីតុណ្ហភាពទៅលើល្បឿនប្រតិកម្ម*

- អង់ស៊ីមមួយមានអំពើទៅលើប្រតិកម្មគីមីតែមួយប៉ុណ្ណោះ ។ ក្នុងសារពាង្គកាយមនុស្សមានអង់ស៊ីមប្រហែល 2 000 ប្រភេទខុសៗគ្នា ដូចនេះក៏មានប្រតិកម្មគីមីប្រហែល 2 000 ប្រភេទដែរ ។
- អង់ស៊ីមមួយមានអំពើទៅលើសារធាតុមួយប៉ុណ្ណោះ ។ ***ឧទាហរណ៍*** អាមីឡាសបំបែកបានតែអាមីដុង លីប៉ាសបំបែកបានតែលីពីត ។




***អំពើនៃpH ទៅលើល្បឿននៃប្រតិកម្មរបស់អង់ស៊ីម***

- អង់ស៊ីមមានសកម្មភាពក្នុងសីតុណ្ហភាពសមស្រប ។ វាគ្មានសកម្មភាពទេ កាលណាសីតុណ្ហភាពទាបពេកឬខ្ពស់ពេក ។ អង់ស៊ីមភាគច្រើនមានសកម្មភាពខ្លាំងក្នុងសីតុណ្ហភាពពី 40 ទៅ 50°C ។
- អង់ស៊ីមមានសកម្មភាពក្នុងមជ្ឈដ្ឋានអាស៊ីត (ពី pH7 ទៅ 4.5) និងមជ្ឈដ្ឋានអាកាល់ឡាំង (ពី pH7 ទៅ 9) ។

## 2.4. អាស៊ីតនុយក្លេអ៊ិច

អាស៊ីតនុយក្លេអ៊ិច ជាសមាសធាតុសរីរាង្គមួយយ៉ាងសំខាន់ក្នុងកោសិកា ។ វាជាម៉ាក្រូម៉ូលេគុលសាំញ៉ាំ ដែលបង្កឡើងដោយអាតូមកាបូន អ៊ីដ្រូសែន អុកស៊ីសែន អាសូត និងផូស្វ័រ ។ អាស៊ីតនុយក្លេអ៊ិចស្តុកនិងបញ្ជូនព័ត៌មានសេនេទិចពីកោសិកាមេទៅឱ្យកោសិកាកូនក្នុងពេលកោសិកាធ្វើចំណែក ។ អាស៊ីតនុយក្លេអ៊ិចមានពីរប្រភេទគឺ ADN និង ARN ។

### ក. ADN (អាស៊ីតដេអុកស៊ីរីបូនុយក្លេអ៊ិច)

ADN ជាប្រភេទអាស៊ីតនុយក្លេអ៊ិចដែលជាធាតុបង្ករបស់ក្រូម៉ូសូមក្នុងណ្វៃយ៉ូ ។ វាកើតពីនុយក្លេអូទីត ។ នុយក្លេអូទីតនីមួយៗផ្សំឡើងដោយបាសអាសូតមួយ ស្ករដេអុកស៊ីរីបូសមួយ និងបណ្តុំផូស្វាតមួយ ។ បាសអាសូតមានបួនប្រភេទគឺ អាដេនីន(A) ស៊ីតូស៊ីន(C) គានីន(G) និងទីមីន(T) ដូចនេះនុយក្លេអូទីតក៏មានបួនប្រភេទខុសគ្នាដែរ ។ ADN កើតពីច្រវាក់នុយក្លេអូទីតពីរខ្សែ ។ វាមាននាទីផ្ទុកព័ត៌មានសេនេទិច ដែលជាប្លង់សាងសង់ម៉ូលេគុលប្រូតេអ៊ីននិងមាននាទីត្រួតពិនិត្យសកម្មភាពរបស់កោសិកា ។

### ខ. ARN (អាស៊ីតរីបូនុយក្លេអ៊ិច)

ARN ជាប្រភេទអាស៊ីតនុយក្លេអ៊ិចដែលស្ថិតនៅក្នុងស៊ីតូប្លាសនិងនុយក្លេអូល ។ វាមានធាតុបង្កស្រដៀងនិង ADN ដែរ តែខុសគ្នាត្រង់ស្ករបស់ ARN គឺស្កររីបូស បាសរបស់ ARN គឺអ៊ុយរ៉ាស៊ីល (U) ដែលជំនួសអាដេនីន (A) របស់ ADN ។ ARN កើតពីច្រវាក់នុយក្លេអូទីតទោល ។ វាមាននាទីចម្លងព័ត៌មានសេនេទិច ហើយបញ្ជូនទៅកាន់ស៊ីតូប្លាសដើម្បីដឹកនាំសំយោគម៉ូលេគុលប្រូតេអ៊ីន ។

## មេរៀនសង្ខេប

- កោសិកានៃសារពាង្គកាយមានផ្ទុកសមាសធាតុអសរីរាង្គផងនិងសមាសធាតុសរីរាង្គផង ។
- សមាសធាតុអសរីរាង្គជាសមាសធាតុដែលមិនផ្ទុកអាតូមកាបូន ។ ទឹកជាសមាសធាតុដែលមានសមាមាត្រច្រើនជាងគេ ព្រោះវាមាននាទីសំខាន់ណាស់ក្នុងកោសិកា ។
- សមាសធាតុសរីរាង្គ ជាសមាសធាតុផ្ទុកអាតូមកាបូន ។ វាមានបួនប្រភេទ គឺគ្លុយស៊ីត លីពីត ប្រូទីត និងអាស៊ីតនុយក្លេអ៊ិច ។
- គ្លុយស៊ីតផ្សំឡើងដោយអាតូម កាបូន អ៊ីដ្រូសែន និងអុកស៊ីសែន ។ គ្លុយស៊ីតចែកជាស្ករងាយ (ម៉ូណូសាការីត) ឌីសាការីតនិងប៉ូលីសាការីត ។ គ្លុយស៊ីត ជាប្រភពថាមពល ។ គ្លុយស៊ីតត្រូវបានបម្រុងទុកក្រោមទម្រង់ជាអាមីដុង ។ សែលុយឡូសជាគ្លុយស៊ីតពិសេសមានចំពោះតែរុក្ខជាតិ ។ សត្វស្តុកគ្លុយស៊ីតក្រោមទម្រង់ជាគ្លីកូសែនក្នុងថ្លើមនិងក្នុងសាច់ដុំ ។
- លីពីតផ្សំឡើងដោយអាតូម កាបូន អ៊ីដ្រូសែន និងអុកស៊ីសែនដូចគ្លុយស៊ីតដែរ ។ វាកើតពីអាស៊ីតខ្លាញ់និងគ្លីសេរ៉ុល ។ លីពីតផ្តល់ថាមពលច្រើនជាងគ្លុយស៊ីត ។
- ប្រូតេអ៊ីនផ្សំឡើងដោយអាតូម កាបូន អ៊ីដ្រូសែន អុកស៊ីសែន និងអាសូត ។ អាមីណូអាស៊ីតជាម៉ូណូមែរបស់ប្រូតេអ៊ីន ។ អាមីណូអាស៊ីតភ្ជាប់គ្នាពីមួយទៅមួយដោយសារចំណងប៉ិបទីត ។ ប្រូតេអ៊ីននីមួយៗខុសគ្នា ដោយសារចំនួន ប្រភេទ និងតំណលំដាប់អាមីណូអាស៊ីត ។ អង់ស៊ីមជាប្រភេទប្រូតេអ៊ីនមាននាទីសំខាន់ក្នុងការជំរុញល្បឿនប្រតិកម្មគីមីផ្សេងៗក្នុងកោសិកា(ជាកតាលីករជីវៈ) ។
- អាស៊ីតនុយក្លេអ៊ិច ជាសមាសធាតុសំខាន់នៃជីវិត ។ វាមានពីរប្រភេទគឺ ADN និង ARN ។

## ? សំណួរនិងលំហាត់

1. ដូចម្តេចហៅថាសមាសធាតុសរីរាង្គ ? សមាសធាតុអសរីរាង្គ?
2. តើសមាសធាតុសរីរាង្គ 4 ក្រុមដែលមាននៅក្នុងភាវៈរស់គឺអ្វីខ្លះ ?
3. តើម៉ូណូសាការីត ឌីសាការីត និងប៉ូលីសាការីតខុសគ្នាដូចម្តេច ?
4. តើលីពីតជាអ្វី ? តើលីពីតមានប្រយោជន៍អ្វីខ្លះចំពោះភាវៈរស់ ?
5. ចូរពណ៌នាពីទម្រង់ប្រូតេអ៊ីន ។
6. ដូចម្តេចហៅថាអង់ស៊ីម? តើវាមានមុខងារអ្វីខ្លះ? ចូរនិយាយពីឫថាប្រភេទនៃអង់ស៊ីម ។
7. ចូរពណ៌នាពីនាទីអាស៊ីតនុយក្លេអ៊ិច ។
8. ប្រូតេអ៊ីនមួយមានអាមីណូអាស៊ីត 480 ។ តើមានចំណងប៉ិបទីតប៉ុន្មាន ដើម្បីភ្ជាប់អាមីណូអាស៊ីតទាំងនោះ? តើមានទឹកប៉ុន្មានម៉ូលេគុល ដែលបានរំដោះចេញពីការសំយោគប្រូតេអ៊ីននេះ?

# ពិសោធន៍ : សង្កេតគ្រាប់អាមីដុងនិងកំណាត់លក្ខណៈរបស់អាមីដុង

## 1. វត្ថុបំណង

- សង្កេតមើលគ្រាប់អាមីដុងដោយមីក្រូទស្សន៍
- ធ្វើអត្តសញ្ញាណអាមីដុងជាមួយសូលុយស្យុងអ៊ីយ៉ូត
- បំផុសចំណូលចិត្តធ្វើពិសោធន៍ ។

## 2. សម្ភារៈ

កែវដាក់ទឹក បំពង់ពិសោធន៍ឬកែវជ័រ ម្សៅអង្ករ ដំឡូងឬចេក ទឹកអ៊ីយ៉ូត បំពង់បន្តក់ មីក្រូទស្សន៍ ។

## 3. រំលឹកចំណេះដឹង

អាមីដុងជាគ្លុយស៊ីត ។ វាកើតពីស្ករងាយ(គ្លុយកូស) រាប់រយ ។ រុក្ខជាតិស្តុកស្តុរលើសតម្រូវការប្រើប្រាស់ក្រោមទម្រង់ជាអាមីដុង ។ អាមីដុងសម្បូរនៅលើបាយ នំប៉័ង ចេក ដំឡូង ។

## 4. ដំណើរការពិសោធ

### 4.1. ការសង្កេតគ្រាប់អាមីដុង

លាយម្សៅជាមួយទឹកដាក់ក្នុងកែវទឹកមួយ (ឬកោសសាច់ផ្លែចេក ហើយលាយជាមួយនឹងទឹក) ។ យកល្បាយនេះមួយតំណក់ដាក់លើកញ្ចក់ រួចគ្របបន្ទះកញ្ចក់ស្តើងពីលើ ហើយសង្កេតមើលក្នុងមីក្រូទស្សន៍ ។

### 4.2. ពិសោធន៍រកលក្ខណៈគីមីរបស់អាមីដុង

ចាក់ទឹកម្សៅអាមីដុងទៅក្នុងបំពង់ពិសោធន៍(ឬក្នុងកែវថ្លា)បន្ទាប់មកបន្តក់ទឹកអ៊ីយ៉ូត ។ ឱ្យសិស្សប្រៀបធៀបទឹកអាមីដុងមុននិងក្រោយពិសោធន៍ ។

## 5. សន្និដ្ឋាន

ទឹកអ៊ីយ៉ូតធ្វើឱ្យល្បាយម្សៅអាមីដុង (គ្លុយស៊ីត) ដែលមានពណ៌សប្រែពណ៌ទៅជាស្វាយ ។

# 2 រូបផ្គុំនិងនាទីកោសិកា

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីទម្រង់កោសិកាសត្វនិងកោសិការុក្ខជាតិ ។
- រៀបរាប់ពីទម្រង់និងនាទីផ្សេងៗនៃធាតុកោសិកានីមួយៗ ។
- ប្រៀបធៀបកោសិកាសត្វនិងកោសិការុក្ខជាតិ ។
- ពណ៌នាពីបន្សាយនិងអូស្មូស ។
- ប្រៀបធៀបដំណឹកនាំសកម្មនិងដំណឹកនាំអកម្ម ។

ភាវៈរស់នៅលើផែនដីមានរាប់លានប្រភេទនិងមានទំហំ រូបរាងខុសៗគ្នា ។ ខ្លះមានរូបរាងធំអាចមើលឃើញដោយភ្នែកទទេបាន ។ ខ្លះទៀតតូចៗមិនអាចមើលឃើញដោយភ្នែកទទេបានទេ ។ អ្នកវិទ្យាសាស្ត្របានរិះរកមធ្យោបាយ ដើម្បីផលិតឧបករណ៍ផ្សេងៗយកមកប្រើប្រាស់ សម្រាប់មើលភាវៈរស់តូចៗទាំងនោះ ។ លោកអង់តូនវ៉ាន់ឡឺវិនហុក(Anton vanleew wenhock) ជីវវិទូ អាល្លឺម៉ង់ បានផលិត មីក្រូទស្សន៍មុនដំបូងគេបង្អស់ ។ តាមរយៈមីក្រូទស្សន៍នោះ គាត់អាចមើលឃើញវត្ថុមានជីវិតតូចៗដែលពីមុនពុំមាននរណាម្នាក់អាចមើលឃើញឡើយ ។

លោក រ៉ូប៊ែ ហ៊ូក(*Robert hook*)ជនជាតិអង់គ្លេស បានប្រើប្រាស់មីក្រូទស្សន៍សង្កេតមើលចំណិតស្តើងៗនៃឫសរុក្ខជាតិ ។ គាត់បានឃើញបន្ទប់តូចៗជាច្រើនតម្រៀបគ្នានៅក្នុងឫសរុក្ខជាតិ ។ គាត់ហៅបន្ទប់តូចៗទាំងនោះ ថាកោសិកា ។

## 1. ធាតុកោសិកានិងនាទី

មានកោសិកាច្រើនប្រភេទណាស់ ដែលមានទំហំនិងរូបរាងខុសៗគ្នា ។ ***ឧទាហរណ៍*** កោសិកាមនុស្សពេញវ័យមានប្រហែល $10^{18}$ ហើយកោសិកានីមួយៗមានអង្កត់ផ្ចិតពី 5 ទៅ 20μm ។ ក្នុងស្បែក $1cm^2$ មានកោសិកាប្រហែល 155 000 ។ ទោះបីវាមានទំហំនិងរូបរាងខុសៗគ្នាក៏ដោយក៏កោសិកាទាំងអស់មានលក្ខណៈជាមូលដ្ឋានបីយ៉ាងដូចគ្នា គឺគ្រប់កោសិកាទាំងអស់មានភ្នាស ស៊ីតូប្លាសនិងណ្វៃយ៉ូ ។ កោសិកាដែលគ្មានណ្វៃយ៉ូដូចជា បាក់តេរី វីរុសជាដើម ហៅថា ប្រូការីយ៉ូត ។ កោសិកា

ដែលមានណៃ្វយ៉ូពេញលេញហៅថា អឺការីយ៉ូត (*ឧទាហរណ៍* កោសិកាក្នុងសារពាង្គកាយពហុកោសិកា) ។ តាមការសង្កេតដោយមីក្រូទស្សន៍អេឡិចត្រូនិច កោសិកាបង្ហាញនូវធាតុនីមួយៗរបស់វាដូចខាងក្រោម ។




*រូបទី 2.1 : កោសិកាសត្វ*




*រូបទី 2.2 : កោសិការុក្ខជាតិ*

## 1.1. ភ្នាសសែលុយឡូស

កោសិការុក្ខជាតិ សារាយ និងបាក់តេរីខ្លះមានភ្នាសមួយព័ទ្ធពីក្រៅហៅថា **ភ្នាសសែលុយឡូស** ។ ភ្នាសសែលុយឡូសមានច្រើនស្រទាប់ ។ កន្លែងដែលកោសិកាពីរជាប់គ្នា គឺជាស្រទាប់កើតពីជាតិស្អិតហៅថា **ប៉ិចទីន** ។ ប៉ិចទីន គឺជាប៉ូលីសាការីត ដែលផ្សារភ្ជាប់កោសិកាជាមួយគ្នា ។ ស្រទាប់ទីមួយកើតពីសែលុយឡូសជាសរសៃដែលជួយភ្នាសឱ្យមានភាពយឺត ។ ស្រទាប់ទីពីរកើតពីសែលុយឡូស

និងលីញ៉ីន ។ លីញ៉ីនជាសារធាតុជួយឱ្យភ្នាសមិនជ្រាបទឹក រឹងមាំ ធន់នឹងជំងឺ ។ ភ្នាសសែលុយឡូសជួយការពារនិងទ្រទ្រង់រុក្ខជាតិឱ្យលូតត្រង់ឡើងលើ ។ ភ្នាសនេះមានរន្ធតូចៗដែលអនុញ្ញាតឱ្យទឹក អុកស៊ីសែន ឧស្ម័នកាបូនិច និងសារធាតុដទៃទៀតឆ្លងកាត់ចេញចូលក្នុងកោសិកាបាន(រូបទី 2.3) ។



*រូបទី 2.3 : ទម្រង់ភ្នាសសែលុយឡូស*

## 1.2. ភ្នាសកោសិកា (ឬភ្នាសស៊ីតូប្លាស)

នៅក្រោមភ្នាសសែលុយឡូសនៃកោសិការុក្ខជាតិមានភ្នាសកោសិកា ។ កោសិកាសត្វមានភ្នាសនេះតែមួយទេ ។ ឯកោសិការុក្ខជាតិមានភ្នាសសែលុយឡូសផងនិងភ្នាសកោសិកាផង ។ ភ្នាសកោសិកាកើតពីស្រទាប់លីពីតពីរស្រទាប់ ហៅថាស្រទាប់លីពីតទ្វេ ។ ស្រទាប់នីមួយៗបង្កើតឡើងដោយបណ្ដុំផូស្វាតមួយម៉ូលេគុលនិងអាស៊ីតខ្លាញ់ពីរម៉ូលេគុល ហៅថា ផូស្វ័រលីពីត (រូបទី 2.4) ។ ស្រទាប់លីពីតទ្វេអនុញ្ញាតឱ្យលីពីតនិងសារធាតុដែលរលាយក្នុងលីពីតឆ្លងកាត់បាន ។ រូបខាងក្រោមនេះ បានបង្ហាញថា ភ្នាសកោសិកាក៏មានប្រភេទប្រូតេអ៊ីនផ្សេងៗនិងគ្លុយស៊ីតផងដែរ ។



*រូបទី 2.4 : ភ្នាសកោសិកាមានប្រូតេអ៊ីនជាច្រើនដែលមានមុខងារផ្សេងៗ*

ភ្នាសស៊ីតូប្លាសមានរន្ធតូចៗជាច្រើនសម្រាប់ឱ្យសារធាតុឆ្លងកាត់ ហើយរារាំងសារធាតុធំៗមិនឱ្យជ្រាបចូលបាន ។ វាជាភ្នាសមានជម្រាបជ្រើស ។ រន្ធទាំងនេះត្រួតពិនិត្យចលនាចេញចូលនៃសារធាតុទាំងនោះ គឺវារក្សាលំនឹងនៃកោសិកា ។

## 1.3. ណ្វៃយ៉ូ

ណ្វៃយ៉ូមានទម្រង់ជាដុំមូល ធំ ស្រអាប់ស្ថិតនៅក្នុងកោសិកា។ ណ្វៃយ៉ូកោសិកាអឺការីយ៉ូតមានអង្កត់ផ្ចិតពី 2 ទៅ 5µm ។ វាជាមជ្ឈមណ្ឌលមួយប្រៀបដូចខួរក្បាលសម្រាប់ត្រួតពិនិត្យសកម្មភាព

កោសិកា ។ ណៃ្វយ៉ូផ្ទុកអាស៊ីតនុយក្លេអ៊ិច ដែលមាន 2 ប្រភេទគឺ ADN និង ARN ។ ADN មាននាទីផ្ទុកព័ត៌មានសេនេទិច ដែលជាប្លង់សាងសង់ប្រូតេអ៊ីន ។ ម៉ូលេគុល ADN ត្រូវបញ្ជូនពីជំនាន់មួយទៅជំនាន់មួយទៀតពេលកោសិកាចែកខ្លួន ។ ARN មាននាទីចម្លងព័ត៌មានសេនេទិចរបស់ ADN នៅក្នុងណៃ្វយ៉ូ រួចដឹកនាំសំយោគប្រូតេអ៊ីននៅក្នុងស៊ីតូប្លាស លើរីបូសូម ។ ដូចនេះ ADN និង ARN មានមុខងាររួមក្នុងសំយោគប្រូតេអ៊ីន ។

## ក. ភ្នាសណៃ្វយ៉ូ

ណៃ្វយ៉ូរុំព័ទ្ធដោយភ្នាសស្តើងមួយហៅថា **ភ្នាសណៃ្វយ៉ូ** ។ ភ្នាសនេះមានពីរស្រទាប់ ហើយមានរន្ធតូចៗរាយប៉ាយស្មើគ្នា សម្រាប់ឱ្យសារធាតុផ្សេងៗឆ្លងកាត់ ។

## ខ. ក្រូម៉ាទីន

នៅក្នុងណៃ្វយ៉ូ មានបណ្តាញសរសៃឆ្មារៗហៅថា**ក្រូម៉ាទីន** ។ ក្រូម៉ាទីនផ្ទុកសំភារៈតំណពូជ ។ វាកើតពី ADN និងប្រូតេអ៊ីនពិសេសមួយ ។ ពេលកោសិកាធ្វើចំណែក ក្រូម៉ាទីនរួញខ្លីក្លាយជាក្រូម៉ូសូម ។ ចំនួនក្រូម៉ូសូមក្នុងកោសិកាអឺការីយ៉ូតខុសគ្នាពីប្រភេទភាវៈរស់មួយទៅប្រភេទមួយទៀត ។ ***ឧទាហរណ៍*** កោសិកាមនុស្សមានក្រូម៉ូសូម 46 កោសិកាឆ្កែមានក្រូម៉ូសូម 78 ។ ក្រូម៉ូសូមផ្ទុកព័ត៌មានសំយោគប្រូតេអ៊ីន ហើយដឹកនាំសកម្មភាពផ្សេងៗក្នុងកោសិកា ។

## គ. នុយក្លេអូល

នុយក្លេអូលមានរាងជាដុំមូលនៅក្នុងណៃ្វយ៉ូ ។ វាបាត់រូបរាងនៅពេលកោសិកាចែកខ្លួន ហើយលេចរូបរាងឡើងវិញនៅក្នុងកោសិកាកូន ។ នុយក្លេអូលកើតពី ARN និងប្រូតេអ៊ីន ។ ក្រូម៉ាទីននិងនុយក្លេអូលអណ្តែតនៅក្នុងនុយក្លេអូប្លាស ដែលជាសារធាតុក្នុងណៃ្វយ៉ូ ។

# 1.4. ធាតុកោសិកាក្នុងស៊ីតូប្លាស

ក្រោមភ្នាសស៊ីតូប្លាស គឺជាប្រូតូប្លាស ។ បើគេដកយកណៃ្វយ៉ូចេញ អ្វីដែលនៅសល់ក្នុងកោសិកា គឺជាស៊ីតូប្លាស ។ ស៊ីតូប្លាសជាសារធាតុខាប់អន្ទិល បង្កឡើងដោយសមាសធាតុសរីរាង្គជាច្រើនដូចជា គ្លុយស៊ីត លីពីត ប្រូទីត ទឹក និងអំបិលខនិជ ។ ក្នុងស៊ីតូប្លាសមានធាតុតូចៗជាច្រើនហៅថា **ធាតុកោសិកា** ។ ធាតុនីមួយៗមានទម្រង់និងមាននាទីជាក់លាក់សម្រាប់ជួយទ្រទ្រង់ជីវិតកោសិកា ។

## ក. មីតូកុងទ្រី






រូបទី 2.5 : មីតូកុងទ្រី

មីតូកុងទ្រី ជាធាតុកោសិកាដែលមានរាងជាកូនដំបងតូចៗ ។ វាមានភ្នាស ពីរស្រទាប់គឺ ស្រទាប់ក្រៅរុំព័ទ្ធធាតុកោសិកានិងស្រទាប់ក្នុងមានរាងជាផ្នត់ៗ ដែលបង្កើនផ្ទៃមីតូកុងទ្រី ។ មីតូកុងទ្រីជាមជ្ឈមណ្ឌលផលិតថាមពល ។ វាបំប្លែងថាមពលគីមីស្តុកក្នុងអាហារឱ្យទៅជាសមាសធាតុដែលកោសិកាអាចប្រើប្រាស់បាន ។ ក្នុងមីតូកុងទ្រី អាហារងាយៗ ដូចជា ស្ករត្រូវបានបំបែកជាទឹក ឧស្ម័នកាបូនិច និងបញ្ចេញថាមពលតាមរយៈដង្ហើមកោសិកា ។ ថាមពលទាំងនោះស្តុកក្នុងមីតូកុងទ្រីក្រោមទម្រង់ជា ATP ។ កាលណាមានតម្រូវការថាមពល ATP ត្រូវបំបែកហើយផ្តល់ថាមពលសម្រាប់ប្រើប្រាស់រាល់សកម្មភាពរបស់កោសិកា ។ ចំនួនមីតូកុងទ្រីប្រែប្រួលទៅតាមតម្រូវការថាមពល ។ កោសិកាណាដែលសកម្មខ្លាំង មានមីតូកុងទ្រីច្រើន ។ កោសិកាសាច់ដុំមានមីតូកុងទ្រីពីរាប់រយដល់រាប់ពាន់ ។

## ខ. រីបូសូម

រីបូសូមមានទម្រង់ជាគ្រាប់ៗ ។ វាជាធាតុកោសិកាដែលតូចជាងគេ (តូចជាង 25nm ) ។ រីបូសូមស្ថិតនៅរាយប៉ាយក្នុងស៊ីតូប្លាសនិងនៅលើបណ្តាញរេទីគុយឡូមអង់ដូប្លាស ។ វាបង្កឡើងពី ARN និងប្រូតេអ៊ីន ។រីបូសូមជាកន្លែងសំយោគប្រូតេអ៊ីន ។ ប្រូតេអ៊ីនដែលសំយោគហើយ ត្រូវបានបញ្ជូនទៅរេទីគុយឡូមអង់ដូប្លាស បន្ទាប់មកត្រូវបានដឹកនាំទៅកាន់កន្លែងដែលត្រូវការ ។

## គ. រេទីគុយឡូមអង់ដូប្លាស(ឬបណ្តាញអង់ដូប្លាស)






រូបទី 2.6 : រេទីគុយឡូមគ្រើម

រេទិគុយឡូមអង់ដូប្លាស ជាបណ្ដាញបំពង់ដែលភ្ជាប់ចេញពីណ្វៃយ៉ូ ហើយខ្លះទៀតនៅរាយប៉ាយក្នុងស៊ីតូប្លាស ។ វាមាន 2 ប្រភេទ គឺរេទិគុយឡូមអង់ដូប្លាសរលីង (គ្មានរីបូសូម)និងរេទិគុយឡូមអង់ដូប្លាសគ្រើម (មានរីបូសូមភ្ជាប់លើផ្ទៃរេទិគុយឡូម) ។ ក្នុងកោសិកាខ្លះ អង់ស៊ីមពិសេសៗនិងសារធាតុគីមីត្រូវបានស្តុកទុកក្នុងរេទិគុយឡូមរលីង ។ ការសំយោគប្រូតេអ៊ីនកើតឡើងនៅក្នុងរីបូសូមដែលស្ថិតនៅសេរីក្នុងស៊ីតូប្លាស ។

## ឃ. ប្រដាប់កុលស៊ីឬឧបករណ៍កុលស៊ី

ប្រដាប់កុលស៊ី ជាថង់ឬបំពង់សំប៉ែតដែលស្ថិតនៅក្បែរណ្វៃយ៉ូ ។ ធាតុកោសិកានេះត្រូវបានគេហៅតាមឈ្មោះអ្នកដែលរកឃើញវា គឺលោកកាមីឡូកុលស៊ី (Camillogolgi) អ្នកវិទ្យាសាស្ត្រជនជាតិអ៊ីតាលី ។ ប្រូតេអ៊ីនដែលផលិតក្នុងរីបូសូមត្រូវបានវេចខ្ចប់ក្នុងថង់ ហើយបញ្ជូនទៅបណ្តាញអង់ដូប្លាសបន្ទាប់មកទៅឧបករណ៍កុលស៊ី ។ ក្នុងឧបករណ៍កុលស៊ី ប្រូតេអ៊ីនត្រូវបានកែច្នៃ ហើយវេចខ្ចប់ជាថ្មី រួចបញ្ជូនទៅក្រៅកោសិកា តាមភ្នាសកោសិកា ។



រូបទី 2.7 :ប្រដាប់កុលស៊ី

## ង. លីសូសូម

លីសូសូម ជាធាតុកោសិកាដែលមានទម្រង់ជាគ្រាប់តូចៗព័ទ្ធជុំវិញដោយភ្នាស ។ វាផ្ទុកសារធាតុគីមីនិងអង់ស៊ីម ចាំបាច់សម្រាប់រំលាយអាហារ ។ លីសូសូម មាននាទីរំលាយធាតុកោសិកាចាស់ៗនិងគ្មានប្រយោជន៍ ។ កោលិកាសនៃឈាមឬអាមីបអាចប្រើជើងបញ្ឆោតសម្រាប់ក្តោបអាហារ ។ អាហារត្រូវបានរំលាយដោយអង់ស៊ីមដែលបញ្ចេញដោយលីសូសូម ។ ជាទូទៅកោសិការុក្ខជាតិគ្មានលីសូសូមទេ ។

## ច. វ៉ាគុយអូល

វ៉ាគុយអូល ជាថង់ស្តុកទឹក អំបិល អាហារផ្សេងៗ និងកាកសំណល់ ។ កោសិការុក្ខជាតិខ្លះមានវ៉ាគុយអូលតូចៗហើយច្រើន ខ្លះទៀតមានវ៉ាគុយអូលតែមួយហើយធំពេញដោយទឹក ។ សម្ពាធទឹកនៅក្នុងវ៉ាគុយអូលធ្វើឱ្យរុក្ខជាតិរឹងមាំ លូតលាស់លឿន និងអាចទ្រទ្រង់ទម្ងន់ដ៏ធ្ងន់នៃស្លឹកនិងផ្កា ។ កោសិកាសត្វក៏មានវ៉ាគុយអូលដែរ តែតូចៗ ។

### ឆ. ប្លាស

ប្លាស ជាថង់តូចៗដែលមានតែក្នុងកោសិការុក្ខជាតិទេ(កោសិកាសត្វគ្មានប្លាសឡើយ) ។ ក៏ដូចមីតូកុងទ្រីដែរ ប្លាសមាន 2 ស្រទាប់ ។ ប្លាសមាននាទីផ្ទុកអាហារនិងសារធាតុពណ៌ផ្សេងៗ ។ ប្លាសមានបីប្រភេទគឺ

**ក្លរ៉ូប្លាស** : ប្លាសផ្ទុកជាតិពណ៌បៃតងដែលហៅថា ក្លរ៉ូភីល ។ ក្លរ៉ូភីលមាននាទីចាប់យកថាមពលពន្លឺព្រះអាទិត្យ ហើយបំប្លែងថាមពលនោះឱ្យទៅជាថាមពលគីមី សម្រាប់ផលិតអាហាររបស់វា គឺគ្លុយកូស ។

**ក្រូម៉ូប្លាស** : ប្លាសផ្ទុកជាតិពណ៌ផ្សេងៗក្រៅពីពណ៌បៃតង ដូចជាពណ៌ក្រហម លឿង ស្វាយ និងពណ៌ទឹកក្រូចជាដើម ។

**ឡឺកូប្លាស** : ប្លាសគ្មានពណ៌ ។ ឡឺកូប្លាសផ្ទុកអាមីដុង ។

### ជ. សង់ទ្រីយ៉ូល



*រូបទី 2.8 : ទម្រង់សង់ទ្រីយ៉ូល*

សង់ទ្រីយ៉ូល ជាធាតុកោសិការាងស៊ីឡាំង ។ សង់ទ្រីយ៉ូលមានមួយគូស្ថិតនៅកែងគ្នា បង្កើតជាតំបន់មួយហៅថា សង់ត្រូសូម ។ សង់ទ្រីយ៉ូលនីមួយៗកើតឡើងពីបំពង់ប្រូតេអ៊ីនតូចៗផ្គុំគ្នា បីៗចំនួន 9 តម្រៀបគ្នាជារង្វង់មូល ។ កោសិការុក្ខជាតិគ្មានសង់ត្រូសូមទេ លើកលែងតែសារាយនិងផ្សិត ។ សង់ត្រូសូម មាននាទីក្នុងកំណត្រយូងអាក្រូម៉ាទិច នៅពេលកោសិកាធ្វើចំណែក ។

កោសិកាសត្វនិងកោសិការុក្ខជាតិមានលក្ខណៈទូទៅដូចគ្នា ប៉ុន្តែវាក៏មានលក្ខណៈមួយចំនួនខុសគ្នាដែរ ។ កោសិការុក្ខជាតិមានភ្នាសសែលុយឡូស ប្លាស ជាពិសេសក្លរ៉ូភីលលើសពីកោសិកាសត្វ ។

## 2. បន្សាយនិងអូស្មូស

កោសិកា ជាឯកតាមានជីវិត ។ វាត្រូវការអាហារ អុកស៊ីសែន ទឹកសម្រាប់ការលូតលាស់ធំធាត់ ។ ទឹកមាននាទីរំលាយសារធាតុទាំងនោះ ។ កោសិការុំព័ទ្ធដោយមជ្ឈដ្ឋានទឹក ។ វត្តមានទឹកនៅក្នុងមជ្ឈដ្ឋានធ្វើឱ្យមានភាពងាយស្រួលសម្រាប់ឱ្យសារធាតុទាំងនោះធ្វើដំណើរចូលក្នុងកោសិកា ។ $CO_2$ និងកាកសំណល់ធ្វើដំណើរចេញពីកោសិកា ។ ទោះបីមានការដឹកជញ្ជូនបែបនេះក៏ដោយ កោសិកាក៏ត្រូវមានលំនឹងជានិច្ច ។ លក្ខខណ្ឌនេះហៅថា **ថេរលំនឹង** (Omeostasis) ។ សារធាតុឆ្លងកាត់ភ្នាសកោសិកាប្រព្រឹត្តទៅតាមរបៀបបីយ៉ាងគឺ បន្សាយ អូស្មូស និងដំណឹកនាំសកម្ម ។

## 2.1. បន្សាយ




***រូបទី 2.9 បន្សាយនៃចលនាម៉ូលេគុល***

អ្នកស្រម៉ៃមើល នៅពេលអ្នកកំពុងអង្គុយអានសៀវភៅក្នុងបន្ទប់ ទន្ទឹមពេលនោះអាហារក៏កំពុងត្រូវបានចម្អិននៅឯចង្ក្រានបាយ ។ អ្នកមានអារម្មណ៍ដូចជា ក្លិនម្ហូបហើរមកប៉ះនិងច្រមុះរបស់អ្នក ។ ក្លិននេះសាយពីចង្ក្រានបាយចូលក្នុងបន្ទប់ ។ ការភាយនៃក្លិននេះ ប្រព្រឹត្តទៅតាមលំនាំមួយ ហៅថាបន្សាយ ។ បន្សាយជាចលនារបស់ម៉ូលេគុលឬអ៊ីយ៉ុង ពីតំបន់ដែលមានកំហាប់ខ្ពស់ ទៅតំបន់ដែលមានកំហាប់ទាប ។

ម៉ូលេគុល តែងមានចលនាស្មើ ។ ពេលវាធ្វើចលនា វាតែងតែប៉ះទង្គិចជាមួយម៉ូលេគុលដទៃទៀត ។ កាលណាម៉ូលេគុលកាន់តែច្រើន ការប៉ះទង្គិចកាន់តែខ្លាំង ។ ការប៉ះទង្គិចនេះធ្វើឱ្យម៉ូលេគុលខ្ចាតខ្ចាយពីម៉ូលេគុលដទៃ ហើយពង្រាយទៅគ្រប់តំបន់ ពីតំបន់ដែលមានកំហាប់ខ្ពស់ទៅតំបន់ដែលមានកំហាប់ទាប ។

តើកត្តាអ្វីដែលនាំឱ្យមានបន្សាយឆ្លងកាត់ភ្នាសកោសិកា ? តាមធម្មតាក្នុងសូលុយស្យុងមួយតែងតែមានសារធាតុ 2 គឺសារធាតុរំលាយនិងសារធាតុរលាយ ។ ***ឧទាហរណ៍*** គេដាក់ស្ករចូលក្នុងកែវទឹក ។ ម៉ូលេគុលស្ករ សាយចូលទៅក្នុងទឹក ។ ទឹកជាសារធាតុរំលាយ ហើយស្ករជាសារធាតុរលាយ ។

ប្រសិនបើសារធាតុ 2 ដែលមានកម្រិតកំហាប់ខុសគ្នា ស្ថិតនៅសងខាងភ្នាសកោសិកា ម៉ូលេគុលនៃសារធាតុនីមួយៗមានទំនោរបំលាស់ទី ឆ្ពោះទៅរកតំបន់ដែលមានកំហាប់ទាប រហូតដល់តំបន់ទាំង 2 មានកំហាប់ស្មើគ្នា ។ កាលណាតំបន់ពីរមានកំហាប់ស្មើគ្នា បន្សាយត្រូវបានបញ្ឈប់ ពោលគឺម៉ូលេគុលឈប់ធ្វើចលនា (រូបទី 2.9) ។

កត្តាសំខាន់មួយទៀត ដែលកំណត់លំនាំបន្សាយគឺភាពជ្រាបនៃភ្នាស ។ កាលណាសារធាតុតូចៗអាចសាយឆ្លងកាត់ភ្នាស គេថាភ្នាសនោះអាចជ្រាបសារធាតុនោះ ។ ភ្នាសមិនជ្រាបចំពោះសារធាតុណាមួយ មានន័យថាមិនអាចឱ្យមានសារធាតុនោះជ្រាបតាមភ្នាសបានទេ ។ បើកាលណាភ្នាសមួយអាចឱ្យសារធាតុខ្លះឆ្លងកាត់បាន ហើយរាំងសារធាតុខ្លះទៀត ភ្នាសនោះជាភ្នាសជ្រាបជ្រើស ឬភ្នាសអន្ល

ជ្រាប ។ ភ្នាសល្បៀង្ស ភ្នាសមីតូកុងឌ្រី ភ្នាសបណ្តាញរេទីគុយឡូមអង់ដូប្លាស ជា**ភ្នាសអឌ្ឍជ្រាប** ។ ភ្នាសសែលុយឡូសមិនមែនជាភ្នាសអឌ្ឍជ្រាបទេ ។ ទឹក គ្លុយកូស $O_2$ $CO_2$ អាល់កុល លីពីត អេទែ ជាដើម អាចឆ្លងកាត់ភ្នាសកោសិកាបានងាយ ។ ម៉ូលេគុលធំៗ ដូចជា អាមីដុងជាដើម មិនអាចឆ្លងកាត់ភ្នាសនេះបានឡើយ ។

បន្សាយមាននាទីសំខាន់ណាស់ ក្នុងដំណើកនាំឧស្ម័នសម្រាប់ទ្រទ្រង់ជីវិតកោសិកា ។ អុកស៊ីសែន និងឧស្ម័នកាបូនិច ស្ថិតនៅជាសូលុយស្យុងក្នុងកោសិកានិងនៅក្រៅកោសិកាជុំវិញភ្នាស ។ ពេលកោសិកាប្រើប្រាស់ $O_2$ កំហាប់ $O_2$ ក្នុងកោសិកាថយចុះ ហើយទាបជាងកំហាប់ $O_2$ នៅក្រៅកោសិកា ។ ភាពខុសគ្នានៃកម្រិតកំហាប់នេះធ្វើឱ្យ $O_2$ សាយចូលក្នុងកោសិកា។ រីឯ $CO_2$ វិញធ្វើដំណើរផ្ទុយពី $O_2$ ។ កោសិកាផលិត $CO_2$ ច្រើន ដែលធ្វើឱ្យកំហាប់ $CO_2$ ក្នុងកោសិកាកើនជាងកំហាប់ $CO_2$ នៅក្រៅកោសិកា ។ ដូចនេះ $CO_2$ ត្រូវសាយចេញពីកោសិកា ។ អ្នកគិតទៅមើល តើមានបាតុភូតអ្វីកើតឡើងនៅពេលដែលកំហាប់ $O_2$ នៅជុំវិញកោសិកាទាបជាងកំហាប់ $O_2$ នៅក្នុងកោសិកាឬកំហាប់ $CO_2$ នៅក្រៅកោសិកាខ្ពស់ជាងកំហាប់ $CO_2$ នៅក្នុងកោសិកា ?

បន្សាយមាននាទីសំខាន់ណាស់សម្រាប់ឱ្យសារធាតុផ្សេងៗចេញចូលក្នុងកោសិកាបាន ។ បើគ្មានបន្សាយទេ ដំណើរប្រព្រឹត្តទៅរបស់កោសិកាត្រូវអាក់ខាន ហើយកោសិកានឹងស្លាប់ ។

## 2.2. អូស្មូស




*រូបទី 2.10 : អូស្មូស*

ទឹកជាសារធាតុរំលាយដ៏សំខាន់ ។ កោសិកាសត្វ រុក្ខជាតិស្រូបយកសារធាតុចិញ្ចឹមបាននៅពេលដែលសារធាតុទាំងនោះរលាយក្នុងទឹកជាសូលុយស្យុង ។ ម៉ូលេគុលទឹកមានទំហំតូចៗអាចឆ្លងកាត់ភ្នាសអឌ្ឍជ្រាបបានយ៉ាងស្រួល ។ បន្សាយនៃម៉ូលេគុលទឹក ឆ្លងកាត់ភ្នាសអឌ្ឍជ្រាបហៅថា អូស្មូស ។ អូស្មូសជាបន្សាយនៃម៉ូលេគុលទឹក ពីតំបន់ដែលមានកំហាប់ទាបទៅតំបន់ដែលមានកំហាប់ខ្ពស់ ។

រូបទី 2.10 បង្ហាញថាម៉ូលេគុលទឹកធ្វើដំណើរពីតំបន់ដែលមានកំហាប់សូលុយស្យុងទាប នៅផ្នែក B ទៅកាន់ A ដែលមានកំហាប់សូលុយស្យុងខ្ពស់ ។ កម្លាំងដែលជំរុញឱ្យម៉ូលេគុលទឹកផ្លាស់ទីពីផ្នែក B ទៅ A ហៅថា អូស្មូស ។ សម្ពាធអូស្មូសរុញចលនានៃម៉ូលេគុលទឹកពីតំបន់ដែលមានម៉ូលេគុលទឹកច្រើនទៅតំបន់ដែលមានម៉ូលេគុលទឹកតិច ។ កាលណាសូលុយស្យុងទាំង 2 មានបរិមាណ សារធាតុរំលាយស្មើគ្នា សម្ពាធអូស្មូសត្រូវបានបញ្ឈប់ ។ កាលណាកំហាប់សូលុយស្យុងកាន់តែខ្ពស់ សម្ពាធអូស្មូសកាន់តែខ្លាំង ។

សម្ពាធអូស្មូសអាចបង្កជាបញ្ហាធំៗសម្រាប់កោសិកា ។ ស៊ីតូប្លាសបង្កឡើងពីអំបិល ស្ករ ប្រូតេអ៊ីន និងម៉ូលេគុលដទៃទៀត ដែលធ្វើឱ្យកំហាប់សារធាតុនៅក្នុងកោសិកាខ្ពស់ ។ កាលណាកំហាប់សារធាតុក្នុងកោសិកាខ្ពស់ជាងកំហាប់ដែលនៅព័ទ្ធជុំវិញកោសិកា ធ្វើឱ្យទឹកសាយចូលក្នុងកោសិកា ។ ពេលនោះមាឌកោសិកាកើនឡើង ហើយអាចនឹងផ្ទុះបែក ។ ***ឧទាហរណ៍*** គោលិកាក្រហមរបស់មនុស្សអាចនឹងផ្ទុះបែក ប្រសិនបើជាគេដាក់វានៅក្នុងមជ្ឈដ្ឋានមួយដែលមានកំហាប់ខ្លាំងឬខ្សោយខុសពីកំហាប់ក្នុងគោលិកាឈាម ។ ហេតុនេះហើយ ក្រោយពេលធ្លាក់ឈាមដ៏ច្រើន ឬក្រោយពេលដាច់ទឹកយូរ ប្រសិនបើអ្នកផឹកទឹកច្រើនភ្លាម គ្រោះថ្នាក់នឹងកើតមានដល់អ្នក ដោយការបែកគោលិកា ក្រហម ។

ខាងក្រោមនេះ ជាលំនាំផ្សេងៗនៃបាតុភូតអូស្មូស នៅក្នុងមជ្ឈដ្ឋានខុសៗគ្នាក្នុងកោសិកា

## ក. ទឹកចេញពីកោសិកា



***រូបទី 2.11 ក : សូលុយស្យុងអ៊ីពែតូនិច***

កាលណាទឹកសាយចេញពីកោសិកា មាឌកោសិការួមតូច ។ កោសិការួមតូច គឺបណ្តាលមកពីកំហាប់សូលុយស្យុងក្រៅកោសិកាខ្ពស់ជាង កំហាប់សូលុយស្យុងក្នុងកោសិកា ។ សូលុយស្យុងដែលធ្វើឱ្យកោសិការួមតូច ហៅថា **សូលុយស្យុង អ៊ីពែតូនិច** ។ ចំពោះរុក្ខជាតិ វាគុយអូលរួមតូច ដោយការបាត់បង់ទឹក ។ បាតុភូតនេះហៅថា **ប្លាស្មូលីស** ។

## ខ. ទឹកចូលក្នុងកោសិកា

កាលណាទឹកសាយចូលក្នុងកោសិកា មាឌកោសិការីកធំ ។ ការរីកធំនេះបណ្តាលមកពី កំហាប់សូលុយស្យុងនៅក្រៅកោសិកាទាបជាងកំហាប់សូលុយស្យុងនៅក្នុងកោសិកា ។ សូលុយស្យុងដែល

ធ្វើឱ្យកោសិការីកមាឌ ហៅថា សូលុយស្យុង អ៊ីប៉ូតូនិច ។ ចំពោះរុក្ខជាតិ វាគុយអូលរីកធំពេញដោយទឹក ។ បាតុភូតនេះហៅថា សម្ពាធប៉ោង (ទូសេសង់) ឬដេប្លាស្មូលីស ។



រូបទី 2.11 ខ : សូលុយស្យុងអ៊ីប៉ូតូនិច

### គ. អចលនាទឹកក្នុងកោសិកា

កាលណាកំហាប់សារធាតុក្នុងកោសិកានិងកំហាប់សារធាតុនៅក្រៅកោសិកាស្មើគ្នា នោះគ្មានចលនាទឹកចេញនិងចូលកោសិកាទេ ។ កោសិការក្សាទំហំរបស់វានៅដដែល ។ សូលុយស្យុងនោះហៅថា **អ៊ីសូតូនិច** ។



រូបទី 2.11 គ : សូលុយស្យុងអ៊ីសូតូនិច

បាតុភូតអូស្មូស មានសារៈសំខាន់ណាស់ចំពោះរុក្ខជាតិ ។ វាធ្វើឱ្យរុក្ខជាតិស្រូបទឹកពីក្នុងដីតាមរោមជញ្ជក់នៃឫស ។ ដោយសារសម្ពាធអូស្មូស ទឹកធ្វើដំណើរពីឫសទៅដើម រួចស្តុកទុកក្នុងស្តូម៉ាតនៃស្លឹក ។ ក្នុងសរសៃជាតិឈើ ទឹកឡើងជានិច្ចដោយសារកម្លាំងបឺតនៃស្លឹកដែលបណ្តាលមកពីរំភាយចំហាយទឹក ។ រំភាយចំហាយទឹក ធ្វើឱ្យកំហាប់សូលុយស្យុងក្នុងស្លឹកកើនដែលបណ្តាលឱ្យមានការបឺតទឹកពីដើម ដើមបឺតទឹកពីឫស ឫសបឺតទឹកពីដី ។ ដូចនេះបើគ្មានបាតុភូតអូស្មូសទេ ក៏គ្មានរំភាយចំហាយទឹក ហើយរុក្ខជាតិនឹងឆេះខ្លោច ។

## ៣. ដំណឹកនាំសកម្ម

***ឧទាហរណ៍ :*** កាលណាអ្នកជិះកង់ចុះពីលើកំពូលភ្នំមួយ អ្នកមិនប្រើប្រាស់ថាមពលទេ ។ លំនាំនេះហៅថា ដំណឹកនាំអកម្ម ។ ប៉ុន្តែបើអ្នកជិះកង់ឡើងទៅលើកំពូលភ្នំវិញអ្នកត្រូវការប្រើប្រាស់ថាមពល ។ លំនាំនេះហៅថា ដំណឹកនាំសកម្ម ។



រូបទី 2.11 : ដំណឹកនាំសកម្មនិងដំណឹកនាំអកម្ម

អូស្មូសនិងបន្សាយ ជាដំណឹកនាំអកម្ម ព្រោះវាមិនបានប្រើប្រាស់ថាមពលទេ ។ ទិសដៅចលនារបស់ម៉ូលេគុលនៃសារធាតុផ្សេងៗកំណត់ឡើងដោយកម្រិតកំហាប់តែប៉ុណ្ណោះ ។

កាលណាចលនាម៉ូលេគុលនៃសារធាតុផ្សេងៗ ឆ្លងកាត់ភ្នាសដោយចំណាយថាមពល លំនាំនេះមានឈ្មោះថា **ដំណឹកនាំសកម្ម** ។ ម៉ូលេគុលនៃសារធាតុធ្វើ

ដំណើរច្រាសពីដំណើកនាំអកម្ម ។ វាធ្វើដំណើរពីតំបន់ដែលមានកំហាប់ទាបទៅកាន់តំបន់ដែលមានកំហាប់ខ្ពស់ដោយចំណាយថាមពល ។

## មេរៀនសង្ខេប

- គ្រប់កោសិកាអឺកាវីយ៉ូតមានបីផ្នែក គឺភ្នាស ស៊ីតូប្លាស និងណ្វៃយ៉ូ ។
- កោសិការុក្ខជាតិ មានភ្នាសសែលុយឡូសរឹងមាំ ដែលកើតពីជាតិសែលុយឡូសសម្រាប់ការពារនិងទ្រទ្រង់រុក្ខជាតិឱ្យរឹងមាំ ។ បន្ទាប់ពីភ្នាសសែលុយឡូសនៅមានភ្នាសកោសិកាមួយជាន់ទៀត ។
- កោសិកាសត្វ មានភ្នាសស៊ីតូប្លាសតែមួយទេ ។ ភ្នាសកោសិកាកើតឡើងពីលីពីត 2 ស្រទាប់និងមានរន្ធសម្រាប់ឱ្យសារធាតុតូចៗឆ្លងកាត់បាន ។ វាជាភ្នាសជ្រាបជ្រើសឬភ្នាសអឌ្ឍជ្រាប ។ ភ្នាសកោសិកាមាននាទីរក្សារាងកោសិកានិងរក្សាលំនឹងមជ្ឈដ្ឋានក្នុងកោសិកា ។
- ណ្វៃយ៉ូជាមជ្ឈមណ្ឌលត្រួតពិនិត្យសកម្មភាពកោសិកា ។ ណ្វៃយ៉ូផ្ទុកធាតុតំណពូជ គឺក្រូម៉ូសូម ។ ណ្វៃយ៉ូរុំព័ទ្ធដោយភ្នាសណ្វៃយ៉ូ ដែលមានរន្ធតូចៗ ស្ថិតនៅរាយប៉ាយស្មើៗ ។
- មីតូកុងឌ្រី មានរាងជាកូនដំបងតូចៗ ។ វាជាកន្លែងផលិតនិងស្តុកថាមពល ។
- រីបូសូម មានរាងជាគ្រាប់តូចៗស្ថិតនៅសេរីក្នុងស៊ីតូប្លាសនិងនៅលើរេទិគុយឡូមអង់ដូប្លាស រីបូសូមមាននាទីជារោងជាងសាងសង់ប្រូតេអ៊ីន ។
- រេទិគុយឡូម អង់ដូប្លាស ជាបណ្តាញសរសៃភ្ជាប់ណ្វៃយ៉ូនិងនៅរាយប៉ាយក្នុងស៊ីតូប្លាស ។ វាមាននាទី ជាផ្លូវដឹកជញ្ជូនប្រូតេអ៊ីនដែលផលិតដោយរីបូសូមទៅកាន់ផ្នែកផ្សេងៗនៃកោសិកា ។
- ប្រដាប់កុលស៊ី ជាថង់សំប៉ែតនៅក្បែរណ្វៃយ៉ូ ។ វាមាននាទីផ្ទុកនិងបញ្ចេញប្រូតេអ៊ីន ។
- លីសូសូម ជាគ្រាប់តូចៗផ្ទុកអង់ស៊ីមរំលាយអាហារនិងបំបែកធាតុកោសិកាចាស់ៗ ។
- វ៉ាគុយអូល ជាថង់ផ្ទុកទឹកនិងសារធាតុផ្សេងៗ ។
- ប្លាស ជាថង់តូចៗផ្ទុកជាតិពណ៌ផ្សេងៗនិងផ្ទុកអាហារបម្រុង ។ ប្លាសមានតែចំពោះរុក្ខជាតិ ។
- សារធាតុឆ្លងកាត់ភ្នាសកោសិកាប្រព្រឹត្តទៅតាមរបៀប 3 យ៉ាងគឺ បន្សាយ អូស្មូស និងដំណើកនាំសកម្ម ។

## សំណួរនិងលំហាត់

1. តើទម្រង់ជាមូលដ្ឋាន ដែលមានស្ទើរគ្រប់កោសិកាគឺអ្វីខ្លះ ?
2. អ្វីទៅជាធាតុកោសិកា ? តើធាតុកោសិកាណាខ្លះដែលមាននាទីផលិត ? ដឹកជញ្ជូន ? ស្តុកទុក ? រំលាយ ឬបំបែក ?
3. ចូរប្រៀបធៀបមីតូកុងទ្រីនិងក្លរ៉ូប្លាស ។
4. ចូរប្រៀបធៀបទម្រង់កោសិការុក្ខជាតិនិងកោសិកាសត្វ ។
5. ចូរប្រៀបធៀបបន្សាយនិងអូស្មូស ។
6. ចូរប្រៀបធៀបដំណឹកនាំអកម្មនិងដំណឹកនាំសកម្ម ។

## ពិសោធន៍ : បាតុភូតអូស្មូស

### 1. វត្ថុបំណង

- ពិនិត្យចលនាទឹកចេញចូលក្នុងកោសិកា
- ពណ៌នាពីបាតុភូតអូស្មូស
- រៀបចំដំណើរការពិសោធ
- សង្កេតទ្រង់ទ្រាយវ៉ាគុយអូលក្នុងកោសិកា ។

### 2. សម្ភារៈ

- កែវជ័រពីរ ហ្វីតសរសេរ កាំបិត ខ្ទឹមបារាំង
- បំពង់បន្តក់ តង្កៀប ឈើចាក់ធ្មេញ
- ទឹក អំបិល មីក្រូទស្សន៍ ។

### 3. រំលឹកចំណេះដឹង

អូស្មូសជាចលនារបស់ទឹក ដែលធ្វើដំណើរពីតំបន់ដែលមានកំហាប់ម៉ូលេគុលទឹកខ្ពស់ ទៅតំបន់ដែលមានកំហាប់ម៉ូលេគុលទឹកទាប ។

### 4. ដំណើរការពិសោធ

- យកហ្វីតសរសេរលើកែវជ័រទាំងពីរ "ទឹក ទឹកអំបិល" ។
- ចាក់ទឹកនិងទឹកអំបិលទៅក្នុងកែវជ័រនីមួយៗតាមសមាមាត្រស្មើគ្នា ។

- កាត់មើមឪឡឹមបារាំងជាបួនជ្រុង ។ ឆ្កឹះយកឪឡឹមបារាំងមួយស្រទាប់ រួចពុះជាពីរចំណិតស្មើគ្នា ដាក់ទៅក្នុងកែវជ័រទាំងពីរ ។ បន្ទាប់មកទុករយៈពេល30នាទី ។
- ប្រើតង្កៀបចាប់យកឪឡឹមបារាំងដែលត្រាំក្នុងទឹកអំបិល ។ ឆ្កឹះយកស្រទាប់ភ្នាសខាងក្នុងដាក់លើកញ្ចក់ ហើយបន្តក់ទឹកលុយកូល(Lugol)មួយតំណក់ ។ បន្ទាប់មកទៀតគ្របបន្ទះកញ្ចក់ស្តើងពីលើ ហើយពិនិត្យមើលក្នុងមីក្រូទស្សន៍ ។
- គូររូបភាពកោសិកា ។
- បន្ទាប់មកប្រើតង្កៀបចាប់យកឪឡឹមបារាំងដែលត្រាំក្នុងទឹក ។ ឆ្កឹះយកស្រទាប់ភ្នាសខាងក្នុងដាក់លើកញ្ចក់ ហើយធ្វើដូចពិសោធន៍លើកមុន ។ ឱ្យសិស្សគូររូបកោសិកា ហើយប្រៀបធៀបកោសិកាទាំងពីរ ។

| | ឪឡឹមបារាំងត្រាំក្នុងទឹក | ឪឡឹមបារាំងត្រាំក្នុងទឹកអំបិល |
|---|---|---|
| ក្រោយពិសោធន៍ | | |

## 5. សន្និដ្ឋាន

1 តើកោសិកាឪឡឹមបារាំងត្រាំក្នុងទឹកមានសភាពដូចម្តេច ? ព្រោះអ្វី ?

2. តើកោសិកាឪឡឹមបារាំងត្រាំក្នុងទឹកអំបិលមាសភាពដូចម្តេច ? ព្រោះអ្វី ?

មេរៀនទី

# 3 ដំណោះដំណាលកោសិកានិងរូបផ្គុំសារពាង្គកាយរស់

**ចប់មេរៀននេះ សិស្សអាច**

- ❑ ឱ្យនិយមន័យមីតូស ។
- ❑ បកស្រាយពីសារៈសំខាន់នៃចន្លោះវគ្គ ។
- ❑ សង្ខេបវគ្គទាំង4 របស់មីតូស ។
- ❑ ប្រៀបធៀបចំណែកកោសិកាសត្វនិងរុក្ខជាតិ ។
- ❑ ពណ៌នាពីកម្រិតទាំង4 របស់រូបផ្គុំក្នុងសារពាង្គកាយសត្វ ។

លក្ខណៈពិសេសមួយរបស់ភាវៈរស់ គឺការលូតលាស់ ។ ការលូតលាស់អាចមើលឃើញនៅពេលទំហំសារពាង្គកាយកើនឡើង ។ ការលូតលាស់របស់សារពាង្គកាយមួយ មិនមែនបណ្តាលមកពីកោសិកាធំធាត់ទេ គឺជាលទ្ធផលនៃកំណើនចំនួនកោសិកាក្នុងសារពាង្គកាយ ។ សារពាង្គកាយមនុស្សពេញវ័យមានកោសិកាប្រមាណ $10^{18}$ ។ កោសិកាទាំងនេះកើតចេញពីស៊ុតកូតតែមួយដែលមានអង្កត់ផ្ចិត $10^{-4}$ ម៉ែត្រប៉ុណ្ណោះ ។ តើលំនាំអ្វីដែលធ្វើឱ្យស៊ុតកូតមួយអាចបង្កើនចំនួនកោសិកាដ៏ច្រើនយ៉ាងនេះ?

## 1. មីតូស

លំនាំដែលកោសិកាមួយ បង្កើតកោសិកាច្រើន គឺចំណែកកោសិកា ។ ចំណែកកោសិកាមានពីរដំណាក់កាលគឺ មីតូសនិងចំណែកស៊ីតូប្លាស ។ មីតូស ជាលំនាំមួយដែលណ្វៃយ៉ូកោសិកាមួយ ត្រូវបានចែកខ្លួនជាណ្វៃយ៉ូកូនពីរ ។ ណ្វៃយ៉ូកូននីមួយៗមានចំនួននិងរូបរាងក្រូម៉ូសូមដូចណ្វៃយ៉ូក្នុងកោសិកាមេ ។ ចំណែកកោសិការ៉ាប់រងកំណើនចំនួនកោសិកានិងរក្សាព័ត៌មានសេនេទិច ។



រូបទី 3.1 ៖ ទម្រង់ក្រូម៉ាទីននៅចន្លោះវគ្គ

យើងដឹងហើយថា ធាតុសំខាន់របស់ណ្វៃយ៉ូគឺ ក្រូម៉ូសូម ។ ក្រូម៉ូសូមផ្ទុកព័ត៌មានសេនេទិចក្រោមរូបភាពជា ADN ។ នៅចន្លោះរវាងចំណែកកោសិកាពីរបន្តបន្ទាប់ដែលហៅថា ចន្លោះវគ្គឬអាំងទែផាស ក្រូម៉ាទីនមានទិដ្ឋភាពជាតំបន់ខាប់ៗរាយប៉ាយក្នុងណ្វៃយ៉ូ ។ បន្ទាប់មកក្រូម៉ាទីនរួញខ្លី ហើយ

ប្លែងជា ក្រូម៉ូសូម ។ ក្រូម៉ូសូម ជាធាតុងាយចាប់ពណ៌ ដែលគេអាចមើលឃើញតាមរយៈមីក្រូទស្សន៍ ក្នុងនៅពេលកោសិកាធ្វើចំណែក ។ គេមើលឃើញក្រូម៉ូសូមតែក្នុងពេលកោសិកាចែកខ្លួនតែប៉ុណ្ណោះ គឺនៅពេលដែលក្រូម៉ាទីនរួញខ្លី ។

នៅមុនពេលកោសិកាចែកខ្លួន ក្រូម៉ូសូមនីមួយៗ ដំឡើងទ្វេបង្កើតបាន **ក្រូម៉ាទីតពីរ** ដូចគ្នាដែលហៅថា ក្រូម៉ាទីតបងប្អូន ។ ក្រូម៉ាទីតទាំងពីរជាប់គ្នាត្រង់ចំណុចមួយមិនចាប់ពណ៌ហៅថាសង់ត្រូមែ(រូបទី 3.2) ។ សង់ត្រូមែជាកន្លែងភ្ជាប់ក្រូម៉ូសូមទៅនឹងត្រយូងអាក្រូម៉ាទិច ។




***រូបទី 3.2 . ទម្រង់ក្រូម៉ូសូមនៅមេតាផាស***

ក្នុងកោសិកាលូតលាស់ ក្រូម៉ូសូមមានរូបរាងដូចគ្នា មួយគូៗ(ទំហំ ប្រវែង និងទីតាំងសង់ត្រូមែ)ដែលហៅថា គូក្រូម៉ូសូមអូម៉ូឡូក ។ ចំនួននិងរូបរាងក្រូម៉ូសូម ជាលក្ខណៈពិសេសរបស់ប្រភេទនៃភាវៈរស់ ។ ***ឧទាហរណ៍*** មនុស្សមានក្រូម៉ូសូម 46 ។ ឆ្មាមានក្រូម៉ូសូម 38 ឆ្កែមានក្រូម៉ូសូម 78 ។

## 1.1. វដ្តកោសិកា

### ក. ចន្លោះវគ្គ

ជីវិតកោសិកាប្រព្រឹត្តទៅ តាមវដ្តមួយហៅថា **វដ្តកោសិកា** ។ វដ្តកោសិកា ជារយៈពេលដែលកោសិកាលូតលាស់និងចែកខ្លួន ។ វគ្គដែលកោសិកាលូតលាស់មុននិងចែកខ្លួនហៅថា ចន្លោះវគ្គ ។ ចន្លោះវគ្គមានបីវគ្គតូចៗគឺ

- វគ្គ $G_1$ កោសិកាលូតលាស់និងរីកចម្រើនយ៉ាងរហ័ស ។
- វគ្គ S ADN ស្វ័យដំឡើងទ្វេ ។ ចុងបញ្ចប់នៃវគ្គនេះក្រូម៉ូសូមនីមួយៗមានក្រូម៉ាទីតពីរៗ ។
- វគ្គ $G_2$ មានរយៈពេលខ្លី ។ កោសិកាលូតលាស់បន្ត ហើយសំយោគធាតុកោសិកានិងរូបធាតុដែលចាំបាច់សម្រាប់កោសិកាចែកខ្លួន ។




***រូបទី 3.3 . វដ្តកោសិកា***

ដូចនេះវដ្តកោសិកាមានពីរដំណាក់ គឺចន្លោះវគ្គនិងចំណែកកោសិកា (មីតូសនិងចំណែកស៊ីតូប្លាស)(រូបទី 3.3) ។ ទោះបីជានៅក្នុងចន្លោះវគ្គ កោសិកាហាក់ដូចជាស្ងៀមស្ងាត់ ប៉ុន្តែវាជារយៈពេលដែលកោសិកាធ្វើសកម្មភាពយ៉ាងខ្លាំងក្លា ល្បៀយ៉ូសំយោគ ARN ប្រូតេអ៊ីនត្រូវបានបង្កើត ADN ស្វ័យដំឡើងទ្វេ ATP ត្រូវបានបង្កើតនិងប្រើប្រាស់ ។ នៅក្នុងសារពាង្គកាយពហុកោសិកា កោសិកាបានធ្វើបំលែងឯកទេសសម្រាប់បំពេញមុខងារផ្សេងៗនៅក្នុងចន្លោះវគ្គ ។

## ១. វគ្គផ្សេងៗនៃមីតូស

បន្ទាប់ពីចន្លោះវគ្គ គឺជាវគ្គផ្សេងៗរបស់មីតូស ។ មីតូស ចែកជា 4 វគ្គបន្តបន្ទាប់ គឺប្រូផាស មេតាផាស អាណាផាស និងតេឡូផាស ។

- ប្រូផាស

ប្រូផាស ជាវគ្គដែលមានរយៈពេលវែងជាងគេ 15 – 60 នាទី ។




កោសិការុក្ខជាតិ *រូបទី 3.4 ក្រូម៉ូសូមក្នុងវគ្គប្រូផាស* កោសិកាសត្វ

ក្រូម៉ូសូម ចាប់ផ្ដើមលេចរូបរាងដោយសារការរួញខ្លីនៃក្រូម៉ាទីន ។ ក្រូម៉ូសូមមានរូបរាងជាកូនដំបងខ្លីៗ ងាយចាប់ពណ៌ ។ ការរួញខ្លីនេះប្រព្រឹត្តទៅកាន់តែខ្លាំងឡើងៗរហូតដល់ចុងវគ្គ ។ ក្រូម៉ូសូមមួយ បង្កឡើងដោយក្រូម៉ាទីតពីរ ដែលជាលទ្ធផលនៃស្វ័យដំឡើងទ្វេ ADN ។ ក្រូម៉ាទីតទាំងពីរជាប់គ្នានៅត្រង់សង់ត្រូមែ ។ សង់ត្រូសូម ដែលមានតែក្នុងកោសិកាសត្វ ចាប់ផ្ដើមដំឡើងទ្វេ បង្កើតជាសង់ត្រូសូមកូនពីរ ។ សង់ត្រូសូមនីមួយៗផ្ទុកសង់ទ្រីយ៉ូលពីរដែលកែងគ្នា ។ សង់ត្រូសូមកូននីមួយៗរុំព័ទ្ធដោយខ្សែកាំបង្កើតជាអាស្ទែ ។ អាស្ទែទាំងពីរឃ្លាតចេញពីគ្នាទៅកាន់ប៉ូលផ្ទុយគ្នា ។ ខ្សែកាំដែលភ្ជាប់អាស្ទែទាំងពីរបង្កើតបានជាត្រយូងអាក្រូម៉ាទិច ។ ត្រយូងអាក្រូម៉ាទិចមានសរសៃពីរបែប គឺសរសៃប៉ូលសម្រាប់ភ្ជាប់ប៉ូលទាំងពីរនៃកោសិកានិងសរសៃក្រូម៉ូសូមសម្រាប់ភ្ជាប់ក្រូម៉ូសូមត្រង់សង់ត្រូមែទៅប៉ូលនីមួយៗ (រូបទី 3.4) ។សរសៃត្រយូងអាក្រូម៉ាទិចនីមួយៗកើតពីបំពង់ប្រូតេអ៊ីនតូចៗ ។ ចំពោះកោសិការុក្ខជាតិ

ដែលគ្មានសង់ត្រូសូម ក៏អាចបង្កើតត្រយ៉ូងអាក្រូម៉ាទិចបាន ដូចកោសិកាសត្វដែរ ។ នៅក្នុងវគ្គនេះភ្នាសណ្វៃយ៉ូនិងនុយក្លេអូលរលាយបាត់ក្នុងស៊ីតូប្លាស ដែលបង្កើតបានជាប្រូតូប្លាស ។

- មេតាផាស

វគ្គមេតាផាស មានរយៈពេលខ្លីតែ 2 – 3 នាទីប៉ុណ្ណោះ ។




*រូបទី 3.5 ក្រូម៉ូសូមក្នុងវគ្គមេតាផាស*

ក្រូម៉ូសូមទាំងអស់ប្រមូលផ្ដុំនៅអេក្វាទ័រនៃត្រយូងអាក្រូម៉ាទិចក្នុងប្លង់តែមួយ បង្កើតបានជាបន្ទះអេក្វាទ័រ ។ សង់ត្រូមែនៃក្រូម៉ូសូមនីមួយៗភ្ជាប់ខ្លួនទៅនឹងសរសៃក្រូម៉ូសូម ។ ក្នុងវគ្គនេះ ក្រូម៉ូសូមលេចរូបរាងច្បាស់ជាងវគ្គដទៃ ។ ដូចនេះគេអាចកំណត់ចំនួននិងរូបរាងក្រូម៉ូសូមបាន ។

- អាណាផាស

វគ្គអាណាផាសក៏មានរយៈពេលខ្លីដែរគឺតែ 2 – 3 នាទីប៉ុណ្ណោះ ។




*រូបទី 3.6 ក្រូម៉ូសូមក្នុងវគ្គអាណាផាស*

សរសៃក្រូម៉ូសូម (កើតពីប្រូតេអ៊ីន) ដែលភ្ជាប់សង់ត្រូមែទៅប៉ូលទាំងពីរ រួញខិតទៅកាន់ប៉ូលរៀងៗខ្លួន ។ ដូចនេះក្រូម៉ាទីតបងប្អូនត្រូវបែកចេញពីគ្នាទៅកាន់ប៉ូល ដោយមានចំណែកសង់ត្រូមែ ។ ក្រូម៉ូសូមនីមួយៗមានក្រូម៉ាទីតតែមួយទេ ។ វគ្គអាណាផាស ត្រូវបានបញ្ចប់នៅពេលដែលក្រូម៉ូសូមរត់

ដល់ប៉ូល ហើយឈប់ធ្វើចលនា ។ នៅត្រង់ប៉ូលនីមួយៗ មានចំនួនក្រូម៉ូសូមស្មើៗគ្នា ហើយស្មើទៅនឹងចំនួនក្រូម៉ូសូមក្នុងកោសិកាមេ ។

- **តេឡូផាស**




***រូបទី 3.7 :ទម្រង់ក្រូម៉ូសូមក្នុងវគ្គតេឡូផាស***

នៅប៉ូលនីមួយៗក្រូម៉ូសូមគរលើគ្នា ។ ភ្នាសណ្វៃយ៉ូកកើត ហើយរុំព័ទ្ធក្រុមក្រូម៉ូសូមកូន ។ ត្រយ៉ូងអាក្រូម៉ាទិចរលាយបាត់ ។ នុយក្លេអូលកើតមានក្នុងណ្វៃយ៉ូកូន ។ក្រូម៉ូសូមរលា ហើយក្លាយជាក្រូម៉ាទីន ។ បន្ទាប់មកវាបាត់រូបរាងបន្តិចម្តងៗ ។

***សន្និដ្ឋាន***

តាមចំណែកមីតូស ណ្វៃយ៉ូនៃកោសិកាមេមួយចែកខ្លួនបានណ្វៃយ៉ូកូនពីរ ។ ណ្វៃយ៉ូកូននីមួយៗមានចំនួននិងរូបរាងក្រូម៉ូសូមដូចគ្នា ហើយដូចទៅនឹងកោសិកាមេ ។ ចំណុចសំខាន់នៅក្នុងលំនាំនេះ គឺនៅចន្លោះវគ្គមានបាតុភូតស្វ័យដំឡើងខ្សែ ADN និងនៅវគ្គអាណាផាស មានការចែកក្រូម៉ូសូមស្មើគ្នាទៅកាន់ប៉ូលទាំងពីរ ។

## 1.2. ចំណែកស៊ីតូប្លាស

ចំពោះកោសិកាសត្វចំណែកស៊ីតូប្លាស ប្រព្រឹត្តទៅដោយការស្តួចនៃផ្ទៃកកណ្តាលនៅត្រង់ចន្លោះណ្វៃយ៉ូកូនទាំងពីរ ដែលបង្កើតបានកោសិកាកូន 2 ។ ចំពោះកោសិការុក្ខជាតិ ចំណែកស៊ីតូប្លាសប្រព្រឹត្តទៅដោយការលេចឡើងនូវ **បន្ទះកោសិកា** ត្រង់ប្លង់អេក្វាទ័រដែលនៅចន្លោះណ្វៃយ៉ូកូនទាំង 2 ។ ភ្នាសគ្រោងដ៏រឹងមាំដែលរុំព័ទ្ធកោសិការុក្ខជាតិមិនអាចធ្វើឱ្យកោសិកាជ្រួញ ហើយស្តួចផ្ទៃកកណ្តាលឡើយ ។ ផ្ទុយទៅវិញ ថង់របស់ស៊ីតូប្លាសដែលមានប្រភពពីឧបករណ៍កុលស៊ីធ្វើដំណើរចុះពីប៉ូលឆ្ពោះទៅតំបន់អេក្វាទ័រ ។ ថង់ទាំងនោះរលាយចូលគ្នាបង្កើតបានជាបន្ទះកោសិកា ។ បន្ទះកោសិកាលូតវែង លាតសន្ធឹងរហូតដល់ភ្នាសស៊ីតូប្លាស ។ ភ្នាសរបស់វាបំពេញឱ្យភ្នាសស៊ីតូប្លាសសម្រាប់កោសិកាកូនទាំងពីរ ។ បន្ទាប់មកវាក៏បញ្ចេញប៉ូលីសាការីតដែលជាសញ្ញាក្នុងការបង្កើតភ្នាសគ្រោង ។ ភ្នាសគ្រោងនេះរឹងមាំដោយ

សារការបង្កើតបន្ថែមសរសៃសែលុយឡូស(រូបទី 3.8) ។ ករណីពិសេសកោសិកាធ្វើចំណែកណ្វៀយ៉ូតែស៊ីតូប្លាសមិនធ្វើចំណែកឡើយ ជាហេតុនាំឱ្យកោសិកាមួយមានណ្វៀយ៉ូច្រើន ។ ***ឧទាហរណ៍*** កោសិកាខ្ទីមបារាំង កោសិកាសាច់ដុំក្រហម ។




***រូបទី 3.8 ចំណែកស៊ីតូប្លាសក្នុងកោសិការុក្ខជាតិ***

## 1.3. ទីតាំងមីតូស

ចំពោះរុក្ខជាតិ ការសង្កេតរកកោសិកាកំពុងធ្វើមីតូសមានភាពងាយស្រួល ព្រោះការលូតលាស់របស់រុក្ខជាតិប្រព្រឹត្តទៅនៅតំបន់មេជាលិកាដែលស្ថិតនៅចុងឫសនិងពន្លកដើម ។ ចំពោះសត្វវិញ មីតូសប្រព្រឹត្តទៅលើគ្រប់កោសិកាលូតលាស់នៃសរីរាង្គទាំងអស់ លើកលែងតែកោសិកាសាច់ដុំ កោសិកាប្រសាទ និងកោសិកាក្រហម ។ កោសិកាទាំងនេះមិនចែកខ្លួនតាមមីតូសទេ ហេតុនេះហើយកាលណាកោសិកាទាំងនោះស្លាប់ មីតូសមិនអាចបង្កើតកោសិកាថ្មីៗដើម្បីជំនួសកោសិកាស្លាប់ឡើយ ។

## 1.4. នាទីមីតូស

ចំពោះសារពាង្គកាយពហុកោសិកា មីតូសធានា

- ការលូតលាស់នៃសារពាង្គកាយ ដោយបង្កើនចំនួនកោសិកា ។
- បង្កើតកោសិកាថ្មីៗ ដើម្បីជួសជុលកោសិកាចាស់ដែលបាត់បង់ ។
- ថែរក្សាព័ត៌មានសេនេទិច គឺរក្សាចំនួន រូបរាងក្រូម៉ូសូមឱ្យនៅថេរដដែល ។
- ចំពោះសារពាង្គកាយឯកកោសិកា ដូចជាអាមីបជាដើម មីតូសធានាការបង្កើតអាមីបថ្មី ។

## 1.5. តម្រូវមីតូស

កោសិកាចែកខ្លួនតាមមីតូស ត្រូវមានកត្តាមួយចំនួនដូចតទៅ

- ពេលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ កោសិកាលូតលាស់ ហើយចែកខ្លួន ។

- អរម៉ូន ដែលផលិតចេញពីក្រពេញអង់ដូគ្រីន ដូចជាក្រពេញភេទ ក្រពេញទីរ៉ូអ៊ីតជាដើម ធ្វើឱ្យកោសិកាលូតលាស់ ហើយចែកខ្លួន ។
- កាលណាផលធៀបរវាងមាឌណ្វៃយ៉ូនិងមាឌស៊ីតូប្លាស កាន់តែតូចទៅៗមានន័យថា ស៊ីតូប្លាសកាន់តែរីកធំ ពេលនោះកោសិកាចែកខ្លួន ។

## 1.6. តើមានអ្វីកើតឡើងបើការត្រួតពិនិត្យត្រូវបាត់បង់ ?

យើងដឹងហើយថា ADN ផ្ទុកព័ត៌មានសេនេទិច ដែលចាំបាច់សម្រាប់បង្កើតប្រូតេអ៊ីន ។ ប្រូតេអ៊ីនខ្លះមាននាទីតម្រូវការលូតលាស់ និងចែកខ្លួនរបស់កោសិកា ។ ប៉ុន្តែនៅពេលព័ត៌មានសេនេទិចត្រូវរងបម្រែបម្រួល ប្រូតេអ៊ីនក៏ត្រូវរងបម្រែបម្រួលដែរ ហើយបាត់បង់នាទីរបស់វាក្នុងការត្រួតពិនិត្យវដ្តកោសិកា ។ កោសិកាចែកខ្លួនគ្មានរបៀប ហើយមិនកំណត់ បង្កើតបានកោសិកាច្រើនអនេក ហើយផ្តុំជាដុំកោសិកាដែលហៅថាដុំពក ។ ដុំពកមានពីរប្រភេទ គឺដុំពកស្លូតនិងដុំពកកាច ។ ដុំពកស្លូតមិនពង្រាយខ្លួនទៅកាន់ផ្នែកផ្សេងៗនៃរាងកាយទេ ហើយអាចវះកាត់យកចេញដោយមិនបង្កជាបញ្ហាអ្វីឡើយ ។ ដុំពកកាច ឬដុំមហារីក អាចបំផ្លាញជាលិកាសរីរាង្គនៅក្បែរវា ។ ក្នុងដំណាក់កាលការរាតត្បាត ដុំមហារីកពង្រាយខ្លួនវាទៅផ្នែកផ្សេងៗនៃរាងកាយ ដោយបង្កើតជាកូនដុំពកថ្មីៗ ។ អ្នកកើតជំងឺមហារីកអាចស្លាប់ បើកាលណាគេមិនបានព្យាបាលឱ្យទាន់ពេល ។

# 2. ឯកទេសកម្មជាលិកា សរីរាង្គ និងប្រព័ន្ធ (ប្រដាប់)

ការលូតលាស់នៃសារពាង្គកាយបានមកពីចំណែកកោសិកា ។ មានកោសិកាច្រើនប្រភេទណាស់ដែលខុសគ្នាដោយទំហំ រូបរាង និងមុខងារ ។ ដំណើរបំលែងពីកោសិកាដែលមិនទាន់មានឯកទេស (មុខងារ) ឱ្យទៅជាកោសិកាមានលក្ខណៈឯកទេស ហៅថា**ឯកទេសកម្ម**នៃកោសិកា ។ កោសិកាមួយមានឯកទេសកម្ម មានន័យថា កោសិកានោះបំពេញមុខងារមួយច្បាស់លាស់នៅក្នុងសារពាង្គកាយ ។ កោសិកាខ្លះមានឯកទេសក្នុងការធ្វើចលនា (កោសិកាសាច់ដុំ) ។ កោសិកាខ្លះទៀត មានឯកទេសក្នុងការផលិតអង់ស៊ីម (កោសិកាក្រពេញទឹកមាត់បង្កើតអង់ស៊ីមអាមីឡាសក្នុងទឹកមាត់) ។

***ឧទាហរណ៍ :*** ខ្យល់ដែលយើងដកដង្ហើមចូល មានផ្ទុកធូលី ផ្សែង បាក់តេរីតូចៗ ។ ហេតុអ្វីបានជាធាតុទាំងនោះមិនអាចរាំងស្ទះផ្លូវដង្ហើម ឬមិនបានចូលទៅក្នុងសួត ? ពីព្រោះភ្នាសខាងក្នុងនៃបំពង់ដង្ហើមមានកោសិកាពិសេសម្យ៉ាងដែលបញ្ចេញជាតិរំអិល (សារធាតុចម្រុះមាន ទឹក អំបិល ស្ករ ស៊ីត) ដើម្បីរាំងស្ទះចុណ្ណភាគទាំងអស់នោះ ។ ម្យ៉ាងទៀតនៅខាងក្រោមស្រទាប់ជាតិរំអិលមានក្រុម

កោសិកាឯកទេសមួយផ្សេងទៀតដែលមានរោមញ័រ ។ ចលនារោមញ័ររាំងស្ទះចុណ្ណភាគនិងសំអាតបំពង់ដង្ហើម ។

**ជីវវិទូ បានចែករូបផ្តុំនៃសារពាង្គកាយជាបួនកម្រិត**

## ក. កោសិកា

កោសិកា ជាធាតុបង្ករបស់សារពាង្គកាយ ។ ពួកវាខុសគ្នាដោយសាររូបរាង ទំហំ និងមុខងារ ។

## ខ. ជាលិកា

ជាលិកា ជាក្រុមកោសិកាដូចគ្នា ដែលធ្វើការរួមគ្នា ដើម្បីបំពេញមុខងារមួយ ។ ក្នុងសារពាង្គកាយមានជាលិកាច្រើនប្រភេទដូចជា ជាលិកាអេពីតេល្យូម ជាលិកាសាច់ដុំ ជាលិកាប្រសាទ ជាលិកាសន្ធាន ។ល ។

***ឧទាហរណ៍*** : កោសិកាដែលពាសផ្ទៃក្នុងនៃសរីរាង្គ ហៅថាជាលិកាអេពីតេល្យូម (ជាលិកាអេពីតេល្យូមក្រអូមមាត់ ក្រពះ ពោះវៀន ) ។ វាមាននាទីគ្របដណ្តប់និងការពារសរីរាង្គ ។ ជាលិកាសន្ធាន ជាក្រុមកោសិកាឯកទេសក្នុងការភ្ជាប់និងទ្រទ្រង់ផ្នែកទាំងឡាយរបស់សារពាង្គកាយ ។



*រូបទី 3.9 : រូបផ្តុំបួនកម្រិតរបស់មនុស្ស*

## គ. សរីរាង្គ

សរីរាង្គ ជាទម្រង់មួយដែលបង្កឡើងដោយជាលិកាច្រើនប្រភេទរួមគ្នា ដើម្បីបំពេញមុខងារតែមួយ ។ ***ឧទាហរណ៍*** សាច់ដុំបង្កឡើងដោយជាលិកាសាច់ដុំ ជាលិកាប្រសាទ ជាលិកាសន្ធាន ។ ជាលិកាទាំងនេះបំពេញមុខងាររួមគ្នា ដើម្បីឱ្យសាច់ដុំបំពេញនាទីរបស់វា (ធ្វើចលនា បំលាស់ទី ) ។

## ឃ. ប្រព័ន្ធសរីរាង្គ (ប្រដាប់)

ប្រព័ន្ធសរីរាង្គ ជាបណ្តុំសរីរាង្គមួយក្រុមធ្វើការរួមគ្នា ដើម្បីបំពេញមុខងារមួយ ។ ក្នុងសារពាង្គកាយមានប្រព័ន្ធសរីរាង្គច្រើន ដូចជា ប្រព័ន្ធរបត់ឈាម ប្រព័ន្ធសាច់ដុំ ។ ***ឧទាហរណ៍*** ប្រដាប់រំលាយអាហារកើតពីសរីរាង្គច្រើនដូចជា មាត់ បំពង់អាហារ ក្រពះ លំពែង ថ្លើម ពោះវៀន )ដែលមាននាទីរំលាយអាហារ ។

## មេរៀនសង្ខេប

- ការលូតលាស់របស់សារពាង្គកាយបណ្ដាលមកពីកំណើនចំនួនកោសិកា ។
- លំនាំដែលកោសិកាមេមួយបង្កើតបានកោសិកាកូនពីរដូចគ្នា ហៅថាចំណែកកោសិកា ។
- ចំណែកកោសិកាមានមីតូសនិងចំណែកស៊ីតូប្លាស ។
- វដ្តកោសិកាមានចំណែកកោសិកានិងចន្លោះវគ្គ ។
- វគ្គចន្លោះ ឬអាំងទែផាស ជាចន្លោះរវាងចំណែកកោសិកាពីរបន្តបន្ទាប់គ្នា ។
- ក្នុងចន្លោះវគ្គមាន វគ្គ $G_1$ (លូតលាស់លើកទី 1) វគ្គ S (ដំឡើងទ្វេ) វគ្គ $G_2$ (លូតលាស់លើកទី 2)
- ក្នុងចន្លោះវគ្គ ក្រូម៉ូសូមមិនទាន់លេចរូបរាងទេ វាជាក្រូម៉ាទីន ។
- ពេលកោសិកាចែកខ្លួន ក្រូម៉ាទីនរួញខ្លីក្លាយជាក្រូម៉ូសូម ។
- ធាតុបង្ករបស់ក្រូម៉ូសូម គឺ ADN និងអ៊ីស្តូន ។
- មីតូស ជាលំនាំដែលណ្វៃយ៉ូនៃកោសិកាមួយចែកខ្លួនបានណ្វៃយ៉ូកូនពីរ ។
- មីតូសមានបួនវគ្គ : ប្រូផាស មេតាផាស អាណាផាស តេឡូផាស ។
- ធាតុភូតសំខាន់របស់មីតូសដែលធ្វើឱ្យណ្វៃយ៉ូកូនមានចំនួន រូបរាងក្រូម៉ូសូមដូចគ្នា គឺការតម្លើងទ្វេក្រូម៉ាទីតនៅវគ្គ S នៃចន្លោះវគ្គនិងការចែកក្រូម៉ូសូមកូនស្មើគ្នាទៅប៉ូលនៅវគ្គអាណាផាស ។
- ចំណែកស៊ីតូប្លាសរបស់កោសិកាសត្វ គឺភាពស្ដួចនៅផ្នែកកណ្ដាលចន្លោះណ្វៃយ៉ូកូនទាំងពីរ ចំពោះចំណែកស៊ីតូប្លាសរបស់កោសិការុក្ខជាតិ គឺមានការកកើតភ្នាសគ្រោងនៅផ្នែកកណ្ដាលចន្លោះណ្វៃយ៉ូកូនទាំងពីរ ។ ភ្នាសគ្រោងនេះខណ្ឌចែកកោសិកាមេជាកោសិកាកូនពីរ ។
- ចំណែកកោសិកាប្រព្រឹត្តទៅ កាលណាកោសិកាលូតលាស់ដល់កម្រិតមួយ ។ ភាពលូតលាស់នេះបណ្ដាលមកពីសារធាតុចិញ្ចឹមគ្រប់គ្រាន់និងដោយសារកត្តាអរម៉ូន ។
- កាលណាភាពត្រួតពិនិត្យរបស់ប្រូតេអ៊ីនបាត់បង់ កោសិកាចែកខ្លួនគ្មានរបៀប ហើយគ្មានកំណត់បង្កើតបានកោសិកាច្រើនអនេក ដែលជាដុំពក ។
- ដុំពកកាច បង្កើតជាជំងឺមហារីកយ៉ាងសាហាវ ។

## ? សំណួរនិងលំហាត់

1. ពន្យល់ពាក្យ ក្រូម៉ាទីន ក្រូម៉ាទីត ក្រូម៉ូសូម មីតូស សង់ត្រូមែ ។
2. ចូរសង្ខេបវគ្គផ្សេងៗនៃមីតូស ។
3. ចូរប្រៀបធៀបលក្ខណៈខុសគ្នារវាងមីតូសកោសិកាសត្វនិងកោសិការុក្ខជាតិ ។
4. ក្នុងចំណែកកោសិកាមានបាតុភូតសំខាន់ពីរដែលធ្វើឱ្យកោសិកាមេនិងកោសិកាកូនមានចំនួននិងរូបរាងក្រូម៉ូសូមដូចកោសិកាមេ ។ តើបាតុភូតទាំងពីរនោះជាអ្វី ? នៅវគ្គណា ?
5. តើចន្លោះវគ្គមានសារៈសំខាន់ដូចម្តេច ?
6. អំប្រីយ៉ុងមួយកកើតចេញពីស៊ីកូតមួយបាន បីថ្ងៃមានកោសិកា 16 ។
   ក. តើស៊ីកូតធ្វើមីតូសប៉ុន្មានដង ?
   ខ. រករយៈពេលនៃវដ្តកោសិកានីមួយៗ ។

## ពិសោធន៍ ៖ សង្កេតចំណែកកោសិកាខ្ទឹមបារាំង

### 1. វត្ថុបំណង

- បង្ហាញវគ្គផ្សេងៗនៃមីតូស
- គូររូបកោសិកាក្នុងវគ្គផ្សេងៗ
- ពណ៌នាពីវគ្គផ្សេងៗនៃមីតូស ។

### 2. សម្ភារៈ

- ខ្ទឹមបារាំង ឬខ្ទឹមស
- កែវទឹក កន្ត្រៃ ឡាមកោរពុកមាត់
- បំពង់ពិសោធន៍ ចង្កៀងអាល់កុល ឬទៀន
- មីក្រូទស្សន៍ ។

## ៣. រំលឹកចំណេះដឹង

ចំពោះរុក្ខជាតិ ចំណែកកោសិកាធ្វើនៅតំបន់មេជាលិកាដែលស្ថិតនៅចុងឫសនិងពន្លកដើម ។ ចំណែកកោសិកាមានពីរដំណាក់កាលគឺ មីតូសនិងចំណែកស៊ីតូប្លាស ។ មីតូសជាលំនាំមួយដែលរៀមយ៉ូនៃកោសិកាមួយ ចែកខ្លួនបានរៀមយ៉ូកូនពីរ ។ មីតូសមានបួនវគ្គគឺ ប្រូផាស អាណាផាស មេតាផាស និងតេឡូផាស ។

## ៤. ដំណើរការពិសោធ

- ជ្រើសរើសខ្ទឹមបារាំងឬមើមខ្ទឹមស ។ ត្រាំមើមខ្ទឹមសមួយយប់ រួចដាក់លើស្បែសើម ឬសំឡីសើម ដើម្បីឱ្យវាចេញឫស (ចំនួនប្រាំថ្ងៃ) ។
- យកកន្ត្រៃកាត់យកចុងឫសប្រហែល 0.50cm ។ គេអាចមើលឃើញចំណុចតូចពណ៌លឿងនៅជិតចុងឫស ដែលជាតំបន់មេជាលិកា (កន្លែងលូតលាស់) ។
- ដាក់ឫសក្នុងសូលុយស្យុងអាស៊ីតកាម៉ាំង(Carmin acetique)ហើយដាក់លើភ្លើងឱ្យពុះចំនួនពីរនាទី ។
- យកឫសចេញ កាត់យកផ្នែកដែលលូតលាស់ចេញពីឫស ។
- កាត់ឫសជាដុំតូចៗ រួចត្រាំក្នុងកាម៉ាំងអាសេទិចត្រជាក់ ។
- ដាក់ឫសលើកញ្ចក់ ហើយគ្របពីលើដោយបន្ទះកញ្ចក់ស្តើង ។
- ដាក់មេដៃលើកញ្ចក់ សង្កត់ថ្នមៗ (អាចប្រើផ្នុកស្មោតម្រមដម) ជៀសវាងកុំឱ្យកម្រើកមេដៃចុះឡើង ។
- ពិនិត្យមើលក្នុងមីក្រូទស្សន៍ ។

## 5. វិភាគ

គូររូបវគ្គផ្សេងៗនៃមីតូស ។

## សំណួរនិងលំហាត់ជំពូក1

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1 បណ្តុំសមាសធាតុដែលមាននៅក្នុងភាវៈរស់

☐ក. C H N P ☐ខ. C H O N ☐គ. C K Cl O ☐ឃ. S P C O ។

2 អង់ស៊ីមជា

☐ក. លីពីត ☐ខ. ប្រូតេអ៊ីន ☐គ. គ្លុយស៊ីត ☐ឃ. អាស៊ីតនុយក្លេអ៊ិច ។

3 មុខងាររបស់អាស៊ីតនុយក្លេអ៊ិច

☐ក. បង្កើតថាមពល ☐ខ. បង្កើតអង់ស៊ីម

☐គ. កាតាលីករប្រតិកម្ម ☐ឃ. បញ្ជូនព័ត៌មានសេនេទិច ។

4 តើសមាសធាតុអ្វីជំរុញប្រតិកម្ម តែមិនចូលរួមក្នុងប្រតិកម្ម ?

☐ក. ស្ករ ☐ខ. បាស ☐គ. អង់ស៊ីម ☐ឃ. អាស៊ីត ។

5 តើភ្នាសអ្វីជារបងការពារកោសិកាសត្វ ?

☐ក. ភ្នាសសែលុយឡូស ☐ខ. ភ្នាសណ្វៃយ៉ូ ☐គ. ភ្នាសស៊ីតូប្លាស ☐ឃ. ភ្នាសមីតូកុងឌ្រី ។

6 តើធាតុណាដែលផលិតប្រូតេអ៊ីន ?

☐ក. ណ្វៃយ៉ូ ☐ខ. លីសូសូម ☐គ. ក្រូម៉ូសូម ☐ឃ. រីបូសូម ។

7 ធាតុកោសិកាដែលមានតែនៅក្នុងកោសិកាសត្វ

☐ក. មីងតូកុងឌ្រី ☐ខ. រីបូសូម ☐គ. សង់ត្រូសូម ☐ឃ. ឧបករណ៍កុលស៊ី ។

8 កោសិកាមួយដែលកំពុងឆ្លងកាត់មីតូស ត្រូវបានពិនិត្យដោយមីក្រូទស្សន៍ ។ វាជាកោសិកាសត្វ កាលណា

☐ក. គូក្រូម៉ូសូមអូម៉ូឡូកបែកពីគ្នា ☐ខ. ក្រូម៉ូសូមរុំជាខ្សែខ្មៅ

☐គ. ណ្វៃយ៉ូរលាយបាត់ ☐ឃ. សង់ត្រូសូមបែកចេញពីគ្នា ។

9 ក្នុងលំនាំមីតូស បាតុភូតដែលកើតឡើងមុនគេគឺ

☐ក. កំណត្រយូងអាក្រូម៉ាទិច ☐ខ. ការលូតលាស់នៃកោសិកាកូន

☐គ. ក្រូម៉ូសូមដំឡើងទ្វេ ☐ឃ. ក្រូម៉ូសូមរលាស្មៀរ ។

10 កោសិកាមួយមានក្រូម៉ូសូម 12 តើមានក្រូម៉ូសូមប៉ុន្មានក្នុងកោសិកាកូន ?

☐ក. 24 ☐ខ. 6 ☐គ. 12 ☐ឃ. 4 ។

II. ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. មាននាទីសំខាន់ព្រោះបើគ្មានវាទេ ប្រតិកម្មគីមីផ្សេងៗក្នុងសារពាង្គកាយមិនអាចប្រព្រឹត្តទៅបានទេ ។

2. លំនាំដែលម៉ូលេគុលឆ្លងកាត់ពីតំបន់ដែលមានកំហាប់សូលុយស្យុងខ្ពស់ ទៅកំហាប់សូលុយស្យុងទាបហៅថា ។ រីឯលំនាំដែលម៉ូលេគុលទឹកឆ្លងកាត់ពីតំបន់មានកំហាប់សូលុយស្យុងទាបទៅកំហាប់សូលុយស្យុងខ្ពស់ហៅថា ។

3. វដ្តកោសិកាមាន និង រីឯចំណែកកោសិកាមាន និង ។

4. បាតុភូតសំខាន់ដែលធានាឱ្យណៃ្វយ៉ូកូនមានចំនួននិងរូបរាងក្រូម៉ូសូមដូចគ្នាគឺបាតុភូត ដែលធ្វើនៅវគ្គ S នៃ និងការ នៅវគ្គអាណាផាស ។

III. ចូរឆ្លើយសំណួរខាងក្រោមនេះ

1. កោសិកាមួយចាប់ផ្តើមប៉ោង កាលណាគេដាក់វាទៅក្នុងសូលុយស្យុងមួយដែលគេមិនស្គាល់ ។ ចូរប្រាប់ឈ្មោះមជ្ឈដ្ឋានសូលុយស្យុងនោះ ហើយពន្យល់បាតុភូត ។

2. សិស្សម្នាក់សាកល្បងយកគំរូបាតុភូតដោយយកថង់សំណាញ់ដាក់ទៅក្នុងសូលុយស្យុងទឹកអំបិល ។ បន្តិចក្រោយមកថង់នោះពេញដោយទឹកអំបិល ដែលកំហាប់សូលុយស្យុងក្នុងថង់ និងនៅក្រៅថង់ស្មើគ្នា ។ នេះមិនមែនជាគំរូល្អសម្រាប់បាតុភូតអូស្មូសទេ ។ ចូរជ្រើសរើសយកចម្លើយមួយដែលត្រូវ ហើយពន្យល់បាតុភូត ។

ក. ទឹកអំបិលមិនមែនជាសូលុយស្យុង ខ. ថង់មិនជ្រាប

គ. សូលុយស្យុងមិនមានកំហាប់សមស្រប ឃ. ថង់មិនមែនជាថង់ជម្រាបជ្រើស ។




3. សិស្សម្នាក់គូររូបតាងក្រូម៉ូសូមនៅប៉ូលនៃកោសិកាកំពុងធ្វើចំណែក ។ កោសិកានេះមានក្រូម៉ូសូម 4 (រូបទី 1) តើសិស្សបានធ្វើកំហុសឆ្គងអ្វីខ្លះក្នុងរូបខាងស្ដាំដៃនេះ? (រូបទី 2) ។

4. ពេលអ្នកបរិភោគប្រៃពេក ឬផ្អែមពេក អ្នកតែងតែស្រេកទឹកមិនឈប់ ។ យោងលើបាតុភូតអូស្មូសចូរពន្យល់ ។

5. កាលណាខ្វះទឹករុក្ខជាតិនឹងស្រពោន ។ អូស្មូសមាននាទីសំខាន់ក្នុងសម្រូបទឹករបស់រុក្ខជាតិ ។ ចូរពន្យល់ពីដំណើរនេះ ។

# ជំពូក 2 ការបន្តពូជនិងការលូតលាស់



ក្នុងដំណើរការបន្តពូជ ស្ពែម៉ាតូសូអ៊ីតជួបជាមួយអូវុលដែលបង្កើតបានជាស៊ីកូត ។

ចំពោះភាវៈរស់គ្រប់ប្រភេទ ការបន្តពូជបង្កើតបានជំនាន់ក្រោយ ដែលមានលក្ខណៈពិសេសសម្រាប់ប្រភេទនីមួយៗ ។ ការបន្តពូជធានាបាននូវភាពបន្តនៃទម្រង់នីមួយៗរបស់ជីវិត ។ វាបានផ្តល់ឱ្យយើងនូវឯកត្តភាព ព្រមទាំងកំណត់នូវឱដ្ឋភាពជាច្រើនសម្រាប់ជីវិតរបស់យើង ។ តើលំនាំដ៏អស្ចារ្យនេះកើតមានចំពោះមនុស្សដូចម្តេចដែរ? តើសរីរាង្គណាខ្លះដែលទាក់ទងនិងការបង្កើតសន្តានក្រោយរបស់មនុស្ស ? តើកោសិកាដើមមួយ (ស៊ីកូត) លូតលាស់ទៅជាមនុស្សពេញវ័យយ៉ាងដូចម្តេចដែរ?

# 1 កំណាកោសិកាបន្តពូជ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ធ្វើអត្តសញ្ញាណប្រដាប់បន្តពូជមនុស្សប្រុសនិងមនុស្សស្រី ។
- ❑ បកស្រាយពីលំនាំផ្សេងៗដែលកើតមានក្នុងវដ្តរដូវ ។
- ❑ ពណ៌នាពីចំណែកទាំងពីររបស់មេយ៉ូស ។
- ❑ ប្រៀបធៀបកំណកាម៉ែតញីនិងកាម៉ែតឈ្មោល ។

ភាវៈរស់គ្រប់ប្រភេទ បន្តពូជដើម្បីបង្កើតជំនាន់ក្រោយ ។ ការបន្តពូជធានានូវភាពបន្តនៃប្រភេទនីមួយៗ ។ ទាំងភេទញី ទាំងភេទឈ្មោលផលិតកោសិកាបន្តពូជដែលហៅថា **កាម៉ែត** ។

## 1. ប្រដាប់បន្តពូជ

វុក្ខជាតិនិងសត្វបង្កើតឯកត្ត ថ្មីតាមរយៈការបន្តពូជ ។ ការបន្តពូជទាក់ទងទៅនឹងសរីរាង្គពិសេសនៃប្រដាប់បន្តពូជ ។ ប្រដាប់ឬប្រព័ន្ធភាគច្រើនរបស់សារពាង្គកាយចាំបាច់ណាស់សម្រាប់ការរស់រានមានជីវិត ។ ចំពោះសត្វភាគច្រើន ការបាត់បង់ឬអសកម្មភាពនៃប្រព័ន្ធប្រសាទ ប្រដាប់រំលាយអាហារ ឬប្រដាប់របត់ឈាមអាចបណ្តាលឱ្យស្លាប់ ។ យ៉ាងណាមិញ ប្រដាប់បន្តពូជមិនសូវចាំបាច់សម្រាប់ការរស់នៅរបស់សារពាង្គកាយឡើយ ។ សារពាង្គកាយអាចមានជីវិតរស់នៅនិងមានសុខភាពល្អ ដោយមិនចាំបាច់មានការបន្តពូជ ។ ដូច្នេះចំពោះភាវៈរស់នីមួយៗ តើប្រដាប់បន្តពូជមានសារៈសំខាន់អ្វីខ្លះ ? ការបន្តពូជពិតជាចាំបាច់ណាស់សម្រាប់ភាពបន្តនៃប្រភេទភាវៈរស់ ។ បើគ្មានការបន្តពូជទេ ប្រភេទនីមួយៗនឹងត្រូវផុតពូជ ។

ចំពោះមនុស្សក៏ដូចជាសត្វឆ្អឹងកងដទៃទៀតដែរ ប្រដាប់បន្តពូជផលិត ស្តុកទុក ចិញ្ចឹម និងបញ្ចេញកាម៉ែត ។

### 1.1. ការលូតលាស់សរីរាង្គភេទ

ប្រាំមួយសប្តាហ៍ដំបូងក្រោយពេលបង្កកំណើត អំប្រ៊ីយ៉ុងទាំងពីរភេទមានរូបរាងខាងក្រៅដូចគ្នាទាំងអស់ ។ នៅសប្តាហ៍ទី 7 នៃការលូតលាស់ ការផ្លាស់ប្តូរសំខាន់ៗកើតមានឡើង ។ សរីរាង្គបន្តពូជដំបូង

របស់ភេទប្រុស (ពងស្វាស)ចាប់ផ្ដើមលូតលាស់ ។ ពងស្វាសចាប់ផ្ដើមផលិតអរម៉ូនតេស្តូស្តេរ៉ូន ។ ដើម្បីឆ្លើយតបទៅនឹងអរម៉ូននេះ ជាលិការនៃអំប្រ៊ីយ៉ុងលូតលាស់ទៅជាសរីរាង្គបន្តពូជរបស់ភេទប្រុស ។

ប្រសិនបើអំប្រ៊ីយ៉ុងជាភេទស្រីវិញ អូវែឬសរីរាង្គបន្តពូជដំបូងផលិតអរម៉ូនអឹស្ត្រូសែន ។ ដើម្បីឆ្លើយតបទៅនឹងអរម៉ូននេះ ជាលិកានៃអំប្រ៊ីយ៉ុងលូតលាស់ទៅជាសរីរាង្គបន្តពូជរបស់ភេទស្រី ។ អរម៉ូនទាំងនេះ ជាអ្នកកំណត់នូវលក្ខណៈរូបសាស្ត្រភេទប្រុស ឬភេទស្រីរបស់អំប្រ៊ីយ៉ុង ។ សរីរាង្គបន្តពូជញីនិងឈ្មោល លូតលាស់ចេញពីជាលិកាប្រភេទតែមួយ នៅដំណាក់កាលអំប្រ៊ីយ៉ុង ។




*រូបទី 1.1 : ការលូតលាស់នៃសរីរាង្គភេទដំបូង*

ក្រោយកំណើត ពងស្វាសនិងអូវែបន្តការផលិតអរម៉ូនភេទរៀងៗខ្លួនក្នុងបរិមាណតិចតួច ។ អរម៉ូនភេទទាំងពីរនេះ នៅតែមានឥទ្ធិពលលើការលូតលាស់របស់សរីរាង្គបន្តពូជ ។ ទោះជាយ៉ាងណាក៏ដោយ ទាំងពងស្វាស ទាំងអូវែ អាចផលិតកាម៉ែតបាន លុះត្រាតែដល់វ័យគ្រប់ការ(ពេញវ័យ) ។ ភាពគ្រប់ការជាដំណាក់កាលមួយដែលនៅពេលនោះ ប្រដាប់បន្តពូជចាប់ផ្ដើមបំពេញនាទីយ៉ាងពេញលេញគឺផលិត កាម៉ែត ។ ជាទូទៅវ័យគ្រប់ការកើតមានចំពោះក្មេងស្រីឆាប់ជាងក្មេងប្រុស ។

## 1.2. ប្រដាប់បន្តពូជមនុស្សប្រុស

### ក. រូបផ្តុំ




*រូបទី 1.2 : ក. រូបផ្តុំប្រដាប់បន្តពូជមនុស្សប្រុស, ខ. រូបផ្តុំពងស្វាស, គ. គំនូសបំប្រួញកាត់ទទឹងបំពង់សេមីនីហ្វែ*

### ១. ពងស្វាស

ពងស្វាស ជាក្រពេញភេទឈ្មោល ដែលមាននាទីពីរយ៉ាង គឺផលិតអរម៉ូនភេទឈ្មោល (តេស្តូស្តេរ៉ូន) និងបង្កើតស្ពែម៉ាតូសូអ៊ីត ។ អរម៉ូនតេស្តូស្តេរ៉ូន បណ្តាលឱ្យមានការលូតលាស់នូវលក្ខណៈភេទបន្ទាប់ដូចជា សម្លេងឡើងគ្រលរ ដុះរោមលើខ្លួននិងមុខ ស្មារីកទូលាយ សាច់ដុំលូតលាស់ ។ លក្ខណៈភេទបន្ទាប់ទាំងនេះមិនទាក់ទងដោយផ្ទាល់ក្នុងការបន្តពូជឡើយ ។

ពងស្វាសស្ថិតនៅក្នុងថង់ស្បែកមួយហៅថា ថង់ពងស្វាស ដែលភ្ជាប់នៅខាងក្រៅរាងកាយ (រូបទី 1.2. ក) ។ ថង់ពងស្វាស រក្សាពងស្វាសឱ្យស្ថិតក្នុងសីតុណ្ហភាពពី 1°C – 3°C ទាបជាងសីតុណ្ហភាពក្នុងសារពាង្គកាយ (37°C) ។ លក្ខណៈបែបនេះមានអំណោយផលល្អសម្រាប់ការផលិតនិងការរក្សាកាម៉ែតឈ្មោលខុក ។ ប្រសិនបើសីតុណ្ហភាពក្តៅពេកសាច់ដុំក្នុងថង់ពងស្វាសបន្ធូរ(យារ)ដែលធ្វើឱ្យពងស្វាសធ្លាក់ចេញឆ្ងាយពីរាងកាយ ។ ប្រសិនបើសីតុណ្ហភាពត្រជាក់ពេក សាច់ដុំថង់ពងស្វាសទាញពងស្វាសឱ្យនៅជាប់នឹងរាងកាយ ។

មុនពេលកើត ពងស្វាសលូតលាស់នៅក្នុងប្រហោងពោះ ។ វាធ្លាក់ចូលទៅក្នុងថង់ពងស្វាស មុនពេលកើត ។ ជួនកាលពងស្វាសមួយឬទាំងពីរមិនធ្លាក់ចូលក្នុងថង់ពងស្វាសទេ ។ ពងស្វាសដែលស្ថិតនៅក្នុងរាងកាយមិនផលិតស្ពែម៉ាតូសូអ៊ីតឡើយ ព្រោះសីតុណ្ហភាពនៅទីនោះខ្ពស់ពេកដែលជាលក្ខខណ្ឌមិនប្រកបចំពោះការផលិតកាម៉ែត ។ ក្នុងករណីខាងលើ គេអាចព្យាបាលតាមវិធីវះកាត់ឬប្រើអរម៉ូន ។

តាមធម្មតា ពងស្វាសដែលធ្លាក់ចុះមកក្នុងថង់ពងស្វាស មិនផលិតស្ពែម៉ាតូសូអ៊ីតភ្លាមទេ ។ វាចាប់ផ្ដើមផលិតនៅវ័យគ្រប់ការ ។ ពងស្វាសផលិតស្ពែម៉ាតូសូអ៊ីតរាប់រយលានរៀងរាល់ថ្ងៃ ។ ពងស្វាសនីមួយៗបង្កឡើងពីបំពង់ឆ្មារៗ វែងៗជាច្រើន ដែលរមូរគងលើគ្នា ហៅថា **បំពង់សេមីនីភែ** ។ ពងស្វាសមួយមានបំពង់សេមីនីភែពី 300-600 (រូបទី 1.2 ខ) ។ ក្នុងបំពង់សេមីនីភែនីមួយៗមានកោសិកាតូចៗជាច្រើនដែលនឹងលូតលាស់ទៅជាកាម៉ែតឈ្មោល ។ កោសិកាអាំងទែស្ទីស្យែលនៅចន្លោះបំពង់សេមីនីភែផលិតអរម៉ូនតេស្តូស្តេរ៉ូន(រូបទី 1.2 គ) ។

នៅវ័យគ្រប់ការ ពងស្វាសចាប់ផ្ដើមផលិតអរម៉ូនភេទឈ្មោលជាច្រើន ។ អរម៉ូននេះ មានឥទ្ធិពលលើការផលិតកាម៉ែតឈ្មោលតាមលំនាំមេយ៉ូស ។ ក្រោយពីផលិតហើយ ស្ពែម៉ាតូសូអ៊ីតត្រូវបានប្រមូលផ្ដុំនិងស្តុកទុកក្នុងបំពង់អេពីឌីឌីម ដែលនៅទីនោះវានឹងក្លាយជាកាម៉ែតពេញវ័យ ។

## គ. ស្ពែម៉ាតូសូអ៊ីត



*រូបទី 1.3 : ស្ពែម៉ាតូសូអ៊ីត*

ស្ពែម៉ាតូសូអ៊ីត ជាកោសិកាតូចល្អិតបំផុតក្នុងសារពាង្គកាយមនុស្សប្រុសឬសត្វឈ្មោល ។ ស្ពែម៉ាតូសូអ៊ីតចែកជាបីផ្នែក ផ្នែកក្បាល កណ្ដាល និងផ្លាសែល (កន្ទុយ) ។ ក្បាលរបស់កាម៉ែតឈ្មោលមានណ្វៃយ៉ូធំមួយដែលមានចំនួនក្រូម៉ូសូមអាប្លូអ៊ីត ។ ផ្នែកខាងលើនៃណ្វៃយ៉ូមានថង់មួយដែលពេញដោយអង់ស៊ីមហៅថា **អាក្រូសូម** ។ អង់ស៊ីមនេះជួយឱ្យស្ពែម៉ាតូសូអ៊ីតជ្រៀតចូលទៅក្នុងស៊ីតូប្លាសរបស់អូវុលបាន ។ ផ្លាសែលបង្កឡើងពីបំពង់ ។ ក្នុងផ្នែកកណ្ដាលរបស់ស្ពែម៉ាតូសូអ៊ីត ឫសរបស់ផ្លាសែលរុំព័ទ្ធដោយមីតូកុងទ្រី ។ ក្នុងទឹកពូជ ស្ពែម៉ាតូសូអ៊ីតស្រូបយកស្ករព្រុចតូស បន្ទាប់មក មីតូកុងទ្រីនៅក្នុងផ្នែកកណ្ដាលបំប្លែងស្ករនេះទៅជាថាមពល ដែលអាចប្រើប្រាស់បានក្រោមទម្រង់ជាម៉ូលេគុល ATP ។ កាម៉ែតឈ្មោលប្រើប្រាស់ថាមពលនេះ ដើម្បីឱ្យផ្លាសែលធ្វើចលនាបាន ។ ស្ពែម៉ាតូសូអ៊ីតទាំងមូល រុំព័ទ្ធដោយស្រទាប់ស៊ីតូប្លាសយ៉ាងស្តើងដែលពាសពីក្រៅដោយភ្នាសស៊ីតូប្លាស ។ នៅពេលបង្កកំណើតមានតែក្បាលស្ពែម៉ាតូសូអ៊ីតប៉ុណ្ណោះ ដែលជ្រៀតចូលទៅក្នុងស៊ីតូប្លាសរបស់អូវុល ។

## ឃ. ទឹកកាមនិងការបញ្ចេញទឹកកាម

នៅក្នុងបង្ហូរនោម ស្ពែម៉ាតូសូអ៊ីតលាយជាមួយធាតុរាវ ដែលបញ្ចេញដោយក្រពេញបញ្ចេញក្រៅរួមមានថង់ពូជ ក្រពេញប្រូស្តាត និងក្រពេញខូពែ ។ ធាតុរាវទាំងនេះ ចិញ្ចឹមកាម៉ែតឈ្មោលព្រមទាំងជួយវាក្នុងការធ្វើដំណើរឆ្លងកាត់ប្រដាប់បន្តពូជញី ។ ថង់ពូជផលិតធាតុរាវសម្បូរជាតិស្ករ ដែលកាម៉ែត

ឈ្មោលប្រើប្រាស់ជាថាមពល ។ ក្រពេញប្រូស្តាត ផលិតធាតុរាវជាបាសសម្រាប់បន្សាបជាតិអាស៊ីតនៅក្នុងប្រដាប់បន្តពូជញី ។ មុននិងទឹកកាមចាកចេញពីរាងកាយ ក្រពេញខូពែបញ្ចេញធាតុរាវជាបាសសម្រាប់បន្សាបអាស៊ីតអ៊ុយរិចនៃទឹកនោមក្នុងបង្ហួរនោម ។ ល្បាយនៃធាតុរាវជាមួយស្ពែម៉ាតូសូអ៊ីតហៅថា**ទឹកកាម** ។ ក្នុងទឹកកាមមួយ $1mm^3$ មានស្ពែម៉ាតូសូអ៊ីតប្រហែលពី 100 – 200 លាន ។

ទឹកកាមចាកចេញពីរាងកាយតាមបង្ហួរនោម ។ ទឹកនោមក៏ចាកចេញពីរាងកាយតាមបង្ហួរនោមដែរ ។ នៅពេលទឹកកាមឆ្លងកាត់តាមបង្ហួរនោម សាច់ដុំនៅក្បែរប្លោកនោមកន្ត្រាក់ ។ ការកន្ត្រាក់នេះធ្វើឱ្យរន្ធបង្ហួររបស់ប្លោកនោមបិទជិត ដែលបង្ការមិនឱ្យទឹកនោមហូរចេញតាមបង្ហួរនោមលាយជាមួយទឹកកាម ។

## 1.3. ប្រដាប់បន្តពូជមនុស្សស្រី

### ក. រូបផ្គុំ




*រូបទី 1.4 : ក. រូបផ្គុំប្រដាប់បន្តពូជមនុស្សស្រី, ខ. ដំណាក់កាលផ្សេងៗនៃការលូតលាស់ផូលីគុលក្នុងអូវែ*

### ខ. អូវែពេញវ័យ

ក្រពេញភេទញីជាអូវែ ដែលស្ថិតនៅក្នុងប្រហោងពោះ ផ្នែកខាងក្រោមចង្កេះបន្តិច ។ វាផលិតអូវុលនិងបញ្ចេញអរម៉ូនអឺស្ត្រូសែនផងដែរ ។ អរម៉ូនអឺស្ត្រូសែន បណ្តាលឱ្យមានការលូតលាស់នូវលក្ខណៈភេទបន្ទាប់របស់ស្ត្រីនិងមាននាទីសំខាន់ក្នុងវដ្តរដូវ ។ *ឧទាហរណ៍* អរម៉ូនអឺស្ត្រូសែនបណ្តាលឱ្យឆ្អឹងត្រគាករីកសាយ ដើមទ្រូងលូតលាស់ជាដើម ។ វាក៏មានឥទ្ធិពលទៅលើការលូតលាស់របស់កាម៉ែតញីផងដែរ ។

អូវែមានពីរផ្នែក ៖

- ផ្នែកក្នុងសម្បូរដោយសរសៃឈាម
- ផ្នែកជាយ (សំបក) ជាកន្លែងកាម៉េតញីលូតលាស់ ។

ពំនុះអូវែនារីពេញវ័យបង្ហាញឱ្យឃើញថា នៅផ្នែកសំបកមានផូលីគុលតូចៗនិងផូលីគុលធំៗ ។ ផូលីគុលនីមួយៗបង្កឡើងពីកាម៉េតញី (អូវូស៊ីត II) ដែលព័ទ្ធជុំវិញដោយកោសិកាផូលីគុល ។ ផូលីគុលទាំងអស់នៅក្នុងអូវែ មានមាឌខុសៗគ្នា ។ នេះបង្ហាញឱ្យឃើញថា វាស្ថិតនៅក្នុងដំណាក់កាលខុសៗគ្នានៃការវិវត្តរបស់វា ។ ផូលីគុលល្អិតជាងគេ ជាផូលីគុលដើម ។ ចាប់តាំងពីវាកកើតឡើងនៅក្នុងអូវែរបស់អំប្រីយ៉ុងរហូតដល់ពេលពេញវ័យ ផូលីគុលដើមមិនវិវត្តទេ ។ ផូលីគុលធំៗមានផូលីគុលទីមួយ ផូលីគុលទីពីរ និងផូលីគុលប្រហោងដែលជាតំណាងដំណាក់កាលនីមួយៗ នៃការវិវត្តរបស់ផូលីគុលដើម ។ កំណើនមាឌផូលីគុលបណ្តាលមកពីការរីកមាឌរបស់កាម៉េតញីនិងកំណើនចំនួនកោសិកាផូលីគុល ។

## គ. អូវុល

កាម៉េតញីឬអូវុលជាកោសិកាធំជាងគេនៅក្នុងរាងកាយមនុស្សស្រី ឬសត្វញី ។ វាមិនធ្វើចលនាទេ ។ ស៊ីតូប្លាសយ៉ាងធំនេះ មាននាទីសំខាន់ នៅក្នុងដំណាក់កាលដំបូងនៃការលូតលាស់របស់អំប្រីយ៉ុង ។ នៅក្នុងស៊ីតូប្លាស មានផ្ទុកអាស៊ីតរីបូនុយក្លេអ៊ិច ដែលចាំបាច់ក្នុងការសំយោគប្រូតេអ៊ីនរបស់កោសិកា ។ លើសពីនេះ ដើម្បីសំយោគប្រូតេអ៊ីន អូវុលត្រូវត្រៀមបម្រុងនូវរូបធាតុដើម ។ ចំពោះថនិកសត្វ រូបធាតុដើមត្រូវផ្តល់ឱ្យដោយសារពាង្គកាយមេ សម្រាប់ការលូតលាស់របស់គភ៌នៅក្នុងស្បូន ។

អូវុលមានទំហំខុសៗគ្នាទៅតាមប្រភេទនីមួយៗរបស់សត្វ ហើយទំហំខុសៗគ្នានេះ អាស្រ័យទៅនឹងបរិមាណជាតិលឿងដែលស្តុកទុក ។ ជាតិលឿងនេះប្រើប្រាស់ដូចជាសារធាតុចិញ្ចឹមសម្រាប់ការលូតលាស់របស់អំប្រីយ៉ុង ។

## 1.4. វដ្តអូវែ

ប្រដាប់បន្តពូជរបស់ស្ត្រី មានដំណើរប្រព្រឹត្តទៅជាវដ្ត ។ វាចាប់ផ្តើមនៅវ័យគ្រប់ការនិងបញ្ចប់នៅវ័យអស់រដូវ (ពីអាយុ 45-50 ឆ្នាំ) ។ ស្ត្រីម្នាក់មានលទ្ធភាពផលិតអូវូស៊ីតពី 400-500 ចំណោះចាប់ពីពេលគ្រប់ការរហូតដល់ពេលអស់រដូវ ។

វដ្តភេទដែលមានរយៈពេលជាមធ្យម 28 ថ្ងៃ (ប៉ុន្តែអាចប្រែប្រួលពី 24 ថ្ងៃទៅ 32 ថ្ងៃតាមលក្ខណៈសរីរៈរបស់ស្ត្រីម្នាក់ៗ) ត្រូវបានកំណត់តាមរយៈការមានរដូវ ។ មូលហេតុនេះហើយ គេហៅវដ្តភេទ

នេះថាជាវដ្តរដូវ ។ វដ្តរដូវនីមួយៗ ធ្វើឱ្យមានការប្រែប្រួលយ៉ាងស្មុគស្មាញ ហើយពាក់ព័ន្ធជាមួយសរីរាង្គជាច្រើន ។ គេអាចញែកចេញជា វដ្តស្បូន វដ្តអូវ៉ែ និងវដ្តអរម៉ូន ។ វដ្តទាំងបីនេះកើតឡើងព្រមៗគ្នា ។ ដោយឡែក វដ្តអូវ៉ែមានបីវគ្គគឺ វគ្គផូលីគុល ដំណើរអូវុល និងវគ្គលុយតេអ៊ីច ។




*រូបទី 1.5 : ការលូតលាស់របស់ផូលីគុល*

## ក. វគ្គផូលីគុល

ក្នុងវ័យអំប្រីយ៉ុង អូវ៉ែនីមួយៗមានផូលីគុលដើមមួយចំនួនធំ ។ ផូលីគុលដើមនេះ បង្កឡើងពីកាម៉ែតញី (អូវ៉ូទីត)ដែលមានមាឌតូចនិងរុំព័ទ្ធដោយកោសិកាផូលីគុលចំនួនពី3ទៅ4 ។ នៅវ័យគ្រប់ការ ពី3 ទៅ4ខែមុនខែមានរដូវ ផូលីគុលដើមវិវត្ត (កើនមាឌ) រហូតដល់ផូលីគុលប្រហោង (រូបទី 1.5) ។ ដូចនេះ នៅដើមវគ្គផូលីគុល ក្នុងអូវ៉ែនីមួយៗមានផូលីគុលប្រហោងចំនួនប្រហែល 10 ដែលមានអង្កត់ផ្ចិតពី 2 – 4mm ។ក្នុងចំណោមផូលីគុលប្រហោងទាំងអស់នោះ មានផូលីគុលប្រហោងតែមួយប៉ុណ្ណោះដែលវិវត្តរហ័សជាងគេ ក្នុងរយៈពេលតែ 2 – 3 ថ្ងៃ ដោយមានអង្កត់ផ្ចិតពី 16 – 27mm (ផូលីគុលដឺក្រាប)ហើយវាក៏បញ្ចប់ការវិវត្តនៅចុងដំណាក់កាលទី 1 (វគ្គផូលីគុល)នៃវដ្តរដូវ ។ ចំណែកផូលីគុលដទៃទៀតស្វិតបាត់អស់ ។

## ខ. ដំណើរអូវុល

ក្រោមអំពើរបស់អង់ស៊ីម ផ្ទៃរបស់អូវ៉ែនិងស្រទាប់កោសិកាផូលីគុលប្រែជាស្តើងហើយធ្លាយ ។ ផូលីគុលទុំបញ្ចេញកាម៉ែតញី (អូវ៉ូស៊ីតII) ទៅក្រៅ ។ នេះជាដំណើរអូវុលដែលមានរយៈពេលយ៉ាងខ្លីបំផុត ។ បន្ទាប់មកកាម៉ែតញីផ្ដើមដំណើរតាមដៃស្បូនដែលនៅទីនោះមានការបង្កកំណើត ប្រសិនបើជួបនឹងស្ពែម៉ាតូសូអ៊ីត ។ ប្រសិនបើមិនបានបង្កកំណើតទេវានឹងងាប់ ហើយបញ្ចេញចោលក្រោមទម្រង់ជាអូវ៉ូស៊ីតII តាមឈាមរដូវ ។




រូបទី 1.6 : ដំណើរអូវុលនិងការបង្កើតអង្គលឿង

## គ. វគ្គលុយតេអ៊ីច

បន្ទាប់ពីដំណើរអូវុល មានការប្រមូលផ្តុំលីពីតនិងជាតិពណ៌លឿងក្នុងកោសិកាផូលីគុលរបស់ផូលីគុលដែលផ្ទុះបែក ហើយបង្កើតបានជាអង្គលឿង ។ អង្គលឿងចាប់ផ្តើមផលិតអរម៉ូនប្រូសេស្តេរ៉ូននិងអឹស្ត្រាឌីយ៉ូលតិចតួច ។ អរម៉ូនទាំងនេះ ត្រួតពិនិត្យលក្ខខណ្ឌនៅក្នុងផ្ទៃស្បូនរយៈពេលនៃវដ្តរដូវ ។ ប្រសិនបើគ្មានការបង្កកំណើតទេ អង្គលឿងរលាយបាត់បន្តិចម្តងៗរហូតនៅសល់តែសំណាកតូចមួយនៅលើផ្ទៃអូវ៉ែ ។ បន្ទាប់មកវដ្តរដូវថ្មីចាប់ផ្តើមឡើង ។

## 1.5. វដ្តស្បូន

ស្របគ្នានឹងការប្រែប្រួលរបស់អូវ៉ែ នៅក្នុងស្បូនក៏មានការផ្លាស់ប្តូរដែរ ។ ការផ្លាស់ប្តូរនេះហៅថាវដ្តស្បូន ។ ស្បូនបង្កឡើងពីស្រទាប់សាច់ដុំក្រាស់ ហើយនៅផ្នែកខាងក្នុងពាសដោយស្រទាប់ភ្នាសស្តើងដែលហៅថា ភ្នាសសើមស្បូន ។

ក្នុងរយៈពេលនៃវគ្គផូលីគុល ភ្នាសសើមស្បូនឡើងក្រាស់ជាលំដាប់ពី 1 – 3mm ។ សរសៃឈាមល្អិតៗលូតលាស់នៅក្នុងស្រទាប់ភ្នាសនេះ ។

បន្ទាប់ពីដំណើរអូវុល អង្គលឿងចាប់ផ្តើមផលិតអរម៉ូនអឹស្ត្រូសែនដែលបណ្តាលឱ្យសរសៃឈាមនៅក្នុងស្រទាប់ភ្នាសសើមស្បូនរីកធំឡើង ។ ភ្នាសសើមស្បូនកាន់តែក្រាស់ជាអតិបរមាពី 5 – 7mm ។ ក្រពេញភ្នាសសើមស្បូនឡើងរមួល ព្រមទាំងបញ្ចេញស្លេស្មខាប់និងគ្លីកូសែន ។ ក្នុងវគ្គលុយតេអ៊ីន ភ្នាសសើមស្បូនត្រៀមទទួលអំប្រីយ៉ុងក្នុងរយៈពេលពី 4 – 5 ថ្ងៃក្រោយដំណើរអូវុល ។ ប្រសិនបើគ្មានការកាច់សំបុករបស់អំប្រីយ៉ុងទេ កម្រិតអរម៉ូនអឹស្ត្រូសែននិងប្រូសេស្តេរ៉ូនធ្លាក់ចុះ ។ លក្ខណៈនេះបណ្តាលឱ្យសរសៃឈាមក្នុងភ្នាសសើមស្បូនបិទ ហើយដាច់ ។ កោសិការបស់ភ្នាសសើមស្បូនទទួលការផ្គត់ផ្គង់ឈាមមិនគ្រប់គ្រាន់ ហើយក៏ដាច់ចេញពីផ្ទៃកខាងក្នុងរបស់ស្បូន ។ ល្បាយឈាមនិងកម្ទេចកំទីនៃកោសិកាភ្នាសសើមស្បូន បង្កើតជាឈាមរដូវ ។ ធាតុរាវនេះហូរចេញទៅក្រៅសារពាង្គកាយតាមផ្លូវភេទ ។




រូបទី 1.7 : សកម្មភាពរបស់ក្រពេញអូវែទាក់ទងទៅនឹងការវិវត្តស្បូន

ការប្រែប្រួលនេះពាក់ព័ន្ធតែជាមួយភ្នាសសើមរបស់តួស្បូនប៉ុណ្ណោះ ។ ក្រពេញកស្បូនបញ្ចេញស្លេស្មខាប់និងគ្មានពណ៌ហៅថា ស្លេស្មកស្បូន ។ ស្លេស្មកស្បូនមានលក្ខណៈដូចគ្នានឹងសស៊ិតរបស់បក្សី ។ ស្លេស្មនេះសម្បូរនៅក្នុងរយៈពេលជុំវិញដំណើរអូវុល (ធ្លាក់ស) ។

រយៈពេលនៃវដ្តរដូវគឺ ជារយៈពេលមួយដែលលាតសន្ធឹងចន្លោះឈាមរដូវពីរ ។ ថ្ងៃទីមួយនៃវដ្តរដូវ គឺជាថ្ងៃដែលធ្លាក់ឈាមរដូវ ។ ថ្ងៃចុងក្រោយនៃវដ្តរដូវ គឺជាថ្ងៃមុនថ្ងៃធ្លាក់ឈាមរដូវខែបន្ទាប់ ។ រយៈពេលមធ្យមរបស់វដ្តរដូវប្រែប្រួលទៅតាមស្ត្រីម្នាក់ៗ ។ ចំពោះស្ត្រីម្នាក់ វដ្តរដូវជួនកាលវែង




រូបទី 1.8 : វដ្តរដូវរយៈពេល30ថ្ងៃ

ជូនកាលខ្លី ។ គួរកត់សំគាល់ថា កាលណាវដ្តរដូវវែងឬខ្លីដោយសារការប្រែប្រួលនៃរយៈពេលវគ្គផូលីគុល ផ្ទុយទៅវិញរយៈពេលវគ្គលុយតេអ៊ិចមិនប្រែប្រួលទេ ។ ជាទូទៅ ពេលរដូវមានក្នុងរយៈពេលពី 13 – 14 ថ្ងៃ ក្រោយមានដំណើរអូវុល ។ វដ្តដែលមានរយៈពេលមិនធម្មតា ច្រើនកើតមានឡើងនៅលើស្ត្រីវ័យក្មេងជាងស្ត្រីវ័យចំណាស់ ។

## 2. មេយ៉ូស

សំណុំនៃចំណែកកោសិកាពីរដងបន្តបន្ទាប់គ្នា ដែលបង្កើតបានជាកោសិកាអាប្លូអ៊ីតបួន ហៅថាមេយ៉ូស ។ មេយ៉ូសកើតឡើងក្នុងគ្រប់សារពាង្គកាយទាំងអស់ ដែលបន្តពូជដោយភេទ ។ ចំពោះរុក្ខជាតិថ្នាក់ខ្ពស់និងសត្វ មេយ៉ូសប្រព្រឹត្តទៅក្នុងសរីរាង្គភេទពិសេស ។ នៅពេលផ្តើមមេយ៉ូស កោសិកាមេមានចំនួនក្រូម៉ូសូមឌីប្លូអ៊ីត ។ នៅពេលចំណែកមេយ៉ូស កោសិកានីមួយៗធ្វើចំណែកពីរដងបន្តបន្ទាប់គ្នា ។ មុនចំណែកទី 1 របស់មេយ៉ូស ក្រូម៉ូសូមស្វ័យដំឡើងទេ ។ ចប់ចំណែកទី 2 របស់មេយ៉ូស កោសិកាដើមនីមួយៗផលិតបានកោសិកាកូនបួន ។ កោសិកាកូននីមួយៗមានចំនួនក្រូម៉ូសូមអាប្លូអ៊ីត ។ ចំណែកទី 1 និងទី 2 របស់មេយ៉ូសមានបួនវគ្គដូចគ្នា ប្រូផាស មេតាផាស អាណាផាស និងតេឡូផាស ។ (រូបទី 1.9)បង្ហាញពីចំណែកមេយ៉ូសនៅក្នុងកោសិកាសត្វ ។

### 2.1. ដំណាក់កាលផ្សេងៗនៃចំណែកមេយ៉ូស

**ចន្លោះវគ្គ** ៖ មុនមេយ៉ូសចាប់ផ្តើម ក្រូម៉ូសូមនីមួយៗធ្វើស្វ័យដំឡើងទ្វេបានជាក្រូម៉ាទីតពីរដូចគ្នា (ក្រូម៉ាទីតបងប្អូន) ដែលភ្ជាប់គ្នាដោយសង់ត្រូមែ ។ ក្នុងចន្លោះវគ្គ ក្រូម៉ូសូមជាភីឡាម៉ង់ឆ្មារៗ និងមិនអាចមើលឃើញ ។

ប្រូផាស I ៖ វគ្គនេះមានរយៈពេលវែង ។ ក្រូម៉ូសូមធ្វើស្ពៀរកម្មរួញខ្លីហើយឡើងក្រាស់ដែលអាចមើលឃើញ ។ ក្រូម៉ូសូមប្រេះតាមបណ្តោយជាក្រូម៉ាទីតពីរ ។ ក្រូម៉ូសូមអូម៉ូឡូកដែលប្រេះតាមបណ្តោយទាំងអស់រំកិលជិតគ្នាពីរៗនិងជាប់គ្នានៅតាមបណ្តោយ ដែលបង្កើតបានជាក្រូម៉ាទីតបួនឬតេត្រាត ។ ពេលខ្លះអាចមានបណ្តូរអង្កត់រវាងក្រូម៉ាទីតពីរនៃគូក្រូម៉ូសូមអូម៉ូឡូក ។ បណ្តូរអង្កត់នេះហៅថា បាតុភូតក្រូស៊ីញអូវើ ។ នៅចុងបញ្ចប់ប្រូផាស I ភ្នាសណ្វៃយ៉ូរលាយបាត់ ត្រយូងអាក្រូម៉ាទិចលេចឡើង តេត្រាតធ្វើចលនាឆ្ពោះទៅអេក្វាទ័ររបស់កោសិកា ។

មេតាផាស I ៖ តេត្រាតទាំងអស់ ដែលតម្រៀបគ្នានៅលើប្លង់អេក្វាទ័រ ភ្ជាប់ខ្លួនទៅនិងត្រយ៉ូងអាក្រូម៉ាទិច ដោយសង់ត្រូមែររបស់វា ។

អាណាផាស I ៖ ក្រូម៉ូសូមអូម៉ូឡូកនៃគូនីមួយៗផ្តាច់ចេញពីគ្នា ហើយធ្វើដំណើរទៅកាន់ប៉ូលផ្ទុយគ្នារបស់កោសិកា ។ ក្រូម៉ាទីតទាំងពីររបស់ក្រូម៉ូសូមនីមួយៗមិនផ្តាច់ចេញពីគ្នាទេ ។ នៅប៉ូលកោសិកានីមួយៗ មានចំនួនក្រូម៉ូសូមអាប្លូអ៊ីត ។

តេឡូផាស I ៖ ស៊ីតូប្លាសចែកខ្លួនបានជាកោសិកាកូនពីរ ។ កោសិកាកូននីមួយៗទទួលបានក្រូម៉ូសូមតែមួយពីគូអូម៉ូឡូក ។ ដូចនេះកោសិកាកូនមានចំនួនក្រូម៉ូសូមតែពាក់កណ្ដាលនៃចំនួនក្រូម៉ូសូមរបស់កោសិកាមេ ។ គួរកត់សំគាល់ថា ក្រូម៉ូសូមនីមួយៗមានក្រូម៉ាទីតពីរ ។ ត្រយូងអាក្រូម៉ាទិចរលាយបាត់ ។




*រូបទី 1.9 : មេយ៉ូស*

នៅពេលបញ្ចប់ តេឡូផាស I ភ្លាម កោសិកាចាប់ផ្ដើមធ្វើចំណែកទី 2 ភ្លាម ។

ប្រូផាស II ៖ ត្រយូងអាក្រូម៉ាទិចកើតមានក្នុងកោសិកាកូននីមួយៗ ។ ក្រូម៉ូសូមដែលប្រេះតាមបណ្ដោយ ធ្វើដំណើរឆ្ពោះទៅផ្នែកកណ្ដាលនៃត្រយូងអាក្រូម៉ាទិច ។

មេតាផាស II ៖ ក្រូម៉ូសូមប្រេះតាមបណ្ដោយ ភ្ជាប់ខ្លួនទៅនឹងត្រយូងអាក្រូម៉ាទិច ដោយសង់ត្រូមែ ។ ក្រូម៉ូសូមទាំងអស់ ប្រមូលផ្ដុំនៅលើប្លង់អេក្វាទ័ររបស់កោសិកា ។

អាណាផាស II ៖ សង់ត្រូមែធ្វើចំណែក ដែលនាំឱ្យក្រូម៉ាទីតបងប្អូនដាច់ចេញពីគ្នា ។ ដូចនេះក្រូម៉ាទីតនីមួយៗ ក្លាយជាក្រូម៉ូសូមកូន ។ បន្ទាប់មកក្រូម៉ូសូមកូនទាំងពីរធ្វើដំណើរឆ្ពោះទៅកាន់ប៉ូល 2 ផ្ទុយគ្នារបស់ត្រយូងអាក្រូម៉ាទិច ។

តេឡូផាស II ៖ ក្រុមក្រូម៉ូសូមកូននីមួយៗបានមកដល់ប៉ូល ។ ភ្នាសណ្វៃយ៉ូកើតឡើង ។ ត្រយូងអាក្រូម៉ាទិចក៏រលាយបាត់ ។ បន្ទាប់មកស៊ីតូប្លាសធ្វើចំណែកបានជាកោសិកាកូន 2 ។ នៅចុងបញ្ចប់នៃចំណែកទី 2 របស់មេយ៉ូសកោសិកាឌីប្លូអ៊ីតមួយបង្កើតបានកោសិកាកូនអាប្លូអ៊ីត 4 ។

សន្និដ្ឋាន

- ចំណែកទី 1 របស់មេយ៉ូសរាប់រងការផ្ដាច់ចេញពីគ្នានៃគូក្រូម៉ូសូមអូម៉ូឡូក ។ ដូចនេះមានការបន្ថយចំនួនក្រូម៉ូសូមពាក់កណ្ដាល ។ កោសិកាកូននីមួយៗមាន n ក្រូម៉ូសូម ។ វាជាកោសិកាអាប្លូអ៊ីត ។
- ចំណែកទី 2 របស់មេយ៉ូស រាប់រងការផ្ដាច់ចេញពីគ្នានៃក្រូម៉ាទីតបងប្អូនរបស់ក្រូម៉ូសូមនីមួយៗ ។ ដូចនេះកាម៉ែតនីមួយៗមានក្រូម៉ូសូមមួយក្នុងគូអូម៉ូឡូកនីមួយៗ ហើយក្រូម៉ូសូមនីមួយៗមានក្រូម៉ាទីតតែមួយ ។

## 2.2. កំណកាម៉ែតឈ្មោល

កោសិកាពូជនីមួយៗដែលស្ថិតនៅលើផ្ទៃខាងក្នុងនៃសំបកបំពង់សេមីនីភែ ធ្វើចំណែកតាមមីតូសជាបន្តបន្ទាប់ បង្កើតបានជាស្ពែម៉ាតូកូនី ។ បន្ទាប់ពីកំណើនមាឌតិចតួច ស្ពែម៉ាតូកូនីនីមួយៗក្លាយជាស្ពែម៉ាតូស៊ីតI ។ ស្ពែម៉ាតូស៊ីតI ធ្វើចំណែកទី 1 នៃមេយ៉ូស បង្កើតបានកោសិកាពីរដែលមានទំហំស្មើគ្នា គឺស្ពែម៉ាតូស៊ីតII ។ បន្ទាប់មកស្ពែម៉ាតូស៊ីតII ធ្វើចំណែកទី 2 នៃមេយ៉ូស បង្កើតបានស្ពែម៉ាទីត 2 ដែលមានរាងមូលនិងទំហំស្មើគ្នា ។ ក្រោយមកវាប្លែងខ្លួនជាកោសិកាតូចៗ ដែលមានកន្ទុយវែង គឺជាស្ពែម៉ាតូសូអ៊ីត ។




*រូបទី 1.10 : កំណកាម៉ែតឈ្មោល*

ចំពោះមនុស្សប្រុសរយៈពេលនៃកំណស្ពែម៉ាតូសូអ៊ីត (ចាប់តាំងពីកោសិកាពូជរហូតដល់ស្ពែម៉ាតូសូអ៊ីត) មានរយៈពេល 74 ថ្ងៃ ។ កំណស្ពែម៉ាតូសូអ៊ីតចាប់ផ្ដើមតាំងពីពេលគ្រប់ការនិងដំណើរការរហូតពេញមួយជីវិតរបស់មនុស្សប្រុស ។

## 2.3. កំណកាម៉ែតញី

កំណកាម៉ែតញី មានរយៈពេលវែងណាស់ ។ វាចាប់ផ្តើមតាំងពីជីវិតជាអំប្រីយ៉ុង ។

ក្នុងអូវែទាំងពីររបស់អំប្រីយ៉ុង កោសិកាពូជធ្វើចំណែកតាមមីតូសយ៉ាងខ្លាំងក្លាបានប្រហែល 6.8 លានអូវ៉ូកូនី ។ អូវ៉ូកូនីមិនធ្វើចំណែកបន្តទៀតទេ ផ្ទុយទៅវិញអូវ៉ូកូនីមួយចំនួនធំ ត្រូវស្វិតបាត់ទៅវិញមុនកំណើតនិងបន្តរួញស្វិតទៀតក្នុងរយៈពេលពេញមួយជីវិតរបស់ស្ត្រី ។

បន្ទាប់ពីវគ្គដំណុះដំណាលនេះមក អូវ៉ូកូនីនីមួយៗរីកមាឌ ហើយក្លាយជាអូវ៉ូស៊ីតI ដែលចាប់ផ្តើមធ្វើចំណែកទីI នៃមេយ៉ូស ហើយត្រូវគាំងនៅចុងវគ្គប្រូផាសI ។

ក្រោយពេលគ្រប់ការ អូវ៉ូស៊ីតI ចាប់ផ្តើមបន្តចំណែកទីI នៃមេយ៉ូស ។ ចំណែកទីI របស់មេយ៉ូសត្រូវបានបញ្ចប់6ម៉ោងមុនដំណើរអូវុល ហើយឱ្យកំណើតបានជាកោសិកាអាប្លូអ៊ីតពីរ ដែលមានមាឌខុសគ្នាយ៉ាងខ្លាំង ។ កោសិកាធំជា អូវ៉ូស៊ីតII រីឯកោសិកាតូចជាគោលិកាប៉ូលទី1 ។ ចំណែកទី2នៃមេយ៉ូសចាប់ផ្តើមបន្តទៀតភ្លាម រួចក៏ឈប់គាំងនៅវគ្គមេតាផាសII ។

ចំណែកទី2នៃមេយ៉ូសត្រូវបានបញ្ចប់ លុះត្រាតែមានការបង្កកំណើត ។ ដូចនេះការជ្រៀតចូលនៃស្ពែម៉ាតូសូអ៊ីតទៅក្នុងស៊ីតូប្លាសរបស់អូវ៉ូស៊ីតII ដាស់ចំណែកទី2នៃមេយ៉ូសឱ្យបន្តដំណើរទៀតដើម្បីបញ្ចប់កំណអូវុល ។ ពេលនេះអូវ៉ូស៊ីតII ចែកខ្លួន រួចបញ្ចេញគោលិកាប៉ូលទី2 ។ អូវ៉ូស៊ីតII ក្លាយជាអូវ៉ូទីត បន្ទាប់មកជាអូវុល ។




*រូបទី 1.11 : កំណកាម៉ែតញី*

ប្រសិនបើ អូវ៉ូស៊ីត II មិនជួបនឹងស្ពែម៉ាតូសូអ៊ីតទេនោះ វានឹងត្រូវបញ្ចេញមកក្រៅ ក្រោមទម្រង់ជាអូវ៉ូស៊ីតII តាមឈាមរដូវ ។

# 3. ការបង្កកំណើតរបស់មនុស្ស

ការបង្កកំណើតប្រព្រឹត្តទៅនៅផ្នែកខាងចុងនៃដៃស្បូនក្បែរអូវែ ។ ការបង្កកំណើតរបស់មនុស្ស ឆ្លងកាត់ដំណាក់កាលដូចខាងក្រោម ។

## 3.1. ការឆ្លងកាត់ស្រោមរបស់អូវ៉ូស៊ីត II

ចំពោះថនិកសត្វ កាម៉េតញីរុំព័ទ្ធដោយស្រោមខាប់អន្ធិល គឺជាតំបន់ប៉េលុយស៊ីត ដែលជាឧបសគ្គដ៏ចម្បងសម្រាប់ស្ពែម៉ាតូសូអ៊ីតឆ្លងកាត់ ។ ស្ពែម៉ាតូសូអ៊ីត ធ្វើដំណើរតាមដៃស្បូន ហើយជួបផ្ទាល់ជាមួយកោសិកាផូលីគុលដែលរុំព័ទ្ធអូវ៉ូស៊ីតII ។ ការជួបនេះធ្វើឱ្យកោសិកាផូលីគុលលិបចូលក្នុងជាហេតុបណ្ដាលឱ្យស្ពែម៉ាតូសូអ៊ីតខិតចូលជិតអូវ៉ូស៊ីតII បាន ។ បន្ទាប់មកស្ពែម៉ាតូសូអ៊ីតចោះតំបន់ប៉េលុយស៊ីត ក្រោមអំពើពីរគឺ ការបញ្ចេញអង់ស៊ីមរបស់អាក្រូសូមនិងកម្លាំងរុញរបស់ផ្លាសែល ។

## 3.2. ការជ្រៀតចូលនៃស្ពែម៉ាតូសូអ៊ីតនិងប្រតិកម្មអូវ៉ូស៊ីត II

បន្ទាប់ពីជួបជាមួយអូវ៉ូស៊ីតII ភ្នាសស្ពែម៉ាតូសូអ៊ីតនិងភ្នាសអូវ៉ូស៊ីតIIរលាយចូលគ្នា។ ក្រោយមក ស្ពែម៉ាតូសូអ៊ីតជ្រៀតចូលទៅក្នុងស៊ីតូប្លាសរបស់អូវ៉ូស៊ីតII ។ ការជ្រៀតចូលនេះ ធ្វើឱ្យអូវ៉ូស៊ីតII មានប្រតិកម្មពីរគឺ

- ការរំដោះចេញនៃបន្ទុករបស់គ្រាប់ល្អិតៗទៅក្នុងលំហ ដែលស្ថិតនៅចន្លោះអូវ៉ូស៊ីតIIនិងតំបន់ប៉េលុយស៊ីត ។ សារធាតុរំដោះចេញនេះបង្កបានជាភ្នាសបង្កកំណើតមួយ ដែលរារាំងមិនឱ្យស្ពែម៉ាតូសូអ៊ីតផ្សេងទៀតជ្រៀតចូលបាន ។
- អូវ៉ូស៊ីតII បន្តធ្វើចំណែកទី 2 នៃមេយ៉ូស ។

## 3.3. ការរលាយចូលគ្នានៃណ្វៃយ៉ូ

បន្ទាប់ពីស្ពែម៉ាតូសូអ៊ីតជ្រៀតចូលទៅក្នុងអូវុល ណ្វៃយ៉ូរបស់វារីកធំ ហើយក្លាយជាប្រូនុយក្លេអូសឈ្មោល ។ ក្រោយពីបញ្ចេញគោលិកាប៉ូលទី 2 ណ្វៃយ៉ូរបស់អូវុលឡើងប៉ោង ហើយក្លាយជាប្រូនុយក្លេអូសញី ។ ប្រូនុយក្លេអូសញីនិងឈ្មោលទាំងពីររលាយចូលគ្នា ។ ការបង្កកំណើតត្រូវបញ្ចប់ ។ អូវុលក្លាយជាស៊ីកូត (ស៊ុតបង្កកំណើត) ។ ចំណែកទីមួយ របស់ស៊ីកូតចាប់ផ្ដើមភ្លាម ហើយបង្កើតបានជាកោសិកាដំបូងពីររបស់អំប្រីយ៉ុង ។




(1) នៅក្នុងដំណើរអូវុល អូវ៉ូស៊ីតត្រូវបានបញ្ចេញមកក្រៅជាមួយនិងស្រទាប់កោសិកាផូលីគុល ។ មេយ៉ូសត្រូវបានគាំងនៅវគ្គមេតាផាសចំណែកទី 2 នៃមេយ៉ូស ។

(2) ដោយប៉ះជាមួយស្ពែម៉ាតូសូអ៊ីត ១ងនៃកោសិកាផូលីគុលលិបចូលទៅក្នុង ។

(3) ក្រោយពីឆ្លងកាត់តំបន់ប៉េលុយស៊ីតនិងលំហក្រៅអូវ៉ូស៊ីត ស្ពែម៉ាតូសូអ៊ីតជ្រៀតចូលទៅក្នុងអូវ៉ូស៊ីត ។ គ្រាប់សំបកបញ្ចេញនូវសារធាតុបន្ទុក បង្កើតជាភ្នាសបង្កកំណើត ដែលរារាំងមិនឱ្យស្ពែម៉ាតូសូអ៊ីតផ្សេងទៀតចូលបាន ។

(4) ណ្វៃយ៉ូស្ពែម៉ាតូសូអ៊ីតនិងអូវុលឡើងប៉ោង ហើយក្លាយជាប្រូនុយក្លេអូសញីនិងឈ្មោល ។ ស៊ីតូប្លាសនៃអូវ៉ូស៊ីតក្លាយជាស៊ីតូប្លាសរបស់អូវុល ។

(5) ការលាយចូលគ្នារវាងប្រូនុយក្លេអូសញីនិងឈ្មោល បញ្ចប់នូវដំណើរការបង្កកំណើត ។

***រូបទី 1.12 : ការបង្កកំណើត***

## មេរៀនសង្ខេប

- ពងស្វាសជាក្រពេញភេទឈ្មោល ដែលផលិតស្ពែម៉ាតូសូអ៊ីតនិងបញ្ចេញអរម៉ូនតេស្តូស្តេរ៉ូន ។ អរម៉ូននេះបណ្តាលឱ្យមានលក្ខណៈភេទបន្ទាប់ ។
- អូវែជាក្រពេញភេទញី ដែលផលិតអូវុលនិងបញ្ចេញអរម៉ូនអឺស្ត្រូសែន ។ អរម៉ូននេះបណ្តាលឱ្យមានការលូតលាស់នូវលក្ខណៈភេទបន្ទាប់ ។
- វដ្តអូវែទាក់ទងនឹងការលូតលាស់របស់ផូលីគុលនិងការបញ្ចេញអូវុលសម្រាប់ការបង្កកំណើត ព្រមទាំងត្រៀមស្បូនដើម្បីទទួលស៊ុតបង្កកំណើត ។ វដ្តអូវែមានបីវគ្គ វគ្គផូលីគុល ដំណើរអូវុលនិងវគ្គលុយតេអ៊ីច ។ ប្រសិនបើអូវុលមិនបង្កកំណើតទេនោះ ភ្នាសសើមស្បូនត្រូវជាច់ចេញជាមួយឈាមមកក្រៅរាងកាយហៅថា **ឈាមរដូវ** ។ ប្រសិនបើអូវុលទទួលការបង្កកំណើត រដូវត្រូវផ្អាក ។
- មេយ៉ូស ជាចំណែកកោសិកាពីរដងបន្តបន្ទាប់គ្នា ដែលបង្កើតបានកោសិកាអាប្លូអ៊ីតបួន ។ចំពោះមនុស្សស្រី អូវ៉ូស៊ីតI ទទួលរងមេយ៉ូសដើម្បីបង្កើតបានកោសិកាអាប្លូអ៊ីត(អូវុល)មួយ ។ ចំពោះមនុស្សប្រុស ស្ពែម៉ាតូស៊ីតI ទទួលរងមេយ៉ូស ដើម្បីបង្កើតបានស្ពែម៉ាតូសូអ៊ីត4 ។
- ចំពោះមនុស្ស ការបង្កកំណើតមានបីដំណាក់កាល ៖ ការឆ្លងកាត់ស្រោមអូវុល ការជ្រៀតចូលនៃស្ពែម៉ាតូសូអ៊ីតនិងប្រតិកម្មអូវ៉ូស៊ីតព្រមទាំងការរលាយចូលគ្នានៃណ្វៃយ៉ូទាំងពីរ ។

## សំណួរនិងលំហាត់

1. តើប្រដាប់បន្តពូជមាននាទីអ្វីខ្លះ ?
2. តើអរម៉ូនភេទរបស់មនុស្សមានអ្វីខ្លះ ?
3. តើទឹកកាមបង្កឡើងពីអ្វីខ្លះ ?
4. តើវដ្តរដូវអាចប្រព្រឹត្តទៅបានដោយមានការចូលរួមពីវដ្តអ្វីខ្លះ ?
5. ដូចម្តេចហៅថាមេយ៉ូស ? តើចំណែកនីមួយៗរបស់មេយ៉ូសចែកចេញជាវគ្គអ្វីខ្លះ?
6. តើស្ពែម៉ាតូស៊ីតI ផលិតបានស្ពែម៉ាតូសូអ៊ីតប៉ុន្មាន ? តើអូវ៉ូស៊ីតIផលិតបានអូវុលប៉ុន្មាន?

មេរៀនទី

# 2 ការលូតលាស់របស់អំប្រឹយ៉ុង

**ចប់មេរៀននេះ សិស្សអាច**

- ប្រៀបធៀបការបង្កកំណើតក្នុងនិងការបង្កកំណើតក្រៅ ។
- ពណ៌នាពីចំណែកកោសិកានិងការលូតលាស់របស់អំប្រឹយ៉ុងក្នុងដំណាក់កាលហ្គាស្ត្រូឡាស្យុង ។
- រាប់ឈ្មោះស្រទាប់ខ្ទាំងបីនិងសរីរាង្គដែលកើតចេញពីស្រទាប់ទាំងនេះ ។
- ពន្យល់ពីការលូតលាស់របស់អំប្រឹយ៉ុងមនុស្សនិងភ្នាសក្រៅរបស់អំប្រឹយ៉ុង ។

ចំពោះសត្វភាគច្រើននិងរុក្ខជាតិថ្នាក់ទាបមួយចំនួន ការបន្តពូជដោយភេទមិនអាចប្រព្រឹត្តទៅបានដោយគ្មានទឹកទេ ។ កាម៉េតឈ្មោលត្រូវការទឹកជាចាំបាច់ ដើម្បីហែលទៅជួបកាម៉េតញី ។ មុននិងក្រោយពេលបង្កកំណើត កាម៉េតទាំងពីរត្រូវរក្សាសំណើមជានិច្ច ។ ផ្ទុយទៅវិញបើគ្មានសំណើមនោះវានឹងស្លាប់ភ្លាម ។ ចំពោះសត្វរស់នៅក្នុងទឹក គឺជាការងាយបំផុតដោយវាគ្រាន់តែបញ្ចេញកាម៉េតទៅក្នុងទឹក ដែលជាមជ្ឈដ្ឋានរស់នៅរបស់វា ។ បន្ទាប់មកការបង្កកំណើតប្រព្រឹត្តទៅនៅទីនោះ ។ ការបង្កកំណើតបែបនេះហៅថា **ការបង្កកំណើតក្រៅ** ផ្ទុយពីនេះគឺ**ការបង្កកំណើតក្នុង** ។ ការបង្កកំណើតក្នុងប្រព្រឹត្តទៅនៅក្នុងខ្លួនរបស់ភាវៈរស់ ។ ការបង្កកំណើតបែបនេះ មិនត្រូវការទឹករបស់មជ្ឈដ្ឋានរស់នៅដូចការបង្កកំណើតក្រៅឡើយ ។ លក្ខណៈខុសគ្នារវាងការបន្តពូជនៅក្នុងទឹកនិងលើគោករបស់រុក្ខជាតិនិងសត្វ ពាក់ព័ន្ធទៅនឹងកន្លែងជួបគ្នារបស់កាម៉េតញីនិងឈ្មោល ។

## 1. ការបង្កកំណើតក្រៅ

ក្នុងការបង្កកំណើតក្រៅ អូវុលនិងស្ពែម៉ាតូសូអ៊ីតជួបគ្នាក្រៅសារពាង្គកាយញី ។ ការបង្កកំណើតបែបនេះ កើតឡើងនៅលើសត្វដែលបង្កាត់គ្នាក្នុងទឹកតែប៉ុណ្ណោះ ។ ចំពោះសត្វបែបនេះ សរីរាង្គចាំបាច់ក្រៅពីក្រពេញភេទ គឺជាបំពង់នាំដែលនាំកាម៉េតចេញពីក្រពេញភេទឆ្ពោះទៅក្នុងទឹក ។ ការបង្កកំណើតប្រព្រឹត្តដោយផ្ទាល់នៅក្នុងទឹក បន្ទាប់ពីមេបាបញ្ចេញកាម៉េតរៀងៗខ្លួន ។ ស្ពែម៉ាតូសូអ៊ីតហែលក្នុងទឹកឆ្ពោះទៅរកអូវុល ។ ថ្វីបើសំណើមមិនបង្កបញ្ហាចំពោះការបង្កកំណើត ប៉ុន្តែឧបសគ្គយ៉ាងច្រើននឹងអាចកើតឡើងនៅក្នុងមជ្ឈដ្ឋានរស់នៅ ។ ជួនកាលស្ពែម៉ាតូសូអ៊ីតនិងអូវុលមិនអាចជួបគ្នាបាន ។ ជួនកាល

កាម៉ែតឬកូនញាស់ អាចជាចំណីរបស់សត្វផ្សេងៗទៀតឬវាអាចងាប់ដោយសារការផ្លាស់ប្តូរសីតុណ្ហភាព បរិមាណអុកស៊ីសែនរលាយក្នុងទឹកមិនគ្រប់គ្រាន់ និងបញ្ហាផ្សេងៗទៀត ។ ការបង្កកំណើតក្រៅអាចទទួលបានជោគជ័យលើឧបសគ្គទាំងអស់នោះបាន ក៏ដោយសារបរិមាណនៃការបញ្ចេញស្ពែម៉ាតូសូអ៊ីតនិងអូវុលមានចំនួនច្រើនអនេកដែរ ។ ការបង្កកំណើតក្រៅកើតមានឡើងចំពោះសត្វឥតឆ្អឹងកងក្នុងទឹកស្ទើរតែទាំងអស់ ថ្នាក់ត្រីមួយភាគធំ (លើកលែងតែឆ្លាម)និងថ្នាក់អំភីប ។

ដើម្បីរក្សាសុវត្ថិភាពនៃការជួបគ្នារវាងស្ពែម៉ាតូសូអ៊ីតនិងអូវុលឱ្យកាន់តែប្រសើរឡើង សារពាង្គកាយទាំងនេះមិនបញ្ចេញកាម៉ែតព្រាវៗទេ ។ ការបញ្ចេញកាម៉ែតបានប្រព្រឹត្តទៅដោយមានអរម៉ូនជាច្រើនត្រួតពិនិត្យបានយ៉ាងត្រឹមត្រូវដូចជា ការជ្រើសរើសទីកន្លែងដូចគ្នានិងពេលវេលាមួយជាក់លាក់ ។ ***ឧទាហរណ៍*** ត្រីសាឡឹម៉ុងនៅទ្វីបអឺរុប(ស្រដៀងត្រីព្រួល)បង្កាត់ពូជនៅរដូវភ្លៀង ។ បន្ទាប់ពីការជ្រើសរើសទីកន្លែងដែលមានក្រួសល្អិតៗតាមជ្រលងទឹកបានហើយ ត្រីញីប្រើកន្ទុយដើម្បីធ្វើសំបុក ។ ក្នុងសំបុកនោះ ត្រីញីពងរាប់រយពាន់អូវុលក្នុងពេលតែមួយ ។ ភ្លាមនោះត្រីឈ្មោលក៏បញ្ចេញស្ពែម៉ាតូសូអ៊ីតស្រោចលើអូវុល ។ ក្រួសល្អិតៗបានគ្របពីលើស៊ុតបង្កកំណើតដែលត្រូវមេបារបស់វាបោះបង់ចោល ។ ពីរទៅបីខែក្រោយមក ស៊ុតបង្កកំណើតទាំងនោះញាស់ ។ ក្នុងរយៈពេលនេះក្រៅពីការការពារ ក្រួសទាំងនេះជួយឱ្យទឹកទន្លេហូរវិចៗពីលើដោយផ្គត់ផ្គង់អុកស៊ីសែនដល់កូនញាស់ទាំងនោះទៀតផង ។



*រូបទី 2.1 ការបង្កកំណើតរបស់ត្រី*

នៅរដូវភ្លៀង កង្កែបញីមានអូវុលពេញពោះ ដើម្បីត្រៀមលក្ខណ បង្កកំណើត ។ តាមសំឡេងទាក់ទាញរបស់កង្កែបឈ្មោល កង្កែបញីធ្វើដំណើរទៅរកកង្កែបឈ្មោល ។ កង្កែបឈ្មោលរិតខ្លួនកង្កែបញីឱ្យបញ្ចេញអូវុលមកក្រៅ ទើបកង្កែបឈ្មោលបញ្ចេញទឹកកាមទៅបង្កកំណើត ។ ក្រោយពេលបង្កកំណើតហើយ កង្កែបញីឈ្មោលបោះបង់ចោលស៊ុតទាំងនោះ ដោយទុកវាឱ្យញាស់ដោយខ្លួនឯង ។ ស្រោមអន្ទិលប៉ោងឡើងសម្រាប់ការពារអំប្រីយ៉ុងពីការស៊ីរបស់សត្វផ្សេងៗ ។




*រូបទី 2.2 ការបង្កកំណើតរបស់កង្កែប*

## 2. ការបង្កកំណើតក្នុង

សត្វរស់នៅលើគោកមិនអាចធ្វើការបង្កកំណើតក្រៅបានទេ ។ ប្រសិនបើវាធ្វើការបង្កកំណើតក្រៅ កាម៉េតឈ្មោលនិងកាម៉េតញីរបស់វាស្ងួតហើយងាប់ភ្លាមនៅពេលដែលវាត្រូវបានបញ្ចេញមកខាងក្រៅ ។ ចំពោះសត្វរស់លើគោក កន្លែងសមស្របតែមួយគត់សម្រាប់ការបង្កកំណើត គឺមជ្ឈដ្ឋានក្នុងសារពាង្គកាយសត្វញី ។ ការបង្កកំណើតបែបនេះ ហៅថាការបង្កកំណើតក្នុង ។ សត្វទឹកខ្លះធ្វើការបង្កកំណើតក្នុង ដូចជាឆ្លាមនិងបង្កងសមុទ្រ ។ ការបង្កកំណើតក្នុងត្រូវការសរីរាង្គពិសេសមួយ ដើម្បីដឹកនាំស្ពែម៉ាតូសូអ៊ីតពីសារពាង្គកាយសត្វឈ្មោលចូលក្នុងសារពាង្គកាយសត្វញី ។ ក្រោយពីស្ពែម៉ាតូសូអ៊ីតចូលទៅក្នុងសារពាង្គកាយសត្វញីរួចហើយ វាធ្វើដំណើរទៅជួបអូវុលដើម្បីបង្កកំណើត ។ ជាលិកាសើមនៃសារពាង្គកាយសត្វញី ផ្តល់មជ្ឈដ្ឋានទឹកសមស្របតាមតម្រូវការសម្រាប់ស្ពែម៉ាតូសូអ៊ីតហែលទៅជួបអូវុល ។ ក្រោយពេលបង្កកំណើត ស៊ីកូតត្រូវបានព័ទ្ធជុំវិញដោយសំបកការពារ ហើយបញ្ចេញមកក្រៅសារពាង្គកាយសត្វញី ឬត្រូវរក្សានិងលូតលាស់ក្នុងកន្លែងពិសេសមួយរបស់សារពាង្គកាយសត្វញី ។

ការបង្កកំណើតក្នុងបំបាត់ចោលភាពរាយប៉ាយនៃកាម៉េតនិងបញ្ចៀសគ្រោះថ្នាក់ផ្សេងៗពីមជ្ឈដ្ឋានខាងក្រៅ ។ ចំពោះការបង្កកំណើតបែបនេះ អូវុលមានលទ្ធភាពជួបជាមួយស្ពែម៉ាតូសូអ៊ីតច្រើនបំផុត ។ ដូចនេះឱកាសនៃការបង្កកំណើតក្នុងមានច្រើនជាងការបង្កកំណើតក្រៅ ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះការបង្កកំណើតក្នុង សារពាង្គកាយសត្វឈ្មោលត្រូវបញ្ចេញស្ពែម៉ាតូសូអ៊ីតយ៉ាងច្រើន (រហូតរាប់លាន) ទៅក្នុងសារពាង្គកាយសត្វញី តែភាគច្រើននៃស្ពែម៉ាតូសូអ៊ីតទាំងនោះងាប់ ដោយសារវាមានសារធាតុចិញ្ចឹមតិចតួច ។ ដូចនេះក្នុងសារពាង្គកាយសត្វញី ស្ពែម៉ាតូសូអ៊ីតអាចបង្កកំណើតជាមួយអូវុលក្នុងពេលយ៉ាងខ្លី ។ ក៏ដូចគ្នាដែរ អូវុលអាចឱ្យស្ពែម៉ាតូសូអ៊ីតជ្រៀតចូលបានក្នុងពេលយ៉ាងខ្លី ។ ចំពោះមនុស្ស អូវុលអាចបង្កកំណើតក្នុងរយៈពេលប្រហែល 24 ម៉ោងប៉ុណ្ណោះក្រោយដំណើរអូវុល ។

ចំពោះសត្វដែលមានការបង្កកំណើតក្នុង ការបន្តពូជពាក់ព័ន្ធទៅនិងពេលវេលានៃការបញ្ចេញកាម៉េតញីនិងកាម៉េតឈ្មោល ។ ដោយសារកាម៉េតទាំងពីរមានអាយុខ្លីពេក ការពាក់គ្នាត្រូវធ្វើឡើងក្នុងពេលកំណត់មួយច្បាស់លាស់ ដើម្បីឱ្យមានការបង្កកំណើត ។ បន្សាំផ្សេងៗនៃការបន្តពូជ ត្រូវបានត្រួតពិនិត្យដោយអរម៉ូនជាច្រើន រួមមានសំឡេងច្រៀង ពណ៌ស្លាប ពណ៌ស្បែក និងការបញ្ចេញសារធាតុគីមី (ផេរ៉ូម៉ូន)ដែលមានក្លិនប្លែកៗ ។ បន្សាំទាំងនេះដាស់ឱ្យមានតំណបនៃការពាក់គ្នានិងការបញ្ចេញកាម៉េត (អូវុលនិងស្ពែម៉ាតូសូអ៊ីត) ។

ចំពោះសត្វល្អិតភាគច្រើន ពេលវេលាមិនចោទជាបញ្ហាចំពោះការបន្តពូជឡើយ ។ ក្រោយពេលខុតគ្នាស្ពែម៉ាតូសូអ៊ីតត្រូវបានស្តុកទុកក្នុងថង់ពិសេសមួយរបស់សារពាង្គកាយសត្វញី បន្តិចក្រោយ

មកវាត្រូវបានប្រើប្រាស់សម្រាប់បង្កកំណើតជាមួយអូវុល ។ ខាងក្រោមនេះជាការបង្កកំណើតក្នុងរបស់សត្វមួយចំនួន ។

## 2.1. សត្វល្អិត

កណ្តូបរស់នៅក្នុងតំបន់វាលខ្សាច់ ។ ក្រោយភ្លៀង នៅពេលដីខ្សាច់សើមនិងក្តៅឧណ្ហៗវាខ្ទុតគ្នា ។ សត្វឈ្មោលយំបញ្ចេញសំឡេង ហើយលោតសង្គ្រុបលើសត្វញី ។ លើខ្នងសត្វញី សត្វឈ្មោលចំកោងពោះយ៉ាងខ្លាំង ដើម្បីឱ្យផ្នែកខាងចុងពោះប៉ះគ្នា ។ ថង់ដែលផ្ទុកស្ពែម៉ាតូសូអ៊ីត ឆ្លងពីពោះសត្វឈ្មោលចូលទៅក្នុងពោះសត្វញី ។ បន្ទាប់មកថង់នោះក៏ផ្ទុះបែក ហើយសត្វញីប្រើប្រាស់ស្ពែម៉ាតូសូអ៊ីតទាំងនោះដើម្បីបង្កកំណើតជាមួយអូវុល ។ ក្រោយមកសត្វញីលាក់ស៊ុតបង្កកំណើតពី 50-100 ស៊ុត ក្នុងដីខ្សាច់សើម ។ ស៊ុតទាំងនោះត្រូវបានគ្របដណ្តប់ដោយសារធាតុពពុះ បន្តិចក្រោយមកពពុះនេះឡើងរឹងហើយបង្កើតបានជាស្រោមការពារមួយជុំវិញស៊ុតទាំងនោះ រហូតដល់ពេលវាញាស់ ។



រូបទី 2.3 ការបង្កកំណើតរបស់សត្វល្អិត

## 2.2. បក្សី

នៅរដូវបន្តពូជ បក្សីប្រភេទនីមួយៗបង្ហាញនូវឥរិយាបថពិសេសផ្ទាល់រៀងៗខ្លួនក្នុងការទាក់ទាញសត្វញី ។ ជាទូទៅបក្សីឈ្មោលចែកដែនដីគ្នាគ្រប់គ្រង ។ វាបញ្ចេញអាកប្បកិរិយាទាក់ទាញសត្វញីដូចជា ការបញ្ចេញសំឡេង ការបង្អួតរាង ឬស្លាបមានពណ៌ឆើតឆាយ ។ ក្រោយពីការទាក់ទាញបានជោគជ័យហើយវាក៏ធ្វើសំបុក ។ ពេលនោះបក្សីឈ្មោលជាន់បក្សីញី ដោយទំលើខ្នងសត្វញីជាមួយកម្លាំងសង្កត់យ៉ាងខ្លាំងទៅលើក្លូអាក់ ។ សត្វឈ្មោលបញ្ចេញធាតុរាវដែលមានផ្ទុកស្ពែម៉ាតូសូអ៊ីត ទៅក្នុងផ្លូវបន្តពូជរបស់សត្វញី ។ ស្ពែម៉ាតូសូអ៊ីត ធ្វើដំណើរតាមបណ្តោយបំពង់អូវុលរហូតបានជួបនិងអូវុល ហើយធ្វើការបង្កកំណើត ។ ក្រោយពេលបង្កកំណើត ខ្ញុត្រូវស្រោបដោយលឿងស៊ុត សស៊ុត និងសំបករឹងព័ទ្ធជុំវិញសម្រាប់ការពារ ។ បន្ទាប់មកបក្សីមេបញ្ចេញស៊ុតមកក្រៅ ។ វាភ្ញាស់ស៊ុតដោយក្រាបកម្តៅស៊ុតនោះរហូតដល់ញាស់ ។



រូបទី 2.4 ការបង្កកំណើតរបស់បក្សី

### ២.៣. ថនិកសត្វ

ថនិកសត្វឈ្មោល មានសរីរាង្គពិសេសមួយ សម្រាប់បញ្ជូនស្ពែម៉ាតូសូអ៊ីតទៅក្នុងខ្លួនសត្វញី ។ សរីរាង្គនេះហៅថាលិង្គ ។ នៅពេលពាក់គ្នាសត្វឈ្មោលបញ្ចេញទឹកកាមដែលជាធាតុរាវល្បាយសារធាតុចិញ្ចឹមនិងស្ពែម៉ាតូសូអ៊ីត ។ ក្នុងប្រដាប់បន្តពូជញី ស្ពែម៉ាតូសូអ៊ីតខ្លះបានទៅដល់ដៃស្បូន ដែលនៅទីនោះវាជួបនឹងអូវុល ហើយបង្កកំណើត ។ ស៊ុតបង្កកំណើត ឬស៊ីកូត ធ្វើចំណែកជាបន្តបន្ទាប់ ហើយក្លាយជាអំប្រីយ៉ុងដែលភ្ជាប់ខ្លួនវាទៅនឹងផ្ទៃស្បូន ។ នៅក្នុងស្បូន អំប្រីយ៉ុងត្រូវបានចិញ្ចឹមជីវិត និងលូតលាស់រហូតដល់ដំណាក់កាលមួយ ដែលកូនសត្វត្រៀមខ្លួនដើម្បីកើត ។




*រូបទី 2.5 : ការបង្កកំណើតរបស់ថនិកសត្វ*

## ៣. ការលូតលាស់របស់អំប្រីយ៉ុង

ចំពោះសត្វក៏ដូចជារុក្ខជាតិដែរ ការបង្កកំណើតរវាងស្ពែម៉ាតូសូអ៊ីតនិងអូវុល បង្កើតបានស៊ីកូត ដែលជាដំណាក់កាលដំបូងនៃការលូតលាស់ ។ ដំណើរការលូតលាស់នេះ កើតមានជាបន្តបន្ទាប់ដែល នៅទីបំផុតវាបង្កើតបានជាសារពាង្គកាយមួយពេញលេញ ។

ការលូតលាស់រួមមាន ចំណែកកោសិកា ការរីកធំធាត់ និងបំលែងឯកទេស ។ សារពាង្គកាយមួយរីកទំហំ(កើនមាឌ) យើងនិយាយថា វាមានការរីកធំធាត់ ។ នៅពេលនោះកោសិកាធ្វើចំណែកជាបន្តបន្ទាប់ដែលនាំឱ្យកើនចំនួន ។ បំលែងឯកទេស កើតមានឡើងនៅពេលកោសិកា មានឯកទេសកម្មផ្នែកទម្រង់និងនាទី ។ ***ឧទាហរណ៍*** កោសិកាសាច់ដុំមានទម្រង់និងនាទីខុសគ្នាយ៉ាងខ្លាំងពីកោសិកាប្រសាទ ។

### ៣.1. ចំណែកកោសិកា

ក្រោយពេលបង្កកំណើត ស៊ីកូត(ស៊ុតបង្កកំណើត) ចាប់ផ្តើមធ្វើចំណែកកោសិកាជាបន្តបន្ទាប់ ។ ដំបូង ស៊ីកូតចែកខ្លួនតាមមីតូស បង្កើតកោសិកាកូន2 ។ កោសិកាកូននីមួយៗ ចែកខ្លួនបន្តទៀតបាន កោសិកាកូនបួន ។ កោសិកាទាំងបួននេះ ចែកបន្តទៀតបានប្រាំបី ។ កោសិកាធ្វើចំណែកជាបន្តបន្ទាប់ ដូចបង្ហាញក្នុងរូបទី 2.6 ។




***រូបទី 2.6 : ចំណែកកោសិកា***

ក្នុងរយ ពេលកោសិកាធ្វើចំណែក វាមិនកើនមាឌទេ ផ្ទុយទៅវិញមាឌវាថយចុះតូចជាងមុន ។ តាមធម្មតា កោសិកាដំបូង (ស៊ីកូត) របស់ប្រភេទនីមួយៗមានទំហំធំជាងទំហំមធ្យមនៃកោសិការបស់សារពាង្គកាយពេញវ័យ ។ ក្រោយមកស៊ីកូត ធ្វើចំណែកច្រើនដង បានជាកោសិកាតូចៗជាច្រើន ។ កោសិកាធ្វើចំណែកបន្តទៀត រហូតដល់កោសិកាទាំងឡាយរបស់អំប្រីយ៉ុងកំពុងលូតលាស់នោះមានទំហំតូចជាងទំហំកោសិការបស់សារពាង្គកាយពេញវ័យ ។ បួនថ្ងៃក្រោយពីការបង្កកំណើត អំប្រីយ៉ុងមានរាងជាកូនបាល់រឹងមួយដែលមានកោសិកាយ៉ាងច្រើន ហៅថាម៉ូរុលឡា (morula) ។ កោសិកានៅតែធ្វើចំណែកបន្តទៀត ពួកវាត្រូវបានរៀបចំជាថ្មីដើម្បីបង្កើតបានជាស្វ៊ែរាងប្រហោងក្នុងមួយ ។ តាមធម្មតាស្វ៊ែនេះកើតឡើងពីកោសិកាក្រាស់តែមួយស្រទាប់ប៉ុណ្ណោះ ។ ផ្នែកខាងក្នុងរបស់ស្វ៊ែនោះពេញទៅដោយធាតុរាវ ។ ក្នុងដំណាក់កាលនេះ គេហៅអំប្រីយ៉ុងថាជាប្លាស្ទូឡា (blastula) ហើយធាតុរាវដែលបំពេញនៅផ្នែកខាងក្នុងស្វ៊ែនោះជាប្លាស្តូស៊ីល (blastocoel) ។




***រូបទី 2.7 : ប្រៀបធៀបដំណាក់កាល :***
***ក. ម៉ូរុលឡារបស់កង្កែបនិងមាន់ ។***
***ខ. ប្លាស្ទូឡារបស់កង្កែបនិងមាន់ ។***

ក្នុងដំណាក់កាលនេះ ការតម្រៀបរបស់កោសិកានៅក្នុងអំប្រីយ៉ុងកំពុងលូតលាស់អាស្រ័យទៅនឹងបរិមាណនិងរបាយជាតិលឿងនៅក្នុងស៊ីកូត ។ ចំពោះមនុស្ស ស៊ីកូតមានជាតិលឿងតិចតួចប៉ុណ្ណោះ ។ ក្នុងករណីបែបនេះ លទ្ធផលនៃចំណែកកោសិកាក្នុងប្លាស្ទូឡា គឺគ្រប់កោសិកាទាំងអស់មានទំហំប្រហាក់ប្រហែលគ្នា ។ ប៉ុន្តែស៊ីកូតដទៃទៀត ដូចជានៅក្នុងថ្នាក់អំភីប លូន បក្សីមានបរិមាណជាតិលឿងច្រើននៅក្នុងផ្នែកខាងចុងម្ខាងនៃកោសិកាស៊ីកូត ។ ជាតិលឿងនេះ បង្អង់ល្បឿនចំណែកកោសិកា ។ ដូចនេះចំណែកកោសិកាច្រើន

តែកើតមានឡើងនៅតែផ្នែកខាងប៉ូល ដែលគ្មានជាតិលឿង ។ ចំពោះស៊ុតរបស់កង្កែបបរិមាណយ៉ាងច្រើននៃជាតិលឿងនៅប៉ូលមួយបង្អង់ល្បឿនចំណែកកោសិកានៅប៉ូលនោះ ។ លទ្ធផលនៃការបង្អង់ល្បឿននៅក្នុងប្លាស្ទូឡា នាំឱ្យកោសិកាមានទំហំធំនៅប៉ូលមានជាតិលឿងច្រើន ។ ចំនួនកោសិកាល្អិតៗយ៉ាងច្រើនកកើតឡើងនៅតំបន់ប៉ូលគ្មានជាតិលឿង ។ ប្លាស្តូស៊ីលកកើតឡើងតែនៅក្នុងតំបន់ប៉ូលគ្មានជាតិលឿងប៉ុណ្ណោះ ។

នៅក្នុងស៊ុតរបស់សត្វមាន់ ល្មៀយ៉ូនិងស៊ុតប្លាសត្រូវបានប្រមូលផ្តុំនៅក្នុងបន្ទះខ្នដែលជាតំបន់មួយរាងសំប៉ែត នៅលើផ្ទៃផ្នែកខាងចុងនៃជាតិលឿង ។ មានតែកោសិកានៃបន្ទះខ្នតែប៉ុណ្ណោះដែលទទួលរងចំណែកកោសិកា ។ កោសិកាទាំងអស់នេះបែកចេញពីជាតិលឿង ដោយទុកលំហមួយរវាងជាតិលឿងនិងកោសិកា ។ លំហនោះហៅថាប្លាស្តូស៊ីល ។ អំប្រីយ៉ុងកំពុងលូតលាស់របស់សត្វមាន់ប្រើប្រាស់ជាតិលឿង សម្រាប់ជាអាហារ ។ នៅទីបញ្ចប់វាបំពេញលំហនោះយ៉ាងពេញនៅក្នុងអំប្រីយ៉ុងនោះ ។

## 3.2. ហ្គាស្ត្រូឡាស្យុង (gastrulation)

ប្លាស្ទូឡាលូតលាស់ដល់កម្រិតមួយ ដែលនៅពេលនោះកោសិកាទាំងអស់ចាប់ផ្តើមរីកមាឌមុននិងធ្វើចំណែក ។ នៅត្រង់កម្រិតនេះ កោសិកាធ្វើចំណែកតាមមីតូសជាបន្តបន្ទាប់ ប៉ុន្តែវាក៏មានការរីកមាឌផងដែរ ។

នៅពេលប្លាស្ទូឡាកើនចំនួនបានបីទៅបួនរយកោសិកា ដំណាក់កាលហ្គាស្ត្រូឡាស្យុងកកើតឡើង ។ កោសិកានៅចំហៀងម្ខាងរបស់ប្លាស្ទូឡាធ្វើចលនាឆ្ពោះទៅខាងក្នុង បង្កើតបានជាអំប្រីយ៉ុងដែលមានពីរស្រទាប់ហៅថា ហ្គាស្ត្រូឡា ។ រន្ធចំហមួយកើតមានឡើង ហៅថាប្លាស្តូព័រ ។ បន្តិចក្រោយមកវាក្លាយទៅជារន្ធចំហមួយរបស់ប្រដាប់រំលាយអាហារក្នុងសារពាង្គកាយពេញវ័យ ។



រូបទី 2.8 : ហ្គាស្ត្រូឡាស្យុង

ក្នុងដំណាក់កាលហ្គាស្ត្រូឡា កោសិកាស្រទាប់ក្រៅ ហៅថាអិចតូឌែម ។ កោសិកាស្រទាប់ខាងក្នុង ហៅថាអង់ដូឌែម ។ ប្រហោងនៅខាងក្នុងហ្គាស្ត្រូឡា គឺជា ពោះវៀនដំបូង ។ ក្រោយមកវាក្លាយជាប្រដាប់រំលាយអាហារ ។

នៅទីបញ្ចប់ផ្នែកខាងចុងនៃប្រហោងពោះវៀនដំបូងរបស់អំប្រីយ៉ុងកំពុងលូតលាស់

ត្រូវបានញែកទៅតាមទិសដៅផ្ទុយនិងប្លាស្តូព័រដែលបង្កើតបានជារន្ធចំហទីពីរនៃប្រដាប់រំលាយអាហារ ។ ក្រោយមកកោសិកាស្រទាប់ទីបី គឺមេសូឌែមត្រូវបានបង្កើតឡើងនៅចន្លោះកោសិកាស្រទាប់អិចតូឌែមនិងអង់ដូឌែម ។

ចំពោះកង្កែប កោសិកាដែលមានផ្ទុកជាតិលឿង នៅប៉ូលម្ខាងមិនឆ្លងកាត់ដំណាក់កាលហ្គាសស្ទ្រូឡាស្យុងទេ ។ ប្លាស្តូព័រកើតឡើងនៅជាប់និងកោសិកាមានជាតិលឿង ។ កោសិកាដែលចេញពីប៉ូលគ្មានជាតិលឿងធ្វើចលនាចុះក្រោមតាមប្លាស្តូព័រ ។



រូបទី 2.9 :

ក. ព្រៀបធៀបដំណាក់កាលហ្គាស ស្ទ្រូឡាដំបូងរបស់កង្កែបនិងមាន់

ខ. ព្រៀបធៀបដំណាក់កាលហ្គាស ស្ទ្រូឡាចុងក្រោយរបស់កង្កែបនិងមាន់

ចំពោះមាន់ កោសិការបស់ប្លាស្ទូឡាញែកជាស្រទាប់ក្រៅនិងស្រទាប់ក្នុង ។ ស្រទាប់ក្រៅក្លាយជាអិចតូឌែមនិងស្រទាប់ក្នុងក្លាយជាអង់ដូឌែម ។ លំហរវាងស្រទាប់ទាំងពីរនេះ គឺជាប្លាស្តូស៊ីល ។ កោសិកានៃស្រទាប់ខាងក្រៅរុញឆ្ពោះទៅក្នុងបង្កើតបានជាកោសិកាស្រទាប់ទីបី គឺមេសូឌែម ។

កោសិកានៃស្រទាប់ទាំងបីមាន អិចតូឌែម មេសូឌែម និងអង់ដូឌែម ហៅថា ស្រទាប់ខ្ទ ព្រោះវាបង្កើតជាលិកានិងសរីរាង្គទាំងអស់របស់សត្វពហុកោសិកា ។ តារាងខាងក្រោមបង្ហាញពីការលូតលាស់របស់សរីរាង្គនិងប្រព័ន្ធសរីរាង្គចេញពីស្រទាប់ខ្ទទាំងបី ។

| អិចតូឌែម | មេសូឌែម | អង់ដូឌែម |
|---|---|---|
| - ប្រព័ន្ធប្រសាទរួមបញ្ចូលទាំងខួរក្បាល ខួរឆ្អឹងខ្នង សរសៃប្រសាទ ។<br>- ភ្នាសខាងក្នុងមាត់ រន្ធច្រមុះ និងទ្វារធំ ។<br>- អេពីឌែមរបស់ស្បែក ក្រពេញញើស សក់ ក្រចក ។ | - ឆ្អឹងនិងសាច់ដុំ<br>- ឈាមនិងសរសៃឈាម<br>- ប្រដាប់បន្តពូជនិងប្រដាប់បញ្ចេញចោល ។<br>- ស្រទាប់ក្នុង (ឌែម) របស់ស្បែក ។ | - ភ្នាសខាងក្នុងរបស់បំពង់រំលាយអាហារ ។<br>- ភ្នាសខាងក្នុងបំពង់ខ្យល់ ទងសួត សួត ។<br>- ថ្លើម លំពែង<br>- ទីរ៉ូអ៊ីត ប៉ារ៉ាទីរ៉ូអ៊ីត ទីមុស ប្លោកនោម ។ |

### ៣.៣. ការរីកធំធាត់និងបំលែងឯកទេស

ដោយហ្គាស្ត្រូឡាលូតលាស់ កំណើនចំនួនកោសិកានៅតែបន្ត ។ កោសិការីកមាឌមុននិងធ្វើចំណែក ។ អំប្រ៊ីយ៉ុងក៏ចាប់ផ្តើមកើនមាឌដែរ ។ កោសិការបស់អំប្រ៊ីយ៉ុង ត្រូវបានតម្រៀបទៅជាទម្រង់ពិសេសមួយ ហើយកោសិកានីមួយៗមាននាទីពិសេសផ្ទាល់ ។ ថ្វីបើកោសិការបស់ហ្គាស្ត្រូឡាតម្រៀបជាស្រទាប់ខុសៗគ្នា ប៉ុន្តែមើលទៅហាក់ដូចជាវាមានរូបរាងដូចគ្នាណាស់ ។ ការប្រែប្រួលនៃកោសិកាគ្មានឯកទេសកម្មរបស់អំប្រ៊ីយ៉ុង ទៅជាកោសិកាមានឯកទេសកម្ម ជាលិកានិងសរីរាង្គដែលបង្កើតបានជាសារពាង្គកាយ ហៅថាបំលែងឯកទេស ។

សញ្ញាដំបូងនៃបំលែងឯកទេសកើតមាននៅលើផ្ទៃផ្នែកខាងលើរបស់ហ្គាស្ត្រូឡា ។ ចំពោះសត្វគរដេ ជាលិកាមេសូឌែមដែលស្ថិតនៅតាមបណ្តោយអ័ក្សកណ្តាលបង្កើតជាពួរប្រសាទ ។ ប្រព័ន្ធប្រសាទលូតលាស់ចេញពីជាលិកាអ៊ិចតូឌែមដែលស្ថិតនៅចំពីខាងលើពួរប្រសាទ ។ កោសិកានៃស្រទាប់អ៊ិចតូឌែមឡើងក្រាស់ ហើយបង្កើតបានជាបន្ទះប្រសាទ (neural plate) ដែលមានកំពកតែមពីរ ហៅថាកំពកប្រសាទ ។ កំពកប្រសាទទាំងពីរលូតវែង ភ្ជាប់គ្នាចំពីខាងលើនៃមជ្ឈមណ្ឌលបន្ទះប្រសាទបង្កើតបានជាបំពង់ប្រសាទ ។ ដំណាក់កាលចុងក្រោយនៃការលូតលាស់ បំពង់ប្រសាទបង្កើតបានជាខួរក្បាលនិងពួរឆ្អឹងខ្នង ។




*រូបទី 2.10 : កំណាចំពង់ប្រសាទ*

## ៤. ការលូតលាស់របស់មនុស្ស

ការលូតលាស់របស់មនុស្សចែកចេញជាពីរដំណាក់កាល គឺដំណាក់កាលលូតលាស់របស់អំប្រ៊ីយ៉ុង(ពីរខែដំបូង)និងដំណាក់កាលលូតលាស់របស់គភ៌ (ខែទី 3-9) ។ សរីរាង្គសំខាន់ៗត្រូវបានបង្កើតក្នុងដំណាក់កាលអំប្រ៊ីយ៉ុង ។ ឯដំណាក់កាលគភ៌ គឺធ្វើឱ្យកាន់តែប្រសើរឡើងនូវសរីរាង្គទាំងនោះ។ ចំពោះស៊ុតរបស់មនុស្សមានជាតិលឿងតិចតួច ហើយសារធាតុចិញ្ចឹមសម្រាប់អំប្រ៊ីយ៉ុងត្រូវបានផ្គត់ផ្គង់ដោយកូរ្យុង (chorion) ដែលបន្ទាប់មកក្លាយជាផ្នែកមួយរបស់សុក ។

## 4.1. ការលូតលាស់ដំបូង

នៅក្នុងដៃស្បូន ស៊ុតបង្កកំណើត ឬស៊ីកូតចាប់ផ្តើមធ្វើចំណែកតាមមីតូស ដូចបង្ហាញក្នុង រូបទី 2.11 ។




*រូបទី 2.11 : ការលូតលាស់ដំបូងរបស់អំប្រីយ៉ុងមនុស្សមុនការកាច់សំបុក*

ចំណែកកោសិកាមានជាបន្តបន្ទាប់ ដោយកោសិកានីមួយៗធ្វើចំណែក ហើយចំនួនកោសិកាកើនទ្វេ ។ បួនថ្ងៃក្រោយពេលបង្កកំណើត អំប្រីយ៉ុង ជាដុំបាលរឹងមួយដែលមានកោសិកាប្រហែល 64 ហៅថាម៉ូរុលឡា ។ ដំណាក់កាលដំបូងនៃការលូតលាស់ រួមមានការកាច់សំបុក ហ្គាសស្រ្តូឡាស្យុងនិងណឺរុលឡាស្យុង ។

### ក. ការកាច់សំបុក

ម៉ូរុលឡារីកធំធាត់ ប្រហោងមួយពេញទៅដោយធាតុរាវកើតឡើងនៅចំកណ្តាល ដែលប្លែងទៅជាទម្រង់ប្រហោងក្នុងមួយហៅថា ប្លាស្តូស៊ីស ។ កោសិការបស់ប្លាស្តូស៊ីស ដែលមានរូបរាងដូចៗគ្នា ចាប់ផ្តើមធ្វើឯកទេសកម្ម ។ នេះជាលទ្ធផលនៃការធ្វើឱ្យសកម្មឡើងរបស់សែន ។ ដំណើរឯកទេសកម្មនេះហៅថាបំលែងឯកទេស ។ បំលែងឯកទេសរ៉ាប់រងការលូតលាស់របស់ជាលិកាប្រភេទផ្សេងៗទាំងអស់នៅក្នុងរាងកាយ ។ ដុំកោសិកាខាងក្នុង ដែលកកើតឡើងបន្តិចម្តងៗពីកោសិកាមួយក្រុម នៅក្នុងតំបន់មួយនៃប្លាស្តូស៊ីស ក្លាយទៅជាអំប្រីយ៉ុង ។ ឯស្រទាប់កោសិកាដែលព័ទ្ធជុំវិញប្រហោងនេះ ហៅថាត្រូផូប្លាស (trophoblast) ។ ត្រូផូប្លាសនេះនឹងក្លាយទៅជាភ្នាស ដែលទ្រទ្រង់និងការពារអំប្រីយ៉ុង ។

ប្រហែលជាប្រាំមួយទៅប្រាំពីរថ្ងៃ ក្រោយពេលបង្កកំណើត ប្លាស្តូស៊ីសភ្ជាប់ខ្លួនទៅនឹងភ្នាសសើមស្បូន ដែលជាកន្លែងសម្បូរទៅដោយសរសៃឈាម ។ នៅពេលនោះស្រទាប់ត្រូផូប្លាសបញ្ចេញអង់ស៊ីម ដើម្បីបំផ្លាញកោសិការបស់ភ្នាសសើមស្បូន ដែលជួយឱ្យប្លាស្តូស៊ីសជ្រៀតចូលទៅក្នុងកម្រាស់នៃភ្នាសសើមស្បូន ។ នៅផ្នែកខាងលើរបស់ប្លាស្តូស៊ីស ជាលិកានៃភ្នាសសើមស្បូនភ្ជាប់គ្នាវិញ ។ លំនាំនេះ ហៅថាការកាច់សំបុក ។

## ១. ហ្កាសស្ត្រូឡាស្យុង

ដុំកោសិកាខាងក្នុងប្លាស្តូស៊ីស បំបែកខ្លួនជាពីរស្រទាប់ដែលបន្ទាប់មកបង្កើតបានជាស្រទាប់ទីបី ។ ស្រទាប់ទីបីនេះកើតឡើងតាមរយៈការផ្លាស់ទីកន្លែងរបស់កោសិកា ។ លទ្ធផលនៃហ្កាសស្ត្រូឡាស្យុងបង្កើតបានកោសិកាបីស្រទាប់ៈ អិចតូឌែម មេសូឌែម និងអង់ដូឌែម ។ ស្រទាប់ទាំងបីនេះក្លាយជាស្រទាប់ខ្ទដំបូង ពីព្រោះជាលិកានិងសរីរាង្គទាំងអស់របស់អំប្រ៊ីយ៉ុងនឹងត្រូវកកើតឡើងចេញពីស្រទាប់ទាំងបីនេះ ។ ស្រទាប់អិចតូឌែមនឹងលូតលាស់ទៅជាស្បែកនិងប្រព័ន្ធប្រសាទ ។ ស្រទាប់អង់ដូឌែមបង្កើតបានជាភ្នាសខាងក្នុងនៃប្រដាប់រំលាយអាហារនិងសរីរាង្គផ្សេងៗនៃប្រដាប់រំលាយអាហារ ។ ស្រទាប់កោសិកាមេសូឌែមប្លែងទៅជាសរីរាង្គនិងជាលិកា ផ្នែកខាងក្នុងរបស់សារពាង្គកាយ ។




*រូបទី 2.12 : ការកើតនៃស្រទាប់ខ្ទដំបូងនិងដំណាក់កាលចាប់ផ្តើមលូតលាស់របស់អំប្រ៊ីយ៉ុង*

### គ. ណឺរុលឡាស្យុង

ក្នុងដំណើរការលូតលាស់របស់មនុស្ស ដំណាក់កាលសំខាន់បន្ទាប់ពីហ្គាស្រ្តូឡាស្យុង គឺណឺរុលឡាស្យុង ដែលជាដំណាក់កាលលូតលាស់របស់ប្រព័ន្ធប្រសាទ ។ ផ្នែកមួយនៃជាលិកាមេសូដែមនៃអ័ក្សកណ្តាល ចាប់ផ្តើមធ្វើបំលែងឯកទេស ក្លាយទៅជាពួរប្រសាទ ។ មជ្ឈមណ្ឌលប្រសាទចាប់ផ្តើមលូតលាស់ចំពីខាងលើពួរប្រសាទ ។ ជាលិកានៃអិចតូដែមនៅក្បែរពួរប្រសាទឡើងក្រាស់ បង្កើតបានជាបន្ទះប្រសាទ ។ គែមទាំងពីរនៃបន្ទះប្រសាទងើបខ្ពស់ឡើង ហើយកកើតបានជាកំពកប្រសាទមួយគូ ។ កំពកទាំងពីរលូតវែងចូលគ្នាបន្តិចម្តងៗ ហើយភ្ជាប់គ្នាបង្កើតបានជាបំពង់ប្រសាទ ។ បន្ទាប់មកបំពង់ប្រសាទលូតលាស់ទៅជាពួរឆ្អឹងខ្នងនិងខួរក្បាល ។




*រូបទី 2.13 : ដំណាក់កាលបង្កើតប្រព័ន្ធប្រសាទរបស់អំប្រ៊ីយ៉ុង*

*ⓀអាយុЁ19 ថ្ងៃ*

### ឃ. ភ្នាសក្រៅរបស់អំប្រ៊ីយ៉ុង

ក្នុងរយៈពេលកាច់សំបុក ផ្នែកមួយរបស់ត្រូផូប្លាសលូតលាស់ទៅជាភ្នាសមួយដែលហៅថា ថង់ទឹកភ្លោះ ។ អំប្រ៊ីយ៉ុងត្រូវបានព័ទ្ធជុំវិញដោយថង់ទឹកភ្លោះ ។ ថង់នោះពេញទៅដោយធាតុរាវ គឺទឹកភ្លោះ ។ ធាតុរាវនេះការពារអំប្រ៊ីយ៉ុងទប់ទល់និងការប៉ះទង្គិចផ្សេងៗពីខាងក្រៅ ។

កូរ្យ៉ុង ជាភ្នាសមួយផ្សេងទៀត ដែលលូតលាស់ចេញពីត្រូផូប្លាសដែរ ។ ភ្នាសនេះស្ថិតនៅជាប់ពីខាងក្រៅថង់ទឹកភ្លោះ ។ កូរ្យ៉ុងមានភាគលយរាងដូចម្រាមដៃ ហៅថាជ្រាំងកូរ្យ៉ុង ដែលលាតសន្ធឹងទៅក្នុងភ្នាសសើមស្បូន ។ សារធាតុគីមីដែលបញ្ចេញដោយជ្រាំងកូរ្យ៉ុង បំផ្លាញជាលិកាភ្នាសសើមស្បូន (អង់ដូម៉ែត) ហើយបង្កើតបានជាកន្លែងមួយក្នុងស្បូនសម្រាប់អំប្រ៊ីយ៉ុងលូតលាស់ ។ សារធាតុគីមីនេះ ក៏បានបើកសរសៃរបួរនៅក្នុងភ្នាសសើមស្បូនផងដែរ ។ ឈាមចេញពីម្តាយ ជ្រាបចូលទៅក្នុងលំហជុំវិញជ្រាំងកូរ្យ៉ុង ។ ជ្រាំងកូរ្យ៉ុងនិងភ្នាសសើមស្បូនបង្កើតបានជាសរីរាង្គមួយសម្រាប់ទ្រទ្រង់ជីវិត ហៅថា សុក ។ ដូចនេះ មួយផ្នែកតូចនៃសុក (ភ្នាសសើមស្បូន)មានប្រភពមកពីម្តាយ ។ មួយផ្នែកធំនៃសុកមានប្រភពមកពីភ្នាសកូរ្យ៉ុង ។

ក្នុងជ្រាំងកូរ្យុង សរសៃឈាមបែកខ្នែងចេញពីអាកទែដែលភ្ជាប់អំប្រីយ៉ុងទៅនឹងសុកតាមទងសុក ។ សារធាតុផ្សេងៗសាយចេញទៅក្នុងសរសៃឈាមនៃជ្រាំងកូរ្យុង ។ វ៉ែនទងសុកដឹកនាំឈាម ត្រឡប់ទៅកាន់អំប្រីយ៉ុង ។ ប្រដាប់រលត់ឈាមរបស់អំប្រីយ៉ុងដាច់ចេញពីប្រដាប់រលត់ឈាមរបស់ម្ដាយ ។ ឈាមរបស់អំប្រីយ៉ុងស្ថិតនៅក្នុងសរសៃឈាមនៃជ្រាំងកូរ្យុង ដូចនេះពុំមានល្បាយរវាងចរន្តឈាមម្ដាយនិងចរន្តឈាមរបស់អំប្រីយ៉ុងទេ ។ ចំពោះអំប្រីយ៉ុង សុកមាននាទីច្រើនយ៉ាង ។ វាមាននាទីដូចសួត ដោយស្រូបយក $O_2$ ពីឈាមម្ដាយនិងបញ្ជូន $CO_2$ ទៅក្នុងឈាមម្ដាយវិញ ។ វាដើរតួដូចជាប្រដាប់រំលាយអាហារ ដោយនាំយកសារធាតុចិញ្ចឹមរលាយពីឈាមម្ដាយទៅឱ្យអំប្រីយ៉ុង ។ វាក៏មាននាទីដូចជាតម្រងនោមដែរ ដោយស្រូបយកកាកសំណល់អាសូតចេញពីឈាមអំប្រីយ៉ុង ។ បន្ទាប់មកប្រដាប់បញ្ចេញចោលរបស់ម្ដាយបំបាត់ចោលកាកសំណល់ទាំងនេះ ។




*រូបទី 2.14 : សុក*

## ង. សារៈសំខាន់នៃការលូតលាស់

ដំណាក់កាលដំបូងនៃការលូតលាស់នេះ មានសារ សំខាន់ណាស់ ព្រោះកត្តាខាងក្រៅមួយចំនួនអាចបង្អាក់ដល់ការលូតលាស់របស់អំប្រីយ៉ុង ។ សុកដើរតួជារបាំងការពារចំពោះសារធាតុចង្រៃមួយចំនួន ឬភ្នាក់ងារបង្កជំងឺ ។ ប៉ុន្តែភ្នាក់ងារបង្កជំងឺខ្លះដូចជាវីរុសអាចឆ្លងពីម្ដាយទៅអំប្រីយ៉ុងនិងបណ្ដាលឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ។ ***ឧទាហរណ៍*** វីរុសបង្កជំងឺកញ្ជ្រឹលឆ្លងទៅអំប្រីយ៉ុង ។ ជំងឺនេះអាចបណ្ដាលឱ្យថ្លង់ ខ្វាក់ភ្នែក ឬក៏អន់ប្រាជ្ញា ។ ថ្នាំមួយចំនួនដូចជា កាផេអ៊ីន អាល់កុលអាចឆ្លងកាត់របាំងសុកទៅដល់អំប្រីយ៉ុង ជួនកាលក៏បណ្ដាលឱ្យមានការលូតលាស់មិនប្រក្រតី ។ ស្ត្រីមានផ្ទៃពោះត្រូវតែចៀសវាងកុំប្រើប្រាស់ឱសថមិនចាំបាច់ក្នុងរយៈ ពេលនោះ ។ ការជក់បារីអាចបណ្ដាលឱ្យមានបញ្ហាក្នុងពេលមានគភ៌ ព្រោះផ្សែងបារីមានជាតិនីកូទីន ។ សារធាតុនេះធ្វើឱ្យសរសៃឈាមរបស់ស្បូនរួមតូចដែលបណ្ដាលឱ្យការផ្ដល់ឈាមរបស់សុកទៅឱ្យអំប្រីយ៉ុងថយចុះ ។ អំប្រីយ៉ុងទទួលបានអាហារតិចតួចដែលធ្វើឱ្យទារកកើតមកមានទម្ងន់ស្រាលនិងសុខភាពមិនប្រក្រតី ។

## 4.2. ការលូតលាស់របស់គភ៌

ចុងខែទី 2 នៃការលូតលាស់ អំប្រ៊ីយ៉ុងក្លាយទៅជាគភ៌ ដែលភាគច្រើនជាលិកានិងសរីរាង្គសំខាន់ៗត្រូវបានកកើតឡើង ។ រយៈពេលនេះ ទងសុកបានកើតឡើង ។ ក្នុងទងសុក មានសរសៃអាកទែពីរនិងសរសៃវ៉ែនមួយ ដែលភ្ជាប់គភ៌ទៅនឹងសុក ។ ប្រព័ន្ធសាច់ដុំរបស់គភ៌លូតលាស់យ៉ាងល្អ ។ គភ៌មានប្រវែងប្រហែល 8cm និងទម្ងន់ប្រហែល 28g ។

ខែទី 4 ទី 5 និងទី 6 ក្រោយពេលបង្កកំណើត ជាលិការបស់គភ៌ក្លាយជាមានលក្ខណៈស្មុគស្មាញនិងមានឯកទេសកម្ម ព្រមទាំងចាប់ផ្តើមបំពេញនាទីរៀងៗខ្លួន ។ បេះដូងរបស់គភ៌ប្រែជាខ្លាំងល្មមគ្រប់គ្រាន់អាចស្តាប់ឮដោយប្រដាប់ស្តាប់ចង្វាក់បេះដូង ( Stethoscope ) ។ ឆ្អឹងជំនួសដោយឆ្អឹងខ្ចីដែលបង្កើតបានជាគ្រោងឆ្អឹងដំបូង ។ ស្រទាប់រោមទន់ៗដុះលូតលាស់នៅលើស្បែករបស់គភ៌ ។ ដោយគភ៌កើនទំហំ ពោះម្តាយក៏ឡើងប៉ោងតម្រូវតាមនោះដែរ ។ ម្តាយចាប់ផ្តើមមានអារម្មណ៍ថាគភ៌កម្រើក ។ នៅចុងខែទី6 គភ៌មានប្រវែង 35cm និងទម្ងន់ប្រហែល 700g ។

ខែទី 7 ទី 8 និងទី 9 ប្រព័ន្ធសរីរាង្គលូតលាស់ពេញលេញ ។ គភ៌លូតលាស់ទំហំនិងទម្ងន់ ។ ទម្រង់របស់វាកើនទ្វេ ហើយសួតនិងសរីរាង្គផ្សេងៗទៀតទទួលរងការប្រែប្រួល ដែលត្រៀមខ្លួនសម្រាប់ការរស់នៅក្រៅស្បូន ។ រយៈពេលនេះ គភ៌អាចតម្រូវសីតុណ្ហភាពរាងកាយរបស់វា ។ លើសពីនេះ មជ្ឈមណ្ឌលប្រសាទនិងសួតលូតលាស់ពេញលេញ ។ គភ៌លូតលាស់បានពេញលេញក្នុងរយៈពេល 9 ខែជាមធ្យម ។ ទារកកើតមុនខែទី8 នៃការលូតលាស់ហៅថា **ទារកកើតមិនគ្រប់ខែ** ។ ទារកបែបនេះតែងមានបញ្ហាដង្ហើម ពីព្រោះសួតរបស់វាលូតលាស់មិនទាន់ពេញលេញ ។




*រូបទី 2.15 ការលូតលាស់នៃអំប្រ៊ីយ៉ុង*

## មេរៀនសង្ខេប

- ការបង្កកំណើតក្រៅកើតមានឡើងចំពោះសត្វភាគច្រើនដែលរស់នៅក្នុងទឹក ។ ស្ពែម៉ាតូសូអ៊ីត និងអូវុលត្រូវបានបញ្ចេញព្រមគ្នា ក្នុងទឹកន្លែងតែមួយនៅក្នុងទឹក ។
- ការបង្កកំណើតក្នុង កើតមានចំពោះសត្វដែលបន្តពូជនៅលើគោក ។ សរីរាង្គភេទដឹកនាំស្ពែម៉ាតូសូអ៊ីត ពីសារពាង្គកាយសត្វឈ្មោលចូលទៅក្នុងសារពាង្គកាយសត្វញី ។ ការបង្កកំណើតប្រព្រឹត្តទៅក្នុងសារពាង្គកាយសត្វញី ។
- ការលូតលាស់ជាលំនាំមួយយ៉ាងស្មុគស្មាញ ដែលកោសិកាមួយក្លាយជាសារពាង្គកាយពហុកោសិកាពេញវ័យមួយ ។ ការលូតលាស់របស់អំប្រីយ៉ុងសត្វទាំងអស់មានចំណែកកោសិកា ការរីកធំធាត់ និងបំលែងឯកទេសជានិច្ច ។
- លទ្ធផលនៃចំណែកកោសិកាបានជាប្លាស្ទូឡា ។ វាមានរាងជាស្វ៊ែប្រហោងក្នុង ដែលបង្កឡើងពីកោសិកាស្រទាប់មួយស្រទាប់ ។ ប្រហោងនោះពេញដោយធាតុរាវហៅថា ប្លាស្តូស៊ីល ។
- កោសិកាបីស្រទាប់របស់ហ្កាស្ត្រូឡាគឺ អិចតូឌែម មេសូឌែម និងអង់ដូឌែម ដែលបង្កើតបានជាស្រទាប់ខ្ន ។ ស្រទាប់ខ្នទាំងបី បង្កើតបានជាជាលិកានិងសរីរាង្គផ្សេងៗ ។ ស្រទាប់អិចតូឌែមបង្កើតបានជាប្រព័ន្ធប្រសាទ ភ្នាសខាងក្នុងមាត់ រន្ធច្រមុះ ទ្វារធំ ។ ស្រទាប់មេសូឌែមបង្កើតបានប្រដាប់បន្តពូជ ប្រដាប់បញ្ចេញចោល ឆ្អឹង សាច់ដុំ ឈាម និងសរសៃឈាម ។ ស្រទាប់អង់ដូឌែមបង្កើតបានជាភ្នាសខាងក្នុងនៃបំពង់រំលាយអាហារ ភ្នាសខាងក្នុងបំពង់ខ្យល់ ទងសួត សួត ថ្លើម លំពែង និងប្លោកនោម ។
- ដំណាក់កាលលូតលាស់ដំបូងរបស់អំប្រីយ៉ុងមនុស្សមានការកាច់សំបុក ហ្កាស្ត្រូឡាស្យុងនិងណឺរុលឡាស្យុង ។
- ក្រោយពេលអំប្រីយ៉ុងភ្ជាប់ខ្លួនទៅនឹងភ្នាសសើមស្បូន សុកត្រូវបានបង្កើតឡើង ។ បណ្តូរសារធាតុចិញ្ចឹម $O_2$ កាកសំណល់និង $CO_2$ រវាងម្តាយនិងអំប្រីយ៉ុងធ្វើឡើងតាមរយៈសុក ។

## សំណួរនិងលំហាត់

1. ដូចម្តេចហៅថាការបង្កកំណើតក្រៅ ? ការបង្កកំណើតក្នុង ? ចូរឱ្យឧទាហរណ៍បញ្ជាក់ ។
2. ដូចម្តេចហៅថាម៉ូរុលឡា ? តើវាកើតនៅពេលណា ?
3. ចូរពណ៌នាពីការលូតលាស់របស់ប្លាស្ទូឡា ។
4. តើស្រទាប់ខ្នទាំងបីនៅក្នុងហ្កាស្ត្រូឡាជាអ្វីខ្លះ ?

## ពិសោធន៍ ៖ ការលូតលាស់របស់បក្សី

បក្សីជាសត្វឆ្អឹងកងថេរកម្ដៅ ។ បក្សីបង្កកំណើតក្នុង ។ ក្រោយពេលបង្កកំណើតអំប្រ៊ីយ៉ុងរបស់វាត្រូវបានស្រោបដោយលឿងស៊ុត សស៊ុត និងសំបករឹងដែលព័ទ្ធជុំវិញសម្រាប់ការពារ ។ បន្ទាប់មកបក្សីមេបញ្ចេញស៊ុតមកក្រៅ ។ មេក្រាបកម្ដៅស៊ុតនោះរហូតដល់ញាស់ ។ ចំពោះមាន់ ឬទា រយៈពេលក្រាបមាន 21 ថ្ងៃ ។ ស៊ុតបក្សីមានប្រាំផ្នែក

- សំបកជាតិកំបោរ
- ភ្នាសស្ដើងមានពីរស្រទាប់ជាប់គ្នា ។ នៅផ្នែកចុងម្ខាងរាងធំនៃស៊ុត ស្រទាប់ទាំងពីរឃ្លាតពីគ្នា ហើយបង្កើតបានជាឃ្លុបខ្យល់
- អាល់ប៊ុយមីន ឬសស៊ុត
- លឿងស៊ុតផ្ទុកសារធាតុបម្រុង
- អំប្រ៊ីយ៉ុងឱ្យកំណើតជាកូនសត្វ ។




### 1. វត្ថុបំណង

- សង្កេតផ្នែកផ្សេងៗរបស់ស៊ុតមាន់
- តាមដានការលូតលាស់របស់អំប្រ៊ីយ៉ុងសត្វមាន់ ។

### 2. សម្ភារៈ

ស៊ុតមាន់មិនបង្កកំណើត ស៊ុតមាន់បង្កកំណើតមានអាយុ 1 ថ្ងៃ 2 ថ្ងៃ និង 4 ថ្ងៃ ប្រអប់ប៉េទ្រី កែវពង្រីកដៃ ។

### 3. ដំណើរការពិសោធ

ថ្ងៃទី 1

- យកស៊ុតមាន់មិនទាន់បង្កកំណើតមកបំបែកដោយប្រុងប្រយ័ត្នដោយកុំឱ្យបែកលឿងស៊ុត ។ ឆ្លុះយកលឿងស៊ុតដាក់ក្នុងប្រអប់ប៉េទ្រី ហើយពិនិត្យមើលវា ។ គូរទម្រង់ស៊ុតបក្សីនិងដាក់ឈ្មោះផ្នែកផ្សេងៗរបស់វា ។

- យកស៊ុតបង្កកំណើតបានមួយថ្ងៃមកបំបែកដោយប្រុងប្រយ័ត្ន ។ ឆ្កិះយកអំប្រ៊ីយ៉ុងដាក់ក្នុងប្រអប់ប៉េទ្រី ។ ពិនិត្យមើលអំប្រ៊ីយ៉ុងដោយយកចិត្តទុកដាក់ជាមួយកែវពង្រីកដោយដៃ ។ គូរទម្រង់របស់អំប្រ៊ីយ៉ុងដែលអាចមើលឃើញ ។

ថ្ងៃទី 2

- ពិនិត្យមើលអំប្រ៊ីយ៉ុងអាយុ 2 ថ្ងៃនិង 4 ថ្ងៃ ។ បំបែកស៊ុត ហើយពិនិត្យមើលការលូតលាស់របស់អំប្រ៊ីយ៉ុងជាមួយកែវពង្រីកដោយដៃ ។ គំនូរព្រាងពីទ្រង់ទ្រាយនិងកត់ត្រាការប្រែប្រួលមួយចំនួនដែលកើតមានចំពោះអំប្រ៊ីយ៉ុងក្នុងរយៈពេលសង្កេត ។

## ៤. វិភាគ

1. តើទំហំធំរបស់ស៊ុតលឿងមានសារៈសំខាន់ដូចម្ដេច ?
2. តើអំប្រ៊ីយ៉ុងអាយុប៉ុន្មានថ្ងៃ ដែលយើងអាចមើលឃើញបេះដូងច្បាស់ ?
3. ធ្វើតារាងកត់ត្រាការប្រែប្រួលដែលអ្នកសំគាល់ឃើញនៅដំណាក់កាលលូតលាស់របស់អំប្រ៊ីយ៉ុង ។

## ? សំណួរនិងលំហាត់ជំពូក 2

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ**

1. កោសិកាភេទញីផលិតនៅក្នុង

☐ក. ពងស្វាស ☐ខ. អូវែ ☐គ. ថង់ពងស្វាស ☐ឃ. បង្ហូរនោម ។

2. ស្ពែម៉ាតូស្ស៊ីតស្តុកទុកក្នុង

☐ក. បង្ហូរនោម ☐ខ. អេពីឌីឌីម ☐គ. តម្រងនោម ☐ឃ. ប្លោកនោម ។

3. អរម៉ូនដែលរាំប់រងការលូតលាស់លក្ខណៈភេទបន្ទាប់របស់មនុស្សប្រុសជា

☐ក. អឺស្ត្រូសែន ☐ខ. ស្ពែម៉ាតូស្ស៊ីត ☐គ. តេស្តូស្តេរ៉ូន ☐ឃ. ឈាមរដូវ ។

4. សរីរាង្គសម្រាប់ទ្រទ្រង់ជីវិតដែលបង្កើតចេញពីអំប្រ៊ីយ៉ុងផងនិងស្បូនផងជា

☐ក. សុក ☐ខ. អូវុល ☐គ. ទងសុក ☐ឃ. អំប្រ៊ីយ៉ុង ។

5. សរីរាង្គភេទលូតលាស់យ៉ាងរហ័សនៅពេល

☐ក. កុមារភាព ☐ខ. ជំទង់ ☐គ. គ្រប់ការ ☐ឃ. ពេញវ័យ ។

6. អូវុលធ្វើដំណើរពីអូវែទៅកាន់ស្បូនតាម

☐ក. ដៃស្បូន ☐ខ. បំពង់យ៉ង ☐គ. បង្ហូរនោម ☐ឃ. បំពង់នោម ។

7 សត្វដែលមានការបង្កកំណើតក្រៅជា

☐ក. ត្រី ☐ខ. មាន់ ☐គ. ជ្រូក ☐ឃ. ខ្លា ។

8 សត្វដែលមានការបង្កកំណើតក្នុងជា

☐ក. កង្កែប ☐ខ. ត្រី ☐គ. កញ្ជាញ់ចេក ☐ឃ. មេអំបៅ ។

9 ស៊ុតបង្កកំណើតនៅក្នុង

☐ក. ស្បូន ☐ខ. ដៃស្បូន ☐គ. អូវែ ☐ឃ. ភ្នាសសើមស្បូន ។

10 ក្រូស៊ុញអូវើកើតឡើងនៅ

☐ក. ចន្លោះវគ្គ ☐ខ. ប្រូផាស I ☐គ. ប្រូផាស II ☐ឃ. មេតាផាស I ។

11 សង់ត្រូមែធ្វើចំណែកនៅក្នុងវគ្គ

☐ក. មេតាផាស I ☐ខ. អាណាផាស I ☐គ. មេតាផាស II ☐ឃ. អាណាផាស II ។

12 ដំណាក់កាលទី១នៃការលូតលាស់របស់អំប្រីយ៉ុងជា

☐ក. ចំណែកកោសិកា ☐ខ. ម៉ូរុលឡា ☐គ. ប្លាស្ទូឡា ☐ឃ. ហ្គាសស្ទ្រូឡាស្យុង ។

13 អំប្រីយ៉ុងលូតលាស់ជាអង់ដូឌែម មេសូឌែម និងអិចតូឌែមនៅ

☐ក. ចំណែកកោសិកា ☐ខ. បង្កកំណើត ☐គ. ហ្គាសស្ទ្រូឡាស្យុង ☐ឃ. កំណាច់សំបុក ។

## II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1 ការបញ្ចេញអូវុលពីអូវែហៅថា ។

2 ការបង្កកំណើតប្រព្រឹត្តទៅនៅក្នុង ។

3 ពងស្វាសស្ថិតនៅក្នុងថង់មួយហៅថា ។

4. រយៈពេលមធ្យមនៃវដ្តរដូវមាន ។

5 ផ្នែកដែលភ្ជាប់អំប្រីយ៉ុងទៅនឹងសុកជា ។

6. ក្នុងផ្ទៃម្តាយទារកលូតលាស់នៅក្នុង ។

7 ទឹកកាមបង្កឡើងពី និង ។

## III. ចូរឆ្លើយសំណួរខាងក្រោមនេះ

1 ពណ៌នាពីនាទីរបស់ប្រដាប់បន្តពូជមនុស្សប្រុសនិងស្រី ។

2 តើមានអ្វីកើតឡើងក្នុងវគ្គនីមួយៗនៃវដ្តអូវែ ?

3 ដូចម្តេចហៅថាភាពគ្រប់ការ ?

4 ពណ៌នាពីលំនាំនៃការបង្កកំណើត ។

5. តើសុកមាននាទីដូចម្តេចខ្លះ ?

6. ពណ៌នាពីដំណាក់កាលទាំងបីនៃការលូតលាស់ដំបូងរបស់សារពាង្គកាយ ។

7. តើស្រទាប់ខ្ទាំងបីដែលជាលទ្ធផលនៃហ្គាសស្រ្ទូឡាស្យុងជាអ្វីខ្លះ ?

8. ពណ៌នាពីទម្រង់របស់ស្ពែម៉ាតូសូអ៊ិត ។

9. តើអ៊ីស្រ្តូសែនមាននាទីអ្វី ?

10. ចូរពណ៌នាសង្ខេបពីដំណើរប្រព្រឹត្តទៅនៃស៊ុតមិនបង្កកំណើតចាប់ពីផូលីគុលដើមរហូតដល់វាចាកចេញពីរាងកាយ ។

11. ចូរបកស្រាយពីដំណើរលូតលាស់របស់ស៊ីកូត ដោយចាប់ផ្តើមពីការបង្កកំណើតរហូតដល់ការកាច់សំបុក ។

12. ពន្យល់ពីសារៈសំខាន់នៃស្រទាប់ខ្ទដំបូង ។

13. សុកលូតលាស់ចេញពីជាលិកាដែលផលិតដោយអំប្រ៊ីយ៉ុងផង ស្បូនផង ។ តើទម្រង់របស់សុកបង្ការមិនឱ្យមានល្បាយរវាងឈាមម្តាយនិងឈាមអំប្រ៊ីយ៉ុងកំពុងលូតលាស់បានដោយរបៀបណា ?

14. ក្នុងករណីខ្លះ ស៊ីកូតមិនអាចធ្វើដំណើរចូលទៅក្នុងស្បូនបាន ។ ប៉ុន្តែវាអាចភ្ជាប់ខ្លួនទៅនឹងជញ្ជាំងនៃបំពង់ផាឡូប (ដៃស្បូន) ជំនួសវិញ ។ ហេតុអ្វីក៏លក្ខណៈបែបនេះជាស្ថានភាពគ្រោះថ្នាក់ខ្លាំងបំផុតចំពោះម្តាយ ។

15. ស្ពែម៉ាតូសូអ៊ិតត្រូវបានស្តុកទុកក្នុងអេពីឌីឌីម ដែលស្ថិតនៅក្នុងថង់ពងស្វាស ។ ហេតុអ្វីបានជាការស្តុកនេះមានអត្ថប្រយោជន៍ចំពោះស្ពែម៉ាតូសូអ៊ិត ?

16. ហេតុដូចម្តេចបានជាស្ត្រីដែលចងដៃស្បូនមិនអាចមានផ្ទៃពោះ ?

17. ស្ត្រីម្នាក់អាយុ48ឆ្នាំឈប់មានរដូវ ។ នាងជឿជាក់ថានឹងមានផ្ទៃពោះ ។ តើអាចមានមូលហេតុផ្សេងទៀតដែរឬទេ ?

18. នៅផ្នែកកណ្តាលនៃស្ពែម៉ាតូសូអ៊ិតមានមីតូកុងឌ្រី ។ តើមីតូកុងឌ្រីមានឥទ្ធិពលដូចម្តេចខ្លះទៅលើសកម្មភាពរបស់ស្ពែម៉ាតូសូអ៊ិត ? ចូរពន្យល់ ។

## ជំពូក 3

# តំណពូជ



ពីកណ្តុរប្រផេះមេបាមួយគូនេះ មានកូនប្រផេះនិងកូនរោមសខ្លះដែរ ។ ហេតុអ្វីបានជាដូច្នេះ ?

ចំពោះមនុស្សក៏ដូច្នេះដែរ យើងសង្កេតឃើញថាកូនខ្លះមានលក្ខណៈដូចឪពុក កូនខ្លះមានលក្ខណៈដូចម្តាយ តែខ្លះទៀតមានលក្ខណៈដូចជីដូនជីតាឬមាមីងណាមួយទៅវិញ ។ ជួនកាល មានលក្ខណៈពិសេសប្រចាំគ្រួសារនីមួយៗ ។ តំណពូជជាការបញ្ជូនលក្ខណៈពីមេបាទៅសន្តានក្រោយ ។ សញ្ញាណតំណពូជមានតាំងពីយូរលង់មកហើយ ។ ចាប់ពីសតវត្សទី 19 អ្នកស្រាវជ្រាវជាច្រើនបានតាមដាននិងពន្យល់អំពីការបញ្ជូនលក្ខណៈពីជំនាន់មួយទៅជំនាន់មួយ ។ ម៉ង់ដែល (Mendel) ជាអ្នករកឃើញច្បាប់តំណពូជដំបូងគេបង្អស់ ។

ហេតុអ្វីបានជាក្នុងករណីខ្លះកូនកាត់ដូចឪពុក ? ក្នុងករណីខ្លះទៀតកូនកាត់ដូចម្តាយ ? ឬដូចជីដូន ជីតា មាមីងណាមួយទៅវិញ ?

ការសិក្សាច្បាប់តំណពូជនឹងពន្យល់យើងពីបញ្ហាទាំងនេះ ។

# 1 ច្បាប់តំណពូជ

**ចប់មេរៀននេះ សិស្សអាច**

- បង្ហាញពីដំណាក់ផ្សេងៗនៃការពិសោធរបស់ម៉ង់ដែល ។
- ឱ្យពំនោលច្បាប់របស់ម៉ង់ដែល ។
- កំណត់និយមន័យលក្ខណៈលុប លក្ខណៈអន់ និងលក្ខណៈលុបមិនពេញលេញ ។
- ប្រើតារាងពុយនេសម្រាប់រកលទ្ធផលនៃការបង្កាត់ក្នុងករណីម៉ូណូអ៊ីប្រ៊ីឌិសនិងឌីអ៊ីប្រ៊ីឌិស ។
- រកសេណូទីបនៃឯកត្តៈមានលក្ខណៈលុបដោយអនុវត្តវិធីបង្កាត់តែស្ត ។

តំណពូជជាការបញ្ជូនលក្ខណៈរបស់មេបាទៅសន្តានក្រោយ ។ ផ្នែកមួយនៃជីវវិទ្យាដែលសិក្សាអំពីបាតុភូតតំណពូជហៅថាសេនេទិច ។ ម៉ង់ដែលបានរកឃើញច្បាប់ដែលជាមូលដ្ឋាននៃតំណពូជដំបូងគេបង្អស់ ។

## 1. ការងាររបស់ម៉ង់ដែល ( Mendel )

### 1.1. ប្រវត្តិរបស់ម៉ង់ដែល



ម៉ង់ដែល ( Mendel ) 1822-1884

ម៉ង់ដែលកើតនៅឆ្នាំ1822 នៅក្នុងភូមិមួយក្នុងប្រទេសឆេកូស្លូវ៉ាគី ។ ដោយឪពុកម្ដាយរបស់គាត់ជាកសិករ គាត់មានការយល់ដឹងច្រើនផ្នែកបច្ចេកទេសកសិកម្ម ។ បន្ទាប់ពីបានសិក្សាផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅទីក្រុងវីយែនមក ម៉ង់ដែលបានចូលបួសជាបព្វជិត ។ ម៉ង់ដែលបានធ្វើការបង្កាត់សណ្ដែកព័រនៅក្នុងសួនដែលមានបណ្ដោយ 37m និងទទឹង 7m ក្នុងទីវត្តរបស់គាត់ ។ ការពិសោធនេះមានរយៈពេល 7 ឆ្នាំ (1856-1863 ) ។ នៅឆ្នាំ1865 ម៉ង់ដែល បានបោះពុម្ពផ្សាយលទ្ធផលនៃការបង្កាត់ក្នុងសៀវភៅមួយមាន 44 ទំព័រ ។ ប៉ុន្តែនៅពេលនោះគ្មានអ្នកណាយកចិត្តទុកដាក់ចំពោះរបកគំហើញរបស់គាត់ឡើយ ។ ម៉ង់ដែលទទួលអនិច្ចកម្មនៅឆ្នាំ 1884 ។

ដល់ឆ្នាំ1900 ទើបរុក្ខវិទូ 3រូប ហ៊ុយកូដឺវ្រី (Hugo de Vries)ជនជាតិហូឡង់ កូរ៉ង់ (Correns) ជនជាតិអាល្លឺម៉ង់ និងឡេម៉ាក (Tschezmak) ជនជាតិអូទ្រីសសិក្សាស្រាវជ្រាវដោយឡែកពីគ្នាបានរកឃើញនិងទទួលស្គាល់សារៈសំខាន់នៃស្នាដៃរបស់ម៉ង់ដែល ។

## 1.2. លក្ខណៈពិសេសនៃសណ្ដែកព័រ



*រូបទី 1.1 ទម្រង់ផ្កាសណ្ដែកព័រ*

ក្នុងការពិសោធ ម៉ង់ដែលធ្វើការបង្កាត់សណ្ដែកព័រ ។ សណ្ដែកព័រជារុក្ខជាតិមានលក្ខណៈពិសេសបីយ៉ាង

- សណ្ដែកព័រជារុក្ខជាតិបន្តពូជដោយភេទ ។ កាម៉ែតញីនិងកាម៉ែតឈ្មោលនៅក្នុងផ្កាតែមួយ ។ ផ្ការបស់វាមានទម្រង់ពិសេស គឺមានស្រទាប់ស្លឹកព័ទ្ធជុំវិញកេសរញីនិងកេសរឈ្មោល ។ លក្ខណៈពិសេសនេះនាំឱ្យសណ្ដែកព័រមានតែស្វ័យបង្កកំណើត ។ ស្វ័យបង្កកំណើត គឺការបង្កកំណើតរវាងកាម៉ែតញីនិងកាម៉ែតឈ្មោលក្នុងផ្កាតែមួយ ។ ដូច្នេះហើយទើបគេងាយនិងបានសណ្ដែកព័រពូជសុទ្ធ ។
- លក្ខណៈនីមួយៗនៃសណ្ដែកព័រមានរូបរាងពីរផ្ទុយគ្នាងាយសំគាល់ ។ ***ឧទាហរណ៍*** លក្ខណៈគ្រាប់មានទិដ្ឋភាពពីរផ្ទុយគ្នា គឺគ្រាប់រលីងនិងគ្រាប់ជ្រួញ ។ លក្ខណៈកម្ពស់ដើមមានទិដ្ឋភាពពីរដែរ គឺដើមខ្ពស់និងដើមទាប ។
- សណ្ដែកព័រជារុក្ខជាតិតូច ងាយលូតលាស់ ឆាប់មានផ្លែផ្កា ហើយផលិតគ្រាប់បានចំនួនច្រើន ។

## 1.3. ដំណាក់ផ្សេងៗនៃការពិសោធរបស់ម៉ង់ដែល

ការងារពិសោធន៍របស់ម៉ង់ដែលមានបីដំណាក់ :

**ដំណាក់ទី 1** : ម៉ង់ដែលទុកឱ្យផ្កាសណ្ដែកធ្វើស្វ័យបង្កកំណើតពីរឬបីជំនាន់ដើម្បីឱ្យបានពូជសុទ្ធនៃលក្ខណៈនីមួយៗ ។

បើគេទុកឱ្យសណ្ដែកព័រពូជសុទ្ធធ្វើស្វ័យបង្កកំណើត នៅជំនាន់ក្រោយគេទទួលបានសណ្ដែកព័រមានលក្ខណៈតែម្យ៉ាងដូចគ្នាហើយដូចរុក្ខជាតិមេ ។ ***ឧទាហរណ៍*** ស្វ័យបង្កកំណើតរបស់សណ្ដែកពូជសុទ្ធផ្កាពណ៌ស្វាយ បង្កើតតែសណ្ដែកផ្កាពណ៌ស្វាយប៉ុណ្ណោះ ។



រូបទី 1.2 ការបង្កាត់សណ្តែកព័រផ្កាពណ៌ស្វាយជាមួយផ្កាពណ៌ស

**ដំណាក់ទី** 2 ៖ ម៉ង់ដែលធ្វើការបង្កាត់សណ្តែកព័រពូជសុទ្ធពីរដែលខុសគ្នាដោយលក្ខណៈតែម្យ៉ាង ។ ដំបូងគាត់កាត់ផង់លំអងពីរុក្ខជាតិផ្កាពណ៌ស្វាយចោល ។ បន្ទាប់មកគាត់យកកូនជក់ផ្ចិតយកគ្រាប់លំអងនៃសណ្តែកផ្កាពណ៌សទៅដាក់លើស្ទិចម៉ាតនៃសណ្តែកផ្កាពណ៌ស្វាយ ។ ការធ្វើដូច្នេះ ហៅថា**ការបង្កកំណើតនិម្មិត** ។ បន្ទាប់មក ម៉ង់ដែលយកគ្រាប់ដែលជាលទ្ធផលនៃការបង្កាត់នេះទៅដាំហើយពិនិត្យមើលលទ្ធផល ។ គាត់ទទួលបានសណ្តែកផ្កាពណ៌ស្វាយទាំងអស់ ។ រុក្ខជាតិដែលជាលទ្ធផលនៃការបង្កាត់ជាអ៊ីប្រ៊ីត ។ ម៉ង់ដែលឱ្យឈ្មោះថាជាអ៊ីប្រ៊ីតជំនាន់ទី 1 ( $F_1$ ) ។

**ដំណាក់ទី** 3 ៖ ម៉ង់ដែលយកគ្រាប់ជំនាន់ទី 1 ( $F_1$ ) ទៅដាំហើយទុកឱ្យផ្កាធ្វើស្វ័យបង្កកំណើត ។ លទ្ធផលដែលទទួលបានគឺ ជំនាន់ទី 2 ( $F_2$ ) ដែលមានផ្កាពណ៌ស្វាយផងនិងផ្កាពណ៌សផង ។

ម៉ង់ដែលតាមដានពិនិត្យមើលលក្ខណៈដែលលេចឡើងនៅគ្រប់ជំនាន់ ។ គាត់រាប់លក្ខណៈនីមួយៗរបស់រុក្ខជាតិយ៉ាងម៉ត់ចត់ ហើយធ្វើផលធៀបតាមគណិតវិទ្យា ។

ម៉ង់ដែលធ្វើការពិសោធរបៀបនេះជាមួយលក្ខណៈ 6 បែបផ្សេងទៀត




រូបទី 1.3 ៖ លក្ខណៈផ្សេងៗនៃសណ្តែកព័រ

បន្ទាប់ពីការសិក្សាពីការបញ្ជូនលក្ខណៈតែម្យ៉ាងមក ម៉ង់ដែលសិក្សាពីការបញ្ជូនលក្ខណៈពីរយ៉ាងទៀត ។

## 2. ហ្សែននិងអាឡែល

ក្រោយពីទទួលបានលទ្ធផលនៃការបង្កាត់ជាច្រើនលើកច្រើនសាមក ម៉ង់ដែលទាញសេចក្តីសន្និដ្ឋានជាច្បាប់តំណពូជ ។ គាត់សន្និដ្ឋានថាលក្ខណៈនីមួយៗកំណត់ដោយកត្តាតំណពូជ ។ ចំពោះលក្ខណៈមួយ ឯកត្តៈមួយមានកត្តាតំណពូជពីរនៅក្នុងកោសិកានីមួយៗនៃសារពាង្គកាយ ។ សព្វថ្ងៃនេះគេហៅកត្តាតំណពូជនេះថាជា **ហ្សែន** (Gène) ។

ប្រហែលនៅឆ្នាំ 1903 ស៊ុតុង (Sutton) បានបង្ហាញថាហ្សែនមានទីតាំងលើក្រូម៉ូសូម ។

រូបរាងផ្សេងៗនៃហ្សែនតែមួយហៅថា **អាឡែល** ។ ***ឧទាហរណ៍*** ចំពោះលក្ខណៈពណ៌ផ្កាសណ្តែកមានទិដ្ឋភាពពីរ គឺផ្កាពណ៌ស្វាយនិងផ្កាពណ៌ស ។ ដូច្នេះហ្សែនកំណត់លក្ខណៈពណ៌ផ្កាមានអាឡែលពីរ គឺអាឡែលកំណត់លក្ខណៈផ្កាពណ៌ស្វាយនិងអាឡែលកំណត់លក្ខណៈផ្កាពណ៌ស ។ ឯកត្តៈនីមួយៗមានអាឡែលចំនួនពីរ មួយបានមកពីមេ មួយទៀតបានមកពីបា ។ អាឡែលទាំងពីរនេះនៅលើចំណុចដូចគ្នានៃក្រូម៉ូសូមអូម៉ូឡូកមួយគូ ។




ចំពោះលក្ខណៈនីមួយៗមេឬបាមានអាឡែលពីរនៅដាច់ពីគ្នា ។

នៅពេលកំណកាម៉ែតតាមចំណែកមេយ៉ូសមានការផ្តាច់ចេញនៃអាឡែលទាំងពីរ ។

នៅពេលបង្កកំណើត កូនទទួលអាឡែលមួយពីមេនិងអាឡែលមួយទៀតពីបា ។

A ជាអាឡែលកំណត់លក្ខណៈផ្កាពណ៌ស្វាយ

a ជាអាឡែលកំណត់លក្ខណៈផ្កាពណ៌ស

## 3. ច្បាប់តំណពូជ

### 3.1. ម៉ូណូអ៊ីប្រ៊ីឌីស

ម៉ូណូអ៊ីប្រ៊ីឌីស ជាការបង្កាត់មេបាខុសគ្នាដោយលក្ខណៈតែម្យ៉ាង ។

#### ក. ការបង្កាត់កណ្តុរ

យើងសិក្សាអំពីការបញ្ជូនលក្ខណៈពណ៌រោមកណ្តុរ ។ ពណ៌រោមកណ្តុរមានទិដ្ឋភាពពីរគឺ រោមពណ៌ប្រផេះនិងរោមពណ៌ស ។ ក្នុងការបង្កាត់គេយកមេបាជាពូជសុទ្ធ ។ ដើម្បីឱ្យបានឯកត្តៈជា

ពូជសុទ្ធចំពោះលក្ខណៈមួយ (ដូចជាកណ្ដុររោមប្រផេះពូជសុទ្ធ) គេបង្កាត់កណ្ដុរប្រផេះជាមួយគ្នាវា លុះបានកូន គេជ្រើសរើសយកតែកណ្ដុរប្រផេះមកបង្កាត់ជាមួយគ្នាទៀត ។ គេធ្វើយ៉ាងនេះបន្តទៀត លុះត្រាតែនៅសន្ដានក្រោយបានកូនប្រផេះទាំងអស់ទើបអាចចាត់ទុកកណ្ដុររោមប្រផេះនេះថាជាពូជសុទ្ធបាន ។ គេបង្កាត់កណ្ដុររោមប្រផេះពូជសុទ្ធជាមួយកណ្ដុររោមសពូជសុទ្ធមួយគូជាច្រើនសាជាមួយគ្នា គេទទួលបានកណ្ដុរប្រផេះទាំងអស់ ។ កណ្ដុរប្រផេះដែលជាលទ្ធផលនៃការបង្កាត់នេះជាអ៊ីប្រ៊ីត គេហៅវាថាជាអ៊ីប្រ៊ីត $F_1$ ។




***រូបទី 1.4 វិភាគអំពីការបញ្ជូនលក្ខណៈពណ៌រោមកណ្ដុរ***

បន្ទាប់មកគេបង្កាត់កណ្ដុរអ៊ីប្រ៊ីត $F_1$ ជាមួយគ្នាវាគេទទួលបានកណ្ដុររោមសលាយឡំនឹងកណ្ដុររោមប្រផេះ ។ ការបង្កាត់កណ្ដុរប្រផេះអ៊ីប្រ៊ីត ជាច្រើនគូជាមួយគ្នារបស់លោកគុយអេណូ(Cuénot)បង្ហាញឱ្យឃើញថានៅជំនាន់ទី 2 មានកណ្ដុររោមប្រផេះ 3 ភាគនិងកណ្ដុររោមសមួយភាគ ។

| ចំនួនកណ្ដុរនៅ ( $F_2$ ) | | |
|---|---|---|
| សរុប | ប្រផេះ | ស |
| 270 | 190 | 72 |
| 120 | 93 | 27 |
| 100 % | ~ 75 % | ~ 25 % |

លទ្ធផលជាស្ថិតិនៅជំនាន់ទី 2 ក្នុងការបង្កាត់ពិសោធរបស់គុយអេណូ

$P_{(ពូជសុទ្ធ)}$ កណ្ដុររោមប្រផេះ × កណ្ដុររោមស

$F_1$ កណ្ដុររោមប្រផេះ 100%

$F_2$ កណ្ដុររោមប្រផេះ 3 ភាគ កណ្ដុររោមស 1 ភាគ

***សំគាល់*** : លទ្ធផលនេះមិនទាក់ទងនឹងភេទរបស់មេបាទេ ។

## ខ. ការបង្កាត់សណ្ដែកពីរ

ម៉ង់ដែលសិក្សាអំពីការបញ្ជូនលក្ខណៈ សភាពគ្រាប់សណ្ដែកពីរ ។ លក្ខណៈពណ៌គ្រាប់មានទិដ្ឋភាពពីរ គឺគ្រាប់លឿងនិងគ្រាប់បៃតង ។

ម៉ង់ដែលធ្វើការបង្កាត់សណ្ដែកគ្រាប់លឿងពូជសុទ្ធ ជាមួយសណ្ដែកគ្រាប់បៃតងពូជសុទ្ធ ។ នៅជំនាន់ទី 1 ( $F_1$ )គាត់ទទួលបានសណ្ដែកគ្រាប់លឿងទាំងអស់ ។ បន្ទាប់មកគាត់យកគ្រាប់លឿងអ៊ីប្រ៊ីត

ជំនាន់ទី ១ ( $F_1$ )ទៅដាំ ហើយទុកឱ្យធ្វើស្វ័យបង្កកំណើត ។ នៅជំនាន់ទី 2 គាត់សង្កេតឃើញមានគ្រាប់បៃតងមួយភាគលេចឡើងលាយឡំនឹងគ្រាប់លឿងបីភាគ ។

| | | |
|---|---|---|
| P(ពូជសុទ្ធ) | សណ្ដែកគ្រាប់លឿង | សណ្ដែកគ្រាប់បៃតង |
| $F_1$ | សណ្ដែកគ្រាប់លឿង 100% | |
| $F_2$ | គ្រាប់លឿង 3 ភាគ | គ្រាប់បៃតង 1 ភាគ |



រូបទី 1.5 វិភាគអំពីការបញ្ជូនលក្ខណៈពណ៌គ្រាប់នៃសណ្ដែកពីរ

ម៉ង់ដែលសិក្សាការបញ្ជូនលក្ខណៈផ្សេងទៀតនៃសណ្ដែកពីរ ហើយទទួលបានលទ្ធផលដូចតទៅ

| លក្ខណៈ | លទ្ធផលនៅជំនាន់ទី 2 ( $F_2$ ) | | ផលធៀប |
|---|---|---|---|
| ពណ៌ផ្កា | 705 ផ្កាពណ៌ស្វាយ | 224 ផ្កាពណ៌ស | 3.14 : 1 |
| ពណ៌គ្រាប់ | 6022 គ្រាប់ពណ៌លឿង | 2001 គ្រាប់បៃតង | 3.00 : 1 |
| សភាពគ្រាប់ | 5475 គ្រាប់រលីង | 1850 គ្រាប់ជ្រួញ | 2.95 : 1 |
| ពណ៌ផ្លែ | 428 ផ្លែបៃតង | 152 ផ្លែលឿង | 2.81 : 1 |
| សភាពផ្លែ | 882 ផ្លែពេញ | 299 ផ្លែជ្រួញ | 2.94 : 1 |
| ទីតាំងផ្កា | 651 ផ្កានៅចំហៀង | 107 ផ្កានៅខាងលើ | 3 14 : 1 |
| កម្ពស់ដើម | 787 ដើមទាប | 277 ដើមទាប | 2.84 : 1 |

## គ. សង្កេត

ក្នុងការបង្កាត់ខាងលើគេសង្កេតឃើញថា

- នៅជំនាន់ទី ១ ឯកត្តៈមានលក្ខណៈ ដូចគ្នាទាំងអស់ ។ ម៉ង់ដែលហៅលក្ខណៈ ដែលលេចឡើងនៅជំនាន់ទី ១( $F_1$ ) ថាជាលក្ខណៈលុប ។ ឯលក្ខណៈ ដែលមិនលេចឡើងនៅ $F_1$ ថាជាលក្ខណៈ**អន់** ។

  ដូចនេះលក្ខណៈ គ្រាប់លឿងនិងលក្ខណៈ រោមពណ៌ប្រផេះជាលក្ខណៈ លុប ។ លក្ខណៈ គ្រាប់បៃតងនិងលក្ខណៈ រោមពណ៌សជាលក្ខណៈ អន់ ។

- នៅ $F_2$ មានការលេចឡើងវិញនូវលក្ខណៈ អន់មួយភាគ លាយឡំនឹងលក្ខណៈ លុបបីភាគ ។

## ឃ. បំណកស្រាយលទ្ធផលម៉ូណូអ៊ីប្រ៊ីឌីស

**ហេតុអ្វីបានជាអ៊ីប្រ៊ីត ($F_1$) មានលក្ខណៈដូចគ្នាទាំងអស់ ?**

លក្ខណៈពណ៌គ្រាប់សណ្ដែកកំណត់ដោយសែន ។ ដោយលក្ខណៈសភាពគ្រាប់មានទិដ្ឋភាពពីរ គឺគ្រាប់លឿងនិងគ្រាប់បៃតង សែនកំណត់លក្ខណៈពណ៌គ្រាប់ក៏មានអាឡែលពីរដែរ គឺអាឡែលកំណត់លក្ខណៈគ្រាប់លឿងនិងអាឡែលកំណត់លក្ខណៈគ្រាប់បៃតង ។

តាង A ជាអាឡែលកំណត់លក្ខណៈគ្រាប់លឿង ។

a ជាអាឡែលកំណត់លក្ខណៈគ្រាប់បៃតង ។

- ក្នុងកោសិកាលូតលាស់ (កោសិកាឌីប្លូអ៊ីត) នៃសណ្ដែកគ្រាប់លឿងពូជសុទ្ធមានអាលែលកំណត់លក្ខណៈគ្រាប់លឿងចំនួនពីរ (AA) នៅលើក្រូម៉ូសូមអូម៉ូឡូកមួយគូ ។ កំណកាម៉ែតប្រព្រឹត្តទៅដោយមានចំណែកមេយ៉ូស ។ នៅចំណែកមេយ៉ូសមានការផ្ដាច់ចេញពីគ្នានៃគូក្រូម៉ូសូមអូម៉ូឡូកដែលនាំឱ្យមានការផ្ដាច់ចេញនៃគូអាឡែល (AA) ។ ដូច្នេះកាម៉ែតនៃសណ្ដែកគ្រាប់លឿងមានអាឡែល (A) តែមួយ ។
- ដូចសណ្ដែកគ្រាប់លឿងដែរ កោសិកាលូតលាស់របស់សណ្ដែកគ្រាប់បៃតងក៏មានអាឡែល a ចំនួនពីរដែរ ។ ឯកាម៉ែតសណ្ដែកគ្រាប់បៃតងមានអាឡែល a តែមួយទេ ។
- ការជួបគ្នារវាងកាម៉ែតញីនិងកាម៉ែតឈ្មោលនៅពេលបង្កកំណើតបណ្ដាលឱ្យមានការជួបគ្នារវាងក្រូម៉ូសូមមានដើមកំណើតពីមេនិងក្រូម៉ូសូមមានដើមកំណើតពីបា ។ ដូច្នេះក្នុងស៊ីកូតមានអាឡែលពីរគឺ (Aa) ។ តែអាឡែល A កំណត់លក្ខណៈគ្រាប់លឿងលុបលើអាឡែល a កំណត់លក្ខណៈគ្រាប់បៃតង ។ ដូចនេះអ៊ីប្រ៊ីតមានតែលក្ខណៈគ្រាប់លឿងទេដែលលេចចេញឡើង ។ អ៊ីប្រ៊ីត $F_1$ មានលក្ខណៈដូចគ្នាទាំងអស់ គឺគ្រាប់លឿងដូចបានបង្ហាញនៅក្នុងការពិសោធរបស់ម៉ង់ដែល ។




*បំណកស្រាយម៉ូណូអ៊ីប្រ៊ីតឌីសតាមក្រូម៉ូសូម*

***សំគាល់*** វាក្យស័ព្ទសេនេទិច :

- ផេណូទីប ជាបណ្ដុំលក្ខណៈនៃសារពាង្គកាយមួយដែលយើងឃើញ ។ ***ឧទាហរណ៍*** សក់រួញ ។
- សេណូទីប ជាសំណុំអាឡែលដែលកំណត់លក្ខណៈមួយរបស់សារពាង្គកាយ ។ សេណូទីបជាអ្នកកំណត់ផេណូទីប ។ កណ្ដុររោមពណ៌ប្រផេះមានសេណូទីបពីរយ៉ាង : AA ឬ Aa ។ កណ្ដុររោមពណ៌សមានសេណូទីប aa ។ រោមពណ៌ប្រផេះនិងរោមពណ៌សជាផេណូទីប ។

សណ្ដែកគ្រាប់លឿងពូជសុទ្ធមានអាឡែល 2 ដូចគ្នាគឺ AA ។ គេហៅឯកត្តៈនេះថាជា **អូម៉ូស៊ីកូត** ចំពោះលក្ខណៈគ្រាប់លឿង ។ វាបង្កើតកាម៉ែតតែមួយបែប គឺ A ។

សណ្ដែកគ្រាប់លឿងអ៊ីប្រ៊ីត $F_1$ មានអាឡែល 2 ខុសគ្នាគឺ Aa ។ គេថាឯកត្តៈនេះជា **អេតេរ៉ូស៊ីកូត** ចំពោះលក្ខណៈគ្រាប់លឿង ។ វាបង្កើតកាម៉ែត 2 បែបគឺ A និង a ។

**ហេតុអ្វីបានជានៅជំនាន់ទី 2 ( $F_2$ ) មានលក្ខណៈអន់លេចឡើងវិញ?**

សណ្ដែកគ្រាប់លឿងអ៊ីប្រ៊ីត $F_1$ មានសេណូទីប Aa ។ ក្នុងកំណកាម៉ែតតាមចំណែកមេយ៉ូសមានការផ្ដាច់ចេញនៃគូក្រូម៉ូសូមអូម៉ូឡូក ដែលនាំឱ្យមានការផ្ដាច់ចេញនៃគូអាឡែល Aa ។ ដូច្នេះកាម៉ែតនៃ $F_1$ មានអាឡែលតែមួយគឺ A ឬ a ។ អ៊ីប្រ៊ីត $F_1$ (ញីឬឈ្មោល) បង្កើតកាម៉ែតបានពីរបែប ដែលមានសមាមាត្រ 50% ស្មើគ្នា គឺមួយ បែបមាន A និងមួយបែបទៀតមាន a ។ នៅពេលបង្កកំណើតមានការជួបគ្នាដោយចៃដន្យរវាងកាម៉ែតឈ្មោលពីរបែបនិងកាម៉ែតញីពីរបែប ហើយអាចមានលទ្ធភាពបង្កើតបានជា




គេអាចបង្ហាញលទ្ធផលនៅ $F_2$ ដោយតួរតារាងពុយនេដូចខាងក្រោម

Aa × Aa

| កាម៉ែត ♀ \ ♂ | A | a |
|---|---|---|
| A | AA លឿង | Aa លឿង |
| a | Aa លឿង | aa បៃតង |

នៅ $F_2$ គេទទួលបាន
គ្រាប់លឿង 3 ភាគ
គ្រាប់បៃតង 1 ភាគ

ក្នុងករណីម៉ូណូអ៊ីប្រ៊ីឌីស ក្រោយពីការបង្កាត់ជាច្រើនលើកច្រើនសា ម៉ង់ដែលទាញសេចក្តីសន្និដ្ឋានជាច្បាប់ពីរគឺ

- **ច្បាប់ឯកសណ្ឋានភាពនៃអ៊ីប្រ៊ីតជំនាន់ទី ១** ៖ បើមេបាជាពូជសុទ្ធ អ៊ីប្រ៊ីតជំនាន់ទី ១ មានលក្ខណៈដូចគ្នាទាំងអស់ ។
- **ច្បាប់ការផ្តាច់ចេញនៃគូអាឡែល** ៖ ចំពោះសារពាង្គកាយមួយ លក្ខណៈនីមួយៗកំណត់ដោយអាឡែលពីរ ។ នៅពេលកំណកាម៉ែត អាឡែលទាំងពីរបែកចេញពីគ្នា កាម៉ែតមានអាឡែលតែមួយចំពោះលក្ខណៈនីមួយៗ ។ នៅពេលបង្កកំណើតសារពាង្គកាយថ្មីមានអាឡែលពីរ មួយបានពីមេ ហើយមួយទៀតបានមកពីបា ។

ដូចនេះនៅ $F_1$ គេបានទាំងលក្ខណៈលុបនិងលក្ខណៈអន់តាមសមាមាត្រ 3/1 ។

## ង. ករណីភាពលុបមិនពេញលេញ

គេបង្កាត់ផ្កាម៉ោងបួនពណ៌សពូជសុទ្ធជាមួយផ្កាម៉ោងបួនពណ៌ក្រហមពូជសុទ្ធ ។ នៅជំនាន់ទី ១ ($F_1$) គេទទួលបានផ្កាម៉ោងបួនពណ៌ផ្កាឈូកទាំងអស់ ។

បើគេបង្កាត់ផ្កាម៉ោងបួនពណ៌ផ្កាឈូកជាមួយគ្នាវា នៅជំនាន់ទី 2 ($F_2$) គេទទួលបានផ្កាពណ៌ស 25% ផ្កាពណ៌ផ្កាឈូក 50% និងផ្កាពណ៌ក្រហម 25% ។

$P_{(ពូជសុទ្ធ)}$ ផ្កាម៉ោងបួនពណ៌ក្រហម × ផ្កាម៉ោងបួនពណ៌ស

$F_1$ ផ្កាម៉ោងបួនពណ៌ផ្កាឈូក 100%

$F_2$ ផ្កាពណ៌ក្រហម 25% ផ្កាពណ៌ផ្កាឈូក 50% ផ្កាពណ៌ស 25%




***រូបទី 1.6 ៖ វិភាគអំពីការបញ្ជូនលក្ខណៈពណ៌ផ្កាម៉ោងបួន***

### ✍ បំណកស្រាយលទ្ធផល

**ក្នុងករណីផ្កាម៉ោងបួននេះ តើលក្ខណៈមួយណាជាលក្ខណៈលុប ? មួយណាជាលក្ខណៈអន់ ?**

តាមការពិសោធខាងលើយើងសង្កេតឃើញថា មេបាទាំងពីរជាពូជសុទ្ធ ហើយអ៊ីប្រ៊ីតមិនមានលក្ខណៈដូចទៅនឹងមេបាណាមួយទាំងស្រុងទេ ។ ដូច្នេះចំពោះលក្ខណៈមេបាទាំងពីរ លក្ខណៈផ្កាពណ៌ក្រហមនិងលក្ខណៈផ្កាពណ៌សមិនមានលក្ខណៈណាមួយអន់ឬលក្ខណៈណាមួយលុបទាំងស្រុងទេ ។ យើងសន្និដ្ឋានថា លក្ខណៈមេបាទាំងពីរមានសមត្ថភាពស្មើគ្នា គឺលក្ខណៈផ្កាក្រហមនិងផ្កាសជាលក្ខណៈ

លុបមិនពេញលេញ ។ អ៊ីប្រ៊ីតមានលក្ខណៈ កណ្ដាលរវាងមេបាទាំងពីរ ។ ដូច្នេះលក្ខណៈ ផ្កាពណ៌ផ្កាឈូកជាលក្ខណៈ កណ្ដាល (លក្ខណៈ ចន្លោះ) ។

តាង A ជាអាឡែលកំណត់លក្ខណៈ ផ្កាពណ៌ក្រហម

A′ ជាអាឡែលកំណត់លក្ខណៈ ផ្កាពណ៌ស

P(ពូជសុទ្ធ) ផ្កាម៉ោងបួនពណ៌ក្រហម × ផ្កាម៉ោងបួនពណ៌ស

សេណូទីប P AA A′A′

កាម៉ែត P A A′

សេណូទីប $F_1$ AA′

កាម៉ែតនៃ $F_1$ មានពីរបែបគឺ A និង A′

យើងរក $F_2$ ដោយតួរតារាងពុយនេ

$F_1$ × $F_1$

$F_2$ AA′ × AA′

| កាម៉ែត ♀ ♂ | A | A′ |
|---|---|---|
| A | AA 25% ផ្កាពណ៌ក្រហម | AA′ 25% ផ្កាពណ៌ផ្កាឈូក |
| A′ | AA′ ផ្កាពណ៌ផ្កាឈូក 25% | A′A′ ផ្កាពណ៌ស 25% |

នៅ $F_2$ មាន

ផ្កាពណ៌ក្រហម 25%

ផ្កាពណ៌ផ្កាឈូក 50%

ផ្កាពណ៌ស 25%

## ច. ការបង្កាត់តែស្ត

យើងអាចស្គាល់សេណូទីបនៃឯកត្តៈ មានលក្ខណៈ អន់ ពីព្រោះលក្ខណៈ អន់លេចឡើងតែក្នុងករណីអូម៉ូស៊ីកូតនៃអាឡែលអន់ aa ។ ***ឧទាហរណ៍*** ចំពោះកណ្ដុរ លក្ខណៈ រោមសជាលក្ខណៈ អន់ យើងអាចស្គាល់សេណូទីបកណ្ដុររោមសបានភ្លាម គឺ aa ។

តែចំពោះឯកត្តៈ មានលក្ខណៈ លុបវិញ យើងមិនស្គាល់សេណូទីបរបស់វាទេ ពីព្រោះវាអាចមានសេណូទីបពីរយ៉ាង ។ ***ឧទាហរណ៍*** សេណូទីបនៃកណ្ដុររោមប្រផេះអាចជា AA ឬ Aa ។

ដើម្បីឱ្យស្គាល់សេណូទីបនៃឯកត្តៈ មានលក្ខណៈ លុប គេត្រូវធ្វើការបង្កាត់តែស្តគឺយកឯកត្តៈ ដែលមានលក្ខណៈ លុបនេះទៅបង្កាត់ជាមួយឯកត្តៈ មានលក្ខណៈ អន់ ហើយរង់ចាំមើលលទ្ធផលនៃការបង្កាត់ ។ ឯកត្តៈ ដែលមានលក្ខណៈ អន់បង្កើតកាម៉ែតតែមួយប្រភេទមានអាឡែលអន់ a ដូច្នេះផេណូទីបរបស់សន្តានក្រោយ កំណត់ដោយកាម៉ែតរបស់ឯកត្តៈ ដែលមានលក្ខណៈ លុប ។

គេស្គាល់សេណូទីបរបស់ឯកត្តៈ មានលក្ខណៈ លុបដោយពិនិត្យមើលលទ្ធផលនៃការបង្កាត់តែស្ត

- បើបានឯកត្តៈមានលក្ខណៈលុបទាំងអស់ នោះសេណូទីបនៃឯកត្តៈមានលក្ខណៈលុបគឺ AA ។ វាជាពូជសុទ្ធ ។
- បើបានឯកត្តៈមានលក្ខណៈលុប 50% លក្ខណៈអន់ 50% នោះសេណូទីបនៃឯកត្តៈមានលក្ខណៈលុបគឺ Aa វាជាអ៊ីប្រ៊ីត(អេតេរ៉ូស៊ីកូត) ។

**ករណីទី 1**

សេណូទីបនៃឯកត្តៈមានលក្ខណៈលុបគឺ AA

| | | | |
|---|---|---|---|
| P | AA | × | aa |
| កាម៉ែត P | A | | a |
| $F_1$ | | Aa | |

ឯកត្តៈមានលក្ខណៈលុប 100%

**ករណីទី 2**

សេណូទីបនៃឯកត្តៈមានលក្ខណៈលុបគឺ Aa

| | | | | |
|---|---|---|---|---|
| P | Aa | | × | aa |
| កាម៉ែត P | A | a | | a |
| $F_1$ | Aa | | | aa |
| | ឯកត្តៈមានលក្ខណៈលុប 50% | | | ឯកត្តៈមានលក្ខណៈអន់ 50% |

## 3.2. ឌីអ៊ីប្រ៊ីឌីស

ឌីអ៊ីប្រ៊ីឌីសជាការបង្កាត់មេបាដែលខុសគ្នាដោយលក្ខណៈពីរយ៉ាង ។

ម៉ង់ដែលបានសិក្សាលើលក្ខណៈពីរយ៉ាងគឺ

- លក្ខណៈសភាពគ្រាប់ដែលមានទិដ្ឋភាពពីរ គឺគ្រាប់រលីងនិងគ្រាប់ជ្រួញ ។
- លក្ខណៈពណ៌គ្រាប់ដែលមានទិដ្ឋភាពពីរ គឺគ្រាប់ពណ៌លឿងនិងគ្រាប់ពណ៌បៃតង ។

ម៉ង់ដែលធ្វើការបង្កាត់សណ្តែកគ្រាប់រលីងពណ៌លឿងពូជសុទ្ធជាមួយសណ្តែកគ្រាប់ជ្រួញពណ៌បៃតងពូជសុទ្ធ ។ នៅជំនាន់ទី 1 ( $F_1$ )គាត់ទទួលបានសណ្តែកគ្រាប់រលីងពណ៌លឿងទាំងអស់ ។

បន្ទាប់មកគាត់យកសណ្តែកគ្រាប់រលីងពណ៌លឿង អ៊ីប្រ៊ីត $F_1$ ទៅដាំហើយទុកឱ្យធ្វើស្វ័យបង្កកំណើត ។ នៅជំនាន់ទី 2 ( $F_2$ ) គាត់ឃើញមានផេណូទីបបួនយ៉ាងដែលក្នុងនោះមានផេណូទីប




*រូបទី 1.7 : វិភាគអំពីការបញ្ជូនលក្ខណៈពណ៌និងសភាពគ្រាប់របស់សណ្តែកពីរ*

មេបាពីរនិងផេណូទីបថ្មីពីរ គឺគ្រាប់រលីងពណ៌ បៃតងនិងគ្រាប់ជ្រួញពណ៌លឿង ។

សណ្តែកនៅ ( $F_1$ ) 15 ដើមឱ្យផលជាគ្រាប់នៅ ( $F_2$ ) ចំនួន 556 គ្រាប់ ដែលក្នុងនោះមាន

- គ្រាប់រលីងពណ៌លឿង 315 គ្រាប់ គឺ $\frac{9}{16}$ នៃចំនួនគ្រាប់សរុប
- គ្រាប់រលីងពណ៌បៃតង 108 គ្រាប់ គឺ $\frac{3}{16}$ នៃចំនួនគ្រាប់សរុប
- គ្រាប់ជ្រួញពណ៌លឿង 103 គ្រាប់ គឺ $\frac{3}{16}$ នៃចំនួនគ្រាប់សរុប
- គ្រាប់ជ្រួញពណ៌បៃតង 32 គ្រាប់ គឺ $\frac{1}{16}$ នៃចំនួនគ្រាប់សរុប

✍ បំណកស្រាយលទ្ធផល

**តើហេតុអ្វីបានជានៅជំនាន់ទី 2 ( $F_2$ ) មានលេចឡើងផេណូទីបថ្មីផ្សេងពីមេបា ?**

ដោយមេបាជាពូជសុទ្ធ ឯកត្ត នៅជំនាន់ទី 1 ( $F_1$ ) មានលក្ខណៈ ដូចគ្នាទាំងអស់ គឺគ្រាប់រលីងពណ៌លឿង ដូច្នេះយើងសន្និដ្ឋានថា

ចំពោះលក្ខណៈ សភាពគ្រាប់ លក្ខណៈ គ្រាប់រលីងលុបលើគ្រាប់ជ្រួញ

ចំពោះ លក្ខណៈ ពណ៌គ្រាប់ លក្ខណៈ គ្រាប់ពណ៌លឿងលុបលើគ្រាប់ពណ៌បៃតង

តាង A ជាអាឡែលកំណត់លក្ខណៈ គ្រាប់រលីង

a អាឡែលកំណត់លក្ខណៈ គ្រាប់ជ្រួញ

B ជាអាឡែលកំណត់លក្ខណៈ គ្រាប់ពណ៌លឿង

b ជាអាឡែលកំណត់លក្ខណៈ គ្រាប់ពណ៌បៃតង

សេណូទីបសណ្តែកគ្រាប់រលីងពណ៌លឿងពូជសុទ្ធគឺ AABB វាបង្កើតកាម៉ែតមួយបែបដែលមានអាឡែល AB ។

សេណូទីបសណ្តែកគ្រាប់ជ្រួញពណ៌បៃតងពូជសុទ្ធគឺ aabb វាបង្កើតកាម៉ែតមួយបែបដែលមានអាឡែល ab ។

សេណូទីបនៃអ៊ីប្រ៊ីត $F_1$ គឺ AaBb ផេណូទីបរបស់វាគឺ គ្រាប់រលីងពណ៌លឿងទាំងអស់ ។

ក្នុងកំណកាម៉ែតនៃអ៊ីប្រ៊ីត $F_1$ មានការផ្តាច់ចេញពីគ្នានៃគូអាឡែល Aa និងការផ្តាច់ចេញពីគ្នានៃគូអាឡែល Bb ។ កាម៉ែតទទួលបានអាឡែលតែមួយក្នុងគូអាឡែលនីមួយៗ ។

ដើម្បីពន្យល់អំពីការលេចឡើងនូវផេណូទីបថ្មីពីរដែលជាគ្រាប់រលីងពណ៌បៃតងនិងគ្រាប់ជ្រួញពណ៌លឿង គេត្រូវទទួលស្គាល់ថា ការផ្តាច់ចេញពីគ្នានៃគូអាឡែល Aa ប្រព្រឹត្តទៅដោយឯករាជ្យមិនជាប់ទាក់ទងទៅនឹងការបែកចេញពីគ្នានៃគូអាឡែល Bb ទេ ។ ***ឧទាហរណ៍*** អាឡែល A បែកចេញពី a

តែ A អាចទៅជួបដោយចៃដន្យជាមួយ B ឬជាមួយ b ។ ចំណែកឯ a វិញក៏ដូច្នេះដែរ វាអាចទៅជួប B ក៏បានឬជាមួយ b ក៏បាន ។ ដោយសារការផ្ដាច់ចេញដោយឯករាជ្យនៃគូអាឡែលធ្វើឱ្យកាម៉ែតនៅ $F_1$ មានបួនបែបគឺ AB , Ab , aB , ab ។




$P_{(ពូជសុទ្ធ)}$ សណ្ដែកគ្រាប់រលីងលឿង × សណ្ដែកគ្រាប់ជ្រួញបៃតង

| | | | |
|---|---|---|---|
| សេណូទិប P | AABB | × | aabb |
| កាម៉ែត P | AB | | ab |
| សេណូទិប $F_1$ | | AaBb | |
| ផេណូទិប $F_1$ | | គ្រាប់រលីងពណ៌លឿង 100% | |
| កាម៉ែតនៃ $F_1$ | | AB, Ab, aB, ab | |

***បំណកស្រាយឌីអ៊ីប្រ៊ីឌីសតាមក្រូម៉ូសូម***

$F_2$ បានមកពីការជួបគ្នារវាងកាម៉ែតញីនៃ $F_1$ និងកាម៉ែតឈ្មោលនៃ $F_1$

$F_1$ × $F_1$

$F_2$ ♀ AaBb × AaBb ♂

| កាម៉ែត ♀ \ ♂ | AB | Ab | aB | ab |
|---|---|---|---|---|
| AB | AABB ○ | AABb ○ | AaBB ○ | AaBb ○ |
| Ab | AABb ○ | AAbb ● | AaBb ○ | Aabb ● |
| aB | AaBB ○ | AaBb ○ | aaBB ✿ | aaBb ✿ |
| ab | AaBb ○ | Aabb ● | aaBb ✿ | aabb ✿ |

| សេណូទីបនៅ $F_2$ | | | ផេណូទីបនៅ $F_2$ |
|---|---|---|---|
| 1 AABB<br>2 AABb<br>2 AaBB<br>4 AaBb | ⇒ | 9A – B – | គ្រាប់រលីងពណ៌លឿង $\frac{9}{16}$ |
| 1 AAbb<br>2 Aabb | ⇒ | 3A – bb | គ្រាប់រលីងពណ៌បៃតង $\frac{3}{16}$ |
| 1 aaBB<br>2 aaBb | ⇒ | 3aaB– | គ្រាប់ជ្រួញពណ៌លឿង $\frac{3}{16}$ |
| 1 aabb | ⇒ | 1aabb | គ្រាប់ជ្រួញពណ៌បៃតង $\frac{1}{16}$ |

***សំគាល់*** : ចំពោះគូអាឡែលនីមួយៗ គំនូស (– ) តាងឱ្យអាឡែលទី 2 លុបឬអន់ ។

ដូច្នេះយើងឃើញថានៅជំនាន់ទី 2 ($F_2$ ) មានលេចឡើងនូវផេណូទីបបួនយ៉ាង ក្នុងសមាមាត្រ 9.3.3.1 ដែលក្នុងនោះមានផេណូទីបបន្សំថ្មីពីរ គឺគ្រាប់រលីងពណ៌បៃតងនិងគ្រាប់ជ្រួញពណ៌លឿងដូចក្នុងការពិសោធរបស់ម៉ង់ដែល ។

ដូចនេះក្នុងករណីឌីអ៊ីប្រ៊ីឌីស ការផ្តាច់ចេញដោយឯករាជ្យនៃគូអាឡែលបណ្តាលឱ្យអ៊ីប្រ៊ីត $F_1$ បង្កើតកាម៉េតបួនបែប ។ នៅពេលបង្កកំណើត មានការជួបគ្នាដោយចៃដន្យនៃកាម៉េតញីឈ្មោលនៃ $F_1$ នាំឱ្យនៅ $F_2$ មានលេចឡើងផេណូទីបបួនបែប ។

**ច្បាប់ការផ្តាច់ចេញដោយឯករាជ្យនៃគូអាឡែល** : កាលណាគេបង្កាត់មេបាខុសគ្នាដោយលក្ខណច្រើនយ៉ាង នៅពេលកំណកាម៉េតគូអាឡែលកំណត់លក្ខណ មួយបែកចេញពីគ្នា ដោយមិនជាប់ទាក់ទងទៅនឹងការផ្តាច់ចេញពីគ្នានៃគូអាឡែលដែលកំណត់លក្ខណ ផ្សេងទៀតទេ ។ ដូច្នេះមានការបន្សំជាថ្មីនៃអាឡែលក្នុងកាម៉េត ។

***សំគាល់*** : ការផ្តាច់ចេញដោយឯករាជ្យនៃគូអាឡែលប្រព្រឹត្តទៅក្នុងករណីដែលសែនកំណត់លក្ខណ ផ្សេងៗស្ថិតនៅលើគូក្រូម៉ូសូមអូម៉ូឡូកខុសគ្នា ។

ដូច្នេះយើងឃើញថាក្នុងករណីមានលក្ខណ ខុសគ្នាច្រើនយ៉ាង គេអាចធ្វើការបង្កាត់ដើម្បីបង្កើតពូជថ្មីៗ ។ កសិករនិងអ្នកចិញ្ចឹមសត្វប្រើវិធីនេះដើម្បីបង្កើតពូជថ្មីដោយផ្សំសែនល្អៗមានក្នុងពូជផ្សេងៗគ្នា ។ ***ឧទាហរណ៍*** គេបង្កាត់ពូជស្រូវស្រាលឱ្យផលតិចនិងពូជស្រូវធ្ងន់ឱ្យផលច្រើន គេនឹងទទួលបានពូជស្រូវថ្មី គឺស្រូវស្រាលបានផលច្រើន ។

## ៣.៣. ការសិក្សាអំពីការបញ្ជូនលក្ខណៈលើសពីពីរ

| ចំនួនគូលក្ខណៈដែលសិក្សា (ឬគូអាឡែល) | ចំនួនប្រភេទកាម៉ែតដែលផលិតដោយអ៊ីប្រ៊ីត $F_1$ | ចំនួនបន្សំនៅ $F_2$ | ចំនួនសេណូទីបនៅ $F_2$ | ចំនួននិងសមាមាត្រផេណូទីបនៅ $F_2$ និងរបាយផេណូទីបនេះក្នុងករណីអាឡែលមួយលុបលើអាឡែលមួយទៀតក្នុងគូដែលគេពិនិត្យឃើញ |
|---|---|---|---|---|
| 1 ម៉ូណូអ៊ីប្រ៊ីឌីស | $2^1 = 2$ | $(2^1)^2 = 4$ | $3^1 = 3$ | $3 + 1$ |
| 2 ឌីអ៊ីប្រ៊ីឌីស | $2^2 = 4$ | $(2^2)^2 = 16$ | $3^2 = 9$ | $9 + 3 + 3 + 1 = (3 + 1)^2$ |
| 3 ទ្រីអ៊ីប្រ៊ីឌីស | $2^3 = 8$ | $(2^3)^2 = 64$ | $3^3 = 27$ | $27 + 9 + 9 + 9 + 3 + 3 + 3 + 1 = (3 + 1)^3$ |
| n ប៉ូលីអ៊ីប្រ៊ីឌីស | $2^n$ | $(2^n)^2$ | $3^n$ | $(3 + 1)^n$ |

យើងសង្កេតឃើញថា បើចំនួនលក្ខណៈ ខុសគ្នាកាន់តែច្រើន ការផ្តាច់ចេញដោយឯករាជ្យនៃគូអាឡែលធ្វើឱ្យកាម៉ែតកាន់តែមានចំនួនច្រើនបែប ហើយនៅសន្តានក្រោយលេចឡើងនូវផេណូទីបថ្មីៗកាន់តែច្រើនដែរ ។ ***ឧទាហរណ៍*** ដោយមនុស្សមានសែនរាប់សិបម៉ឺននៅលើក្រូម៉ូសូម 23 គូ កាម៉ែតមនុស្សមានច្រើនយ៉ាងណាស់ $(2)^{23}$ ។ ដូច្នេះនៅពេលបង្កកំណើត អាចលេចឡើងផេណូទីបបន្សំថ្មីច្រើនអនេក $(2^{23})^2$ ។ ដូចនេះហើយបានជាគេកម្រនឹងរកមនុស្សពីរនាក់ដែលមានសេណូទីបដូចគ្នាលើកលែងតែករណីកូនភ្លោះចេញពីស៊ីកូតតែមួយ ។

## ៣.៤. ពហុអាឡែល

យើងបានឃើញថាលក្ខណៈ មួយមានទិដ្ឋភាពពីរ ។ តែជួនកាលមានលក្ខណៈ ខ្លះមានទិដ្ឋភាពលើសពី 2 ។ ដូច្នេះសែនកំណត់លក្ខណៈ នេះមានអាឡែលលើសពី 2 ដែលស្ថិតនៅលើឡូគុស 1 នៃក្រូម៉ូសូម ។ សភាពដែលសែនមួយមានអាឡែលលើសពី 2 ហៅថា ពហុអាឡែល ។

***ឧទាហរណ៍ទី 1*** : លក្ខណៈ ពណ៌រោមរបស់ទន្សាយមានទិដ្ឋភាពបួន : រោមពណ៌ប្រាក់ រោមពណ៌សលាយខ្មៅនៅខាងចុង រោមពណ៌ប្រផេះខ្ចីនិងរោមពណ៌ស (ភៀក)



សេណូទីប C – ផេណូទីប ប្រភេទព្រៃពណ៌អាកូទី (ពណ៌ប្រាក់)



សេណូទីប $C^{ch}$ – ផេណូទីបស៊ីងស៊ីឡារោមពណ៌ប្រផេះខ្ចី



សេណូទីប $C^h$ – ផេណូទីបរោមពណ៌សលាយខ្មៅនៅផ្នែកខាងចុង)



សេណូទីប cc ផេណូទីបរោមពណ៌ស(ភៀក)

ដូច្នេះសែនកំណត់លក្ខណៈ ពណ៌រោមរបស់ទន្សាយមានអាឡែលបួន

តាង $C$ ជាអាឡែលកំណត់លក្ខណៈ រោមពណ៌ប្រាក់

$C^{ch}$ ជាអាឡែលកំណត់លក្ខណៈ រោមពណ៌ប្រផេះខ្ចី

$C^{h}$ ជាអាឡែលកំណត់លក្ខណៈ រោមពណ៌សលាយខ្មៅនៅផ្នែកខាងចុង

$c$ ជាអាឡែលកំណត់លក្ខណៈ រោមពណ៌ស (ភឿក)

អាឡែលទាំង 4 មានភាពលុបលើគ្នាជាបន្តបន្ទាប់ $C > C^{ch} > C^{h} > c$ ។

***ឧទាហរណ៍ទី2*** : ចំពោះមនុស្សសែនកំណត់លក្ខណៈ ក្រុមឈាមក្នុងប្រព័ន្ធ (ABO) មានអាឡែលបី

តាង $I^{A}$ ជាអាឡែលកំណត់លក្ខណៈ ឈាមក្រុម A
តាង $I^{B}$ ជាអាឡែលកំណត់លក្ខណៈ ឈាមក្រុម B
} លុបលើគ្នាមិនពេញលេញ

តាង $I^{O}$ ជាអាឡែលកំណត់លក្ខណៈ ឈាមក្រុម O (អន់)

| ក្រុមឈាម | សេណូទីប |
|---|---|
| A | $I^{A}I^{A}$ ឬ $I^{A}I^{O}$ |
| B | $I^{B}I^{B}$ ឬ $I^{B}I^{O}$ |
| AB | $I^{A}I^{B}$ |
| O | $I^{O}I^{O}$ |

## ៣.៥. ពហុសែន

ចំពោះសណ្តែកព័រ លក្ខណៈ កម្ពស់ដើមមានទិដ្ឋភាពពីរ គឺដើមខ្ពស់និងដើមទាប ។ លក្ខណៈ ពណ៌រោមកណ្តុរក៏មានទិដ្ឋភាពតែពីរដែរ គឺរោមសនិងរោមប្រផេះ ។ តែចំពោះមនុស្សវិញ លក្ខណៈ កម្ពស់និងលក្ខណៈ ពណ៌សម្បុរមានទិដ្ឋភាពច្រើនយ៉ាងណាស់ ក្នុងករណីនេះលក្ខណៈ មួយកំណត់ដោយសែនមួយក្រុមហៅថា ពហុសែន ។ សែនផ្សេងៗក្នុងក្រុមនេះមានឡូគុសខុសៗគ្នានៅលើក្រូម៉ូសូម ។

***ឧទាហរណ៍*** : សម្បុរស្បែកមនុស្សអាចមានច្រើនពណ៌នៅចន្លោះរវាងស្បែកសនិងស្បែកខ្មៅ ។ លក្ខណៈ ពណ៌ស្បែកកំណត់ដោយសែនពី 4 ដល់ 6 គូ ។ សែនទាំងនោះដឹកនាំការផលិតមេឡានីនខុសគ្នា ខ្លះសំយោគមេឡានីនតិច ខ្លះសំយោគមេឡានីនច្រើន ។ អំពើនៃសែនផ្សេងៗដែលកំណត់ពណ៌ស្បែកធ្វើការព្រមគ្នាដើម្បីបង្កើតផេណូទីបមួយ ។ ប្រសិនបើភាគច្រើននៃអាឡែលជាប្រភេទអាឡែលដែលផលិតមេឡានីនច្រើន ផលរបស់វាទាំងនោះនឹងបញ្ចូលគ្នា ដើម្បីបង្កើតបានស្បែកពណ៌ខ្មៅ ។ ប្រសិនបើភាគច្រើននៃអាឡែលជាប្រភេទអាឡែលដែលផលិតមេឡានីនតិចតួច ផលរបស់វាទាំងនោះបញ្ចូលគ្នាដើម្បីបង្កើតស្បែកស ។

## មេរៀនសង្ខេប

- តំណពូជជាការបញ្ជូនលក្ខណៈពីមេបាទៅសន្តានក្រោយ ។ ផ្នែកមួយនៃជីវវិទ្យាដែលសិក្សាអំពីតំណពូជហៅថា សេនេទិច ។
- ម៉ង់ដែលជាអ្នកវិទ្យាសាស្ត្រទី 1 ដែលបានរកឃើញច្បាប់មូលដ្ឋាននៃតំណពូជ ។
- ម៉ង់ដែលធ្វើការបង្កាត់សណ្ដែកព័រ ។ ការពិសោធរបស់គាត់មានបីដំណាក់
  ទី 1 គាត់ទុករុក្ខជាតិធ្វើស្វ័យបង្កកំណើត 3 ទៅ 4 ជំនាន់ដើម្បីឱ្យបានពូជសុទ្ធ
  ទី 2 គាត់ធ្វើការបង្កាត់រុក្ខជាតិមេបាពូជសុទ្ធ ដើម្បីឱ្យបានអ៊ីប្រ៊ីតជំនាន់ទី 1 ( $F_1$ )
  ទី 3 គាត់ទុកអ៊ីប្រ៊ីតជំនាន់ទី 1 ធ្វើស្វ័យបង្កកំណើត ។ ម៉ង់ដែលតាមដានពិនិត្យលទ្ធផលនៃការបង្កាត់ គាត់រាប់រុក្ខជាតិកូន ហើយធ្វើផលធៀបតាមគណិតវិទ្យា ។
- ម៉ង់ដែលសន្និដ្ឋានថា លក្ខណៈរបស់ភាវៈរស់កំណត់ដោយកត្តាតំណពូជដែលសព្វថ្ងៃគេហៅថា សែន ។ អាឡែលជារូបរាងផ្សេងៗនៃសែនមួយ ។
- ម៉ូណូអ៊ីប្រ៊ីឌីស ជាការបង្កាត់មេបាខុសគ្នាដោយលក្ខណៈតែម្យ៉ាង ។
- **ច្បាប់ឯកសណ្ឋានភាពនៃអ៊ីប្រ៊ីតជំនាន់ទី 1 ( $F_1$ )** : បើមេបាជាពូជសុទ្ធ អ៊ីប្រ៊ីតជំនាន់ទី 1 មានលក្ខណៈដូចគ្នាទាំងអស់ ។
- នៅជំនាន់ទី 2 ( $F_2$ )មានលក្ខណៈអន់លេចឡើងលាយឡំនឹងលក្ខណៈលុបក្នុងសមាមាត្រ 3:1 ។
- ក្នុងកោសិកានៃសារពាង្គកាយ លក្ខណៈមួយកំណត់ដោយអាឡែលពីរបែបដែលស្ថិតនៅលើក្រូម៉ូសូមអូម៉ូឡូកមួយគូ ។
- **ច្បាប់ការផ្ដាច់ចេញនៃគូអាឡែល** : នៅពេលកំណកាម៉ែត គូអាឡែលផ្ដាច់ចេញពីគ្នា កាម៉ែតទទួលបានអាឡែលតែមួយ ក្នុងចំណោមអាឡែល 1 គូ ។
- ការបង្កាត់តេស្តជាការបង្កាត់ឯកត្តៈមានលក្ខណៈអន់ជាមួយឯកត្តៈមានលក្ខណៈលុប ដើម្បីរកសេណូទីបនៃឯកត្តៈមានលក្ខណៈលុបនោះ ។

**ច្បាប់នៃការផ្ដាច់ចេញដោយឯករាជ្យនៃគូលក្ខណៈ**

- បើមេបាជាពូជសុទ្ធខុសគ្នាដោយលក្ខណៈពីរយ៉ាង នៅជំនាន់ទី 2 ( $F_2$ )មានផេណូទីបបួនយ៉ាងក្នុងសមាមាត្រ 9:3:3:1 ដែលក្នុងនោះមានផេណូទីបបន្សំថ្មីពីរខុសពីមេបា ។
- ពហុអាឡែលជាសភាពសែនមួយដែលមានអាឡែលលើសពី 2 ។
- ពហុសែនជាតំណពូជនៃលក្ខណៈមួយដែលកំណត់ដោយសែនមួយក្រុម ។

## ? សំណួរនិងលំហាត់

1 ចូរពន្យល់ថាហេតុអ្វីបានជាសណ្តែកព័រជាជម្រើសយ៉ាងល្អសម្រាប់ការពិសោធរបស់ម៉ង់ដែល ។

2 ចូរពន្យល់ពាក្យ ស្វ័យបង្កកំណើត បង្កកំណើតកាត់ សែន អាឡែល លក្ខណៈលុប លក្ខណៈអន់ អូម៉ូស៊ីកូត អេតេរ៉ូស៊ីកូត ។

3. ក្នុងករណីម៉ូណូអ៊ីប្រ៊ីឌីស តើអ៊ីប្រ៊ីត $F_1$ មានសេណូទីបដូចម្តេច ? តើវាបង្កើតកាម៉ែតប៉ុន្មានបែប ? ព្រោះអ្វី ?

4. ក្នុងករណីម៉ូណូអ៊ីប្រ៊ីឌីស នៅជំនាន់ទី2 តើម៉ង់ដែលទទួលលទ្ធផលដូចម្តេច ?

5. ក្នុងករណីឌីអ៊ីប្រ៊ីឌីស តើអ៊ីប្រ៊ីត $F_1$ មានសេណូទីបដូចម្តេច ? វាបង្កើតកាម៉ែតប៉ុន្មានបែប ? ពីព្រោះអ្វី ?

6. ឱ្យពំនោលច្បាប់របស់ម៉ង់ដែល ។

7. ចូរពន្យល់ពាក្យ ពហុអាឡែល ពហុសែន ។ ឱ្យឧទាហរណ៍បញ្ជាក់ ។

8. ក្នុងករណីឌីអ៊ីប្រ៊ីឌីស ហេតុអ្វីបានជានៅជំនាន់ទី2($F_2$) មានលេចឡើងផេណូទីបថ្មីខុសពីមេបា។

9. ចំពោះសណ្តែកព័រ លក្ខណៈ គ្រាប់ពណ៌លឿងលុបលើលក្ខណៈ គ្រាប់ពណ៌បៃតង ។ គេបង្កាត់សណ្តែកគ្រាប់លឿងអេតេរ៉ូស៊ីកូតជាមួយគ្នាវា តើគេទទួលបានលទ្ធផលដូចម្តេចខ្លះ ?

10. ចំពោះជ្រូកហ្គីណេ លក្ខណៈ ខ្លួនពណ៌ប្រផេះលុបលើលក្ខណៈ ខ្លួនខ្មៅ ។ គេបង្កាត់ជ្រូកហ្គីណេខ្លួនប្រផេះពីរគេទទួលបានកូនខ្លួនប្រផេះ ហើយកូនខ្លួនខ្មៅខ្លះ ។

ក. តើជ្រូកហ្គីណេប្រផេះមេបាមានសេណូទីបដូចម្តេច ?

ខ. ក្នុងការបង្កាត់នេះ បើសិនជាគេទទួលបានកូន 280 តើក្នុងចំនួននេះមានជ្រូកហ្គីណេខ្លួនប្រផេះប៉ុន្មាន ? ជ្រូកហ្គីណេខ្លួនខ្មៅប៉ុន្មាន ? ជ្រូកហ្គីណេខ្លួនប្រផេះអេតេរ៉ូស៊ីកូតប៉ុន្មាន ? ជ្រូកហ្គីណេខ្លួនប្រផេះអូម៉ូស៊ីកូតប៉ុន្មាន ?

គ. តើគេត្រូវធ្វើការបង្កាត់បែបណា ដើម្បីឱ្យដឹងថាជ្រូកហ្គីណេខ្លួនប្រផេះមួយជាអេតេរ៉ូស៊ីកូត ឬអូម៉ូស៊ីកូត ?

11 ចំពោះមនុស្ស លក្ខណៈ រោមភ្នែកវែងលុបលើលក្ខណៈ រោមភ្នែកខ្លី ។ បុរសម្នាក់ជាអេតេរ៉ូស៊ីកូតចំពោះលក្ខណៈ រោមភ្នែកវែង ភរិយារបស់គេមានរោមភ្នែកខ្លី ។

តើគូស្វាមីនេះមានលទ្ធភាពនឹងបានកូនមានរោមភ្នែកវែងប៉ុន្មានភាគរយ ? កូនមានរោមភ្នែកខ្លីប៉ុន្មានភាគរយ ?

មេរៀនទី

# 2 ក្រូម៉ូសូម

**ចប់មេរៀននេះ សិស្សអាច**

- ❑ ឱ្យនិយមន័យ ការីយ៉ូទីប ចំនួនឌីប្លូអ៊ីត ចំនួនអាប្លូអ៊ីត និងក្រូម៉ូសូមអូម៉ូឡូក ។
- ❑ បង្ហាញពីធាតុបង្កនិងទម្រង់នៃក្រូម៉ូសូម នៅចន្លោះវគ្គនិងនៅវគ្គផ្សេងៗនៃចំណែកកោសិកា ។
- ❑ បកស្រាយពីការបញ្ជូនលក្ខណៈកំណត់ដោយសែនមាននៅលើក្រូម៉ូសូម X ។
- ❑ ពណ៌នានិងពន្យល់ពីការបញ្ជូនជំងឺតពូជមួយចំនួន ។
- ❑ ពន្យល់ពីបុព្វហេតុនិងផលវិបាកនៃមុយតាស្យុង ។

យើងបានសិក្សាហើយថា សែនដែលមាននាទីកំណត់លក្ខណៈភាវៈរស់ ស្ថិតនៅលើក្រូម៉ូសូម ។ ដូច្នេះក្រូម៉ូសូមមាននាទីយ៉ាងសំខាន់ក្នុងការបញ្ជូនលក្ខណៈរបស់ភាវៈរស់ ។ យើងដឹងហើយថា ក្រូម៉ូសូមលេចរូបរាងច្បាស់តែនៅពេលកោសិកាកំពុងធ្វើចំណែក ជាពិសេសនៅវគ្គមេតាផាស ។ តើបណ្តាលមកពីអ្វី ? តើមនុស្សយើងមានក្រូម៉ូសូមប៉ុន្មាន ? ហើយមានរូបរាងដូចម្តេចខ្លះ ?

## 1. ក្រូម៉ូសូមមនុស្ស

### 1.1. បច្ចេកទេសសិក្សាក្រូម៉ូសូម

គោលិកាសរបស់មនុស្សជាកោសិកាដែលងាយស្រួលក្នុងការពិនិត្យមើលក្រូម៉ូសូម ។ មុនដំបូងគេបូមយកឈាម ហើយបំបែកយកគោលិកាសចេញពីធាតុបង្កផ្សេងៗទៀតនៃឈាម ។ គេអាចធ្វើឱ្យកោសិកាទាំងនោះធ្វើចំណែកគ្រាន់តែបន្ថែមសារធាតុដាស់ម្យ៉ាងទៅក្នុងមជ្ឈដ្ឋានដែលគេចិញ្ចឹមវា ។ បន្ទាប់មក គេប្រើកុលស៊ីស៊ីន (សារធាតុគីមីបំផ្លាញមិនឱ្យមានកំណត្រយ៉ូងអាក្រូម៉ាទិច) ដើម្បីបង្អាក់ចំណែកកោសិកានៅវគ្គមេតាផាស ។ ក្រោយពីការដាក់ពណ៌ គេពិនិត្យក្នុងមីក្រូទស្សន៍ ហើយថតយកបន្ទះអេក្វាទ័រដែលមានក្រូម៉ូសូមស្ថិតនៅជុំគ្នា ។ គេកាត់យករូបក្រូម៉ូសូមមកប្រៀបធៀប ហើយតម្រៀបទៅតាមរូបរាងនិងទំហំពីធំទៅតូច ។




រូបទី 2.1 ៖ ការរៀបចំធ្វើការីយ៉ូទីប

## 1.2. ការសិក្សាការីយ៉ូទីបមនុស្ស



រូបទី 2.2 ៖ ការីយ៉ូទីបមនុស្សស្រី



រូបទី 2.3 ៖ ការីយ៉ូទីបមនុស្សប្រុស

សំណុំក្រូម៉ូសូមដែលតម្រៀបពីធំទៅតូចមាននៅក្នុងកោសិកាមួយរបស់មនុស្សជា ការីយ៉ូទីបនៃមនុស្ស ។

បើពិនិត្យមើលការីយ៉ូទីបបុរសនិងស្ត្រី យើងសង្កេតឃើញថា

- បុរសនិងស្ត្រីមានចំនួនក្រូម៉ូសូម 46 ដូចគ្នា ។
- ក្រូម៉ូសូមមានរាងដូចគ្នាពីរៗ (រូបរាង ប្រវែង និងទីតាំងសង់ត្រូមែ) ។ ក្រូម៉ូសូមដូចគ្នាទាំងពីរនេះជា ក្រូម៉ូសូមអូម៉ូឡូក ។

បើយើងប្រៀបធៀបការីយ៉ូទីបបុរសនិងស្រ្តី យើងសង្កេតឃើញថា

- បុរសនិងស្រ្តីមានក្រូម៉ូសូម 22 គូដូចគ្នា ។ ក្រូម៉ូសូមទាំង 22 គូនេះជា **អូតូសូម ឬក្រូម៉ូសូមធម្មតា** ។
- បុរសនិងស្រ្តីមានក្រូម៉ូសូមគូទី 23 ខុសគ្នា ។ ក្រូម៉ូសូមគូទី 23 ជា ក្រូម៉ូសូមភេទ ឬអេតេរ៉ូក្រូម៉ូសូម ។ ចំពោះស្រ្តីក្រូម៉ូសូមភេទគឺ XX ចំពោះបុរសគឺ XY ។



*រូបទី 2.៤ ការីយ៉ូទីបនៃស្ពែម៉ាតូស៊ីត*

រូបមន្តក្រូម៉ូសូមរបស់បុរស

$2n = 46 = 44$ អូតូសូម + ក្រូម៉ូសូមភេទ XY

រូបមន្តក្រូម៉ូសូមរបស់នារី

$2n = 46 = 44$ អូតូសូម + ក្រូម៉ូសូមភេទ XX

បើពិនិត្យមើលការីយ៉ូទីបរបស់កាម៉ែត យើងសង្កេតឃើញថា កាម៉ែតមានក្រូម៉ូសូមតែពាក់កណ្តាលគឺ 23 ហើយមានក្រូម៉ូសូមតែមួយក្នុងគូក្រូម៉ូសូមអូម៉ូឡូកនីមួយៗ ។

## 1.៣. វិភាគទូទៅលើការីយ៉ូទីប

| សត្វ | ចំនួនក្រូម៉ូសូម | រុក្ខជាតិ | ចំនួនក្រូម៉ូសូម |
|---|---|---|---|
| ដ្រូសូភីល | $2n = 8$ | ខ្ទឹមបារាំង | $2n = 16$ |
| កង្កែប | $2n = 26$ | ពោត | $2n = 20$ |
| ឆ្មា | $2n = 38$ | សណ្តែកបាយ | $2n = 22$ |
| ទន្សាយ | $2n = 44$ | ថ្នាំជក់ | $2n = 48$ |
| សេះ | $2n = 64$ | ស្រូវ | $2n = 24$ |
| លា | $2n = 66$ | ស្រូវភោជន៍សាលី | $2n = 42$ |
| ឆ្កែ | $2n = 78$ | សណ្តែកព័រ | $2n = 14$ |
| ព្រូន | $2n = 2$ ឬ 4 តាមប្រភេទ | | |

### ក. បើពិនិត្យមើលតារាងខាងលើ យើងសង្កេតឃើញថា

- ចំនួនក្រូម៉ូសូមថេរចំពោះប្រភេទភាវៈរស់មួយ គឺឯកត្ត ក្នុងប្រភេទភាវៈរស់តែមួយមានចំនួនក្រូម៉ូសូមដូចគ្នា ។ ភាវៈរស់ប្រភេទខុសគ្នាមានចំនួនក្រូម៉ូសូមខុសគ្នា ។
- ចំនួនក្រូម៉ូសូមជាចំនួនគូជានិច្ច យើងតាងដោយ 2n ។ ចំនួន 2n ក្រូម៉ូសូមជា **ចំនួនឌីប្លូអ៊ីត** ។

១. ក្នុងសារពាង្គកាយមានកោសិកា2 បែប គឺកោសិកាលូតលាស់និងកោសិកាបន្តពូជឬកាម៉ែត

- កោសិកាលូតលាស់ : ក្រៅពីកោសិកាបន្តពូជ កោសិកាដទៃទៀតក្នុងសារពាង្គកាយជាកោសិកាលូតលាស់ ។ ជាទូទៅកោសិកាលូតលាស់មានចំនួន 2n ក្រូម៉ូសូម (ចំនួនឌីប្លូអ៊ីត) ។ ចំពោះមនុស្ស ចំនួនឌីប្លូអ៊ីត 2n = 46 ឆ្មា 2n = 38 ពោត 2n = 20 ។

ក្នុងកោសិកាឌីប្លូអ៊ីត គូក្រូម៉ូសូមអូម៉ូឡូកនីមួយៗបង្កឡើងដោយក្រូម៉ូសូមមួយដែលទទួលបានមកពីមេនិងក្រូម៉ូសូមមួយទៀតដែលបានមកពីបា ។

- កោសិកាបន្តពូជឬកាម៉ែតមានចំនួន n ក្រូម៉ូសូម ។ ចំនួន n ក្រូម៉ូសូមជា **ចំនួនអាប្លូអ៊ីត** ។ ចំពោះមនុស្ស ចំនួនអាប្លូអ៊ីត n = 23 ឆ្មា n = 19 ពោត n = 10 ។ កាម៉ែតមានក្រូម៉ូសូមតែមួយ ក្នុងគូក្រូម៉ូសូមអូម៉ូឡូកនីមួយៗ ។

***សំគាល់***

- ចំពោះថនិកសត្វ ល្អូន កង្កែប សត្វល្អិតស្លាបពីរមានក្រូម៉ូសូមភេទដូចមនុស្សគឺ XX ចំពោះភេទញីនិង XY ចំពោះភេទឈ្មោល ។
- ចំពោះបក្សីនិងមេអំបៅ ក្រូម៉ូសូមភេទរបស់សត្វញីគឺ XY និងសត្វឈ្មោលគឺ XX ។
- រុក្ខជាតិខ្លះមានចំនួនក្រូម៉ូសូមលើសពី 2n គឺជារុក្ខជាតិប៉ូលីប្លូអ៊ីត (3n ទ្រីប្លូអ៊ីត 4n តេត្រាប្លូអ៊ីត ) ។

## 2. រូបផ្តុំក្រូម៉ូសូម

យើងបានសិក្សារួចហើយ ថាក្រូម៉ូសូមលេចឡើងតែនៅពេលកោសិកាធ្វើចំណែកមីតូស ។ នៅមុនចំណែកមីតូស ក្រូម៉ូសូមមិនលេចជារូបរាងទេ ។ ក្នុងណៃយ៉ូគេឃើញមានតែក្រូម៉ាទីន ។ តើក្រូម៉ូសូមលេចជារូបរាងឡើង ហើយបាត់ទៅវិញយ៉ាងដូចម្តេច ?

### ក. ទម្រង់ក្រូម៉ាទីននៅចន្លោះវគ្គ

បើពិនិត្យនុយក្លេអូប្លាសក្នុងណៃយ៉ូ ដោយមីក្រូទស្សន៍អុបទិចនៅចន្លោះវគ្គ គេឃើញមានសារធាតុដែលមានសភាពជាគ្រាប់ គឺក្រូម៉ាទីន ។ តែបើពិនិត្យមើលក្នុងមីក្រូទស្សន៍អេឡិចត្រូនិច ( X40, 000 ដង) ក្រូម៉ាទីនមានភាពជាបណ្តាញសរសៃប្រទាក់គ្នា ។ តែបើពង្រីកកាន់តែខ្លាំង (X 500 000) ក្រូម៉ាទីនមានភាពជាសរសៃដែលមានភាគចោង រាងគ្រាប់ជាប់បន្តគ្នា មានទិដ្ឋភាពដូចជា

ខ្សែកអង្កាំ ។ គ្រាប់អង្កាំមួយគ្រាប់ជានុយក្លេអូសូមមួយដែលមានអង្កត់ផ្ចិតប្រវែង 10nm ។ ធាតុបង្ករបស់នុយក្លេអូសូមជាម៉ូលេគុលប្រូតេអ៊ីនអ៊ីស្តូន និង ADN ។ ខ្សែម៉ូលេគុលADN រុំលើដុំប្រូតេអ៊ីននីមួយៗ 2 ជុំ ហើយតភ្ជាប់ពីដុំប្រូតេអ៊ីនមួយទៅប្រូតេអ៊ីនមួយទៀត បង្កើតជាភីឡាម៉ង់រាងស៊ីឡាំងដោយមានអង្កត់ផ្ចិត 10nm ។ នុយក្លេអូភីឡាម៉ង់នេះបង្កជាក្រូម៉ាទីនក្នុងណ្វៃយ៉ូនៅចន្លោះវគ្គ ។ ដូចនេះក្រូម៉ាទីនបង្កឡើងពីម៉ូលេគុល ADN និងប្រូតេអ៊ីន ។



*ក. ទម្រង់ក្រូម៉ាទីននៅចន្លោះវគ្គ ( X40 000 )*



*ខ. នុយក្លេអូភីឡាម៉ង់មានសភាពជាខ្សែកគ្រាប់គុជ( X500 000 )*




*គ. សរសៃនុយក្លេអូភីឡាម៉ង់ (បំណកស្រាយរូបខាងលើ)*

*រូបទី 2.5 ទម្រង់ក្រូម៉ាទីន*

## ១. ទម្រង់ក្រូម៉ូសូមនៅវគ្គមេតាផាស




*រូបទី 2.6 ទម្រង់ក្រូម៉ូសូមនៅមេតាផាស*

នៅវគ្គនេះ ក្រូម៉ូសូមលេចរូបរាងយ៉ាងច្បាស់ ។ វាបង្កឡើងដោយក្រូម៉ាទីត 2 ដែលជាប់គ្នាដោយសង់ត្រូមែ ។ ការលេចឡើងនៃក្រូម៉ូសូមបណ្តាលមកពីការរួញខ្លីនៃក្រូម៉ាទីន ។ ក្រូម៉ាទីតនីមួយៗបង្កឡើងពីនុយក្លេអូភីឡាម៉ង់ ដែលរងស្ពៀរកម្មរួញខ្លី ។ នៅវគ្គមេតាផាស ស្ពៀរកម្មនេះប្រព្រឹត្តទៅដល់កម្រិតអតិបរមា ។

ដូច្នេះក្រូម៉ូសូមជាធាតុបង្កអចិន្ត្រៃយ៍នៃកោសិកា ។ ប៉ុន្តែវាផ្លាស់ប្តូររូបរាងទៅតាមចន្លោះវគ្គនិងវគ្គផ្សេងៗនៃមីតូស ។

## គ. ទម្រង់ផ្សេងៗនៃក្រូម៉ូសូមក្នុងវដ្តកោសិកា




*រូបទី 2.7 ការវិវត្តនៃក្រូម៉ូសូមក្នុងវដ្តកោសិកា*

នៅចន្លោះវគ្គ ក្រូម៉ូសូមមិនលេចជារូបរាងទេ ដោយនុយក្លេអូភីឡាម៉ង់រលា វាបង្កជាក្រូម៉ាទីន នៅក្នុងណ្វៃយ៉ូ ។ នៅពេលមីតូស នុយក្លេអូភីឡាម៉ង់រួញធ្វើឱ្យក្រូម៉ូសូមលេចជារូបរាងឡើង ។

## 2.1. ការកំណត់ភេទនៃឯកត្តៈមួយ

***ឧទាហរណ៍*** : ចំពោះដ្រូសូភីលមានក្រូម៉ូសូមអូម៉ូឡូក 4 គូ ដែលក្នុងនោះមានអូតូសូម 3 គូ និង ក្រូម៉ូសូមភេទ ។ គូ XX ចំពោះភេទញី និង XY ចំពោះភេទឈ្មោល ។




*រូបទី 2.8 ក. ការីយ៉ូទីបដ្រូសូភីល ខ. ចលនការកំណត់ភេទដ្រូសូភីល*

កំណកាម៉ែតប្រព្រឹត្តទៅដោយមានចំណែកមេយ៉ូស ។ ក្នុងចំណែកមេយ៉ូសមានការផ្តាច់ចេញពីគ្នានៃគូក្រូម៉ូសូមអូម៉ូឡូក ។ ដូច្នេះក្នុងកាម៉ែតនៃរុយសូភីលមានអូតូសូមចំនួន 3 និងក្រូម៉ូសូមភេទមួយ ។

បើគិតតែក្រូម៉ូសូមភេទ រុយសូភីលញីបង្កើតអូវុលតែមួយបែបដែលមានក្រូម៉ូសូម X ។ រុយសូភីលឈ្មោលបង្កើតស្ពែម៉ាតូសូអ៊ីត 2 បែបដែលមានសមាមាត្រស្មើគ្នា មួយបែបមានក្រូម៉ូសូម X និងមួយបែបទៀតមានក្រូម៉ូសូម Y ។

នៅពេលបង្កកំណើត បើស្ពែម៉ាតូសូអ៊ីត X រលាយចូលជាមួយអូវុល នោះនឹងកើតស៊ីកូតដែលមានសេណូទីប XX ហើយលូតលាស់ជាភេទញី ♀ ។ បើស្ពែម៉ាតូសូអ៊ីតមានក្រូម៉ូសូម Y រលាយចូលជាមួយអូវុល នោះនឹងកើតស៊ីកូតមានក្រូម៉ូសូម XY ហើយលូតលាស់ជាភេទឈ្មោល ♂ ។

P : XX x XY

កាម៉ែត P : X X , Y

$F_1$ : XX XY

ញី 50% ឈ្មោល 50%

## 2.2. លក្ខណៈជាប់នឹងភេទ

### ក. សែននៅលើក្រូម៉ូសូម X

***ឧទាហរណ៍*** : លក្ខណៈពណ៌ភ្នែករុយសូភីល ។

ម៉័រកង់ (*Morgan*) ជាអ្នករកឃើញតំណពូជនៃលក្ខណៈជាប់នឹងភេទនៅពេលគាត់ធ្វើការពិសោធទៅលើរុយសូភីល ។ មានរុយសូភីលពូជសុទ្ធពីរដែលខុសគ្នាដោយលក្ខណៈពណ៌ភ្នែក ពូជទី 1 (ពូជព្រៃ) មានភ្នែកពណ៌ក្រហមនិងពូជទី 2 មានភ្នែកពណ៌ស ។

**បង្កាត់ទី 1**

គេបង្កាត់រុយសូភីលញីភ្នែកពណ៌ក្រហមពូជសុទ្ធជាមួយរុយសូភីលឈ្មោលភ្នែកសពូជសុទ្ធ ។ នៅជំនាន់ទី 1 ($F_1$) គេទទួលបានរុយសូភីលភ្នែកក្រហម 100 % ដែលនៅក្នុងនោះមាន 50 % ជាញី និង 50 % ជាឈ្មោល ។

P (ពូជសុទ្ធ) : រុយសូភីល ♀ ភ្នែកក្រហម x រុយសូភីល ♂ ភ្នែកស

$F_1$ : រុយសូភីលភ្នែកក្រហម (ញី 50% , ឈ្មោល 50% )

បង្កាត់ទី 2

ម្ដងនេះគេបង្កាត់ដ្រូសូភីលញីភ្នែកសពូជសុទ្ធនិងដ្រូសូភីលឈ្មោលភ្នែកក្រហមពូជសុទ្ធ ។ នៅជំនាន់ទី 1 ($F_1$) គេឃើញមានផេណូទីបពីរបែបគឺ ដ្រូសូភីលញីភ្នែកក្រហម(ផេណូទីបរបស់បា) 50 % និងដ្រូសូភីលឈ្មោលភ្នែកស (ផេណូទីបរបស់មេ) 50 % ។

P (ពូជសុទ្ធ) : ដ្រូសូភីល ♀ ភ្នែកស X ដ្រូសូភីល ♂ ភ្នែកក្រហម

$F_1$ : - ដ្រូសូភីល ♀ ភ្នែកក្រហម 50%
- ដ្រូសូភីល ♂ ភ្នែកស 50%

## ✍ *បំណកស្រាយលទ្ធផល*

**តើហេតុអ្វីបានជាលទ្ធផលក្នុងការបង្កាត់ទាំងពីរខុសគ្នា ?**

ក្នុងការបង្កាត់ទាំងពីរលើក មេបាមានផេណូទីបដូចគ្នា តែខុសគ្នាត្រង់ការបង្កាត់ទី 1 ដ្រូសូភីលញីមានលក្ខណៈភ្នែកក្រហម ការបង្កាត់ទី 2 ដ្រូសូភីលញីមានលក្ខណ ភ្នែកពណ៌ស ។

ក្នុងការបង្កាត់ទី 1 គេទទួលបានដ្រូសូភីលភ្នែកពណ៌ក្រហមទាំងអស់ ។ យើងសន្និដ្ឋានបានថា លក្ខណ ភ្នែកពណ៌ក្រហមលុបលើលក្ខណ ភ្នែកស ។

ក្នុងការបង្កាត់ទី 2 លទ្ធផលមិនគោរពតាមច្បាប់ឯកសណ្ឋានភាពនៃអ៊ីប្រីតនៅជំនាន់ទី 1 ទេ ។ កូនភេទឈ្មោលមានលក្ខណ ដូចមេ កូនភេទញីមានលក្ខណ ដូចបា ។ ត្រង់ចំណុចនេះយើងសន្និដ្ឋានថា សែនកំណត់លក្ខណ ពណ៌ភ្នែកដ្រូសូភីលមិនស្ថិតនៅលើក្រូម៉ូសូមធម្មតាទេ គឺវាស្ថិតនៅលើក្រូម៉ូសូមភេទ ។ តើសែននេះស្ថិតនៅលើក្រូម៉ូសូម X ឬ Y ? យើងអាចលើកសម្មតិកម្មបីបែប

- សម្មតិកម្មទី 1 សែនកំណត់លក្ខណ ពណ៌ភ្នែកដ្រូសូភីលស្ថិតនៅលើក្រូម៉ូសូម X ផងនិង Y ផង
- សម្មតិកម្មទី 2 សែនកំណត់លក្ខណ ពណ៌ភ្នែកដ្រូសូភីលស្ថិតនៅតែលើក្រូម៉ូសូម Y
- សម្មតិកម្មទី 3 សែនកំណត់លក្ខណ ពណ៌ភ្នែកដ្រូសូភីលស្ថិតនៅតែលើក្រូម៉ូសូម X ។

តើសម្មតិកម្មណាមួយដែលត្រឹមត្រូវ ?

- បើសិនជាសែនកំណត់លក្ខណ ពណ៌ភ្នែកដ្រូសូភីលស្ថិតនៅលើក្រូម៉ូសូម X ផងនិង Y ផង គេនឹងទទួលបានអ៊ីប្រីត $F_1$ ដែលមានលក្ខណ លុប 100 % ដូចក្នុងករណីសែននៅលើអូតូសូមដែរ ។
- បើសិនជាសែនកំណត់លក្ខណ ពណ៌ភ្នែកដ្រូសូភីលស្ថិតនៅតែលើក្រូម៉ូសូម Y នោះ មានតែដ្រូសូភីលឈ្មោលទេ ដែលមានលក្ខណ ពណ៌ភ្នែក ។

តាមការបកស្រាយខាងលើ សម្មតិកម្មទី 1 និងទី 2 មិនសមស្របទេ ពីព្រោះលទ្ធផលផ្ទុយនឹងការពិសោធ ។

ដូច្នេះយើងសន្មតថាសែនកំណត់លក្ខណៈពណ៌ភ្នែកជ្រូកសូភីលស្ថិតនៅតែលើក្រូម៉ូសូម X ហើយគ្មានគូអាឡែលនៅលើក្រូម៉ូសូម Y ទេ ។

**ផ្ទៀងផ្ទាត់**

តាង R ជាអាឡែលកំណត់លក្ខណៈភ្នែកពណ៌ក្រហម (លុប)

តាង b ជាអាឡែលកំណត់លក្ខណៈភ្នែកពណ៌ស (អន់)

**បង្កាត់ទី 1**

| | | | | |
|---|---|---|---|---|
| ផេណូទីបP (ពូជសុទ្ធ) | : | ជ្រូសូភីលញីភ្នែកក្រហម | × | ជ្រូសូភីលឈ្មោលភ្នែកស |
| សេណូទីប P | : | $X_RX_R$ | | $X_bY$ |
| កាម៉ែត P | : | $X_R$ | | $X_b$ , $Y$ |
| $F_1$ | : | $X_RX_b$ | , | $X_RY$ |
| | | ញីភ្នែកក្រហម 50 % | , | ឈ្មោលភ្នែកក្រហម 50 % |

**បង្កាត់ទី 2**

| | | | | |
|---|---|---|---|---|
| ផេណូទីបP (ពូជសុទ្ធ) | : | ជ្រូសូភីលញីភ្នែកស | × | ជ្រូសូភីលឈ្មោលភ្នែកក្រហម |
| សេណូទីប P | : | $X_bX_b$ | | $X_RY$ |
| កាម៉ែត P | : | $X_b$ | | $X_R$ , $Y$ |
| $F_1$ | : | $X_RX_b$ | , | $X_bY$ |
| | | ញីភ្នែកក្រហម 50 % | , | ឈ្មោលភ្នែកស 50 % |

លទ្ធផលនៃការបកស្រាយតាមតារាងពុយណេទាំងពីរនេះ ដូចលទ្ធផលនៃការពិសោធ ។ ដូច្នេះយើងសន្និដ្ឋានថាសម្មតិកម្មទី 3 ត្រឹមត្រូវគឺ **សែនកំណត់លក្ខណៈពណ៌ភ្នែកជ្រូសូភីលមានតែនៅលើក្រូម៉ូសូម X ។**

## ១. ជំងឺតពូជ

ជំងឺតពូជមានបុព្វហេតុមកពីសែន ។ គេចែកជំងឺតពូជជាពីរប្រភេទ គឺជំងឺតពូជលើក្រូម៉ូសូមធម្មតានិងជំងឺតពូជជាប់នឹងភេទ ។

## ៣.១. ជំងឺតពូជលើក្រូម៉ូសូមធម្មតា

### ក. ជំងឺតពូជលក្ខណៈអន់

***ឧទាហរណ៍*** : ជំងឺភឿក ។ ជំងឺភឿកមានចំពោះមនុស្សនិងសត្វ ។ មនុស្សភឿកមានស្បែកស ដូចទឹកដោះ សក់សឬទង់ដែងភាវ ប្រស្រីពណ៌កូឡាប ពីព្រោះគេអាចមើលឃើញសរសៃឈាមនៃស្រទាប់កូរ៉ូអ៊ីតនៅក្នុងភ្នែក ។ ជំងឺភឿកបណ្តាលមកពីអវត្តមាននៃជាតិពណ៌មេឡានីន ។ ប្រតិកម្មសំយោគមេឡានីនត្រូវបានរាំងស្ទះដោយអវត្តមាននៃអង់ស៊ីមមួយ ។

**តើជំងឺភឿកតពូជតាមរបៀបដូចម្តេច?ហើយសែនដែលកំណត់ជំងឺនេះជាសែនលុប ឬអន់ ?**



តារាងពង្សាវលីបង្ហាញអំពីការបញ្ជូនជំងឺភឿកក្នុងគ្រួសារមួយ

និមិត្តសញ្ញា

□ បុរសគ្មានជំងឺ ○ នារីគ្មានជំងឺ

■ បុរសមានជំងឺ ● នារីមានជំងឺ

I , II , III ជំនាន់

1 , 2 , 3 , 4 , 5 ឯកត្តៈក្នុងជំនាន់នីមួយៗ

ចូរពិនិត្យតារាងពង្សាវលីដែលបង្ហាញអំពីការបញ្ជូនជំងឺភឿកក្នុងគ្រួសារមួយ ។ នៅជំនាន់ទី I, ទី II គ្មានអ្នកណាមានជំងឺភឿកទេ ។ នៅជំនាន់ទី III ទើបមានជំងឺភឿកលេចឡើង ។ កូនមានលក្ខណៈភឿក តែឪពុកម្តាយគ្មានលក្ខណៈនេះទេ ។ ដូច្នេះយើងអាចសន្និដ្ឋានបានថាលក្ខណៈភឿក ជាលក្ខណៈអន់ ហើយលេចចេញតែក្នុងករណីអូម៉ូស៊ីកូតនៃសែនអន់ (aa) ។ មេបា I និង 2 ក្នុងជំនាន់ទី II ជាអេតេរ៉ូស៊ីកូត(Aa) ។ កូនភឿកមានសេណូទីប (aa) ដោយគេទទួលអាឡែល a មួយពីម្តាយនិងអាឡែល a មួយពីឪពុក ។ ឪពុកម្តាយអេតេរ៉ូស៊ីកូត អាចមានលទ្ធភាពនិងបង្កើតកូនភឿកក្នុងសមាមាត្រ 25 % ។ លក្ខណៈភឿកអាចមានចំពោះឯកត្តៈទាំងពីរភេទ គឺបុរសនិងនារី ។ ដូច្នេះសែនកំណត់ជំងឺភឿកនេះមាននៅលើក្រូម៉ូសូមធម្មតា ។

***សំគាល់*** : ជំងឺគថ្លង់ក៏កំណត់ដោយសែនអន់ ដែលមាននៅលើក្រូម៉ូសូមធម្មតាដែរ ។ បើគ្រួសារមួយមានសែនកំណត់ជំងឺគថ្លង់ ឬភឿក អាពាហ៍ពិពាហ៍រវាងបងប្អូនជីដូនមួយធ្វើឱ្យលទ្ធភាពនៃការលេចឡើងជំងឺកាន់តែមានអត្រាខ្ពស់ ។

### ខ. ជំងឺតពូជលក្ខណៈលុប

***ឧទាហរណ៍*** : ជំងឺកូរ៉េហង់ទីងតុង (Chorée de Huntington) ។ ជំងឺកូរ៉េហង់ទីងតុងលេចឡើងចំពោះឯកត្តៈដែលមានសែនកំណត់ជំងឺនេះនៅអាយុប្រហែល 40 ឆ្នាំ ។ អ្នកជំងឺកូរ៉េហង់ទីងតុងមាន

ចលនាខុសពីប្រក្រតីនិងមានខួរក្បាលទន់ខ្សោយ ដែលនាំឱ្យការចងចាំថយចុះនិងរហូតដល់មានភាពវិកលចរិត ។ វិបត្តិនេះបណ្តាលមកពីការខូចខាតនៃណឺរ៉ូន (កោសិកាប្រសាទ) ក្នុងសារធាតុ ប្រផេះរបស់ខួរក្បាល ជាពិសេសនៅតំបន់ដែលមានការសម្របសម្រួលចលនា ។



*ការបញ្ជូនជំងឺកូរ៉េហាង់ទីងតុង*

តារាងពង្សាវលីបង្ហាញឱ្យឃើញថា

- កូនមានជំងឺបណ្តាលមកពីឪពុក ឬម្តាយឈឺ ។
- បើឪពុកម្តាយគ្មានជំងឺ នោះកូនក៏គ្មានជំងឺដែរ ។
- មនុស្សមានជំងឺរៀបការជាមួយមនុស្សជាធម្មតាអាចមានកូនឈឺ ។
- ជំងឺនេះត្រូវបញ្ជូនផ្ទាល់ពីឪពុក ឬម្តាយទៅឱ្យកូន ពុំមានការរំលងជំនាន់ទេ ។

គ្រប់លក្ខណៈវិនិច្ឆ័យខាងលើនេះ បង្ហាញថាអាឡែលដែលធ្វើឱ្យមានជំងឺមានភាពលុបលើអាឡែលធម្មតា ។ ម្យ៉ាងទៀតជំងឺនេះកើតមានចំពោះភេទទាំងពីរ(បុរសនិងនារី) ។ ដូច្នេះជំងឺកូរ៉េហាង់ទីងតុងជាជំងឺបញ្ជូនដោយក្រូម៉ូសូមធម្មតា ។

តាង C ជាអាឡែលកំណត់ជំងឺកូរ៉េហាង់ទីងតុង (លុប)

តាង n ជាអាឡែលធម្មតា (អន់)

មនុស្សជាធម្មតាមានសេណូទីប nn ឯមនុស្សមានជំងឺជាអេតេរ៉ូស៊ីកូតមានសេណូទីប Cn ។ បើឪពុកឬម្តាយមានជំងឺនេះ ជំនាន់កូនអាចមានគ្រោះថ្នាក់ 50 % និងកើតជំងឺនេះ ។

## ១.2. ជំងឺតពូជជាប់នឹងភេទ

ជំងឺភ្លើកនិងជំងឺកូរ៉េហាង់ទីងតុងកើតមានចំពោះភេទទាំងពីរ (បុរសនិងនារី) ។ តែជំងឺតពូជខ្លះមានច្រើនតែចំពោះបុរស ហើយមានតិចតួចណាស់ចំពោះនារី ។ ដូច្នេះគេថាជំងឺទាំងនេះជាជំងឺតពូជជាប់នឹងភេទ ។ ជំងឺមីញ៉ូប៉ាទី ជំងឺឈាមក្រកក និងជំងឺងងឹតពណ៌ជាជំងឺតពូជជាប់នឹងភេទ ។

### ក. ជំងឺមីញ៉ូប៉ាទី *(Myopathie)*

ជំងឺមីញ៉ូប៉ាទីសំគាល់ដោយសារការចុះខ្សោយនៃសាច់ដុំ ។ ជំងឺនេះចាប់ផ្តើមលេចឡើងមុនក្មេងអាយុបាន 2 ឆ្នាំ ។ ក្មេងដើរអឹកអាក ហើយដួលញឹកញាប់ ។ ពីអាយុ 10 ទៅ 12 ឆ្នាំ សាច់ដុំកាន់តែខ្សោយទៅៗ ធ្វើឱ្យក្មេងមិនអាចដើរបាន ។ នៅអាយុប្រមាណ 20 ឆ្នាំ សាច់ដុំប្រអប់ទ្រូងលូតលាស់មិនប្រក្រតី

ធ្វើឱ្យពិបាកដកដង្ហើម ហើយបណ្ដាលឱ្យស្លាប់ ។ មនុស្សកើតជំងឺនេះកម្ររស់បានលើសពីអាយុ 20 ឆ្នាំណាស់ ។

## ខ. ជំងឺឈាមក្រកក (អេម៉ូភីលី *Hémophilie*)

ជំងឺឈាមក្រកកនេះកើតមានតែចំពោះបុរស ។ ឈាមអ្នកជំងឺមិនកកដូចឈាមធម្មតាទេ ។ គ្រាន់តែរបួសបន្តិចបន្តួច ក៏បណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ដោយការបាត់បង់ឈាមច្រើនពេក ។ ជំងឺនេះបណ្ដាលមកពីក្នុងឈាមខ្វះសារធាតុដែលចាំបាច់សម្រាប់ប្រតិកម្មនៃដំណើរកំណកឈាម ។

ពីសម័យមុន អ្នកជំងឺស្លាប់តាំងពីវ័យក្មេង ។ តែឥឡូវនេះគេអាចព្យាបាលជំងឺនេះ ដោយចាក់បញ្ចូលឱ្យអ្នកជំងឺនូវសារធាតុសម្រង់ពីឈាមដែលមានកត្តាកំណកឈាម ។ គេទាញកត្តាកំណកឈាមពីឈាមអ្នកផ្ដល់ដែលមានឈាមធម្មតា ។

## គ. ជំងឺងងឹតពណ៌ (ដាល់តូនីស *Daltonisme*)

មនុស្សដែលមានជំងឺដាល់តូនីស មិនអាចញែកពណ៌ក្រហមពីពណ៌បៃតងបានទេ ។

## ឃ. របៀបបញ្ជូនជំងឺទាំងបី

បើពិនិត្យតារាងពង្សាវលីនៃគ្រួសារ មានជំងឺមីញ៉ូប៉ាទី និងគ្រួសារមានឈាមក្រកក យើងសង្កេតឃើញ

- សែនកំណត់លក្ខណៈ ឈាមក្រកកនិងសែនកំណត់ជំងឺមីញ៉ូប៉ាទីជាសែនអន់ ពីព្រោះឪពុកម្ដាយមានលក្ខណៈធម្មតាអាចមានកូនមានជំងឺ ។
- ជំងឺទាំងពីរនេះមានរបៀបបញ្ជូនដូចគ្នា គឺជំងឺទាំងនេះកើតមានចំពោះតែមនុស្សប្រុស ។ ឪពុកមានជំងឺមិនបញ្ជូនជំងឺនេះទៅកូនប្រុសទេ តែកូនស្រីដែលគ្មានជំងឺអាចបញ្ជូនជំងឺនេះទៅកូនប្រុសរបស់ខ្លួន ។



ការបញ្ជូនជំងឺមីញ៉ូប៉ាទី



ការបញ្ជូនជំងឺឈាមក្រកក

# ង. បំណាកស្រាយតាមក្រូម៉ូសូម

**តើហេតុអ្វីបានជាជំងឺខាងលើច្រើនតែកើតមានចំពោះបុរស ?**

***ឧទាហរណ៍*** : ចំពោះជំងឺមីញ៉ូប៉ាំទី ។ បើសិនជាសែនកំណត់ជំងឺស្ថិតនៅលើអូតូសូម នោះជំងឺនេះអាចកើតមានចំពោះឯកត្តៈទាំងពីរភេទក្នុងសមាមាត្រប្រហែលគ្នា តែជំងឺមីញ៉ូប៉ាំទីមានចំពោះបុរសច្រើនជាងនារី ។ ដូច្នេះសែនកំណត់ជំងឺនេះមិនស្ថិតនៅលើអូតូសូមទេ ។



*រូបទី 2.9 : ក្រូម៉ូសូមភេទរបស់មនុស្ស*

សែនកំណត់ជំងឺនេះមិនស្ថិតនៅលើក្រូម៉ូសូម Y ទេ ព្រោះតារាងពង្សាវលីបង្ហាញថា ឪពុកមានជំងឺមិនបានបញ្ជូនជំងឺនេះទៅកូនប្រុសគាត់ទេ ។ យើងអាចសន្និដ្ឋានថា សែនកំណត់ជំងឺមីញ៉ូប៉ាំទីជាសែនអន់ ហើយស្ថិតនៅតែលើក្រូម៉ូសូម X គ្មាននៅលើក្រូម៉ូសូម Y ទេ ។ ដូច្នេះ :

- មនុស្សប្រុសមានក្រូម៉ូសូមភេទ XY បើបុរសមានអាឡែលកំណត់ជំងឺតែមួយ គេនឹងកើតជំងឺ ។
- តែចំពោះនារីដែលមានក្រូម៉ូសូមភេទ XX វិញនឹងមានជំងឺ លុះត្រាតែមានអាឡែលអន់ពីរកំណត់ជំងឺ ។ នេះជាករណីកម្រកើតមាន ។ នារីគ្មានជំងឺ តែអាចជាអេតេរ៉ូស៊ីកូតគឺមានអាឡែលមួយកំណត់ជំងឺ នារីនេះអាចចម្លងជំងឺទៅកូនបាន ។ កូនប្រុសទទួលក្រូម៉ូសូម X ពីម្ដាយ និងក្រូម៉ូសូម Y ពីឪពុក ដូច្នេះកូនប្រុសកើតជំងឺត្រូវទទួលសែនកំណត់ជំងឺនេះពីម្ដាយ ។

***ឧទាហរណ៍*** : ជំងឺងងឹតពណ៌

តាង D ជាអាឡែលកំណត់លក្ខណៈគំហើញធម្មតា

តាង d ជាអាឡែលកំណត់ជំងឺងងឹតពណ៌

ករណីបីអាចកើតមាន

- ម្ដាយផ្ទុកសែនជំងឺនិងឪពុកជាធម្មតា

សេណូទីប P $X_D X_d$ X $X_D Y$

| គាម៉ែត ♀ \ ♂ | $X_D$ | $Y$ |
|---|---|---|
| $X_D$ | $X_D X_D$ កូនស្រីជា 25% | $X_D Y$ កូនប្រុសជា 25% |
| $X_d$ | $X_D X_d$ កូនស្រីផ្ទុកជំងឺ 25% | $X_d Y$ កូនប្រុសងងឹតពណ៌ 25% |

- ម្ដាយអូម៉ូស៊ីកូតលក្ខណៈធម្មតានិងឪពុកឈឺ

សេណូទីប P $X_DX_D$ X $X_dY$

| កាម៉ែត ♀ \ ♂ | $X_d$ | Y |
|---|---|---|
| $X_D$ | $X_DX_d$ កូនស្រីផ្ទុកសែនកំណត់ជំងឺ 50% | $X_DY$ កូនប្រុសជា 50% |

- ម្ដាយផ្ទុកសែនជំងឺនិងឪពុកឈឺ

សេណូទីប P $X_DX_d$ X $X_dY$

| កាម៉ែត ♀ \ ♂ | $X_d$ | Y |
|---|---|---|
| $X_D$ | $X_DX_d$ កូនស្រីផ្ទុកសែនកំណត់ជំងឺ 25% | $X_DY$ កូនប្រុសជា 25% |
| $X_d$ | $X_dX_d$ កូនស្រីងងឹតពណ៌ 25% | $X_dY$ កូនប្រុសងងឹតពណ៌ 25% |

***សំគាល់*** : ស្ត្រីអាចកើតជំងឺងងឹតពណ៌ តែក្នុងសមាមាត្រតិចជាងបុរស ( បុរសមាន 4 % តែស្ត្រីមាន 0.2 % កើតជំងឺងងឹតពណ៌) ។ តែកម្រមាននារីមានជំងឺឈាមក្រកកណាស់ ពីព្រោះឯកត្តៈជាអូម៉ូស៊ីកូត ចំពោះសែនអន់កំណត់ឈាមក្រកក(អន់) $X_hX_h$ ត្រូវបានស្លាប់តាំងពីអំប្រ៊ីយ៉ុង ។

# 4. មុយតាស្យុង

ក្នុងធម្មជាតិនិងក្នុងកសិដ្ឋានចិញ្ចឹមសត្វ ជួនកាលគេឃើញមានសត្វដែលមានលក្ខណៈខុសប្លែកពីគេ ។ ***ឧទាហរណ៍*** ជ្រូសូកិលស្លាបរួញ ឆ្កែគ្មានកន្ទុយ គោឬក្របីគ្មានស្នែង កណ្ដុរគ្មានរោម ឬមានពណ៌ផ្សេងៗ ។ វត្តមាននៃលក្ខណៈថ្មីនេះបណ្ដាលមកពីមុយតាស្យុង ។ មុយតាស្យុងជាកំណែប្រែសំភារសេនេទិចគឺបម្រែបម្រួលសែន ឬបម្រែបម្រួលក្រូម៉ូសូម ។ បម្រែបម្រួលនេះបណ្ដាលឱ្យមានបម្រែបម្រួលលក្ខណៈ ។



*រូបទី 2.10 : កណ្ដុរគ្មានរោម (មុយតាស្យុង)*

## 4.1. បុព្វហេតុនៃមុយតាស្យុង

អ្នកបង្កាត់រុក្ខជាតិនិងសត្វបានដឹងជាយូរមកហើយថា លក្ខណៈ តពូជថ្មីអាចលេចចេញភ្លាមនៅក្នុងពូជមួយនៃរុក្ខជាតិឬសត្វ ។ មុយតាស្យុងកើតឡើងដោយចៃដន្យនិងដោយឯកឯងនៅក្នុងចំណោមប្រភេទភាវៈរស់ទាំងអស់ ។ តែក្នុងធម្មជាតិ ប្រេកង់នៃមុយតាស្យុងកើតឯង មានកម្រិតទាបណាស់ ។ កត្តាខ្លះហៅថាមុយតាសែន អាចធ្វើឱ្យអត្រាមុយតាស្យុងកើនឡើង ។ គេអាចបង្កើតមុយតាស្យុងដោយប្រើកត្តាទាំងនោះ ។ មុយតាសែន (ភ្នាក់ងារមុយតាស្យុង) មាន

- ភ្នាក់ងាររូប កាំរស្មី X កាំរស្មីស្វាយអ៊ុលត្រាVU , កាំរស្មី λ ។
- ភ្នាក់ងារគីមី អាស៊ីតនីទ្រី (acide nitreux) ឬអាស៊ីតអាគ្រីឌីន (acide acridine) ។

សារពាង្គកាយដំបូងគេបង្អស់ដែលមានលក្ខណៈថ្មីកើតឡើងដោយសារមុយតាស្យុងហៅថា **មុយតង់** ។

បើសិនជាមុយតាស្យុងកើតឡើងក្នុងកោសិកាលូតលាស់ (មុយតាស្យុងសូម៉ា) មុយតាស្យុងនេះត្រូវបញ្ជូនទៅឱ្យកោសិកាផ្សេងៗទៀតនៃសារពាង្គកាយតាមមីតូស តែមិនអាចបញ្ជូនទៅសន្តានក្រោយបានទេ ។ ***ឧទាហរណ៍*** ជំងឺមហារីកមួយចំនួនបណ្តាលមកពីមុយតាស្យុងសូម៉ា ។

ប្រសិនបើមុយតាស្យុងកើតឡើងក្នុងកោសិកាបន្តពូជ (មុយតាស្យុងខ្នា) មុយតាស្យុងនេះអាចត្រូវបញ្ជូនទៅឱ្យស៊ីកូតតាមរយៈកាម៉ែត ។ ដូចនេះគ្រប់កោសិកាទាំងអស់របស់សារពាង្គកាយមួយដែលលូតលាស់ចេញពីស៊ីកូតក៏មានមុយតាស្យុងដែរ ។

មុយតាស្យុងមានពីរយ៉ាង គឺមុយតាស្យុងក្រូម៉ូសូមនិងមុយតាស្យុងសែន ។

មុយតាស្យុងក្រូម៉ូសូមបណ្តាលមកពីបម្រែបម្រួលទម្រង់ក្រូម៉ូសូម ឬចំនួនក្រូម៉ូសូម ។ គេអាចមើលឃើញបម្រែបម្រួលនេះនៅក្នុងការីយ៉ូទីប ។ ចំណែកឯមុយតាស្យុងសែនវិញ គឺជាបម្រែបម្រួលនៃទម្រង់សែន ដែលមាននៅលើក្រូម៉ូសូម ។

## 4.2. មុយតាស្យុងទម្រង់ក្រូម៉ូសូម

មុយតាស្យុងនេះលេចឡើងក្រោមរូបរាងដូចខាងក្រោម

- **ការដាច់អង្កត់** កើតឡើងនៅពេលដែលអង្កត់មួយនៃក្រូម៉ូសូមជ្រុះបាត់ ។ ចំពោះមនុស្ស ការបាត់ដៃខ្លីនៃក្រូម៉ូសូមទី5 នាំឱ្យខ្សោយប្រាជ្ញា និងមានសរីរាង្គខ្លះ ដូចជាបំពង់សំឡេងលូតលាស់មិនធម្មតា ។ នៅពេលទើបកើត ក្មេងយំមានសំឡេងដូចសំឡេងឆ្មា ដូចនេះគេឱ្យឈ្មោះថាជាជំងឺសម្រែកឆ្មា ។ ការបាត់ដៃខ្លីនៃក្រូម៉ូសូមទី18 នាំឱ្យភាពមិនប្រក្រតីនៃភ្នែកមុខ ហើយនិងប្រាជ្ញាខ្សោយ ។

- ការជ្រៀតអង្គត់មួយចូលកើតឡើងពេលដែលអង្គត់មួយនៃក្រូម៉ូសូមដាច់ ហើយទៅភ្ជាប់នឹងក្រូម៉ូសូមមួយទៀត ដែលជាគូអូម៉ូឡូករបស់វា ។ ដូច្នេះក្រូម៉ូសូមនេះមានអង្គត់ដូចគ្នាដល់ទៅពីរ ។
- បញ្ច្រាសតំណលំដាប់ កើតឡើងនៅពេលមានអង្គត់មួយនៃក្រូម៉ូសូមដាច់ ហើយភ្ជាប់មកវិញតាមទិសដៅបញ្ច្រាសគ្នា ។
- បន្ទេរអង្គត់ អង្គត់មួយនៃក្រូម៉ូសូមដាច់ ហើយទៅជាប់នឹងក្រូម៉ូសូមមួយទៀតដែលមិនមែនជាគូអូម៉ូឡូកនឹងគ្នា ។

ករណីខាងលើច្រើនតែបង្កើតជំងឺដ៏មានគ្រោះថ្នាក់ដល់មនុស្ស ។




*មុយតាស្យុងនៃទម្រង់ក្រូម៉ូសូម*

## 4.3. មុយតាស្យុងនៃចំនួនក្រូម៉ូសូម

ចំពោះមុយតាស្យុងបែបនេះ អាចមានបម្រែបម្រួលចំនួនក្នុងគូក្រូម៉ូសូមអូម៉ូឡូកណាមួយ ឬបម្រែបម្រួលចំនួនក្រូម៉ូសូមទាំងអស់ក្នុងកោសិកា (ប៉ូលីប្លូអ៊ីឌី) ។

### ក. បម្រែបម្រួលចំនួនក្រូម៉ូសូមក្នុងគូក្រូម៉ូសូមអូម៉ូឡូកណាមួយ

ក្មេងខ្លះអាចមានក្រូម៉ូសូមទី 21 ដល់ទៅ 3 (ទ្រីសូមីទី 21) ។ ចំពោះក្មេងនេះ ចំនួនឌីប្លូអ៊ីត $2n = 47$ ។ ចំពោះក្មេងដែលមានទ្រីសូមីទី 21 (ឬអាការ ដូវ Down's syndrome ) សារពាង្គកាយរបស់គេមិនលូតលាស់ តឿ មិនសូវមានប្រាជ្ញា ប្រអប់ដៃខ្លី ភ្នែកបញ្ឈិតចុះក្រោម ហើយអារ ។ បុព្វហេតុនៃជំងឺនេះ គឺនៅចំណែកមេយ៉ូសក្នុងពេលកំណកាម៉ែត គ្មានការផ្ដាច់ចេញនៃគូក្រូម៉ូសូមអូម៉ូឡូកទី 21 ទេ ។ ដូចនេះចំពោះកាម៉ែតដែលកើតឡើង គឺមានកាម៉ែតម្យ៉ាងដែលមានគូក្រូម៉ូសូមទី 21 ដល់ទៅ 2 និងកាម៉ែតម្យ៉ាងទៀត គ្មានក្រូម៉ូសូមទី 21 សោះ ។ នៅពេលបង្កកំណើត បើកាម៉ែតដែលមានក្រូម៉ូសូមទី 21 ចំនួន 2 ទៅជួបកាម៉ែតធម្មតា នោះនឹងកើតឡើងស៊ីកូត ដែលមានក្រូម៉ូសូមទី 21 ដល់ទៅ 3 គឺជាទ្រីសូមីទី 21 ។ បើកាម៉ែតធម្មតាទៅជួបកាម៉ែតដែលគ្មានក្រូម៉ូសូមទី 21 នោះស៊ីកូតមានក្រូម៉ូសូមទី 21 តែមួយ នេះជាករណីម៉ូណូសូមី ។ ជាទូទៅម៉ូណូសូមីបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរជាងទ្រីសូមី ។

ទ្រីសូមីទី 21 កើតមានជាញឹកញាប់ មួយករណីក្នុងចំណោម 650 – 700 កំណើត ។ សមាមាត្រនេះកើនឡើងទៅតាមអាយុរបស់ម្ដាយ ($\frac{1}{200}$ មុនអាយុ 30 ឆ្នាំ) $\frac{4}{100}$ នៅអាយុលើ 35 ឆ្នាំ និង $\frac{1}{50}$ នៅអាយុ 45 ឆ្នាំ)




ការីយ៉ូទីបនៃក្មេងទ្រីសូមី




មុយតាស្យុងចំនួនក្រូម៉ូសូមក៏អាចកើតឡើងនៅលើក្រូម៉ូសូមភេទដែរ ដោយក្នុងដំណើរកំណាអូវុលនៅចំណែកមេយ៉ូសគ្មានការផ្ដាច់ចេញនៃក្រូម៉ូសូមភេទ XX ។ ពេលនោះ មានអូវុលពីរបែបកើតឡើងគឺមួយបែបមានក្រូម៉ូសូម X ដល់ទៅពីរ XX និងមួយបែបទៀតគ្មានក្រូម៉ូសូមភេទសោះ (O) ។ ដូចនេះនៅពេលបង្កកំណើត ស៊ីកូតដែលកើតឡើងពីការរួមគ្នារវាងស្ពែម៉ាតូសូអ៊ីតធម្មតានិងអូវុលប្រភេទខាងលើនេះអាចមានដូចតារាងខាងក្រោម

| ហ្គាម៉ែត ♀ ♂ | X | Y |
|---|---|---|
| XX | XXX | XXY |
| O | OX | Oy |

- ឯកត្តៈមានក្រូម៉ូសូមភេទ XO (ក្រូម៉ូសូម X តែមួយ) មានអាការៈរោគតួណេ (*Turner*) ។ អ្នកជំងឺភេទស្រីមានរូបរាងទាប អារ ហើយលក្ខណៈភេទបន្ទាប់លូតលាស់តិចបំផុត (អូវែមិនដំណើរការ គ្មានរដូវនិងដើមទ្រូងមិនលូតលាស់) ។
- ឯកត្តៈមានក្រូម៉ូសូមភេទ XXY មានអាការៈរោគគ្លីណឺភែលធើ (*Klinefelter*) ។ គឺជាបុរសដែលមានលក្ខណៈភេទបន្ទាប់ជាប្រុសផង (មានឧធំ ស្មាទូលាយ) និងស្រីផង (ត្រគាកសាយ ដើមទ្រូងលូតលាស់ ) ។ បុរសនេះអារដោយពងស្វាស មិនលូតលាស់ ។
- ឯកត្តៈមានក្រូម៉ូសូមភេទ XXX (ទ្រីសូមី) ជាស្រីមានអូវែមិនលូតលាស់ អារ និងប្រាជ្ញាអន់ ។
- ឯកត្តៈមានក្រូម៉ូសូម OY មិនអាចរស់បានទេ ។

## ១. ប៉ូលីប្លូអ៊ីឌី

ជួនកាលចំនួនក្រូម៉ូសូមទាំងអស់ក្នុងកោសិកាកើនឡើងតាមពហុគុណរបស់ n (3n , 4n 5n ... ) បាតុភូតនេះហៅថា ប៉ូលីប្លូអ៊ីឌី ។




រូបទី 2.11 : ប៉ូលីប្លូអ៊ីឌី

ការលេចឡើងនូវបាតុភូតប៉ូលីប្លូអ៊ីឌីបណ្តាលមកពីមានដំណើរប្រព្រឹត្តទៅមិនធម្មតានៃមីតូសឬមេយ៉ូស ។ នៅចំណែកមីតូស ក្រូម៉ូសូមទាំងអស់ស្ទួនឡើងទ្វេ តែដោយសារបុព្វហេតុណាមួយត្រយូងអាក្រូម៉ាទិចមិនបានកើតឡើងដែលនាំឱ្យក្រូម៉ូសូមកូនមិនអាចធ្វើដំណើរទៅប៉ូល ។

ដូច្នេះកោសិកាមួយមានចំនួនក្រូម៉ូសូមទ្វេជាពីរ គឺ 4n កើតឡើង ។ បើសិនជាបាតុភូតនេះកើតឡើងនៅចំណែកមេយ៉ូស នោះនឹងគ្មានការផ្តាច់ចេញនៃគូក្រូម៉ូសូមអូម៉ូឡូកទាំងអស់ទៅប៉ូលទេ ។ ដូច្នេះកាម៉ែតមានចំនួន 2n ក្រូម៉ូសូម ។ នៅពេលបង្កកំណើតបើកាម៉ែតឌីប្លូអ៊ីតនេះជួបកាម៉ែតអាប្លូអ៊ីតធម្មតានិងបង្កើតបានស៊ីកូតដែលមាន 3n ក្រូម៉ូសូម (ទ្រីប្លូអ៊ីត) ។

ចំពោះសត្វភាគច្រើន ប៉ូលីប្លូអ៊ីឌីបណ្តាលឱ្យស្លាប់ ។ តែចំពោះរុក្ខជាតិប៉ូលីប្លូអ៊ីតវិញ ដើម ផ្កា និងផ្លែមានទំហំធំ និងលូតលាស់ល្អជាងរុក្ខជាតិឌីប្លូអ៊ីតធម្មតា ។

ក្នុងកសិកម្ម គេអនុវត្តបាតុភូតប៉ូលីប្លូអ៊ីឌីនេះ ដើម្បីបង្កើតពូជរុក្ខជាតិដែលផ្តល់ទិន្នផលខ្ពស់ ។ គេអាចប្រើសារធាតុគីមីខ្លះដូចជា កុលស៊ីស៊ីនទៅលើកោសិកាកំពុងធ្វើចំណែក ដើម្បីបំផ្លាញត្រយូងអាក្រូម៉ាទិចដែលកើតមានឡើង ។

## 4.4. មុយតាស្យុងសែន

ម៉ង់ដែល ( Mendel )បានសន្និដ្ឋានថា លក្ខណៈរបស់ភាវៈរស់កំណត់ដោយកត្តាតំណពូជហៅថាសែនដែលមានទីតាំងលើក្រូម៉ូសូម ។

សែនជាអង្កត់មួយរបស់ ADN ។ ម៉ូលេគុល ADN កើតពីនុយក្លេអូទីតបួនប្រភេទ : អាដេនីន ស៊ីតូស៊ីន កានីន និងទីមីន ។ ម៉ូលេគុល ADN នីមួយៗ ជាច្រវាក់នុយក្លេអូទីតយ៉ាងវែងដែលមានចំនួននិងលំដាប់តម្រៀបនុយក្លេអូទីតយ៉ាងជាក់លាក់ ។

មុយតាស្យុងអាចបណ្តាលមកពីបម្រែបម្រួលសែន ។ មុយតាស្យុងសែនលេចឡើងដូចខាងក្រោម

- ការបាត់បង់នុយក្លេអូទីតមួយក្នុងម៉ូលេគុល ADN
- ការបន្ថែមនុយក្លេអូទីតមួយក្នុងម៉ូលេគុល ADN
- ការជួសនុយក្លេអូទីតមួយដោយនុយក្លេអូទីតមួយប្រភេទទៀត ។

មុយតាស្យុងសែនអាចបង្កើតជំងឺធ្ងន់ធ្ងរដល់មនុស្សដូចជា ជំងឺជ្រែបាំឈ្មស៊ីតូស(Drepanocytose ) ឬជំងឺគោលិកាក្រហមរាងកណ្តៀវ ។ គោលិកាក្រហមអ្នកជំងឺមានរាងដូចកណ្តៀវ ហើយមិនអាចបំពេញនាទីដឹកនាំអុកស៊ីសែនបាន ។ អ្នកជំងឺស្លាប់តាំងពីវ័យក្មេង ។ មុយតាស្យុងសែនអាចបណ្តាលឱ្យកើតឡើងនូវសែនថ្មីៗ ហើយមាននាទីសំខាន់ក្នុងការវិវត្តនៃភាវៈរស់ ។

## មេរៀនសង្ខេប

- បើគេពិនិត្យមើលគោលិកាសមនុស្សដែលផ្អាកចំណែកមីតូសនៅវគ្គមេតាផាស គេសង្កេតឃើញមានក្រូម៉ូសូម 46 ។ សំណុំក្រូម៉ូសូមទាំង 46 ដែលតម្រៀបពីធំទៅតូចជាការីយ៉ូទីបរបស់មនុស្ស ។
- កោសិកាលូតលាស់មានចំនួន 2n ក្រូម៉ូសូម (ចំនួនឌីប្ល៉ូអ៊ីត) ។
- កាម៉េតមានតែ n ក្រូម៉ូសូម (ចំនួនអាប្ល៉ូអ៊ីត) ។
- នៅចន្លោះវគ្គ ក្រូម៉ាទីនបង្កឡើងដោយនុយក្លេអូភីឡាម៉ង់វលា ។ នៅវគ្គប្រូផាសនិងមេតាផាស ក្រូម៉ូសូមនីមួយៗមានក្រូម៉ាទីត 2 ។ ក្រូម៉ាទីតនីមួយៗជានុយក្លេអូភីឡាម៉ង់ដែលរួញខ្លី ។ ក្រូម៉ូសូមជាធាតុបង្កអចិន្ត្រៃយ៍ក្នុងកោសិកា ។
- ភេទនៃកូនត្រូវកំណត់ឡើងនៅពេលបង្កកំណើត ហើយអាស្រ័យទៅនឹងស្ពែម៉ាតូសូអ៊ីត ចំពោះមនុស្សនិងជ្រូសូភីល ។
- លក្ខណ ពណ៌ភ្នែកជ្រូសូភីលកំណត់ដោយសែនដែលស្ថិតនៅលើក្រូម៉ូសូម X ក្នុងករណីនេះ ជ្រូសូភីលឈ្មោលពុំបញ្ជូនលក្ខណ របស់ខ្លួនទៅកូនឈ្មោលទេ វាបញ្ជូនទៅតែកូនញី ។
- ជំងឺតពូជលើក្រូម៉ូសូមធម្មតាមានលក្ខណ ភឿក (លក្ខណ អន់)និងជំងឺកូរ៉េហង់ទីងតុង (លក្ខណ លុប) បណ្តាលមកពីសែនដែលស្ថិតនៅលើក្រូម៉ូសូមធម្មតា ។ ជំងឺទាំងនេះ កើតនៅលើភេទទាំងពីរដូចគ្នា ។
- ជំងឺតពូជជាប់នឹងភេទ ដូចជាជំងឺងងឹតពណ៌ ជំងឺមីញ៉ូប៉ាទី និងជំងឺឈាមក្រកក បណ្តាលមកពីសែនអន់ដែលស្ថិតនៅលើក្រូម៉ូសូម X ។ ភាគច្រើននៃជំងឺទាំងនេះ កើតមាននៅលើភេទប្រុស ហើយម្តាយជាអ្នកបញ្ជូនជំងឺ ។
- ការលេចឡើងនូវលក្ខណ ថ្មីមួយបង្កឡើងដោយមុយតាស្យុង ។ មុយតាស្យុង គឺជាកំណែប្រែសំភារ សេនេទិច គឺកំណែប្រែសែន ឬកំណែប្រែចំនួននិងទម្រង់ក្រូម៉ូសូម ។

## ? សំណួរនិងលំហាត់

1. ចូរប្រៀបធៀបការីយ៉ូទីបបុរសនិងនារី ។
2. ហេតុអ្វីបានជាគេប្រើកុលស៊ីស៊ីន ក្នុងការធ្វើការីយ៉ូទីប ?
3. ហេតុអ្វីបានជាក្រូម៉ូសូមមិនលេចជារូបរាងនៅចន្លោះវគ្គ ?
4. តើក្រូម៉ូសូមលេចជារូបរាងនៅពេលណា ? ពីព្រោះអ្វី ?

5 តើក្រូម៉ូសូមបាត់រូបរាងទៅវិញនៅពេលណា ? ពីព្រោះអ្វី ?

6 តើនៅវគ្គណាដែលក្រូម៉ូសូមលេចរូបរាងច្បាស់ជាងគេ ? ពីព្រោះអ្វី ?

7 ចូរសរសេររូបមន្តក្រូម៉ូសូមជ្រួសូភ៊ីលញី និងជ្រួសូភ៊ីលឈ្មោល ។

8 ចំពោះមនុស្ស តើភេទរបស់កូនអាស្រ័យទៅនឹងស្ពែម៉ាតូសូអ៊ីត ឬអូវុល ? ចូរពន្យល់ ?

9 តើភេទនៃឯកត្តៈមួយ ត្រូវកំណត់ឡើងនៅពេលណា ?

10 អ្វីជាជំងឺតពូជ ?

11 ក្នុងករណីណា ទើបកូនស្រីអាចកើតជំងឺងងឹតពណ៌បាន ?

12 អ្វីជាមុយតាស្យុង ? តើបុព្វហេតុអ្វីដែលបណ្តាលឱ្យមានមុយតាស្យុង ?

13 អ្វីជាទ្រីសូមីទី 21 ? ចូរពន្យល់ថាហេតុអ្វីបានជាក្មេងអាចកើតទ្រីសូមីទី 21 ?

14. តើបាតុភូតប៉ូលីប្លូអ៊ីឌីមានអត្ថប្រយោជន៍ដូចម្តេចដែរចំពោះរុក្ខជាតិ ?

## ពិសោធន៍ : ការសម្រេចធ្វើការីយ៉ូទីប

មានជំងឺឬភាពមិនប្រក្រតីខ្លះបណ្តាលពីចំនួននិងរូបរាងក្រូម៉ូសូម ។ ការពិនិត្យមើលការីយ៉ូទីបមានសារៈសំខាន់ ក្នុងការរកបុព្វហេតុនៃភាពមិនប្រក្រតីខ្លះ ។

### 1. វត្ថុបំណង

- ចេះធ្វើចំណែកថ្នាក់ក្រូម៉ូសូម ដើម្បីសម្រេចធ្វើការីយ៉ូទីបមួយ
- អាចធ្វើវិភាគការីយ៉ូទីប

### 2. សម្ភារៈ

រូបភាពការីយ៉ូទីប កន្ត្រៃ ក្រដាស ការបិទ ប្រអប់តូចមួយឬស្រោមសំបុត្រ

### 3. របៀបធ្វើ

- ថតចម្លងឬផ្តាមរូបភាពក្រូម៉ូសូមពីតំនួសនៅទំព័រ 112
- កាត់ក្រូម៉ូសូមមួយម្តងៗពីរូបភាពការីយ៉ូទីបនេះ ដោយប្រុងប្រយ័ត្នកុំឱ្យបាត់រូបក្រូម៉ូសូមណាមួយ ។ បន្ទាប់មកប្រមូលរូបទាំងអស់ដាក់ក្នុងស្រោមសំបុត្រឬប្រអប់ ។
- រាប់ចំនួនក្រូម៉ូសូម ។
- កំណត់រកគូក្រូម៉ូសូមអូម៉ូឡូក ដោយមើលទំហំ រូបរាង និងទីតាំងសង់ត្រូមែ ។
- តម្រៀបគូក្រូម៉ូសូមអូម៉ូឡូកតាមលំដាប់ពីធំទៅតូច ។
- បិទក្រូម៉ូសូមលើក្រដាស ។

## 4. វិភាគនិងសន្និដ្ឋាន

1. ចូរកំណត់ចំនួនក្រូម៉ូសូមរបស់ឯកត្តៈ ដែលមានការីយ៉ូទីបនេះ ។
2. កំណត់រកភេទនៃឯកត្តៈ ។
3. កំណត់រកភាពមិនប្រក្រតី ដែលមានក្នុងការីយ៉ូទីបនេះ ។
4. ចូរគូរគូក្រូម៉ូសូមអូម៉ូឡូកណាមួយ ដោយដាក់ឈ្មោះ សង់ត្រូមែ ក្រូម៉ាទីត ក្រូម៉ូសូម ក្រូម៉ូសូមអូម៉ូឡូក ។



## ? សំណួរនិងលំហាត់ជំពូក3

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1. សារពាង្គកាយដែលចំពោះលក្ខណៈមួយកំណត់ដោយអាឡែលពីរដូចគ្នាជា

☐ក. អេតេរ៉ូស៊ីកូត ☐ខ. អ៊ីប្រ៊ីត ☐គ. អូម៉ូស៊ីកូត ☐ឃ. ផេណូទីប ។

2. ចំពោះទន្សាយ អាឡែល B ដែលកំណត់រោមខ្មៅលុបលើអាឡែល b កំណត់លក្ខណៈរោមស ។ ទន្សាយរោមសមានសេណូទីប

☐ក. BB ☐ខ. bb ☐គ. Bb ☐ឃ. BB និង Bb ។

3. ចំពោះមនុស្ស លក្ខណៈចិញ្ចើមស្រមូវ B លុបលើលក្ខណៈចិញ្ចើមស្តើង b ។ ឪពុកនារីម្នាក់មានចិញ្ចើមស្រមូវ តែនារីនោះនិងម្តាយរបស់គេមានចិញ្ចើមស្តើង ។ សេណូទីបរបស់ឪពុកគឺ

☐ក. BB ☐ខ. Bb ☐គ. bb ☐ឃ. BB និង Bb ។

II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ក្នុងកំណកាម៉ែតមាន ............ នៃគូអាឡែលដែលស្ថិតនៅលើគូក្រូម៉ូសូមអូម៉ូឡូកមួយគូ ។
2. កូនប្រុសទទួលក្រូម៉ូសូម Y ពី ............ ។
3. សែនកំណត់លក្ខណៈក្រុមឈាមមនុស្សមាន ............ ចំនួនបី ។
4. ចំពោះមនុស្ស ភេទរបស់កូនអាស្រ័យទៅនឹង ............ ។
5. កូនប្រុសមានជំងឺងងឹតពណ៌ទទួលសែនកំណត់ជំងឺនេះពី ............ ។

III. ចូរឆ្លើយសំណួរខាងក្រោមនេះ

1. បើគិតតែក្រូម៉ូសូមភេទ តើមនុស្សប្រុសមានស្ពែម៉ាតូសូអ៊ីតប៉ុន្មានបែប ? មនុស្សស្រីមានអូវុលប៉ុន្មានបែប ? ចូរពន្យល់
2. តើឪពុកកើតជំងឺឈាមក្រកក អាចបញ្ជូនជំងឺនេះទៅកូនប្រុសឬទេ ? ចូរពន្យល់
3. ក្នុងករណីណា ទើបកូនអាចកើតជំងឺភ្លៀក ? ចូរពន្យល់ ។

លំហាត់

4. ចំពោះមនុស្ស លក្ខណៈម្រាមដៃខ្លីលុបលើលក្ខណៈម្រាមដៃវែង ។ បុរសម្នាក់មានម្រាមដៃខ្លី តែឪពុករបស់គេមានម្រាមដៃវែង ។ បុរសនេះរៀបការជាមួយនារីម្នាក់ដែលមានម្រាមដៃវែង ។ តើកូនរបស់គេអាចមានលទ្ធភាពនិងមានម្រាមដៃខ្លីប៉ុន្មានភាគរយ ?
5. ឪពុកនិងម្តាយមានក្រុមឈាម A ។ តើកូនអាចមានក្រុមឈាមអ្វីខ្លះ ?
6. គេបង្កាត់គោគ្មានស្នែងពីរជាមួយគ្នា បានកូនគោមានស្នែងមួយ ។

ក. ចំពោះលក្ខណ គ្មានស្នែង និងមានស្នែង តើលក្ខណ ណាមួយជាលក្ខណ អន់ លក្ខណ ណាមួយជាលក្ខណ លុប ?

ខ. ចូរសរសេរសេណូទីបគោទាំងបី ។

7 ចំពោះទន្សាយ លក្ខណ រោមខ្មៅលុបលើលក្ខណ រោមពណ៌ត្នោត លក្ខណ រោមខ្លីលុបលើលក្ខណ រោមវែង ។ គេបង្កាត់ទន្សាយរោមពណ៌ខ្មៅ ហើយវែងអូម៉ូស៊ីកូតជាមួយទន្សាយរោមពណ៌ត្នោត ហើយខ្លីអូម៉ូស៊ីកូត ។

ក. តើទន្សាយជំនាន់ទី1 មានលក្ខណ ដូចម្តេច ?

ខ. បើគេបង្កាត់ជំនាន់ទី1 ជាមួយគ្នាវា តើជំនាន់ទី2មានលក្ខណ ដូចម្តេច ?

គ. បើគេបង្កាត់ទន្សាយជំនាន់ទី1 ជាមួយទន្សាយរោមពណ៌ត្នោតវែង តើគេទទួលបានផេណូទីបក្នុងសមាមាត្រដូចម្តេច ?

8. នេះជាការីយ៉ូទីបរបស់ទារកម្នាក់ដែលមានលក្ខណ មិនប្រក្រតី ដូចជាបបូរមាត់ឆែប ទម្រង់បេះដូងមិនល្អ ។



ក. តើទារកនេះមានភេទដូចម្តេច ? ចូរពន្យល់ ។

ខ. ចូរបង្ហាញអំពីភាពមិនប្រក្រតីដែលពិនិត្យឃើញក្នុងការីយ៉ូទីបនេះ ។ តើគេឱ្យឈ្មោះភាពមិនប្រក្រតីនេះថាដូចម្តេចដែរ ?

គ. ចូរសរសេររូបមន្តក្រូម៉ូសូមដែលត្រូវនឹងការីយ៉ូទីបនេះ

9 ក. ចូរពិនិត្យមើលការីយ៉ូទីបនេះ ហើយចូរបញ្ជាក់អំពីភេទនៃឯកត្ត ដែលមានការីយ៉ូទីបនេះ ។



ខ. ចូរសរសេររូបមន្តក្រូម៉ូសូមដែលត្រូវនឹងការីយ៉ូទីបនេះ ។

10 នេះជាតារាងពង្សាវលីនៃគ្រួសារមួយ ។ គ្រួសារនេះមានលក្ខណ មិនប្រក្រតីមួយ ។



តើលក្ខណ នេះមានតំណពូជដូចម្តេចដែរ? ( តើសែនដែលកំណត់លក្ខណ នេះមានភាពលុបឬអន់? ស្ថិតនៅលើក្រូម៉ូសូមធម្មតា ឬនៅលើក្រូម៉ូសូមភេទ ? )

# ជំពូក 4 អាហារនិងការរំលាយអាហាររបស់មនុស្ស



ភាវៈរស់ទាំងអស់ត្រូវការអាហារ ដើម្បីរស់រាននិងធំធាត់ ប៉ុន្តែអ្នកខ្លះមានរាងស្គម ស្បែកជ្រីវជ្រួញ ដំណើរទុយមុយ ខ្លះទៀតធាត់ជ្រុល ពោះកំប៉ោង ដំណើរអឹកអាក ដង្ហើមថប់ៗ ។ រីឯខ្លះទៀតមានរាងកាយសមរម្យ កម្ពស់ល្មម មិនធាត់មិនស្គម ស្វាហាប់ ទឹកមុខស្រស់ស្រាយ ។ ចំពោះលក្ខណៈខុសគ្នានេះ មួយចំណែកធំបណ្ដាលមកពីរបបអាហារ ។

តើក្នុងអាហារមានសារធាតុអ្វីខ្លះ ? តើអាហារប្រភេទណាដែលល្អសម្រាប់សុខភាព ?

តើការរំលាយអាហារប្រព្រឹត្តទៅនៅកន្លែងណាខ្លះ ? ហើយប្រព្រឹត្តទៅដូចម្ដេច ?

# 1 អាហារ

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ថាហេតុអ្វី បានជាយើងត្រូវការបរិភោគអាហារ ។
- ពន្យល់ពីប្រភពនៃសារធាតុចិញ្ចឹមនីមួយៗ ។
- ជ្រើសរើសអាហារ ដែលផ្តល់គុណភាពសម្រាប់សុខភាព ។
- បង្ហាញពីប្រភពផ្សេងៗនៃថាមពល ។

ភាវៈរស់ទាំងអស់ត្រូវការអាហារ ។ ការបរិភោគអាហារមានសារធាតុចិញ្ចឹមផ្សេងៗមានសារៈសំខាន់ណាស់សម្រាប់ការលូតលាស់ ថាមពល សុខភាព និងបំពេញតម្រូវការក្នុងសកម្មភាពមេតាបូលីស ។ តើអាហារប្រភេទណាខ្លះ ដែលល្អសម្រាប់សុខភាព ? តើសារធាតុចិញ្ចឹមទាំងនោះមានអ្វីខ្លះ ?

## 1. សារធាតុចិញ្ចឹមក្នុងអាហារ

មនុស្សក៏ដូចជាសត្វដែរ ជាភាវៈរស់បរជីពដែលតែងតែបរិភោគភាវៈរស់ដទៃទៀតជាអាហារ ។ ហេតុអ្វីបានជាភាវៈរស់ត្រូវការអាហារ ? ព្រោះអាហារមានផ្ទុកសារធាតុចិញ្ចឹម ។ សារធាតុចិញ្ចឹមជាសារធាតុដែលសារពាង្គកាយត្រូវការជាចាំបាច់សម្រាប់ការលូតលាស់ ការជួសជុលកោសិកាចាស់ៗ ការផ្តល់ថាមពល ការបន្តពូជ និងការទ្រទ្រង់រាងកាយឱ្យមានសុខភាពល្អប្រយុទ្ធប្រឆាំងនិងជំងឺផ្សេងៗ ។ សារធាតុចិញ្ចឹមមានគ្លុយស៊ីត លីពីត ប្រូទីត ទឹក អំបិលខនិជ និងវីតាមីន ។ សារធាតុទាំងនេះមានក្នុងអាហារ ។

### 1.1. គ្លុយស៊ីត

គ្លុយស៊ីតជាសមាសធាតុសរីរាង្គផ្សំឡើងដោយ C H O ។ ស្ករងាយរបស់គ្លុយស៊ីត គឺគ្លុយកូស ព្រុចតូស និងកាឡាក់តូស ។ វាមានរូបមន្តរួមគឺ $C_6H_{12}O_6$ ។ គេហៅស្ករងាយទាំងនោះថា ម៉ូណូសាការីត ។ វាមាននៅក្នុងទឹកផ្លែឈើ ទឹកឃ្មុំ និងបន្លែខ្លះ ។ បណ្តុំស្ករងាយពីរឬម៉ូណូសាការីតពីរបង្កើតបានជាឌីសាការីត ដែលមានម៉ាល់តូស(ស្ករក្នុងតាប៉ែ) សាការ៉ូស(ស្ករអំពៅ) ឡាក់តូស (ស្ករទឹកដោះគោ) ។

ម៉ូណូសាការីតច្រើន តភ្ជាប់ជាច្រវាក់វែងបង្កើតបានជា ប៉ូលីសាការីត ។ ស្ករលើសដែលស្តុកទុកក្នុងសត្វនិងរុក្ខជាតិជាប៉ូលីសាការីត ។ ប៉ូលីសាការីតសំខាន់ៗរបស់រុក្ខជាតិគឺអាមីដុងនិងសែលុយឡូស ។ អាមីដុង ជាគ្លុយស៊ីតសំខាន់ក្នុងរបបអាហាររបស់មនុស្ស ។ ពោត ចេក អង្ករ ដំឡូងបារាំង សម្បូរអាមីដុង ។ អាមីដុងត្រូវបំបែកជាឌីសាការីត (ម៉ាល់តូស) បន្ទាប់មកជាម៉ូណូសាការីត(គ្លុយកូស) ។ សែលុយឡូសជាប៉ូលីសាការីតដែលបង្កើតភ្នាសកោសិការុក្ខជាតិ ។ ចំពោះមនុស្ស ការបរិភោគសែលុយឡូសមិនអាចផ្តល់ថាមពលទេ ប៉ុន្តែវាមាននាទីសំខាន់សម្រាប់ភ្លោចសាច់ដុំបំពង់រំលាយអាហារកាត់បន្ថយជំងឺពោះវៀនធំនិងមហារីកចុងពោះវៀន ពោលគឺវាជួយសម្រួលដល់ការបន្ទោបង់លាមក ។ សត្វស្តុកអាមីដុងក្នុងកោសិកាថ្លើមនិងកោសិកាសាច់ដុំក្រោមទម្រង់ជាគ្លីកូសែន ។

## 1.2. លីពីត

ការបរិភោគខ្លាញ់ក្នុងបរិមាណសមស្រប មានសារៈសំខាន់សម្រាប់សុខភាពល្អ ដូចសារធាតុចិញ្ចឹមដទៃទៀតដែរ ។ ខ្លាញ់ជួយសម្រួលមុខងារផ្សេងៗក្នុងសារពាង្គកាយឱ្យប្រសើរឡើងដូចជា ការស្តុកថាមពល រំលាយវីតាមីន និងបង្កើតប្រូតូប្លាស ។ ស្រទាប់ខ្លាញ់នៅក្រោមស្បែកជួយការពារស្បែក ប្រឆាំងនិងបំលាស់ប្តូរសីតុណ្ហភាពក្នុងបរិស្ថាន ។

ដូចគ្លុយស៊ីតដែរ លីពីតដែលជាផ្នែកមួយរបស់ខ្លាញ់ ជាសមាសធាតុសរីរាង្គបង្កឡើងដោយ C H O ។ លីពីតកើតពីគ្លីសេរ៉ុលមួយម៉ូលេគុលនិងអាស៊ីតខ្លាញ់បីម៉ូលេគុល ។ អាស៊ីតខ្លាញ់មានពីរប្រភេទ គឺអាស៊ីតខ្លាញ់ឆ្អែតនិងអាស៊ីតខ្លាញ់មិនឆ្អែត ។ លីពីតកើតពីអាស៊ីតខ្លាញ់ឆ្អែតហៅថា លីពីតឆ្អែត (ខ្លាញ់ ក្រមួន) ។ វាតែងកកជានិច្ចនៅសីតុណ្ហភាពធម្មតា (ប្រហែល 20°C ) ។ លីពីតឆ្អែត ផ្តល់គ្រោះថ្នាក់ដល់សុខភាពមនុស្ស ។ កាលណាវាមានបរិមាណច្រើននៅក្នុងសរសៃឈាមនិងព័ទ្ធជុំវិញបេះដូង វាប្រមូលផ្តុំជាលីពីតម្យ៉ាងហៅថា កូឡេស្តេរ៉ូល ដែលបង្កជំងឺដល់ប្រព័ន្ធរបត់ឈាម ។ ផ្ទុយទៅវិញកូឡេស្តេរ៉ូលក៏មាននាទីសំខាន់ក្នុងកោសិកានៃសារពាង្គកាយដែរ ។ ថ្លើមបានផលិតកូឡេស្តេរ៉ូលដែលកោសិកាត្រូវការ ដូចនេះតម្រូវការវានៅក្នុងអាហារ គឺមិនចាំបាច់ឡើយ ។លីពីតកើតពីអាស៊ីតខ្លាញ់មិនឆ្អែតហៅថា លីពីតមិនឆ្អែត (ប្រេងចញ្ចជាតិ) ។ លីពីតប្រភេទនេះមិនកកទេ ហើយក៏មិនប៉ះពាល់ដល់សុខភាពដែរ ។ ដូចនេះគួរតែប្បីបរិភោគប្រេងជំនួសខ្លាញ់វិញ ។

## 1.3. ប្រូតេអ៊ីន

ប្រូតេអ៊ីន ជាសមាសធាតុសរីរាង្គផ្សំឡើងដោយ C H O N ។ ធាតុបង្ករបស់ប្រូតេអ៊ីន គឺអាមីណូអាស៊ីត ។ អាមីណូអាស៊ីតមានប្រហែល 20 ប្រភេទ ដែលបង្កើតបានប្រូតេអ៊ីនច្រើនប្រភេទរាប់មិនអស់ ។ ប្រូតេអ៊ីនមាននាទីសំខាន់ណាស់ ។ វាជាធាតុបង្ករបស់ប្រូតូប្លាស ធានានូវការលូតលាស់ ការ

សាងសង់ និងជួសជុលកោសិកាចាស់ៗ ។ ប្រូតេអ៊ីនបង្កើតអង់ស៊ីមនិងអរម៉ូន ។ ប្រូតេអ៊ីនខ្លះមានមុខងារបង្កើតអង់ទីករនិងដឹកនាំអុកស៊ីសែនក្នុងឈាម ។ សារពាង្គកាយអាចផលិតអាមីណូអាស៊ីតប្រហែល 10 ប្រភេទ ។ ឯអាមីណូអាស៊ីតប្រហែល 10 ប្រភេទទៀត ហៅថា អាមីណូអាស៊ីតគ្រឹះ ដែលសារពាង្គកាយមិនអាចសំយោគបានទេ គឺត្រូវយកពីរបបអាហារប្រចាំថ្ងៃ ។ អាមីណូអាស៊ីតគ្រឹះទាំងនេះមាននាទីសំខាន់ណាស់ក្នុងសំយោគប្រូតេអ៊ីន ។ វាមាននៅក្នុងសាច់ត្រី បក្សី សាច់គោ ស៊ុត និងទឹកដោះ ។ ប្រូតេអ៊ីនណាមានអាមីណូអាស៊ីតគ្រឹះទាំង 10 ប្រភេទ ហៅថា ប្រូតេអ៊ីនពេញលេញ ។ អាហាររុក្ខជាតិតែមួយប្រភេទ មិនផ្តល់អាមីណូអាស៊ីតគ្រឹះទាំងអស់ទេ ។ គេហៅវាថា ជាប្រូតេអ៊ីនមិនពេញលេញ ។ ដូចនេះគេត្រូវហូបអាហាររុក្ខជាតិចម្រុះឱ្យបានច្រើនប្រភេទ ។ បន្លែ សណ្តែកសៀង សណ្តែកដី ជាប្រភពផ្តល់ប្រូតេអ៊ីនយ៉ាងប្រសើរបំផុត ។ ចំពោះមនុស្សចាស់ ដើម្បីឱ្យមានសុខភាពល្អ ការបរិភោគសាច់ត្រូវកាត់បន្ថយ ហើយត្រូវបរិភោគប្រូតេអ៊ីនដែលមានប្រភពពីរុក្ខជាតិជំនួសវិញ ។

## 1.4. ទឹក

ទឹកជាសារធាតុចិញ្ចឹមសំខាន់បំផុត ។ មនុស្សអាចស្លាប់ដោយគ្មានទឹកឆាប់ជាងការស្លាប់ដោយគ្មានអាហារ ។ ទឹកមិនផ្តល់ថាមពលទេ ។ ទឹកមានបរិមាណច្រើនជាងសមាសធាតុដទៃទៀតនៃទម្ងន់សារពាង្គកាយ ។ ប្លាស្មាដែលជាផ្នែកមួយនៃឈាមមានទឹក 90 % ។ ទឹកជួយឱ្យប្រតិកម្មគីមីក្នុងសារពាង្គកាយប្រព្រឹត្តទៅបានល្អ ។ វាជាធាតុបង្ករបស់ប្រូតូប្លាសនិងជាសារធាតុរំលាយសម្រាប់អង់ស៊ីម អាហារ និងសារធាតុពុលផ្សេងៗ ព្រមទាំងជួយតម្រូវសីតុណ្ហភាពក្នុងរាងកាយ ។ សារធាតុពុលផ្សេងៗរលាយក្នុងទឹកនោម ហើយបញ្ចេញមកក្រៅ ។ ពេលអ្នកហាត់ប្រាណ ឬធ្វើការធ្ងន់ ក្រពេញញើសបញ្ចេញជាតិទឹក(ញើស)ពីជាលិកាដើម្បីផ្សើមស្បែកនិងធ្វើឱ្យរាងកាយត្រជាក់ ។ ពេលអ្នកដកដង្ហើមចេញ ទឹកត្រូវបានបញ្ចេញពីសួត តាមមាត់និងច្រមុះ ។ ដូចនេះទឹកត្រូវបាត់បង់ពីរាងកាយជារៀងរាល់ថ្ងៃ ។ ការបាត់បង់ទឹកនេះត្រូវជំនួសមកវិញដោយការផឹកទឹកនិងការបរិភោគអាហារ ។ បើមិនដូច្នោះទេ ឈាមក្នុងខ្លួននឹងឡើងខាប់ ហើយការប្រព្រឹត្តទៅរបស់កោសិកានឹងត្រូវអាក់ខាន ។ ***ឧទាហរណ៍*** អ្នកដែលកើតជំងឺរាគមួលខ្លាំង ត្រូវរងការបាត់បង់ទឹកយ៉ាងច្រើន ដូចនេះអ្នកជំងឺត្រូវបញ្ចូលទឹកឱ្យទាន់ពេល ទើបអាចជៀសវាងពីគ្រោះថ្នាក់ដែលអាចបណ្តាលឱ្យស្លាប់បាន ។

## 1.5. អំបិលខនិជឬអំបិលរ៉ែ

អំបិលខនិជ ជាសមាសធាតុអសរីរាង្គ ដែលរាងកាយត្រូវការជាចាំបាច់ក្នុងបរិមាណតិចតួច ។ ***ឧទាហរណ៍*** អេម៉ូក្លូប៊ីន ដែលជាប្រូតេអ៊ីនក្នុងគោលិកាក្រហមមានជាតិដែក 4 អាតូមសម្រាប់ភ្ជាប់ជាមួយអុកស៊ីសែន ។ ADN ARN ATP ផ្ទុកផូស្វ័រ ។ កាល់ស្យូម ជារ៉ែដែលបង្កើតសមាសភាពធ្មេញ

និងឆ្អឹង ហើយមាននាទីក្នុងកំណកឈាម ។ បើគ្មានម៉ាញ៉េស្យូមនិងរ៉ែផ្សេងៗទៀតទេ ជាលិកាប្រសាទ និងកោសិកាសាច់ដុំមិនអាចដំណើរការបានឡើយ ។ កង្វះជាតិអ៊ីយ៉ូតធ្វើឱ្យកើតជំងឺពកក ។ ទោះបីរាងកាយមិនបានបំផ្លាញជាតិរ៉ែក៏ដោយ ក៏ជាតិរ៉ែត្រូវបាត់បង់ពីរាងកាយទៅតាមញើស ទឹកនោម និងជាតិពុលផ្សេងៗ ។ ដូចនេះគេត្រូវបរិភោគជាប្រចាំនូវអំបិលខនិជ ឬរ៉ែ ដែលមាននៅក្នុងអាហារ ។ បន្លែ ផ្លែឈើមានគ្រាប់ សាច់ ស៊ុត ទឹកដោះគោ ប្រូម៉ាស មានជាតិដែក កាល់ស្យូម ម៉ាញ៉េស្យូម សូដ្យូមក្លរ និងជាតិរ៉ែដទៃទៀត ។ អ៊ីយ៉ូតមាននៅក្នុងអាហារសមុទ្រ ។ អំបិលយកបានពីសមុទ្រផ្ទាល់ មានអ៊ីយ៉ូតគ្រប់គ្រាន់សម្រាប់រាងកាយ ។ ប៉ុន្តែដោយចង់ឱ្យអំបិលមានពណ៌សម៉ដ្ឋ លំនាំផលិតកម្មឧស្សាហកម្មបានបំផ្លាញអ៊ីយ៉ូតស្ទើរតែអស់ពីអំបិលទាំងនោះ ។ ហេតុនេះហើយ ឥឡូវនេះគេនាំគ្នាបញ្ចូលអ៊ីយ៉ូតទៅក្នុងអំបិលវិញ ។

## 1.6. វីតាមីន ( ឬជីវជាតិ)

តើអ្នកដឹងទេ នៅក្នុងមជ្ឈិមសម័យ (សតវត្សទី 5-14) មានទាហានជើងទឹកដែលរស់នៅច្រើនខែលើនាវា កើតជំងឺយ៉ាងធ្ងន់ធ្ងរ ។ ពួកគេមានអញ្ចាញធ្មេញហើមហើយហូរឈាម ធ្មេញជ្រុះ សន្លាក់ហើមហើយឈឺ ។ ក្រោយមកមាននាវិកជាតិអង់គ្លេសម្នាក់ឈ្មោះហាវគីន(Hawkin)បានរកឃើញមូលហេតុជំងឺនេះ នៅពេលដែលគាត់ឱ្យទាហានរបស់គាត់បរិភោគផ្លែឈើ ជាពិសេសក្រូចឆ្មារនិងបន្លែស្រស់ ។ កូនទាហានរបស់គាត់ ក៏ជាសះស្បើយពីជំងឺទាំងនេះ ។ ដូចនេះជំងឺខាងលើបណ្តាលមកពីកង្វះវីតាមីន ជាពិសេសវីតាមីន C ។

ក៏ដូចទឹកនិងរ៉ែដែរ វីតាមីនជាសារធាតុចិញ្ចឹមមិនផ្តល់ថាមពលទេ ។ វីតាមីនជាម៉ូលេគុលសាំញ៉ាំដែលសារពាង្គកាយត្រូវការក្នុងបរិមាណតិចតួច តែវាមាននាទីសរីរៈយ៉ាងសំខាន់ក្នុងនាទីជាកាតាលីករដែលជួយអង់ស៊ីមក្នុងប្រតិកម្មគីមីផ្សេងៗ ។ បើគ្មានវីតាមីនជាជំនួយទេ អង់ស៊ីមមិនអាចបំពេញនាទីរបស់វាបានឡើយ ។ វាមិនអាចជួយឱ្យសារពាង្គកាយលូតលាស់ ហើយរឹងមាំបានទេ ។ ទោះបីវាចាំបាច់មិនអាចអត់បានក៏ដោយក៏ការបរិភោគវីតាមីននិមិត្តមិនអាចជំនួសវីតាមីនក្នុងអាហារបានឡើយ ។ ផ្ទុយទៅវិញការប្រើប្រាស់វីតាមីនលើសចំណុះ ក៏អាចបង្កផលអាក្រក់ដល់សារពាង្គកាយដែរ ។ វីតាមីននីមួយៗមានមុខងារខុសៗគ្នា ។ ***ឧទាហរណ៍*** វីតាមីន A ជួយដល់ភ្នែក និងឆ្អឹង វីតាមីន K ជួយដល់កំណកឈាម វីតាមីន C ការពារប្រឆាំងនិងការបង្ករោគឈាមអញ្ចាញធ្មេញនិងធ្វើឱ្យមានជម្រាបធាតុដែកនិងវិតាមីន B12 បង្កើតគោលិកាក្រហម ។ ជាទូទៅសារពាង្គកាយមិនអាចផលិតវីតាមីនបានទេ លើកលែងវីតាមីនខ្លះ ដូចជាវីតាមីន D ដែលត្រូវបានបង្កើតក្នុងស្បែកដោយពន្លឺព្រះអាទិត្យនៅពេល

ព្រិក ។ វីតាមីនបានមកពីរបបអាហារ ជាពិសេសនៅក្នុងផ្លែឈើស្រស់ បន្លែបៃតង គ្រាប់ធញ្ញជាតិ ត្រី សាច់ ស៊ុត ថ្លើម ។ គេចែកវីតាមីនជាពីរប្រភេទ គឺវីតាមីនរលាយក្នុងខ្លាញ់ (វីតាមីនK E D និងA) ដែលស្តុកទុកក្នុងស្រទាប់ខ្លាញ់ក្រោមស្បែកសម្រាប់ប្រើប្រាស់ថ្ងៃក្រោយ និងវីតាមីនរលាយក្នុងទឹក (វីតាមីនBនិងC ) ដែលត្រូវផ្គត់ផ្គង់ជាប្រចាំក្នុងរបបអាហារ ។



រូបទី 1.1 : ពីរ៉ាមីតអាហារ

ក្នុងការណែនាំនៃពីរ៉ាមីតអាហារ គេបានចែកអាហារជា6ក្រុម ។ រូបខាងស្តាំនេះបង្ហាញពីការប្រើប្រាស់អាហារក្នុងក្រុមនីមួយៗ ដើម្បីធានារបបអាហារផ្តល់សុខភាពល្អ ។

## 2. ថាមពលក្នុងអាហារ

សារពាង្គកាយត្រូវការថាមពលសម្រាប់លំនាំជីវិតផ្សេងៗ ។ ថាមពលទាំងនោះស្តុកទុកក្នុងអាហារ ។ ការបំបែកតាមបែបគីមីនៃគ្លុយស៊ីត លីពីត ប្រូតេអ៊ីន ក្នុងលំនាំដង្ហើមកោសិកាផ្តល់ថាមពល ។ បរិមាណអាហារដែលផ្តល់ឱ្យនិងបរិមាណថាមពលដែលទទួលបានពីដង្ហើមកោសិកា ( អុកស៊ីតកម្មឬចំហេះសព្វ) គឺស្មើគ្នា ។

គ្លុយស៊ីត ជាប្រភពថាមពលដ៏សំខាន់ ។ ក្នុងប្រដាប់រំលាយអាហារ គ្លុយស៊ីតត្រូវបំបែកជាគ្លុយកូស ហើយសាយចូលទៅក្នុងកោសិកា ។ ក្នុងទីនោះដំណើរអុកស៊ីតកម្មប្រព្រឹត្តទៅតាមលំដាប់ប្រតិកម្មគីមីជាច្រើន ក្រោមអំពើរបស់អង់ស៊ីម ។ ដំណើរនេះអាចសង្ខេបតាមរបៀបខ្លីដូចតទៅ

$C_6H_{12}O_6 + 6O_2 \longrightarrow 6CO_2 + 6H_2O +$ ថាមពល 674Kcal

ថាមពលដែលទទួលបាន ត្រូវស្តុកទុកក្នុងកោសិកាក្រោមទម្រង់ជា ATP ADP និង AMP ។ ថាមពលនេះ ត្រូវប្រើប្រាស់ដោយកោសិកាផ្ទាល់ ។

ATP (អាដេណូស៊ីនទ្រីផូស្វាត) = 1 ម៉ូ. អាដេនីន + 1 ម៉ូ. ស្កររីបូស + 3 ម៉ូ. អាស៊ីតផូស្វរិច

ADP (អាដេណូស៊ីនឌីផូស្វាត) = 1 ម៉ូ. អាដេនីន + 1 ម៉ូ. ស្កររីបូស + 2 ម៉ូ. អាស៊ីតផូស្វរិច

AMP (អាដេណូស៊ីនម៉ូណូផូស្វាត) = 1 ម៉ូ. អាដេនីន + 1 ម៉ូ. ស្កររីបូស + 1 ម៉ូ. អាស៊ីតផូស្វរិច

កាលណាសារពាង្គកាយត្រូវការប្រើប្រាស់ថាមពល ATP ដែលស្តុកទុកត្រូវបានបំបែកជា ADP ដោយផ្តាច់មួយម៉ូលេគុលអាស៊ីតផូស្វរិចឬផ្តាច់ 2 ម៉ូលេគុលអាស៊ីតផូស្វរិច បង្កើតជា AMP ។រាល់ពេល

ផ្ដាច់មួយម៉ូលេគុលអាស៊ីតផូស្វរិច វាបញ្ចេញថាមពល 10000cal ។ AMP ក៏អាចផ្សំជាមួយអាស៊ីតផូស្វរិចមួយម៉ូលេគុលដើម្បីបង្កើតជា ADP ឬផ្សំ 2 ម៉ូលេគុលអាស៊ីតផូស្វរិចបានជា ATP វិញបានដែរ ។

ឧបករណ៍សម្រាប់វាស់ថាមពល គឺកាឡូរីម៉ែត ។ ខ្នាតសម្រាប់វាស់ថាមពលគឺកាឡូរី(cal) ។ កាឡូរីជាឯកតានៃកម្ដៅ ។ មួយកាឡូរី គឺជាបរិមាណកម្ដៅដែលត្រូវការដើម្បីបង្កើនសីតុណ្ហភាពទឹក 1g នៅសីតុណ្ហភាព 1°C ។ ឯស៊ូល (Joule) ជាខ្នាតក្នុងប្រព័ន្ធអន្តរជាតិសម្រាប់វាស់ថាមពល ។

$1cal = 4.2J$

$1kcal = 4.2kJ$

អាហារសរីរាង្គដែលសម្បូរថាមពល ផ្ដល់តម្លៃថាមពលខុសៗគ្នា ។ គ្លុយស៊ីត 1g នេះអស់ផ្ដល់ថាមពល 16kJ នេះជាតម្លៃថាមពលរបស់គ្លុយស៊ីត ។ តម្លៃថាមពលរបស់ប្រូតេអ៊ីនគឺ 17kJ/g ។ លីពីតមានតម្លៃថាមពល 38kJ/g ។

តម្រូវការថាមពល

អាយុ ភេទ របៀបរស់នៅ និងលក្ខខណ្ឌនៃសារពាង្គកាយ ជាកត្តាដែលមានឥទ្ធិពលទៅលើតម្រូវការថាមពលប្រចាំថ្ងៃ ។ ជាទូទៅក្មេងត្រូវការថាមពលច្រើនជាងមនុស្សចាស់ ។ បុរសត្រូវការថាមពលច្រើនជាងស្ត្រី ។ អ្នកធ្វើការច្រើនត្រូវការថាមពលច្រើនជាងអ្នកធ្វើការតិច ។




តើមានអ្វីកើតឡើង កាលណាថាមពលដែលទទួលបាននិងថាមពលដែលប្រើប្រាស់គ្មានតុល្យភាព ?

| ថាមពលដែលទទួលបាន | ថាមពលដែលប្រើប្រាស់ | លទ្ធផល |
|---|---|---|
| 3000 cal | 3000 cal | គ្មានបម្រែបម្រួលម៉ាសសារពាង្គកាយ |
| 3000 cal | 1500 cal | កើនម៉ាស សារពាង្គកាយ (ធាត់) |
| 1500 cal | 3000 cal | ថយម៉ាស សារពាង្គកាយ (ស្គម) |

## មេរៀនសង្ខេប

- សារពាង្គកាយត្រូវការអាហារ ព្រោះអាហារផ្ទុកសារធាតុចិញ្ចឹម សម្រាប់ផ្តល់ថាមពល ការលូតលាស់ និងសម្រាប់ដំណើរការប្រព្រឹត្តទៅរបស់កោសិកា ។
- សារធាតុចិញ្ចឹមមាន គ្លុយស៊ីត លីពីត ប្រូទីត ទឹក អំបិលខនិជ និងវីតាមីន ។
- គ្លុយស៊ីតសំខាន់ៗមាន អាមីដុងនិងសែលុយឡូស ។ វាជាអាហារគ្រឹះនិងជាប្រភពថាមពល ។
- លីពីត ជាប្រភពថាមពលដ៏ចម្បង ។ លីពីតរុក្ខជាតិមិនបង្កគ្រោះថ្នាក់ដល់មនុស្សទេ ។
- ប្រូតេអ៊ីនមាននាទីសម្រាប់ការលូតលាស់ ជួសជុលកោសិកាចាស់ៗ ផលិតអង់ស៊ីម និងបង្កើតអង់ទីករ ។ ចំពោះមនុស្សចាស់ ប្រូតេអ៊ីនបានពីរុក្ខជាតិ មានលក្ខណៈប្រសើរជាង ប្រូតេអ៊ីនសត្វ ។
- ទឹកមាននាទីសំខាន់សម្រាប់សារពាង្គកាយ ។ ការហូបទឹកច្រើនជំនួសការបាត់បង់ទឹកពីសារពាង្គកាយធ្វើឱ្យសារពាង្គកាយមានសុខភាពល្អនិងបាត់ជាតិពុលផ្សេងៗ ។
- អំបិលខនិជនិងវីតាមីនមាននាទីសំខាន់ដូចទឹកដែរ ។ ថ្វីត្បិតតែវាមានបរិមាណតិចតួចក្នុងសារពាង្គកាយតែកង្វះរបស់វានាំឱ្យកើតជំងឺ ។
- សារធាតុចិញ្ចឹម ផ្តល់តម្លៃថាមពលខុសៗគ្នា លើកលែងតែទឹក អំបិលខនិជ និងវីតាមីន ។

## ? សំណួរនិងលំហាត់

1. តើប្រេងនិងខ្លាញ់មានលក្ខណៈខុសគ្នាដូចម្តេច ?
2. ចូរប្រៀបធៀបអាមីដុងនិងគ្លីកូសែន ?
3. ដូចម្តេចដែលហៅថាអាមីណូអាស៊ីតគ្រឹះ? ហេតុដូចម្តេចបានជាយើងត្រូវហូបបន្លែច្រើនប្រភេទចម្រុះគ្នា ?
4. តើវីតាមីនមាននាទីអ្វីខ្លះ? តើការបរិភោគវីតាមីននិមិត្ត( ផលិតដោយមនុស្ស)ច្រើនធ្វើឱ្យសារពាង្គកាយយើងលូតលាស់ឬទេ ? តើវីតាមីនធម្មតាមាននៅឯណា ?
5. តើត្រូវធ្វើដូចម្តេច ដើម្បីឱ្យសារពាង្គកាយមានតុល្យភាពនិងមានសុខភាពល្អ ?

## ពិសោធន៍ : រង្វាស់ថាមពលក្នុងសណ្តែកដី

### 1. វត្ថុបំណង

- វាស់ថាមពលចំហេះសព្វនៃសណ្តែកដី
- បញ្ជាក់ថា អាហារផ្ទុកថាមពល
- ចេះតាមដានការពិសោធ ។

## 2. សម្ភារៈ

បំពង់កែវពិសោធន៍ ទែម៉ូម៉ែត ដែកលួស 2cm សឺរ៉ាំង ទឹកធម្មតា ឈើគូសទៀន ឬចង្កៀងអាល់កុល សណ្តែកដី (រើសយកគ្រាប់ធំ ហើយស្ងួតល្អ) ។

## 3. រំលឹកចំណេះដឹង

គ្រាប់សណ្តែកដី ផ្ទុកអាមីដុង ។ វាជាសារធាតុសរីរាង្គផ្តល់ថាមពល ។ ចរោះសព្វនៃសារធាតុសរីរាង្គផ្តល់បរិមាណកម្តៅ ។ កាឡូរីជាខ្នាតវាស់ថាមពល ។ cal ជាបរិមាណកម្តៅ ដែលបានកើនសីតុណ្ហភាព 1°C ក្នុងទឹក 1g ។ តម្លៃថាមពលរបស់ត្នយស៊ុត ផ្តល់បរិមាណកម្តៅ 16kJ ( 1cal = 4.2J ) ។

## 4. ដំណើរការពិសោធ

- យកដែកលួសដែលកាត់ហើយដោតគ្រាប់សណ្តែកដី
- ចាក់ទឹក 100ml ទៅក្នុងកែវពិសោធន៍
- ដាក់ទែម៉ូម៉ែត្រទៅក្នុងបំពង់កែវ ហើយកត់ត្រាសីតុណ្ហភាពទឹក
- ដុតគ្រាប់សណ្តែកឱ្យឆេះ រួចដាក់ពីក្រោមបំពង់កែវដោយដៃម្ខាងកាន់បំពង់កែវ ដៃម្ខាងទៀតកាន់ដែកលួស ។
- ពេលគ្រាប់សណ្តែកឆេះអស់ ដាក់ទែម៉ូម៉ែតទៅក្នុងបំពង់ ហើយកូរទឹកថ្នមៗ រួចវាស់សីតុណ្ហភាព ។
- បំពេញតារាងខាងក្រោម

| | មុនពិសោធន៍ | ក្រោយពិសោធន៍ |
|---|---|---|
| សីតុណ្ហភាពទឹក | | |
| សភាពគ្រាប់សណ្តែក | | |

## 5. សំណួរពិភាក្សា

1 ហេតុអ្វីបានជាទឹកកើនកម្តៅ ?

2 តើបរិមាណនៃថាមពលកម្តៅក្នុងការពិសោធមានការបាត់បង់ឬទេ ? ដោយសារអ្វី ?

មេរៀនទី

# 2 ការរំលាយអាហារ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីរូបផ្គុំនៃប្រដាប់រំលាយអាហារ ។
- ❑ បកស្រាយពីមុខងារនៃសរីរាង្គនីមួយៗរបស់ប្រដាប់រំលាយអាហារ ។
- ❑ ពណ៌នាពីលំនាំបំបែកអាហារតាមបែបគីមីនិងសម្រូបអាហារក្នុងពោះវៀនតូច ។
- ❑ ប្រៀបធៀបនាទីថ្លើមនិងលំពែងក្នុងការរំលាយអាហារ ។

យើងបានសិក្សារួចមកហើយថា អាហារផ្ទុកសារធាតុចិញ្ចឹម ។ បន្ទាប់ពីបរិភោគរួច អាហារត្រូវបានឆ្លងកាត់តាមប្រដាប់រំលាយអាហារ ដោយបំបែកជាសារធាតុចិញ្ចឹម រួចសាយចូលទៅក្នុងកោសិកា ។ សារធាតុចិញ្ចឹមទ្រទ្រង់ការលូតលាស់នៃកោសិកា ស្តុកថាមពលសម្រាប់ដំណើរប្រព្រឹត្តទៅរបស់កោសិកា ។ តើការរំលាយអាហារប្រព្រឹត្តទៅដូចម្តេច ? តើសារធាតុចិញ្ចឹមសាយចូលក្នុងកោសិកាតាមរបៀបណា ?

## 1. ដំណាក់ដំបូងនៃការរំលាយអាហារ

ការរំលាយអាហារ ជាលំនាំនៃការបំបែកម៉ូលេគុលអាហារធំៗឱ្យទៅជាម៉ូលេគុលតូចៗ ដែលកោសិកាងាយស្រូបបាន ។ ការរំលាយអាហារប្រព្រឹត្តទៅក្នុងប្រដាប់រំលាយអាហារ ។ ប្រដាប់រំលាយអាហារមានមុខងារបីយ៉ាងសំខាន់ៗគឺ

- បំបែកម៉ូលេគុលធំឱ្យទៅជាម៉ូលេគុលតូច
- សម្រូបម៉ូលេគុលតូចៗទៅក្នុងឈាម
- ការបំបាត់កាកសំណល់និងជាតិពុលពីសារពាង្គកាយ ។

ប្រដាប់រំលាយអាហារមានបំពង់រំលាយអាហារ (មាត់ ដើមក បំពង់អាហារ ក្រពះ ពោះវៀនតូច ពោះវៀនធំ និងទ្វារធំ) និងក្រពេញរំលាយអាហារ(ក្រពេញទឹក




*រូបទី 2.1 : រូបផ្គុំប្រដាប់រំលាយអាហាររបស់មនុស្ស*

មាត់ ថ្លើម លំពែង និងពោះវៀនតូច) សម្រាប់បញ្ចេញរសរំលាយអាហារ (រូបទី2.1) ។ ការរំលាយអាហារប្រព្រឹត្តទៅតាមលំនាំពីរ គឺការបំបែកតាមបែបមេកានិចនិងការបំបែកតាមបែបគីមី ។

## 1.1. មាត់

មាត់ជាសរីរាង្គទីមួយដែលចាប់ផ្តើមធ្វើការរំលាយអាហារមុនគេ ។ នៅក្នុងមាត់ការបំបែកអាហារធ្វើតាមលំនាំពីរបែបគឺ

### ក. តាមបែបមេកានិច

ការបំបែកនេះជានាទីរបស់ធ្មេញនិងអណ្តាត ។ មនុស្សពេញវ័យមានធ្មេញចែកជាបួនក្រុមដែលមានរូបមន្ត ៖ ធ្មេញមុខ $\frac{2}{2}$ (សម្រាប់ខាំកកេរ)ចង្កូម $\frac{1}{1}$ (សម្រាប់ហែក) ថ្គាមតូច $\frac{2}{2}$ និងថ្គាមធំ $\frac{3}{3}$ (សម្រាប់ទំពារអាហារ) ។ ធ្មេញបំបែកអាហារធំៗឱ្យទៅជាដុំតូចៗ ។ អណ្តាតជាសរីរាង្គវិញ្ញាណសម្រាប់ដឹងរសជាតិអាហារនិងប្រមូលអាហារឱ្យចូលទៅកន្លែងខាំឬទំពា ។




*រូបទី2.2 : មាត់របស់មនុស្ស*

### ខ. តាមបែបគីមី

ទន្ទឹមនឹងការបំបែកមេកានិច ការបំបែកតាមបែបគីមីក៏ធ្វើឡើងព្រមពេលជាមួយគ្នាដែរ ។ ក្រពេញទឹកមាត់មានបីគូ (រូប 2.2) ។ វាបញ្ចេញទឹកមាត់ជ្រើមអាហារធ្វើឱ្យអាហាររអិល ទន់ និងបំបែក អាហារ ។ ទឹកមាត់ចេញតាមកូនបំពង់តូចៗទៅក្នុងក្រអូមមាត់ ។ វាមាននាទី ៖

- ផ្សំជាមួយជាតិរំអិលដើម្បីឱ្យអាហារឆ្លងកាត់បំពង់អាហារបានលឿន ។
- សម្លាប់មីក្រូសារពាង្គកាយដែលចូលតាមអាហារ ។
- រំលាយអាហារខ្លះៗ ព្រោះទឹកមាត់មានអង់ស៊ីមអាមីឡាសដែលបំបែកអាមីដុងឱ្យទៅជាម៉ាល់តូស ។ ឧទាហរណ៍ ពេលអ្នកបៀមបាយយូរ អ្នកមានអារម្មណ៍ថាបាយនោះផ្អែម គឺអាមីដុងត្រូវបានបំបែកដោយអង់ស៊ីមទឹកមាត់ទៅជាស្ករ ។

## 1.2. ដើមក

ដើមកជាផ្នែកមួយដែលនៅចន្លោះមាត់និងបំពង់អាហារ ។ វាជាផ្លូវរួមកាត់ខ្វែងរវាងផ្លូវអាហារនិងផ្លូវខ្យល់ (បំពង់អាហារនិងបំពង់ខ្យល់) ។ នៅផ្នែកលើនៃបំពង់ខ្យល់ មានសន្ទះឆ្អឹងខ្ចីមួយ ហៅថា

សន្ទះខ្យល់សម្រាប់បិទបំពង់ខ្យល់នៅពេលលេបអាហារ ។ ពេលនោះអាហារក៏ធ្លាក់ទៅក្នុងបំពង់អាហារ (រូបទី 2.3) ។

## 1.3. បំពង់អាហារ



រូបទី 2.3 ការលេបដុំអាហារ



រូបទី 2.4 : ចលនាបើរីស្តាល់ស៊ីស

បំពង់អាហារ ជាបំពង់ដែលតពីដើមកទៅក្រពះ ដោយឆ្លងកាត់សន្ទះទ្រូង ។ វាមានប្រវែងប្រហែល 25cm ។ ផ្ទៃបំពង់កើតពីសាច់ដុំរលីងដែលព័ទ្ធជុំវិញបំពង់ ។ នៅផ្នែកខាងក្នុងបំពង់មានស្រទាប់ជាតិរំអិលដែលផ្តល់ភាពងាយស្រួលក្នុងបំលាស់ទីនៃដុំអាហារ ។ នៅក្នុងបំពង់អាហារគ្មានការបំបែកអាហារទេ ហើយដុំអាហារក៏មិនធ្លាក់ដោយខ្លួនឯងបានដែរ ។ ក្រោយការលេបដុំអាហារធ្លាក់ក្នុងបំពង់អាហារ ហើយវាផ្លាស់ទីដោយសារការកន្ត្រាក់នៃសាច់ដុំបំពង់អាហារដូចជា ចលនាច្របាច់ទៅមុខ (ចលនាបើរីស្តាល់ស៊ីសរូបទី 2.4) ។ ដុំអាហារធ្លាក់បន្តិចម្តងតាមបណ្តោយបំពង់អាហារទៅក្នុងក្រពះ ដោយចំណាយពេលប្រហែល 10 វិនាទី ។ នៅត្រង់ផ្លូវចូលក្រពះ មានសាច់ដុំមួយស្តើងហៅថា **សាច់រឹបទ្វារ**ដែលមាននាទី ដូចជាប្រឹសសម្រាប់ឱ្យអាហារចូលក្នុងក្រពះ តែមិនអាចឱ្យអាហារត្រឡប់មកបំពង់អាហារវិញបានទេ ។

## 1.4. ក្រពះ



រូបទី 2.5 : សាច់ដុំក្រពះ

ក្រពះ ជាសរីរាង្គប្រហោងក្នុងមួយដូចជាថង់រាងអក្សរ ( J )។ វាមាននាទីសម្រាប់ទទួលអាហារដែលបញ្ជូនពីបំពង់អាហារ ហើយជាកន្លែងដែលដំណើររំលាយអាហារប្រព្រឹត្តទៅបន្តពីមាត់ ។ ក្រពះស្ថិតនៅខាងឆ្វេងនៃផ្នែកពោះជាប់ផ្នែកខាងក្រោមនៃសន្ទះទ្រូង ។ វាកើតពីស្រទាប់សាច់ដុំរលីង ក្រាស់ មាំហើយយឺត (រូបទី 2.5) ។ ក្នុងក្រពះការរំលាយអាហារប្រព្រឹត្តតាមបែបមេកានិចនិងតាមបែបគីមី ។

## ក. តាមបែបមេកានិច

លំនាំនេះធ្វើឡើងដោយសាច់ដុំរបស់ក្រពះ ។ ក្រោយពេលអាហារចូលដល់ក្រពះ ទ្វារក្រោមរបស់ក្រពះបិទ ។ ក្រពះចាប់ផ្ដើមកិនច្របាច់អាហារដោយការកន្ត្រាក់ អង្រួន ច្របល់ជាមួយរសក្រពះ ។ ការកិននេះប្រៀបដូចជាសាប៊ូ និងសម្លៀកបំពាក់ដែលច្របល់គ្នាក្នុងម៉ាស៊ីនបោកខោអាវ ។

## ខ. តាមបែបគីមី

នៅក្រោមស្រទាប់រំអិលនៃក្រពះ មានរន្ធជាច្រើនដែលតភ្ជាប់ទៅក្រពេញក្រពះ ។ ក្រពះមានក្រពេញបីប្រភេទដែលបញ្ចេញរសក្រពះ(រូបទី 2.6 ) ។ កាលណាអាហារធ្លាក់ដល់ក្រពះ វាភ្ញោចក្រពេញទាំងនោះឱ្យមានសកម្មភាព ។ ក្រពេញទី 1 បញ្ចេញអាស៊ីតក្លរីឌ្រិច (HCl) ដែលធ្វើឱ្យក្រពះផ្ទុកជាតិអាស៊ីតច្រើន ។ អាស៊ីតក្លរីឌ្រិចមាននាទី



*រូបទី2.6 : ខ្នាត់ថ្លៃក្រពះ*

- បញ្ឈប់សកម្មភាពអង់ស៊ីមអាមីឡាស ។
- បំបែកអាហារនិងសម្លាប់បាក់តេរីក្នុងអាហារ ។
- ធ្វើឱ្យអង់ស៊ីម ប៉ិបស៊ីនមានសកម្មភាពឡើង ។

ក្រពេញទី 2 បញ្ចេញអង់ស៊ីមប៉ិបស៊ីន ។ អង់ស៊ីមប៉ិបស៊ីនមានសកម្មភាពតែនៅក្នុងមជ្ឈដ្ឋានអាស៊ីតទេ ។ វាបំបែកប្រូតេអ៊ីនឱ្យទៅជាប៉ូលីប៉ិបទីត ។

ក្រពះបញ្ចេញអាស៊ីតក្លរីឌ្រិច ប្រហែល $2\ell$ ក្នុងមួយថ្ងៃ ។ ដូច្នេះតើហេតុអ្វីបានជាក្រពះមិនរលាកដោយសារជាតិអាស៊ីត ? ព្រោះប៊ីកាបូណាតក្នុងក្រពះជួយបន្សាបជាតិអាស៊ីត ហើយក្រពេញទី 3 របស់ក្រពះបញ្ចេញជាតិរំអិលដែលការពារផ្ទៃសាច់ដុំក្រពះ ។

អាហារត្រូវបានកិនក្នុងក្រពះរយៈពេលពី 2 ទៅ 6 ម៉ោង មានសភាពជាធាតុរាវ ហៅថា ស៊ីម (Chyme) ។ ប្រើសនៃទ្វារក្រោមក្រពះបើកឡើង អាហារក៏ធ្លាក់ទៅក្នុងពោះវៀនតូច ។

# 2. ដំណាក់កាលចុងក្រោយនៃការរំលាយអាហារនិងស្រូបអាហារ

## 2.1. ដំណាក់កាលចុងក្រោយនៃការរំលាយអាហារ

ដំណាក់កាលចុងក្រោយនៃការរំលាយអាហារប្រព្រឹត្តទៅនៅក្នុងពោះវៀនតូច ។ ពោះវៀនតូចជាបំពង់តូចដែលមានអង្កត់ផ្ចិត 2 – 3cm និងបណ្ដោយប្រវែងប្រហែល 7m ។ វាភ្ជាប់ពីក្រពះទៅពោះ

វៀនធំ ។ គេដាក់ឈ្មោះថាពោះវៀនតូច ព្រោះវាមានអង្កត់ផ្ចិតតូច ។ ក្នុងពោះវៀនតូចគ្មានការបំបែកអាហារតាមបែបមេកានិចទេ ។ ការបំបែកអាហារក្នុងពោះវៀនតូចមានរយៈពេលពី 3 – 6 ម៉ោង ។ អាហារដែលគិនបំបែកដោយក្រពះ(ស៊ីម)ធ្លាក់ចូលតល់ពោះវៀនតូចតាមទ្វារក្រោមក្រពះ ។ តល់ពោះវៀនជាផ្នែកខាងលើនៃពោះវៀនតូច ។ នៅទីនោះស៊ីមត្រូវបានច្របល់ជាមួយសារធាតុដែលបញ្ចេញដោយថ្លើម លំពែង និងពោះវៀន ។ សារធាតុទាំងនោះបង្កើតជាមជ្ឈដ្ឋានបាស (អាល់កាឡាំង) ដែលអាចបន្សាបជាតិអាស៊ីតនៅក្នុងអាហារនិងជួយរំលាយអាហារ ។

## ក. ថ្លើម



រូបទី2.7 : ទម្រង់តល់ពោះវៀន

ថ្លើមជាសរីរាង្គធំជាងគេបង្អស់ដែលស្ថិតនៅផ្នែកខាងស្តាំនៃពោះ ជាប់នឹងសន្ទះទ្រូង ។ វាមានពណ៌ក្រហមក្រម៉ៅទម្ងន់ប្រហែល 1 500g ។ ថ្លើមមាននាទីផលិតទឹកប្រមាត់ ។ ទឹកប្រមាត់មានពណ៌បៃតងលឿង ។ ទឹកប្រមាត់ជាមជ្ឈដ្ឋានបាសដែលផ្ទុកទឹកនិងសារធាតុរលាយអំបិលខនិជ កូឡេស្តេរ៉ុល អំបិលប្រមាត់(ជាតិពណ៌) ។ ទឹកប្រមាត់ស្តុកទុកក្នុងថង់ទឹកប្រមាត់ដែលស្ថិតនៅជាប់នឹងថ្លើម ។ កាលណាថង់ទឹកប្រមាត់កន្ត្រាក់ វាបញ្ចេញទឹកប្រមាត់ទៅក្នុងតល់ពោះវៀនតូចតាម បំពង់ទឹកប្រមាត់ ។ ក្នុងទឹកប្រមាត់គ្មានអង់ស៊ីមរំលាយអាហារទេ ដូចនេះវាមិនអាចបំបែកអាហារបានឡើយ ។ តាមលក្ខណៈរូប ទឹកប្រមាត់ជួយក្នុងការបំបែកខ្លាញ់ ។ អំបិលទឹកប្រមាត់បំបែកម៉ូលេគុលខ្លាញ់ឱ្យទៅជាតំណក់តូចៗ ដែលត្រូវបំបែកបន្តទៀតដោយរសលំពែង ។ យើងអាចប្រៀបធៀបសកម្មភាពទឹកប្រមាត់ទៅនឹងសកម្មភាពសាប៊ូដែលបំបែកខ្លាញ់ឱ្យទៅជាតំណក់តូចៗ ។ អំបិលទឹកប្រមាត់ធ្វើឱ្យមានអេមុលស្យុង( Emulsion)ខ្លាញ់ ។

## ខ. លំពែង

លំពែងជាសរីរាង្គត្រីកោណ ស្ថិតនៅក្រោមក្រពះ ។ ជាលិកាលំពែងផ្ទុកក្រពេញដែលបញ្ចេញរសលំពែង ។ កាលណាអាហារចូលក្នុងពោះវៀនតូច ក្រពេញលំពែងត្រូវបានភ្ញោច ហើយបញ្ចេញរសលំពែង តាមកូនបំពង់ចូលទៅក្នុងពោះវៀន ។ រសលំពែងមានអង់ស៊ីមច្រើនដែលរ៉ាប់រងការបំបែកគ្លុយស៊ីត ខ្លាញ់ និងប្រូតេអ៊ីន ។ អាមីឡាសបំបែកគ្លុយស៊ីត ប្រូតេអាស បំបែកប្រូតេអ៊ីន លីប៉ាសបំបែក

ខ្លាញ់ ។ លំពែងក៏មាននាទីផលិតអរម៉ូនអាំងស៊ុយលីនផងដែរ ។ អាំងស៊ុយលីន មាននាទីតម្រូវកម្រិតជាតិស្ករក្នុងឈាម ។ រសលំពែងមានផ្ទុកសូដ្យូមប៊ីកាបូណាត($Na_2CO_3$) សម្រាប់បន្សាបអាស៊ីតក្លរីឌ្រិចដែលមាននៅក្នុងអាហារនៅពេលវាធ្លាក់ទៅក្នុងតល់ពោះវៀន ។

### គ. ពោះវៀនតូច

ពោះវៀនតូច ជាសរីរាង្គចុងក្រោយដែលបំបែកអាហារ ។ ក្នុងពោះវៀនតូច ការបំបែកតាមបែបគីមីប្រព្រឹត្តទៅយ៉ាងសកម្មក្រោមអំពើរបស់អង់ស៊ីម ។ នៅស្រទាប់ខាងក្នុងនៃផ្ទៃពោះវៀន មានក្រពេញជាច្រើនដែលបញ្ចេញរសពោះវៀន ។ រសពោះវៀនមានអង់ស៊ីមរំលាយអាហារ ។

- **ការបំបែកគ្លុយស៊ីត**

អាមីដុង ចាប់ផ្ដើមបំបែកនៅក្នុងមាត់ ។ ប៉ុន្តែអាមីដុងមានតិចតួចប៉ុណ្ណោះដែលត្រូវបំបែកដោយអង់ស៊ីមអាមីឡាសក្នុងទឹកមាត់ ។ ក្នុងក្រពះគ្មានការបំបែកគ្លុយស៊ីតទេ ។ កាលណាគ្លុយស៊ីតធ្លាក់ក្នុងពោះវៀនតូច អាមីដុងដែលនៅសល់ត្រូវបំបែកជាម៉ាល់តូស ដោយអង់ស៊ីមអាមីឡាសលំពែង ។ ម៉ាល់តូសបំបែកជាគ្លុយកូសដោយម៉ាល់តាស ។ ឡាក់តូសបំបែកជាគ្លុយកូសនិងកាឡាក់តូសដោយឡាក់តាស ។ ស៊ុចក្រូសឬសាការ៉ូសបំបែកជាគ្លុយកូសនិងព្រុចតូសដោយស៊ុចក្រាស ។

$$\text{អាមីដុង} \xrightarrow{\text{អាមីឡាសលំពែង}} \text{ម៉ាល់តូស} \xrightarrow{\text{ម៉ាល់តាស}} \text{គ្លុយកូស}$$

$$\text{ឡាក់តូស} \xrightarrow{\text{ឡាក់តាស}} \text{គ្លុយកូស} + \text{កាឡាក់តូស}$$

$$\text{សាការ៉ូសឬស៊ុចក្រូស} \xrightarrow{\text{ស៊ុចក្រាស}} \text{គ្លុយកូស} + \text{ព្រុចតូស}$$

ដូចនេះផលិតផលចុងក្រោយនៃការបំបែកគ្លុយស៊ីត គឺស្ករងាយដែលមានគ្លុយកូស កាឡាក់តូស និងព្រុចតូស ។ ចំណែកឯសែលុយឡូសមិនត្រូវបានបំបែកទេ ។

- **ការបំបែកខ្លាញ់**

ទឹកប្រមាត់បំបែកខ្លាញ់ឱ្យទៅជាតំណក់ខ្លាញ់តូចៗនៅក្នុងទឹកដែលបង្កើតបានជាអេម៉ុលស្យុង ។ អេម៉ុលស្យុងខ្លាញ់ត្រូវបានបំបែកដោយអង់ស៊ីមលីប៉ាសរបស់រសលំពែងនិងរសពោះវៀនតូចឱ្យទៅជាអាស៊ីតខ្លាញ់និងគ្លីសេរ៉ុល ។

$$\text{ខ្លាញ់} \xrightarrow{\text{ទឹកប្រមាត់}} \text{អេម៉ុលស្យុងខ្លាញ់} \xrightarrow[\text{រសពោះវៀន}]{\text{លីប៉ាសលំពែង}} \text{អាស៊ីតខ្លាញ់} + \text{គ្លីសេរ៉ុល}$$

ដូចនេះផលិតផលចុងក្រោយនៃការបំបែកខ្លាញ់ គឺអាស៊ីតខ្លាញ់និងគ្លីសេរ៉ុល ។

• ការបំបែកប្រូតេអ៊ីន

ម៉ូលេគុលប្រូតេអ៊ីនខ្លះត្រូវបំបែកនៅក្នុងក្រពះ ។ ប្រូតេអ៊ីនខ្លះទៀតដែលមិនបានបំបែកធ្លាក់ចូលទៅក្នុងពោះវៀនតូច ។ នៅទីនោះ វាត្រូវបានបំបែកជាប៉ូលីប៉ិបទីតដោយអង់ស៊ីម ទ្រីបស៊ីន ។ ទ្រីបស៊ីនបានមកពីការបំប្លែងទ្រីបស៊ីណូសែន ដោយអង់ស៊ីមអង់តេរ៉ូគីណាសរបស់ពោះវៀន ។ ប៉ូលីប៉ិបទីតក៏ត្រូវបំបែកបន្តទៅទៀត ជាអាមីណូអាស៊ីតដោយអង់ស៊ីមអេរិបស៊ីន ។

ទ្រីបស៊ីណូសែន $\xrightarrow{\text{អង់តេរ៉ូគីណាស}}$ ទ្រីបស៊ីន

ប្រូតេអ៊ីន $\xrightarrow{\text{ទ្រីបស៊ីន}}$ ប៉ូលីប៉ិបទីត

ប៉ូលីប៉ិបទីត $\xrightarrow{\text{អេរិបស៊ីន}}$ អាមីណូអាស៊ីត

ដូចនេះលទ្ធផលចុងក្រោយនៃការបំបែកប្រូតេអ៊ីន គឺអាមីណូអាស៊ីត ។

ខាងក្រោមនេះជាតារាងសង្ខេបពីការរំលាយអាហារតាមបែបគីមីនៅក្នុងប្រដាប់រំលាយអាហាររបស់មនុស្ស ។

| សរីរាង្គ | សារធាតុបញ្ចេញ | ប្រភព | អង់ស៊ីម | សកម្មភាព |
|---|---|---|---|---|
| មាត់ | ទឹកមាត់ | ក្រពេញទឹកមាត់ | អាមីឡាស | អាមីដុង → ម៉ាល់តូស |
| ក្រពះ | រសក្រពះ | ក្រពេញក្រពះ | ប៉ិបស៊ីន | ប្រូតេអ៊ីន → ប៉ូលីប៉ិបទីត |
| ពោះវៀនតូច | ទឹកប្រមាត់ | ថ្លើម | | អេម៉ុលស្យុងខ្លាញ់ |
| | រសលំពែង | លំពែង | អាមីឡាស<br>ទ្រីបស៊ីន<br>លីប៉ាស | អាមីដុង → ម៉ាល់តូស<br>ប្រូតេអ៊ីន → ប៉ូលីប៉ិបទីត<br>ខ្លាញ់ → អាស៊ីតខ្លាញ់និងគ្លីសេរ៉ុល |
| | រសពោះវៀន | ក្រពេញពោះវៀន | អង់តេរ៉ូគីណាស<br>ម៉ាល់តាស<br>ឡាក់តាស<br>ស៊ុចក្រាស<br>អេរិបស៊ីន<br>លីប៉ាស | ទ្រីបស៊ីណូសែន → ទ្រីបស៊ីន<br>ម៉ាល់តូស → គ្លុយកូស<br>ឡាក់តូស → គ្លុយកូសនិងកាឡាក់តូស<br>ស៊ុចក្រូស → គ្លុយកូសនិងព្រុចតូស<br>ប៉ូលីប៉ិបទីត → អាមីណូអាស៊ីត<br>ខ្លាញ់ → អាស៊ីតខ្លាញ់និងគ្លីសេរ៉ុល |

ក្នុងពោះវៀនតូច អាហារត្រូវបានរុញច្រានយឺតៗ ដោយចលនាបេរីស្តាល់ស៊ីសអស់រយៈពេលជាច្រើនម៉ោង ។ ទន្ទឹមពេលនោះ សម្រូបអាហារក៏មានដំណើរការ ។ សារធាតុដែលមិនអាចស្រូបបានត្រូវបានបញ្ជូនទៅពោះវៀនធំ ដោយឆ្លងកាត់ផ្នែកមួយនៃចុងពោះវៀនតូច ហៅថាខ្នែងពោះវៀន ។ ខ្នែងពោះវៀនរបស់មនុស្សមានប្រវែងខ្លី ហើយគ្មានមុខងារអ្វីទេ ។ ផ្ទុយទៅវិញ វាអាចបង្កជំងឺម្យ៉ាងហៅថា ជំងឺរលាកខ្នែងពោះវៀន (appendicite) ។ សត្វស៊ីស្មៅមានខ្នែងពោះវៀនវែង ព្រោះវាមាននាទីជួយបំបែកសារធាតុសែលុយឡូស ។

## ឃ. ពោះវៀនធំ

កាលណាអាហារចាកចេញពីពោះវៀនតូច វាត្រូវធ្លាក់ទៅក្នុងពោះវៀនធំតាមប្រិសមួយ ។ ពោះវៀនធំជាសរីរាង្គចុងក្រោយនៃប្រដាប់រំលាយអាហារ ។ វាមានរាងជាបំពង់វែងប្រហែល 1.5m និងអង្កត់ផ្ចិតធំជាងអង្កត់ផ្ចិតពោះវៀនតូចពី 2 ទៅ 3 ដង ។ ក្នុងពោះវៀនធំគ្មានការបំបែកអាហារអ្វីទាំងអស់ ។ នៅទីនោះមានបាក់តេរីរស់នៅដោយពឹងពាក់សារធាតុដែលឆ្លងកាត់ពោះវៀនធំ ។ បាក់តេរីទាំងនោះមិនបង្កជំងឺទេ ផ្ទុយទៅវិញវាជួយបង្កើតវីតាមីនខ្លះ ដូចជាវីតាមីន K និងវីតាមីន B ជាដើម ។ វីតាមីនទាំងនេះ ត្រូវបានស្រូបដោយភ្នាសពោះវៀនធំចូលទៅក្នុងឈាមវិញ ។ លើសពីនេះទៀត បាក់តេរីជួយធ្វើឱ្យសារធាតុមិនរលាយទៅជារឹងដែលជាលទ្ធផលចុងក្រោយគឺ លាមក ។ សារធាតុដែលឆ្លងកាត់ពោះវៀនធំមាន ទឹក ស្លេស្ម អំបិលប្រមាត់ បាក់តេរី ផ្សិត និងអាហារមិនរលាយ ។ ពោះវៀនធំត្រូវបញ្ចប់ដោយចុងពោះវៀន ដែលនៅទីនោះអាហារមិនរលាយ ផ្តុំជាដុំលាមក ។ កាលណាចុងពោះវៀនកន្ត្រាក់ លាមកត្រូវបញ្ចេញពីសារពាង្គកាយតាមទ្វារធំ ដោយចលនាបេរីស្តាល់ស៊ីស ។ រយៈពេលអាហារឆ្លងកាត់ពោះវៀនធំ គឺពី 12 ទៅ 20 ម៉ោង ។

## 2.2. សម្រូបអាហារ

សម្រូបអាហារ ជាលំនាំមួយដែលសារធាតុចិញ្ចឹម (បានពីការបំបែកអាហារ) សាយឆ្លងកាត់ភ្នាសកោសិកាពោះវៀនតូចចូលទៅក្នុងឈាម ។ សម្រូបអាហារចែកចេញជាពីរដំណាក់កាល ។

### ក. សម្រូបអាហារនៅក្នុងពោះវៀនតូច

ផ្ទៃខាងក្នុងនៃពោះវៀនតូច មានភាពរដិបរដុបផុសឡើងច្រើនដូចម្រាមដៃគឺជ្រាំងពោះវៀន (រូបទី 2.8) ។ លក្ខណៈបែបនេះធ្វើឱ្យពោះវៀនតូចបង្កើនផ្ទៃសម្រូបអាហារបានធំ ។




*រូបទី 2.8 : ទម្រង់ភ្នាសពោះវៀនតូច*




*រូបទី 2.9 : ទម្រង់ជ្រាំងពោះវៀនតូច*

ជ្រាំងពោះវៀននីមួយៗពាសដោយស្រទាប់ជាលិកាអេពីល្យូមមួយស្រទាប់ សរសៃឈាម (អាកទែ វ៉ែន) និងសរសៃទឹករងៃ(រូបទី 2.9) ។ ផលនៃការរំលាយអាហាររួមមាន គ្លុយកូស អាមីណូអាស៊ីត អំបិលខនិជ វីតាមីន ជ្រាបចូលទៅក្នុងសរសៃឈាមដោយឆ្លងកាត់ជាលិកាអេពីតេល្យូមនៃជ្រាំងពោះវៀន ។ ឈាមដឹកនាំសារធាតុទាំងនេះទៅកាន់ផ្នែកផ្សេងៗនៃសារពាង្គកាយ ។ គ្លីសេរ៉ុលរលាយក្នុងទឹក ហើយសាយចូលទៅក្នុងជាលិកាអេពីតេល្យូម ។ អាស៊ីតខ្លាញ់ដែលបំបែកដោយអំបិលទឹកប្រមាត់បង្កើតជាសាប៊ូរលាយហើយសាយចូលទៅក្នុងជាលិកាអេពីតេល្យូមដែរ ។ នៅទីនោះសាប៊ូរលាយផ្សំឡើងវិញជាតំណក់ខ្លាញ់តូចៗជ្រាបចូលទៅក្នុងសរសៃឈាមទឹករងៃ ។

## ១. សម្រូបអាហារនៅក្នុងពោះវៀនធំ

យើងបានដឹងហើយថា សារធាតុនៅក្នុងពោះវៀនធំមានទឹកនិងសារធាតុមិនរលាយ ។ សារធាតុមិនរលាយត្រូវបានបញ្ចេញទៅក្រៅក្រោមទម្រង់ជាលាមក ។ ចំណែកទឹកនិងអំបិលខនិជត្រូវបានស្រូបចូលទៅក្នុងកោសិកានៃភ្នាសពោះវៀនធំ ។ ដូចនេះមុខងាររបស់ពោះវៀនធំ គឺសម្រូបទឹក អំបិលខនិជ និងការបញ្ចេញចោលនូវកាកសំណល់ ។ ប៉ុន្តែនៅពេលខ្លះ មុខងាររបស់ពោះវៀនធំត្រូវបានរំខាន ហើយមិនអាចស្រូបទឹកបាន ជាហេតុធ្វើឱ្យបរិមាណទឹកត្រូវបានបញ្ចេញយ៉ាងច្រើនជាមួយលាមក ។ បាតុភូតនេះហៅថា ជំងឺរាក(អាសន្នរោគក៏ជាប្រភេទជំងឺនេះដែរ) ។

## មេរៀនសង្ខេប

- ការរំលាយអាហារ ជាលំនាំនៃការបំបែកម៉ូលេគុលអាហារធំៗឱ្យទៅជាម៉ូលេគុលតូចៗដែលកោសិកាអាចស្រូបយកបាន ។
- ការរំលាយអាហារមានពីរបែប គឺការរំលាយតាមបែបមេកានិចនិងការរំលាយតាមបែបគីមី ។
- ក្នុងមាត់ អាហារត្រូវបានបំបែកដោយការទំពារនៃធ្មេញនិងដោយទឹកមាត់ ។
- ក្នុងក្រពះអាហារត្រូវបានគីនបំបែក ដោយសារការកន្ត្រាក់របស់សាច់ដុំក្រពះនិងដោយរសក្រពះ ។
- ក្នុងពោះវៀនតូច ការបំបែកអាហារធ្វើឡើងតាមបែបគីមីដោយរសរំលាយអាហារ ដែលបញ្ចេញដោយថ្លើម លំពែង ពោះវៀន ។
- សម្រូបអាហារ ជាលំនាំដែលសារធាតុចិញ្ចឹមត្រូវបានស្រូបចូលទៅក្នុងឈាម ។ សម្រូបអាហារប្រព្រឹត្តទៅនៅក្នុងពោះវៀនតូចនិងក្នុងពោះវៀនធំ ។
- ក្នុងពោះវៀនតូច គ្លុយកូស អាស៊ីតអាមីណេ វីតាមីន ត្រូវបានស្រូបដោយកោសិកាអេពីតេល្យូមនៃជ្រាំងពោះវៀនចូលក្នុងសរសៃឈាម ។ គ្លីសេរ៉ុល និងអាស៊ីតខ្លាញ់ត្រូវបានស្រូបចូលក្នុងសរសៃទឹករងៃ ។
- ក្នុងពោះវៀនធំ ទឹកនិងអំបិលខនិជ ត្រូវបានស្រូបចូលតាមភ្នាសកោសិកាពោះវៀនធំ ។ ឯសារធាតុមិនរលាយត្រូវបានបញ្ចេញមកក្រៅជាលាមក ។

## សំណួរនិងលំហាត់

1. ចូរប្រៀបធៀបការបំបែកអាហារតាមបែបមេកានិចនិងគីមី ដោយលើកយកឧទាហរណ៍មកបញ្ជាក់ ។
2. ចូរសង្ខេបការរំលាយអាហារតាមបែបគីមី ។
3. ហេតុដូចម្តេចបានជាជ្រាំងពោះវៀនបង្កើនផ្ទៃសម្រូបអាហារ ?
4. ចូរពណ៌នាពីទម្រង់ជ្រាំងពោះវៀន ។
5. តើរសរំលាយអាហារនិងអង់ស៊ីមខុសគ្នាដូចម្តេច ?
6. ចូរប្រៀបធៀបពោះវៀនធំនិងពោះវៀនតូច ។

# ពិសោធន៍ : វិធីបង្កើនល្បឿនរំលាយអាហារ

## 1. វត្ថុបំណង

- អនុវត្តវិធីបង្កើនល្បឿនរំលាយអាហារ
- បង្ហាញពីរបៀបបរិភោគអាហារ ដើម្បីងាយស្រួលក្នុងការរំលាយ
- រក្សាសុខភាព ជៀសវាងជំងឺក្រពះ និងពោះវៀន ។

## 2. សម្ភារៈ

កែវពីរ (ធំល្មម) ទឹក ជញ្ជីង ដុំស្ករស ស្ករសម៉ត់ ។

## 3. រំលឹកចំណេះដឹង

ការរំលាយអាហារ គឺជាការបំបែកម៉ូលេគុលអាហារធំៗឱ្យទៅជាម៉ូលេគុលតូចៗ ដែលអាចបន្សាយចូលក្នុងកោសិកាបាន ។ ការបំបែកអាហារតាមបែបមេកានិច ធ្វើឱ្យមានភាពងាយស្រួលដល់ការបំបែកអាហារតាមបែបគីមី ។

## 4. ដំណើរការពិសោធ

- វាស់ទឹកស្មើគ្នា សីតុណ្ហភាពដូចគ្នា ចាក់ចូលទៅក្នុងកែវទឹកទាំងពីរ ។
- ថ្លឹងស្ករម៉ត់និងដុំស្ករសក្នុងទម្ងន់ស្មើគ្នា ហើយចាក់ចូលក្នុងកែវទាំងពីរ ។
- ដៃម្ខាងកាន់កែវមួយ ដៃម្ខាងទៀតកាន់កែវមួយទៀត ។
- អង្រួនកែវទាំងពីរក្នុងរយៈពេលស្មើគ្នា ហើយក្នុងល្បឿនដូចគ្នា ។
- ដាក់កែវទាំងពីរនៅលើតុ រួចសង្កេត ហើយបំពេញតារាងខាងក្រោម

| | សភាពស្ករក្នុងកែវទី 1 | សភាពស្ករក្នុងកែវទី 2 |
|---|---|---|
| មុនពិសោធន៍ | | |
| ក្រោយពិសោធន៍ | | |

## 5. សំណួរពិភាក្សា

1. តើស្ករក្នុងកែវណាដែលរលាយអស់មុនគេ ? ហេតុអ្វី ?
2. ដើម្បីឱ្យអាហារដែលបរិភោគឆាប់រំលាយអស់ តើត្រូវធ្វើដូចម្ដេច ?

# សំណួរនិងលំហាត់ជំពូក 4

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1 ឌីសាការីតបំបែកជា

☐ក. ខ្លាញ់ ☐ខ. ម៉ូណូសាការីត ☐គ. ប្រូតេអ៊ីន ☐ឃ. សែលុយឡូស ។

2. សែលុយឡូស ដែលជាសារធាតុបង្កើតភ្នាសកោសិកាកើតពីម៉ូលេគុល

☐ក. ទឹក ☐ខ. អាមីណូអាស៊ីត ☐គ. អាមីដុង ☐ឃ. ស្ករ ។

3 លីពីតផ្អែតកើតពី

☐ក. បរិមាណ $O_2$ គ្រប់គ្រាន់ ☐ខ. សម្ព័ន្ធទ្វេ

☐គ. សម្ព័ន្ធទោល ☐ឃ. ចំនួន $H_2$ មិនគ្រប់

4. សត្វស្តុកគ្លុយកូសក្រោមរូបភាពជា

☐ក. អាមីដុង ☐ខ. សែលុយឡូស ☐គ. ATP ☐ឃ. គ្លីកូសែន ។

5 អាមីណូអាស៊ីតត្រីះទាំងអស់

☐ក. មានក្នុងរុក្ខជាតិ ☐ខ. សារពាង្គកាយអាចផលិតបាន

☐គ. មានក្នុងរបបអាហារ ☐ឃ. ផ្តល់ថាមពល ។

6. ខ្នាតនៃបរិមាណថាមពលក្នុងអាហារគឺ

☐ក. ATP ☐ខ. ឌីសាការីត ☐គ. ADN ☐ឃ. កាឡូរី ។

7 ក្នុងទឹកមាត់មានអង់ស៊ីមបំបែក

☐ក. ខ្លាញ់ ☐ខ. ប្រូតេអ៊ីន ☐គ. សែលុយឡូស ☐ឃ. អាមីដុង ។

8. ដុំអាហារផ្លាស់ទីតាមបំពង់អាហារដោយ

☐ក. ជាតិរំអិល ☐ខ. ចូលរួមពីអង់ស៊ីម

☐គ. ចលនាបេរីស្តាល់ស៊ីស ☐ឃ. ក្រពេញរំលាយអាហារ ។

9 ផលិតផលចុងក្រោយនៃការបំបែកគ្លុយស៊ីតគឺ

☐ក. អាមីណូអាស៊ីត ☐ខ. អាស៊ីតខ្លាញ់និងគ្លីសេរ៉ុល

☐គ. ស្ករងាយ ☐ឃ. វីតាមីន ។

10 ផលិតផលចុងក្រោយនៃការបំបែក លីពីតគឺ

☐ក. អាមីណូអាស៊ីត ☐ខ. ATP

☐គ. អាស៊ីតខ្លាញ់ និងគ្លីសេរ៉ុល ☐ឃ. អេមុលស្យុង ។

11 ផលិតផលចុងក្រោយនៃការបំបែក ប្រូតេអ៊ីនគឺ

☐ក. ប្រូតេអាស ☐ខ. អេរិបស៊ីន ☐គ. ទ្រីបស៊ីន ☐ឃ. អាមីណូអាស៊ីត ។

12. សម្រួបអាហារប្រព្រឹត្តទៅនៅ

☐ក. អណ្ដាត ☐ខ. ក្រពះ ☐គ. ពោះវៀន ☐ឃ. ជ្រាំងពោះវៀន ។

13. ពោះវៀនធំមាននាទី

☐ក. បំបែកអាហារជាកាកសំណល់ ☐ខ. ប្រមូលផ្ដុំជាលាមក

☐គ. សម្រួបអាហាររលាយ ☐ឃ. សម្លាប់បាក់តេរីដោយសារជាតុពុល ។

**II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ**

1. ជាសារធាតុចិញ្ចឹមដែលមិនផ្ដល់ថាមពល ទោះជាវាមានបរិមាណតិចតួចក៏ដោយតែមិនអាចអត់បានទេគឺ និង ។
2. ថាមពលបានមកពីការបំបែក ក្នុង ។ ថាមពលទាំងនេះស្ដុកទុកក្រោមទម្រង់ជា ។
3. ថ្វីបើអាស៊ីតក្លរីឌ្រិចក្នុងក្រពះអាចធ្វើឱ្យមានការរលាកភ្នាសក្រពះ តែវាក៏មាននាទីច្រើនដែរ ដូចជា បញ្ឈប់សកម្មភាព បំបែក និងធ្វើឱ្យអង់ស៊ីម មានសកម្មភាពឡើងវិញ ។
4. ទឹកប្រមាត់ជួយក្នុងការ ឱ្យទៅជា ។
5. រសលំពែងមាន ច្រើនដែលរាប់រងក្នុងការបំបែកអាហារ ។ លំពែងក៏មាននាទីផលិត ដើម្បីកម្រិតជាតិស្ករក្នុងឈាម ។
6. សម្រួបធ្វើនៅក្នុង ។ សារធាតុចិញ្ចឹមឆ្លងកាត់កោសិកាអេពីតេល្យូមនៃតាមវិធី ។

**III. ចូរឆ្លើយសំណួរខាងក្រោមនេះ**

1. ឧបមាថា គ្រូពេទ្យផ្ដល់ថ្នាំសម្លាប់បាក់តេរី ឱ្យលេបដើម្បីសម្លាប់បាក់តេរីឱ្យអស់ពីក្នុងខ្លួន ។ តើវាអាចឱ្យផលអ្វីខ្លះចំពោះសារពាង្គកាយ ។ ចូរពន្យល់ ។
2. ជំងឺក្ដៅ ឆ្អល់ចុងដង្ហើមកើតមាននៅពេលដែលអាស៊ីតក្នុងក្រពះឡើងទៅក្នុងបំពង់អាហារ ។ ចូរប្រើប្រាស់ចំណេះដឹងក្នុងការរំលាយអាហារ ពន្យល់ពីហេតុការដែលកើតមានឡើង ។ ដើម្បីបង្ការបញ្ហានេះ តើគេត្រូវធ្វើដូចម្ដេច ?
3. តើចលនាបេរីស្តាល់ស៊ីស ជួយបំលាស់ទីអាហារដូចម្ដេច ? តើចលនានេះប្រព្រឹត្តទៅនៅកន្លែងណាខ្លះ ?
4. សត្វដែលមានជីវិតក្រាំងតែងតែបរិភោគអាហារដែលមានកម្រិតខ្លាញ់ខ្ពស់មុនរដូវប្រាំង ។ តើវាមានប្រយោជន៍ដូចម្ដេចចំពោះសត្វនោះ ?

# ជំពូក 5 បណ្ដូរឧស្ម័ននិងការបញ្ចេញចោលរបស់សត្វ



បន្ទាប់ពីលេងកីឡារួច កីឡាករទាំងនេះបែកញើស ហើយហត់។ ពួកគេដកដង្ហើមញាប់ៗ ហើយស្រូបយកខ្យល់និងបញ្ចេញខ្យល់ពីសួត។ ដំណកដង្ហើមមានមុខងារសំខាន់ក្នុងដំណើរជីវិត។ ដំណកដង្ហើមធ្វើឱ្យមានបណ្ដូរឧស្ម័នក្នុងសារពាង្គកាយដោយស្រូបយកអុកស៊ីសែននិងបញ្ចេញចោលកាបូនឌីអុកស៊ីត ($CO_2$) ។ ប៉ុន្តែក្រៅពី $CO_2$ សារពាង្គកាយត្រូវបញ្ចេញនូវសារធាតុខ្លះទៀតតាមញើស និងទឹកនោម ។ នេះជាការបញ្ចេញចោល។

មេរៀនទី

# 1 បណ្តូរឧស្ម័នរបស់សត្វ

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីបណ្តូរឧស្ម័នរបស់ប្រូទីស ជន្លេន អ៊ិត សត្វល្អិត ត្រី និងមនុស្ស ។
- បង្ហាញលក្ខណ នៃស្រកីនិងកូនថង់សួតក្នុងការបំពេញនាទីបណ្តូរឧស្ម័ន ។
- បកស្រាយចលនាដង្ហើមចេញនិងដង្ហើមចូលរបស់មនុស្ស ។
- បង្ហាញធាតុបង្កនៃឈាមដែលមាននាទីដឹកនាំអុកស៊ីសែននិងកាបូនឌីអុកស៊ីត ។

ភាវៈរស់ស្ទើរទាំងអស់មិនអាចរស់នៅដោយមិនដកដង្ហើមទេ ។ សារពាង្គកាយត្រូវការស្រូបយកអុកស៊ីសែននិងបញ្ចេញកាបូនឌីអុកស៊ីតទៅមជ្ឈដ្ឋានវិញ សម្រាប់ដំណើរប្រព្រឹត្តទៅនៃគ្រប់សរីរាង្គទាំងអស់ ។ ចំពោះភាវៈរស់នីមួយៗ តើបណ្តូរឧស្ម័នប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ ?

## 1. បណ្តូរឧស្ម័នរបស់សត្វឥតឆ្អឹងកង

### 1.1. បណ្តូរឧស្ម័នរបស់ប្រូទីស

ចំពោះអាមីបនិងប៉ារ៉ាមេស៊ី បណ្តូរឧស្ម័នជាមួយមជ្ឈដ្ឋានប្រព្រឹត្តទៅយ៉ាងងាយ ។ ឧស្ម័នឆ្លងកាត់ភ្នាសកោសិកាចូលទៅក្នុងស៊ីតូប្លាសតាមបន្សាយ ។ អុកស៊ីសែនឬកាបូនឌីអុកស៊ីតធ្វើចលនាពីតំបន់កំហាប់ខ្ពស់ទៅតំបន់កំហាប់ទាប ។ ដូច្នេះអុកស៊ីសែននៃមជ្ឈដ្ឋាន(តំបន់មានកំហាប់អុកស៊ីសែនខ្ពស់) ភាយចូលទៅស៊ីតូប្លាស (តំបន់មានកំហាប់អុកស៊ីសែនទាប) ។ សារពាង្គកាយនៃប្រូទីសស្រូបយកអុកស៊ីសែនដោយផ្ទាល់ពីមជ្ឈដ្ឋានជុំវិញនិងបញ្ចេញកាបូនឌីអុកស៊ីតឱ្យទៅមជ្ឈដ្ឋានដោយផ្ទាល់តែម្តង ។



រូបទី 1.1: បណ្តូរឧស្ម័នរបស់ប្រូទីស

## 1.2. បណ្តូរឧស្ម័នរបស់អ៊ីត



រូបទី 1.2: បណ្តូរឧស្ម័នក្នុងអ៊ីត

សារពាង្គកាយអ៊ីតកើតឡើងពីកោសិកាពីរស្រទាប់ ។ កោសិកានៃស្រទាប់ទាំងពីរមានទំនាក់ទំនងដោយផ្ទាល់ជាមួយទឹក ។ ដូចនេះបណ្តូរឧស្ម័នក្នុងដង្ហើមអាចកើតមានដោយផ្ទាល់តាមបន្សាយរវាងកោសិកានៃសារពាង្គកាយនិងមជ្ឈដ្ឋាន ។ អ៊ីតគ្មានសរីរាង្គពិសេសសម្រាប់បណ្តូរឧស្ម័នទេ ។

## 1.3. បណ្តូរឧស្ម័នរបស់ជន្លេន



រូបទី 1.3: បណ្តូរឧស្ម័នជន្លេននិងបរិយាកាសខាងក្រៅ

ជន្លេនខុសប្លែកពីអ៊ីត ដោយកោសិកានៃសរីរាង្គផ្សេងៗរបស់វាមិនប៉ះផ្ទាល់ជាមួយមជ្ឈដ្ឋានទេ ។ ជន្លេនដកដង្ហើមតាមស្បែក ។ បើគេដាក់ជន្លេននៅក្នុងប្រអប់ដែក ឬដាក់វាចោលនៅហាលថ្ងៃ ស្បែកវាឡើងស្ងួត ហើយរឹងពេលនោះវាស្លាប់ភ្លាម ។ ដូច្នេះបណ្តូរឧស្ម័នប្រព្រឹត្តទៅបាន លុះត្រាតែស្បែកមានភាពសើម ។ ដោយជន្លេនមិនមានប្រដាប់ដង្ហើមក្រៅពីស្បែកទេ វានឹងស្លាប់ដោយថប់ដង្ហើម កាលណាស្បែកស្ងួត ។ ស្បែករបស់វាស្តើង ហើយសើមជានិច្ចដោយមានជាតិរំអិលដែលបញ្ចេញដោយកោសិកាពិសេស ។ បើយើងពិនិត្យរូបខ្វាត់ទទឹងជន្លេន យើងសង្កេតឃើញថា នៅក្រោមស្បែកមានសរសៃបួរមួយចំនួនធំ ។ អុកស៊ីសែនភាយចេញពីខ្យល់ដែលនៅក្នុងដី រួចឆ្លងតាមស្បែកសើមចូលទៅក្នុងសរសៃបួរ ។ ក្នុងសរសៃបួរ អេម៉ូក្លូប៊ីនចាប់យកអុកស៊ីសែន រួចដឹកនាំទៅកាន់កោសិកានៃសារពាង្គកាយ ។ ឈាមបោះបង់អុកស៊ីសែនឱ្យកោសិកា ហើយចាប់យកកាបូនឌីអុកស៊ីតមកវិញ ។ ឈាមដឹកនាំកាបូនឌីអុកស៊ីតទៅកាន់ស្បែក ។ កាបូនឌីអុកស៊ីតឆ្លងកាត់សរសៃបួរ ហើយភាយចេញពីស្បែកចូលក្នុងបរិយាកាសវិញ ។ ដូច្នេះដីសើមរក្សាស្បែកជន្លេនឱ្យសើមជានិច្ចនិងជួយឱ្យដំណាកដង្ហើមរបស់វាមានដំណើរការបានល្អ ។ ពេលអាកាសធាតុស្ងួត វាជីករន្ធយ៉ាងជ្រៅក្នុងដីរហូតដល់កន្លែងសើម ។ ភ្លៀងធ្វើឱ្យរន្ធជន្លេនលិចទឹក ជន្លេនតែងតែចាកចេញពីរន្ធរបស់វាដើម្បីគេចចេញពីការលង់ទឹកស្លាប់ ដោយសារទឹកមានអុកស៊ីសែនរលាយតិចពេក ។

## 1.4. បណ្ដូរឧស្ម័នរបស់សត្វល្អិត




*រូបទី 1.4: ប្រព័ន្ធបំពង់ខ្យល់របស់សត្វល្អិត*

តើសត្វល្អិតដកដង្ហើមរបៀបដូចម្ដេច ? បើយើងពិនិត្យមើលពោះសត្វល្អិតនៅផ្នែកចំហៀងទាំងសងខាងខ្លួនមានរន្ធតូចៗ គឺជារន្ធខ្យល់ ។ តពីរន្ធទាំងនេះ គឺជាបំពង់ខ្យល់តូចៗ ។ បំពង់ខ្យល់បែកមែកសាខា ជាបំពង់ល្អិតៗចូលទៅក្នុងសរីរាង្គទាំងឡាយ ។ ខ្យល់នៃមជ្ឈដ្ឋានចូលតាមរន្ធខ្យល់ទៅក្នុងបំពង់ខ្យល់ដែលបញ្ជូនខ្យល់ទៅដល់កោសិកានៃសរីរាង្គដោយផ្ទាល់ ។ ដូច្នេះគ្មានការដឹកជញ្ជូនឧស្ម័នតាមឈាមដូចជនេ្លនទេ ។ បណ្ដូរឧស្ម័ននៃសត្វល្អិតមិនអាស្រ័យលើប្រដាប់របត់ឈាមទេ ។ អុកស៊ីសែនភាយចេញពីបំពង់ខ្យល់ចូលទៅក្នុងកោសិកានៃសារពាង្គកាយ ឯកាបូនឌីអុកស៊ីតក៏ភាយចេញពីកោសិកាចូលក្នុងបំពង់ខ្យល់វិញដែរ ។ ខ្យល់ចូលនិងចេញពីប្រព័ន្ធបំពង់ខ្យល់ដោយសារការកន្ត្រាក់នៃសាច់ដុំទាំងអស់របស់សារពាង្គកាយ ។

# 2. បណ្ដូរឧស្ម័នរបស់សត្វឆ្អឹងកង

## 2.1. បណ្ដូរឧស្ម័នរបស់សត្វរស់នៅក្នុងទឹក (ត្រី)

ត្រីដកដង្ហើមតាមស្រកី ។ ស្រកីកើតឡើងពីបន្ទះពីរ បន្ទះនីមួយៗមានសរសៃស្រកីជាច្រើន ។ បន្ទះស្រកីទាំងពីរនេះភ្ជាប់ទៅនឹងឆ្អឹងមានរាងកោងដូចធ្នូ ។ ស្រកីជា ជាលិកាស្តើងដែលសម្បូរដោយសរសៃឈាម ។ ស្រកីនីមួយៗមានសរសៃស្រកីជាច្រើន ដូចនេះស្រកីទាំងអស់បង្កើតបានជាផ្ទៃដ៏ធំទូលាយសម្រាប់បណ្ដូរឧស្ម័ន ។ ត្រីដកដង្ហើមដោយទឹកហូរចូលក្នុងមាត់ ស្រោចស្រពលើស្រកី រួចចេញវិញតាមគម្របស្រកី ។ អុកស៊ីសែនដែលរលាយក្នុងទឹក ឆ្លងកាត់ស្រកីហើយចូលទៅក្នុងឈាម ។ ឈាមដឹកនាំអុកស៊ីសែនទៅគ្រប់កោសិកាទាំងអស់នៃសារពាង្គកាយ ។

ឈាមដឹកនាំកាបូនឌីអុកស៊ីតពីកោសិកាទៅកាន់ស្រកី ។ កាបូនឌីអុកស៊ីតចេញពីសរសៃឈាមក្នុងស្រកី ហើយភាយចូលក្នុងទឹក ។ នៅលើស្រកីត្រូវតែមានលំហូរទឹកឥតឈប់ឈរ ។ បើលំហូរទឹកត្រូវបញ្ឈប់ស្រកីនឹងស្ងួតហើយស្អិតជាប់គ្នា បណ្ដូរឧស្ម័នមិនអាចប្រព្រឹត្តទៅបានទេ សត្វនឹងត្រូវងាប់ដោយគ្មានអុកស៊ីសែន ។




*រូបទី 1.5: ស្រកីត្រី*

## 2.2. បណ្ដូរឧស្ម័នរបស់មនុស្ស

ដើម្បីឱ្យបានថាមពល កោសិកាក្នុងសារពាង្គកាយមនុស្សត្រូវការអុកស៊ីសែន។ តើអុកស៊ីសែនក្នុងបរិយាកាសអាចចូលទៅដល់កោសិកាយ៉ាងដូចម្ដេចដែរ ?

### ក. ចលនាដង្ហើម

ដើម្បីធានាឱ្យមានការផ្លាស់ប្ដូរខ្យល់ក្នុងសួត យើងត្រូវដកដង្ហើម។ ដំណកដង្ហើម ជាការឆ្លាស់គ្នាយ៉ាងទៀងទាត់នូវដំណើរពីរគឺ ដង្ហើមចូលនិងដង្ហើមចេញ។




**ក. ប្រអប់ទ្រូងនៅពេលដង្ហើមចូល** (មើលពីចំហៀង)

**ខ. ប្រអប់ទ្រូងនៅពេលដង្ហើមចេញ**

*រូបទី 1.6: បម្រែបម្រួលមាឌប្រអប់ទ្រូង*

បើយើងសង្កេតមនុស្សម្នាក់កំពុងដកដង្ហើមចូលយើងឃើញថា ប្រអប់ទ្រូងរបស់គេឡើងប៉ោង ។ ផ្ទុយទៅវិញប្រអប់ទ្រូងនោះផតចុះវិញ នៅពេលដង្ហើមចេញ ។ នៅពេលដកដង្ហើមចូល សាច់ដុំដង្ហើមកន្ត្រាក់ហើយទាញឆ្អឹងជំនីរឱ្យប៉ោងឡើង ឯសាច់ដុំសន្ទះទ្រូងក៏ស្រុតចុះ ធ្វើឱ្យប្រអប់ទ្រូងប៉ោងឡើង ។ ពេលនោះសួតដែលមានសភាពយឺត ហើយជាប់យ៉ាងជិតស្និទ្ធទៅនឹងផ្ទៃប្រអប់ទ្រូងដោយស្រោមសួតក៏រីកមាឌតាមប្រអប់ទ្រូង ។ ការរីកមាឌនេះបណ្តាលឱ្យខ្យល់ចូលទៅក្នុងសួត ។ ពេលដង្ហើមចេញ សាច់ដុំដែលទាញឆ្អឹងជំនីរក៏រលាមកវិញ ធ្វើឱ្យឆ្អឹងជំនីរស្រុតចុះ ឯសន្ទះទ្រូងក៏ប៉ោងឡើងវិញដែរ ។ ពេលនោះប្រអប់ទ្រូងនិងសួតរួមទំហំមកវិញ ដែលបណ្តាលឱ្យខ្យល់ចេញពីសួត ។ ដូច្នេះដង្ហើមចូលជាបាតុភូតសកម្ម ឯដង្ហើមចេញជាបាតុភូតអកម្ម ។

- **ចង្វាក់ដង្ហើម** : ចលនាដង្ហើមនីមួយៗ មានដង្ហើមចេញមួយនិងដង្ហើមចូលមួយ ។ ចង្វាក់ដង្ហើមជាចំនួនចលនាដង្ហើមដែលមានក្នុងមួយនាទី ។ មនុស្សពេញវ័យដែលសម្រាកមិនធ្វើការ មានចលនាដង្ហើមចំនួន 16ដងក្នុងមួយនាទី ។ ចង្វាក់ដង្ហើមប្រែប្រួលទៅតាមភេទ អាយុ និងសកម្មភាពការងារ ។



រូបទី 1.7: ចំណុះខ្យល់ក្នុងសួត

- **ចំណុះខ្យល់ដង្ហើម** : ចលនាដង្ហើមធម្មតាអាចឱ្យខ្យល់ចេញ ឬចូលបាន 0.5ℓ (ខ្យល់ធម្មតា) ។ ចលនាដង្ហើមចូលបង្ខំប្រព្រឹត្តទៅដោយឆន្ទៈរបស់យើងគឺ ប្រឹងដកដង្ហើមចូលឱ្យខ្លាំងៗ ។ ដង្ហើមចូលបង្ខំនេះអាចឱ្យខ្យល់ចូលបាន 1.5ℓ ។ ខ្យល់ 1.5ℓ នេះជាខ្យល់បង្គ្រប់ ។ បន្ទាប់ពីចលនាដង្ហើមចូលធម្មតា បើយើងខំដកដង្ហើមចេញបង្ខំ យើងបញ្ចេញបានខ្យល់ធម្មតា 0.5ℓ និងខ្យល់ 1.5ℓ បន្ថែមទៀត ។ ខ្យល់ 1.5ℓ ជាខ្យល់បម្រុង ។ បន្ទាប់ពីចលនាដង្ហើមចូលបង្ខំ បើគេដកដង្ហើមចេញបង្ខំគេអាចបញ្ចេញខ្យល់បាន

ខ្យល់ចេញចូលធម្មតា0.5ℓ + ខ្យល់បង្គ្រប់ 1.5ℓ + ខ្យល់បម្រុង 1.5ℓ = 3.5ℓ ។

ខ្យល់ 3.5ℓ ដែលអាចផ្លាស់ប្តូរបានមានឈ្មោះថា ចំណុះខ្យល់ជីវិត ។ មាឌខ្យល់នេះអាចប្រែប្រួលតាមមនុស្សម្នាក់ៗ ។ ក្នុងសួតមានខ្យល់ 1.5ℓ ដែលគេមិនអាចបញ្ចេញមកក្រៅបាន ទោះជាគេខំប្រឹងបញ្ចេញយ៉ាងណាក៏ដោយ ។ ខ្យល់ 1.5ℓ នេះជាខ្យល់សល់ក្នុងសួត ។

ចំណុះខ្យល់សរុបក្នុងសួតគឺ ចំណុះខ្យល់ជីវិត 3.5ℓ +ខ្យល់សល់ 1.5ℓ = 5ℓ

ចលនាដង្ហើមធម្មតាប្រព្រឹត្តទៅដោយស្វ័យប្រវត្តិ ។ ចលនាអឆន្ទៈនេះត្រួតពិនិត្យដោយមជ្ឈមណ្ឌលប្រសាទដែលស្ថិតនៅខួរក្បាលកញ្ចឹងក ។

## ១. ដំណើរខ្យល់ក្នុងប្រដាប់ដង្ហើម




*រូបទី 1.8: ប្រដាប់ដង្ហើមមនុស្ស*

ខ្យល់ចូលតាមរន្ធច្រមុះ ហើយឆ្លងកាត់ផ្លូវដង្ហើមដែលមាន

- រូងច្រមុះដែលពាសដោយភ្នាសសើម ។ លើភ្នាសសើមមានរោម ។
- ដើមកជាកន្លែងដែលផ្លូវដង្ហើមនិងផ្លូវរំលាយអាហារប្រសព្វគ្នា ។
- បំពង់សំឡេង ជាប្រអប់ឆ្អឹងខ្ចីមួយដែលលយចេញមកលើបំពង់កហៅថា គ្រាប់ពោន (ឃើញចំពោះបុរស) ។ ក្នុងប្រអប់នេះមានខ្សែសំឡេងដែលអាចញ័រ ហើយបង្កើតបានជាសំឡេង ។
- បំពង់ខ្យល់ដែលបែកជាទងសួតពីរ ។ ទងសួតបែកមែកសាខាជាកូនទងសួត ។ នៅចុងទងសួតនីមួយៗមានថង់សួតដែលមានកូនថង់សួតជាច្រើន ។ សួតនីមួយៗស្រោបដោយថង់មួយហៅថាស្រោមសួត ។ ស្រោមសួតមានពីរស្រទាប់គឺស្រទាប់ក្នុងនៅជិតជាប់ផ្ទាល់នឹងសួតនិងស្រទាប់ក្រៅនៅជិតជាប់នឹងប្រអប់ទ្រូង ។ ដូចនេះសួតត្រូវបានភ្ជាប់យ៉ាងមាំទៅនឹងប្រអប់ទ្រូង ។ នៅចន្លោះស្រទាប់ទាំងពីរនៃស្រោមសួត មានទឹកស្រោមសួត ។

**តារាងទី I សមាសភាពឧស្ម័នក្នុងខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល**

| ខ្យល់ $100cm^3$ | អុកស៊ីសែន | កាបូនឌីអុកស៊ីត | អាសូត | ទឹក |
|---|---|---|---|---|
| ខ្យល់ដង្ហើមចូល | $21cm^3$ | $0.3cm^3$ | $79cm^3$ | អថេរ |
| ខ្យល់ដង្ហើមចេញ | $16cm^3$ | $5cm^3$ | $79cm^3$ | ឆ្អែត |

តារាងទី 2 មានឧស្ម័នក្នុងឈាមចូលសួតនិងឈាមចេញពីសួត

| មានឧស្ម័នក្នុងឈាម $100cm^3$ | អុកស៊ីសែន | កាបូនឌីអុកស៊ីត |
|---|---|---|
| ឈាមចូលក្នុងសួត | $15cm^3$ | $53cm^3$ |
| ឈាមចេញពីសួត | $20cm^3$ | $49cm^3$ |

បើពិនិត្យតារាងប្រៀបធៀបអត្រាឧស្ម័នអុកស៊ីសែនមានក្នុងខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល (តារាងទី 1) យើងសង្កេតឃើញថា ក្នុងខ្យល់ដង្ហើមចេញមានអុកស៊ីសែនតិចជាងខ្យល់ដង្ហើមចូល ។ ដូច្នេះសារពាង្គកាយបានរក្សាអុកស៊ីសែនទុក ។

បើយើងប្រៀបធៀបបរិមាណអុកស៊ីសែនក្នុងឈាម ដែលចូលក្នុងសួតនិងឈាមដែលចេញពីសួត(តារាងទី 2) យើងសង្កេតឃើញថាឈាមដែលចេញពីសួតមានបរិមាណអុកស៊ីសែនច្រើនជាងឈាមដែលចូលក្នុងសួត ។ ដូច្នេះយើងសន្និដ្ឋានថា អុកស៊ីសែនដែលចេញពីសួតបានចូលទៅក្នុងឈាម ។ ផ្ទុយទៅវិញ ខ្យល់ដង្ហើមចេញមានបរិមាណកាបូនឌីអុកស៊ីតច្រើនជាងខ្យល់ដង្ហើមចូល ហើយបរិមាណកាបូនឌីអុកស៊ីតក្នុងឈាមចេញពីសួតតិចជាងឈាមដែលចូលក្នុងសួត ។ ឈាមបានបោះបង់កាបូនឌីអុកស៊ីតឱ្យទៅសួត ។ ដូចនេះមានបណ្តូរឧស្ម័នអុកស៊ីសែននិងកាបូនឌីអុកស៊ីតរវាងសួតនិងឈាម ។ ក្នុងសួត តើបណ្តូរឧស្ម័នប្រព្រឹត្តទៅយ៉ាងដូចម្តេច ?

ខ្យល់ដែលយើងដកដង្ហើមចូល ធ្វើដំណើរទៅដល់កូនថង់សួត ។ កូនថង់សួតនីមួយៗមានភ្នាសយ៉ាងស្តើង ហើយរុំព័ទ្ធទៅដោយបណ្តាញសរសៃឫសយ៉ាងញឹក ។ ដូច្នេះកូនថង់សួតនីមួយៗប៉ះគ្នាយ៉ាងជិតស្និទ្ធជាមួយសរសៃឫស ដែលមានភ្នាសស្តើងដូចៗគ្នា ។ សួតទាំងពីរមានកូនថង់សួតប្រហែល 300 លាន បើគិតជាផ្ទៃសរុបស្មើនឹង $70m^2$ ចំពោះមនុស្សពេញវ័យ ។ បាតុភូតបណ្តូរឧស្ម័នកើតឡើងនៅកូនថង់សួតនោះ ។ ឧស្ម័នឆ្លងកាត់ភ្នាសកូនថង់សួតនិងភ្នាសសរសៃឫសតាមបន្សាយ ។ អុកស៊ីសែនចេញពីកូនថង់សួត(មជ្ឈដ្ឋានដែលមានកំហាប់អុកស៊ីសែនខ្ពស់)ចូលទៅក្នុងសរសៃឫស (មជ្ឈដ្ឋានដែលមានកំហាប់អុកស៊ីសែនទាប) ។ ផ្ទុយទៅវិញ $CO_2$ ចេញពីសរសៃឫស(មជ្ឈដ្ឋានមានកំហាប់ $CO_2$ ខ្ពស់) ហើយចូលទៅក្នុងកូនថង់សួត (មជ្ឈដ្ឋានមានកំហាប់ $CO_2$ ទាប) ។

កូនថង់សួតមានផ្ទៃប៉ះយ៉ាងធំធេងជាមួយសរសៃឫសឈាម ។ ម្យ៉ាងទៀតភ្នាសកូនថង់សួតនិងភ្នាសសរសៃឫសមានកម្រាស់ស្តើងណាស់ (មិនលើសពី 0.5 មីក្រូម៉ែត្រ) ។ លក្ខណៈទាំងពីរនេះ ធ្វើឱ្យបណ្តូរឧស្ម័នប្រព្រឹត្តទៅយ៉ាងងាយ ។




រូបទី 1.9: ថង់សួតនីមួយៗព័ទ្ធជុំវិញដោយបណ្ដាញសរសៃប្ញូរឈាម




រូបទី 1.10: បណ្ដូរឧស្ម័នក្នុងកូនថង់សួត

លក្ខខណ្ឌពីរដែលធ្វើឱ្យបណ្ដូរឧស្ម័នប្រព្រឹត្តទៅបានគឺ

- ដង្ហើមចេញនិងដង្ហើមចូលដែលធ្វើឱ្យមានបំលាស់ប្ដូរខ្យល់ក្នុងសួត ។ បាតុភូតនេះនាំមកនូវអុកស៊ីសែននិងបញ្ចេញចោលនូវកាបូនឌីអុកស៊ីត ។
- ដំណើរឈាមក្នុងសរសៃប្ញូរដែលនាំមកនូវកាបូនឌីអុកស៊ីតនិងដឹកយកអុកស៊ីសែនទៅវិញ ។

## គ. បណ្ដូរឧស្ម័នក្នុងសរីរាង្គ

| ក្នុងឈាម $100cm^3$ | អុកស៊ីសែន | កាបូនឌីអុកស៊ីត |
|---|---|---|
| ឈាមចូលក្នុងសរីរាង្គ | $20cm^3$ | $40cm^3$ |
| ឈាមចេញពីសរីរាង្គ | $12cm^3$ | $48cm^3$ |

តារាងទី៣ បរិមាណឧស្ម័នមានក្នុងឈាមចូលនិងឈាមចេញពីសរីរាង្គ

តារាងទី 3 បង្ហាញឱ្យឃើញថា ឈាមចេញពីសរីរាង្គមានបរិមាណអុកស៊ីសែនថយចុះ ហើយបរិមាណកាបូនឌីអុកស៊ីតកើនឡើង ។ ដូចនេះក្នុងសរីរាង្គមានបណ្ដូរឧស្ម័នរវាងកោសិកានៃសរីរាង្គនិងសរសៃប្ញូរតាមរយៈ ធាតុរាវ ឈាមបោះបង់អុកស៊ីសែនឱ្យទៅសរីរាង្គ ហើយទទួលយកកាបូនឌីអុកស៊ីតពីសរីរាង្គវិញ ។

បើគេវាស់បរិមាណគ្លុយកូសក្នុងឈាម ដែលចូលក្នុងសាច់ដុំនិងនៅក្នុងឈាមដែលចេញពីសាច់ដុំ គេសង្កេតឃើញថា ឈាមចូលក្នុងសាច់ដុំមានបរិមាណគ្លុយកូសច្រើនជាងឈាមដែលចេញពីសាច់ដុំ ។ ដូច្នេះកោសិកាក៏ត្រូវការប្រើប្រាស់គ្លុយកូសដែរ ។

ហេតុអ្វីបានជាកោសិកាត្រូវការអុកស៊ីសែននិងគ្លុយកូស? ដំណើរប្រព្រឹត្តនៃសរីរាង្គក្នុងសារពាង្គកាយត្រូវការថាមពល ។ ដើម្បីឱ្យបានថាមពលនេះ កោសិកាបំបែកគ្លុយកូស ឬអាហាររលាយផ្សេងៗទៀតឱ្យទៅជាម៉ូលេគុលតូចៗ ។ ការបំបែកគ្លុយកូសដោយមានវត្តមានអុកស៊ីសែនប្រព្រឹត្តទៅតាម

ប្រតិកម្មគីមីជាច្រើន ។ អង់ស៊ីមយ៉ាងប្រភេទផ្សេងៗមាននាទីជម្រុញប្រតិកម្មគីមីទាំងនេះ ។ លទ្ធផលចុងក្រោយ គឺទឹកនិងកាបូនឌីអុកស៊ីត ។ ដំណើរបំបែកគ្លុយកូសដោយមានវត្តមាននៃអុកស៊ីសែន ហើយផ្តល់ថាមពលសម្រាប់កោសិកាហៅថា ដង្ហើមកោសិកា ។

## ឃ. នាទីឈាមក្នុងដំណើរឧស្ម័ន

តើធាតុបង្កណាមួយនៃឈាមដែលមាននាទីដឹកនាំឧស្ម័នអុកស៊ីសែននិងកាបូនឌីអុកស៊ីត ?

**ដំណឹកនាំអុកស៊ីសែន**

អេម៉ូគ្លូប៊ីន ជាប្រូតេអ៊ីនមានធាតុដែក ។ អាតូមដែកអាចភ្ជាប់ទៅនឹងម៉ូលេគុលអុកស៊ីសែន ។ ក្នុងមជ្ឈដ្ឋានមានអុកស៊ីសែនច្រើន អេម៉ូគ្លូប៊ីនផ្សំជាមួយអុកស៊ីសែនបង្កើតបានជាអុកស៊ីអេម៉ូគ្លូប៊ីន ដែលមានពណ៌ក្រហមស្រស់ ។

$$\underset{\text{អេម៉ូគ្លូប៊ីន}}{Hb} + \underset{\text{អុកស៊ីសែន}}{O_2} \longrightarrow \underset{\text{អុកស៊ីអេម៉ូគ្លូប៊ីន}}{HbO_2}$$

ក្នុងមជ្ឈដ្ឋានខ្សត់អុកស៊ីសែន អុកស៊ីអេម៉ូគ្លូប៊ីនបំបែក រំដោះអុកស៊ីសែន ហើយប្លែងជា អេម៉ូគ្លូប៊ីនពណ៌ក្រហមក្រម៉ៅវិញ ។

$$\underset{\text{អុកស៊ីអេម៉ូគ្លូប៊ីន}}{HbO_2} \longrightarrow \underset{\text{អេម៉ូគ្លូប៊ីន}}{Hb} + \underset{\text{អុកស៊ីសែន}}{O_2}$$

ដូចនេះអេម៉ូគ្លូប៊ីនមាននាទីដឹកនាំអុកស៊ីសែនពីសួតទៅកាន់កោសិកានៃសរីរាង្គកាយ ។

នៅក្នុងសរសៃឈាមតូចៗនៃសួត អេម៉ូគ្លូប៊ីនផ្សំជាមួយអុកស៊ីសែន ហើយបង្កើតបានជាអុកស៊ីអេម៉ូគ្លូប៊ីន ។ ដូច្នេះឈាមដែលចេញពីសួត ហើយចូលសរីរាង្គវិញ មានពណ៌ក្រហមស្រស់ ។ ក្នុងសរសៃឈាមតូចៗនៃសរីរាង្គ អុកស៊ីអេម៉ូគ្លូប៊ីនបំបែក ហើយរំដោះអុកស៊ីសែន ។ បន្ទាប់មកអុកស៊ីសែនសាយចូលក្នុងកោសិកា ។ ដូចនេះឈាមដែលចេញពីសរីរាង្គ ហើយត្រឡប់ទៅសួតវិញមានពណ៌ក្រហមក្រម៉ៅ ។

បរិមាណតិចតួចរបស់អុកស៊ីសែនរលាយក្នុងប្លាស្មា ។ ដូច្នេះប្លាស្មាអាចដឹកនាំអុកស៊ីសែនបានបន្តិចបន្តួចដែរ ។

**ដំណឹកនាំកាបូនឌីអុកស៊ីត :** ប្លាស្មានៃឈាមបង្កឡើងដោយទឹក 90 % ។ កាបូនឌីអុកស៊ីតអាចរលាយក្នុងទឹកបានប្រហែល 30 ដងច្រើនជាងអុកស៊ីសែន ។ ដូច្នេះប្លាស្មាអាចដឹកនាំកាបូនឌីអុកស៊ីតបាន ។ ឈាមដឹកនាំកាបូនឌីអុកស៊ីតតាមរបៀបបីយ៉ាង :

- ប្រហែលជា 70 % នៃកាបូនឌីអុកស៊ីតត្រូវដឹកនាំតាមប្លាស្មា ក្រោមរូបរាងជាអ៊ីយ៉ុងកាបូណាត $HCO_3^-$ ។ កាបូនឌីអុកស៊ីតផ្សំជាមួយនឹងទឹកបង្កើតជាអាស៊ីតកាបូនិច

$$CO_2 + H_2O \longrightarrow H_2CO_3$$

អាស៊ីតកាបូនិចបំបែកយ៉ាងរហ័សជាអ៊ីយ៉ុង $H^+$ និង $HCO_3^-$

$$H_2CO_3 \longrightarrow H^+ + HCO_3^-$$

- ប្រហែលជា 10 % នៃកាបូនឌីអុកស៊ីតរលាយដោយផ្ទាល់ក្នុងប្លាស្មាតែម្តង
- អេម៉ូក្លូប៊ីននៃគោលិកាក្រហមដឹកនាំកាបូនឌីអុកស៊ីតបានមួយផ្នែកដែរ ។

ក្នុងសរសៃបូរនៃសរីរាង្គ អេម៉ូក្លូប៊ីនភ្ជាប់ជាមួយកាបូនឌីអុកស៊ីត ហើយបង្កើតជាកាបូស៊ីអេម៉ូក្លូប៊ីន ។ ក្នុងសរសៃបូរនៃសួត កាបូស៊ីអេម៉ូក្លូប៊ីនអាចបំបែក ហើយបញ្ចេញកាបូនឌីអុកស៊ីតវិញ ។

$$Hb + CO_2 \longrightarrow HbCO_2$$

អេម៉ូក្លូប៊ីន កាបូនឌីអុកស៊ីត កាបូស៊ីអេម៉ូក្លូប៊ីន

## ង. គ្រោះថ្នាក់បណ្តាលមកពីឧស្ម័នកាបូនម៉ូណូអុកស៊ីត (CO)

កាបូនម៉ូណូអុកស៊ីត ជាឧស្ម័នពុល គ្មានក្លិន និងគ្មានពណ៌ ។ វាកើតឡើងនៅពេលចំហេះសមាសធាតុកាបូន (ឧស ឬ ធ្យូង) ប្រព្រឹត្តទៅដោយមានអុកស៊ីសែនមិនគ្រប់គ្រាន់ ។ ឧស្ម័ននេះភ្ជាប់ជាមួយនិងអេម៉ូក្លូប៊ីន ហើយបង្កើតជាសមាសធាតុថេរដែលមិនអាចបំបែកបាន ។ ដូច្នេះអេម៉ូក្លូប៊ីនបាត់បង់លទ្ធភាពក្នុងការដឹកនាំអុកស៊ីសែន ។ កាលណាមនុស្សដកដង្ហើមស្រូបយកខ្យល់ដែលមានកាបូនម៉ូណូអុកស៊ីត គោលិកាក្រហមដឹកនាំបានអុកស៊ីសែនកាន់តែតិចទៅៗ ។ CO អាចបង្កគ្រោះថ្នាក់ឱ្យមនុស្សស្លាប់បាន ។

## ច. គ្រោះថ្នាក់បណ្តាលមកពីថ្នាំជក់

ក្នុងផ្សែងបារីមានសារធាតុគីមីជាង 4 000 ប្រភេទ ។ ភាគច្រើនជាធាតុពុលនិងធាតុដែលធ្វើឱ្យរលាកកោសិកា ។ ក្នុងចំណោមនោះមានធាតុគីមី 69 ប្រភេទ ដែលបណ្តាលឱ្យកើតជំងឺមហារីក ។ ធាតុពុលខ្លាំងជាងគេក្នុងផ្សែងបារីមាន

- **នីកូទីន** (Nicotine) នីកូទីនជាសារធាតុពុលនិងញៀនខ្លាំង ។ បើគេចាក់បញ្ចូលវាទៅក្នុងខ្លួនកណ្តុរមួយតំណក់ វានឹងស្លាប់ភ្លាម ។ម្យ៉ាងទៀតនីកូទីនបណ្តាលឱ្យមានការកន្ត្រាក់នៃទងសួត និងរាំងដំណើរខ្យល់ក្នុងផ្លូវដង្ហើម ។
- **សារធាតុជ័រថា** (Tar) ជ័រថា ជាសារធាតុគីមីពុល ពណ៌ខ្មៅស្អិត ។ វាបណ្តាលឱ្យកើតមហារីកសួត រលាកទងសួត ហើមសួតនិងជំងឺផ្លូវដង្ហើមដទៃទៀត ។ វាធ្វើឱ្យក្រចកដៃ ធ្មេញ និងជាលិកាសួតឡើងពណ៌លឿង ។
- **កាបូនម៉ូណូអុកស៊ីត** (Carbone monooxyde) វាទៅភ្ជាប់និងអេម៉ូក្លូប៊ីនដែលធ្វើឱ្យគោលិកាក្រហមបាត់បង់លទ្ធភាពក្នុងការដឹកនាំអុកស៊ីសែន ។

ដូច្នេះការជក់បារីអាចធ្វើឱ្យមានជំងឺផ្លូវដង្ហើម ដូចជាមហារីកសួត មហារីកទងសួត។ ជំងឺរលាកសួតរ៉ាំរ៉ៃនិងជំងឺអំភីស៊ែមកើតចំពោះអ្នកជក់បារី 6 ដងច្រើនជាងអ្នកមិនជក់បារី ។

អ្នកជក់បារីមិនត្រឹមតែប្រឈមមុខនឹងជំងឺខាងលើតែម្នាក់ឯងទេ តែអ្នកនៅក្បែរខ្លួនគេក៏ស្រូបយកផ្សែងបារី ហើយអាចមានជំងឺផ្លូវដង្ហើមបានដែរ ។

## មេរៀនសង្ខេប

- បណ្ដូរឧស្ម័ន ជាលំនាំមួយបែបដែលសារពាង្គកាយចាប់យកអុកស៊ីសែនពីបរិយាកាស ហើយបញ្ចេញកាបូនឌីអុកស៊ីតទៅបរិយាកាសវិញ ។
- ចំពោះប្រូទីសនិងអ៊ិត បណ្ដូរឧស្ម័នប្រព្រឹត្តទៅដោយផ្ទាល់រវាងកោសិកានិងមជ្ឈដ្ឋាន ។
- ចំពោះជន្លេន បណ្ដូរឧស្ម័នប្រព្រឹត្តទៅដោយឆ្លងកាត់ស្បែកសើម ដែលមានសរសៃប្ញូរ ។
- ចំពោះសត្វល្អិតវិញប្រដាប់របត់ឈាមមិនមាននាទីដឹកនាំឧស្ម័នទេ ។
- ចំពោះត្រី សរីរាង្គដង្ហើម គឺស្រកី ។ ស្រកីជាផ្ទៃប៉ះយ៉ាងធំរវាងឈាមនិងទឹក ។
- ប្រដាប់ដង្ហើមមនុស្សមានសួតនិងប្រព័ន្ធបំពង់ដែលដឹកនាំឧស្ម័នចូលនិងចេញពីសួត ។
- ចលនាដង្ហើមចូលនិងចលនាដង្ហើមចេញ ធ្វើឱ្យមានបំលាស់ប្តូរខ្យល់ក្នុងថង់សួត ។
- បណ្ដូរឧស្ម័នដង្ហើមប្រព្រឹត្តទៅរវាងខ្យល់ក្នុងកូនថង់សួតនិងឈាមក្នុងសរសៃប្ញូរ ។ កូនថង់សួតដែលបង្កើតជាផ្ទៃប៉ះយ៉ាងធំជាមួយសរសៃប្ញូរឈាម ។ បណ្ដូរឧស្ម័ននេះប្រព្រឹត្តទៅលុះត្រាតែមានចលនាដង្ហើម ដែលផ្លាស់ប្តូរខ្យល់ក្នុងសួតនិងដំណើររបត់ឈាមដែលដឹកនាំឧស្ម័នដង្ហើម ។
- នៅនីវ៉ូសរីរាង្គមានបណ្ដូរឧស្ម័នរវាងកោសិកានិងឈាម ។ កោសិកាដកដង្ហើមដោយចាប់យក $O_2$ ពីឈាម និងបោះបង់ $CO_2$ ឱ្យទៅឈាមវិញ ។

## ? សំណួរនិងលំហាត់

1. ចូរពណ៌នាអំពីបណ្ដូរឧស្ម័នរបស់ប្រូទីស ។ តើបណ្ដូរឧស្ម័នរបស់អ៊ិតនិងជន្លេនខុសគ្នាត្រង់ណា ?
2. ចូរពណ៌នាអំពីទម្រង់ស្រកីរបស់ត្រី ។ ចូរពណ៌នាអំពីបណ្ដូរឧស្ម័នរបស់ត្រី ។
3. ចំពោះសត្វល្អិត តើសរីរាង្គអ្វីខ្លះដែលរ៉ាប់រងដំណើរដង្ហើម ?
4. ចូរពណ៌នាអំពីផ្លូវដង្ហើមរបស់មនុស្ស ។
5. នៅពេលចេញពីសរីរាង្គ តើឈាមមានពណ៌ដូចម្តេច ? ពីព្រោះអ្វី ?
6. ចំពោះមនុស្ស តើបណ្ដូរឧស្ម័នប្រព្រឹត្តទៅនៅកន្លែងណាខ្លះ ?
7. តើថង់សួតមានលក្ខណៈពិសេសដូចម្តេចខ្លះ ក្នុងបណ្ដូរឧស្ម័ន ?
8. តើធាតុបង្កណាមួយនៃឈាមដែលមាននាទីដឹកនាំអុកស៊ីសែន ? កាបូនឌីអុកស៊ីត ?

# ពិសោធន៍ : ប្រៀបធៀបខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល

ទឹកកំបោរថ្លាជាសារធាតុចង្អុលបង្ហាញវត្តមានកាបូនឌីអុកស៊ីត ពីព្រោះទឹកកំបោរមានប្រតិកម្មជាមួយកាបូនឌីអុកស៊ីតដែលបង្កជាកករតូចៗ ។ដូច្នេះទឹកកំបោរថ្លាក្លាយជាល្អក់បើមានវត្តមានកាបូនឌីអុកស៊ីត $Ca(OH)_2 + CO_2 \longrightarrow CaCO_3\downarrow + H_2O$

## 1. វត្ថុបំណង

ធ្វើអត្តសញ្ញាណកាបូនឌីអុកស៊ីត ។ ប្រៀបធៀបខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល ។

## 2. សម្ភារៈ

ទឹកកំបោរថ្លា បំពង់សាក ឬកូនកែវជ័រចំនួនបួន សឺរ៉ាំង បំពង់បឺត បន្ទះកញ្ចក់ កែវមួយដែលមានដាក់ចិញ្ចឹមត្រីរយៈពេលពី 6 ឬ 7 ម៉ោងហើយ ។

## 3. ដំណើរការពិសោធ

ក. ដាក់ទឹកកំបោរថ្លាក្នុងកែវជ័រពីរ : កែវ " ក " និង កែវ " ខ "

- យកសឺរ៉ាំងមួយចាក់បញ្ចូលខ្យល់ទៅក្នុងកែវ " ក "
- ផ្លុំបញ្ចូលខ្យល់ទៅក្នុងកែវ " ខ "
- ដកដង្ហើមបញ្ចេញខ្យល់ទៅលើកញ្ចក់មួយ ។

ខ ដាក់ទឹកបន្តិចក្នុងកូនកែវ " គ "

- យកទឹកក្នុងកែវដែលមានដាក់ត្រីរស់បាន 6 ឬ 7 ម៉ោងទៅចាក់ក្នុងកូនកែវ " ឃ "
- ចាក់ទឹកកំបោរថ្លាទៅក្នុងកែវ " គ " និង " ឃ " ។

## 4. លទ្ធផល

1. តើទឹកកំបោរក្លាយជាល្អក់នៅក្នុងកែវណាខ្លះ ? ពីព្រោះអ្វី ?
2. តើទឹកកំបោរនៅថ្លានៅក្នុងកែវណា ? ពីព្រោះអ្វី ?
3. បើដកដង្ហើមនៅលើកញ្ចក់មួយ តើនៅកញ្ចក់មានអ្វី ?

## 4. សន្និដ្ឋាន

1. តើខ្យល់ដង្ហើមចេញមានឧស្ម័នអ្វី លើសពីខ្យល់ដង្ហើមចូល ?
2. តើឧស្ម័ននេះមានប្រភពមកអំពីអ្វី ?

# 2 ការបញ្ចេញចោល

**ចប់មេរៀននេះ សិស្សអាច**

- ❑ កំណត់និយមន័យការបញ្ចេញចោល ។
- ❑ រៀបរាប់អំពីកាកសំណល់មេតាបូលីស ។
- ❑ ពណ៌នាពីការបញ្ចេញចោលរបស់ប្រូទីស សត្វល្អិត ។
- ❑ ប្រៀបធៀបការបញ្ចេញចោលរបស់អ៊ិតនិងជន្លេន ។
- ❑ បង្ហាញពីសរីរាង្គបញ្ចេញចោលផ្សេងៗរបស់មនុស្ស ។
- ❑ បង្ហាញពីនាទីថ្លើមក្នុងការបញ្ចេញចោល ។
- ❑ បង្ហាញពីទម្រង់និងនាទីនៃតម្រងនោម ។

ក្នុងកោសិកា មានប្រតិកម្មគីមីជាច្រើន ដែលបញ្ចេញថាមពល ។ ប្រតិកម្មទាំងនេះផលិតកាកសំណល់ដែលជាធាតុពុលនៅក្នុងកោសិកា ។ បើមិនបានបញ្ចេញកាកសំណល់ទេ សារពាង្គកាយត្រូវស្លាប់ ។

ការបំបាត់កាកសំណល់នៃមេតាបូលីសពីសារពាង្គកាយហៅថា ការបញ្ចេញចោល ។

## 1. កាកសំណល់ក្នុងសារពាង្គកាយ

ក្នុងដង្ហើមកោសិកា អុកស៊ីតកម្មគ្លុយកូសបញ្ចេញថាមពល ។ ក្នុងប្រតិកម្មនេះ មានកាបូនឌីអុកស៊ីតនិងទឹកជាកាកសំណល់ ។ ក្រៅពីកាបូនឌីអុកស៊ីត មានអំបិលខនិជ (សូដ្យូមក្លរ៉ួនិងប៉ូតាស្យូមស៊ុលផាត)និងកាកសំណល់សមាសធាតុអាសូត (អាម៉ូញ៉ាក់ អ៊ុយរ៉េ និងអាស៊ីតអ៊ុយរិច) ។

កាកសំណល់សមាសធាតុអាសូតមានប្រភពពីប្រូតេអ៊ីន ។ ប្រូតេអ៊ីនអាហារបំបែកជាអាស៊ីតអាមីនេ ។ កោសិកាប្រើប្រាស់អាស៊ីតអាមីនេ សម្រាប់សំយោគប្រូតេអ៊ីនផ្ទាល់របស់សារពាង្គកាយឬសមាសធាតុអាសូតផ្សេងទៀត ។ អាស៊ីតអាមីនេដែលសល់អំពីការសំយោគនេះ ត្រូវប្លែងជាថាមពលឬជាលីពីតនិងគ្លុយស៊ីតបម្រុងទុក ។ ក្នុងករណីនេះបណ្តុំអាមីន $(NH_2)$ ផ្តាច់ចេញពីម៉ូលេគុល ។

បណ្ដុំអាមីនដែលផ្ដាច់ចេញពីអាស៊ីតអាមីនេទៅផ្សំជាមួយអ៊ីយ៉ុងអ៊ីដ្រូសែន ដើម្បីបង្កើតជាឧស្ម័នអាម៉ូញ៉ាក់ ($NH_3$) ។ ប្រតិកម្មនេះត្រូវការថាមពលតែបន្តិចបន្តួចប៉ុណ្ណោះ ។ ឧស្ម័នអាម៉ូញ៉ាក់ជាធាតុពុលខ្លាំង ។ ការបញ្ចេញសមាសធាតុនេះពីសារពាង្គកាយត្រូវការទឹកច្រើន ។ សត្វដែលបញ្ចេញកាកសំណល់អាសូតក្រោមរូបរាងជាអាម៉ូញ៉ាក់មាន សត្វឥតឆ្អឹងកងរស់នៅក្នុងទឹក អំភិបនិងត្រី ដែលមានស្រកី ប៉ះផ្ទាល់នឹងទឹក ។ ចំពោះអំភិបគោកនិងថនិកសត្វ កាកសំណល់សមាសធាតុអាសូតមួយផ្នែកធំគឺ អ៊ុយរ៉េដែលប្លែងពីអាម៉ូញ៉ាក់ ។ ការបំប្លែងពីអាម៉ូញ៉ាក់ទៅអ៊ុយរ៉េត្រូវការថាមពលនិងអង់ស៊ីម ។ អ៊ុយរ៉េមានធាតុពុលតិចជាងអាម៉ូញ៉ាក់ ។ ចំពោះសត្វល្អិត បក្សី និងល្មូនវិញ អាស៊ីតអ៊ុយរិចជាកាកសំណល់សមាសធាតុអាសូត ។ អាស៊ីតអ៊ុយរិចមានធាតុពុលតិច ហើយមិនសូវរលាយក្នុងទឹកទេ ។

*សំគាល់ :* ចូរកុំច្រឡំ លាមកមិនមែនជាកាកសំណល់មេតាបូលីសក្នុងកោសិកាទេ តែជាសំណល់នៃការរំលាយអាហារ ដូចនេះវាត្រូវបញ្ចេញមកក្រៅសារពាង្គកាយតាមទ្វារធំ ។

## 2. ការបញ្ចេញចោលរបស់ប្រូទីស

ចំពោះប្រូទីស កាកសំណល់សាយចេញមកក្រៅកោសិកាតាមភ្នាសកោសិកាចូលទៅក្នុងមជ្ឈដ្ឋានទឹកដែលនៅជុំវិញ ។ កាកសំណល់មេតាបូលីសមាន $CO_2$ អំបិលខនិជនិងអាម៉ូញ៉ាក់ ។ ប្រូទីសទឹកសាបដូចជាអាមីប ប៉ារ៉ាមេស៊ីជាដើម ត្រូវប្រើដំណើកនាំសកម្មដើម្បីរក្សាលក្ខណ រូបគីមីនៃមជ្ឈដ្ឋានក្នុង ។ ទឹកជ្រាបចូលក្នុងកោសិកាតាមបាតុភូតអូស្មូស ។ ទឹកក៏ត្រូវផលិតឡើងដោយដង្ហើមកោសិកាដែរ ។ ទឹកលើសពីតម្រូវការត្រូវតែបញ្ចេញពីកោសិកា ។ ទឹកដែលលើសនេះស្តុកទុកក្នុងវ៉ាគុយអូលកន្ត្រាក់ ។ ពេលទឹកពេញ វ៉ាគុយអូលកន្ត្រាក់ក៏បាញ់ទឹកចេញពីកោសិកា ។



រូបទី 2.2: វ៉ាគុយអូលកន្ត្រាក់របស់ប៉ារ៉ាមេស៊ី

## 3. ការបញ្ចេញចោលរបស់អ៊ីត

អ៊ីតរស់នៅក្នុងទឹកសាប ។ កោសិកាភាគច្រើនរបស់អ៊ីតប៉ះផ្ទាល់ជាមួយនឹងមជ្ឈដ្ឋានទឹក ។ ដូចនេះអ៊ីតគ្មានប្រដាប់បញ្ចេញចោលទេ ។ កាកសំណល់មេតាបូលីស($CO_2$ , $NH_3$ និងអំបិលខនិជ) សាយចេញតាមភ្នាសកោសិកាចូលទៅក្នុងមជ្ឈដ្ឋានទឹក ។

ទឹកជ្រាបចូលទៅក្នុងកោសិការបស់អ៊ីតតាមអូស្មូស ។ នៅក្នុងកោសិការបស់អ៊ីតពុំមានវ៉ាគុយអូលកន្ត្រាក់ទេ ទឹកដែលលើសពីតម្រូវការចេញពីសារពាង្គកាយតាមភ្នាសកោសិកាដោយដំណើកនាំសកម្ម ។

## 4. ការបញ្ចេញចោលរបស់ជន្លេន

សារពាង្គកាយរបស់ជន្លេនខណ្ឌជាកង់ៗ ។ ស្ទើរតែគ្រប់កង់ទាំងអស់មានប្រដាប់បញ្ចេញចោលហៅថា នេព្រីដ្យូម( néphridium)មួយគូ ។ ប្រដាប់បញ្ចេញចោលនេះស្ថិតនៅចំហៀងសងខាងនៃកង់នីមួយៗ ។ នេព្រីដ្យូមនីមួយៗ ជាបំពង់ដែលមានរន្ធចូលមួយគឺ នេព្រីដ្យូស្តូម (néphridiostome) និងរន្ធចេញមួយគឺនេព្រីដ្យូស្ប៉ (néphridiospore) ។ រន្ធចូលស្ថិតនៅក្នុងកង់មួយ ហើយរន្ធចេញស្ថិតនៅក្នុងកង់បន្ទាប់មួយទៀត ។ រន្ធចូលមានរាងដូចជីឡាវព័ទ្ធជុំវិញទៅដោយរោមញ័រ ។ តពីរន្ធចូលជាបំពង់បត់ចុះឡើងជាច្រើនផ្នត់ ។ បំពង់បត់នេះព័ទ្ធជុំវិញទៅដោយបណ្តាញសរសៃប្ហូរ ។ បន្ទាប់មកបំពង់បត់នេះរីកធំបង្កើតជាប្លោកនោម ។ ប្លោកនោមបង្ហូរកាកសំណល់ទៅក្រៅខ្លួនតាមរន្ធចេញ ។




*រូបទី 2.2: ប្រដាប់បញ្ចេញចោលរបស់ជន្លេន*

កាកសំណល់ខ្លះរបស់កោសិកាសាយចូលក្នុងធាតុរាវរបស់ខ្លួនជន្លេន ។ ដោយចលនានៃរោមញ័រ ធាតុរាវក្នុងខ្លួនជន្លេនចូលទៅក្នុងនេព្រីដ្យូមតាមរន្ធចូល ។ នៅត្រង់បំពង់បត់ កាកសំណល់ចេញពីសរសៃប្ហូរចូលទៅក្នុងនេព្រីដ្យូម ។ ពេលនោះសារធាតុមានប្រយោជន៍ខ្លះដូចជា គ្លុយកូសនិងទឹកត្រូវបានស្រូបពីនេព្រីដ្យូមចូលទៅក្នុងឈាមវិញ ។ តាមដំណើរនេះមានការកកើតឡើងនូវទឹកនោមដែលមានសំណល់មេតាបូលិស ដូចជាអាម៉ូញ៉ាក់ អ៊ុយរ៉េ អំបិលខនិជ និងទឹក ។

## 5. ការបញ្ចេញចោលរបស់សត្វល្អិត

ប្រដាប់បញ្ចេញចោលរបស់សត្វល្អិតជាបំពង់ម៉ាល់ពីញី ។ បំពង់ម៉ាល់ពីញីកើតឡើងពីបំពង់ឆ្មារៗ ហើយវែង ដែលភ្ជាប់ទៅនឹងពោះវៀន ។ អាស៊ីតអ៊ុយរិចដែលជាកាកសំណល់និងទឹកនៃធាតុរាវក្នុងប្រហោងសារពាង្គកាយស្រូបចូលទៅក្នុងបំពង់ម៉ាល់ពីញី រួចហូរចូលទៅក្នុងពោះវៀនផ្នែកខាងក្រោយ ។ នៅទីនេះទឹកនិងសារធាតុមានប្រយោជន៍មួយចំនួនត្រូវបានជ្រាបត្រឡប់ចូលទៅក្នុងធាតុរាវរបស់សារពាង្គកាយវិញ ។ កាកសំណល់អាសូតគឺ អាស៊ីតអ៊ុយរិចចេញទៅក្រៅខ្លួនជាមួយលាមកតាមទ្វារធំ ។




*រូបទី 2.3 : ប្រដាប់បញ្ចេញចោលសត្វល្អិត*

## ៦. ការបញ្ចេញចោលរបស់មនុស្ស

សួតមាននាទីបញ្ចេញចោលកាបូនឌីអុកស៊ីតនិងទឹក ដែលផលិតនៅក្នុងដង្ហើមកោសិកា ។ ក្រៅពីសួត តម្រងនោម ថ្លើម និងស្បែកក៏មាននាទីសំខាន់ក្នុងការបញ្ចេញកាកសំណល់ពីសារពាង្គកាយដែរ ។

### ៦.1. នាទីថ្លើមក្នុងការបញ្ចេញចោល

#### ក. នាទីបង្កើតអ៊ុយរ៉េ

អាស៊ីតអាមីនេដែលបានមកពីការរំលាយអាហារត្រូវបានប្រើប្រាស់ក្នុងការសំយោគជាប្រូតេអ៊ីនយថាប្រភេទរបស់សារពាង្គកាយ ។ អាស៊ីតអាមីនេដែលលើសពីសេចក្តីត្រូវការ ត្រូវបំបែកក្នុងថ្លើម ។ នៅទីនោះ បណ្តុំអាមីនត្រូវផ្តាច់ចេញ ហើយប្លែងជាឧស្ម័នអាម៉ូញ៉ាក់ ($NH_3$) ។ បន្ទាប់មកទៀតថ្លើមប្លែងឧស្ម័នអាម៉ូញ៉ាក់និងកាបូនឌីអុកស៊ីតទៅជាអ៊ុយរ៉េ ។ ឈាមដឹកអ៊ុយរ៉េចេញពីថ្លើមទៅតម្រងនោម ។

$$2NH_3 + CO_2 \longrightarrow NH_2 - \underset{\underset{O}{\|}}{C} - NH_2 + H_2O$$

ឧស្ម័នអាម៉ូញ៉ាក់   កាបូនឌីអុកស៊ីត   អ៊ុយរ៉េ   ទឹក

បន្ទាប់ពីការផ្តាច់ចេញនៃបណ្តុំអាមីន ហើយផ្នែកដែលនៅសល់នៃម៉ូលេគុលអាស៊ីតអាមីនេត្រូវប្លែងជាគ្លុយកូសនិងបន្ទាប់មកទៀតជាគ្លីកូសែនស្តុកទុកក្នុងថ្លើមនិងសាច់ដុំ ។



## ខ. នាទីបន្សាបជាតុពុល

ក្រៅពីផលិតអ៊ុយរ៉េ ថ្លើមមាននាទីបន្សាបជាតុពុលផ្សេងៗទៀត ដូចជា អំបិលទង់ដែងនិងអំបិលអាសេនិច នីកូទីន ថ្នាំមួយចំនួន និងពិសរបស់សត្វជាដើម ។ ក្រៅពីនេះថ្លើមមាន នាទីកាត់បន្ថយជាតុពុលផ្សេងៗដែលបានមកពីការរលួយអាហារក្នុងពោះវៀន ។

## គ. នាទីបញ្ចេញទឹកប្រមាត់

កោសិកាថ្លើមផលិតទឹកប្រមាត់ ។ ទឹកប្រមាត់មានពណ៌លឿងបណ្ដាលមកពីជាតិពណ៌ប្រមាត់ប៊ីលីរុយប៊ីន( bilirubine )និងប៊ីលីឌីន( biliverdine) ។ ជាតិពណ៌នេះកើតឡើងពីការបំបែកនៃអេម៉ូក្លូប៊ីនរបស់គោលិកាក្រហមចាស់ៗ ។ ក្រៅពីជាតិពណ៌ប្រមាត់ ទឹកប្រមាត់មានកាកសំណល់ផ្សេងៗទៀត ដូចជា អំបិលប្រមាត់ អំបិលខនិជ កូឡេស្តេរ៉ូល និងទឹក ។

ចេញពីថ្លើម ទឹកប្រមាត់ត្រូវបានស្តុកទុកក្នុងថង់ទឹកប្រមាត់ ។ នៅពេលរំលាយអាហារ ទឹកប្រមាត់ហូរចូលក្នុងពោះវៀនតូចតាមបំពង់ទឹកប្រមាត់ ។ នៅទីនោះវាជួយរំលាយអាហារជាតិខ្លាញ់ ។ នៅផ្នែកខាងចុងពោះវៀន អំបិលប្រមាត់មួយផ្នែកស្រូបចូលទៅក្នុងឈាម ។ ឈាមដឹកនាំអំបិលប្រមាត់ចូលថ្លើមវិញ ។ ទឹកប្រមាត់ដែលនៅសល់ ធ្វើដំណើរចូលទៅពោះវៀនធំ ហើយត្រូវបញ្ចេញចោលជាមួយលាមក ។

ទឹកប្រមាត់មានកាកសំណល់ជាតុពុលយ៉ាងខ្លាំង ។ ដូច្នេះបើវាមិនហូរទៅក្នុងពោះវៀនតូចទេ វានឹងចូលទៅក្នុងឈាម ហើយបង្កជាជំងឺដ៏ធ្ងន់ធ្ងរមួយហៅថាជំងឺខាន់លឿង ។ អ្នកកើតជំងឺខាន់លឿងមានស្បែកនិងភ្នែកពណ៌លឿង ។

# 6.2. ប្រដាប់ទឹកនោម

យើងដឹងថាតម្រងនោមមាននាទីផលិតទឹកនោមដែលត្រូវបញ្ចេញពីសារពាង្គកាយ ។ តើទឹកនោមត្រូវផលិតឡើងដូចម្ដេច ?

## ក. ការប្រៀបធៀបទឹកនោមនិងប្លាស្មា

ការប្រៀបធៀបទឹកនោមនិងប្លាស្មាបង្ហាញឱ្យឃើញថា

- សារធាតុដែលមានក្នុងទឹកនោមក៏មានក្នុងប្លាស្មាទាំងអស់ ។
- សារធាតុខ្លះដូចជាគ្លុយកូស ប្រូតេអ៊ីនមានក្នុងប្លាស្មា តែគ្មានក្នុងទឹកនោមទេ ។
- កាកសំណល់ខ្លះដូចជាអ៊ុយរ៉េនិងអាស៊ីតអ៊ុយរិចក្នុងទឹកនោមមានកំហាប់ខ្ពស់ជាងនៅក្នុងប្លាស្មា ។

| | ទឹកនោម (g/ℓ) | ប្លាស្មា (g/ℓ) |
|---|---|---|
| ទឹក | 950 | 900 |
| គ្លុយកូស | 0 | 0.8 |
| ប្រូតេអ៊ីន | 0 | 70 |
| អាស៊ីតអាមីនេ | 0 | 0.5 |
| លីពីត | 0 | 3 |
| អំបិលខនិជ | 10 – 20 | 7.5 |
| អ៊ុយរ៉េ | 30 – 35 | 0.25 |
| អាស៊ីតអ៊ុយរិច | 0.1 – 2 | 0.04 |

*តារាងប្រៀបធៀបទឹកនោមនិងប្លាស្មា*

- កំហាប់អំបិលក្នុងទឹកនោមប្រែប្រួល តែនៅក្នុងប្លាស្មាកំហាប់នេះថេរ ។
- ម្យ៉ាងទៀត បើសិនជាគេចាក់សារធាតុមួយក្នុងឈាម មួយស្របក់ក្រោយមក គេឃើញសារធាតុដដែលនេះមាននៅក្នុងទឹកនោម ។

ដូចនេះយើងអាចសន្និដ្ឋានថា ទឹកនោមត្រូវបានផលិតឡើងចេញពីឈាមដោយតម្រងនោម ។

## ១. ផ្នែកផ្សេងៗនៃប្រដាប់ទឹកនោម

ប្រដាប់ទឹកនោមបង្កឡើងដោយ

- តម្រងនោមពីរដែលស្ថិតនៅសងខាងឆ្អឹងខ្នងក្រោមសន្ទះទ្រូង ។ តម្រងនោមនីមួយៗមានរាងដូចគ្រាប់សណ្ដែក ហើយមានផ្នែកផតហៅថា អ៊ីល(hile)បែររកឆ្អឹងខ្នង ។ បំពង់នោមចេញពីផ្នែកផតនៃតម្រងនោមនីមួយៗ ។ បំពង់នោមទាំងពីរចេញពីតម្រងនោមឆ្ពោះទៅប្លោកនោម ។
- ប្លោកនោមជាថង់ដែលមានភ្នាសជាសាច់ដុំ ។ ប្លោកនោមមាននាទីស្តុកទឹកនោម ។ ទឹកនោមត្រូវបញ្ចេញពីសារពាង្គកាយតាមបង្ហួរនោម ។ ឈាមចូលទៅក្នុងតម្រងនោម តាមអាកទែតម្រងនោម និងចេញពីតម្រងនោមតាមវ៉ែនតម្រងនោម ។




*រូបទី 2.4 : ពិនុរតម្រងនោមមនុស្ស*

### គ. ទម្រង់តម្រងនោម

ពំនុះបណ្តោយតម្រងនោម បង្ហាញថា តម្រងនោមមានបីផ្នែកគឺ

- ផ្នែកក្រៅ គឺសំបកដែលមានសភាពជាគ្រាប់
- ផ្នែកកណ្តាលមានទម្រង់ជាសាជីតូចៗចំនួន11 ទៅ12 ដែលមានកំពូលបែរទៅរកអ៊ីល ។ ផ្នែកនេះមានភាពជាសរសៃ ។
- ផ្នែកខាងក្នុង គឺជាប្រហោងមានរាងជាបំពង់ជីឡាវ ហៅថាប្រឡង់ដែលបន្តដោយបំពង់នោម ។

*ណេប្រុង :* ភាពជាឆ្នូតនៅផ្នែកកណ្តាលនៃតម្រងនោម បណ្តាលមកពីវត្តមាននៃបំពង់តូចៗ ហៅថាណេប្រុង ។ ណេប្រុងជាឯកតាទម្រង់គ្រឹះដែលបង្កបានជាតម្រងនោម ។ ក្នុងតម្រងនោមនីមួយៗមាន ណេប្រុងប្រហែលមួយលាន ។

ណេប្រុងចាប់ផ្តើមឡើងពីផ្នែកសំបក ហើយមានរាងជាពែងមួយហៅថាកន្សោមបូម៉ាន់ ឬកន្សោមក្លូម៉េរុល ។ កន្សោមបូម៉ាន់បន្តដោយបំពង់បត់ជិត ។ បន្ទាប់ពីបំពង់បត់មានបំពង់រាងអក្សរ U ហៅថាភ្នែនហេនឡេ( Henlé ) ។ តពីបំពង់រាងអក្សរ U ណេប្រុងមានរាងជាបំពង់បត់ម្តងទៀត ។ បំពង់បត់នេះ ភ្ជាប់ទៅនឹងបំពង់រួមមួយ ដែលបន្តចូលទៅក្នុងប្រឡង់ ។

ឈាមចូលទៅក្នុងតម្រងនោមតាមអាកទែតម្រងនោម ។ អាកទែតម្រងនោមបំបែកជាសរសៃឈាមតូចៗ ។ សរសៃឈាមតូចៗទាំងនេះបំបែកជាបណ្តាញសរសៃប្តូរមួយក្រុមហៅថា ក្លូម៉េរុលដែលស្ថិតនៅក្នុងកន្សោមបូម៉ាន់ ។ សំណុំក្លូម៉េរុលនិងកន្សោមបូម៉ាន់ជាអង្គម៉ាល់ពីញី ។ ឈាមចាកចេញពីក្លូមេរុល ហើយចូលទៅក្នុងសរសៃប្តូរដែលរុំព័ទ្ធជុំវិញបំពង់បត់និងបំពង់រាងអក្សរ U ។ សរសៃប្តូរទាំងនេះភ្ជាប់គ្នាជាសរសៃតែមួយ គឺវ៉ែនតម្រងនោមដែលចាកចេញពីតម្រងនោម ។

### ឃ. ការបង្កើតទឹកនោម

ការបង្កើតទឹកនោមប្រព្រឹត្តទៅតាមពីរដំណាក់កាលគឺ

**ដំណាក់ទី 1: ចម្រោះ**

នៅពេលឈាមចូលទៅដល់ក្លូម៉េរុល សម្ពាធឈាមខ្ពស់ធ្វើឱ្យម៉ូលេគុលទឹក អំបិល គ្លុយកូស អ៊ុយរ៉េ និងអាស៊ីតអាមីនេឆ្លងកាត់ភ្នាសយ៉ាងស្តើងរបស់ក្លូម៉េរុលចូលក្នុងកន្សោមបូម៉ាន់ ។ កោសិកាឈាមនិងម៉ូលេគុលធំៗខ្លះទៀត ដូចជាប្រូតេអ៊ីនមិនអាចឆ្លងកាត់ភ្នាសក្លូម៉េរុលបានទេ វាត្រូវស្ថិតនៅក្នុងសរសៃឈាម ។ សមាសធាតុដែលច្រោះចេញពីប្លាស្មា បង្កើតជាទឹកនោមដំបូងដែលមានចំណុះ 180ℓ ក្នុងរយៈពេល 24h ។ ចម្រោះកើតឡើងដោយមានសម្ពាធឈាមខ្ពស់ក្នុងក្លូម៉េរុល ។ សម្ពាធខ្ពស់នេះបណ្តាលមកពីសរសៃអាកទែចូលក្នុងក្លូម៉េរុលធំជាងសរសៃចេញពីក្លូម៉េរុល ។

ដំណាក់ទី 2 : សម្រូបឡើងវិញ

នៅពេលទឹកនោមដំបូងចាកចេញពីកន្សោមបូម៉ាន់ ហើយហូរទៅដល់បំពង់បត់ គ្លុយកូស អាស៊ីត អាមីនេ អំបិលខ្លះ និងទឹក 99 % ត្រូវស្រូបឡើងវិញចូលទៅក្នុងឈាមនៃសរសៃបួរដែលរុំព័ទ្ធជុំវិញបំពង់នេះ ។ ទឹកស្រូបចូលក្នុងសរសៃបួរវិញដោយសារបាតុភូតអូស្មូស ។ តែសម្រូបនៃសារធាតុរលាយដទៃទៀតចូលក្នុងឈាមវិញប្រព្រឹត្តទៅដោយសារដំណឹកនាំសកម្ម ហើយត្រូវការថាមពល ។ ដោយហេតុថាទឹកភាគច្រើនត្រូវបានស្រូបឡើងវិញ ដូចនេះកំហាប់របស់កាកសំណល់មានកម្រិតខ្ពស់ក្នុងទឹកនោមជាងក្នុងឈាម ។

ក្រោយពេលសម្រូបឡើងវិញ ធាតុរាវដែលនៅសល់ក្នុងបំពង់បត់របស់ណេប្រុងជាទឹកនោម ។ ក្នុងទឹកនោមមាន ទឹក អ៊ុយរ៉េ និងអំបិលផ្សេងៗ ។ ទឹកនោមហូរចូលក្នុងបំពង់រួម ហើយចាកចេញពីណេប្រុងជាច្រើនទៅប្រមូលផ្តុំក្នុងប្រឡង់ ។ បន្ទាប់មកទឹកនោមហូរចូលទៅក្នុងប្លោកនោមតាមបំពង់នោម ។ ចំណែកឯឈាមដែលបានជម្រះជាតិពុលរួច ចេញពីតម្រងនោមតាមវ៉ែនតម្រងនោម ។

## ង. នាទីរបស់តម្រងនោម

- ការប្រៀបធៀបប្លាស្មានិងទឹកនោមបង្ហាញថាកំហាប់កាកសំណល់អាសូតក្នុងទឹកនោមខ្ពស់ជាងក្នុងឈាម ។ កាកសំណល់មេតាបូលីសដែលកើតឡើងក្នុងកោសិកាត្រូវបំប្លែងជាអ៊ុយរ៉េក្នុងថ្លើម ។ អ៊ុយរ៉េចូលទៅក្នុងឈាម ហើយតម្រងនោមមាននាទីទាញយកអ៊ុយរ៉េពីក្នុងឈាម ។ ម្យ៉ាងទៀតកាកសំណល់ផ្សេងទៀត ដូចជានីកូទីនក៏ចេញពីឈាមចូលក្នុងតម្រងនោមដែរ ។ ដូចនេះតម្រងនោមមាននាទីបន្សុទ្ធឈាម ។
- យើងសង្កេតឃើញថា កាលណាយើងផឹកទឹកច្រើន យើងក៏បញ្ចេញទឹកនោមច្រើនដែរ ។ បរិមាណទឹកនោមប្រែប្រួលទៅតាមបរិមាណទឹកដែលយើងទទួលទាន ។ ដូចនេះតម្រងនោមមាននាទីរក្សាមាឌប្លាស្មាឱ្យនៅថេរ ។ ម្យ៉ាងទៀត ការប្រៀបធៀបទឹកនោមនិងប្លាស្មាបង្ហាញថាអត្រាអំបិលក្នុងឈាមថេរ តែប្រែប្រួលក្នុងទឹកនោម ។ ដូច្នេះតម្រងនោមមាននាទីតម្រូវបរិមាណអំបិលក្នុងឈាមឱ្យនៅថេរ ។

## ច. ផលិតផលមិនប្រក្រតីក្នុងទឹកនោម

ក្នុងករណីនេះ វេជ្ជបណ្ឌិតបានធ្វើវិភាគទឹកនោមអ្នកជំងឺ ។ ផលិតផលមិនប្រក្រតីខ្លះលេចឡើងចំពោះអ្នកជំងឺខ្លះ

- ការលេចឡើងអាល់ប៊ុយមីនៈ ជាទូទៅអាល់ប៊ុយមីនមិនឆ្លងកាត់ពីឈាមចូលទៅក្នុងណេប្រុងទេ ។ វត្តមានអាល់ប៊ុយមីនក្នុងទឹកនោមជាសញ្ញាបង្ហាញថាណេប្រុងមានការខូចខាត ហើយមានដំណើរប្រព្រឹត្តមិនល្អ ។
- ការលេចឡើងគ្លុយកូស : យើងដឹងថាគ្លុយកូសនៃឈាមត្រូវច្រោះចូលទៅក្នុងកន្សោមបូម៉ាន់ ហើយសម្រូបចូលក្នុងឈាមវិញនៅត្រង់បំពង់បត់ ។ វត្តមានរបស់គ្លុយកូសក្នុងទឹកនោម បង្ហាញថាគ្លុយកូសមិនបានស្រូបចូលទៅក្នុងឈាមទាំងអស់ទេ ។ បាតុភូតនេះលេចឡើង កាលណាអត្រាគ្លុយកូសក្នុងឈាមលើសពី $1.8g/\ell$ ។ វត្តមានគ្លុយកូសក្នុងឈាមមិនបណ្តាលមកពីដំណើរប្រព្រឹត្តមិនល្អនៃតម្រងនោមទេ តែបណ្តាលមកពីក្នុងឈាមមានគ្លុយកូសលើសពីបរិមាណធម្មតា ។

**តម្រងនោមសិប្បនិម្មិតឬដ្យាលីស**

តម្រងនោមជាសរីរាង្គចាំបាច់សម្រាប់ជីវិត ។ បើតម្រងនោមមិនធ្វើការពីរ ឬបីថ្ងៃក្រោយមក សារពាង្គកាយនឹងស្លាប់ ។ គេអាចប្រើបច្ចេកទេសតម្រងនោមសិប្បនិម្មិត ឬដ្យាលីសជំនួសតម្រងនោមដែលមិនដំណើរការ ។ ឈាមអ្នកជំងឺត្រូវបញ្ចូលក្នុងឧបករណ៍មួយ ។ ឧបករណ៍នេះមានវត្ថុរាវដែលអាចច្រោះយកកាកសំណល់ផ្សេងៗពីឈាម ។ ដូច្នេះគេអាចប្រើឧបករណ៍នេះសម្រាប់បន្សុទ្ធនិងតម្រូវប្លាស្មាក្នុងឈាមអ្នកជំងឺបាន ។



រូបទី 2.5 : តម្រងនោមសិប្បនិម្មិត

## 6.3. ស្លួត

ស្លួតបំបាត់ឧស្ម័នកាបូនិចនិងទឹកចេញពីសារពាង្គកាយ ។

## 6.4. ស្បែក

ស្បែកក៏ជាសរីរាង្គបញ្ចេញចោលមួយសំខាន់ដែរ ។ វាបញ្ចេញទឹក អំបិលដែលលើសនិងបរិមាណអ៊ុយរ៉េបន្តិចបន្តួច ។

## មេរៀនសង្ខេប

- ការបញ្ចេញចោលជាដំណើរនៃការបំបាត់កាកសំណល់នៃមេតាបូលីសពីសារពាង្គកាយ ។ កាកសំណល់ទាំងនោះមាន $CO_2$ ទឹក សមាសធាតុអាសូត និងអំបិលខនិជ ។ កាកសំណល់អាសូតមាន អាម៉ូញ៉ាក់ អ៊ុយរ៉េ និងអាស៊ីតអ៊ុយរិច ។
- ចំពោះប្រូទីសនិងអ៊ីត កាកសំណល់ភាយចេញពីកោសិកាចូលផ្ទាល់ទៅក្នុងមជ្ឈដ្ឋានជុំវិញ ។
- ចំពោះប្រូទីសនិងពពួកសត្វក្នុងទឹកបញ្ចេញចោលនូវ $NH_3$ ដែលជាកាកសំណល់មានជាតុពុលខ្លាំងទៅក្នុងទឹក ។
- សរីរាង្គបញ្ចេញចោលរបស់ជន្លេន គឺលោព្រីដ្យូម ។ ចំពោះសត្វល្អិត គឺបំពង់ម៉ាល់ពីហ្គី ។
- សរីរាង្គបញ្ចេញចោលរបស់មនុស្សគឺ ស្បែក តម្រងនោម ថ្លើម និងសួត ។
- ថ្លើមមាននាទីបំប្លែងបណ្ដុំអាមីននៃអាស៊ីតអាមីនេឱ្យទៅជាអ៊ុយរ៉េ បន្សាបជាតុពុលនិងបញ្ចេញទឹកប្រមាត់ ។
- ក្នុងតម្រងនោមទឹកនោមផលិតឡើងដោយទាញយកកាកសំណល់ពីឈាម ។ តម្រងនោមមាននាទីបន្សុទ្ធឈាម តម្រូវបរិមាណទឹក និងអំបិលក្នុងប្លាស្មាឈាម ។
- ក្នុងតម្រងនោមនីមួយៗមានលោប្រុងដែលជាឯកតាទម្រង់និងនាទីប្រហែលមួយលាន ។ លោប្រុងនីមួយៗមានប្រដាប់ច្រោះ គឺកន្សោមបូម៉ាន់បន្តដោយបំពង់វែង ។ វារុំព័ទ្ធដោយបណ្ដាញសរសៃឈាមបូរ ។

## សំណួរនិងលំហាត់

1 តើការបញ្ចេញចោលជាអ្វី ?

2. តើកាកសំណល់សមាសធាតុអាសូតមានអ្វីខ្លះ ?

3. តើកាកសំណល់សមាសធាតុអាសូតរបស់សត្វរស់នៅក្នុងទឹកមានអ្វីខ្លះ ?

4. ចូរពណ៌នាអំពីសរីរាង្គបញ្ចេញចោលរបស់ជន្លេន ។

5. ចូរពណ៌នាអំពីការបញ្ចេញចោលរបស់សត្វល្អិត ។

6. តើថ្លើមមាននាទីដូចម្ដេចខ្លះ ?

7 ចូរពណ៌នាអំពីទម្រង់លោប្រុងក្នុងតម្រងនោមរបស់មនុស្ស ។

8. តើតម្រងនោមមាននាទីដូចម្ដេច ?

## ពិសោធន៍ ៖ សង្កេតរូបផ្ទុំក្រៅនិងរូបផ្ទុំក្នុងតម្រងនោមរបស់ជ្រូក

### 1. វត្ថុបំណង

ពណ៌នារូបផ្ទុំក្រៅនិងរូបផ្ទុំក្នុងនៃតម្រងនោមជ្រូក

### 2. សម្ភារៈ

តម្រងនោមជ្រូក ក្តារសម្រាប់វះ កាំបិត ក្រដាសជូតមាត់ ។

### 3. ដំណើរការពិសោធ

ក. ពិនិត្យមើលរូបផ្ទុំក្រៅនៃតម្រងនោម ( រូបរាង ពណ៌ ) ចូររកចំណុចផ្តើមនៃបំពង់នោមស្ពាមអាកទែនិងវ៉ែនតម្រងនោម ។

ខ. ចូរពុះតម្រងនោមតាមបណ្តោយ ។

- ចូរពិនិត្យមើលស្រទាប់ខាងក្រៅ ដែលមានសភាពជាគ្រាប់ៗ
- ចូរពិនិត្យមើលផ្នែកកណ្តាល ដែលមានទម្រង់ជាសាជីតូចៗ ហើយមានសភាពជាឆ្នូតៗ
- ចូរពិនិត្យមើលប្រឡង់ ដែលបន្តដោយបំពង់នោមនិងស្ពាមសរសៃឈាម ។



ផ្ទាត់បណ្តោយតម្រងនោមជ្រូក

### 4. សង្កេតនិងសន្និដ្ឋាន

ក. តើតម្រងនោមមានពណ៌អ្វី ?

ខ. តើប្រឡង់នោមមានពណ៌អ្វី ?

គ. តើទឹកនោមកកើតឡើងនៅផ្នែកណានៃតម្រងនោម ?

ឃ. តើអាកទែតម្រងនោមមាននាទីដូចម្តេច ?

ង. ចូរគូររូបពំនុះតាមបណ្តោយនៃតម្រងនោម ?

# ? សំណួរនិងលំហាត់ជំពូក5

I. ចូរគូរសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយត្រឹមត្រូវ

1. ប្រដាប់របត់ឈាមគ្មាននាទីក្នុងដំណឹកនាំឧស្ម័នដង្ហើមចំពោះ

☐ ក. មនុស្ស ☐ ខ. ជន្លេន ☐ គ. ចង្រិត ☐ ឃ. អ៊ិត ។

2. ចំពោះមនុស្ស បំពង់ខ្យល់បែកជាបំពង់ពីរហៅថា

☐ ក. បំពង់សំឡេង ☐ ខ. ទងសួត ☐ គ. បំពង់អាហារ ☐ ឃ. កូនទងសួត ។

3. ខ្យល់ចូលក្នុងសួតមនុស្ស ពីព្រោះ

☐ ក. សម្ពាធបរិយាកាសខ្សោយជាងសម្ពាធខ្យល់ក្នុងសួត

☐ ខ. សម្ពាធបរិយាកាសខ្លាំងជាងសម្ពាធខ្យល់ក្នុងសួត

☐ គ. សម្ពាធបរិយាកាសស្មើនិងសម្ពាធខ្យល់ក្នុងសួត

☐ ឃ. សម្ពាធអុកស៊ីសែនក្នុងសួតខ្សោយជាងសម្ពាធខាងក្រៅ ។

4. បណ្តូរឧស្ម័នដង្ហើមរវាងខ្យល់និងឈាមប្រព្រឹត្តទៅតាមផ្ទៃនៃ

☐ ក. កូនទងសួត ☐ ខ. បំពង់ខ្យល់ ☐ គ. ថង់សួត ☐ ឃ. ទងសួត ។

5. ចំពោះមនុស្ស ឯកតាទម្រងនិងនាទីនៃតម្រងនោមគឺ

☐ ក. ប្លោកនោម ☐ ខ. កន្សោមបូម៉ាន់ ☐ គ. ក្លូមេរ៉ុល ☐ ឃ. ណេប្រុង ។

6. ចំពោះមនុស្ស កាកសំណល់ចេញពីឈាមនៅ

☐ ក. បំពង់នោម ☐ ខ. បង្ហួរនោម ☐ គ. ប្លោកនោម ☐ ឃ. កន្សោមបូម៉ាន់ ។

7. សរីរាង្គដែលទឹកនោមឆ្លងកាត់ក្រោយគេបង្អស់មុននឹងចេញពីសារពាង្គកាយគឺ

☐ ក. ប្លោកនោម ☐ ខ. តម្រងនោម ☐ គ. បង្ហួរនោម ☐ ឃ. បំពង់នោម ។

8. សរីរាង្គដែលមាននាទីបញ្ចេញចោលផងនិងដំណកដង្ហើមផងគឺ

☐ ក. ថ្លើម ☐ ខ. សួត ☐ គ. ស្បែក ☐ ឃ. តម្រងនោម ។

9. សារធាតុដែលគ្មានក្នុងទឹកនោមនៃមនុស្សមានសុខភាពល្អគឺ

☐ ក. ទឹក ☐ ខ. អំបិលខនិជ

☐ គ. អាស៊ីតអ៊ុយរិច ☐ ឃ. អាស៊ីតអាមីនេ ។

10. សរសៃឈាមដែលសម្បូរទៅដោយម៉ូលេគុលអុកស៊ីអេម៉ូក្លូប៊ីនច្រើនជាងគេគឺ

☐ ក. សរសៃបួរទាំងអស់ ☐ ខ. អាកទែសួត

☐ គ. វ៉ែនសួត ☐ ឃ. អាកទែទាំងអស់ ។

II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1 ក្នុងគោលិកាក្រហម                    មាននាទីដឹកនាំអុកស៊ីសែន ។

2. ការច្រោះយកកាកសំណល់ពីឈាមប្រព្រឹត្តទៅនៅ                    ក្នុងតម្រងនោម ។

3. អាស៊ីតអាមីនេលើសពីតម្រូវការបំប្លែងជាអ៊ុយរ៉េនៅក្នុង                    ។

4. ក្នុងសរីរាង្គ ឈាមចាប់យក                    ហើយមានពណ៌ក្រហមក្រម៉ៅ ។

5. ចំពោះត្រី ស្រកីជាផ្ទៃដីធំសម្រាប់បណ្ដូរឧស្ម័នរវាង                    និងឈាម ។

III. ចូរឆ្លើយសំណួរខាងក្រោមនេះ

1 ហេតុអ្វីបានជាភាវៈរស់ត្រូវតែធ្វើបណ្ដូរឧស្ម័ន ?

2. ចូរពន្យល់ថាខ្យល់អាចចូលក្នុងសួតបានរបៀបដូចម្ដេច ?

3 នៅពេលដង្ហើមចេញ តើហេតុអ្វីបានជាខ្យល់ចេញពីសួតបាន ?

4. តើហេតុអ្វីបានជាគោលិកាក្រហមអាចដឹកនាំអុកស៊ីសែនបាន ?

5 តើឈាមចេញពីសរីរាង្គមានពណ៌អ្វី ? ពីព្រោះអ្វី ? តើឈាមចេញពីសួតមានពណ៌អ្វី ? ពីព្រោះអ្វី ?

6. ក្នុងបណ្ដូរឧស្ម័ន តើថង់សួតមាននាទីដូចម្ដេចខ្លះ ?

7 តើណោប្រុងនិងថង់សួតមានលក្ខណៈដូចគ្នាត្រង់ណា ?

8. តើថ្លើមនិងតម្រងនោមមាននាទីដូចម្ដេចក្នុងការបញ្ចេញចោល ?

9 តើហេតុអ្វីបានជាកាបូនម៉ូណូអុកស៊ីតជាឧស្ម័នពុលចំពោះសារពាង្គកាយ ?

10. នេះជាលទ្ធផលនៃការវិភាគឈាមនៃមនុស្សពីរនាក់ " ក " និង " ខ " ។

| | ជន " ក " | ជន " ខ " |
|---|---|---|
| ចំនួនគោលិកាក្រហម | $3500000/mm^3$ | $5000000/mm^3$ |
| បរិមាណអេម៉ូក្លូប៊ីនក្នុងឈាម | 100g/l | 150g/l |

ក. តើអ្នកណាមួយដែលមានឈាមដឹកនាំអុកស៊ីសែនទៅកាន់សរីរាង្គបានតិចជាងគេ ? ពីព្រោះអ្វី ?

ខ. លោក " ក " មានភាពស្លេកស្លាំង ឆាប់ហត់ ។ តើហេតុអ្វី ?

11. តើហេតុអ្វីបានជាអត្រាអ៊ុយរ៉េខ្ពស់ក្នុងសារពាង្គកាយបណ្ដាលឱ្យស្លាប់ ?

12. តើអត្រាអ៊ុយរ៉េខ្ពស់ក្នុងឈាមអាចមានបុព្វហេតុមកអំពីអ្វី ?

13 តើអ៊ុយរ៉េកកើតឡើងក្នុងសារពាង្គកាយរបៀបដូចម្ដេចដែរ ?

# ជំពូក 6 ប្រតិកម្មរវាងសត្វនិងមជ្ឈដ្ឋាន



ពេញមួយជីវិត ឈាមរត់នៅក្នុងសារពាង្គកាយ ដឹកនាំរូបធាតុផ្សេងៗទៅកាន់កោសិកានីមួយៗ ។ ក្នុងចំណោមរូបធាតុទាំងនេះ មានសារធាតុចិញ្ចឹមដែលបានពីអាហារ សារធាតុផ្សេងទៀតជួយរាងកាយប្រឆាំងនឹងជំងឺ រូបធាតុខ្លះទៀត ជួយក្នុងដំណើរកំណកឈាមនិង$O_2$ ។ នៅក្នុងឈាម មានសារធាតុគីមីមួយចំនួនដែលចូលរួមក្នុងលំនាំថេរលំនឹងរបស់សារពាង្គកាយ ។ តើឈាមមានធាតុបង្កអ្វីខ្លះ ? ក្នុងសកម្មភាពរស់នៅរបស់មនុស្ស តើឈាមមាននាទីអ្វីខ្លះ ?

# 1 របត់ឈាមនិងភាពស៊ាំ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីប្រដាប់របត់ឈាមបិទនិងបើក ទោលនិងទ្វេ ។
- ❑ ធ្វើអត្តសញ្ញាណប្រភេទផ្សេងៗនៃកោសិកាឈាមនិងនាទីរបស់វា ។
- ❑ ប្រៀបធៀបប្រភេទផ្សេងៗរបស់កោសិកាឈាមសនិងនាទីរបស់វាប្រឆាំងនឹងជំងឺ ។
- ❑ បកស្រាយពីតំណបស៊ាំតាមរយៈ អង់ទីករនិងតំណបស៊ាំ តាមរយៈ កោសិកា ។

គ្រប់កោសិកាទាំងអស់ត្រូវការ $O_2$ និងអាហារចិញ្ចឹម ហើយត្រូវបញ្ចេញចោលដោយខ្លួនឯងនូវកាកសំណល់ ។ ចំពោះសារពាង្គកាយឯកកោសិកា បណ្តូរសារធាតុចិញ្ចឹមប្រព្រឹត្តទៅដោយផ្ទាល់ជាមួយមជ្ឈដ្ឋានខាងក្រៅដែលនៅផ្ទាល់ជុំវិញខ្លួនវា ។ សត្វពហុកោសិកាតូចៗមួយចំនួនគ្មានប្រព័ន្ធដឹកនាំខាងក្នុងសារពាង្គកាយទេ(អ៊ីត) ព្រោះកោសិការបស់វាមានបណ្តូរសារធាតុចិញ្ចឹមដូចសារពាង្គកាយឯកកោសិកា។ តាមធម្មតា សត្វឥតឆ្អឹងកងមួយចំនួនធំនិងសត្វឆ្អឹងកង មានប្រដាប់របត់ឈាម ដែលដឹកនាំ $O_2$ និងសារធាតុចិញ្ចឹមទៅឱ្យកោសិកា និងដឹកនាំកាកសំណល់ចេញពីកោសិកាមកវិញ ។

## 1. ប្រដាប់របត់ឈាម

ប្រព័ន្ធដឹកនាំក្នុងសត្វមានលក្ខណៈស្មុគស្មាញជាងរុក្ខជាតិ ។ ចំពោះសត្វនិងមនុស្សដែលមានរូបធាតុស្មុគស្មាញ ប្រដាប់របត់ឈាមរួមមាន បេះដូងនិងសរសៃឈាម ។

### 1.1. ប្រដាប់របត់ឈាមបិទនិងបើក

អាកត្រូប៉ូតនិងសិប្បីសត្វភាគច្រើនមានប្រដាប់របត់ឈាមបើក ។ ជាទូទៅក្នុងប្រដាប់របត់ឈាមបើក ឈាមមិនស្ថិតនៅក្នុងសរសៃឈាមបិទជិតទេ ។ ផ្ទុយទៅវិញ ឈាមហូរចេញស្រោចស្រព់ដោយផ្ទាល់ទៅលើជាលិកា ដែលស្ថិតនៅក្នុងលំហនៃរាងកាយ ។



រូបទី 1.1 : ប្រដាប់របត់ឈាមកណ្តូប

***ឧទាហរណ៍*** : កណ្ដូបមានប្រដាប់របត់ឈាមបើក ។ នៅតាមបណ្ដោយខ្នង ផ្នែកខាងលើប្រដាប់រំលាយអាហារ ប្រដាប់បន្តពូជរបស់កណ្ដូប មានសរសៃឈាមមួយហៅថាអាអកនិងបំពង់បេះដូងមួយ ។ ការកន្ត្រាក់របស់បេះដូងជំរុញឱ្យឈាមហូរឆ្លងកាត់អាអកទៅកាន់ក្បាល ។ នៅក្នុងក្បាល ឈាមហូរចេញពីអាអក ហើយស្រក់កាត់លំហនៃសារពាង្គកាយ ទៅលើជាលិកាទាំងអស់ ។ បណ្ដូរសារធាតុផ្សេងៗរវាងឈាមនិងជាលិកាប្រព្រឹត្តទៅនៅពេលនោះដែរ ។ ឈាមបានបន្តចលនាឆ្លងកាត់លំហនៃរាងកាយតាមចលនាដង្ហើមនិងចលនាផ្សេងៗទៀតនៃរាងកាយ ហើយត្រឡប់ចូលបេះដូងវិញតាមសន្ទះបើកដែលស្ថិតក្នុងភ្នាសបេះដូង ។

ឈាមកណ្ដូបគ្មានពណ៌ទេ ព្រោះវាគ្មានអេម៉ូក្លូប៊ីន ហើយវាមិនដឹកនាំ $O_2$ និង $CO_2$ ទេ ។ វាដើរតួយ៉ាងសំខាន់ក្នុងដំណឹកនាំសារធាតុចិញ្ចឹមនិងកាកសំណល់អាសូត ។ កោសិកាចាប់យក $O_2$ និងបញ្ចេញ $CO_2$ ទៅវិញតាមរយៈខ្យល់ដែលមាននៅពាសពេញក្នុងរាងកាយ ។

សត្វឆ្អឹងកងនិងសត្វឥតឆ្អឹងកងមួយចំនួនមានប្រដាប់របត់ឈាមបិទ(***ឧទាហរណ៍*** ដង្កូវខ្លួនកង់មឹក បង្កងយក្ស) ។ តាមធម្មតា បេះដូងសប់ឈាមបញ្ចូលទៅក្នុងប្រព័ន្ធសរសៃឈាម តាមទិសដៅតែមួយ ពីព្រោះក្នុងសរសៃឈាមមានប្រិសបង្ការមិនឱ្យឈាមរត់បញ្ច្រាស់មកវិញ ។ ក្នុងប្រដាប់របត់ឈាមបិទ ជាទូទៅឈាមត្រូវស្ថិតនៅក្នុងសរសៃឈាមរបស់សារពាង្គកាយ ។




*រូបទី 1.2 : ប្រដាប់របត់ឈាមជន្លេន*

ក្នុងខ្លួនជន្លេនមានសរសៃឈាមពីរប្រភេទមួយជាសរសៃឈាមផ្នែកខ្នងដែលស្ថិតនៅតាមបណ្ដោយខ្នងជន្លេន ចាប់ពីផ្នែកខាងដើមនៃបំពង់រំលាយអាហាររបស់វា ។ មួយទៀតជាសរសៃឈាមផ្នែកពោះ ដែលស្ថិតនៅតាមបណ្ដោយផ្នែកខាងក្រោមនៃបំពង់រំលាយអាហារ ។ សរសៃឈាមទាំងពីរនេះជួបគ្នា នៅក្បែរផ្នែកខាងចុងក្បាលជន្លេនដោយសារសរសៃឈាមប្រាំគូ គឺបេះដូង ។ បេះដូងនិងសរសៃឈាម រុញឈាមពីផ្នែកខ្នងទៅផ្នែកពោះ ។ សរសៃឈាមផ្នែកពោះចែកជាសរសៃឈាមឆ្មារៗ ដែលទៅដល់គ្រប់ផ្នែកទាំងអស់នៃសារពាង្គកាយ ។ បណ្ដូរសារធាតុផ្សេងៗរវាងឈាមនិងកោសិកានៃរាងកាយប្រព្រឹត្តទៅដោយឆ្លងកាត់ភ្នាសសរសៃឈាមឆ្មារៗ ដែលហៅថា សរសៃប្ញូរ ។ សារធាតុចិញ្ចឹមអាចឆ្លងកាត់ភ្នាសដ៏ស្តើងនៃសរសៃប្ញូរបាន ។ បន្ទាប់មកសរសៃប្ញូរភ្ជាប់គ្នាជាសរសៃធំយ៉ាង

ច្រើន ដែលដឹកនាំឈាមទៅកាន់សរសៃឈាមផ្ទៃកខ្នង ។ សរសៃឈាមផ្ទៃកខ្នងកន្ត្រាក់ជាចង្វាក់ ដែលធ្វើឱ្យឈាមត្រឡប់ចូលបេះដូងវិញ ។

ឈាមរបស់ជន្លេនដឹកនាំសារធាតុចិញ្ចឹមរលាយ ឧស្ម័ន កាកសំណល់ ទឹក និងសារធាតុផ្សេងៗទៀត ។ ឈាមរបស់វាមានពណ៌ក្រហម ដោយសារវត្តមានអេម៉ូក្លូប៊ីន ។ ជន្លេនគ្មានសរីរាង្គពិសេសសម្រាប់បណ្តូរឧស្ម័នជាមួយមជ្ឈដ្ឋានខាងក្រៅទេ ។ បណ្តូរឧស្ម័នកើតឡើងដោយឆ្លងកាត់តាមភ្នាសរបស់សារពាង្គកាយ (ស្បែក) ដែលវាត្រូវតែរក្សាភាពសើមជានិច្ច ។

លក្ខណៈខុសគ្នារវាងប្រដាប់របត់ឈាមបិទនិងបើកមានសារៈសំខាន់ណាស់ ។ ចំពោះប្រដាប់របត់ឈាមបិទ ឈាមស្ថិតនៅក្រោមសម្ពាធ ។ សម្ពាធបែបនេះ បណ្តាលឱ្យឈាមរបស់សារពាង្គកាយធ្វើចលនាលឿន ។ ចំពោះប្រដាប់របត់ឈាមបើក ចលនាឈាមលឿនល្មមគ្រប់គ្រាន់សម្រាប់តម្រូវការរបស់សារពាង្គកាយដែលមានប្រព័ន្ធរបត់ឈាមបែបនេះ ។

## 1.2. ប្រដាប់របត់ឈាមទោលនិងទ្វេ

គ្រប់សត្វឆ្អឹងកងទាំងអស់មានប្រដាប់របត់ឈាមបិទ ។ ប្រដាប់របត់ឈាមបិទរបស់សត្វឆ្អឹងកងមានពីរបែបខុសគ្នា ។ ចំពោះត្រីដែលប្រើប្រាស់ស្រកីសម្រាប់ដកដង្ហើមមានដំណើររបត់ឈាមទោល ។ របត់ឈាមទោលជារបត់ឈាមងាយដែលបេះដូងមានថតពីរ ថតលើជាអ្នកទទួលឈាមខ្សត់ $O_2$ ពីសារពាង្គកាយ ហើយថតក្រោមជាអ្នករុញឈាមទៅស្រកីបន្ទាប់មកទៅសារពាង្គកាយទាំងមូល ។ ក្នុងដំណើររបត់ឈាមទោល ឈាមធ្វើដំណើរពីបេះដូងទៅស្រកី រួចទៅជាលិកានៃសារពាង្គកាយ បន្ទាប់មកត្រលប់ចូលបេះដូងវិញ ។ បេះដូងត្រីមានសន្ទះខណ្ឌ ដែលចែកដាច់រវាងថតលើនិងថតក្រោមរបស់បេះដូង ។ ដូចនេះឈាមដែលសម្បូរ $O_2$ លាយចូលជាមួយឈាមដែលមាន $CO_2$ ។ ផ្ទុយទៅវិញ ចំពោះសត្វឆ្អឹងកងដទៃទៀត ដែលប្រើប្រាស់សួតសម្រាប់ដកដង្ហើម មានដំណើររបត់ឈាមទ្វេ ។

របត់ឈាមទី 1 : ឈាមដែលខ្សត់ $O_2$ ចេញពីបេះដូងទៅកាន់សួត ហើយឈាមដែលសម្បូរ $O_2$ ចេញពីសួតត្រឡប់ចូលបេះដូងវិញ ។

របត់ឈាមទី 2 : ឈាមដែលសម្បូរ $O_2$ ចេញពីបេះដូងទៅកាន់សរីរាង្គផ្សេងៗរបស់សារពាង្គកាយទាំងមូល ហើយឈាមខ្សត់ $O_2$ ចេញពីសារពាង្គកាយចូលបេះដូងវិញ ។

កូនកង្កែបរស់នៅតែក្នុងទឹក ។ វាមានស្រកីដូចត្រី ។ ដូចនេះវាចាប់យក $O_2$ តាមស្រកី ។ ចំណែកកង្កែបពេញវ័យ សួតលូតលាស់ ។ កង្កែបប្រើប្រាស់សួតសម្រាប់ដកដង្ហើមនៅលើគោក ។ បេះដូងកង្កែបមានថតលើពីរនិងថតក្រោមមួយ ។ ឈាមសម្បូរ $O_2$ និងឈាមខ្សត់ $O_2$ មិនអាចលាយចូលគ្នានៅ

ក្នុងថតលើទេ តែឈាមទាំងពីរនេះអាចលាយចូលគ្នាក្នុងថតក្រោមរបស់បេះដូងបាន ។ ដូចនេះកំហាប់ $O_2$ ក្នុងឈាមធ្វើដំណើរទៅសារពាង្គកាយទាំងមូលមិនអាចខ្ពស់បានទេ ។




រូបទី 1.4 ប្រដាប់រត់ឈាមត្រី កង្កែប ល្មូន បក្សី និងថនិកសត្វ

ចំពោះល្មូន បេះដូងរបស់វាមានសន្ទះខណ្ឌដែលបែងចែកផ្នែកខាងក្នុងរបស់បេះដូង ។ សន្ទះនេះចែកថតក្រោមរបស់បេះដូងមិនបានពេញលេញទេ ។ ប៉ុន្តែវាធ្វើឱ្យល្បាយរវាងឈាមសម្បូរ $O_2$ និងឈាមខ្វះ $O_2$ កាន់តែតិចទៅៗ ។ វាគ្មានការបញ្ចេញចោលពេញលេញទេ ។ ចំពោះក្រពើ សន្ទះនេះចែកថតក្រោមរបស់បេះដូងជាពីរផ្នែកពេញលេញ គឺថតក្រោមឆ្វេងនិងស្តាំ ។

ចំពោះបក្សីនិងថនិកសត្វ បេះដូងមានសន្ទះខណ្ឌពេញលេញ ដែលចែកបេះដូងជាបួនថត នេះមានន័យថា ដំណើររបស់ឈាមពីបេះដូងទៅសួតនិងពីបេះដូងទៅកាន់សារពាង្គកាយទាំងមូល មានសន្ទះខណ្ឌពេញលេញ ។ ដូចនេះគ្មានល្បាយរវាងឈាមសម្បូរ $O_2$ និងឈាមខ្វះ $O_2$ ក្នុងបេះដូងទេ ។ ថតទាំងបួននៃបេះដូងបង្ហាញនូវកម្លាំងរុញពីរបែប ការរុញឈាមទៅកាន់សួតនិងការរុញឈាមទៅកាន់សារពាង្គកាយទាំងមូល ។

## 1.3. ប្រដាប់រូបត់ឈាមមនុស្ស

មនុស្សក៏ដូចជាសត្វឆ្អឹងកងដទៃទៀតដែរ មានប្រដាប់រត់ឈាមបិទ ប៉ុន្តែវាមានលក្ខណៈស្មុគស្មាញជាងគេ ។ ប្រដាប់រត់ឈាមមនុស្សមាន បេះដូងមួយនិងបណ្តាញសរសៃឈាម ។ បេះដូងរុញឈាម ហើយសរសៃឈាមដឹកនាំឈាមទៅនិងមកពីគ្រប់កោសិកាទាំងអស់របស់សារពាង្គកាយ ។

### ក. បេះដូង

បេះដូងជាសរីរាង្គសាច់ដុំប្រហោងពិសេសមួយដែលកន្ត្រាក់ច្រើនជាងមួយរយពាន់(100 000 )ដងក្នុងមួយថ្ងៃ ។ ផ្ទៃបេះដូងមានបីស្រទាប់ :




*រូបទី 1.4 : គំនូរបេះដូង*

- ស្រទាប់ក្នុងរបស់បេះដូងបង្កឡើងពីកោសិកាអេពីតេល្យូមតែមួយស្រទាប់ ។ វាមានផ្ទុកជាលិកាសន្ទានដែលភ្ជាប់ស្រទាប់ក្នុងទៅនឹងស្រទាប់កណ្តាល ។ ស្រទាប់ក្នុងគ្មានសរសៃឈាមទេ ។លើសពីនេះទម្រង់កូឡូអ៊ីត *(Colloïde)* របស់វា បង្ការភាពសិករិចរិលរបស់បេះដូងក្នុងពេលកន្ត្រាក់និងរលា ។
- ស្រទាប់កណ្តាលនៃបេះដូងបង្កឡើងពីជាលិកាសាច់ដុំបេះដូង ។ កម្រាស់របស់ស្រទាប់កណ្តាលមានការប្រែប្រួល ។ ថតលើមានកម្រាស់ស្តើង ឯថតក្រោមមានកម្រាស់ក្រាស់ ។ ថតក្រោមឆ្វេងមានស្រទាប់ក្នុងក្រាស់ជាងថតក្រោមស្តាំ ។ កោសិការបស់សាច់ដុំបេះដូងមិនទទួលយកសារធាតុចិញ្ចឹមពីឈាមនៅក្នុងថតបេះដូងដោយផ្ទាល់ទេ ។ ឈាមខ្សត់ $O_2$ ដែលប្រមូលបានពីជាលិការបស់សារពាង្គកាយ ហូរចូលទៅក្នុងថតលើស្តាំ បន្ទាប់មកចូលទៅក្នុងថតក្រោមស្តាំ ហើយរុញឈាមទៅសួតតាមសរសៃអាកទែសួត ។ ឈាមសម្បូរ $O_2$ ត្រឡប់ចូលបេះដូង ហើយចូលទៅក្នុងសរសៃប្ដូរនៃស្រទាប់កណ្តាលរបស់បេះដូង ដើម្បីផ្គត់ផ្គង់សារធាតុចិញ្ចឹមដល់កោសិកាបេះដូង ។

កោសិកាបេះដូងត្រូវបានផ្គត់ផ្គង់ដោយប្រដាប់របត់ឈាម ដែលមានសរសៃអាកទែកូរ៉ូណែ (បេះដូង )សរសៃប្ញូរ និងវ៉ែន ។ អាអកនាំឈាមសម្បូរ $O_2$ និងសារធាតុចិញ្ចឹមទៅកាន់អាកទែកូរ៉ូណែ ។ ឈាមត្រូវបានបែងចែកទៅសរសៃប្ញូរ ដែលនៅទីនោះសារធាតុចិញ្ចឹមនិង $O_2$ ចូលទៅក្នុងកោសិកាបេះដូងតាមបន្សាយ ។ នៅពេលជាមួយគ្នា កាកសំណល់អាសូត និង $CO_2$ សាយទៅក្នុងឈាម ។ ឈាមខ្សត់ $O_2$ រួមជាមួយកាកសំណល់ ត្រូវបានប្រមូលផ្តុំតាមសរសៃវ៉ែនកូរ៉ូណែ បន្ទាប់មកហូរចូលទៅក្នុងថតលើស្តាំ ។

- ស្រទាប់ក្រៅរបស់បេះដូងជាជាលិកាសរសៃ (ភីប) ។ លំហរវាងផ្ទៃទាំងពីរពេញទៅដោយធាតុរាវ ។ ទម្រង់កូឡូអ៊ិតនៃស្រទាប់ក្រៅជួយសម្រួលនាទីរបស់បេះដូងនិងការពារវាពីការប៉ះទង្គិចដោយចៃដន្យពីខាងក្រៅ ។

## ១. សរសៃឈាម

- ក្រោយពេលចាកចេញពីបេះដូង ឈាមត្រូវបានរុញចេញតាមបណ្តាញសរសៃឈាមទៅគ្រប់កន្លែងនៃសារពាង្គកាយ ។ សរសៃឈាមមានបីប្រភេទគឺ អាកទែ វ៉ែននិងសរសៃប្ញូរ ។
- អាកទែដឹកនាំឈាមពីបេះដូងទៅកាន់ជាលិកាផ្សេងៗរបស់សារពាង្គកាយ ។ គ្រប់សរសៃអាកទែទាំងអស់ ដឹកនាំឈាមសម្បូរ $O_2$ លើកលែងតែអាកទែសួត ។ ភ្នាសរបស់អាកទែ ក្រាស់ហើយយឺត ។ ភ្នាសរបស់វាមានបីស្រទាប់ ។ ស្រទាប់ក្នុងរលីង ដែលកើតឡើងពីជាលិកាអេពីតេល្យូម ។ ផ្ទៃរលីងបែបនេះ អាចឱ្យឈាមហូរដោយសេរី ។ ស្រទាប់កណ្តាលជាជាលិកាសាច់ដុំ ។ ស្រទាប់ក្រៅជាជាលិកាសន្ធាន ដែលបត់បែនបាន ។ ដោយសារទម្រង់របស់ស្រទាប់ទាំងនេះ អាកទែមានលក្ខណៈរឹងមាំនិងបត់បែនបាន ។ អាកទែអាចទប់នឹងសម្ពាធខ្ពស់របស់ឈាម ដូចជា នៅពេលឈាមចេញពីបេះដូងនិងពេលឈាមចូលបេះដូងវិញ ។



រូបទី1.6 : សរសៃឈាម

- វ៉ែន ជាសរសៃឈាមដែលនាំឈាមពីជាលិការបស់សារពាង្គកាយត្រឡប់ចូលបេះដូងវិញ ។ ភ្នាសរបស់វ៉ែនស្តើង និងមានភាពយឺតតិចតួចប៉ុណ្ណោះ ។ នៅក្នុងសរសៃវ៉ែនមានប្រិសដែលអាចឱ្យឈាមហូរតាមទិសដៅតែមួយឆ្ពោះទៅកាន់បេះដូង ។ វ៉ែននៅក្នុងដៃនិងជើងមានប្រិសច្រើន ដើម្បីជួយទប់មិនឱ្យឈាមហូរច្រាស់ត្រឡប់ទៅបេះដូងវិញ ។ ម្យ៉ាងទៀត កម្លាំងរុញឈាមរបស់បេះដូងក្នុងសរសៃវ៉ែនមានឥទ្ធិពលតិចជាងនៅក្នុងសរសៃអាកទែ ។ កត្តាមួយចំនួនជួយឱ្យឈាមធ្វើចលនាតាមសរសៃវ៉ែន ទីមួយ សរសៃវ៉ែនភាគច្រើនស្ថិតនៅក្បែរសាច់ដុំជាប់ឆ្អឹង ។ ការកន្ត្រាក់របស់សាច់ដុំ ជួយរុញឈាមតាមបណ្តោយសរសៃឈាម ។ ***ឧទាហរណ៍*** នៅពេលអ្នករត់ឬដើរ សាច់ដុំជាប់ឆ្អឹងនៅក្នុងជើងរបស់អ្នកកន្ត្រាក់ ហើយគាបសរសៃវ៉ែន នៅក្នុងជើង ។ ទីពីរ វ៉ែនធំៗនៅក្នុងសារពាង្គកាយមានប្រិស ដែលបង្ការឈាមហូរថយក្រោយ ។ទីបី ចលនាដង្ហើមដែលដាក់សម្ពាធច្របាច់ទល់ទៅនឹងវ៉ែនក្នុងទ្រូង គឺបង្ខំឈាមឱ្យរត់ឆ្ពោះទៅបេះដូងដែរ ។




*រូបទី 1.7 : ព័ទុរវ៉ែនមានប្រិស*

- នៅក្នុងសរសៃប្អូរ មានបណ្តូររូបធាតុផ្សេងៗរវាងឈាមនិងកោសិការបស់សារពាង្គកាយ ។ ភ្នាសរបស់សរសៃប្អូរ បង្កឡើងពីកោសិកាក្រាស់តែមួយស្រទាប់ ។ ដូចនេះ រូបធាតុទាំងឡាយអាចជ្រាបយ៉ាងងាយតាមភ្នាសនេះ ។ រូបធាតុផ្សេងៗដូចជា $O_2$ និងស្ករឆ្លងកាត់ពីឈាមទៅកោសិកាតាមភ្នាសសរសៃប្អូរ ។ ផលិតផលកាកសំណល់កោសិកា ធ្វើដំណើរតាមទិសដៅផ្ទុយ គឺចេញពីកោសិកាចូលទៅក្នុងឈាមតាមភ្នាសសរសៃប្អូរ ។ បណ្តាញសរសៃប្អូរ ភ្ជាប់អាកទែទៅនឹងវ៉ែន ។ សរសៃប្អូរភាគច្រើនតូចៗ ដូចនេះកោសិកាឈាមត្រូវតែឆ្លងកាត់ជាជួរ ។

## គ. ដំណើររបត់ឈាម

បេះដូងបញ្ជូនឈាមតាមដំណើររបត់ឈាមពីរសំខាន់គឺ របត់ឈាមសួត ឬរបត់ឈាមខ្លីនិងរបត់ឈាមទូទៅ ឬរបត់ឈាមវែង ។

- **របត់ឈាមសួត** បន្ថែម $O_2$ និងដកយក $CO_2$ ពីឈាម ។ឈាមខ្សត់ $O_2$ មកពីជាលិកាផ្សេងៗរបស់សារពាង្គកាយ ត្រឡប់ចូលបេះដូង ។ ឈាមនេះចូលទៅក្នុងថតលើស្តាំ ហើយហូរចូលទៅក្នុងថតក្រោមស្តាំ ។ ថតក្រោមស្តាំរុញឈាមនេះតាមសរសៃអាកទែសួតចូលទៅសួត ។អាកទែសួតជាអាកទែតែមួយគត់ដែលដឹកនាំឈាមខ្សត់ $O_2$ ។ អាកទែដទៃទៀតដឹកនាំឈាមសម្បូរ $O_2$ ។

ឈាមធ្វើដំណើរតាមសរសៃបូរនៅក្នុងសួត វាទទួលបាន$O_2$ និងបោះបង់ $CO_2$ ។ សរសៃបូរទាំងនេះបញ្ចូលគ្នាទៅជាវ៉ែនសួត ។ វ៉ែនទាំងនេះដឹកនាំឈាមសម្បូរ $O_2$ ទៅកាន់ថតលើឆ្វេងរបស់បេះដូង ។ វ៉ែនសួតជាវ៉ែនតែមួយគត់ដែលដឹកនាំឈាមសម្បូរ $O_2$ ។ វ៉ែនដទៃទៀតដឹកនាំឈាមខ្សត់ $O_2$ ។



*រូបទី 1.9 : ប្រដាប់របត់ឈាមមនុស្ស*

- **របត់ឈាមទូទៅ** ចេញពីថតលើឆ្វេង ឈាមហូរចូលថតក្រោមឆ្វេង ។ របត់ឈាមទូទៅចាប់ផ្ដើមចេញពីថតក្រោមឆ្វេងនៃបេះដូង ។ ថតក្រោមឆ្វេងខ្លាំង មានជញ្ជាំងក្រាស់ជាងថតផ្សេងទៀតរបស់បេះដូង ព្រោះវារុញឈាមទៅគ្រប់កន្លែងទាំងអស់នៃសារពាង្គកាយ ។ ចេញពីថតក្រោមឆ្វេង ឈាមត្រូវបានរុញចូលទៅក្នុងអាអក ។ អាអកបែកខ្នែងបង្កើតបានជាសរសៃអាកទែដែលបម្រើគ្រប់ផ្នែកទាំងអស់នៃសារពាង្គកាយ ។ អាកទែចែកជាបន្តបន្ទាប់ បង្កើតបានជាសរសៃឈាមតូចៗ ។ នៅចុងបញ្ចប់សរសៃឈាមតូចៗបង្កើតបានជាសរសៃបូរ ។ កោសិកានីមួយៗនៅក្នុងសារពាង្គកាយ នៅជិតសរសៃបូរ ។ បណ្ដូររូបធាតុរវាងឈាមនិងជាលិកាកើតមានឡើងតាមរយៈភ្នាសសរសៃបូរ ។ សរសៃបូររួមបញ្ចូលគ្នាបង្កើតបានជាវ៉ែន ។ នៅទីបញ្ចប់ វ៉ែនទាំងនេះដឹកនាំឈាមទៅកាន់បេះដូងវិញ ។ វ៉ែនធំជាងគេនៅក្នុងសារពាង្គកាយ ជាវ៉ែនការលើនិងវ៉ែនការក្រោម ។ វ៉ែនធំៗទាំងនេះនាំឈាមទៅថតលើស្ដាំនៃបេះដូង ។ វ៉ែនការលើដឹកនាំឈាម ត្រឡប់ពីក្បាល ដៃ និងទ្រូងទៅកាន់បេះដូង ។ វ៉ែនការក្រោមដឹកនាំឈាមត្រឡប់ពីផ្នែកខាងក្រោមនៃសារពាង្គកាយទៅកាន់បេះដូង ។

## 2. ឈាម

ឈាម ជាជាលិកាដែលដឹកនាំអ្វីៗស្ទើរទាំងអស់នៅក្នុងសារពាង្គកាយ ។ ក្នុងចំណោមជាលិកាទាំងអស់របស់សារពាង្គកាយ ឈាមជាជាលិការាវតែមួយប៉ុណ្ណោះ ។ វាមានប្រភពចេញពីស្រទាប់មេសូដែមរបស់អំប្រីយ៉ុង ។ ឈាមដែលមានផ្ទុករូបធាតុរលាយនិងរូបធាតុអណ្ដែត ធ្វើដំណើរតាមសរសៃឈាមទៅកាន់ផ្នែកនីមួយៗនៃសារពាង្គកាយ ។ ធាតុបង្កនីមួយៗរបស់ឈាម មាននាទីសំខាន់នៅក្នុងតំហែរក្សាថេរលំនិងនៅក្នុងសារពាង្គកាយ ។

## 2.1. នាទីរបស់ឈាម

ឈាមមាននាទីសំខាន់ដូចខាងក្រោម

- **ដឹកនាំសារធាតុចិញ្ចឹម** : ចំពោះមនុស្សនិងសត្វឆ្អឹងកងផ្សេងៗ ឈាមដឹកនាំសារធាតុចិញ្ចឹមរួមមានគ្លុយកូស អាស៊ីតអាមីនេ វីតាមីន រ៉ែ និង $O_2$ ទៅគ្រប់កោសិកាទាំងអស់នៃសារពាង្គកាយ ។ កាកសំណល់មេតាបូលីស ដូចជា $CO_2$ អ៊ុយរ៉េ ទឹកដែលច្រោះយកចេញពីកោសិកា ត្រូវបានដឹកនាំតាមឈាមទៅកាន់សរីរាង្គបញ្ចេញចោល ។
- **ដឹកនាំអរម៉ូន** : អរម៉ូនដែលផលិតចេញពីក្រពេញអង់ដូគ្រីន ក៏ដឹកនាំតាមឈាមទៅកាន់ជាលិកា និងកោសិកាគោលដៅ ។
- **តម្រូវកម្ដៅនិងថេរលំនឹង** : ***ឧទាហរណ៍*** ឈាមស្រូបកម្ដៅពីផ្នែកក្ដៅនៃសារពាង្គកាយ ហើយបញ្ចេញកម្ដៅនោះឱ្យទៅផ្នែកត្រជាក់ ។ ឈាមក៏រក្សាលំនឹង pH និងតុល្យភាពទឹក ។ សារធាតុមួយចំនួនដែលរលាយក្នុងឈាម ធន់នឹងការប្រែប្រួលរបស់ pH ។ សារធាតុខ្លះទៀតនៅក្នុងឈាមការពារមិនឱ្យទឹកចាកចេញពីឈាមនិងចូលក្នុងជាលិកានៃសារពាង្គកាយច្រើនពេក ។
- **កំណកឈាម** : ឈាមមាននាទីក្នុងការធ្វើឱ្យមានកំណកឈាមផងដែរ ដូចនេះវាការពារសារពាង្គកាយពីការបាត់បង់ឈាមក្នុងពេលមានរបួស ។
- **តំណាបស៊ាំ** : ឈាមក៏ការពារសារពាង្គកាយផងដែរ ។ វាដឹកនាំកោសិកាពិសេសនិងសាធាតុគីមីដែលការពារសារពាង្គកាយប្រឆាំងទល់និងភ្នាក់ងារបង្កជំងឺ ដូចជាវីរុស បាក់តេរីជាដើម ។

## 2.2. សមាសភាគឈាម

ឈាមបង្កឡើងពីប្លាស្មានិងកោសិកាឈាម ។ ប្លាស្មាមានប្រហែល 55 % នៃចំណុះឈាមទាំងអស់ ហើយ 45 % ដែលនៅសល់ គឺជាកោសិកាឈាម ។ មនុស្សពេញវ័យមានចំណុះឈាមពី 4 – 6 លីត្រក្នុងសារពាង្គកាយ ។

### ក. ប្លាស្មា

រូបធាតុភាគច្រើនដែលដឹកនាំតាមឈាម ធ្វើដំណើរនៅក្នុងប្លាស្មា ។ វាជាធាតុរាវពណ៌លឿងថ្លា ដែលមានទឹក 90 % ឯ 10 % នៅសល់ជារូបធាតុរលាយ រួមមានអំបិល គ្លុយកូស អាស៊ីតអាមីនេ ខស្ទ័នខ្លាញ់ វីតាមីន អង់ស៊ីម អរម៉ូន អ៊ុយរ៉េ អាស៊ីតអ៊ុយរិច អាស៊ីតឡាក់ទិច អង់ទីករ និងប្រូតេអ៊ីន ។

- **ទឹក** នៅក្នុងប្លាស្មាមាននាទីជាធាតុរំលាយ ។ វាដឹកនាំសារធាតុផ្សេងៗ ។
- **អំបិល** ត្រូវបានរលាយនៅក្នុងប្លាស្មា ក្រោមទម្រង់ជាអ៊ីយ៉ុង ។ នៅក្នុងប្លាស្មាមានសូដ្យូម ក្លរីត ប៊ីកាបូណាត ប៉ូតាស្យូម កាល់ស្យូម ផូស្វាត ម៉ាញ៉េស្យូម ទង់ដែង ដែក អ៊ីយ៉ូត ។

- ប្រូតេអ៊ីនប្លាស្មា ដែលជាធាតុរលាយ សម្បូរជាងគេនៅក្នុងប្លាស្មា មាននាទីនៅក្នុងតំហែរក្សាតុល្យភាពអូស្មូស រវាងស៊ីតូប្លាសកោសិកានិងប្លាស្មា ។ ទឹកមិនធ្វើចលនាតាមអូស្មូសទៅកោសិកាទេ ពីព្រោះប្លាស្មាសម្បូរដោយប្រូតេអ៊ីនរលាយ ។ ប្រូតេអ៊ីនសំខាន់បីប្រភេទដែលមាននៅក្នុងប្លាស្មា គឺអាល់ប៊ុយមីន ភីប្រីណូសែន និងក្លូប៊ុយលីន ។ ប្រូតេអ៊ីនប្លាស្មានីមួយៗមាននាទីផ្ទាល់របស់វា ។ អាល់ប៊ុយមីន ដែលជាប្រូតេអ៊ីនប្លាស្មាសម្បូរជាងគេ រក្សាទឹកមិនឱ្យចាកចេញពីឈាមនិងចូលទៅក្នុងកោសិកាច្រើនពេកតាមអូស្មូស ។ លក្ខណៈបែបនេះ គឺជួយរក្សាកំហាប់ទឹកឱ្យដូចគ្នាទាំងនៅក្នុងឈាមនិងក្នុងជាលិការបស់សារពាង្គកាយ ។

ភីប្រីណូសែន ពាក់ព័ន្ធទៅនិងកំណកឈាម ។ ក្លូប៊ុយលីនមាននាទីមួយចំនួនខុសៗគ្នា ។ ក្លូប៊ុយលីនខ្លះពាក់ព័ន្ធក្នុងដំណឹកនាំប្រូតេអ៊ីននិងសារធាតុដទៃទៀតពីផ្នែកមួយទៅផ្នែកមួយទៀតនៃសារពាង្គកាយ ។ ក្លូប៊ុយលីនផ្សេងទៀតជាអង់ទីករជួយក្នុងការប្រយុទ្ធប្រឆាំងនិងជំងឺឆ្លង ។ អង់ទីករជាប្រូតេអ៊ីនសម្រាប់បំផ្លាញសារធាតុចម្លែកនៅក្នុងសារពាង្គកាយ ។ សារធាតុទាំងនោះរួមមានសារពាង្គកាយបង្កជំងឺ ។

## ១. កោសិកាឈាម

ប្រហែល 40 % នៃមាឌឈាមទាំងអស់ជាកោសិកានិងបំណែកកោសិកាដែលអណ្តែតនៅក្នុងប្លាស្មា ។ នៅក្នុងឈាមមនុស្សមានកោសិកាសំខាន់បំផុត បីប្រភេទគឺ កោសិកាឈាមក្រហម ឬអេរីត្រូស៊ីត កោសិកាឈាមស ឬឡឹកូស៊ីត និងប្លាកែត ឬត្រុំបូស៊ីត ។

- កោសិកាឈាមក្រហម : ភាគច្រើននៃកោសិកាដែលបង្កើតឈាម គឺកោសិកាឈាមក្រហម ឬអេរីត្រូស៊ីតឬគោលិកាក្រហម ។ ក្នុងឈាម $1mm^3$ មានអេរីត្រូស៊ីតប្រហែល 5 លាន ។ នាទីសំខាន់របស់វា គឺដឹកនាំ $O_2$ ពីសួតទៅគ្រប់កោសិកាទាំងអស់នៃសារពាង្គកាយនិងនាំយក $CO_2$ ពីកោសិកាត្រឡប់ទៅកាន់សួតវិញនៅពេលដង្ហើមចេញ ។

នៅវ័យគភ៌ គោលិកាក្រហមត្រូវបានផលិតចេញពីថ្លើមនិងផាល ។ ចាប់ពីខែទី 5 នៃការលូតលាស់រហូតដល់ចុងបញ្ចប់នៃជីវិតគោលិកាក្រហមផលិតនៅក្នុងខួរក្រហមនៃឆ្អឹង (សន្ទះទ្រូង ឆ្អឹងជំនីរ ឆ្អឹងកង ឆ្អឹងវែង) ។ដំបូង អេរីត្រូប្លាសនៅក្នុងខួរក្រហមនៃឆ្អឹងធ្វើចំណែកយ៉ាងសកម្ម ។ វាជាកោសិកាគ្មានអេម៉ូក្លូប៊ីនទេ ប៉ុន្តែវាមានណ្វៃយ៉ូ ហើយធ្វើចំណែកយ៉ាងរហ័ស ។ បន្ទាប់មក វាបាត់បង់ណ្វៃយ៉ូ ប្រដាប់កុលស៊ី មីតូកុងឌ្រី និងធាតុកោសិកាដទៃទៀត ក្រោយពេលអេម៉ូក្លូប៊ីនត្រូវបានសំយោគរួចហើយនៅក្នុងអេរីត្រូប្លាស ។ នៅចុងបញ្ចប់រូបរាងរបស់វាប្រែប្រួលនិងមានសណ្ឋានដូចជាគូនថាសផតកណ្តាលនៅលើផ្ទៃទាំងសងខាង ។ គេហៅកោសិកានេះថាអេរីត្រូស៊ីត ។ លក្ខណៈផតនេះ ជួយ

សម្រួលនៅពេលវាឆ្លងកាត់ភ្នាសសរសៃឈាមតូចៗ (អាចបត់បែនបាននិងរមូលបានងាយស្រួល)និងបង្កើនសមត្ថភាពរបស់វា ក្នុងការភ្ជាប់ជាមួយ $O_2$ ។

ដូចនេះចំពោះមនុស្ស គោលិកាក្រហមពេញវ័យ គ្មានណ្វៃយ៉ូទេ ។ ស៊ីតូប្លាសរបស់វាពេញទៅដោយប្រូតេអ៊ីនដែលផ្ទុកជាតុដែក ហៅថា អេម៉ូក្លូប៊ីន ។ អេម៉ូក្លូប៊ីនជាសារធាតុម្យ៉ាងដែលផ្តល់ឱ្យឈាមមានពណ៌ក្រហម ។ $O_2$ ចងភ្ជាប់យ៉ាងងាយស្រួលជាមួយជាតុដែកនៅក្នុងអេម៉ូក្លូប៊ីន ដែលធ្វើឱ្យគោលិកាក្រហមមានសមត្ថភាពដឹកនាំ $O_2$ ។ គោលិកាក្រហមមួយអាចផ្ទុកអេម៉ូក្លូប៊ីន ប្រហែល 250 លានម៉ូលេគុល ។ គោលិកាក្រហមនីមួយៗអាចដឹកនាំ $O_2$ ចំនួន មួយពាន់លាន( 1 000 000 000 ) ម៉ូលេគុល ។




*រូបទី 1.10 : តុល្យភាពជាតុដែកក្នុងសារពាង្គកាយ*

ចំពោះមនុស្ស អេរីត្រូស៊ីតរស់បានប្រហែល 80 ទៅ 120 ថ្ងៃនៅក្នុងប្រដាប់របត់ឈាម ។ អាយុយ៉ាងខ្លីនេះបណ្តាលមកពីវាគ្មានណ្វៃយ៉ូនិងធាតុកោសិកាផ្សេងៗចាំបាច់សម្រាប់សំយោគប្រូតេអ៊ីន ។ រៀងរាល់នាទី គោលិកាក្រហមត្រូវបានបង្កើតឡើងជំនួសគោលិកាក្រហមចាស់ដែលត្រូវបំផ្លាញក្នុងសមាមាត្រស្មើគ្នា គឺ 2 លានកោសិកា ។ ដោយហេតុថា អេរីត្រូស៊ីតមិនអាចបន្តជីវិតបានវែង និងបន្តពូជបានដោយខ្លួនឯង ដូចនេះអេរីត្រូស៊ីតចាស់ងាច់រេចរឹលត្រូវបានយកចេញពីរបត់ឈាម ដោយបណ្តាញរេទីគុយឡូមអង់ដូប្លាសនៅក្នុងសរសៃឈាមរបស់ខួរក្រហមនៃឆ្អឹង ផាល ថ្លើម និងក្រពេញទីករងៃ ។ កោសិកាផាកូស៊ីតនៅក្នុងបណ្តាញរេទីគុយឡូមអង់ដូប្លាស រំលាយអេរីត្រូស៊ីត ហើយញែកជាតុដែកចេញសម្រាប់ប្រើប្រាស់ជាថ្មី ក្នុងការផលិតអេរីត្រូស៊ីតថ្មីនៅក្នុងផាលនិងខួរឆ្អឹងក្រហម ។

- គោលិកាឈាមសឬឡឺកូស៊ីតឬគោលិកាស ជាកោសិកាឈាមគ្មានពណ៌ ។ វាមានរូបរាងធំជាងគោលិកាក្រហមនិងមានណ្វៃយ៉ូ ។ ដូចនេះវាអាចរស់បានច្រើនខែឬរាប់ឆ្នាំ ។ ចំពោះមនុស្សមានសុខភាពល្អ គោលិកាសមានប្រហែល 6 000 ទៅ 7 000 ក្នុង $1mm^3$ ឈាម ។

នាទីសំខាន់របស់គោលិកាស គឺការពារសារពាង្គកាយទល់និងភ្នាក់ងារបង្កជំងឺដូចជា បាក់តេរី វីរុស ។ គោលិកាសខ្លះអាចបំផ្លាញបាក់តេរីនិងកោសិកាចម្លែកតាមផាកូស៊ីតូស ។ គោលិកាសខ្លះទៀតផលិតប្រូតេអ៊ីនពិសេសហៅថាអង់ទីករ ។

ខួរឆ្អឹងនិងជាលិកាទឹករងៃផលិតប្រហែលមួយលានគោលិកាសរៀងរាល់វិនាទី ។ ពេលមានការចម្លងរោគ នៅក្នុងឈាមចំនួនគោលិកាសអាចកើនឡើងពី 30 000 ឬច្រើនជាងនេះក្នុង $1mm^3$ ឈាម ។ គោលិកាសចែកជាពីរក្រុមសំខាន់ គឺក្រានុយឡូស៊ីតនិងអាក្រានុយឡូស៊ីត ។ ក្រុមទាំងពីរនេះមានលក្ខណៈខុសគ្នាដោយសារទំហំ អាយុ ទីតាំងនៅក្នុងសារពាង្គកាយ រូបរាងរបស់ណ្វៃយ៉ូ ចំនួនគ្រាប់នៅក្នុងស៊ីតូប្លាស ។

- ក្រានុយឡូស៊ីត កើតនៅក្នុងខួរឆ្អឹងក្រហម ។ ណ្វៃយ៉ូរបស់វាមានរាងជាក្លែបនិងស៊ីតូប្លាសមានគ្រាប់ ។ នៅពេលក្រានុយឡូស៊ីតមានវ័យចំណាស់ ណ្វៃយ៉ូចែកចេញជា 2 – 5 ក្លែប ដែលភ្ជាប់គ្នាដោយសរសៃក្រូម៉ាទីន ។ ចំនួនក្លែបរបស់ណ្វៃយ៉ូទាក់ទងទៅនិងវ័យរបស់កោសិកា ។

+ ណឺត្រូភីល : វាមានពី 60 ទៅ 70 % នៃគោលិកាស ។ ណឺត្រូភីលមានទំហំពី 9 ទៅ 12μm ។ ណ្វៃយ៉ូមានពី 2 ទៅ 5 ក្លែប ដែលភ្ជាប់គ្នាពីមួយទៅមួយ ដោយសរសៃក្រូម៉ាទីន ។ ណឺត្រូភីលរំលាយគោលិកាសចាស់រេចរិលនិងចាប់បាក់តេរីដោយផាកូស៊ីតូស ។




*រូបទី 1.11 : ប្រភេទផ្សេងៗនៃគោលិកាស*

+ អេអូស៊ីណូភីល : កោសិកានេះមានត្រឹមតែពី 1 ទៅ 4 % នៃគោលិកាស ។ វាមានទំហំពី 10 ទៅ 12μm ហើយណ្វៃយ៉ូរបស់វាមានត្រឹមតែពីរក្លែប ។ សកម្មភាពផាកូស៊ីតូសមានលក្ខណៈខ្សោយជាងគោលិកាសដទៃទៀត ។

+ បាសូភីល : កោសិកានេះមាន 0.5 % នៃគោលិកាស ។ វាមានទំហំពី 8 ទៅ 11μm ។ ណ្វៃយ៉ូរបស់វាធំនិងមានក្លែបតិចតួច ។ បាសូភីលមិនធ្វើផាកូស៊ីតូសទេ ប៉ុន្តែវាអាចបញ្ចេញធាតុគីមីអេប៉ារីន (*heparin*) និងអ៊ីស្តាមីន (*histamine*) ។

- អាក្រានុយឡូស៊ីត : ណ្វៃយ៉ូមានរាងកោងនិងគ្មានក្លែប ហើយស៊ីតូប្លាសរបស់វាថ្លា ។ វាមានលក្ខណៈខុសពីក្រានុយឡូស៊ីត ដោយសមត្ថភាពធ្វើចំណែករបស់វា ។ អាក្រានុយឡូស៊ីតភាគច្រើន គឺឡាំផូស៊ីតនិងម៉ូណូស៊ីតត្រូវបានពេញវ័យនៅក្នុងក្រពេញទឹករងៃ ផាល និងទីមុស ។

+ ម៉ូណូស៊ីត : កោសិកានេះមានពី 2 ទៅ 8 % នៃឡឺកូស៊ីត ។ ម៉ូណូស៊ីតជាឡឺកូស៊ីតធំៗដែលមានណ្វៃយ៉ូកោង ស៊ីតូប្លាសថ្លានិងសម្បុរធាតុកោសិកា ។ វាមានទំហំពី 12 ទៅ 20μm ។ វាមានអាយុ

វែងជាងគេ ។ វាមានសមត្ថភាពធ្វើជាកូស៊ីតូសខ្ពស់ ។ ម៉ូណូស៊ីតលូតលាស់ទៅជាម៉ាក្រូផាសដែលអាចជ្រៀតតាមភ្នាសសរសៃប្លូរនិងផ្លាស់ទីក្នុងជាលិកានិងសរីរាង្គ ។ វាអាចក្តោបបាក់តេរីបានប្រហែល 100 ក្នុងមួយដង ។ ម៉ូណូស៊ីតមាននាទីសំខាន់ក្នុងការត្រួតពិនិត្យជំងឺឆ្លងដោយបាក់តេរីរយៈពេលយូរនិងសំអាតជាលិកាមានរបួស ។

+ **ឡាំផូស៊ីត** : កោសិកានេះមានពី 20 ទៅ 35 % នៃឡឺកូស៊ីតទាំងអស់ ។ វាជាឡឺកូស៊ីតដែលតូចជាងគេបង្អស់ ដោយមានទំហំ 8μm ។ វាមានណ្វៃយ៉ូធំរាងមូលនិងស៊ីតូប្លាសតិច ដែលជាហេតុមិនអាចឱ្យវាធ្វើជាកូស៊ីតូសបាន ។ ឡាំផូស៊ីតមាននៅក្នុងជាលិកាគ្រប់ប្រភេទ លើកលែងតែជាលិកាសរសៃប្រសាទ ។ វាសម្បូរនៅក្នុងប្រព័ន្ធទឹករងៃនិងឈាម ។ ឡាំផូស៊ីតផលិតសារធាតុគីមីពិសេស ដែលចូលរួមក្នុងការប្រឆាំងជាមួយមេរោគ ។ ឡាំផូស៊ីតមានពីរប្រភេទ :

**ឡាំផូស៊ីត B** វិវត្តទៅជាប្លាស្មូស៊ីត ដែលបញ្ចេញអង់ទីករ ។




***រូបទី 1.12 : កំណកោសិកាឈាមនៅក្នុងខួរឆ្អឹង***

**ឡាំផូស៊ីត T** សំខាន់ជាងគេមានពីរប្រភេទ ឡាំផូស៊ីត $T_8$ និងឡាំផូស៊ីត $T_4$ ។ ឡាំផូស៊ីត $T_8$ វិវត្តទៅជាឡាំផូស៊ីត ស៊ីតូតុកស៊ិច (ឬឡាំផូស៊ីត T សម្លាប់) ។ ឡាំផូស៊ីត $T_4$ ក្លាយជាឡាំផូស៊ីតT ជំនួយ ដែល

ផលិតប្រូតេអ៊ីនម្យ៉ាងហៅថា អាំងទែឡឺគីន ។ អាំងទែឡឺគីនមាននាទីជាសំឡាំផូស៊ីត B ព្រមទាំងត្រួតពិនិត្យការធ្វើចំណែក និងបំលែងឯកទេសរបស់ឡាំផូស៊ីតផ្សេងៗទៀត ។

- **ប្លាកែត ឬត្រុំបូស៊ីត** មានចំនួនពី 250 000 ទៅ 500 000 ក្នុងឈាម $1 mm^3$ ។ វាមានទំហំពី 2 ទៅ $4\mu m$ គ្មានណ្វៃយ៉ូនិងគ្មានពណ៌ ។ ប្លាកែតមិនមែនជាកោសិកាទេ ។ វាជាលទ្ធផលដែលបានមកពីបំណែកតូចៗនៃកោសិកាធំមួយចំនួនហៅថា **មេកាការីយ៉ូស៊ីត** នៅក្នុងខួរនៃឆ្អឹង ។ ប្លាកែតអាចរស់បានប្រហែលមួយអាទិត្យ ។ វាមាននាទីយ៉ាងសំខាន់ក្នុងការបញ្ឈប់ការហូរឈាមពីមុខរបួស ។

នៅពេលសរសៃឈាមមានរបួស ប្លាកែតផលិតស៊ីរ៉ូតូនីន (*serotonin*) ដែលធ្វើឱ្យកន្លែងមុខរបួសរួមតូច ។ លក្ខណ នេះជួយបន្ថយល្បឿននៃការហូរឈាមពីមុខរបួស ។ ប្លាកែតនិងជាលិការងរបួស (ភ្នាសសរសៃឈាមរបួស) បញ្ចេញអង់ស៊ីមត្រុំបូប្លាស្ទីន ។ អង់ស៊ីមនេះ បំប្លែងប្រូតេអ៊ីនប្រូត្រុំប៊ីនឱ្យទៅជាត្រុំប៊ីន ដោយមានវត្តមានអ៊ីយ៉ុងអំបិលកាល់ស្យូម $Ca^{++}$ ។ បន្ទាប់មក ត្រុំប៊ីនមានអំពើដូចជាអង់ស៊ីមដោយចាប់ផ្តើមដំណើរការប្រតិកម្មគីមីជាបន្តបន្ទាប់ ដែលបំប្លែងប្រូតេអ៊ីនប្លាស្មា ភីប្រ៊ីណូសែនទៅជាភីប្រ៊ីន ។ ម៉ូលេគុលភីប្រ៊ីនបង្កើតបានជាបណ្តាញសរសៃឆ្មារៗ ដែលទាក់គោលិកាក្រហមនិងប្លាកែតដើម្បីបង្កើតបានជាកំណកឈាម ។ គោលិកាក្រហមទាំងនេះធ្វើឱ្យកំណកឈាមមានពណ៌ក្រហម ។ ប្លាកែត ដែលទាក់ជាប់នៅក្នុងសំណាញ់នៃកំណកឈាម បញ្ចេញអង់ស៊ីមត្រុំបូប្លាស្ទីនយ៉ាងច្រើន ។ អង់ស៊ីមនេះជួយឱ្យឈាមកកកាន់តែខ្លាំង ។ ក្រោយពីសរសៃឈាមរបួសជួសជុលរួចហើយ ប្លាស្មាផលិតអង់ស៊ីមអេប៉ារីន ដែលបង្អាក់ដំណើរកំណកឈាមក្នុងសរសៃឈាម ។ វីតាមីនដ៏មានប្រសិទ្ធភាពមួយក្នុងដំណើរកំណកឈាម ជាវីតាមីន K ។ នាទីរបស់វា គឺបំប្លែងប្រូត្រុំប៊ីនឱ្យទៅជាត្រុំបូប្លាស្ទីននៅក្នុងថ្លើម ។




1 ជាលិការបួសនិងប្លាកែត បញ្ចេញអង់ស៊ីមត្រុំបូប្លាស្ទីន

2. ប្លាកែតបិទរន្ធរបួស ។ នៅក្នុងប្លាស្មាអង់ស៊ីមត្រុំបូប្លាស្ទីនបំប្លែងប្រូត្រុំប៊ីនជាត្រុំប៊ីន ។

3 ភីប្រ៊ីណូសែនប្លាស់ជាភីប្រ៊ីន ដោយវត្តមានរបស់ត្រុំប៊ីន ។ ភីប្រ៊ីនបង្កើតជាសំណាញ់ដែលទាក់គោលិកានិងភ្ជិតមុខរបួស ។

***រូបទី 1.13 : កំណកឈាម***

## ១. តាពស៊ាំ

ប្រៀបដូចជាទីក្រុងមួយស្ថិតនៅក្រោមការឡោមព័ទ្ធរបស់ខ្មាំង សារពាង្គកាយរបស់អ្នកក៏ព័ទ្ធជុំវិញដោយហ្វូងមេរោគ ដូចជាបាក់តេរី វីរុស ប្រូទីស និងបរាសិតផ្សេងៗទៀត ។ តាមធម្មតា អ្នកនៅតែមានសុខភាពល្អ ពីព្រោះសារពាង្គកាយរបស់អ្នករុញច្រានមេរោគទាំងនោះចេញឆ្ងាយ ។ សារពាង្គកាយអ្នកបានប្រើប្រាស់ប្រព័ន្ធការពារយ៉ាងខ្លាំងក្លា ប្រឆាំងទៅនឹងមេរោគមួយចំនួន ដែលជ្រៀតចូល ។ ប្រព័ន្ធការពារនោះ ហៅថាប្រព័ន្ធស៊ាំ ។ ប្រព័ន្ធស៊ាំ ក្លាយជាសកម្មបាន ក្រោយពីមានការជ្រៀតចូលរបស់មេរោគឬសារធាតុចម្លែកពីក្នុងបរិស្ថាន ។ ស្បែកប្រៀបដូចជា របាំងការពារមេកានិចជាបណ្ដោះអាសន្ន ដែលការពារសារពាង្គកាយពីការជ្រៀតចូលរបស់បាក់តេរី ឬមីក្រូសារពាង្គកាយចង្រៃពីខាងក្រៅ ។ តាមធម្មតា បាក់តេរីខ្លះដែលរស់នៅលើស្បែក រារាំងការបង្ករោគរបស់មីក្រូសារពាង្គកាយ ។ សារធាតុគីមីនៅក្នុងទឹកភ្នែកនិងញើស បំបាត់ចោលបាក់តេរីមួយចំនួន ។ រសក្រពះរួមមានHCl និងអង់ស៊ីមបង្អាក់ការលូតលាស់របស់មេរោគ ដែលត្រូវបានលេបចូលតាមចំណីអាហារទៅក្នុងក្រពះ ។ កម្ទេចកំទីធូលីនិងសារធាតុផ្សេងៗក្នុងខ្យល់ ដែលចូលទៅក្នុងសារពាង្គកាយតាមដង្ហើមចូលត្រូវបានច្រោះនៅក្នុងរន្ធច្រមុះ ។ មេរោគដែលចូលទៅដល់បំពង់ខ្យល់ ត្រូវបានទាក់ជាប់ដោយស្រទាប់ស្លេស្ម ចំណែកឯមេរោគដែលចូលទៅដល់កូនថង់សួត ត្រូវបានបំបាត់ចោលដោយម៉ាក្រូផាស ។

ថ្វីបើរបាំងការពារមាននៅគ្រប់ផ្នែកទាំងអស់ក៏ដោយ ប៉ុន្តែក៏នៅតែមានធាតុបង្ករោគមួយចំនួនដែលអាចជ្រៀតចូលទៅដល់ប្រដាប់របត់ឈាមរបស់សារពាង្គកាយ ។ ដើម្បីឆ្លើយតប សារពាង្គកាយផលិតសារធាតុមួយចំនួន ដែលប្រឆាំងទៅនឹងកោសិកាចម្លែកទាំងនោះ គឺតំណបស៊ាំ ។

### ១.1. តំណបមិនយថាប្រភេទ

ការមុតបំណែកឈើតូចមួយនៅចុងម្រាមដៃ គឺជារបួសតូចមួយប៉ុណ្ណោះ ។ វាចាក់ទម្លុះរន្ធមួយនៅលើស្បែក កើតជាមុខរបួសមួយដែល មេរោគអាចជ្រៀតចូលបានភ្លាម ។ ដំបូងមេរោគលូតលាស់ហើយបន្តពូជយ៉ាងរហ័ស បន្ទាប់មកវាបញ្ចេញធាតុពុល ដែលសម្លាប់កោសិការបស់សារពាង្គកាយនៅជុំវិញកន្លែងរបួសនោះ ។ សារពាង្គកាយរបស់អ្នកឆ្លើយតបយ៉ាងរហ័សដោយបិទជិតរន្ធធ្លុះនោះ ហើយធ្វើឲ្យកើតមាននូវប្រតិកម្មគីមីជាបន្តបន្ទាប់ ដើម្បីបំផ្លាញមេរោគទាំងនោះ ។ ម្រាមដៃរបស់អ្នកហើមប៉ោង ពណ៌ក្រហម ហើយមានអារម្មណ៍ក្ដៅនិងឈឺចាប់ ។ ទាំងអស់នេះជាសញ្ញាបង្ហាញថាសារពាង្គកាយប្រឆាំងតបទៅនឹងមេរោគ ។ ពណ៌ក្រហមនិងការហើមជាផ្នែកមួយនៃប្រតិកម្មរលាកចំពោះការបង្ករោគឬរបួស ។

## ក. អ៊ីស្តាមីន




*រូបទី 1.14 : ប្រតិកម្មរលាក*

កោសិការបួសនៅក្បែរផ្ទៃស្បែកបញ្ចេញសារធាតុអ៊ីស្តាមីន (*histamine*) ដែលបណ្តាលឲ្យសរសៃឈាមក្បែរមុខរបួសរីកធំឡើងនិងបង្កើនការហូរឈាមនៅទីនោះ ។ ធាតុរាវជ្រាបចេញពីសរសៃឈាមទាំងនោះ ទៅក្នុងកន្លែងរបួស ។ លក្ខណ ទាំងនេះបណ្តាលឱ្យកន្លែងរបួសហើមប៉ោងនិងមានពណ៌ក្រហម ។ កោលិកាងាប់ កោសិកាខូចខាតរបស់សារពាង្គកាយនិងមេរោគងាប់ ផ្សំជាមួយធាតុរាវ ដើម្បីបង្កើតបានជាសារធាតុពណ៌លឿងខ្ចី ឬពណ៌ស ហៅថាខ្ទុះ ។ ជារឿយៗ ខ្ទុះប្រមូលផ្តុំនៅត្រង់មុខរបួស ។ វត្តមាននៃខ្ទុះ ឲ្យសញ្ញាថាផាកូស៊ីតកំពុងវាយប្រហារមេរោគ ។

## ខ. តំណាបសីតុណ្ហភាព

ពេលសារពាង្គកាយរបស់អ្នកចាប់ផ្តើមប្រយុទ្ធទល់នឹងមេរោគ សីតុណ្ហភាពក្នុងសារពាង្គកាយរបស់អ្នកកើនឡើងពី 2 ទៅ 3 អង្សា លើសពីសីតុណ្ហភាពធម្មតា (37°C ) ។ ការឡើងខ្ពស់នៃសីតុណ្ហភាពនេះ ហៅថាជំងឺគ្រុន ។ វាជារោគសញ្ញាមួយ ដែលបង្ហាញថាសារពាង្គកាយកំពុងតែឆ្លើយតបទៅនិងការឆ្លងមេរោគ ។ គ្រុនមានប្រយោជន៍ ព្រោះបាក់តេរីដែលបង្កជំងឺភាគច្រើនមិនអាចលូតលាស់បានល្អនៅក្នុងសីតុណ្ហភាពខ្ពស់បានទេ ។ ថ្វីបើគ្រុនអាចបន្ថយល្បឿននៃការលូតលាស់របស់បាក់តេរីក៏ដោយ ប៉ុន្តែក្តៅខ្លាំងពេក ក៏បណ្តាលឱ្យមានគ្រោះថ្នាក់បានដែរ ។ កម្តៅខ្ពស់ពេកអាចបំផ្លាញប្រូតេអ៊ីនសំខាន់ៗរបស់កោសិកា ។ សីតុណ្ហភាពខ្ពស់ជាង 39°C អាចចាត់ទុកថាគ្រោះថ្នាក់ ហើយខ្ពស់ជាង 41°C អាចបណ្តាលឱ្យស្លាប់ ។

## ១.2. តំណបយថាប្រភេទ

នៅពេលជំងឺមួយកើតឡើង កិច្ចការពារតាមបែបធម្មជាតិ ដូចជា ជាកូស៊ីតូស មិនអាចកំចាត់មេរោគឈ្លានពានបានទេ ។ ប៉ុន្តែជាអំណោយផលល្អ សារពាង្គកាយរបស់យើងមានប្រព័ន្ធស៊ាំផ្សេងទៀត ដែលមានសកម្មភាពខ្លាំងប្រឆាំងទៅនិងមេរោគយថាប្រភេទនោះ ។ ដើម្បីប្រឆាំងទៅនិងមេរោគយថាប្រភេទ ចលនការនៃកិច្ចការពារយថាប្រភេទរបស់ប្រព័ន្ធស៊ាំ មានពីរបែប ៖

*ទី1* : ប្រព័ន្ធស៊ាំផលិតប្រូតេអ៊ីនរលាយ (អង់ទីករ) ដែលរត់ក្នុងចរន្តឈាម ។ អង់ទីករចងភ្ជាប់ទៅនិងអង់ទីសែនរបស់មេរោគ ។ លំនាំនេះហៅថាតំណបស៊ាំតាមរយៈ អង់ទីករ ។ តំណបស៊ាំ នេះមានប្រសិទ្ធភាពពិសេសប្រឆាំងទៅនិងបាក់តេរី ឬវីរុសដែលជួបប្រទះនៅក្នុងធាតុរាវ (ឈាមនិងទឹករងៃ) សារពាង្គកាយ ។

*ទី2* : ប្រព័ន្ធស៊ាំរៀបចំជាក្រុមកោសិកាដែលមានអំពើដោយផ្ទាល់ប្រឆាំងនឹងកោសិកាចម្លែកឬជាលិកាផ្ទុកមេរោគ ។ លំនាំនេះ ហៅថាតំណបស៊ាំតាមរយៈ កោសិកា ។

### ក. តំណបស៊ាំតាមរយៈអង់ទីករ

ឡាំផូស៊ីត B កើតឡើងនិងធ្វើបំលែងឯកទេសនៅក្នុងខួរឆ្អឹង ។ វាស្គាល់អង់ទីសែនដោយសារធ្នូលលើភ្នាសរបស់វា ។ ពេលចេញពីខួរឆ្អឹង ឡាំផូស៊ីតនីមួយៗអាចផ្ទុកធ្នូលលើភ្នាសតែមួយបែបទេ ។

បន្ទាប់ពីមេរោគជ្រៀតចូលក្នុងសារពាង្គកាយ នៅក្នុងឈាមនិងទឹករងៃមានឡាំផូស៊ីត B ចំនួនពីរទៅបីជួបប្រទះដោយចៃដន្យជាមួយអង់ទីសែនមួយ ឬច្រើនរបស់មេរោគនោះ ។ ក្នុងករណីនេះ ឡាំផូស៊ីត B ជួបអង់ទីសែនដែលស្ថិតលើផ្ទៃភ្នាសរបស់មេរោគ មិនទាន់ខូចខាត ។ ក្នុងករណីខ្លះទៀត វាអាចជួបអង់ទីសែន នៅលើផ្ទៃភ្នាសរបស់ម៉ាក្រូផាសដែលបានមកពីជាកូស៊ីតូស ។

ប្រសិនបើឡាំផូស៊ីត B លេចឡើង ហើយជួបជាមួយអង់ទីសែនដែលត្រូវគ្នាទៅនិងធ្នូលលើភ្នាសរបស់វា ធ្នូលលើភ្នាសនេះចងភ្ជាប់ទៅនិងអង់ទីសែននោះ ។ ដំណើរការចងភ្ជាប់នេះធ្វើឱ្យឡាំផូស៊ីតB សកម្មនិងចាប់ផ្តើមដំណើរការតំណបស៊ាំតាមរយៈអង់ទីករ ។

ភ្លាមនោះឡាំផូស៊ីត B បំបែកអង់ទីសែនជាប៉ិបទីតតូចៗជាច្រើន ដែលនៅលើភ្នាសកោសិការបស់ឡាំផូស៊ីត B ។ ប្រសិនបើប៉ិបទីតនេះ ត្រូវបានទទួលស្គាល់ដោយធ្នូលលើភ្នាសរបស់ឡាំផូស៊ីត T ជំនួយ ឡាំផូស៊ីត T ជំនួយនេះភ្ជាប់ជាមួយឡាំផូស៊ីត B ។ ឡាំផូស៊ីត T ជំនួយបញ្ចេញអាំងទែឡឺគីនដែលភ្ញោចឡាំផូស៊ីតB ឱ្យធ្វើចំណែកយ៉ាងរហ័ស ដោយបង្កើតជាក្រុមឡាំផូស៊ីត B (ក្លូន) ដែលមានសេនេទិចដូចគ្នាបេះបិទ ។




① ផ្ទៃលភ្នាសឡាំផូស៊ីត B ចងភ្ជាប់ជាមួយអង់ទីសែនរបស់មេរោគ ។

② ម៉ាក្រូផាសក្តោបបាក់តេរី ហើយរំលាយវា ។

③ នៅលើភ្នាសម៉ាក្រូផាសមានអង់ទីសែនរបស់បាក់តេរី ។ ឡាំផូស៊ីត T ជំនួយចងភ្ជាប់ជាមួយអង់ទីសែននៅលើភ្នាសម៉ាក្រូផាស ។ ចំណងនេះ ភ្ញោចឡាំផូស៊ីត T ជំនួយធ្វើចំណែក ។

④ ឡាំផូស៊ីត T ជំនួយភ្ជាប់ទៅនឹងបំណែកនៃអង់ទីសែន លើភ្នាសឡាំផូស៊ីត B និងបញ្ចេញកត្តាលូតលាស់ដែលភ្ញោចឡាំផូស៊ីត B ឲ្យចែកខ្លួនបានជាក្លូនឡាំផូស៊ីត B

⑤ ឡាំផូស៊ីត B ខ្លះក្លាយជាប្លាស្មូស៊ីតដែលផលិតអង់ទីករ ។ ឡាំផូស៊ីត B ខ្លះទៀតក្លាយជាឡាំផូស៊ីត B លំនឹក ។

*រូបទី 1.15 : តំណាបស៊ាំតាមរយៈអង់ទីករ*

រយៈពេលពី 5 ទៅ 10 ថ្ងៃ ក្រោយពេលចំណែកកោសិកា ឡាំផូស៊ីត B ជាច្រើននៃក្លូននេះ បានក្លាយទៅជាប្លាស្មូស៊ីត ។ ប្លាស្មូស៊ីតនេះចាប់ផ្តើមផលិតអង់ទីករសម្រាប់ប្រឆាំងនឹងអង់ទីសែនរបស់មេរោគ ។ រយៈពេលនៃការផលិតនេះ (5-10ថ្ងៃ)ជាមូលហេតុមួយដែលអ្នកមិនទាន់ជាសះស្បើយពីជំងឺភ្លាមៗ ។ ឡាំផូស៊ីត B ផ្សេងទៀតនៃក្លូន ក្លាយទៅជាឡាំផូស៊ីត B លំនឹក ហើយត្រូវបានស្តុកក្នុងផាលដែលនៅទីនោះ វាត្រៀមខ្លួនសម្រាប់ឆ្លើយយ៉ាងរហ័សនៅពេលសារពាង្គកាយជួបប្រទះអង់ទីសែនដដែលនេះម្តងទៀត ។ វត្តមានឡាំផូស៊ីត B លំនឹកទាំងនេះ បង្កើតតំណាបលើកទី 2 នៃប្រព័ន្ធស៊ាំមេរោគទៅនឹងអង់ទីសែនដដែលលឿននិងខ្លាំងជាងលើកទី 1 ។ នេះជាមូលដ្ឋានសម្រាប់ភាពស៊ាំអចិន្ត្រៃយ៍ចំពោះជំងឺមួយចំនួន ។

## ១. តំណាបស៊ាំតាមរយៈកោសិកា

កោសិកាដែលទទួលខុសត្រូវចំពោះតំណាបស៊ាំនេះ គឺឡាំផូស៊ីត T ។ ពេលវីរុសចូលក្នុងសារពាង្គកាយ វាជ្រៀតចូលក្នុងកោសិកា បន្ទាប់មកវាបន្តពូជនិងលូតលាស់នៅទីនោះ ។ មេរោគបង្កើតបានអង់ទីសែនថ្មីនៅលើភ្នាសកោសិកា (ឧទាហរណ៍ អង់ទីសែនវីរុស) ហើយអង់ទីករមិនអាចបំផ្លាញមេរោគនេះបានទេ ។ ពេលនោះ កោសិកាផ្ទុកមេរោគ មានសភាពដូចជា កោសិកាក្រៅសារពាង្គកាយ ហើយប្រតិកម្មតំណាបស៊ាំតាមរយៈកោសិកា ចាប់ផ្តើមដំណើរការឡើង ( រូបទី 1.16) ។

ឡាំផូស៊ីត T ក៏មានចួលភ្នាសរបស់វាដែរ ប៉ុន្តែវាមិនផលិតអង់ទីករទេ ។ សារពាង្គកាយរបស់យើងផលិតឡាំផូស៊ីត T បួនប្រភេទ ដែលមាននាទីខុសៗពីគ្នា ។

***ឡាំផូស៊ីត T ជំនួយ*** : វាផលិតអាំងទែឡឺគីនដែលភ្ញោចឡាំផូស៊ីតB ឱ្យធ្វើចំណែកនិងបំលែងឯកទេសជាប្លាស្មូស៊ីត( ផលិតអង់ទីករ )និងឡាំផូស៊ីត B លំនឹក ។ ឡាំផូស៊ីតT ជំនួយផលិតសារធាតុគីមីដែលភ្ញោចឡាំផូស៊ីតT សម្លាប់ ឱ្យធ្វើចំណែកនិងបំផ្លាញកោសិកាផ្ទុកមេរោគដោយបង្កើនសកម្មភាពរបស់ម៉ាក្រូផាស ។

***ឡាំផូស៊ីត T សម្លាប់*** : វាភ្ជាប់ខ្លួនទៅលើភ្នាសកោសិកា ដែលមានផ្ទុកអង់ទីសែន (កោសិកាផ្ទុកមេរោគ) បន្ទាប់មកវាបញ្ចេញប្រូតេអ៊ីនមួយប្រភេទសម្រាប់ចោះភ្នាសកោសិកានោះ ។ តាមរយៈរន្ធនេះអាចឲ្យទឹក និងអំបិលចូលទៅក្នុងកោសិកា ។ កោសិកាដែលស្ថិតក្រោមការវាយប្រហារ ឡើងប៉ោងហើយផ្ទុះបែក ។

***ឡាំផូស៊ីត T លំនឹក*** : វារក្សាលំនឹកនៃការទទួលស្គាល់អង់ទីសែន ។ ប្រសិនបើអង់ទីសែនចូលទៅក្នុងសារពាង្គកាយជាលើកទី2នោះ ឡាំផូស៊ីត T លំនឹកធ្វើចំណែក ហើយប្រតិកម្មតំណបស៊ាំតាមរយៈកោសិកាកើតឡើងយ៉ាងលឿននិងខ្លាំងបំផុត ។

***ឡាំផូស៊ីត T បង្អាក់*** : ជួយបង្អាក់តំណបស៊ាំ ដោយបន្ថយអត្រាចំណែករបស់ឡាំផូស៊ីតB និងការផលិតអង់ទីករថយចុះនៅពេលការឆ្លងរោគស្ថិតនៅក្រោមការត្រួតពិនិត្យ ។ វាក៏អាចបង្អាក់សកម្មភាពឡាំផូស៊ីត T សម្លាប់ដែរ ។




***រូបទី 1.16 : តំណបស៊ាំតាមរយៈកោសិកា***

## មេរៀនសង្ខេប

- កណ្ដូបមានប្រដាប់របត់ឈាមបើក ដែលក្នុងនោះឈាមហូរទៅក្នុងលំហនៃរាងកាយ ហើយស្រោចស្រពទៅលើជាលិកាទាំងឡាយ ។ ជន្លេនមានប្រដាប់របត់ឈាមបិទ ហើយឈាមរបស់វាស្ថិតនៅក្នុងសរសៃឈាម ។
- សត្វឆ្អឹងកងមានប្រដាប់របត់ឈាមបិទ ។ ចំពោះត្រីមានប្រដាប់របត់ឈាមទោល ។ ឈាមធ្វើដំណើរពីបេះដូងទៅស្រកី រួចបន្តទៅសារពាង្គកាយ បន្ទាប់មកត្រលប់ចូលបេះដូងវិញ ។ ចំពោះអំភិបពេញវ័យ ភាគច្រើនមានសួតលូតលាស់ ដែលប្រើប្រាស់សម្រាប់ដកដង្ហើមនៅលើគោក ។ បេះដូងរបស់វាមានថតលើពីរនិងថតក្រោមមួយ ។ ដូចនេះឈាមសម្បូរ $O_2$ និងឈាមខ្សត់ $O_2$ មិនអាចលាយចូលគ្នានៅក្នុងថតលើទេ តែឈាមទាំងពីរបែបនេះ អាចលាយចូលគ្នាក្នុងថតក្រោមរបស់បេះដូង ។
- បេះដូងបក្សីនិងថនិកសត្វមានសន្ទះខណ្ឌដែលចែកបេះដូងជាបួនថត ។ ដំណើររបត់ឈាមមានពីរគឺ ដំណើរពីបេះដូងទៅសួតនិងដំណើរពីបេះដូងទៅសារពាង្គកាយ ។ ដូចនេះគ្មានល្បាយរវាងឈាមមាន$O_2$ និងឈាមខ្សត់ $O_2$ ។
- ឈាមបង្កឡើងពីប្លាស្មា និងកោសិកាឈាម ។ ប្លាស្មាជាធាតុរាវពណ៌លឿងថ្លា ដែលក្នុងនោះភាគច្រើនជាទឹកនិងរូបធាតុរលាយ ។ គោលិកាក្រហមជាកោសិកាឈាមដែលដឹកនាំ $O_2$ និង $CO_2$ ។ គោលិកាសជាកោសិកាឈាមដែលមាននាទីសំខាន់ប្រឆាំងនឹងមេរោគផ្សេងៗ ។ ប្លាកែតជាភាគល្អិតនៃកោសិកាឈាម ដែលមាននាទីក្នុងកំណកឈាម ។
- សារពាង្គកាយយើងមានរបាំងការពារសម្រាប់ប្រឆាំងទៅនឹងជំងឺ. របាំងការពាររូបគីមី (ដូចជាស្បែក ភ្នាសក្នុងនៃរាងកាយ) ប្រតិកម្មរលាកនិងប្រព័ន្ធស៊ាំ ។ ប្រព័ន្ធស៊ាំ ការពារសារពាង្គកាយដោយការបំផ្លាញសារធាតុចម្លែកពីខាងក្រៅដែលបង្កជំងឺ ។ អង់ទីសែនជាសារធាតុដែលបង្កឱ្យមានតំណបស៊ាំ ។ អង់ទីករជាសារធាតុដែលត្រូវបានផលិតឡើងនៅពេលមានមេរោគ ឬសារធាតុចម្លែកជ្រៀតចូលក្នុងសារពាង្គកាយ ។

## សំណួរនិងលំហាត់

1. តើប្រដាប់របត់ឈាមបិទខុសពីប្រដាប់របត់ឈាមបើកដូចម្ដេចខ្លះ ?
2. តើប្រដាប់របត់ឈាមទោលខុសពីប្រដាប់របត់ឈាមទ្វេដូចម្ដេចខ្លះ ?
3. តើប្រដាប់របត់ឈាមរបស់ថនិកសត្វមានលក្ខណៈ ដូចម្ដេចខ្លះ ?

4. តើសរសៃឈាមរបស់មនុស្សមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
5. តើសរសៃឈាមនីមួយៗ មាននាទីដូចម្ដេច ?
6. តើសរសៃឈាមប្រភេទណាមួយមានប្រិស ? តើប្រិសមាននាទីដូចម្ដេច ?
7. តើធាតុបង្ករបស់ឈាមមានអ្វីខ្លះ ? តើធាតុបង្កនីមួយៗមាននាទីដូចម្ដេច ?
8. ដូចម្ដេចហៅថាអង់ទីករ ? អង់ទីសែន ?
9. តើកោសិកាឈាមប្រភេទណាដែលបង្កើតអង់ទីករ ?

## ពិសោធន៍ : សង្កេតបេះដូងថនិកសត្វ

### 1. វត្ថុបំណង

សង្កេតរូបរាងខាងក្រៅនិងទម្រង់ខាងក្នុងរបស់បេះដូងជ្រូក ។

### 2. សម្ភារៈ

បេះដូងជ្រូក (ឬគោ) កូនកាំបិត កូនកន្ត្រៃ តង្កៀប ថាសវះកាត់ ទឹក កន្សែងជូតដៃ ។

### 3. ដំណើរការពិសោធ

#### ក. រូបរាងខាងក្រៅរបស់បេះដូងជ្រូក (១៦)

- ជ្រើសរើសយកបេះដូងទាំងមូល (ជ្រូក ឬគោ) ហើយលាងទឹកឲ្យស្អាត ។ ពិនិត្យមើលផ្នែកខាងមុខនិងខាងក្រោយរបស់បេះដូង ។
- ដាក់បេះដូងបញ្ឈរដោយយកផ្នែកខាងស្រួចចុះក្រោម រាងបញ្ឆិតទៅឆ្វេង ។ ផ្នែកខាងលើនៃបេះដូងមានសរសៃឈាមធំៗ ។ ផ្នែកខាងមុខមានស្នាមរាងបញ្ឆិតនៅតាមបណ្ដោយបេះដូង ។ នៅលើនោះគេឃើញមានសរសៃឈាមកូរ៉ូណែនិងកំណាកខ្លាញ់ដែលបែងចែកថតក្រោមស្ដាំនិងថតក្រោមឆ្វេង ។


*បេះដូងជ្រូក*

- សង្កេតរូបរាងផ្នែកខាងក្រៅរបស់បេះដូង ហើយរកមើលសរសៃឈាមនៅលើផ្ទៃបេះដូង : សរសៃឈាមកូរ៉ូណែ អាកទែ និងវ៉ែន ។
- ពិនិត្យមើលថតលើឆ្វេងនិងថតក្រោមឆ្វេង ថតលើស្ដាំនិងថតក្រោមស្ដាំ ។
- ចូរគូររូបបេះដូងដែលអ្នកពិនិត្យឃើញ ព្រមទាំងដាក់ឈ្មោះលើផ្នែកនីមួយៗ (ថតលើនិងថតក្រោមឆ្វេង ថតលើនិងថតក្រោមស្ដាំ អាកទែសួតនិងអាអក) ។

## ១. ទម្រង់ក្នុងបេះដូងជ្រូក (2h)



ខ្ទាត់ពីនុះបេះដូង

- ពេលប្រើសំភារៈមុតស្រួច ត្រូវប្រយ័ត្នហើយអនុវត្តតាមការណែនាំរបស់គ្រូអ្នក ។
- ពុះបេះដូងតាមបណ្តោយ (ឲ្យចំពាក់កណ្តាលនៃថតលើនិងថតក្រោម) ពីផ្នែកខាងលើរហូតដល់ចុងបេះដូង ។ រួចលាងបេះដូងជាមួយទឹកឲ្យស្អាត ហើយដាក់វាទៅលើថាសជ័រ ។
- សង្កេតមើលសរសៃឈាមធំៗដែលចូលទៅក្នុងថតលើស្តាំ។ នេះជាវ៉ែនកាវលើនិងវ៉ែនកាវក្រោម ។
- រកសរសៃឈាមដែលចាកចេញពីថតក្រោមស្តាំ។ នេះជាសរសៃអាកទែសួត ។
- រកមើលថតលើស្តាំនិងថតលើឆ្វេង ។ បន្ទាប់មកពិនិត្យមើលប្រិសនៅចន្លោះថតលើស្តាំនិងថតក្រោមស្តាំ ។
- សង្កេតមើលប្រិសនៅចន្លោះថតលើឆ្វេងនិងថតក្រោមឆ្វេង ។ កំណត់សំគាល់សរសៃឈាមចាកចេញពីថតក្រោមឆ្វេង ។ នេះជាអាអក ។
- វាស់កម្រាស់ភ្នាសសាច់ដុំបេះដូងរវាងថតក្រោមស្តាំនិងថតក្រោមឆ្វេង ។

## 4. សន្និដ្ឋាន

1. ចូរគូររូបទម្រង់ក្នុងបេះដូងនិងដាក់ឈ្មោះផ្នែកផ្សេងៗរបស់វា (ថតលើនិងថតក្រោមស្តាំ ថតលើនិងថតក្រោមឆ្វេង វ៉ែនកាវ អាកទែសួត វ៉ែនសួត អាអក ប្រិស) ។
2. តើបេះដូងផ្នែកណាមួយដែលមានជញ្ជាំងក្រាស់ ?
3. តើប្រិសត្រួតពិនិត្យការហូរឈាមនៅក្នុងបេះដូងយ៉ាងដូចម្តេច ?
4. តើថតបេះដូងណាមួយដែលមានសាច់ដុំជញ្ជាំងក្រាស់ ? ហេតុអ្វី ?
5. តើអាកទែគ្រប់ទាំងអស់ដឹកនាំឈាមសម្បូរ $O_2$ ឬទេ ? ហេតុអ្វី ?

មេរៀនទី

# 2 ថេរលំនឹង

**ចប់មេរៀននេះ សិស្សអាច**

- កំណត់និយមន័យពាក្យ " ថេរលំនឹង " ។
- បកស្រាយថេរលំនឹងដែលទាក់ទងទៅនឹងតំណបអវិជ្ជមាន ។
- រាប់ឈ្មោះផ្នែកផ្សេងៗរបស់ស្បែក ។

នៅតំបន់អង់តាក់ទិច សីតុណ្ហភាពអាចធ្លាក់ចុះដល់ –40°C ក្រោមសូន្យ ឬក៏ទាបជាងនេះទៀត នៅពេលមានព្យុះទឹកកកយ៉ាងខ្លាំង ។ ស៊ុតរបស់ភេសមុទ្រមិនត្រូវឱ្យប៉ះដីទេ ព្រោះវានឹងកកហើយងាប់ភ្លាម ។ ដូច្នេះបក្សីឈ្មោលទ្រស៊ុតនៅលើជើងរបស់វា ។ ថ្វីបើអាកាសធាតុត្រជាក់ខ្លាំងបែបនេះក៏ដោយ ស៊ុតនៅតែរក្សាសីតុណ្ហភាព 38°C ជានិច្ច ។ សីតុណ្ហភាពសារពាង្គកាយភេសមុទ្រ មិនដែលធ្លាក់ក្រោមកម្រិតនេះទេ ។ លំនាំដែលរក្សាសីតុណ្ហភាពសារពាង្គកាយឱ្យនៅថេរ ជាឧទាហរណ៍មួយនៃថេរលំនឹង ។

## 1. ឥទ្ធិពលការថេរលំនឹង

លក្ខខណ្ឌនៅក្នុងសារពាង្គកាយរបស់យើង មានការប្រែប្រួលជានិច្ច ។ ការប្រែប្រួលយ៉ាងខ្លាំងនៅក្នុងឈាមនិងជុំវិញជាលិការាវ ជះឥទ្ធិពលទៅលើប្រតិកម្មគីមីក្នុងកោសិកានៃជាលិកា ព្រមទាំងផ្តល់ផលអាក្រក់ដល់រាងកាយ ។ ដើម្បីរស់រានមានជីវិត សារពាង្គកាយត្រូវតែមានសមត្ថភាពរកឱ្យឃើញនូវការប្រែប្រួលនៅក្នុងមជ្ឈដ្ឋានជុំវិញខ្លួនរបស់វា និងឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងការប្រែប្រួលនោះ ។ ចំពោះសត្វពហុកោសិកា មានមនុស្សជាដើម ផ្នែកផ្សេងៗរបស់សារពាង្គកាយត្រូវតែត្រូតពិនិត្យឱ្យបានជិតដល់ ដើម្បីឱ្យផ្នែកទាំងអស់នោះមានដំណើរការត្រូវគ្នា ។ លក្ខណៈបែបនេះ ហៅថាការសម្របសម្រួលដែលត្រួតពិនិត្យដោយប្រព័ន្ធប្រសាទនិងប្រព័ន្ធអង់ដូគ្រីន ។ បញ្ជាដែលបញ្ជូនតាមប្រព័ន្ធប្រសាទរហ័សប៉ុន្តែមានរយៈពេលខ្លី ចំណែកឯបញ្ជាដែលចេញពីប្រព័ន្ធអង់ដូគ្រីនយឺត តែឥទ្ធិពលរបស់វាមានរយៈពេលយូរ ។ ជាការពិត ប្រព័ន្ធទាំងពីរនេះបំពេញឱ្យគ្នាទៅវិញទៅមក ។ ***ឧទាហរណ៍*** អាដ្រេណាលីនធ្វើឱ្យរាងកាយមានសមត្ថភាពខ្ពស់និងត្រៀមខ្លួនធ្វើសកម្មភាព ។ ចំណែកប្រព័ន្ធប្រសាទសម្របសម្រួលនិងបញ្ជាឱ្យមានលំហូរនៃអរម៉ូនអាដ្រេណាលីន ។

កោសិកាស្ទើរទាំងអស់នៃសារពាង្គកាយមិនដែលប៉ះផ្ទាល់ជាមួយមជ្ឈដ្ឋានខាងក្រៅទេ ។ កោសិកាត្រូវបានព័ទ្ធជុំវិញដោយជាលិការាវដែល ហៅថាមជ្ឈដ្ឋានខាងក្នុង ។ តែយ៉ាងណាក៏ដោយ កោសិកាអាចធន់ទៅនឹងការប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ នៅក្នុងមជ្ឈដ្ឋានរបស់វាដោយគ្មានការខូចខាត ។ សីតុណ្ហភាព សម្ពាធអូស្មូសនិងកំហាប់គ្លុយកូសជាលក្ខខណ្ឌខ្លះដែលបណ្តាលឱ្យមានការប្រែប្រួលតិចតួចក្នុងសារពាង្គកាយ ។ សារពាង្គកាយប្រើប្រាស់មធ្យោបាយថេរលំនឹងដើម្បីត្រួតពិនិត្យមជ្ឈដ្ឋានខាងក្នុង ។ ថេរលំនឹងជាការរក្សាមជ្ឈដ្ឋានខាងក្នុងសារពាង្គកាយឱ្យនៅនឹងមិនប្រែប្រួល ។ ដូចនេះថេរលំនឹងចាំបាច់ណាស់ ថ្វីបើកោសិការបស់រាងកាយសត្វ ដូចជាថនិកសត្វ និងបក្សីមានសមត្ថភាពក៏ដោយ ប៉ុន្តែវាក៏ត្រូវការថេរលំនឹងដែរ ។ ពួកវាត្រូវតែរក្សាសីតុណ្ហភាព កម្រិត pH និងប៉ូតង់ស្យែលទឹកឱ្យបានត្រឹមត្រូវ ។ នេះមានន័យថា សត្វទាំងអស់នោះរួមទាំងមនុស្សផងត្រូវរក្សានូវសមាសភាពរបស់ជាលិការាវក្នុងដែនកំណត់ជាក់លាក់ ។ ***ឧទាហរណ៍*** កត្តាមួយដែលត្រូវរក្សាឱ្យនៅថេរជានិច្ច គឺសីតុណ្ហភាពរបស់រាងកាយ ។ អង់ស៊ីមក្នុងរាងកាយអាចធ្វើការបានក្នុងកម្រិត សីតុណ្ហភាពមួយច្បាស់លាស់ ។ ការផ្លាស់ប្តូរសីតុណ្ហភាពក្នុងសារពាង្គកាយ បណ្តាលឱ្យអង់ស៊ីមអសកម្ម ឬខូចទម្រង់ ។




*រូបទី2.1 : មជ្ឈដ្ឋានខាងក្នុងរាងកាយ*

## 1.1. តំណាបអវិជ្ជមាន

ការត្រួតពិនិត្យថេរលំនឹង ទាក់ទងទៅនឹងគោលការណ៍សំខាន់មួយហៅថា តំណាបអវិជ្ជមាន ។ ***ឧទាហរណ៍*** ប្រសិនបើប៉ូតង់ស្យែលទឹកក្នុងឈាមកើនឡើងខ្ពស់ខុសពីធម្មតា រាងកាយនឹងកែតម្រូវដោយបន្ថយមកនៅត្រឹមលក្ខខណ្ឌធម្មតាវិញ ។ ស្រដៀងគ្នាដែរ ប្រសិនបើប៉ូតង់ស្យែលទឹកក្នុងឈាមធ្លាក់ចុះក្រោមកម្រិតធម្មតា រាងកាយនឹងឆ្លើយតបដោយបង្កើនឱ្យទៅដល់លក្ខខណ្ឌធម្មតាវិញ ។ ដូចនេះរាងកាយតែងតែធ្វើឱ្យកើតមានឡើងនូវផលផ្ទុយទៅនឹងការប្រែប្រួល ។ នេះជាលំនាំនៃតំណាបអវិជ្ជមាន ។

តើសារពាង្គកាយមានសកម្មភាពដូចម្តេច ទើបយើងដឹងថាមានប្រតិកម្ម ? វាត្រូវតែមានសរីរាង្គ ឬទម្រង់មួយចំនួននៅក្នុងសារពាង្គកាយ ដែលអាចដឹងពីការប្រែប្រួលលក្ខខណ្ឌនៅក្នុងសារពាង្គកាយ ។

សរីរាង្គ ឬទម្រង់ទាំងនេះហៅថាច្នួល (*ឧទាហរណ៍* សរីរាង្គវិញ្ញាណ) ។ ការប្រែប្រួលណាមួយកើតចេញពីលក្ខខណ្ឌធម្មតាហៅថា រំញោច ។

ការត្រួតពិនិត្យថេរលំនឹងណាមួយកើតឡើង ត្រូវតែមាន

- រំញោច គឺការប្រែប្រួលរបស់មជ្ឈដ្ឋានខាងក្នុងរាងកាយ
- ច្នួលជាសរីរាង្គដែលអាចរកឃើញរំញោច
- ចលនការកែតម្រូវស្វ័យប្រវត្តិកើតមានឡើង
- តំណបអវិជ្ជមាន ។

## 1.2. ឧទាហរណ៍ថេរលំនឹងចំពោះមនុស្ស

### ក. និយ័តកម្មកំហាប់គ្លុយកូសក្នុងឈាម

គ្លុយកូសជាស្ករសំខាន់ដែលដឹកនាំតាមឈាម ។ ប្រសិនបើកម្រិតជាតិស្ករទាបពេកសរីរាង្គផ្សេងៗជាពិសេសខួរក្បាល និងបេះដូងត្រូវបានបាត់បង់នូវប្រភពថាមពលដ៏សំខាន់របស់ពួកវា ។ ប្រសិនបើកម្រិតជាតិស្ករខ្ពស់ពេក វាបណ្ដាលឱ្យជាលិកាបាត់បង់ទឹកតាមអូស្មូស ។ ដូចនេះទឹកចាកចេញពីឈាម ។




*រូបទី 2.2 : ការត្រួតពិនិត្យជាតិស្ករក្នុងឈាម*

កម្រិតគ្លុយកូសក្នុងឈាមអាចកើនឡើងក្រោយពេលបរិភោគអាហារ ។ វាអាចធ្លាក់ចុះក្នុងរយៈពេលលំហាត់ប្រាណយ៉ាងខ្លាំងក្លា ឬការអត់ឃ្លាន ។ ការប្រែប្រួលនៃកម្រិតជាតិស្ករក្នុងឈាមបានភ្ញោចអ៊ីឡូឡង់កេរ៉ង់ (Ilots de Langerhans) នៅក្នុងលំពែង ។ អ៊ីឡូឡង់កេរ៉ង់មានប្រតិកម្មតបដោយតម្រូវបរិមាណអាំងស៊ុយលីន(Insuline) ដែលវាផលិត ។ ផលត្រឡប់មកវិញ គឺបណ្ដាលឱ្យថ្លើមបញ្ចេញគ្លុយកូស ឬក៏ស្តុកគ្លុយកូសទុកក្រោមទម្រង់ជាគ្លីកូសែន ។

ជំងឺទឹកនោមផ្អែម បណ្ដាលមកពីលំពែងគ្មានសមត្ថភាពក្នុងការផលិតអាំងស៊ុយលីនឱ្យបានគ្រប់គ្រាន់ ។ កម្រិតគ្លុយកូសក្នុងឈាមកើនឡើង ហើយគ្លុយកូសចាប់ផ្ដើមលេចឡើងក្នុងទឹកនោមរបស់អ្នកជំងឺទឹកនោមផ្អែម ។ គេអាចព្យាបាលជំងឺទឹកនោមផ្អែមបានដោយអនុវត្តរបបអាហារឱ្យបានត្រឹមត្រូវ និងចាក់អរម៉ូនអាំងស៊ុយលីន ។

## ១. ថេរលំនឹងតាមរយៈតម្រងនោម

តម្រងនោមជាសរីរាង្គសំខាន់នៃថេរលំនឹង ។ វាសម្របសម្រួលបរិមាណទឹកនៅក្នុងឈាម ដោយតម្រូវនូវបរិមាណទឹកនោមដែលវាផលិត ។ ប្រសិនបើយើងប្រើប្រាស់ជាតុរាវច្រើននោះ ក្នុងឈាមនឹងមានទឹកយ៉ាងច្រើន ។ ពេលនោះតម្រងនោមនឹងផលិតទឹកនោមយ៉ាងរាវ ហើយច្រើនដើម្បីបំបាត់ចោលទឹកដែលលើស ។ ប្រសិនបើរាងកាយប្រើប្រាស់ទឹកតិច តម្រងនោមនឹងផលិតបរិមាណទឹកនោមតិចតួចដែលមានកំហាប់ខ្ពស់ ។

មជ្ឈមណ្ឌលត្រួតពិនិត្យការងារនេះស្ថិតនៅក្នុងខួរក្បាល ។ នៅទីនោះធ្លូលពិនិត្យមើលលក្ខខណ្ឌរបស់ឈាមដែលឆ្លងកាត់វា ។ ប្រសិនបើឈាមខាប់ពេក(ទឹកមិនគ្រប់គ្រាន់) វាភ្ញោចក្រពេញអ៊ីប៉ូភីសឱ្យបញ្ចេញអរម៉ូន ADH ( Hormone Antidiuretique) ។ អរម៉ូននេះធ្វើដំណើរតាមចរន្តឈាមយ៉ាងរហ័ស ឆ្ពោះទៅតម្រងនោម ។ ADH បណ្ដាលឱ្យមានការស្រូបយកទឹកយ៉ាងច្រើនឡើងវិញពីបំពង់នៃតម្រងនោមទៅក្នុងឈាម ។ ដូចនេះមានទឹកតិចតួចប៉ុណ្ណោះត្រូវបាត់បង់តាមទឹកនោម ហើយឈាមត្រឡប់ជារាវខ្លាំង ។ បន្ទាប់មកឈាមធ្វើដំណើរត្រឡប់ទៅកាន់ខួរក្បាលវិញ ។ ឈាមរាវនេះភ្ញោចក្រពេញអ៊ីប៉ូភីសឱ្យបន្ថយការផលិត ADH រហូតដល់មានតុល្យភាពដូចដើមវិញ ។




*រូបទី 2.3 : ថេរលំនឹងតាមរយៈតម្រងនោម*

ប្រព័ន្ធត្រួតពិនិត្យប្រភេទនេះ ប្រព្រឹត្តទៅតាមការត្រួតពិនិត្យអវិជ្ជមាន ។ ការប្រែប្រួលនៃបរិមាណទឹកក្នុងឈាម ធ្វើដំណើរត្រឡប់ទៅកាន់មជ្ឈមណ្ឌលត្រួតពិនិត្យវិញ ហើយវាមានសកម្មភាពប្រឆាំងតបវិញ ។ បើបរិមាណទឹកកាន់តែតិច ការផលិត ADH កាន់តែច្រើន ។ បើបរិមាណទឹកកាន់តែច្រើនការផលិត ADH ត្រូវធ្លាក់ចុះ ។ ដូចនេះកំហាប់ទឹកនៅក្នុងឈាមប្រែប្រួលជានិច្ច ។ ប្រព័ន្ធត្រួតពិនិត្យអវិជ្ជមានប្រភេទនេះមានលក្ខណៈ ត្រឹមត្រូវ តែទោះជាយ៉ាងណាក៏ដោយ វាត្រូវតែស្ថិតក្នុងដែនកំណត់ដែលអាចទទួលយកបានជានិច្ច ។

## 2. ស្បែក

ស្បែកមិនត្រឹមតែការពារនិងគ្របដណ្ដប់ផ្ទៃខាងលើសារពាង្គកាយទាំងមូលប៉ុណ្ណោះទេ ប៉ុន្តែវាជាសរីរាង្គបញ្ចេញចោលនិងជានិយ័តករនៃសីតុណ្ហភាពរបស់រាងកាយដែរ ។ ស្បែកអាចដឹងពីការប្រែប្រួលនៃសីតុណ្ហភាពនៅក្នុងមជ្ឈដ្ឋានជុំវិញ ។ នៅពេលអ្នកយកម្ជុលចាក់ដៃ អ្នកមានអារម្មណ៍ឈឺចាប់ ។ នៅពេលអ្នកខឹងឬខ្មាស់ ស្បែកមុខប្រែជាពណ៌ក្រហម ។ លក្ខណៈនេះបញ្ជាក់ថា ក្នុងស្បែកសម្បូរដោយសរសៃឈាមនិងសរសៃប្រសាទ ។ នៅពេលដេកសំងំលខ្លួនក្រោមកម្តៅព្រះអាទិត្យ ស្បែករបស់អ្នកឡើងពណ៌ក្រម៉ៅ ។ ពេលថ្ងៃក្តៅខ្លាំង អ្នកបែកញើសច្រើន ។ ហេតុដូចម្តេចបានជាមានបាតុភូតបែបនេះកើតឡើង ?

### 2.1. រូបផ្គុំស្បែក

ពំនុះទទឹងរបស់ស្បែក(រូបទី 2.4)មានពីរផ្នែកសំខាន់ គឺផ្នែកក្រៅស្តើងជាអេពីឌែមនិងផ្នែកក្នុងក្រាស់ជាឌែម ។

### ក. អេពីឌែម

អេពីឌែមកើតឡើងពីស្រទាប់កោសិកាងាប់និងកោសិការស់ ។ ស្រទាប់លើបង្អស់មានពី 25 ទៅ 30 ស្រទាប់ ។ វាបង្កឡើងដោយកោសិកាងាប់ដែលមានរាងសំប៉ែត ។ កោសិកាងាប់ទាំងនេះត្រូវបានជម្រុះចេញបន្តបន្ទាប់ ។ ថ្វីបើវាជាកោសិកាងាប់ក៏ដោយ ប៉ុន្តែវានៅតែមាននាទីយ៉ាងសំខាន់ ។ កោសិកាអេពីតេល្យូមងាប់មានផ្ទុកប្រូតេអ៊ីនកេរ៉ាទីនដែលធ្វើឱ្យស្បែកស្ងួត គ្រីន មិនជ្រាបទឹក និងការពារកោសិការស់នៃស្រទាប់ខាងក្រោម ។

ស្រទាប់ក្រោមនៃអេពីឌែមជាកោសិការស់ ដែលធ្វើចំណែកតាមមីតូសជាបន្តបន្ទាប់ ដើម្បីជំនួសកោសិកាងាប់នៃស្រទាប់លើ ។ កោសិកាស្បែកថ្មីៗដែលកើតឡើង ផ្លាស់ទីទៅផ្ទៃខាងលើរបស់ស្បែក

ព្រមទាំងផលិតនូវបរិមាណកេរ៉ាទីនយ៉ាងច្រើន ។ បន្ទាប់មកល្បឿនរុញស្រទាប់ កោសិកាក៏ងាប់ ។ ជាយថាហេតុ មួយខែក្រោយពេលវាឱតទៅដល់ផ្ទៃខាងលើបង្អស់របស់ស្បែក កោសិកាងាប់ទាំងនេះនឹងត្រូវជម្រុះចោល ។ កោសិកានៃស្រទាប់ក្នុងរបស់អេពីឌែមផលិតជាតិពណ៌មេឡានីន ។ មេឡានីនមានពីពណ៌លឿងទៅពណ៌ក្រហម ពីត្នោតទៅខ្មៅ ហើយវាជួយកំណត់ពណ៌ស្បែក ។ មនុស្សដែលមានមេឡានីនច្រើន មានស្បែកពណ៌ខ្មៅ ហើយមនុស្សមានមេឡានីនតិច តាមធម្មតាមានស្បែកពណ៌ស ។ ជាតិពណ៌នេះការពារកោសិកាពីការខូចខាតដែលបណ្តាលមកពីកាំរស្មីព្រះអាទិត្យ ។ មេឡានីនស្រូបយកកាំរស្មីស្វាយអ៊ុលត្រា( UV ) ។ វាការពារស្បែកពេលស្ថិតនៅក្រោមកម្តៅព្រះអាទិត្យ ។ កំណើនកាំរស្មីស្វាយអ៊ុលត្រាបង្កើនការផលិតមេឡានីន ។




*រូបទី 2.4 : រូបជុំស្បែក*

ចូរពិនិត្យមើលចុងម្រាមដៃរបស់អ្នក ។ ស្រទាប់អេពីឌែមនៃម្រាមដៃ និងបាតដៃ ម្រាមជើង និងបាតជើង មានចង្អូរ និងស្នាមលកដែលកើតឡើងតាំងពីមុនកំណើត ។ ចង្អូរនេះសំខាន់ណាស់សម្រាប់ក្តាប់ឬកាន់ ពីព្រោះវាបង្កើនភាពកកិត ។ ស្នាមចង្អូរនៅចុងម្រាមហៅថាក្រយ៉ៅដៃដែលមានសារៈសំខាន់សម្រាប់កំណត់លក្ខណៈពិសេសរបស់មនុស្សម្នាក់ៗ ។



*រូបទី 2.5 : ស្នាមក្រយ៉ៅដៃ*

### ១. ខែម

ផ្នែកទីពីររបស់ស្បែកជាខែមដែលជាផ្នែកខាងក្នុងបង្អស់និងក្រាស់ជាងអេពីខែម ។ កម្រាស់ខែមប្រែប្រួលទៅតាមផ្នែកនីមួយៗនៃសារពាង្គកាយ អាស្រ័យទៅនឹងនាទីរបស់ផ្នែកទាំងនោះ ។ ***ឧទាហរណ៍*** បាតដៃនិងម្រាមដៃ ខែមមានកម្រាស់ពី 3 ទៅ 4mm ដែលផ្តល់ជាទ្រនាប់និងកិច្ចការពារស្បែក ។ ស្បែកនៅលើផ្ទៃភ្នែកមានកម្រាស់ 0.5mm ដែលអាចឱ្យភ្នែកមើលធ្លុះបាន ។ ជាលិកាសន្ទាននៅក្នុងស្រទាប់ខែមធ្វើឱ្យស្បែកស្វិតនិងយឺត ។ ស្រទាប់ខែម មានកោសិកាប្រសាទ សរសៃឈាម សាច់ដុំ ឫសសក់ និងក្រពេញ ។ វេទនារម្មណ៍នៃការប៉ះសីតុណ្ហភាពនិងការឈឺចាប់មានប្រភពមកពីកោសិកាប្រសាទនៅក្នុងស្រទាប់ខែម ។ សាច់ដុំរលីងដែលភ្ជាប់ទៅនឹងឫសរោមនីមួយៗនៅក្នុងស្បែកធ្វើឱ្យរោមមានចលនា ។ នៅពេលអ្នករងា សាច់ដុំទាំងនេះកន្ត្រាក់ ហើយទាញសរសៃរោមត្រង់ឡើងលើ ដែលជួយមិនឱ្យកម្តៅចេញឬចូលបាន ។ សាច់ដុំនេះក៏បណ្តាលឱ្យអ្នកឡើងសម្បុរគីង្គក់នៅលើផ្ទៃស្បែកដែរ ។

### គ. តម្រូវសីតុណ្ហភាព

បណ្តាញសរសៃឈាមនៅក្នុងស្រទាប់ខែម ផ្តល់នូវសារធាតុចិញ្ចឹមដល់កោសិការស់របស់ស្បែក ។ សរសៃឈាមទាំងនេះជួយតម្រូវសីតុណ្ហភាពនៃរាងកាយផងដែរ ដោយការភាយកម្តៅទៅក្នុងខ្យល់ ឬរក្សាកម្តៅ ។ ប្រសិនបើរាងកាយទទួលកម្តៅខ្លាំង សរសៃឫសជាច្រើននៅក្នុងស្រទាប់ខែមរីកធំដែលអាចឱ្យឈាមហូរបានច្រើននៅក្បែរផ្ទៃស្បែក ហើយបញ្ចេញកម្តៅ ។ ហេតុនេះហើយបានជានៅពេលធ្វើលំហាត់ប្រាណខ្លាំងក្លា ស្បែកសម្បុរសប្រែជាពណ៌ក្រហម ។ នៅពេលអ្នកត្រជាក់ខ្លាំង សរសៃឈាមក្រោមស្បែកកន្ត្រាក់រួមតូច ហើយបន្ថយការបាត់បង់កម្តៅ ។

ញើសជាមធ្យោបាយមួយផ្សេងទៀតដែលអាចឱ្យរាងកាយរបស់អ្នកដកយកកម្តៅលើសចេញ ។ ស្បែករបស់អ្នកមានក្រពេញញើសប្រហែល $100/1cm^2$ ។ រំហួតញើសចេញពីផ្ទៃ ស្បែកដកយកកម្តៅយ៉ាងមានប្រសិទ្ធភាពច្រើនជាងការភាយកម្តៅតាមសរសៃឈាមចូលទៅក្នុងខ្យល់ ។ ញើសទាំងអស់មិនដូចគ្នាទេ ។ ញើសភាគច្រើន មានទឹកប្រហែល 99 % និង 1 % ជាល្បាយរវាងអំបិលនិងអាស៊ីតព្រមទាំងផលិតផលកាកសំណល់ ។ ដោយឡែកញើសដែលចេញពីក្រពេញញើសអាប៉ូគ្រីន (apocrine) មានផ្ទុកប្រូតេអ៊ីននិងអាស៊ីតខ្លាញ់ ។ សារធាតុទាំងនេះជាប្រភពអាហារសម្រាប់បាក់តេរីដែលរស់នៅលើស្បែក ។ ផលិតផលកាកសំណល់របស់បាក់តេរីទាំងនេះ ធ្វើឱ្យញើសមានក្លិនមិនល្អ ។ ក្រពេញអាប៉ូគ្រីនច្រើនមាននៅត្រង់ក្លៀកនិងត្រលៀន ។ ស្បែកក៏ជាសរីរាង្គវិញ្ញាណដែរ ។ កោសិកាប្រសាទនៅក្នុងស្រទាប់ខែមទទួលបានរំញោចពីមជ្ឈដ្ឋានខាងក្រៅ ហើយបញ្ជូនព័ត៌មានស្តីពីសម្ពាធ ការឈឺចាប់និងសីតុណ្ហភាព ។

## មេរៀនសង្ខេប

- ថេរលំនឹងជាការរក្សាមជ្ឈដ្ឋានខាងក្នុងសារពាង្គកាយឱ្យនៅនឹងមិនប្រែប្រួល ។
- ស្បែកការពារផ្ទៃខាងក្រៅនៃខ្លួនមនុស្សទាំងមូល ។ វាជាសរីរាង្គបញ្ចេញចោលនិងជានិយ័តករនៃសីតុណ្ហភាពរបស់រាងកាយ ។ ស្បែកមានពីរផ្នែកសំខាន់ គឺផ្នែកក្រៅស្តើងជាអេពីឌែមនិងផ្នែកខាងក្នុងក្រាស់ជាឌែម ។
- អេពីឌែមកើតឡើងពីស្រទាប់កោសិកាងាប់និងកោសិការស់ ។ ស្រទាប់លើជាស្រទាប់កោសិកាងាប់ រាងសំប៉ែតដែលត្រូវជម្រុះចោលបន្តបន្ទាប់ ។ កោសិកាងាប់ផ្ទុកកេរ៉ាទីនដែលធ្វើឱ្យស្បែកស្ងួត ក្រិន មិនជ្រាបទឹក និងការពារកោសិការស់នៃស្រទាប់ក្រោម ។ កោសិការស់ចែកតាមមីតូសដោយបង្កើតកោសិកាថ្មីៗ ដើម្បីជំនួសកោសិកាងាប់នៃស្រទាប់លើ ។ ស្រទាប់ក្នុងនៃអេពីឌែមមានកោសិកាដែលផ្ទុកជាតិពណ៌មេឡានីន ។ មេឡានីន កំណត់ពណ៌របស់ស្បែក ។
- ឌែមជាផ្នែកខាងក្នុងបង្អស់និងក្រាស់ជាងគេ ។ ក្នុងស្រទាប់ឌែមមានកោសិកាប្រសាទ សរសៃឈាម សាច់ដុំ ឫសរោម និងក្រពេញ ។ បណ្ដាញសរសៃឈាមនៅក្នុងស្រទាប់ឌែម ផ្ដល់សារធាតុចិញ្ចឹមដល់កោសិការស់របស់ស្បែក ។
- ប្រសិនបើរាងកាយទទួលកម្ដៅខ្លាំង សរសៃឫសរីកធំ ឈាមហូរច្រើនក្បែរផ្ទៃស្បែក ហើយបញ្ចេញកម្ដៅទៅក្រៅយ៉ាងច្រើន ។ ក្រពេញញើសបញ្ចេញញើសច្រើន ។ ញើសហួត ហើយកម្ដៅនៃរាងកាយធ្លាក់ចុះ ។ នៅពេលរាងកាយត្រជាក់ហួស សរសៃឫសក្រោមស្បែកកន្ត្រាក់រួមតូច ឈាមហូរតិច បន្ថយការបាត់បង់កម្ដៅ ។ ការកន្ត្រាក់របស់សាច់ដុំផលិតកម្ដៅយ៉ាងច្រើនដើម្បីធ្វើឱ្យសារពាង្គកាយក្ដៅ ។

## សំណួរនិងលំហាត់

1 ដូចម្ដេចហៅថាថេរលំនឹង ?

2. តើមជ្ឈដ្ឋានខាងក្នុងនៃរាងកាយជាអ្វី ?

3 តើការត្រួតពិនិត្យថេរលំនឹងចាំបាច់ត្រូវមានអ្វីខ្លះ ?

4. តើនិយ័តកម្មនៃកំហាប់គ្លុយកូសប្រព្រឹត្តទៅដូចម្ដេច ?

5 ចូរសង្ខេបពីថេរលំនឹងរបស់តម្រងនោម ។

6. តើស្បែកមានប៉ុន្មានផ្នែក ? អ្វីខ្លះ ?

## ? សំណួរនិងលំហាត់ជំពូក 6

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ**

1 ប្រហោងផ្នែកខាងលើរបស់បេះដូងហៅថា

☐ក. ថតលើ ☐ខ. ថតក្រោម ☐គ. ប្រិស ☐ឃ. កូនអាកទែ ។

2. បណ្តូរសារធាតុចិញ្ចឹមរវាងឈាមនិងកោសិការបស់រាងកាយកើតមាននៅក្នុង

☐ក. វ៉ែន ☐ខ. សរសៃប្លូរ ☐គ. អារអក ☐ឃ. អាកទែ ។

3. សមាសភាគឈាមដែលជួយរាងកាយ ដើម្បីត្រួតពិនិត្យកំណកឈាមជា

☐ក. គោលិកាក្រហម ☐ខ. គោលិកាស ☐គ. ប្លាកែត ☐ឃ. អេម៉ូគ្លូប៊ីន ។

4. អង់ទីករត្រូវបានផលិតដោយ

☐ក. ផាកូស៊ីតូស ☐ខ. ឡាំផូស៊ីត B ☐គ. ឡាំផូស៊ីត T ☐ឃ. មេរោគ ។

**II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ**

1 ស្រទាប់ក្នុងរបស់ស្បែកជា ដែលភាគច្រើនជាកោសិការស់ ។

2. ស្រទាប់ក្រៅរបស់ស្បែកជា ដែលមានទាំងកោសិការស់និងងាប់ ។

3. សរសៃឈាមដែលមានប្រិសជា ។

4. សារធាតុដែលផ្ទុកជាតិដែកនៅក្នុងគោលិកាក្រហមជា ។

5. ឈាមដឹកនាំ និង ទៅឱ្យកោសិកា ។

**III. ចូរឆ្លើយសំណួរខាងក្រោមនេះ**

1 ហេតុអ្វីបានជាសរសៃឈាមរីកធំនៅពេលរាងកាយឡើងក្តៅ ?

2. ចូរប្រៀបធៀបទម្រង់របស់អេពីឌែមនិងឌែម ?

3 តើស្បែកត្រួតពិនិត្យសីតុណ្ហភាពរាងកាយដូចម្តេចដែរ ?

4 ចូរប្រៀបធៀបរបត់ឈាមស្ងួតនិងរបត់ឈាមទូទៅ ។

5 កោសិកាសាច់ដុំបេះដូងសម្បូរមីតូកុងឌ្រី ។ ចូរពន្យល់ពីអត្ថប្រយោជន៍របស់មីតូកុងឌ្រី ។

6 ប្រសិនបើប្រិសនៅក្នុងសរសៃវ៉ែនសំខាន់ៗមិនដំណើរការ តើនឹងមានអ្វីកើតឡើង ?

7 គោលិកាក្រហមពេញវ័យ(ទុំ)របស់មនុស្សគ្មានណ្វៃយ៉ូទេ ។ តើលក្ខណៈបែបនេះផ្តល់អត្ថប្រយោជន៍ដូចម្តេចដែរ ?

8 មនុស្សម្នាក់ដែលមានចំនួនគោលិកាក្រហមតិច ធ្វើការឆាប់ហត់នឿយ ។ ចូរពន្យល់ ។

9 តើតំណាបស៊ាំតាមរយៈអង់ទីករនិងតាមរយៈកោសិកាមានលក្ខណៈខុសគ្នាដូចម្តេច ?

# ជំពូក 7 រុក្ខជាតិមានសរសៃនាំ



នៅលើផែនដីយើងនេះ មានរុក្ខជាតិប្លែកៗជាច្រើនរាប់មិនអស់ ។ រុក្ខជាតិខ្លះរស់ដោយស្រូបទឹក និងសារធាតុខនិជពីក្នុងដី ហើយប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យក្នុងដំណើររស្មីសំយោគ ។ រុក្ខជាតិខ្លះចាប់សត្វជាអាហារ(រុក្ខជាតិមំសាសី) ខ្លះទៀតចេញផ្កាតែម្ដងក្នុងរយ ពេល 30ឆ្នាំ ។ រុក្ខជាតិផ្សេងទៀតមានផ្កាដែលមានក្លិនស្អុយដូចជាសាច់រលួយ ។ ប៉ុន្តែរុក្ខជាតិទាំងអស់នេះក៏មានលក្ខណៈមួយចំនួនដែលដូចគ្នា ។

មេរៀនទី

# 1 ជាលិការុក្ខជាតិ

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីទម្រង់មេជាលិកានិងការលូតលាស់កោសិកាអេពីឌែមក្នុងផ្នែកផ្សេងៗរបស់រុក្ខជាតិ ។
- ពណ៌នាពីទម្រង់និងនាទីកោសិកាប៉ារ៉ង់ស៊ីម កូឡង់ស៊ីម និងស្គេរ៉ង់ស៊ីមក្នុងជាលិកាល្បាត ។
- រៀបរាប់ពីទម្រង់និងនាទីរបស់ស៊ីឡែមនិងផ្លូអែមក្នុងជាលិកាបាច់សរសៃនាំ ។
- ប្រៀបធៀបរុក្ខជាតិស្មៅនិងរុក្ខជាតិឈើ ។

គ្រប់រុក្ខជាតិទាំងអស់ ទោះបីជាស្ថិតក្នុងអម្បូរជាមួយគ្នា ឬក៏អម្បូរផ្សេងគ្នាក្តី ក៏នៅមានលក្ខណៈរួមមួយចំនួនដែរ ។ ក្នុងមេរៀននេះយើងនឹងសិក្សាពីទម្រង់ជាលិកាផ្សេងៗនៃរុក្ខជាតិមានផ្កា ដែលមាន**ឯកទេសកម្ម** ស្របទៅតាមមុខងារផ្សេងៗរបស់វា ។ ឯកទេសកម្មនេះអាចឱ្យជាលិកានីមួយៗបំពេញមុខងាររបស់វាប្រកបដោយប្រសិទ្ធភាព ។ រុក្ខជាតិលូតលាស់ដោយសារការផលិតកោសិកាថ្មីៗនៅក្នុងពន្លកដើមនិងក្បាលឫស ។

សារពាង្គកាយរបស់រុក្ខជាតិរួមមានជាលិកាបួនប្រភេទគឺ មេជាលិកា ជាលិកាការពារ ជាលិកានាំ និងជាលិកាគ្រឹះ ។

## 1. មេជាលិកា

រុក្ខជាតិលូតលាស់ពេញមួយជីវិត អាស្រ័យដោយមេជាលិកាដែលស្ថិតនៅក្នុងពន្លកដើមនិងក្បាលឫស ។ វាធ្វើចំណែកជាបន្តបន្ទាប់ដើម្បីបង្កើតកោសិកាថ្មីៗនៅក្បាលឫសនិងកំពូលដើម ។ កោសិកាមេជាលិកាមានភ្នាសស្តើងនិងស៊ីតូប្លាសខាប់ ។ ស្រទាប់ខោលនៃកោសិកាមេជាលិកាដែលស្ថិតនៅក្នុងសំបកហៅថាស្រទាប់មេក្រៅ ។ រីឯមេជាលិកាដែលស្ថិតនៅផ្នែកកណ្តាលនៃដើម (ស៊ីឡាំងកណ្តាល)ឬឫសរុក្ខជាតិមានឈ្មោះថា ស្រទាប់មេក្នុងឬរ៉ឺអិលឈើ ។



*រូបទី 1.1 : មេជាលិកានៅក្បាលឫស*

កោសិកាដែលកើតចេញពីមេជាលិកា ធ្វើបំលែងឯកទេសទៅជាជាលិកាប្រភេទផ្សេងៗទៀតរបស់រុក្ខជាតិ ។ ជាលិកាទាំងនេះមានទម្រង់ស្របទៅតាមនាទីរបស់វា ។ កោសិកាមួយចំនួនមានភ្នាសក្រាស់ កោសិកាផ្សេងទៀតមានរាងវែងៗ ។ ទម្រង់ខុសៗគ្នាបែបនេះជាលក្ខណៈពិសេសស្របទៅតាមមុខងារខុសៗគ្នារបស់កោសិកាដូចជា សម្រួប ដំណឹកនាំ ការស្តុក ការបន្តពូជ ។

## 2. ជាលិកាការពារ

ជាលិកាការពាររួមមាន កោសិកាអេពីឌែមនិងល្បែស ។




រូបទី 1.2 : កោសិកាល្បាត



រូបទី 1.3 : កោសិកាអេពីឌែម

### 2.1. កោសិកាអេពីឌែម

គ្រប់សារពាង្គកាយរបស់រុក្ខជាតិស្មៅនិងរុក្ខជាតិឈើ សុទ្ធតែគ្របដណ្តប់ដោយស្រទាប់កោសិកាអេពីឌែម ។ កោសិកាអេពីឌែមតម្រៀបគ្នាយ៉ាងណែន ហើយជាកោសិកាស្រទាប់ក្រៅបង្អស់ ។ វាមាននាទីការពារជាលិកាផ្នែកខាងក្នុងរបស់រុក្ខជាតិ ។ ចំពោះរុក្ខជាតិឈើធំៗ ស្រទាប់អេពីឌែមនៃដើមត្រូវជំនួសដោយជាលិកាសំបក ។ កោសិកាអេពីឌែមដែលគ្របដណ្តប់ដើមរបស់រុក្ខជាតិអាចបញ្ចេញសារធាតុម្យ៉ាងភ្លឺរលោងមានឈ្មោះថាគុយទីន ។ ស្រទាប់គុយទីនដែលស្ថិតនៅលើផ្ទៃអេពីឌែមមានឈ្មោះថា **គុយទីគុល** (ឬសំណើ) ។ គុយទីគុលមាននាទីបន្ថយការបាត់បង់ទឹកនិងការពាររុក្ខជាតិទប់ទល់នឹងការជ្រៀតចូលនៃមីក្រូសារពាង្គកាយ ។

កោសិកាអេពីឌែមរបស់ឫសដែលដុះវែងៗហៅថារោមជញ្ជក់ ។ វាបង្កើនផ្ទៃនៃឫសក្នុងការស្រូបទឹកនិងសារធាតុខនិជ ជាពិសេសជួយចងភ្ជាប់រុក្ខជាតិយ៉ាងរឹងមាំទៅនឹងដី ។ ចំពោះរុក្ខជាតិឈើកោសិកាអេពីឌែមនៃដើមត្រូវជំនួសដោយជាលិកាល្បែស ។

## 2.2. ល្បែស

ល្បែស ជាប្រភេទជាលិកាងាប់ ដែលគ្របដណ្ដប់លើផ្ទៃដើមនិងឫសរបស់រុក្ខជាតិ ។ វាមាននាទីការពារជាលិកាខាងក្នុងទល់នឹងការប៉ះទង្គិចផ្សេងៗ ។ ល្បែសការពារការបាត់បង់ទឹកព្រមទាំងការជ្រៀតចូលនៃមេរោគ ។ ល្បែស កើតឡើងពីមេជាលិកាដែលមានឈ្មោះថាកំបូម ។ វាមានជីវិតរស់នៅក្នុងរយៈពេលខ្លីបំផុត ។ កាលណាកោសិកាលូតលាស់ពេញលេញ ល្បែសក៏ត្រូវងាប់ទៅវិញ ។ កោសិកាងាប់ទាំងនេះ ការពារជាលិការស់ទាំងឡាយដែលស្ថិតនៅក្នុងដើមនិងឫសរុក្ខជាតិ ។



*រូបទី 1.4 : កោសិកាល្បែស*

# 3. ជាលិកានាំ

គ្រប់រុក្ខជាតិមានសរសៃនាំ សុទ្ធតែមានជាលិកាសរសៃនាំ ។ ជាលិកាសរសៃនាំមានពីរប្រភេទ គឺ ស៊ីឡែមនិងផ្លូអែម ។







*រូបទី 1.5 : ស៊ីឡែម*



*រូបទី 1.6 : ផ្លូអែម*

## 3.1. ស៊ីឡែម

ស៊ីឡែមដឹកនាំទឹកនិងសារធាតុរ៉ែពីឫសទៅកាន់ស្លឹក ។ កោសិកាស៊ីឡែមមានពីរប្រភេទ

- **ត្រាកេអ៊ីត (Tracheid)** : ជាកោសិកាប្រហោងក្នុងនិងមានភ្នាសក្រាស់ ហើយមានរាងទ្រវែង ។

- **សរសៃស៊ីវ៉ែម** ៖ ជាកោសិកាវែងៗប្រហោងក្នុងស្ថិតនៅបន្តគ្នា ។ វាដឹកនាំទឹកនិងសារធាតុរ៉ែនិង ទៅគ្រប់ផ្នែកផ្សេងៗនៃរុក្ខជាតិ ។ កោសិកានេះមានស្ទើរគ្រប់រុក្ខជាតិអង់ស្យូស្ពែមនិងរុក្ខជាតិមានសរសៃនាំមួយចំនួនផ្សេងទៀត ។

## 3.2. ផ្លូអែម

ផ្លូអែមជាជាលិកាសរសៃនាំរួមមានជាលិកាបំពង់ប្រហោងនិងជាលិកាបំពង់ដែលភ្ជាសមានប្រហោងស្ថិតនៅជាគូនិងគ្នា ។

ផ្លូអែមមាននាទីដឹកនាំសារធាតុសរីរាង្គ ដែលជាផលនៃដំណើររស្មីសំយោគ ទៅគ្រប់ផ្នែកទាំងអស់នៃរុក្ខជាតិដើម្បីចិញ្ចឹមផ្នែកទាំងនោះ ។ ផ្លូអែមជាជាលិការស់ ។

ជាលិកាសរសៃនាំ(ស៊ីវ៉ែមនិងផ្លូអែម)មានសារៈសំខាន់ណាស់ចំពោះរុក្ខជាតិ ។ វាមាននៅគ្រប់ផ្នែកទាំងអស់នៃរុក្ខជាតិ ។ នៅក្នុងឫស ជាលិកាសរសៃនាំមាននៅក្នុងសរសៃស៊ីឡាំង ។ នៅក្នុងដើម វាមាននៅក្នុងបាច់សរសៃនាំ ។ ចំណែកក្នុងស្លឹកវិញ គេឃើញវាមាននៅក្នុងទ្រនុងស្លឹក ។

# 4. ជាលិកាគ្រឹះ

ជាលិកាគ្រឹះបង្កើននូវទំហំ(មាឌ) របស់ឈើ ។ ជាលិកានេះមាននាទីផលិតនិងស្តុកអាហារបម្រុងព្រមទាំងពង្រឹងនិងទ្រទ្រង់រុក្ខជាតិទៀតផង ។ ជាលិកាគ្រឹះមានបីប្រភេទ គឺប៉ារ៉ង់ស៊ីម កូឡង់ស៊ីម និងស្កេរ៉ង់ស៊ីម ។

## 4.1. ប៉ារ៉ង់ស៊ីម



*រូបទី 1.7 : កោសិកាប៉ារ៉ង់ស៊ីម*

កោសិកាប៉ារ៉ង់ស៊ីមទាក់ទងយ៉ាងខ្លាំងទៅនិងប្រភេទរុក្ខជាតិ ។ កោសិកានេះជាអ្នកកំណត់ប្រភេទរុក្ខជាតិ ។ វាមាននៅគ្រប់សរីរាង្គទាំងអស់របស់រុក្ខជាតិដូចជា ដើម ឫស ស្លឹក និងផ្លែ ។ កោសិកាប៉ារ៉ង់ស៊ីមក្នុងស្លឹកនិងដើមខ្ចីៗសុទ្ធតែមានក្លរ៉ូប្លាសដែលផ្ទុកក្លរ៉ូភីលសម្រាប់រាប់រងក្នុងដំណើររស្មីសំយោគ ។ ជាលិកាប៉ារ៉ង់ស៊ីមមានឯកទេសកម្មក្នុងការស្តុកស្តារ អាមីដុង និងសារធាតុបម្រុងដទៃទៀត ។ ជាលិកាទាំងនោះមាននៅក្នុងឫសនិងផ្នែកខ្លះនៃដើម ។

## 4.2. កូឡង់ស៊ីម



រូបទី 1.8 : កោសិកាកូឡង់ស៊ីម

ដូចគ្នានឹងជាប៉ារ៉ង់ស៊ីមដែរ កោសិកាកូឡង់ស៊ីមជាកោសិការស់ ។ វាមានរាងទ្រវែង មានផ្ទៃក្រាស់ហើយទន់ ។ កូឡង់ស៊ីមជាជាលិកាពង្រឹងនិងទ្រទ្រង់ ។ កូឡង់ស៊ីមច្រើនមាននៅក្នុងដើមរុក្ខជាតិខ្ចីៗហើយស្ថិតនៅជាប់នឹងជាលិកាអេពីឌែម ។ ***ឧទាហរណ៍*** ទង របស់បន្លែម្យ៉ាងឈ្មោះថា សេឡេរី (Celery) ភាគច្រើនសុទ្ធតែបង្កឡើងពីកោសិកាកូឡង់ស៊ីម ។

## 4.3. ក្លេរ៉ង់ស៊ីម



រូបទី 1.9 : កោសិកាក្លេរ៉ង់ស៊ីម

ក្លេរ៉ង់ស៊ីមជាកោសិកាងាប់ហើយរឹង ។ ភាពរឹងនេះបណ្ដាលមកពីកោសិកាដែលមានភ្នាសក្រាស់និងផ្ទុកសារធាតុម្យ៉ាងឈ្មោះថា លីញីន ។ លីញីនអាចធ្វើឱ្យឈើរឹងមាំ ។ មុខងាររបស់ក្លេរ៉ង់ស៊ីមគឺទ្រទ្រង់ផ្នែកចាស់ៗរបស់រុក្ខជាតិ ។ កោសិកាក្លេរ៉ង់ស៊ីមមានពីរប្រភេទគឺ សរសៃរុក្ខជាតិនិងក្លេរេអ៊ីត ។

- **សរសៃរុក្ខជាតិ** : ជាប្រភេទកោសិកាវែងៗ ស្តួចសងខាង ហើយមានភ្នាសក្រាស់ ។ វាជួយទ្រទ្រង់និងការពាររុក្ខជាតិ ។
- **ក្លេរេអ៊ីត** : កោសិកាមានរាងខ្លីៗជាងសរសៃរុក្ខជាតិ ហើយមានរាងច្រើនបែប ។ គេកម្រឃើញសរសៃរុក្ខជាតិមានក្នុងជាលិកាគ្រឹះ ប៉ុន្តែភាគច្រើនមានក្នុងជាលិកាសរសៃនាំគឺ ក្នុងស៊ីឡែមនិងផ្លូអែម ។ គេយកសរសៃក្លេរ៉ង់ស៊ីមរបស់ប្រភេទរុក្ខជាតិខ្លះទៅវេញជាខ្សែ ធ្វើអង្រឹង ឬបាវជាដើម ។

## មេរៀនសង្ខេប

- សារពាង្គកាយរុក្ខជាតិមានផ្កា ចែកចេញជាពីរផ្នែកសំខាន់ៗគឺ ក្បាលឫសនិងកំពូលដើមដែលហៅថា មេជាលិកាកំពូល ។
- មេជាលិកាកំពូលធ្វើមីតូសជាបន្តបន្ទាប់ ។ កោសិកាដែលកើតចេញពីមេជាលិកាបំលែងឯកទេសទៅជាជាលិកាផ្សេងៗទៀតរបស់រុក្ខជាតិ ។ ជាលិកាសំខាន់ៗទាំងនោះមាន មេជាលិកា ជាលិកាការពារ ជាលិកានាំ និងជាលិកាគ្រឹះ ។ ។
- កោសិកានៃជាលិកានីមួយៗមាននាទីផ្សេងៗគ្នាដូចជា សម្រួប ដំណឹកនាំ ការស្តុក និងការបន្តពូជ ។
- ជាលិកាល្បាតមាននាទីការពាររុក្ខជាតិនិងបន្ថយការបាត់បង់ទឹក ។
- ជាលិកាសរសៃនាំមាននាទីដឹកនាំទឹកនិងសារធាតុរនិជពីឫសទៅស្លឹកនិងដឹកនាំអាហារពីស្លឹកទៅឫសវិញ ។
- ជាលិកាគ្រឹះបង្កើននូវទំហំរបស់ឈើ ។ វាមាននាទីពង្រឹង និងទ្រទ្រង់រុក្ខជាតិ ។ ជាលិកាគ្រឹះក៏អាចធ្វើរស្មីសំយោគបានដែរ ប្រសិនបើក្នុងកោសិកាប៉ារ៉ង់ស៊ីមមានក្លរ៉ូប្លាស ។

## សំណួរនិងលំហាត់

1. តើជាលិកាសំខាន់ៗរបស់រុក្ខជាតិមានសរសៃនាំមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
2. តើកោសិកាប៉ារ៉ង់ស៊ីមមាននៅផ្នែកណាខ្លះនៃរុក្ខជាតិ ? ហើយមាននាទីអ្វីខ្លះ ?
3. តើជាលិកានាំមាននាទីដូចម្តេចខ្លះ ?
4. តើកោសិកាអេពីឌែមរបស់ជាលិកាល្បាតមាននាទីអ្វីខ្លះ ?
5. តើកោសិកាណាខ្លះ ដែលស្ថិតក្នុងជាលិកាគ្រឹះ ? ហើយមាននាទីយ៉ាងដូចម្តេច ?
6. តើកោសិកាក្លេរ៉ង់ស៊ីមមានផ្ទុកសារធាតុអ្វី ? តើសារធាតុនោះមានប្រយោជន៍អ្វីដែរចំពោះរុក្ខជាតិ ។
7. ដូចម្តេចដែលហៅថាល្បែស ? តើល្បែសរបស់រុក្ខជាតិមាននាទីអ្វីខ្លះ ?

## ពិសោធន៍ : សង្កេតចម្រង់ទី 1 និងទី 2 នៃដើមរុក្ខជាតិឌីកូទីលេដុន

## 1. វត្ថុបំណង

- កំណត់ពីរូបរាងនិងវិមាត្ររបស់កោសិកាកូឡង់ស៊ីម ក្លេរ៉ង់ស៊ីម និងល្បែស ។
- បែងចែកពីរូបរាងនិងទំហំរបស់ជាលិកាការពារ ជាលិកាពង្រឹង ។
- ប្រៀបធៀបពីទម្រង់កោសិកាកូឡង់ស៊ីមនិងក្លេរ៉ង់ស៊ីម ។

## 2. សម្ភារៈ

- មីក្រូទស្សន៍ ទងព្រលិត(ឬទងល្ពៅ ដើមផ្កាវ៉ៃយោល ដើមស្លាក់ ) ទឹកសាវែល ទឹកសុទ្ធ ចានកែវ អាស៊ីតអាសេទិច $\frac{1}{1000}$ ខៀវមេទីឡែន $\frac{1}{1000}$ សូលុយស្យុងកាម៉ាំង កូនកាំបិត បន្ទះឡាម បន្ទះឡាមែល ។

## 3. ដំណើរការពិសោធ

ធ្វើខ្នាត់ទទឹងដើមឬទងរុក្ខជាតិខាងលើ រួចបន្ស៊ីពណ៌ពីរដង

- កាត់ទទឹងដើមឬទងរុក្ខជាតិខាងលើឱ្យបានស្តើងបំផុត
- ត្រាំខ្នាត់នោះក្នុងទឹកសាវែលពី 15 – 20 នាទី
- លាងសំអាតនិងទឹកឬទឹកអាស៊ីតអាសេទិច $\frac{1}{1000}$ ឱ្យស្អាត
- បន្ស៊ីពណ៌ដោយខៀវមេទីឡែនរាវ $\frac{1}{1000}$ ពី 1 – 3 នាទី
- លាងនឹងទឹកស្អាតយ៉ាងតិចបីដង ។
- បន្ស៊ីពណ៌ក្រហមដោយសូលុយស្យុងកាម៉ាំង ពី 15 – 20 នាទី
- លាងនឹងទឹកស្អាតឱ្យបានស្អាតល្អ
- ដាក់ខ្នាត់ដែលលាងរួចត្រាំក្នុងចានកែវដែលមានទឹកសុទ្ធ (ការពារកុំឱ្យខូច)
- យកខ្នាត់ដាក់លើបន្ទះឡាមដែលមានតំណក់ទឹកសុទ្ធ គ្របបន្ទះឡាមែលពីលើ រួចយកទៅពិនិត្យក្នុងមីក្រូទស្សន៍ ។

## 4. វិភាគ

ក្រោយសង្កេត ឱ្យសិស្សគូរឡើងវិញ ពីអ្វីដែលគេបានសង្កេត ដោយដាក់ចំណងជើងផ្នែកនីមួយៗ ឱ្យបានត្រឹមត្រូវ ។




A. ទម្រង់កាត់ទទឹងដើមឃ្លោក

B. ទម្រង់លំអិតបាច់សរសៃនាំ

1. កូឡង់ស៊ីម

2. ក្លេរ៉ង់ស៊ីម

3. អេពីឌែម

4. ផ្លូអែមក្រៅឬលីប៊ែរ I

5 ស៊ីឡែមឬសាច់ឈើ

6. ផ្លូអែមក្នុងឬលីប៊ែរក្នុង

7 បាច់លីប៊ែរ-សាច់ឈើ

# 2 ឫស

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីប្រភេទទាំងបីនៃឫសដែលលូតលាស់ ។
- ❑ បកស្រាយពីទម្រង់និងនាទីរបស់តំបន់ទាំងបីនៃឫស ។
- ❑ រៀបរាប់ពីមុខងារបីយ៉ាងរបស់ឫស ។
- ❑ ប្រៀបធៀបឫសរុក្ខជាតិម៉ូណូកូទីលេដូននិងឌីកូទីលេដូន ។

អ្នកបានសិក្សារួចមកហើយ ពីប្រភេទជាលិកាផ្សេងៗរបស់រុក្ខជាតិ ។ ជាលិកាទាំងនេះស្ថិតនៅផ្គុំគ្នានិងបំពេញនាទីរួមគ្នាមួយដែលបង្កើតបានជាសរីរាង្គផ្សេងៗរបស់រុក្ខជាតិ ។ សរីរាង្គទាំងនេះភ្ជាប់គ្នាដោយជាលិកាបាច់សរសៃនាំ ។ រុក្ខជាតិមានសរសៃនាំភាគច្រើន មានដើម ឫស ស្លឹកពិតប្រាកដ និងមានសរីរាង្គបន្តពូជ ។

## 1. សរីរាង្គផ្សេងៗរបស់រុក្ខជាតិមានសរសៃនាំ

សរីរាង្គសំខាន់ៗរបស់រុក្ខជាតិមានសរសៃនាំមាន ឫស ដើម និងស្លឹក ។

- **ឫស** : ឫសចងភ្ជាប់រុក្ខជាតិទៅនឹងដី ។ វាមាននាទីពិសេសម្យ៉ាងទៀតគឺ ស្រូបទឹក អំបិលខនិជរលាយក្នុងដីទៅកាន់ដើមនិងស្លឹក ព្រមទាំងមាននាទីស្តុកផលិតផលនៃដំណើររស្មីសំយោគដែលបានពីស្លឹក ។ ឫសអាចលាតសន្ធឹងនិងចាក់ចូលជ្រៅទៅក្នុងដី ។
- **ដើម** : ដើមមាននាទីដឹកនាំទឹកនិងសារធាតុខនិជពីឫសទៅកាន់ផ្នែកផ្សេងៗនៃរុក្ខជាតិ ហើយដឹកនាំសារធាតុសរីរាង្គដែលជាផលនៃដំណើររស្មីសំយោគ ពីស្លឹកទៅកាន់ផ្នែកផ្សេងៗរបស់រុក្ខជាតិវិញ ។ ដើមមួយចំនួនអាចធ្វើរស្មីសំយោគ ហើយក៏អាចផ្ទុកសារធាតុបម្រុងបានដែរ ។
- **ស្លឹក** : ស្លឹករុក្ខជាតិមាននាទីសំខាន់ក្នុងដំណើររស្មីសំយោគ ។ ចំពោះរុក្ខជាតិមានសរសៃនាំ ស្លឹកច្រើនមានរាងសំប៉ែត ។ ផ្ទៃសំប៉ែតរបស់ស្លឹកអាចឱ្យស្លឹកស្រូបពន្លឺបានជាអតិបរមាក្នុងពេលធ្វើរស្មីសំយោគ ។ ស្លឹកផ្តល់សារធាតុសរីរាង្គ ដែលជាផលិតផលនៃដំណើររស្មីសំយោគទៅគ្រប់សរីរាង្គផ្សេងៗរបស់រុក្ខជាតិ ។

## 2. ប្រភេទផ្សេងៗនៃឫស

យើងដឹងហើយថា ឫសរុក្ខជាតិដុះចាក់ចូលទៅក្នុងដី ហើយចងភ្ជាប់រុក្ខជាតិទៅនឹងដី ។ ឫសស្រូបទឹកនិងសារធាតុរំលាយក្នុងដីឱ្យទៅដើមនិងស្លឹក ។ ចំពោះរុក្ខជាតិខ្លះ ជាពិសេសរុក្ខជាតិឌីកូទីលេដូន តែងមានឫសធំមួយដុះត្រង់ទៅក្រោមហៅថា ឫសកែវ ។ ឫសនេះធំនិងមាននាទីស្តុកអាហារទៀតផង ។នៅពេលរុក្ខជាតិលូតលាស់ពេញលេញ ឫសកែវដុះចេញឫសថ្មីៗជាច្រើន ឫសទាំងនោះហៅថាឫសរយាង ។



ក. ឫសស្វៃ

ចំពោះរុក្ខជាតិម៉ូណូកូទីលេដូន គ្មានឫសកែវទេ គឺមានតែឫសស្វៃ ។ ឫសរបស់រុក្ខជាតិមានច្រើនប្រភេទ ។ ឫសរុក្ខជាតិភាគច្រើនផ្ទុកសារធាតុបម្រុង ។

ប្រព័ន្ធឫសដែលស្ថិតនៅក្រោមដីតែងតែដុះលាតសន្ធឹង ដូចជា មែកធាងរុក្ខជាតិដែលនៅលើដីដែរ ។ ទិសនៃការលូតលាស់របស់ឫសអាចលូតវែងឬប្រែប្រួលក្នុងករណីនៅក្នុងដី មានថ្ម ឬឫសឈើ ដទៃទៀតមកបាំងពីមុខ ។ នៅមានកត្តាជាច្រើនទៀតដែលបណ្តាលឱ្យឫសលូតលាស់មិនបានល្អដូចជាសំណើម ឬសមាសធាតុគីមីក្នុងដី ។



ខ ឫសស្ទឹង

ឫសដែលយើងច្រើនជួបប្រទះ គឺឫសស្នឹងនិងឫសស្វៃ ។ ឫសស្នឹងជាឫសកែវដែលធំជាងគេ មានសាច់ច្រើន ហើយក្រាស់ដុះចាក់ចូលជ្រៅទៅក្នុងដី ។

***ឧទាហរណ៍*** : មើមការ៉ុត ឆៃថាវ ប៊ិតក់ ។

ប្រព័ន្ធឫសស្វៃ កើតពីឫសជាច្រើនដែលមានទំហំប្រហាក់ប្រហែលគ្នា ជាពិសេសចំពោះរុក្ខជាតិម៉ូណូកូទីលេដូន ។

***ឧទាហរណ៍*** : ស្រូវ ពោត ។



គ. ឫសព្រយោង

ក្រៅពីឫសស្នឹងនិងឫសកែវ នៅមានឫសមួយប្រភេទទៀត ដែលយើងកម្រជួបប្រទះ គឺឫសព្រយោង ។ ឫសនេះមិនដុះចេញពីឫសកែវ ឬឫសរយាងទេ ប៉ុន្តែវាលូតចេញពីមែក ដើម ឬថ្នាំងនៃដើម ។ ប៉ុន្តែវាក៏អាចលូតលាស់ចាក់ចូលទៅក្នុងដីបានដែរ ។

***ឧទាហរណ៍*** : ឫសពោធិ៍ ឫសជ្រៃ ឫសត្រកួន ។

***រូបទី2.1 :ទម្រង់ឫស***

## ៣. ការលូតលាស់របស់ឫស

ក្នុងរុក្ខជាតិមួយដើម អាចមានក្បាលឫសច្រើនពាន់រាប់មិនអស់ ដែលលូតលាស់បន្តិចម្តងៗចាក់ចូលទៅក្នុងដី ។ ទោះបីជាមានឫសច្រើននិងប្រវែងវែងយ៉ាងណាក៏ដោយ ក៏ការលូតលាស់របស់ឫសមានតែនៅតំបន់តូចមួយនៃក្បាលឫសប៉ុណ្ណោះ ។ ឯតំបន់ផ្សេងទៀតមិនលូតវែងទេ ។ ប្រសិនបើគេគូសចំណាំនៅលើឫសមួយ នៅឆ្នាំក្រោយៗមកគេនឹងឃើញស្នាមនោះស្ថិតនៅដដែលមិនផ្លាស់ប្តូរទីកន្លែងទេ ។

មេជាលិកាកំពូលរបស់ឫស ជាកន្លែងដែលកោសិកាធ្វើចំណែក ។ គឺនៅកន្លែងនោះហើយដែលកោសិកានៃក្បាលឫសកាន់តែដុះវែង ។ ប្រសិនបើយើងសង្កេតមើលក្បាលឫសដោយមីក្រូទស្សន៍ យើងនឹងឃើញមានតំបន់ខុសៗគ្នា ។ តំបន់នីមួយៗមានកោសិកាលូតលាស់ទៅតាមដំណាក់ផ្សេងៗ ។ តំបន់ទាំងនោះមាន

- **មួក** : មួកការពារក្បាលឫសនិងគ្របដណ្តប់មេជាលិកាក្បាលឫស ។ កោសិកានៅក្បាលឫសត្រូវបានជំនួសដោយកោសិកាថ្មីៗជានិច្ចដោយហេតុថា កាលណាកោសិកានៅបន្ទាប់មួកលូតលាស់ វារុញកោសិកាមួកទៅក្នុងដី ។
- **តំបន់មេជាលិកា** : ជាតំបន់ដែលកោសិកាធ្វើចំណែកយ៉ាងសកម្ម ។ តំបន់នេះមានកោសិកាតូចៗនិងមានភ្នាសស្តើង ។ តំបន់មេជាលិកាស្ថិតនៅបន្ទាប់តំបន់មួក ហើយជាកន្លែងដែលកោសិកាដទៃទៀតនៃឫសកើតចេញពីមេជាលិកានេះ ។
- **តំបន់លូតវែង** : ជាតំបន់ដែលកោសិកាកាន់តែលូតវែង ហើយក្លាយជាកោសិកាបំលែងឯកទេស ។ តំបន់នេះស្ថិតនៅបន្ទាប់តំបន់មេជាលិកា ។ តំបន់នេះជា



*រូបទី 2.2 ខ្នាត់បណ្តោយឫស*

កន្លែងដែលកោសិកាកើតចេញដំបូងពីតំបន់មេជាលិកា។ នៅទីនោះ កោសិកាកើនមាឌ ហើយរុញក្បាលឫសទៅមុខទៀត ។

- **តំបន់រោមជញ្ជក់**(ឬតំបន់បំបែងឯកទេស) : ជាតំបន់នៅបន្ទាប់តំបន់លូតវែង ។ នៅទីនោះ កោសិកាទាំងឡាយមានបំបែងឯកទេស ។ នៅក្នុងឫសក៏ដូចជាក្នុងដើមដែរ នៅពេលកោសិកាទាំងឡាយលូតលាស់ពេញលេញ វាបំពេញនាទីផ្សេងៗគ្នា ។ (បំបែងឯកទេសជាលំនាំដែលកោសិកាមិនទាន់មានឯកទេសកម្មលូតលាស់ជាកោសិកាមានឯកទេសកម្ម) ។ ខ្នាត់ទទឹងជាលិកាឫសនៅត្រង់តំបន់រោមជញ្ជក់ បង្ហាញឱ្យឃើញស្រទាប់ជាលិកាមួយចំនួនរបស់ឫស ។ ស្រទាប់ទាំងនោះមាន
- **អេពីឌែម** : ជាស្រទាប់ក្រៅបង្អស់កើតឡើងពីកោសិកាក្រាស់មួយស្រទាប់ ។ កោសិកាទាំងនេះច្រើនមានរោមឆ្មារៗហៅថារោមជញ្ជក់ ។ រោមជញ្ជក់បង្កើនផ្ទៃឫសក្នុងការស្រូបទឹក ។ នៅពេលឫសលូតលាស់ រោមជញ្ជក់ថ្មីៗក៏កើតមានឡើង ឯរោមជញ្ជក់ចាស់ៗក៏ងាប់ហើយជ្រុះចេញ ។ រោមជញ្ជក់អាចមានប្រវែងពី 5 ទៅ 8 មិលីម៉ែត្រចាក់ចូលទៅក្នុងដី ។
- **សំបក** : ស្ថិតនៅក្រោមអេពីឌែម ។ កោសិកាប៉ារ៉ង់ស៊ីមរបស់សំបកផ្ទុកសារធាតុបម្រុងដែលភាគច្រើនជាអាមីដុង ។ កោសិកាប៉ារ៉ង់ស៊ីមក៏មាននាទីដឹកនាំទឹក និងអំបិលរ៉ែទៅកាន់ជាលិកានាំកណ្ដាលឫសដោយស្រូបតាមរោមជញ្ជក់ ។
- **អង់ដូឌែម** : ជាស្រទាប់ក្នុងបង្អស់នៃសំបក ។ កោសិកាទាំងឡាយនៃសំបកមាននាទីត្រួតពិនិត្យចលនាទឹកនៅក្នុងស៊ីឡាំងកណ្ដាល ។



*រូបទី 2.3 : ខ្នាត់ទទឹងរបស់ឫស*

ស៊ីឡាំងកណ្ដាលត្រូវព័ទ្ធជុំវិញ ដោយកោសិកាមួយស្រទាប់ដែលស្ថិតនៅខាងក្រោមជាប់នឹងអង់ដូឌែម ។ វាមានឈ្មោះថាប៉េរីស៊ីក ។ ឫសរយាងដុះចេញពី ស្រទាប់ប៉េរីស៊ីកដោយដុះឆ្លងកាត់សំបកនិងអេពីឌែម ហើយចាក់ចូលទៅក្នុងដី ។

ចំពោះរុក្ខជាតិខ្លះ ស៊ីឡាំងកណ្ដាលមានស្រទាប់មេក្នុង ។ ស្រទាប់មេក្នុងផលិតស៊ីឡែមថ្មីៗដោយរុញស៊ីឡែមចាស់ៗទៅផ្នែកកណ្ដាលឫសនិងផ្លូអែមចាស់ៗទៅផ្នែកសំបកឫស ។

## 4. ឫសនិងមីក្រូសារពាង្គកាយ

នៅម្ដុំឫសរុក្ខជាតិ តែងតែមានមីក្រូសារពាង្គកាយរស់នៅដូចជា ផ្សិតនិងបាក់តេរីជាដើម ។ ឫសនិងមីក្រូសារពាង្គកាយទាំងនោះតែងផ្ដល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ។ ទំនាក់ទំនងនេះមានឈ្មោះថា **ទំនាក់ទំនងសហប្រាណ** ។ រុក្ខជាតិផ្ដល់អាហារខនិជទៅគ្រប់ផ្នែកទាំងអស់បានតាមវិធីសហប្រាណពីរយ៉ាង

- សហប្រាណជាមួយបាក់តេរី : រុក្ខជាតិមិនអាចប្រើប្រាស់អាសូតពីបរិយាកាសបានទេ ព្រោះគ្មានអង់ស៊ីមសម្រាប់បំបែកសម្ព័ន្ធអាសូត ($N\equiv N$) ។ ម្យ៉ាងទៀតរុក្ខជាតិមានអ៊ីយ៉ុងនីត្រាត ($NO_3^-$) ដែលឫសស្រូបពីក្នុងដី ។ ចំពោះប្រភេទរុក្ខជាតិមួយចំនួនដូចជាអម្បូរសណ្ដែក(ជាបាសេ) ឫសរបស់វាមានកំពកឫសនិងមានបាក់តេរីនៅក្នុងកំពកឫស ។ បាក់តេរីទាំងនោះអាចបំបែកសម្ព័ន្ធអាសូត ដោយបន្ថយអាសូតពីអ៊ីយ៉ុងអាម៉ូញ៉ូម ( $NH_4^+$ ) ដើម្បីផ្សំបញ្ចូលគ្នាបង្កើតជាសមាសធាតុសរីរាង្គដែលរុក្ខជាតិអាចស្រូបយកបាន ។ លំនាំនៃការបន្ថយអាសូតពីអ៊ីយ៉ុងអាម៉ូញ៉ូម($NH_4^+$ ) មានឈ្មោះថា **ការភ្ជាប់អាសូត** ។
- សហប្រាណជាមួយផ្សិតៈ ផ្សិតលូតលាស់នៅជុំវិញឫសរុក្ខជាតិ ហើយតែងតែជ្រៀតចូលក្នុងសំបកឫស ។ ផ្សិតបង្កើនផ្ទៃដែលអាចឱ្យរុក្ខជាតិស្រូបសារធាតុខនិជនិងទឹកបានច្រើន ។ មិនតែប៉ុណ្ណោះ ផ្សិតបំបែកសមាសធាតុសរីរាង្គព្រមទាំងបញ្ចេញអាហារចិញ្ចឹមដែលរុក្ខជាតិត្រូវការប្រើប្រាស់ ។ ផ្ទុយទៅវិញ ឫសផ្ដល់ដល់ផ្សិតនូវស្ករនិងអាមីណូអាស៊ីត (អាស៊ីតអាមីនេ) ។ ដូចនេះទំនាក់ទំនងរវាងផ្សិតនិងឫសរុក្ខជាតិជួយរុក្ខជាតិឱ្យលូតលាស់ល្អ ។

ចំពោះរុក្ខជាតិដែលមិនធ្វើរស្មីសំយោគ វាប្រើប្រាស់ផ្សិតដើម្បីចំរាញ់យកអាហារពីដើមឈើដែលនៅក្បែរពួកវា ។ អ៊ីបរបស់ផ្សិតភ្ជាប់ទៅនឹងរុក្ខជាតិដែលនៅក្បែរតាមវិធីសហប្រាណហើយភ្ជាប់ទៅនឹងឫសរបស់រុក្ខជាតិមួយទៀត ។ ចំពោះរុក្ខជាតិដែលឫសមិនសូវលូតលាស់ឬគ្មានឫស ទឹកនិងសារធាតុខនិជត្រូវបានផ្ដល់ដោយវិធីផ្សេងទៀត គឺពឹងលើស្លឹកក្នុងការស្រូបសមាសធាតុសរីរាង្គ (***ឧទាហរណ៍*** រុក្ខជាតិមំសាសី) ។ ចំពោះរុក្ខជាតិអេពីភីត ឫសរបស់វាស្រូបយកសំណើមនិងអាហារពីខ្យល់ (***ឧទាហរណ៍*** អ័រគីដេ) ។ រុក្ខជាតិទាំងនេះមិនមែនជាបរាសិតទេ ។

## មេរៀនសង្ខេប

- សរីរាង្គផ្សេងៗរបស់រុក្ខជាតិមាន ឫស ដើម និងស្លឹក ។
- ឫសចងភ្ជាប់រុក្ខជាតិទៅនឹងដី ។ ឫសមាននាទីសំខាន់ក្នុងការស្រូបទឹកនិងសារធាតុខនិជរលាយក្នុងដី ។ ប្រព័ន្ធឫសមានពីរប្រភេទធំៗគឺ ឫសស្នឹងនិងឫសស្វៃ ។
- ឫសស្និងជាឫសកែវដុះលូតលាស់លឿនចាក់ជ្រៅទៅក្នុងដី ហើយក្លាយជាឫសធំជាងគេ ។
- ឫសស្វៃ ជាឫសមានចំនួនច្រើន ហើយមានទំហំប្រហាក់ប្រហែលគ្នា ។
- ឫសចែកជាតំបន់ផ្សេងៗរួមមាន មួក តំបន់មេជាលិកា តំបន់លូតវែង និងតំបន់រោមជញ្ជក់ (តំបន់បំលែងឯកទេស) ។ ក្បាលឫសជាកន្លែងលូតលាស់ខ្លាំងជាងគេ ។
- ខ្នាត់ទទឹងឫស គេឃើញជាលិកាឫសមាន អេពីឌែម សំបកដែលមានអង់ដូឌែមនិងស៊ីឡាំងកណ្តាល (ស៊ីឡែមនិងផ្លូអែម) ។
- ឫសតែងតែមានមីក្រូសារពាង្គកាយរស់នៅជាមួយ ។ ទំនាក់ទំនងរវាងឫសនិងមីក្រូសារពាង្គកាយហៅថាទំនាក់ទំនងសហប្រាណ ។

## សំណួរនិងលំហាត់

1. តើឫសមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
2. តើតំបន់ទាំងបីរបស់ឫសដែលលូតលាស់មានអ្វីខ្លះ ?
3. តើឫសមានមុខងារអ្វីខ្លះ ?
4. ដូចម្តេចដែលហៅថា ឫសព្រយោង ? ចូរឱ្យឧទាហរណ៍រុក្ខជាតិឫសព្រយោងឱ្យបានពីរ ។
5. តើឫសរុក្ខជាតិនិងមីក្រូសារពាង្គកាយមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចខ្លះ ?
6. រកលក្ខណៈខុសគ្នារវាងឫសម៉ូណូកូទីលេដូននិងឌីកូទីលេដូន ?
7. បើធ្វើខ្នាត់ទទឹងឫស តើអ្នកសង្កេតឃើញកោសិកាអ្វីខ្លះ ? ចូរពន្យល់និងបញ្ជាក់ពីនាទីរបស់កោសិកាប្រភេទនីមួយៗ ។

# ពិសោធន៍ : សង្កេតទម្រង់ទី 1 និងទី 2 នៃឫសរុក្ខជាតិឌីកូទីលេដុង

## 1. វត្ថុបំណង

- កំណត់បានពីទម្រង់និងវិមាត្រជាលិកាផ្សេងៗរបស់ឫស ។
- ក្រោយសង្កេត សិស្សគូររូបជាលិកាផ្សេងៗរបស់ឫស ។
- ចង្អុលបង្ហាញជាលិកាផ្សេងៗរបស់ឫស ។

## 2. សម្ភារៈ

- មីក្រូទស្សន៍ ឫសល្ពៅ ឬ ឫសជ្រៃក្រិម ទឹកសាវែល ទឹកសុទ្ធ ចានកែវ អាស៊ីតអាសេទិច $\frac{1}{100}$ ខៀវមេទីឡែនវារ $\frac{1}{1000}$ សូលុយស្យុងកាម៉ាំង កូនកាំបិត បន្ទះឡាម បន្ទះឡាមែល ។

## 3. ដំណើរការពិសោធ

ធ្វើខ្នាត់ទទឹងឫសរបស់រុក្ខជាតិខាងលើ រួចបន្សុំពណ៌ពីរដង

- កាត់ទទឹងឫសឱ្យបានស្តើងបំផុត
- ត្រាំខ្នាត់នោះក្នុងទឹកសាវែលពី 15 – 20 នាទី
- លាងទឹកសំអាត ឬទឹកអាស៊ីតអាសេទិច $\frac{1}{100}$ ឱ្យស្អាត
- បន្សុំពណ៌ដោយខៀវមេទីឡែនវារ $\frac{1}{1000}$ ពី 1 – 3 នាទី
- លាងនឹងទឹកស្អាតយ៉ាងតិចបីដង ។
- បន្សុំពណ៌ក្រហមដោយសូលុយស្យុងកាម៉ាំង ពី 15 – 20 នាទី
- លាងនឹងទឹកស្អាតឱ្យបានស្អាតល្អ
- ដាក់ខ្នាត់ដែលលាងរួចត្រាំក្នុងចានកែវដែលមានទឹកសុទ្ធ (ការពារកុំឱ្យខូច)
- យកខ្នាត់ដាក់លើបន្ទះឡាមដែលមានតំណក់ទឹកសុទ្ធ រួចយកទៅពិនិត្យក្នុងមីក្រូទស្សន៍ ។

## 4. វិភាគ

- សិស្សចង្អុលបង្ហាញជាលិកាផ្សេងរបស់ឫស ។
- សិស្សគូររូបឡើងវិញពីអ្វីដែលគេបានសង្កេត ។




A. ទម្រង់ទូទៅរបស់ឫសល្ពៅ

1. អិចសូឌែម
2. ប៉ារ៉ង់ស៊ីមសំបក
3. មែបញ្ចេញ
4. អង់ដូឌែម
5. ម៉ាំរីស៊ិក
6. ផ្លូអែម
7. ស៊ីឡែម
8. ប៉ារ៉ង់ស៊ីមបណ្តូល

B.




1. ស្បៃល
2. រំអិលឈើ
3. ឆ្នូតបណ្តូរ
4. បារ៉ង់ស៊ីមសំបក
5. ស៊ីឡែមទី 1
6. ស៊ីឡែមទី 2
7. ផ្លូអែមទី 2

A : ទម្រង់ទូទៅ ឫសល្ពៅ

B : ទម្រង់លំអិត

# 3 ដើមនិងស្លឹក

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាបានពីទម្រង់និងនាទីរបស់ដើមរុក្ខជាតិ ។
- ពណ៌នាបានពីប្រភេទផ្សេងៗនៃស្លឹក ។
- ប្រៀបធៀបបានដើមរុក្ខជាតិស្មៅនិងដើមរុក្ខជាតិឈើ ។
- ប្រៀបធៀបបានទម្រង់ខាងក្រោមនៃស្លឹកម៉ូណូកូទីលេដុននិងស្លឹកឌីកូទីលេដុន ។
- ស្គាល់អត្ថប្រយោជន៍ មានស្មារតីស្រឡាញ់ និងថែរក្សារុក្ខជាតិ ។

អ្នកបានសិក្សារួចមកហើយ អំពីផ្នែកខាងក្នុងដីរបស់រុក្ខជាតិ គឺឫស ។ ក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីផ្នែកខាងលើដីរបស់រុក្ខជាតិ ។ ផ្នែកខាងលើដីមានពន្លកដើមដែលមានដើមនិងស្លឹក ។ មុនដំបូង ថ្នាំងស្ថិតនៅជាប់ៗគ្នា ។ បន្ទាប់មកមានចន្លោះថ្នាំងដែលធ្វើឱ្យថ្នាំងកាន់តែឃ្លាតឆ្ងាយពីមួយទៅមួយ ។ ដើមមាននាទីទ្រទ្រង់ស្លឹក ផ្កា និងផ្លែ ។ វាដឹកនាំសំភារៈពីឫសទៅស្លឹកនិងពីស្លឹកមកវិញ ។ មិនតែប៉ុណ្ណោះ វាជួយស្តុកទឹកនិងផលិតផលនៃរស្មីសំយោគទៀតផង ។

## 1. ដើម

ដើមរុក្ខជាតិក៏មាននាទីដូចជាឫសដែរ ។ នៅចុងពន្លកនៃកំពូលដើម មានមេជាលិកាកំពូល ។ យើងបានឃើញហើយថា មេជាលិកាកំពូលឫសត្រូវបានការពារដោយមួក ។ រីឯចុងពន្លកដើម ត្រូវបានការពារដោយត្រួយខ្ចីៗនៅក្នុងពន្លកដើម ។ មេជាលិកាកំពូលផលិតកោសិកាថ្មីៗដែលនឹងក្លាយទៅជាដើមនិងស្លឹក ។ មុនដំបូងថ្នាំងស្ថិតនៅជាប់ៗគ្នា បន្ទាប់មកចន្លោះថ្នាំងលូតលាស់ធ្វើឱ្យថ្នាំងកាន់តែឃ្លាតឆ្ងាយពីគ្នា ។ ការលូតលាស់នេះកាន់តែស្មុគស្មាញឡើងៗ រហូតបង្កើតបានជាដើម ហើយគេក៏មិនអាចមើលឃើញចំណែកកោសិកាឬការលូតវែងក្នុងដើមដូចឫសបានដែរ ។

ដើមរុក្ខជាតិខ្ពស់ៗអាចទ្រស្លឹកឱ្យខ្ពស់ ដែលអាចឱ្យស្លឹកត្រូវពន្លឺបានច្រើន ។ ដោយផ្អែកលើទម្រង់របស់វា គេបែងចែករុក្ខជាតិទាំងឡាយជាពីរ គឺរុក្ខជាតិស្មៅនិងរុក្ខជាតិឈើ ។

## 1.1. រុក្ខជាតិស្មៅ

រុក្ខជាតិស្មៅមានដើមទន់ ពណ៌បៃតង ហើយមានទឹកដម ។ តាមធម្មតារុក្ខជាតិស្មៅមានអាយុពីមួយឆ្នាំទៅពីរឆ្នាំ។ ***ឧទាហរណ៍*** : សណ្តែក ពោត ស្រូវ ប៉េងប៉ោះ ថ្នាំជក់ ។

ជាលិកាក្រៅបង្អស់របស់រុក្ខជាតិស្មៅជាកោសិកាអេពីឌែម ដែលគ្របដណ្តប់ដោយស្រទាប់គុយទីគុល ដើម្បីការពារការបាត់បង់ទឹក ។ ដើមមានបាច់សរសៃនាំដែលមានស៊ីឡែមនិងផ្លូអែម ។ ក្នុងបាច់សរសៃនាំនីមួយៗ ស៊ីឡែមស្ថិតនៅខាងក្នុង ឯផ្លូអែមស្ថិតនៅខាងក្រៅ ។

ជាលិកាទាំងអស់របស់រុក្ខជាតិស្មៅ លូតលាស់ចេញពីជាលិកាដែលផលិតដោយមេជាលិកាកំពូល ។ ទោះបីជាវាកើតចេញពីប្រភពតែមួយក៏ដោយ ក៏របផ្គុំនៃជាលិកាទាំងនេះខុសៗគ្នាទៅតាមប្រភេទរុក្ខជាតិស្មៅនីមួយៗដែរ ។

គេចែករុក្ខជាតិស្មៅជាពីរក្រុមគឺ ម៉ូណូកូទីលេដូន (រុក្ខជាតិដែលមានគ្រាប់កូទីលេដុងតែមួយ)និងឌីកូទីលេដូន (រុក្ខជាតិដែលមានគ្រាប់កូទីលេដុងពីរ) ។

### ក. រុក្ខជាតិស្មៅម៉ូណូកូទីលេដូន




*រូបទី3.1 : ក. ដើមរុក្ខជាតិស្មៅឌីកូទីលេដូន ខ. ស្មៅម៉ូណូកូទីលេដូន*

រុក្ខជាតិស្មៅម៉ូណូកូទីលេដូន មានកោសិកាប៉ារ៉ង់ស៊ីម ។ បាច់សរសៃនាំមានស៊ីឡែមនិងផ្លូអែមស្ថិតនៅរាត់រាយពាសពេញជាមួយកោសិកាប៉ារ៉ង់ស៊ីមដែលជាហេតុធ្វើឱ្យយើងពិបាកក្នុងការបែងចែកសំបកឬសាច់ឈើ ។ ***ឧទាហរណ៍*** ដើមពោត ស្រូវ ។ ពោតមានអេពីឌែមមួយស្រទាប់ដែលព័ទ្ធពីក្រៅសម្រាប់ការពារដើមពណ៌បៃតងនិងកុំឱ្យខ្ទន់ ។ ស្រទាប់អេពីឌែមនេះ មានរន្ធតូចៗជាច្រើន ហៅថា ស្តូម៉ាត ។រន្ធតូចៗទាំងនេះអាចឱ្យជាលិកាខាងក្នុងដើមនិងបរិយាកាសខាងក្រៅធ្វើបណ្តូរឧស្ម័នបាន ។ នៅខាងក្រោមអេពីឌែម មានស្រទាប់កោសិកាផ្ទុកក្លរ៉ូប្លាសដែលមាននាទីចូលរួមក្នុងដំណើររស្មីសំយោគ ។

## ខ. រុក្ខជាតិស្មៅឌីកូទីលេដូន

ដើមរុក្ខជាតិស្មៅឌីកូទីលេដូន រុំព័ទ្ធដោយស្រទាប់អេពីឌែមសម្រាប់ការពារ ។ នៅខាងក្រោមអេពីឌែម មានសំបកដែលកើតឡើងពីកោសិកាប៉ារ៉ង់ស៊ីមនិងកូឡង់ស៊ីម ។ កោសិកាទាំងនេះមាននាទីទ្រទ្រង់ដើមនិងជាកន្លែងស្តុកសារធាតុបម្រុង ។ ក្នុងសំបកមានបាច់សរសៃនាំ ។ ជួនកាលសំបកមានពណ៌បៃតងដែលមាននាទីក្នុងរស្មីសំយោគ ។ បាច់សរសៃនាំនីមួយៗកើតឡើងពីកោសិកា ផ្លូអែមនៅខាងក្រៅ ស៊ីឡែមនៅខាងក្នុងនិងស្រទាប់មេក្នុងដែលស្ថិតនៅចន្លោះស៊ីឡែមនិងផ្លូអែម ។ ស្រទាប់មេក្នុងអាចរងចំណែកកោសិកាមួយរយ ខ្លី ដែលបណ្តាលឱ្យកើនបរិមាណស៊ីឡែមនិងផ្លូអែម ។នៅកណ្តាលដើមឬបណ្តូលមានកោសិកាប៉ារ៉ង់ស៊ីម ដែលមានផ្ទុកសារធាតុបម្រុង ។

***ឧទាហរណ៍*** ៈ ដើមថ្នាំជក់ ជី ផ្កាឈូករតន៍ ។



ក. ទន្ទ្រានខៃព្រ ខ. ជី គ. ស្បៀវៀង

***រូបទី3.2 ៈដើមរុក្ខជាតិស្មៅឌីកូទីលេដូន***

## 1.2. ដើមរុក្ខជាតិឈើ

រុក្ខជាតិឈើស្ទើរតែទាំងអស់ជារុក្ខជាតិឌីកូទីលេដូន ។ ដើមនិងឫសរបស់រុក្ខជាតិឈើលូតលាស់ផ្នែកទទឹង ។ ការលូតលាស់ផ្នែកទទឹងនេះ បណ្តាលមកពីស្រទាប់មេក្នុងផលិតជាលិកាថ្មីៗពេញមួយជីវិតរបស់វា ។ ស្រទាប់មេក្នុងបង្កើតវង់ស៊ីឡែមនិងផ្លូអែមថ្មីៗជារៀងរាល់ឆ្នាំ ។ ការលូតលាស់របស់ស៊ីឡែមថ្មីៗបង្កើតជាវង្វង់ឆ្នាំ ។ ដើមរុក្ខជាតិរឹងមាំដោយមានបរិមាណស៊ីឡែមច្រើន ។ ការកើនវង្វង់ស៊ីឡែមធ្វើឱ្យដើមរុក្ខជាតិលូតលាស់ផ្នែកទទឹង ។ ក្នុងរយៈពេលលូតលាស់ ទំហំនៃវង្វង់ឆ្នាំអាចប្រែប្រួលទៅតាមអាកាសធាតុ ។ ក្នុងករណីលក្ខខណ្ឌជីវិតសមស្រប វង្វង់ឆ្នាំនិងលូតធំនាប់រហ័ស ។ វង្វង់នីមួយៗបង្ហាញ

ពីអាយុមួយឆ្នាំនៃការលូតលាស់ ។ គេអាចដឹងអាយុរុក្ខជាតិឈើឌីកូទីលេដូនដោយការរាប់រង្វង់សាច់ឈើ ។ ដូចនេះ រុក្ខជាតិមួយចំនួនក៏អាចបង្ហាញពីប្រវត្តិនៃបម្រែបម្រួលអាកាសធាតុផងដែរ ។

***ឧទាហរណ៍*** : ដើមសេកូយ៉ា នៅកាលីហ្វ័រនីញ៉ា (អាមេរិក) មានជីវិតរាប់ពាន់ឆ្នាំ ។

ដើមរុក្ខជាតិឈើឌីកូទីលេដូន ខុសគ្នាទាំងស្រុងពីដើមរុក្ខជាតិស្មៅឌីកូទីលេដូន ។ ដើមរុក្ខជាតិឈើចែកចេញជាតំបន់បីខុសៗគ្នា គឺសំបកឈើ សាច់ឈើ និងខ្លឹមឈើ ។

នៅកណ្តាលដើមរុក្ខជាតិឈើឌីកូទីលេដូនដែលនៅខ្ចី មានបណ្តូលនិងសំបកដែលមានអេពីឌែមនៅពីក្រៅ ។ ចំពោះរុក្ខជាតិឈើចាស់ៗ ស្រទាប់សំបកត្រូវជំនួសដោយផ្លូអែម ដែលកើតចេញពីស្រទាប់មេក្នុង ហើយកោសិកានៃបណ្តូលត្រូវងាប់ ។ ស៊ីឡែមរស់មានពណ៌ភ្លឺថ្លា មានឈ្មោះថាឈើស្រាយ ស្ថិតនៅជាប់និងស្រទាប់មេក្នុង មាននាទីដឹកនាំទឹក ។ ពីមួយឆ្នាំទៅមួយឆ្នាំ ឈើស្រាយមានកម្រាស់ថេរ ។ ស្ថេរភាពនៃកម្រាស់ឈើស្រាយបណ្តាលមកពីឈើស្រាយចាស់ៗវិវត្តទៅជាឈើខ្លឹម នៅពេលដែលស្រទាប់មេក្នុងបង្កើតបានឈើស្រាយថ្មីៗទៀត ។ ឈើខ្លឹមនៅខាងក្នុងមានពណ៌ក្រមៅ ។ គឺជាតំបន់ស៊ីឡែមចាស់ៗ ។ ដោយស្រទាប់ឈើខ្លឹមចេះតែកើតឡើងថ្មីៗទៀត ទើបខ្លឹមឈើកាន់តែកើនច្រើនឡើងៗ ។




*រូបទី 3.3 : វង់ឆ្នាំរបស់រុក្ខជាតិឈើ(ប្រវត្តិជីវិតរបស់រុក្ខជាតិដែលដាំពីឆ្នាំ ១៩០៨ និងកាប់នៅឆ្នាំ ១៩៧០)*

ស្រទាប់ក្រៅបង្អស់នៃដើមរុក្ខជាតិឈើជាជាលិកាការពារហៅថា ក្រមរឈើ ។ ចំពោះដើមតូចៗ ក្រមរឈើមានភាពស្តើង ។ នៅពេលដើមឈើឡើងចាស់ ក្រមរឈើកាន់តែក្រាស់ខ្លាំង ។ ក្រមរឈើកើតឡើងពីកោសិកាសំបកថ្មីៗ ស្រទាប់មេក្រៅនិងល្បែស ។ ផ្នែកនៅខាងក្នុងក្រមរឈើ ជាផ្នែកខ្ចី ជាកោសិកាមានជីវិត ឯផ្នែកចាស់ៗជាកោសិកាងាប់ ។ នៅពេលរុក្ខជាតិរីកទំហំ ក្រមរឈើថ្មីៗកើតឡើងជំនួសក្រមរចាស់ដែលត្រូវបែកនិងរបើកចេញ ។

## 1.3. ឫយ៉ាងផ្សេងៗរបស់ដើមឈើ

ក្រៅពីរុក្ខជាតិស្មៅនិងរុក្ខជាតិឈើដែលដុះនៅលើដី នៅមានដើមរុក្ខជាតិមួយចំនួនទៀតដែលដុះកប់ក្នុងដី ។ ដើមទាំងនោះមាន

### ក. មើម

ជាដើមក្រោមដីដែលមានរាងកំប៉ោងធំ ។ មើមមានលក្ខណៈខុសពីឫស ព្រោះវាតែងតែមានភ្នែកជានិច្ច ។ *ឧទាហរណ៍ :* មើមដំឡូងបារាំង (មានភ្នែក) ។ ប្រសិនបើមើមគ្មានភ្នែក នោះមិនមែនជាមើមទេ គឺជាប្រភេទឫសផ្ទុកសារធាតុបម្រុង ។ *ឧទាហរណ៍ :* មើមត្រាវ មើមដំឡូងជ្វា ។

### ខ. ក្លៀង

ជាដើមដែលលូតលាស់នៅក្រោមដី ។ នៅលើក្លៀង មានស្លឹក ឬស្រកា ។ *ឧទាហរណ៍* រមៀត រំដេង ខ្ញី . . . ។

### គ. មើមស្រទាប់

ជាមើមខ្លីរុំព័ទ្ធដោយគ្របកមើមស្រទាប់ក្រាស់ៗជាច្រើន ដែលផ្ទុកអាហារបម្រុងសម្រាប់ផ្តល់ថាមពលដល់រុក្ខជាតិប្រើប្រាស់នៅពេលវាលូតលាស់ ។ *ឧទាហរណ៍* ខ្ទឹមបារាំង ។




*រូបទី 3.4 : មើម ក្លៀង និងមើមស្រទាប់*

# 2. ស្លឹក

ស្លឹកជាសរីរាង្គសំខាន់របស់រុក្ខជាតិដែលមាននាទីក្នុងដំណើររស្មីសំយោគ ។ ជាទូទៅ ស្លឹកមានទងស្លឹកនិងតួស្លឹកមួយរាងសំប៉ែត ។ ទ្រង់ទ្រាយសំប៉ែតនិងទីតាំងរបស់ស្លឹកនៅជុំវិញដើមអាចឱ្យផ្ទៃស្លឹកប៉ះនឹងពន្លឺព្រះអាទិត្យបានច្រើន ។

## 2.1. ប្រភេទផ្សេងៗនៃស្លឹក

ទងភ្ជាប់តួស្លឹកទៅនឹងដើម ។ ការតម្រៀបរបស់ស្លឹកនៅលើដើម ទ្រង់ទ្រាយស្លឹកនិងទ្រនុងស្លឹកជាលក្ខណៈពិសេសរបស់ប្រភេទរុក្ខជាតិនីមួយៗ ដែលអាស្រ័យទៅនឹងមជ្ឈដ្ឋានដែលវារស់នៅ ។ ស្លឹក

រុក្ខជាតិមានច្រើនបែប ស្លឹកទោល ស្លឹករួមសមាស ស្លឹកស្ថិតតួ ស្លឹកកញ្ចុំ ស្លឹកឆ្លាស់ ស្លឹកឈម ។ ស្លឹកទោលមានតែតួស្លឹកមួយនិងទងស្លឹកមួយ ។ ឯស្លឹករួមសមាស តួស្លឹកត្រូវបែងចែកជាស្លឹកតូចៗដែលតម្រៀបភ្ជាប់ទៅនឹងទងមួយ ។ ចំពោះរុក្ខជាតិស្មៅ ម្ទូលក្ខណ៍លេដូន ស្លឹកគ្មានទងទេ ប៉ុន្តែមានស្រោបស្លឹកបន្តពីតួស្លឹកដើម្បីក្តោបដើម ។ នៅតាមបណ្តោយទ្រនុងស្លឹក មានផ្ទុកជាលិកានាំដែលមានស៊ីឡែមនិងផ្លូអែម ស្ថិតនៅពេញផ្ទៃស្លឹក ។ ***ឧទាហរណ៍*** ស្លឹកស្រូវ ពោត ។

រុក្ខជាតិមួយចំនួនមានជីវិតបន្សាំទៅនឹងអាកាសធាតុស្ងួត ។ ***ឧទាហរណ៍*** ដើមដំបងយក្ស ។ វាស៊ាំទៅនឹងជីវិតក្នុងវាលលំហ ដែលធ្វើឱ្យស្លឹករបស់វាក្លាយទៅជាបន្លា ហើយមាននាទីការពារដើម ។ ឯដើមមាននាទីធ្វើរស្មីសំយោគនិងស្តុកទឹក ។ រុក្ខជាតិខ្លះ មានស្លឹកចំាៗដែលអាចយកមកខ្ចូរការពារភ្លៀងបាន (***ឧទាហរណ៍*** ស្លឹកម៉ៃសាក់) ។ ស្លឹករុក្ខជាតិខ្លះទៀតអាចចាប់សត្វល្អិតធ្វើជាអាហារបាន ។ ***ឧទាហរណ៍*** រុក្ខជាតិ ចាណកាសិ (ដ្រូសេរ៉ា) ។




***រូបទី 3.5 : ស្លឹកទោល***

## 2.2. ទម្រង់ក្នុងរបស់ស្លឹក

ទោះបីជាស្លឹករុក្ខជាតិមានទម្រង់ខុសគ្នាយ៉ាងណាក៏ដោយ គឺស្លឹករុក្ខជាតិសុទ្ធតែបង្កើតឡើងដោយជាលិកាបីប្រភេទ ។ ជាលិកាទាំងនោះ គឺជាលិកាការពារ ជាលិកាគ្រឹះ និងជាលិកានាំ ។

### ក. គុយទីគុលនិងអេពីឌែម

ស្រទាប់ក្រៅបង្អស់នៃផ្នែកខាងលើនិងខាងក្រោមផ្ទៃស្លឹក មានសារធាតុម្យ៉ាងភ្លឺរលោង មានឈ្មោះថាគុយទីគុល ។ ស្រទាប់គុយទីគុលនេះ ការពារជាលិកាក្នុងស្លឹកនិងបន្ថយការបាត់បង់ទឹកចេញពីស្លឹក ។ ផ្ទុយទៅវិញ ស្រទាប់គុយទីគុលក៏ការពារបណ្តូរឧស្ម័នផងដែរ ព្រោះឧស្ម័នមិនអាចជ្រាបចូលបាន ។ ប៉ុន្តែនៅក្រោមស្រទាប់គុយទីគុល មានកោសិកាអេពីឌែមដែលជាស្រទាប់ការពារជាលិកាខាងក្នុងស្លឹក ហើយមានផ្ទុកស្តូម៉ាតច្រើន ។ ក៏ដូចជាស្រទាប់អេពីឌែមដទៃទៀតដែរ អេពីឌែមរបស់ស្លឹកកើតឡើងពីកោសិកាក្រាស់តែមួយស្រទាប់ កោសិកាអេពីឌែមភាគច្រើនមានលក្ខណៈថ្លា ព្រោះវាគ្មានជាតិពណ៌ឬ

មានតិចតួច លក្ខណៈថ្លារបស់អេពីឌែមអាចឱ្យពន្លឺឆ្លងចូលទៅដល់កោសិកានៅពេលធ្វើរស្មីសំយោគ ។ តាមធម្មតា នៅផ្ទៃក្រោមស្លឹកមានស្តូម៉ាតច្រើនជាងផ្ទៃលើស្លឹក ។ ស្តូម៉ាតជាកន្លែងដែលធ្វើបណ្តូរឧស្ម័នកាបូនិចនិងអុកស៊ីសែន រវាងជាលិកាខាងក្នុងស្លឹកនិងមជ្ឈដ្ឋាន ជាពិសេសរំភាយចំហាយទឹកក៏ចេញទៅក្រៅស្លឹកតាមរយៈ ស្តូម៉ាតនេះដែរ ។ ការបើកឬបិទរបស់ស្តូម៉ាតអាស្រ័យទៅនឹងតម្រូវការរបស់ស្លឹក ។វាមិនមែនបើកគ្រប់ពេលនោះទេ ។ ការបើកបិទរបស់ស្តូម៉ាតនីមួយៗត្រូវបានត្រួតពិនិត្យដោយកោសិកាមួយគូដែលមានទ្រង់ទ្រាយ ដូចតម្រងនោមមានឈ្មោះថា កោសិកាល្បាត ។ កោសិកាល្បាត ជាកោសិកាអេពីឌែមដែលមានឯកទេសកម្ម ។




*រូបទី3.6 : ទម្រង់ក្នុងរបស់ស្លឹក*

## ១. មេសូភីល

តាមធម្មតា កោសិកាអេពីឌែមមិនផ្ទុកក្លរ៉ូប្លាសទេ ។ មានតែកោសិកាល្បាតទេដែលផ្ទុកក្លរ៉ូប្លាស ។ នៅចន្លោះអេពីឌែម ទាំងផ្នែកលើនិងក្រោមស្លឹក មានស្រទាប់ជាលិកាសម្រាប់ធ្វើរស្មីសំយោគដែលមានឈ្មោះថា មេសូភីល ។ មេសូភីលជាកោសិកាមានភ្នាសស្តើង ។ រុក្ខជាតិមានមេសូភីលពីរប្រភេទ ។ ស្រទាប់ខាងលើមានឈ្មោះថា មេសូភីលប៉ាលីសាត ដែលកើតឡើងពីកោសិកាមួយ ឬពីរស្រទាប់ ។ ស្រទាប់នេះកើតឡើងពីកោសិកាវែងៗស្ថិតនៅកៀកជិតគ្នាយ៉ាងខ្លាំង ។ កោសិកាទាំងនេះផ្ទុកទៅដោយក្លរ៉ូប្លាស ។ នៅក្រោមស្រទាប់ប៉ាលីសាត មានមេសូភីលស្ពោត ។ ស្រទាប់នេះកើតឡើងពីកោសិកាជាច្រើន ដែលមានទ្រង់ទ្រាយមិនទៀងទាត់ ។ នៅចន្លោះកោសិកាទាំងនេះ មានប្រហោងធំៗ ។ ផ្ទៃក្រោមស្លឹក នៅជាប់និងលំហចន្លោះកោសិកានៃមេសូភីលស្ពោត មានរន្ធស្តូម៉ាតនៃអេពីឌែម ។ កោសិកានៃមេសូភីលស្ពោត មានក្លរ៉ូប្លាសតិចជាងកោសិកានៃមេសូភីលប៉ាលីសាត ។

## គ. ទ្រនុងស្លឹក

នៅក្នុងស្រទាប់មេសូភីលមានបណ្ដាញទ្រនុងស្លឹក ។ ទ្រនុងស្លឹកមានផ្ទុកជាលិកានាំ ដែលមានស៊ីឡែមនិងផ្លូអែម ។ ស៊ីឡែមនិងផ្លូអែមរបស់ទ្រនុងស្លឹកបន្តពីស៊ីឡែមនិងផ្លូអែមរបស់ដើមនិងឫស ។ការតម្រៀបទ្រនុងស្លឹករបស់រុក្ខជាតិម៉ូណូកូទីលេដូន មានលក្ខណៈខុសគ្នាស្រឡះពីរុក្ខជាតិឌីកូទីលេដូន ។ រុក្ខជាតិម៉ូណូកូទីលេដូនមានទ្រនុងស្លឹកធំៗ ហើយស្របគ្នាតាមបណ្ដោយស្លឹក ។ ឯស្លឹករុក្ខជាតិឌីកូទីលេដូនវិញ មានទ្រនុងស្លឹកបែកមែកជាបណ្ដាញនៅពាសពេញក្នុងស្លឹក ។




*រូបទី3.7 : ទម្រង់ស្លឹក*

### មេរៀនសង្ខេប

- ដើមរុក្ខជាតិមាននាទីទ្រទ្រង់ស្លឹក ។ វាដឹកនាំសំភារៈពីឫសទៅស្លឹកនិងពីស្លឹកមកឫសវិញ ។
- រុក្ខជាតិចែកចេញជា រុក្ខជាតិស្មៅនិងរុក្ខជាតិឈើ
- រុក្ខជាតិស្មៅមានដើមទន់ពណ៌បៃតង
    - បាច់សរសៃនាំរបស់រុក្ខជាតិស្មៅម៉ូណូកូទីលេដូន មានស៊ីឡែមនិងផ្លូអែម
    - ចំពោះរុក្ខជាតិស្មៅឌីកូទីលេដូន បាច់សរសៃនាំមាន ស៊ីឡែម ផ្លូអែម និងស្រទាប់មេក្នុងនៅចន្លោះស៊ីឡែមនិងផ្លូអែម ។
- រុក្ខជាតិឈើភាគច្រើនសុទ្ធតែជាឌីកូទីលេដូន ។ វាមានដើមរឹងមាំ ព្រោះមានស៊ីឡែមច្រើន ។
- ជាទូទៅស្លឹករុក្ខជាតិមានរាងសំប៉ែត ។ ស្លឹកជាសរីរាង្គសំខាន់ក្នុងដំណើររស្មីសំយោគរបស់រុក្ខជាតិ ។
- ស្រទាប់ក្រៅបង្អស់របស់រុក្ខជាតិ គ្របដណ្ដប់ដោយស្រទាប់ថ្លា មានឈ្មោះថា គុយទីគុល ។
- ក្នុងអេពីឌែមរបស់ស្លឹក មានស្តូម៉ាតច្រើន ។ ស្តូម៉ាតជាកន្លែងធ្វើបណ្ដូរឧស្ម័នរវាងជាលិកានិងមជ្ឈដ្ឋានក្រៅ ព្រមទាំងរំភាយចំហាយទឹកផងដែរ ។

## សំណួរនិងលំហាត់

1. តើដើមរុក្ខជាតិមាននាទីដូចម្ដេចខ្លះ ?
2. តើរុក្ខជាតិស្មៅនិងរុក្ខជាតិឈើខុសគ្នាដូចម្ដេចខ្លះ ?
3. តើលក្ខណៈអ្វីខ្លះ ដែលសំគាល់ថាជារុក្ខជាតិស្មៅម៉ូណូកូទីលេដូន ?
4. តើរង្វង់ឆ្នាំ កើតឡើងយ៉ាងដូចម្ដេច ?
5. តើគេសំគាល់ឈើស្រាយនិងឈើខ្លឹមបានដោយសារអ្វី ?
6. តើស្តូម៉ាតមាននាទីធ្វើអ្វីខ្លះ ?

## ពិសោធន៍ : សង្កេតខ្ទាត់ទទឹងស្លឹក

### 1. វត្ថុបំណង

- សិស្សស្គាល់ច្បាស់សមាសធាតុផ្សេងៗក្នុងស្លឹករុក្ខជាតិ តាមរយៈការសង្កេតទម្រង់ក្នុងរបស់ស្លឹកដោយមីក្រូទស្សន៍ ។
- សិស្សបង្ហាញពីទម្រង់កោសិកាផ្សេងៗក្នុងស្លឹករុក្ខជាតិ ។
- សិស្សមានបំណិនប្រសប់ក្នុងការប្រើប្រាស់មីក្រូទស្សន៍ ។

### 2. សំភារៈ

- ប្រភេទស្លឹករុក្ខជាតិឌីកូទីលេដូន (យកស្លឹកទន់ល្មមអាចប្រើការបាន មិនខ្ចីពេក មិនចាស់ពេក)
- ការ៉ុត នៃថាវ ត្រឡាចខ្ចី ដំឡូងបារាំង ផ្លែល្ពៅ ផ្លែស្វាយខ្ចី (យកមួយណាក៏បាន)
- ទឹកស្អាត (ទឹកដែលបានសម្លាប់មេរោគរួចហើយ)
- ចាស
- ជ្រុញ
- ក្រដាសជក់ទឹក
- ផ្លែឡាមថ្មី
- ដង្កៀប
- កែវទឹក
- មីក្រូទស្សន៍អុបទិច
- បន្ទះឡាម
- បន្ទះឡាមែល
- ម្ជុលមានដង
- កូនកាំបិត
- ខ្មៅដៃ

- ជ័រលុប
- ក្រដាសស
- បន្ទាត់ ។

## 1. ដំណើរការពិសោធន៍

### ក. របៀបកាត់បន្លែឬផ្លែឈើធ្វើជាទម្រចម្រៀកស្លឹក

ការ៉ុត នៃថាវ ល្ពៅ ត្រឡាចខ្ចី ដំឡូងបារាំង ឬផ្លែស្វាយខ្ចីជាប្រភេទបន្លែ ឬផ្លែឈើដែលអាចយកធ្វើជាទម្រចម្រៀកស្លឹកបានល្អ ព្រោះមានជ័រតិចមិនសូវស្អិត មិនដូចរុក្ខជាតិដែលមានជ័រច្រើន ជាហេតុធ្វើឱ្យស្អិតជាប់នឹងចម្រៀកស្លឹកតែម្តង ។

- កាត់ការ៉ុត ឬនៃថាវប្រវែង $3cm^2$
- រួចចិតការ៉ុត ឬនៃថាវជារាងព្រីស (ឬប្រឡេពីប៉ែត) ដែលមានផ្ទៃបាត $0.8cm \times 0.8cm$ និងកម្ពស់ 3cm ។
- ចិតលុបមុំទាំងអស់នៃព្រីសឱ្យមូលកុំឱ្យមានជ្រុង
- ពុះច្រៀកព្រីស ឬប្រឡេពីប៉ែតនៃថាវ ឬការ៉ុតនោះជាពីរ តែកុំឱ្យដាច់ដល់បាតក្រោម (ក្នុងជម្រៅ 0.25cm ។

### ខ. របៀបធ្វើខ្នាត់ស្លឹក

មុននឹងកាត់ គប្បីជ្រើសរើសផ្ទៃស្លឹកដែលមានលក្ខណ ល្អ គ្មានស្នាមសត្វល្អិតខិច ឬចោះ ។

- យកឡាមកាត់ស្លឹកនោះជារាងចតុកោណកែង ដែលមានទទឹង 2cm និងបណ្តោយ 3cm ដើម្បីតម្រូវទៅនឹងទម្រចម្រៀកស្លឹកខាងលើ ។
- យកចម្រៀកស្លឹកនោះទៅស៊កបញ្ចូលត្រង់មុខកាំបិត ដែលបានពុះកាត់ព្រីស ឬប្រឡេពីប៉ែត ។
- យកផ្លែឡាមថ្មីចិតឱ្យត្រង់ទាំងទម្រនិងចម្រៀកស្លឹកឱ្យបានស្តើងបំផុត ។
- រៀបចំចាននិងទឹកស្អាត ។
- ដាក់ចំណិតស្លឹកនិងចំណិតព្រីសទៅក្នុងចាន ។
- បន្តក់ទឹកមួយតំណក់លើបន្ទះឡាម រួចជ្រើសរើសយកចំណិតស្លឹកណាដែលស្តើងបំផុត ដាក់ត្រង់តំណក់ទឹកលើបន្ទះឡាម រួចយកបន្ទះឡាមែលនៅគ្របពីលើ ។
- យកក្រដាសជក់ទឹកទៅថ្លិតទឹកដែលសើមខ្លាំងនៅគែមឡាមែល ។
- យកបន្ទះឡាមទៅពិនិត្យក្នុងមីក្រូទស្សន៍ ។




**2. វិភាគ**

- បន្ទាប់ពីសង្កេតរួច ណែនាំសិស្សឱ្យគូររូបដែលមើលឃើញក្នុងមីក្រូទស្សន៍ ។
- បន្ទាប់ពីគូររួច ឱ្យសិស្សបំពេញចំណងជើងនិងឈ្មោះគ្រប់សមាសធាតុផ្សេងៗរបស់ស្លឹក ។
- ផ្ទៀងផ្ទាត់ចម្លើយក្នុងរូបគំនូរដែលសិស្សបានគូរជាមួយរូបគំនូររបស់គ្រូនៅលើក្តារខៀន ។

## ? សំណួរនិងលំហាត់ជំពូក7

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ**

1. ចាំរ៉ង់ស៊ីមជា
   - ☐ក. ជាលិកាការពារ
   - ☐ខ. ជាលិកានាំ
   - ☐គ. ជាលិកាគ្រឹះ
   - ☐ឃ. ជាលិកាលូតលាស់ ។
2. ចាំរ៉ង់ស៊ីមមាននាទី
   - ☐ក. ដឹកនាំសារធាតុសរីរាង្គ
   - ☐ខ. ស្តុកស្តុរនិងអាមីដុង
   - ☐គ. ធ្វើឱ្យឈើរឹងមាំ
   - ☐ឃ. ពង្រឹងនិងទ្រទ្រង់រុក្ខជាតិ ។
3. ឫសដុះចេញដំបូង ហើយធំជាងគេហៅថា
   - ☐ក. ឫសព្រយោង
   - ☐ខ. ឫសកែវ
   - ☐គ. ឫសស្មៃ
   - ☐ឃ. ឫសរយាង ។
4. ជាលិកាដែលបង្កើនកម្រាស់ដើមរុក្ខជាតិគឺ
   - ☐ក. អេពីឌែម
   - ☐ខ. គុយទីគុល
   - ☐គ. ហ្សីលីក
   - ☐ឃ. ស្រទាប់មេក្នុង ។

5 កោសិកាពីរដែលរុំព័ទ្ធស្តូម៉ាត ហើយមាននាទីត្រួតពិនិត្យអត្រានៃបណ្តូរឧស្ម័ននិងទឹកគឺ

☐ ក. កោសិកាមេសូភីលស្តោត ☐ ខ. កោសិកាមេសូភីលប៉ាលីសាត

☐ គ. កោសិកាបាច់សរសៃនាំ ☐ ឃ. កោសិកាល្បាត ។

6. ស្រទាប់ក្រមួនធន់នឹងទឹកនៅផ្ទៃខាងលើនៃស្លឹកជា

☐ ក. ស្រទាប់គុយទីគុល ☐ ខ. អេពីឌែមស្រទាប់លើ

☐ គ. អេពីឌែមស្រទាប់ក្រោម ☐ ឃ. ស្រទាប់មេក្នុង

7 ចូរផ្គូរផ្គងផ្នែក A នឹង B ឱ្យបានត្រឹមត្រូវ

| A | B | ចម្លើយ |
|---|---|---|
| 1 ស្តូម៉ាត | ក. ស្រទាប់ក្រៅខាងក្រោមកោសិកាក្នុងស្លឹក | |
| 2 អេពីឌែមក្រោម | ខ ជាប្រព័ន្ធរុក្ខសដែលដឹកនាំទឹកនិងសារធាតុខនិជឆ្លងកាត់រុក្ខជាតិ | |
| 3 ស៊ីឡែម | គ. រន្ធដែលមាននាទីបណ្តូរឧស្ម័ននិងទឹក | |
| 4 ផ្លូអែម | ឃ. ស្រទាប់ក្រមួនធន់នឹងទឹកនៅលើផ្ទៃខាងលើនៃស្លឹក | |
| 5 កោសិកាល្បាត | ង. ជាកោសិកាខ្ចប់ជាប់ទៅនឹងស្រទាប់លើនៃក្លរ៉ូប្លាសដែលមានក្នុងកោសិកា | |
| 6 កោសិកាមេសូភីលប៉ាលីសាត | ច. កោសិកាពីរដែលហ៊ុំព័ទ្ធស្តូម៉ាត | |
| 7 កោសិកាមេសូភីលស្តោត | ឆ. ជាប្រព័ន្ធរុក្ខសដែលនាំស្កររលាយនិងសមាសធាតុសរីរាង្គ | |
| | ជ. ស្រទាប់ក្រោមនៃក្លរ៉ូប្លាសដែលមានព្រុងខ្យល់នៅជុំវិញ | |
| | ឈ បាច់សរសៃជាច្រើនសម្រាប់ដឹកនាំសារធាតុសរីរាង្គ | |

II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1 រុក្ខជាតិធ្វើរស្មីសំយោគក្រោមឥទ្ធិពលនៃ ។

2. រុក្ខជាតិទាំងអស់ត្រូវការទឹក និងសារធាតុខនិជផ្សេងៗដើម្បីផលិតអុកស៊ីសែននិងថាមពលគីមី (ATP) ។

3 រុក្ខជាតិស្រូបទឹកនិងសារធាតុខនិជតាម ។

4. ស្លឹករុក្ខជាតិចាប់យក ពីបរិយាកាសតាមរយៈស្តូម៉ាត ។

5. ស្តូម៉ាតត្រូវបានកើតឡើងដោយ មួយគូ ដែលមាននាទីត្រួតពិនិត្យអត្រាបណ្តូរឧស្ម័ននិងទឹក ។

6. ផលិតផលសំរាមនៃដំណើររស្មីសំយោគគឺ ។

7. ឯផលិតផលផ្សេងទៀតនៃដំណើររស្មីសំយោគគឺ និងថាមពល (ATP) ។

III ចូរឆ្លើយសំណួរខាងក្រោមនេះ

1. តើកោសិកាល្បាតមានមុខងារដូចម្តេច ?

2. ចូរបង្ហាញពីមុខងាររបស់ស៊ីឡែមនិងផ្លូអែម ។

3. ចូររកលក្ខណៈខុសគ្នារវាងអេពីឌែមលើនិងអេពីឌែមក្រោម ។

4. តើរុក្ខជាតិស្មៅនិងរុក្ខជាតិឈើខុសគ្នាដូចម្តេចខ្លះ ?

5 ហេតុអ្វីបានជាគេថា ជាលិកានាំជួយផ្តល់ភាពរឹងមាំដល់ដើមរុក្ខជាតិ ?

6. ហេតុអ្វីបានជាឬសកូសមានសារៈសំខាន់ចំពោះកោសិការុក្ខជាតិ ?

7 តើកត្តាអ្វីខ្លះ ដែលមានឥទ្ធិពលទៅលើដំណើររស្មីសំយោគ ?

8. តើរោមជញ្ជក់មានមុខងារអ្វី ?

9 តើកត្តាអ្វីខ្លះដែលមានឥទ្ធិពលទៅលើការលូតលាស់របស់ស្លឹករុក្ខជាតិ ?

10. តើគេសំគាល់រុក្ខជាតិស្មៅឌីកូទីលេដូនដោយសារលក្ខណៈអ្វីខ្លះ ?

11 រកលក្ខណៈខុសគ្នារវាងរុក្ខជាតិស្មៅម៉ូណូកូទីលេដូននិងរុក្ខជាតិស្មៅឌីកូទីលេដូន ។

ជំពូក 8

# ជីវវិទ្យានិងសុខភាព



មុនសតវត្សទី 20 គ្រូពេទ្យផ្នែកវះកាត់មានការប្រថុយប្រថានក្នុងការវះកាត់ប្រកបដោយគ្រោះថ្នាក់ ។ ទោះបីជាប្រជាជនត្រូវឆ្លងកាត់ការវះកាត់ក៏ដោយ ក៏ពួកគេមិនអាចគេចផុតពីគ្រោះថ្នាក់បានដែរ ព្រោះក្រោយពេលវះកាត់ របួសរបស់អ្នកជំងឺតែងតែក្លាយ ហើយអ្នកជំងឺក៏ស្លាប់ ។ គ្មានអ្នកណាម្នាក់ដឹងពីមូលហេតុដែលបណ្តាលឱ្យរបួសក្លាយនេះទេ ។

នៅឆ្នាំ 1860 គ្រូពេទ្យវះកាត់ជនជាតិអង់គ្លេសម្នាក់ឈ្មោះ **សូសេហ្វលីស្ទ័រ** (Joseple Lister) បានបង្កើតសម្មតិកម្មថា " របួសក្លាយបណ្តាលមកពីមីក្រូសារពាង្គកាយ " ។ មុននឹងធ្វើការវះកាត់ លីស្ទ័របានសាកល្បងលាងសំភារ វះកាត់និងដៃរបស់គាត់ជាមួយនឹងអាស៊ីតកាបូលិច ដែលជាសារធាតុគីមីសម្លាប់មីក្រូសារពាង្គកាយ ។ ក្រោយពេលវះកាត់ គាត់យកបង់ដែលត្រូវរុំរបួសឱ្យអ្នកជំងឺទៅជ្រលក់នឹងអាស៊ីតកាបូលិចសិន ។ គាត់សង្កេតឃើញថា មុនពេលគាត់ប្រើវិធីថ្មីនេះ 45 % នៃអ្នកជំងឺដែលបានវះកាត់ត្រូវស្លាប់ ។ ប៉ុន្តែក្រោយពេលគាត់អនុវត្តបច្ចេកទេសថ្មីនេះអត្រានៃការស្លាប់របស់អ្នកជំងឺដែលបានវះកាត់ថយចុះ គឺមានតែ 15 % ប៉ុណ្ណោះដែលស្លាប់ ។

មេរៀនទី

# 1 ការប្រយុទ្ធប្រឆាំងនឹងជំងឺ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីភ្នាក់ងារបង្កជំងឺផ្សេងៗ ។
- ❑ ពណ៌នាពីការរីករាលដាលរបស់ភ្នាក់ងារបង្កជំងឺ ។
- ❑ បកស្រាយពីការឆ្លងជំងឺពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។
- ❑ ស្វែងយល់ពីរបាំងការពារពីខាងក្រៅរបស់សារពាង្គកាយ ។
- ❑ មានអនាម័យក្នុងការរស់នៅ ដើម្បីចៀសវាងពីជំងឺឆ្លងផ្សេងៗ ។

ក៏ដូចជារបួសក្រោយពេលការវះកាត់ដែរ លោកលីស្ទ័របានសង្កេតឃើញថា ជំងឺមួយចំនួនទៀត ដូចជា អំបៅអំបែក ការពុលចំណីអាហារសុទ្ធតែបណ្តាលមកពីភាវៈរស់តូចៗដែលអាចមើលឃើញដោយមិនបាច់ប្រើមីក្រូទស្សន៍ ។ ភាវៈរស់តូចៗដែលបណ្តាលឱ្យមានជំងឺហៅថាភ្នាក់ងារបង្កជំងឺ(ភ្នាក់ងារបង្ករោគ) ។ ជំងឺដែលបណ្តាលមកពីភ្នាក់ងារជំងឺហៅថា ជំងឺឆ្លង ។

## 1. ជំងឺឆ្លង

ជំងឺឆ្លងបណ្តាលមកពីវត្តមានភ្នាក់ងារបង្ករោគក្នុងសារពាង្គកាយ ។ ជំងឺនេះឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈភ្នាក់ងារបង្ករោគ ដូចជា វីរុស បាក់តេរី ផ្សិត និងប្រូទីស ។ នៅពេលកើតជំងឺឆ្លង ភ្នាក់ងារបង្កជំងឺបានចូលទៅក្នុងខ្លួនយើង ហើយធ្វើឱ្យយើងឈឺនិងបំផ្លាញកោសិកានៅក្នុងខ្លួនយើង ។

មុនរបកគំហើញរបស់លីស្ទ័រ ប្រជាជនមានជំនឿថា ការកើតជំងឺបណ្តាលមកពីបិសាច ។ នៅចុងឆ្នាំ1800 អ្នកវិទ្យាសាស្ត្រមួយចំនួនបានចំណាយពេលយ៉ាងច្រើនក្នុងការស្វែងយល់ពីជំងឺឆ្លង ។ ក្នុងឆ្នាំ 1860 អ្នកវិទ្យាសាស្ត្រជនជាតិបារាំង លូីប៉ាស្ទ័រ(Louis Pasteur)បានបង្ហាញថា ជំងឺឆ្លងមួយចំនួន បណ្តាលមកពីមីក្រូសារពាង្គកាយ ។ ប៉ាស្ទ័រក៏បានបញ្ជាក់ផងដែរថា បើចង់សម្លាប់មីក្រូសារពាង្គកាយ លុះត្រាតែការពារការរីករាលដាលនៃជំងឺឆ្លងសិន ។ នៅឆ្នាំ1870 និងឆ្នាំ1880 អ្នកវិទ្យាសាស្ត្រផ្នែករូបវិទ្យាជនជាតិអាល្លឺម៉ង់ឈ្មោះ រ៉ូប៊ែរ កុច (Robert Koch) បានបង្ហាញថា ជំងឺឆ្លងនីមួយៗបណ្តាលមកពីភ្នាក់ងារបង្ក

ជំងឺយថាប្រភេទមួយ ។ *ឧទាហរណ៍* ភ្នាក់ងារបង្កជំងឺមួយប្រភេទបង្កជំងឺរលាកសួត មួយប្រភេទទៀតបង្កជំងឺអុតស្វាយ ហើយមួយប្រភេទផ្សេងទៀតបង្កជំងឺកញ្ជ្រឹល ។

## 1.1. ភ្នាក់ងារបង្កជំងឺ

យើងឃើញហើយថា នៅលើផែនដីនេះ មានភាវៈរស់ច្រើនប្រភេទរាប់មិនអស់ ។ ភាគច្រើននៃភាវៈរស់ទាំងនោះមិនផ្តល់ទុក្ខទោសដល់យើងទេ ។ ប៉ុន្តែក៏នៅមានមួយចំនួនទៀតដែលបណ្តាលឱ្យយើងមានជំងឺដែរ ។ ភ្នាក់ងារបង្កជំងឺភាគច្រើនអាចមើលឃើញបានដោយមីក្រូទស្សន៍ ។ ភ្នាក់ងារបង្កជំងឺមាន4ក្រុមចម្បងគឺ បាក់តេរី វីរុស ផ្សិត និងប្រូទីស ។

### ក. បាក់តេរី


រូបទី ៤.1 : បាក់តេរីបង្កជំងឺតេតាណូស

បាក់តេរី ជាមីក្រូសារពាង្គកាយឯកកោសិកា ។ វាអាចចិញ្ចឹមជីវិត ផ្លាស់ទី និងបន្តពូជបាន ។ វាបង្កជំងឺច្រើនរាប់មិនអស់ ។ *ឧទាហរណ៍* អំពៅអំបែក ការពុលអាហារ របេង គ្រុនពោះវៀន ។ បាក់តេរីបង្កជំងឺដល់ភាវរស់ដទៃទៀតតាមរបៀបពីរបែប គឺដោយផ្ទាល់និងដោយប្រយោល ។

- បាក់តេរីបំផ្លាញកោសិកានៃសារពាង្គកាយដោយផ្ទាល់ ។ *ឧទាហរណ៍* ការរលាកបំពង់កបណ្តាលមកពីបាក់តេរីឈ្មោះ ស្ត្រិបតូកូកដែលទន្ទ្រានកនៅក្នុងបំពង់ក ។ ជំងឺរបេង ជាជំងឺបណ្តាលមកពីបាក់តេរីដែលបំផ្លាញជាលិកាសួត ។
- បាក់តេរីមួយចំនួនបំផ្លាញកោសិកានៃសារពាង្គកាយដោយប្រយោល តាមការបញ្ចេញធាតុពុលហៅថា តុកស៊ីន ។ *ឧទាហរណ៍* បាក់តេរីនៃជំងឺតេតាណូស ជ្រៀតចូលតាមមុខរបួសហើយផលិតធាតុពុលដែលធ្វើឱ្យខូចប្រព័ន្ធប្រសាទ ។ គេហៅជំងឺតេតាណូសថាជាជំងឺរឹងថ្គាម ព្រោះសរសៃប្រសាទដែលខូចបណ្តាលឱ្យសាច់ដុំថ្គាមមិនអាចកម្រើកបាន ។

### ខ. វីរុស


រូបទី 1.2 : វីរុសបង្ករលាកបំពង់ក

វីរុស ជាមេរោគដែលមានមាឌល្អិតតូចជាងបាក់តេរី ។ វីរុសមិនអាចមើលឃើញដោយភ្នែកទទេ ឬដោយមីក្រូទស្សន៍ធម្មតាបានឡើយ ។ វីរុសអាចបង្កើតកូនចៅបាន លុះត្រាតែវារស់នៅក្នុងកោសិកានៃភាវៈរស់ដទៃទៀត ។ បើមានវីរុសនៅ

ក្នុងកោសិកានៃភាវៈរស់ណាមួយ វានឹងបង្កើតវីរុសថ្មីៗហើយចម្លងពីកោសិកាមួយទៅកោសិកាមួយទៀត ។ ជំងឺគ្រុនក្តៅនិងផ្តាសាយ បណ្តាលមកពីវីរុសនៅក្នុងកោសិកានៃប្រដាប់ដង្ហើម ។ មានវីរុសប្រមាណជាង 200 ប្រភេទដែលបណ្តាលឱ្យមានជំងឺគ្រុនផ្តាសាយ ។ ជំងឺផ្សេងៗដែលបណ្តាលមកពីវីរុសមាន ជំងឺអុតស្វាយ កញ្ជ្រិល រលាកថ្លើម ។


*រូបទី 1.3 : វីរុស*

### គ. ផ្សិត

ផ្សិតរួមមាន ផ្សិតផ្សូរនិងដំបែដែលបង្កឱ្យមានជំងឺឆ្លងមួយចំនួន ។ ផ្សិតលូតលាស់ក្នុងកន្លែងក្តៅឧណ្ហៗ មានម្លប់និងសើម ។ ជំងឺដែលបណ្តាលមកពីផ្សិតមានទឹកស៊ីជើង ស្រែង ជ្រាំងមាត់ ។

### ឃ. ប្រូទីស

ប្រូទីសក៏បណ្តាលឱ្យមានជំងឺដែរ ។ ជំងឺគ្រុនចាញ់ជាជំងឺមួយក្នុងតំបន់ត្រូពិច ដែលបណ្តាលមកពីប្រូទីសដែរ ។ នៅមានជំងឺផ្សេងៗទៀតដែលបណ្តាលមកពីប្រូទីស ដូចជា ជំងឺងុយដេក ជំងឺរាកមូល ។

## 1.2. ការរីករាលដាលរបស់ភ្នាក់ងារបង្កជំងឺ

ក៏ដូចជាភាវៈរស់ដទៃទៀតដែរ ភ្នាក់ងារបង្កជំងឺត្រូវការអាហារនិងទឹកន្លែងរស់នៅដើម្បីបន្តពូជ ។ ជាសំណាងអាក្រក់ សារពាង្គកាយមនុស្សយើងជាកន្លែងសមស្របបំផុតដែលភ្នាក់ងារបង្កជំងឺត្រូវការ ។ អ្នកនឹងត្រូវឆ្លងជំងឺតាមវិធីច្រើនយ៉ាង ។ ភ្នាក់ងារបង្កជំងឺ អាចឆ្លងតាមរយៈការប៉ះអ្នកជំងឺផ្ទាល់ តាមអាហារ ទឹក វត្ថុមិនស្អាត ឬឆ្លងតាមសត្វមួយចំនួនដែរ ។

### ក. ការឆ្លងជំងឺពីមនុស្ស

ភ្នាក់ងារបង្កជំងឺតែងតែឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត តាមរយៈការប៉ះផ្ទាល់ ដូចជាថើបនិងចាប់ដៃ ។ ជំងឺក៏អាចឆ្លងទៅមនុស្សម្នាក់ទៀតដោយប្រយោលផងដែរ ។ ***ឧទាហរណ៍*** ការប៉ះពាល់វត្ថុដែលអ្នកជំងឺប្រើប្រាស់ ដូចជាសំលៀកបំពាក់ កន្សែងជូតខ្លួន កែវទឹក (ជំងឺអុតស្វាយ កញ្ជ្រិល) ។ ការដកដង្ហើម អាចនាំយកមេរោគពីអ្នកជំងឺនៅពេលក្អក កណ្តាស់ឬថើប ។ ***ឧទាហរណ៍*** ជំងឺរបេង ផ្តាសាយ ហើមស្ងួត ។ ដូចនេះ ដើម្បីកុំឱ្យឆ្លងទៅអ្នកដទៃ អ្នកជំងឺគួរតែយកកន្សែងដៃខ្ទប់មាត់ ឬច្រមុះនៅពេលក្អកឬកណ្តាស់ ។

### ខ. ការឆ្លងតាមចំណីអាហារនិងទឹក

ការទទួលទានចំណីអាហារនិងផឹកទឹកមិនស្អាត ក៏បណ្ដាលឱ្យមានជំងឺផងដែរ ។ ភ្នាក់ងារបង្កជំងឺមួយចំនួនមាននៅក្នុងបរិស្ថាន ។ បាក់តេរីដែលបង្កឱ្យមានជំងឺពុលអាហារបង្កើតជាតុពុលនៅក្នុងអាហារ ។ នៅក្នុងអាហារកំប៉ុង បាក់តេរីក៏អាចបង្កើតជាតិពុលបានដែរ ។ ភ្នាក់ងារបង្កជំងឺមួយចំនួនក៏ឆ្លងតាមទឹកនិងអាហារ ។ ***ឧទាហរណ៍*** អាសន្នរោគ រាកមួល ។

### គ. ការឆ្លងតាមវត្ថុមិនស្អាត

ភ្នាក់ងារបង្កជំងឺមួយចំនួនអាចរស់នៅក្រៅខ្លួនមនុស្សបានមួយរយៈ ។ មនុស្សយើងអាចប៉ះផ្ទាល់និងភ្នាក់ងារបង្កជំងឺតាមរយៈការប្រើប្រាស់កូនកន្សែង ឬសមស្លាបព្រាដែលអ្នកជំងឺធ្លាប់ប្រើប្រាស់ ។ ជំងឺផ្ដាសាយក៏ឆ្លងតាមវិធីនេះដែរ ។ បាក់តេរីនៃជំងឺតេតាណូសក៏អាចឆ្លងទៅមនុស្សម្នាក់ទៀត ប្រសិនបើគេប្រើប្រាស់វត្ថុកខ្វក់លាយឡំគ្នា ។

### ឃ. ការឆ្លងពីសត្វ

ប្រសិនបើមនុស្សម្នាក់ត្រូវសត្វខាំ សត្វនោះនឹងចម្លងភ្នាក់ងារបង្កជំងឺដល់មនុស្សនោះ ។ ភ្នាក់ងារបង្កជំងឺទៅបំផ្លាញប្រព័ន្ធប្រសាទ ធ្វើឱ្យមនុស្សទៅជាឆ្កួត ។ ***ឧទាហរណ៍*** ឆ្កែខាំ ។ យើងក៏អាចគ្រុនក្ដៅបានដែរ នៅពេលចៃពស់ខាំ ។

## 2. ការការពារសារពាង្គកាយ

សង្គ្រាមនៅក្នុងរឿងភាពយន្ត គឺជាការប្រយុទ្ធដ៏ស្រមើស្រមៃមួយ ។ ប៉ុន្តែក្នុងសារពាង្គកាយមនុស្សតែងតែមានការប្រយុទ្ធពិតប្រាកដនិងជាប្រចាំ ហើយសត្រូវដែលលុកលុយក្នុងសារពាង្គកាយយើង គឺភ្នាក់ងារបង្កជំងឺ ។

### 2.1. របាំងការពារភ្នាក់ងារបង្កជំងឺពីខាងក្រៅ

សារពាង្គកាយមនុស្ស មានប្រព័ន្ធការពារប្រឆាំងនឹងភ្នាក់ងារបង្កជំងឺ គឺរបាំងការពារពីខាងក្រៅ តំណាបស៊ាំមេរោគនិងតំណាបរលាក ។

ក្នុងមេរៀននេះ យើងលើកយកតែរបាំងការពារពីខាងក្រៅមកសិក្សា ។ របាំងទាំងនោះមាន ស្បែក ដំណក់ដង្ហើម មាត់ និងក្រពះ ។

ក. ស្បែក

ស្បែកមានស្រទាប់ក្រៅជាកោសិកាងាប់ ដែលបង្កើតបានជារបាំងការពារមួយប្រឆាំងនិងមេរោគ ។ ស្រទាប់ការពារនៃស្បែកបង្កើតជាតិពណ៌នៃស្បែកដែលជារបាំងការពារពន្លឺព្រះអាទិត្យ ។ ក្រពេញសេបូមដែលមាននៅក្រោមស្បែក បញ្ចេញសារធាតុរាវ ដូចប្រេង ដើម្បីរក្សាឱ្យស្បែកទន់និងអាចសម្លាប់មេរោគបាន ។ សារធាតុរាវនេះមានឈ្មោះថា សេបូម ។ សេបូមការពារការជ្រៀតចូលនៃមេរោគនិងធ្វើឱ្យស្បែកមិនជ្រាបទឹក ។

ខ. ដំណកដង្ហើម

ភ្នាក់ងារបង្កជំងឺក៏អាចចូលក្នុងសារពាង្គកាយយើងបានដែរ នៅពេលយើងស្រូបខ្យល់ចូល ។ រន្ធច្រមុះ បំពង់ខ្យល់ និងទងសួតសុទ្ធតែមានរោមញ័រនិងជាតិរំអិលហៅថា ស្លេស្ម ។ ស្លេស្មនិងរោមញ័រជាអន្ទាក់សម្រាប់ចាប់មេរោគនិងកម្ទេចធូលីនៅក្នុងខ្យល់ដង្ហើមរបស់យើង ។ ការជ្រៀតចូលនៃមេរោគទៅក្នុងរន្ធច្រមុះ ធ្វើឱ្យយើងក្អកឬកណ្តាស់ ។ ការក្អកនិងកណ្តាស់ជួយសំអាតច្រមុះនិងផ្លូវដង្ហើម ដោយបញ្ចេញមេរោគពីសារពាង្គកាយយើង ។

គ. មាត់និងក្រពះ

មេរោគមួយចំនួនត្រូវបានរកឃើញនៅក្នុងអាហារ ។ នៅក្នុងទឹកមាត់មានអង់ស៊ីម ឯក្រពះផលិតអាស៊ីត ។ មេរោគមួយចំនួនដែលយើងលេបចូលជាមួយអាហារ ត្រូវបានបំផ្លាញដោយអង់ស៊ីមក្នុងទឹកមាត់និងអាស៊ីតក្នុងក្រពះ ។

## 2.2. វិធីការពារកុំឱ្យឆ្លងជំងឺ

ដើម្បីចៀសវាងពីជំងឺឆ្លងផ្សេងៗ អ្នកគប្បី

- លាងសំអាតដៃជានិច្ចមុនពេលបរិភោគអាហារ មុនពេលធ្វើម្ហូបនិងជាពិសេសក្រោយពេលចេញពីបង្គន់ ។
- ផឹកទឹកស្អិន (ទឹកដាំពុះ)
- ចៀសវាងកុំងូតទឹកទន្លេ សមុទ្រដែលនៅក្បែរលូបង្ហូរទឹកស្អុយ
- លាងសំអាតមុខឱ្យបានស្អាត ជាពិសេសនៅពេលយប់ ដោយប្រើសាប៊ូដែលមានគុណភាពស្របទៅតាមស្បែករបស់យើង
- ចៀសវាងកុំប្រើក្រាស់សិតសក់ឬកន្សែងជូតខ្លួនរួមគ្នា

- កក់សក់ឱ្យបានញឹកញាប់ជាមួយសាប៊ូកក់សក់ ដែលមានសារធាតុបំបាត់អង្គែនិងសម្លាប់ចៃ ជាពិសេសនៅរដូវក្តៅ
- ងូតទឹកឱ្យបានច្រើនដង ជាពិសេសនៅរដូវក្តៅ ។ ការងូតទឹកច្រើនដងអាចជួយឱ្យយើងចៀសផុតពីជំងឺស្បែក
- ត្រូវផ្លាស់ប្តូរសម្លៀកបំពាក់ឱ្យបានញឹកញាប់
- ចំពោះចំណីអាហារនិងភេសជ្ជ ត្រូវចម្អិនឱ្យបានឆ្អិនល្អ ហើយមិនត្រូវទុកឱ្យផ្អូម ។ បើចង់រក្សាទុកឱ្យបានយូរ ត្រូវទុកវាក្នុងទូទឹកកក ។
- ត្រូវលាងសំអាតជើងនិងជូតឱ្យស្អាត ជាពិសេសនៅចន្លោះម្រាមជើងនីមួយៗ ។ ត្រូវប្តូរស្រោមជើងឱ្យបានរាល់ថ្ងៃ ហើយចៀសវាងការប្រើស្បែកជើងចង្អៀត ។

# 3. ការបង្ការជំងឺឆ្លង

ប្រសិនបើយើងសង្កេតមើលអ្នកណាម្នាក់ដែលកំពុងកើតអុតស្វាយ យើងឃើញគេមានស្នាមនិងរមាស់ ។ ប៉ុន្តែគេនឹងជាសះស្បើយ ហើយបាត់ស្នាមទៀតផង ។ បើអ្នកណាម្នាក់បានកើតជំងឺអ្វីមួយ រាងកាយរបស់គេនឹងទទួលភាពស៊ាំទៅនឹងជំងឺនោះ ។

***ភាពស៊ាំ***: ជាសមត្ថភាពរបស់សារពាង្គកាយក្នុងការបំផ្លាញភ្នាក់ងារបង្កជំងឺ ។ ភាពស៊ាំមានពីរបែប ភាពស៊ាំសកម្មនិងភាពស៊ាំអកម្ម ។

## 3.1. ភាពស៊ាំសកម្ម

នៅពេលមេរោគជាច្រើនជ្រៀតចូលទៅក្នុងឈាម សារពាង្គកាយយើងផលិតអង់ទីករ ដើម្បីប្រយុទ្ធជាមួយមេរោគទាំងនោះ ។ អង់ទីករទាំងនោះស្ថិតនៅនឹងធ្វើសកម្មភាពក្នុងឈាម ។ វាក្លាយជាសកម្មនៅពេលវាបានជួបប្រយុទ្ធជាមួយមេរោគ ។ បន្ទាប់មកទើបសារពាង្គកាយយើងទទួលបានភាពស៊ាំចំពោះជំងឺណាមួយដែលបង្កឡើងដោយមេរោគនោះ ។

***ឧទាហរណ៍*** : បើអ្នកណាម្នាក់កើតជំងឺអុតស្វាយ សារពាង្គកាយគេត្រូវបានរាតត្បាតដោយវីរុសនៃជំងឺអុតស្វាយ ។ ប្រព័ន្ធស៊ាំឆ្លើយតបទៅនឹងអង់ទីសែនវីរុសដោយការផលិតអង់ទីករ ដែលប្រយុទ្ធប្រឆាំងនឹងមេរោគនេះ ។ មនុស្សម្នាក់មានភាពស៊ាំសកម្ម នៅពេលដែលប្រព័ន្ធស៊ាំរបស់គេបានផលិតអង់ទីករពេលមានភ្នាក់ងារបង្កជំងឺ ។ ប្រសិនបើសារពាង្គកាយជួបនឹងវីរុសជំងឺអុតស្វាយម្តងទៀត អង់ទីករ ដែលមានរួចជាស្រេចក្នុងឈាមនឹងបំផ្លាញវា ។ ដូចនេះភាពស៊ាំសកម្មអាចជាលទ្ធផលលេចចេញក្រោយពេលយើងកើតជំងឺម្តងរួចហើយឬចាក់វ៉ាក់សាំងរួច ។ ភាពស៊ាំសកម្មមានពីរបែបគឺ តំណបស៊ាំនិងវ៉ាក់សាំង ។

## ក. តំណាបស៊ាំ

នៅពេលអ្នកណាម្នាក់មានជំងឺ ប្រព័ន្ធស៊ាំបង្កើតភាពស៊ាំដែលជាផ្នែកមួយនៃតំណាបស៊ាំ ។ គួរចងចាំដែរថា ក្នុងពេលមានតំណាបស៊ាំ (មានជំងឺ) ឡាំផូស៊ីត T និង B ជួយបំផ្លាញភ្នាក់ងារបង្កជំងឺ ។ ក្រោយពេលអ្នកជំងឺបានជាសះស្បើយ ឡាំផូស៊ីត T និង B មួយចំនួននៅស្គាល់អង់ទីសែនរបស់មេរោគ ។ ប្រសិនបើមេរោគដដែលនោះចូលមកក្នុងសារពាង្គកាយយើងម្តងទៀត កោសិកា(ឡាំផូស៊ីត)ស្គាល់មេរោគនោះភ្លាម ។ ការចងចាំរបស់កោសិកា ចាប់ផ្តើមមានភាពស៊ាំយ៉ាងឆាប់រហ័សជាមួយនឹងមេរោគ ។ ដូចនេះមនុស្សនោះមិនឈឺទេ ។ ភាពស៊ាំសកម្មតែងមានរយៈពេលយូរឆ្នាំ ហើយជួនកាលមានរយៈពេលពេញមួយជីវិត ។

## ខ. វ៉ាក់សាំង

ភាពស៊ាំសកម្មទីពីរ គឺវ៉ាក់សាំង ។ វ៉ាក់សាំងអាចប្រព្រឹត្តទៅតាមរយៈការចាក់ថ្នាំ ការបញ្ចូលថ្នាំតាមមាត់ឬតាមច្រមុះ ។ វ៉ាក់សាំងអាចការពារជំងឺគ្រុនស្វិតដៃជើង អុតឬកញ្ច្រិល និងជំងឺផ្សេងៗទៀត ។ សារធាតុដែលប្រើសម្រាប់ធ្វើវ៉ាក់សាំង ហៅថា ថ្នាំបង្ការរោគ ។ ថ្នាំបង្ការរោគភ្ញោចប្រព័ន្ធស៊ាំឱ្យសកម្មក្នុងការសម្លាប់ ឬធ្វើឱ្យមេរោគចុះខ្សោយ ។ កាលណាយើងបានទទួលវ៉ាក់សាំងយើងមិនមានជំងឺទេ ។

***តើយើងឈឺនៅពេលណា ?***



①ការចាក់វ៉ាក់សាំងដែលធ្វើឱ្យខ្សោយ ឬសម្លាប់មេរោគ

②ប្រព័ន្ធស៊ាំផលិតអង់ទីករប្រយុទ្ធប្រឆាំងនឹងជំងឺ ។ វាផលិតកោសិកាល់នឹក

③ប្រសិនបើមានមេរោគចូលមកក្នុងខ្លួនម្តងទៀត កោសិកាល់នឹកបង្កើតអង់ទីករសម្លាប់មេរោគ

អ្នកមានភាពស៊ាំទៅនឹងជំងឺផ្សេងៗ ព្រោះអ្នកធ្លាប់ឈឺ ឬបានទទួលវ៉ាក់សាំងប្រឆាំងនឹងមេរោគរួចហើយ ។ ប៉ុន្តែគ្មានអ្នកណាម្នាក់ដែលស៊ាំទៅនឹងគ្រប់មេរោគនោះទេ ។ ពីមួយថ្ងៃទៅមួយថ្ងៃ អ្នកនឹងធ្លាក់ខ្លួនឈឺនៅថ្ងៃណាមួយ ។ ថ្នាំអាចព្យាបាលឱ្យជាសះស្បើយបាន ។ ប្រសិនបើអ្នកមានជំងឺដែលបណ្តាល

មកពីបាក់តេរី អ្នកប្រហែលជាត្រូវប្រើថ្នាំអង់ទីប្យូទិច ។ អង់ទីប្យូទិចគឺ ជាសារធាតុគីមីដែលសម្លាប់បាក់តេរីឬពន្យឺតការលូតលាស់របស់បាក់តេរីដែលឈ្លានពានដល់កោសិកានៃសារពាង្គកាយ ។ ផ្ទុយទៅវិញ គ្មានថ្នាំណាដែលមានប្រសិទ្ធភាពសម្រាប់ប្រឆាំងនឹងវីរុសបង្កជំងឺបានទេ ដូចជាគ្រុនផ្ដាសាយជាដើម ។ វិធីដ៏ប្រសើរបំផុតក្នុងការទប់ទល់ជាមួយវីរុសបង្កជំងឺនេះ គឺការសម្រាកឱ្យបានច្រើន ។ ទោះបីជាថ្នាំមួយចំនួន មិនសម្លាប់មេរោគក៏ដោយ ប៉ុន្តែវាក៏អាចជួយឱ្យយើងមានអារម្មណ៍ថាបានប្រសើរឡើងវិញដែរ ។ ឱសថមួយចំនួនក៏អាចកាត់បន្ថយអាការ គ្រុនក្ដៅ ធ្វើឱ្យច្រមុះស្រឡះ ជកដង្ហើមបានស្រួល និងបំបាត់ក្អកផងដែរ ។

## 3.2. ភាពស៊ាំអកម្ម

ជំងឺមួយចំនួនជាជំងឺដែលមិនអាចចាក់ថ្នាំបង្ការបានទេ (*ឧទាហរណ៍ :* ជំងឺឆ្កែឆ្កួតខាំ) ។ ប្រសិនបើមនុស្សណាម្នាក់ត្រូវឆ្កែខាំអ្នកនោះនឹងត្រូវទទួលការចាក់ថ្នាំអង់ទីប្យូទិចប្រឆាំងទៅនឹងអង់ទីសែននៃរោគឆ្កួត ។ ការការពារដោយវិធីនេះ ជា**ភាពស៊ាំអកម្ម** ។ ទារកម្នាក់អាចទទួលនូវភាពស៊ាំអកម្មមុនកំណើត ។ ភាពស៊ាំនេះ បានមកពីអង់ទីករក្នុងឈាមរបស់ម្ដាយបញ្ជូនទៅក្នុងឈាមកូននៅក្នុងផ្ទៃ ។ ក្រោយកំណើត អង់ទីករការពារទារកបានក្នុងរយៈពេលតែពីរបីខែប៉ុណ្ណោះ ។ បន្ទាប់មកភាពស៊ាំរបស់ទារកចាប់ផ្ដើមធ្វើការយ៉ាងមានប្រសិទ្ធភាព ។

## 3.3. វីរុសអេដស៍និងប្រព័ន្ធស៊ាំ

HIV ឬមេរោគអេដស៍ខុសប្លែកពីវីរុសផ្សេងទៀត ដោយវាបំផ្លាញឡាំផូស៊ីត T និងធ្វើឱ្យប្រព័ន្ធស៊ាំចុះខ្សោយ ។ ពេលចូលទៅក្នុងខ្លួនយើងជាលើកដំបូង វាចូលទៅក្នុងឡាំផូស៊ីត T ហើយបន្តពូជនៅក្នុងនោះ ។ ដូចនេះហើយទើបសារពាង្គកាយយើងមិនអាចស៊ូទ្រាំជាមួយមេរោគបាន ព្រោះប្រព័ន្ធស៊ាំទាំងមូលត្រូវបំផ្លាញ ។ ដោយហេតុថា ប្រព័ន្ធស៊ាំបាត់បង់សមត្ថភាពទប់ទល់ជាមួយមេរោគ នោះទើបមេរោគផ្សេងៗទៀត អាចចូលមកឈ្លានពានសារពាង្គកាយរបស់យើងបាន ។ ហេតុនេះទើបអ្នកដែលមានជំងឺអេដស៍ អាចស្លាប់ដោយជំងឺផ្សេងៗបាន(ជំងឺឱកាសនិយម)ដូចជា ជំងឺ របេង ហើមសួត មហារីករលាកថ្លើម ។

ក៏ដូចជាវីរុសដទៃទៀតដែរ វីរុសHIV អាចបន្តពូជបានតែក្នុងកោសិកានៃសារពាង្គកាយ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏វាអាចរស់បានមួយរយៈពេលខ្លីនៅក្រៅសារពាង្គកាយមនុស្ស ដូចជាក្នុងឈាម ក្នុងទឹកកាម ឬទឹករំអិលនៃប្រដាប់បន្តពូជ ។

វីរុស HIV អាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាម

- ការចាក់ថ្នាំដោយប្រើម្ជុលរួមគ្នា
- ការបញ្ចូលឈាម
- ការរួមភេទ
- ពីម្ដាយទៅកូននៅក្នុងផ្ទៃ ឬទៅទារកដោយការបំបៅដោះ ។

យើងដឹងហើយថា វីរុស HIV មិនអាចរស់នៅលើស្បែកបានទេ ។ ដូច្នេះវាមិនឆ្លងទៅមនុស្សម្នាក់ទៀតតាមរយៈការឱបរឹត ឬចាប់ដៃអ្នកជំងឺនោះទេ ។ វាក៏មិនឆ្លងទៅមនុស្សម្នាក់ទៀតដែរក្នុងករណីប្រើប្រាស់បន្ទប់ទឹក ឬបង្គន់រួមគ្នា ឬការប៉ះទង្គិចគ្នានៅពេលលេងកីឡាផ្សេងៗ ។

## 4. ជំងឺមិនឆ្លង

ទោះបីជាជំងឺឆ្លងកាន់តែថយចុះ ប៉ុន្តែជំងឺមិនឆ្លងកាន់តែកើនឡើង ។ ជំងឺមិនឆ្លង ជាជំងឺមួយដែលមិនបណ្ដាលមកពីភ្នាក់ងារបង្កជំងឺក្នុងសារពាង្គកាយទេ ។ មិនដូចជម្ងឺឆ្លងទេ ជំងឺមិនឆ្លងមិនចម្លងពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀតឡើយ ។ ជំងឺលើសឈាមជាជំងឺនាំមុខគេនៅសហរដ្ឋអាមេរិក ដែលបណ្ដាលឱ្យស្លាប់ ។ ក្រៅពីនោះ នៅមានជំងឺប្រតិកម្មទៅនឹងអ្វីមួយ ជំងឺទឹកនោមផ្អែមនិងជំងឺមហារីកសុទ្ធតែជាជំងឺមិនឆ្លង ។

- រដូវរងាបានចូលមកដល់ រុក្ខជាតិចេញផ្កា ។ មនុស្សមួយចំនួនក្អកនិងកណ្ដាស់ក្នុងរដូវនេះ ប៉ុន្តែមិនមែនឈឺគ្រុនទេ ។ វាជាការឈឺចាប់ដែលបណ្ដាលមកពីប្រតិកម្មជាមួយលំអងផ្កា ។ ប្រតិកម្មគឺជាភាពរួសហួសហេតុនៃប្រព័ន្ធស៊ាំទៅនឹងសារធាតុពីខាងក្រៅ ឬទៅនឹងអ្វីខុសពីធម្មតាដែលរកឃើញនៅក្នុងសារពាង្គកាយយើង ។ សារធាតុដែលបណ្ដាលឱ្យមានប្រតិកម្មផ្សេងៗហៅថា អាល់លែសែន (Allergen) រួមមាន ៈ ធូលី ផ្សិត លំអងផ្កា អាហារ ឱសថ និងគ្រឿងសំអាងមួយចំនួន ។ ភ្នាក់ងារទាំងនេះចូលទៅក្នុងសារពាង្គកាយយើងតាមខ្យល់ដង្ហើម តាមអាហារ ឬការប៉ះពាល់ផ្ទាល់ ។ កាលណាឡាំផូស៊ីតជួបនិងភ្នាក់ងារទាំងនេះ វាផលិតអង់ទីករ ។ អង់ទីករបញ្ចេញសារធាតុម្យ៉ាងឈ្មោះថា អ៊ីស្តាមីន (Histamine) ។ អ៊ីស្តាមីនជាសារធាតុគីមី ដែលមានតំណបទៅនិងប្រតិកម្មផ្សេងៗដោយធ្វើឱ្យកណ្ដាស់ ឬចេញទឹកភ្នែក ។
- ***ជំងឺទឹកនោមផ្អែម*** : លំពែងជាសរីរាង្គមួយដែលមានមុខងារច្រើនយ៉ាង ។ មុខងារដែលសំខាន់ជាងគេ គឺផលិតអាំងស៊ុយលីន ។ ក្នុងករណីមានជំងឺទឹកនោមផ្អែម លំពែងគ្មានសមត្ថភាពក្នុងការផលិតអាំងស៊ុយលីនឱ្យបានគ្រប់គ្រាន់ ឬកោសិកានៃសារពាង្គកាយប្រើប្រាស់អាំងស៊ុយលីនមិន

បានត្រឹមត្រូវ ។ ករណីនេះ ក្នុងឈាមឬក្នុងទឹកនោមអ្នកកើតជំងឺទឹកនោមផ្អែមមានបរិមាណ គ្លុយកូសច្រើន ។ ឯក្នុងកោសិកានៃសារពាង្គកាយគ្មានគ្លុយកូសគ្រប់គ្រាន់ទេ ។

ប្រសិនបើមិនមានការព្យាបាលទេ អ្នកមានជំងឺទឹកនោមផ្អែមនឹងស្រកទម្ងន់ មានអារម្មណ៍ថា ខ្សោយ ហើយឃ្លានគ្រប់ពេល ។ ក្នុងករណីនេះ កោសិកានៃសារពាង្គកាយមិនអាចប្រើប្រាស់គ្លុយកូស តាមតម្រូវការ ។ មិនតែប៉ុណ្ណោះ អ្នកជំងឺនោមញឹកញាប់ ហើយឧស្សាហ៍ស្រេកទឹក ។ ឥទ្ធិពលដ៏យូរ អង្វែងរបស់ជំងឺទឹកនោមផ្អែម គឺអាចឱ្យមនុស្សខ្វាក់ តម្រងនោមចុះខ្សោយនិងមានជំងឺបេះដូងទៀត ផង ។

រោគសញ្ញានេះត្រូវត្រួតពិនិត្យតាមរយៈការតមអាហារ ការត្រួតពិនិត្យទម្ងន់ និងធ្វើលំហាត់ ប្រាណជាប្រចាំ ។

- ***ជំងឺមហារីក*** : ក្នុងលក្ខខណ្ឌធម្មតា កោសិកាថ្មីត្រូវបានកើតឡើងជំនួសកោសិកាចាស់ៗដែល ងាប់ ។ ក្នុងករណីជំងឺមហារីក មានលក្ខណៈខុសគ្នាទាំងស្រុង ។ ជំងឺមហារីកជាជំងឺដែលកោសិកា មានលក្ខណៈមិនធម្មតា រីកដុះដាលដោយគ្មានការត្រួតពិនិត្យត្រឹមត្រូវ ហើយបំផ្លាញជាលិកាល្អ ទៀតផង ។

កោសិកាចែកខ្លួនជាបន្តបន្ទាប់ ។ វាតែងតែបង្កើតដុំមួយមិនប្រក្រតីហៅថា ដុំពក ។ គ្រប់ដុំពក ទាំងអស់មិនមែនសុទ្ធតែកើតជំងឺមហារីកទេ ។ ដុំពកមានជំងឺមហារីករុករាននិងបំផ្លាញជាលិកាល្អៗ ដែលនៅជុំវិញវា ។ កោសិកាមហារីកបំបែកដុំពក ហើយចូលទៅក្នុងឈាមនិងសរសៃទឹករងៃ ។ ឈាម និងទឹករងៃនាំកោសិកាមហារីកទៅផ្នែកផ្សេងៗទៀតនៃសារពាង្គកាយ ដែលជាកន្លែងចែកចាយនិង បង្កើតដុំពកថ្មី ។ បន្ទាប់មកវារីករាលដាលពាសពេញសារពាង្គកាយ ។

- ***មូលហេតុដែលបណ្តាលឱ្យមានជំងឺមហារីក*** : មានកត្តាជាច្រើនផ្សេងៗគ្នា ។ កត្តាមួយក្នុង ចំណោមកត្តាទាំងនោះ គឺការចម្លងមកពីឪពុកម្តាយ ។ សារធាតុនិងកត្តាមួយចំនួនទៀតក្នុង បរិស្ថានក៏អាចបង្កើតជំងឺមហារីកបានដែរ ។ ***ឧទាហរណ៍*** ជាតិជ័រក្នុងថ្នាំជក់ កាំរស្មីស្វាយអ៊ុល ត្រា ។
- ***ការព្យាបាល*** : ការវះកាត់ ឱសថ និងកាំរស្មីសុទ្ធតែអាចប្រើប្រាស់ក្នុងការព្យាបាលជំងឺមហារីក ។ យើងអាចកំចាត់វាមុនពេលវារីករាលដាលដោយធ្វើការវះកាត់ ។ ក្រោយពេលវះកាត់ កាំរស្មី និងឱសថអាចនឹងបំផ្លាញកោសិកាមហារីកបាន ។

- ***ការបង្ការជំងឺមហារីក*** ៖ វិធីតែមួយគត់ក្នុងការប្រឆាំងនិងជំងឺមហារីក គឺការបង្ការ ។ គេអាចកាត់បន្ថយជំងឺមហារីកបានដោយការតមបារីនិងការតមអាហារតាមវិធីបញ្ចុះទម្ងន់ ។ ការបរិភោគបន្លែនិងផ្លែឈើច្រើនអាចជួយការពារកុំឱ្យមានជំងឺមហារីកប្រដាប់រំលាយអាហារបាន ។

## មេរៀនសង្ខេប

ជំងឺមានពីរប្រភេទ ៖ ជំងឺឆ្លងនិងជំងឺមិនឆ្លង

- ជំងឺឆ្លងជាជំងឺដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈភ្នាក់ងារបង្កជំងឺ ។
- ភ្នាក់ងារបង្កជំងឺមាន ៖ បាក់តេរី វីរុស ផ្សិត និងប្រូទីស ។
- ជំងឺអាចឆ្លងតាមរបៀបច្រើនយ៉ាង ៖ ឆ្លងពីមនុស្ស សត្វ តាមចំណីអាហារ ទឹក និងតាមវត្ថុមិនស្អាត ។
- សារពាង្គកាយមនុស្សមានរបាំងការពារភ្នាក់ងារបង្កជំងឺចំនួនបីគឺ ៖ របាំងការពារពីខាងក្រៅ តំណបស៊ាំនិងប្រតិកម្មរលាក ។
- របាំងការពារពីខាងក្រៅរួមមាន ៖ ស្បែក ដំណក់ជញ្ជើម មាត់ និងក្រពះ ។
- សារពាង្គកាយមនុស្សមានភាពស៊ាំពីរបែប ៖ ភាពស៊ាំសកម្មនិងភាពស៊ាំអកម្ម ។
- ភាពស៊ាំសកម្ម ជាភាពស៊ាំដែលប្រព័ន្ធស៊ាំឆ្លើយតបទៅនឹងអង់ទីសែនរបស់វីរុសដោយការផលិតអង់ទីករដែលប្រយុទ្ធប្រឆាំងនឹងមេរោគបង្កជំងឺ ។
- ភាពស៊ាំសកម្មមានពីរបែប ៖ តំណបស៊ាំនិងវ៉ាក់សាំង ។
- ភាពស៊ាំអកម្ម ជាភាពស៊ាំមានពីកំណើត ដែលមានរយៈពេលតែពី- បីខែប៉ុណ្ណោះឬការប្រយុទ្ធប្រឆាំងទៅនឹងអង់ទីសែនរបស់វីរុស ដោយការចាក់ថ្នាំអង់ទីប៉ូទិច ។
- HIV ឬមេរោគអេដស៍ ជាប្រភេទវីរុសដែលបំផ្លាញប្រព័ន្ធស៊ាំរបស់សារពាង្គកាយមនុស្ស ។ បើអ្នកណាម្នាក់មានផ្ទុកវីរុស HIV គេអាចនឹងស្លាប់ដោយជំងឺផ្សេងៗ ដូចជា ៖ របេង ហើមសួត មហារីក រលាកថ្លើម ។
- ជំងឺមិនឆ្លងជាជំងឺដែលមិនបណ្តាលមកពីភ្នាក់ងារបង្កជំងឺទេ ។ ជំងឺមិនឆ្លងរួមមាន ៖ ជំងឺលើសឈាម ជំងឺទឹកនោមផ្អែម ជំងឺមហារីក ។ ជំងឺមិនឆ្លងមួយចំនួនក៏អាចឆ្លងមកពីឪពុកម្តាយ (***ឧទាហរណ៍*** ៖ ជំងឺមហារីក) ។

## ? សំណួរនិងលំហាត់

1. ដូចម្ដេចដែលហៅថា ជំងឺឆ្លង ? ជំងឺមិនឆ្លង ?
2. តើភ្នាក់ងារបង្កជំងឺមានអ្វីខ្លះ? ចូរឱ្យឧទាហរណ៍បញ្ជាក់ពីជំងឺដែលបណ្ដាលមកពីភ្នាក់ងារនីមួយៗ ។
3. ពណ៌នាពីរបៀបផ្សេងៗនៃការឆ្លងជំងឺ ព្រមទាំងឱ្យឧទាហរណ៍បញ្ជាក់ ។
4. ដូចម្ដេចដែលហៅថា ភាពស៊ាំសកម្ម ? ភាពស៊ាំអកម្ម ?
5. តើមេរោគអេដស៍អាចឆ្លងតាមរបៀបណាខ្លះ ?
6. តើសកម្មភាពណាខ្លះដែលមិនបណ្ដាលឱ្យឆ្លងជំងឺអេដស៍ ?
7. ចូររៀបរាប់ពីជំងឺមិនឆ្លងមួយចំនួន ។
8. ហេតុអ្វីបានជាមនុស្សម្នាក់មិនមានកើតជំងឺអ្វីមួយ ក្រោយពេលគាត់បានចាក់វ៉ាក់សាំងការពារជំងឺនោះ ?

មេរៀនទី

# 2 អាហារនិងសុខភាព

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ប្រភេទអាហារទាំងបីក្រុម ដែលចាំបាច់សម្រាប់សារពាង្គកាយ ។
- ❑ ពណ៌នាអំពីវីតាមីនផ្សេងៗនិងនាទីរបស់វាក្នុងរបបអាហារ ។
- ❑ ប្រៀបធៀបអាហារសុខភាពនិងអាហារមានកូឡេស្តេរ៉ុល ។
- ❑ ជ្រើសរើសអាហារដែលមានប្រយោជន៍ចំពោះសុខភាព ។
- ❑ បង្ហាញពីគុណវិបត្តិនៃអាហារដែលមានកូឡេស្តេរ៉ុលច្រើន ។

មនុស្សគ្រប់រូបតែងតែត្រូវការជាចាំបាច់នូវចំណីអាហារ ដើម្បីផ្តល់ថាមពលសម្រាប់ធ្វើការងារ និងកែតម្រូវសីតុណ្ហភាពក្នុងរាងកាយ ។ ចំណីអាហារ ជាតម្រូវការចាំបាច់សម្រាប់ស្ថាបនា ទ្រទ្រង់ ថែទាំ និងជួសជុលរាងកាយ ។ វាក៏តម្រូវឱ្យមានអាហារចាំបាច់ដើម្បីត្រួតពិនិត្យមេតាបូលីសរបស់សារពាង្គកាយ ការពារកុំឱ្យមានជំងឺនិងការបង្ករោគផ្សេងៗទៀត ។ អាហារដែលមានគុណភាពល្អ មិនត្រឹមតែជួយបង្ការជំងឺប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឱ្យរាងកាយយើងអាចប្រយុទ្ធប្រឆាំងនឹងជំងឺនិងជួយធ្វើឱ្យរាងកាយយើងបានជាសះស្បើយឆាប់រហ័សទៀតផង ។ ដូច្នេះនៅពេលអ្នកណាម្នាក់មានជំងឺ គឺជាការសំខាន់ណាស់ ដែលគេត្រូវតែរក្សាឬបង្កើនការបរិភោគចំណីអាហារដែលមានគុណភាពល្អ ។ ដោយសារតែហេតុនេះហើយ ចំណីអាហារមិនត្រឹមតែជួយទ្រទ្រង់ដល់អាយុជីវិតយើងប៉ុណ្ណោះទេ ថែមទាំងជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវិតមនុស្សយើងទៀតផង ។

## 1. អាហារមូលដ្ឋានទាំងបីក្រុម

ចំណីអាហារផ្តល់នូវការរស់រានមានជីវិត សុខភាព ការធំធាត់លូតលាស់ ។ សុខភាពល្អ ជាភាពសុខកាយសប្បាយចិត្ត ទាំងសតិបញ្ញា ទាំងផ្នែកសង្គម ព្រោះគ្មានជំងឺមកបៀតបៀននិងគ្មានពិការភាព ។ អាហារចែកជាបីក្រុម ៖

### 1.1. អាហារថាមពល

ជាប្រភពមួយដ៏ល្អ ពីព្រោះវាផ្ទុកគ្លុយស៊ីត(កាបូនអ៊ីដ្រាត)និងខ្លាញ់ដែលរាងកាយយើងយកទៅប្រើប្រាស់ដើម្បីផ្តល់ថាមពល សម្រាប់ធ្វើសកម្មភាពផ្សេងៗក្នុងរាងកាយ ។ អាហារដែលសម្បូរទៅដោយ

គួយស៊ីតមាន អង្ករ នំបញ្ចុក ឬគុយទាវ ត្រាវ ដំឡូងមី ពោត ដំឡូងបារាំង ដំឡូងជ្វា នំប៉័ង ស្ករ ទឹកឃ្មុំ និងស្ករអំពៅ ។ ឯអាហារសម្បូរទៅដោយជាតិខ្លាញ់មាន ខ្ទិះដូង ប្រេងឆា ខ្លាញ់សត្វ ។




រូបទី 2.1 : អាហារថាមពល

## 1.2. អាហារស្ថាបនារាងកាយ

អាហារទាំងនេះមានជាតិសាច់ (ប្រូតេអ៊ីន) ដែលរាងកាយយើងយកទៅប្រើប្រាស់សម្រាប់ការរីកធំធាត់ការលូតលាស់ ការទ្រទ្រង់និងជួសជុលជាលិការបស់រាងកាយយើង ។ អាហារក្នុងក្រុមនេះមាន ទឹកដោះម្តាយ សណ្តែកសៀង សណ្តែកដី សណ្តែកខៀវ តៅហ៊ូ ស៊ុត ត្រី ទឹកដោះគោឆៅ សាច់គោ សាច់ជ្រូក សាច់មាន់ សាច់ទា ក្តាម អន្ទង់ មឹក គំពិស កង្កែប និងសាច់សត្វផ្សេងៗទៀត ។




រូបទី 2.2 : អាហារស្ថាបនារាងកាយ

## 1.3. អាហារការពាររាងកាយ

អាហារក្រុមនេះមានពពួកវីតាមីននិងធាតុរ៉ែខនិជសំខាន់ៗជាច្រើនដែលធ្វើការរួមគ្នាជាមួយក្រុមអាហារស្ថាបនារាងកាយនិងក្រុមអាហារថាមពលដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺនិងការបង្ករោគផ្សេងៗ ។ អាហារក្រុមនេះមាន ជីវជាតិអា អ៊ីយ៉ូត និងជាតិដែក ដែលគេហៅថាមីក្រូសារជាតិ ។ វាជាសារធាតុចាំបាច់សំខាន់សម្រាប់ធ្វើឱ្យយើងមានសុខភាពល្អ ។ អាហារក្នុងក្រុមនេះសំខាន់ៗមាន បន្លែនិងផ្លែឈើ ។

- បន្លែស្លឹកពណ៌បៃតងចាស់   ត្រកួន ស្លឹកបាស ថ្មី ស្លឹកងប់ ស្ពៃខ្មៅ ត្រួយល្ពៅ
- បន្លែពណ៌លឿងទុំ   ល្ពៅ ដំឡូងជ្វាពណ៌លឿង និងការ៉ុត
- ផ្លែឈើពណ៌លឿងទុំ   ស្វាយទុំនិងល្ហុងទុំ
- ស៊ុត សាច់មាន់ ត្រីដូចជា ត្រីផ្ទក់ ត្រីប្រា ត្រីឆ្លាំង ឈាមសត្វ ថ្លើម និងគ្រឿងក្នុងផ្សេងៗទៀតរបស់សត្វ ។



*រូបទី 2.3 : អាហារការពាររាងកាយ*

## 2. នាទីវីតាមីនចំពោះសុខភាព

វីតាមីនជាសារធាតុមានក្នុងអាហារធម្មជាតិ ទោះបីជាមានបរិមាណតិចតួចក៏ដោយ ក៏វាចាំបាច់បំផុតសម្រាប់សារពាង្គកាយ ។ អវត្តមានឬកង្វះវីតាមីនក្នុងចំណីអាហារ បណ្តាលឱ្យមានជំងឺដែលអាចស្លាប់បាន ។

### 2.1. របកគំហើញចំពោះវត្តមាននៃវីតាមីន

យើងដឹងជាយូរយារណាស់មកហើយ (តាំងពីមិនទាន់ស្គាល់អត្តសញ្ញាណវីតាមីននៅក្នុងអាហារ) ថា ការបរិភោគអាហារជួយថែទាំនិងលើកកំពស់សុខភាព ។

ពីសម័យបុរាណ ជនជាតិអេហ្ស៊ីបបានរកឃើញថា ការឱ្យអ្នកជំងឺបរិភោគថ្លើមអាចធ្វើឱ្យជំងឺខ្វាក់មាន់ជាសះស្បើយបាន ។ សព្វថ្ងៃគេយល់ថា ជំងឺនេះបណ្តាលមកពីកង្វះវីតាមីន A ។ នៅឆ្នាំ1747 គ្រូពេទ្យវះកាត់ជនជាតិអេកូសម្នាក់ (James Lind) បានស្រាវជ្រាវឃើញថា អាហារដែលមានជាតិក្រូចអាចការពារជំងឺចេញឈាមតាមអញ្ចាញធ្មេញបាន (ស្កររប៊ុតឬរាក់ស៊ីធ្មេញ) ។ នៅឆ្នាំ1881 គ្រូពេទ្យវះកាត់ជនជាតិរុស្ស៊ីឈ្មោះ (Nikolai Lunin) បានស្រាវជ្រាវឃើញថា បើគាត់ឱ្យកណ្តុរស៊ីអាហារដែលគាត់រៀបចំតែមួយមុខៗដោយឡែកពីគ្នាដូចជា ប្រូតេអ៊ីនសុទ្ធ ខ្លាញ់សុទ្ធ ស្ករស៊ីតសុទ្ធ ឬអំបិលសុទ្ធ កណ្តុរទាំងនោះត្រូវស្លាប់ទាំងអស់ ។ ប៉ុន្តែប្រសិនបើគាត់ឱ្យវាស៊ីអាហារដោយខ្លួនវា វាលូតលាស់ធម្មតា ។ គាត់

ធ្វើការសន្និដ្ឋានថា " អាហារធម្មជាតិផ្សំដោយសារធាតុជាច្រើនដែលយើងមិនស្គាល់ ទោះបីជាក្នុងបរិមាណតិចតួចក៏ដោយ ក៏វាចាំបាច់បំផុតសម្រាប់ជីវិត" ។ ក្នុងឆ្នាំ1897 គ្រូពេទ្យជាតិហូឡង់ (អាយគ្មាន)បានស្រាវជ្រាវឃើញថា អង្ករសម្រូបអាចបង្ការជំងឺស្គ័កបាន ។ គាត់បានធ្វើការពិសោធទៅលើបក្សី ដែលមានជំងឺរលាកប្រព័ន្ធសរសៃប្រសាទ ដោយឱ្យស៊ីអង្ករសម្រូបរួចថែមកន្ទក់ ។ គាត់សង្កេតឃើញថា រោគសញ្ញានៃជំងឺក៏បាត់អស់ ហើយបក្សីក៏ជាសះស្បើយឡើងវិញ (មានសុខភាពល្អ) ។ ការព្យាបាលបែបនេះក៏មានប្រសិទ្ធភាពដូចគ្នាដែរចំពោះអ្នកជំងឺដែលមានរោគស្គ័ក ។

## 2.2. វីតាមីនសំខាន់ៗ

បន្ទាប់ពីរបកគំហើញវីតាមីនដំបូងបង្អស់ ទោះបីជាគេមិនទាន់ស្គាល់ទម្រង់គីមីរបស់វាក៏ដោយ ក៏វីតាមីនទាំងអស់ត្រូវបានតាងដោយតួអក្សរសំគាល់ ហើយចែកជាពីរផ្នែកទៅតាមភាពរលាយរបស់វាគឺ វីតាមីនរលាយក្នុងទឹកនិងវីតាមីនរលាយក្នុងខ្លាញ់ ។

### ក. វីតាមីនរលាយក្នុងទឹក

វីតាមីនរលាយក្នុងទឹកមាន វីតាមីន $B_1$ , $B_2$ និងវីតាមីន C ។

- ***វីតាមីន*** $B_1$ ***ឬវីតាមីនការពារជំងឺស្គ័ក*** (មានឈ្មោះមួយទៀតហៅថា អាណឺរីន)

វីតាមីននេះមានអំពើទៅលើប្រព័ន្ធសរសៃប្រសាទ ។ វាមាននៅក្នុងសំបកគ្រាប់ធញ្ញជាតិ ក្នុងចេកសាច់ស្រស់ ស៊ុតលឿង ដំឡូងបារាំង ។ វីតាមីននេះមាននាទីការពារនិងរក្សាលំនឹងនៃប្រព័ន្ធប្រសាទ ។ តម្រូវការរបស់មនុស្សគឺ 1.5mg ក្នុងមួយថ្ងៃ ។

- ***វីតាមីន*** $B_2$

ជាជាតិពណ៌លឿងដែលឃើញមានក្នុងស៊ុត ទឹកដោះ ថ្លើម ។ វីតាមីននេះ ជួយឱ្យសារពាង្គកាយប្រើប្រាស់ខ្លាញ់ស៊ុតបានតាមធម្មតា ។ កង្វះវីតាមីន $B_2$ បង្អាក់ការលូតលាស់និងបន្ថយផលិតផលនៃកម្ដៅ ។ តម្រូវការរបស់វា មាន 1.5mg ក្នុងមួយថ្ងៃ ។

- ***វីតាមីន*** C (ឬវីតាមីនការពារជំងឺរាក់ស៊ីធ្មេញ)

វីតាមីននេះសម្បូរនៅក្នុងផ្លែឈើដែលមានជាតិអាស៊ីត ដូចជា ក្រូចឆ្មារ ក្រូចពោធិ៍សាត់ បន្លែស្រស់ ថ្លើម ទឹកដោះ ។ វីតាមីននេះចាំបាច់ចំពោះមនុស្សគ្រប់វ័យ ។ វាឆាប់វិនាសណាស់ ។ ភាពស្ងួតហែង ឬកម្ដៅ 100°C អាចបំផ្លាញវាបាន ជាពិសេសអាហារកំប៉ុង ឬទឹកដោះគោកំប៉ុងដែលគេរំងាប់មីក្រុប អាហារទាំងនោះគ្មានវីតាមីន C ទេ ។

### ១. វីតាមីនរលាយក្នុងខ្លាញ់

វីតាមីនរលាយក្នុងខ្លាញ់មាន វីតាមីន A និងវីតាមីន D ។

- ***វីតាមីន*** A (វីតាមីនសម្រាប់ការលូតលាស់)

សម្បូរនៅក្នុងខ្លាញ់សត្វ ប្រេង ប៊ឺរ ថ្លើមត្រីម៉ូរុយ ។ អវត្តមានរបស់វាបង្អាក់ការលូតលាស់របស់ក្មេង អន់ភ្នែកដោយខ្វចកញ្ចក់ភ្នែកចំពោះមនុស្សគ្រប់វ័យ ។ វីតាមីន A ក៏អាចមាននៅក្នុងរុក្ខជាតិបៃតងដែរ ។ ក្រៅពីក្លរ៉ូភីល រុក្ខជាតិបៃតងមានជាតិម្យ៉ាងទៀតពណ៌លឿងទុំហៅថា ការ៉ូតែន ដែលក្លាយទៅជាវីតាមីន A ស្តុកទុកក្នុងថ្លើមយើង ។ ការ៉ូតែនគឺជាប្រូវីតាមីន A ដែលសម្បូរនៅក្នុងមើមការ៉ុត ល្ពៅ និងផ្លែឈើឬដំឡូងដែលមានពណ៌លឿង ។

- ***វីតាមីន*** D (វីតាមីនការពាររោគគ្រិស)

វីតាមីននេះចាំបាច់បំផុតចំពោះក្មេង ព្រោះវាអាចធ្វើឱ្យអំបិលកាល់ស្យូមជាប់ទៅនឹងជាលិកាឆ្អឹង ។ រង្វាស់របស់វាក្នុងបរិមាណតិចក្រៃលែង គឺ 0.01mg ក្នុងមួយថ្ងៃ ។ វីតាមីន D មានក្នុងអាហារខ្លាញ់ដូចវីតាមីន A ដែរ ។

ក្រៅពីវីតាមីនដែលបានរៀបរាប់ខាងលើ នៅមានវីតាមីនផ្សេងៗជាច្រើនទៀត ដូចជា វីតាមីន K (វីតាមីនបង្ការការធ្លាក់ឈាម)វីតាមីន E (វីតាមីនបន្តពូជ)និងវីតាមីន $B_{12}$ (វីតាមីនបង្ការជំងឺខ្វះឈាម) ។

## ១. កូឡេស្តេរ៉ុលនិងសុខភាព

កូឡេស្តេរ៉ុលជាលីពីត ។ វាកើតឡើងពីបន្សំរវាងស្តេរ៉ូអ៊ីតនិងអាល់កុល ដែលមាននៅក្នុងភ្នាសកោសិកានៃគ្រប់សារពាង្គកាយ ។ គេក៏បានរកឃើញកូឡេស្តេរ៉ុលក្នុងភ្នាសកោសិការបស់រុក្ខជាតិនិងផ្សិតផងដែរតែក្នុងបរិមាណតិចតួច ។

កូឡេស្តេរ៉ុលជាតម្រូវការចាំបាច់ក្នុងការកសាងនិងទ្រទ្រង់ភ្នាសកោសិកា ។ ជាទូទៅបើនិយាយពីពាក្យ" កូឡេស្តេរ៉ុល" គេតែងតែនឹកដល់គុណវិបត្តិរបស់វាក្នុងសារពាង្គកាយ ។ ភាគច្រើននៃកូឡេស្តេរ៉ុល(75 %)ត្រូវបានសំយោគដោយសារពាង្គកាយនិងមួយចំនួនទៀត(25 %) បានមកពីរបប អាហារ ។ កូឡេស្តេរ៉ុល ដើរតួជាមជ្ឈមណ្ឌលនៃមុខងារក្នុងលំនាំគីមីជីវ ផ្សេងៗ ។ ប៉ុន្តែវាត្រូវបានគេស្គាល់ច្បាស់ដោយសារវាបណ្តាលឱ្យមានជំងឺសរសៃបេះដូង ព្រោះមានប្រូតេអ៊ីនដែលមានខ្លាញ់ច្រើនកកនៅក្នុងសរសៃឈាម ។ កូឡេស្តេរ៉ុលមិនរលាយក្នុងឈាមទេ ប៉ុន្តែវាត្រូវបានដឹកនាំតាមប្រដាប់របត់ឈាម ។ បរិមាណកូឡេស្តេរ៉ុលអាចប្រែប្រួលទៅតាមអាយុ ។

កូឡេស្តេរ៉ុល ត្រូវបានរកឃើញនៅក្នុងខ្លាញ់សត្វ ។ គ្រប់អាហារទាំងអស់ដែលមានខ្លាញ់សត្វសុទ្ធតែមានកូឡេស្តេរ៉ុល ។ អាហារដែលគ្មានខ្លាញ់សត្វ គ្មានកូឡេស្តេរ៉ុលទេ ប្រសិនបើមានក៏ក្នុងបរិមាណតិចតួចបំផុត ។

ក្នុងសារពាង្គកាយមនុស្ស កូឡេស្តេរ៉ុលមាននៅក្នុងប្រដាប់របត់ឈាម ។ កូឡេស្តេរ៉ុលក្នុងឈាមមនុស្សមានប្រភពចម្បងពីរគឺ ការបរិភោគអាហារនិងការផលិតរបស់ថ្លើម ។ កូឡេស្តេរ៉ុលក្នុងអាហារបានមកពីសាច់សត្វ បក្សី ត្រី និងផលិតផលធ្វើពីទឹកដោះគោ ។ អាហារមានជាតិសាច់ដូចជាថ្លើម មានកូឡេស្តេរ៉ុលច្រើន ។ បន្ទាប់ពីការបរិភោគអាហារ កូឡេស្តេរ៉ុលជ្រាបតាមភ្នាសពោះវៀន ចូលក្នុងប្រដាប់របត់ឈាម រួចទៅកកនៅក្នុងស្រទាប់ប្រូតេអ៊ីន បង្កើតជាប្រូតេអ៊ីនសាំញ៉ាំ ។ ថ្លើមអាចបញ្ជូនកូឡេស្តេរ៉ុលទៅក្នុងប្រដាប់របត់ឈាម ហើយក៏អាចបញ្ចេញពីក្នុងប្រដាប់របត់ឈាមវិញដែរ ។ កូឡេស្តេរ៉ុលមានពីរយ៉ាងគឺ ល្អនិងអាក្រក់ ។ កូឡេស្តេរ៉ុលល្អជ្រាបតាមភ្នាសសរសៃអាកទែ ហើយបញ្ចេញចោលទៅក្នុងថ្លើម ។ ចលនានេះអាចការពារជំងឺស្ទះសរសៃឈាមបាន ហើយមេតាបូលីសក្នុងសារពាង្គកាយប្រព្រឹត្តទៅបានល្អ ។ កូឡេស្តេរ៉ុលអាក្រក់ ជាកូឡេស្តេរ៉ុលកកក្នុងសរសៃអាកទែ ជាហេតុធ្វើឱ្យសរសៃអាកទែស្ទះ ហើយបណ្តាលឱ្យមានជំងឺបេះដូងឬជំងឺលើសឈាម ។

## 4. ការថែរក្សាសុខភាពឱ្យបានល្អ

មនុស្សគ្រប់រូប ទាំងចាស់ទាំងក្មេង ទាំងស្រីទាំងប្រុស ត្រូវចេះថែរក្សាសុខភាពឱ្យបានល្អ ។ ទោះបីជាយើងប្រុងប្រយ័ត្នយ៉ាងណាក៏ដោយ ក៏នៅតែអាចកើតមានជំងឺដដែល ។ ជំងឺខ្លះទាក់ទងនិងវ័យ ខ្លះទាក់ទងនិងភេទ ខ្លះទៀតទាក់ទងនិងការបរិភោគចំណីអាហារនិងទឹក ហើយខ្លះទៀតទាក់ទងនិង ជីវភាពរស់នៅប្រចាំថ្ងៃ ។

ការបរិភោគចំណីអាហារមានប្រយោជន៍ក្នុងការចិញ្ចឹមរាងកាយនិងទ្រទ្រង់ជីវិត ។ មនុស្សគ្រប់រូបត្រូវការចំណីអាហារខុសៗគ្នា បរិមាណក៏ខុសគ្នាដែរ ។ កាលណារូបរាងកាយប្រែប្រួល មនុស្សក៏ត្រូវផ្លាស់ប្តូររបបអាហារផងដែរ ។ ចំណីអាហារតែមួយមុខមិនអាចមានសារធាតុចិញ្ចឹមគ្រប់គ្រាន់សម្រាប់តម្រូវការសុខភាពទេ ។ អនាម័យនិងសុវត្ថិភាពចំណីអាហារក៏ជាកត្តាមួយចំពោះសុខភាពផងដែរ ។ ចំណីអាហារដែលមិនស្អាតនិងមានជាតុពុល ជាតុគីមីអាចធ្វើឱ្យមានជំងឺនិងខូចសុខភាព ហើយប៉ះពាល់ដល់អាយុជីវិតទៀតផង ។ ហេតុនេះ គប្បីបរិភោគអាហារឱ្យបានគ្រប់មុខនិងមានអនាម័យ ។ ទឹកក៏ជាតម្រូវការចាំបាច់សម្រាប់ជីវិតផងដែរ ។ ទឹកមានគ្រប់ទិសទី ទឹកភ្លៀង ទឹកចេញពីក្នុងដី ទឹកជ្រោះតាមជ្រលងថ្ម ទឹកជំនន់ហូរតាមទន្លេ ។ តែយើងមិនអាចទទួលទានទឹកទាំងនោះដោយមិនកំចាត់

មេរោគឬ ជាតុពុលបានឡើយ ។ មនុស្សគ្រប់រូបត្រូវការទឹកជារៀងរាល់ថ្ងៃសម្រាប់ទ្រទ្រង់ជីវិតនិងដើម្បីឱ្យសារពាង្គកាយដំណើរការបានល្អ ។ ដូច្នេះ ទឹកមិនស្អាតអាចបង្កជំងឺនិងធ្វើឱ្យខូចសុខភាព ។

ក្រៅពីទទួលទានចំណីអាហារនិងទឹក មនុស្សគ្រប់រូបត្រូវរស់នៅមានអនាម័យក្នុងសង្គមមួយដ៏សុខសាន្ត មានបរិស្ថានល្អ គ្មានជាតុពុល ។ សំរាមនិងកាកសំណល់គឺជាបញ្ហាដ៏ធំមួយចំពោះសុខភាពយើង ។ មេរោគដែលរស់នៅក្នុងទឹកខ្វក់ ក្នុងធុងសំរាមគ្មានគម្របនិងក្នុងបង្គន់អាចចម្លងទៅមនុស្សបាន ។ ការសំអាតផ្ទះសម្បែង(ក្នុងនិងក្រៅផ្ទះ) ជាវិធីមួយដ៏ល្អបំផុតក្នុងការការពារកុំឱ្យឆ្លងជំងឺដែលបណ្ដាលមកពីមេរោគ ។ អ្វីៗដែលនៅជុំវិញខ្លួនយើង សុទ្ធតែអាចកំណត់សុខភាពយើងទាំងអស់ ដូចជាផ្ទះសម្បែង បរិស្ថាន ខ្យល់អាកាស កន្លែងធ្វើការ ។ល ។

សាច់ត្រីជាអាហារដ៏ល្អបំផុតដែលមិនសូវសម្បូរខ្លាញ់ ប៉ុន្តែវាផ្ទុកទៅដោយអំបិលខនិជ វីតាមីន ផូស្វ័រ ម៉ាញ៉េស្យូម សេឡេនីញ៉ូម ភ្លុយអរ ស័ង្កសី វីតាមីន $B_2$ , $B_{12}$ ។ លើសពីនេះទៅទៀត សាច់ត្រីសម្បូរទៅដោយជាតិអ៊ីយ៉ូត ។

លំហាត់ប្រាណត្រឹមត្រូវ ទៀងទាត់ និងមានកម្រិតក៏ជាកត្តាចាំបាច់ក្នុងការទ្រទ្រង់សុខភាពផងដែរ ។

## មេរៀនសង្ខេប

- វត្តមានវីតាមីនក្នុងអាហារ ទោះបីជាក្នុងបរិមាណតិចតួចក៏ដោយ ក៏សារពាង្គកាយត្រូវការជាចាំបាច់ដោយខានមិនបាន ។ វីតាមីនមានពីរបែបគឺ វីតាមីនរលាយក្នុងទឹកនិងវីតាមីនរលាយក្នុងខ្លាញ់ ។ វីតាមីនរលាយក្នុងទឹក មានវីតាមីន C និងវីតាមីន B ទាំងអស់ ។ វីតាមីនរលាយក្នុងខ្លាញ់មាន វីតាមីន A , D , E និង K ។ កង្វះវីតាមីន A បណ្ដាលឱ្យកើតជំងឺខ្វាក់មាន់ ។ កង្វះវីតាមីន B បណ្ដាលឱ្យកើតរោគស្ពឹកឬខ្វះឈាមក្រហម(ខ្វះគោលិកាក្រហម) ។ កង្វះវីតាមីន C បណ្ដាលឱ្យចេញឈាមតាមអញ្ចាញធ្មេញ (រាក់ស៊ីធ្មេញ) ។ កង្វះវីតាមីន D បណ្ដាលឱ្យកើតរោគគ្រិស ។
- កូឡេស្តេរ៉ុល ជាលីពីតកើតឡើងពីបន្សំរវាងស្តេរ៉ូអ៊ីតនិងអាល់កុល ហើយសំយោគដោយសារពាង្គកាយនិងបានមកពីអាហារ ។ កូឡេស្តេរ៉ុលភាគច្រើនមាននៅក្នុងខ្លាញ់សត្វ ។ ប្រភពកូឡេស្តេរ៉ុលក្នុងអាហារមាន ស៊ុត សាច់ និងផលិតផលធ្វើពីទឹកដោះគោ ។ ក្នុងសារពាង្គកាយមនុស្ស កូឡេស្តេរ៉ុលមាននៅក្នុងប្រដាប់របត់ឈាម ។ កូឡេស្តេរ៉ុលមានពីរបែបគឺ ល្អនិងអាក្រក់ ។ កូឡេស្តេរ៉ុលល្អការពារជំងឺស្ទះសរសៃឈាម ដោយវាជ្រាបតាមភ្នាសសរសៃអាកទែ ហើយបញ្ចេញចោលទៅក្នុងថ្លើម ។ ឯកូឡេស្តេរ៉ុលអាក្រក់បណ្ដាលឱ្យមានជំងឺបេះដូងឬជំងឺលើសឈាម ដោយសារវាកកក្នុងសរសៃអាកទែ ដែលធ្វើឱ្យដំណើររបត់ឈាមត្រូវរាំងស្ទះ ។

## ? សំណួរនិងលំហាត់

1 តើអាហារចែកជាប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

2 ដូចម្ដេចដែលហៅថា អាហារថាមពល ? អាហារស្ថាបនារាងកាយ ? អាហារការពាររាងកាយ ?

3 តើវីតាមីនមានប៉ុន្មានបែប ? អ្វីខ្លះ ?

4 តើកង្វះវីតាមីន A បណ្ដាលឱ្យមនុស្សយើងកើតជំងឺអ្វី ?

5 តើរោគស្លឹកបណ្ដាលមកពីអ្វី ?

6 អ្វីជាកូឡេស្តេរ៉ូល ?

7 ក្នុងសារពាង្គកាយមនុស្ស តើកូឡេស្តេរ៉ុលបានមកពីអ្វីខ្លះ ?

8. តើជំងឺបេះដូងបណ្ដាលមកពីអ្វី ?

## ? សំណួរនិងលំហាត់ជំពូក ៨

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1 ជំងឺរបេងបណ្ដាលមកពីបាក់តេរីដែលបំផ្លាញ

☐ ក. ជាលិកាក្រពះ ☐ ខ. ជាលិកាពោះវៀន

☐ គ. ជាលិកាថ្លើម ☐ ឃ. ជាលិកាសួត ។

2. ជំងឺគ្រុនក្ដៅនិងផ្ដាសាយបណ្ដាលមកពីវីរុសនៅក្នុងកោសិកានៃ

☐ ក. ប្រដាប់របត់ឈាម ☐ ខ. ប្រដាប់ដង្ហើម

☐ គ. ប្រដាប់បញ្ចេញចោល ☐ ឃ. ប្រព័ន្ធប្រសាទ ។

3 ជំងឺដែលបណ្ដាលមកពីផ្សិតមាន

☐ ក. ជ្រាំងមាត់ ☐ ខ. កញ្ជ្រិល

☐ គ. អុតស្វាយ ☐ ឃ. រលាកថ្លើម ។

4. លំពែងផលិត

☐ ក. ទីរ៉ុកស៊ីន ☐ ខ. អាំងសុយលីន

☐ គ. ត្រីកូសែន ☐ ឃ. អង់ស៊ីម ។

5. ធាតុបង្កនៃឈាមដែលផលិតអង់ទីករតី

☐ ក. គោលិកាក្រហម ☐ ខ. គោលិកាស

☐ គ. ប្លាស្មា ☐ ឃ. ប្លាកែត ។

6. ជំងឺដែលមិនអាចចាក់ថ្នាំបង្ការបានគឺ

- [ ] ក. របេង
- [ ] ខ. កញ្ជ្រឹល
- [ ] គ. ស្អូត
- [ ] ឃ. រលាកថ្លើម ។

7 ជំងឺមិនឆ្លងមាន

- [ ] ក. របេង
- [ ] ខ រលាកថ្លើម
- [ ] គ អុតស្វាយ
- [ ] ឃ ទឹកនោមផ្អែម ។

8. សាច់គោជា

- [ ] ក. អាហារថាមពល
- [ ] ខ. អាហារស្ថាបនារាងកាយ
- [ ] គ. អាហារការពាររាងកាយ
- [ ] ឃ. វីតាមីន ។

9 កង្វះវីតាមីន " A " បណ្ដាលឱ្យកើតជំងឺ

- [ ] ក. រាក់ស៊ីធ្មេញ
- [ ] ខ. ស្វិក
- [ ] គ. ខ្វាក់មាន់
- [ ] ឃ. រលាកស្បែក ។

10. វីតាមីន " C " មាននៅក្នុង

- [ ] ក. ផ្លែប៉ោម
- [ ] ខ. ផ្លែក្រូច
- [ ] គ. ផ្លែប៉េងប៉ោះ
- [ ] ឃ. ផ្លែល្ពៅ ។

II. ចូរជ្រើសរើសពាក្យមកបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ស្បែកជាកោសិកាងាប់ដែលបង្កើតជា .......... មួយប្រឆាំងនឹងមេរោគ ។
2. នៅក្រោមស្បែកមាន .......... សម្រាប់បញ្ចេញសារធាតុរាវ ដូចប្រេងដើម្បីរក្សាស្បែកឱ្យទន់និងអាចសម្លាប់មេរោគបាន ។
3. សារធាតុរាវមានឈ្មោះថា .......... ដែលការពារការជ្រៀតចូលនៃមេរោគនិងធ្វើឱ្យ .......... មិនជ្រាបទឹក ។
4. នៅក្នុងឈាមមាន .......... ដែលផលិតដោយសារពាង្គកាយដើម្បីប្រយុទ្ធប្រឆាំងមេរោគ ។
5. មេរោគដែលចូលទៅក្នុងក្រពះជាមួយអាហារត្រូវបំផ្លាញដោយ .......... ក្នុងទឹកមាត់និង .......... ក្នុងក្រពះ ។
6. ថ្នាំបង្ការោគជាសារធាតុដែលប្រើសម្រាប់ធ្វើ .......... ។
7. ក្រៅពីនេះនៅមានថ្នាំអាចសម្លាប់ឬពន្យឺតការលូតលាស់របស់បាក់តេរី ដែលហៅថាថ្នាំ .......... ។

8. ចូរផ្គូរផ្គងផ្នែក A និង B ឱ្យបានត្រឹមត្រូវ

| A | B | |
|---|---|---|
| 1 - វីតាមីន A | ក. ការពាររាក់ស៊ីធ្មេញ | 1 → |
| 2 - វីតាមីន $B_2$ | ខ. ការពាររោគគ្រិស | 2 → |
| 3 - វីតាមីន $B_6$ | គ. ការពាររោគខ្វាក់មាន់ | 3 → |
| 4 - វីតាមីន $B_{12}$ | ឃ. ការពាររោគស្លឹក | 4 → |
| 5 - វីតាមីន C | ង. ការពាររោគខ្វះឈាម | 5 → |
| 6 - វីតាមីន D | ច. ធ្វើឱ្យឆ្អឹងលូតលាស់ | 6 → |
| | ឆ. ការពាររោគរលាកស្បែក | |
| | ជ. សម្រួលការប្រើប្រាស់គ្លុយកូស | |

**III. ចូរឆ្លើយសំណួរខាងក្រោមនេះ**

1. ដូចម្ដេចដែលហៅថាជំងឺឆ្លង ? ជំងឺមិនឆ្លង ?
2. ដូចម្ដេចដែលហៅថាភាពស៊ាំសកម្ម ? ភាពស៊ាំអកម្ម ?
3. តើជំងឺឆ្លងអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈអ្វីខ្លះ ?
4. ក្នុងសារពាង្គកាយមនុស្ស មានរបាំងការពារប្រឆាំងនឹងភ្នាក់ងារបង្កជំងឺប៉ុន្មានយ៉ាង ? អ្វីខ្លះ ?
5. តើក្នុងករណីណាដែលមនុស្សម្នាក់កើតជំងឺទឹកនោមផ្អែម ?
6. តើអ្នកកើតជំងឺទឹកនោមផ្អែមមានលក្ខណៈសំគាល់យ៉ាងដូចម្ដេច ?
7. ដូចម្ដេចដែលហៅថាអាហារថាមពល ? អាហារស្ថាបនារាងកាយ ? អាហារការពាររាងកាយ ?
8. តើកង្វះវីតាមីន " D " បណ្ដាលឱ្យមានជំងឺអ្វី ?
9. ដូចម្ដេចដែលហៅថាកូឡេស្តេរ៉ុលល្អ ? កូឡេស្តេរ៉ុលអាក្រក់ ?
10. ដើម្បីឱ្យមានសុខភាពល្អ តើយើងត្រូវធ្វើដូចម្ដេចខ្លះ ?

# បទានុក្រម

| | |
|---|---|
| កន្សោមបូម៉ាន់ | ផ្នែកមួយនៃណេប្រុងដែលមានរាងដូចពែងនៃតម្រងនោមសត្វឆ្អឹងកងថ្នាក់ខ្ពស់ ។ |
| កាតាលីករ | ជាសមាសធាតុដែលបង្កើនល្បឿនប្រតិកម្ម ។ |
| កំណាច់សម្បុក | ដំណើរលូតលាស់ដំបូងរបស់អំប្រីយ៉ុង ដែលក្នុងនោះប្លាស្តូស៊ីសភ្ជាប់ខ្លួនវាទៅនឹងផ្ទៃស្បូនរបស់ម្តាយ ។ |
| គ្លូម៉េរុល | បណ្តុំសរសៃឈាមប្លូររុំព័ទ្ធដោយកន្សោមបូម៉ាន់របស់ណេប្រុង ។ នៅទីនោះទឹកនិងម៉ូលេគុលរលាយតូចៗច្រោះចេញពីឈាមចូលក្នុងកន្សោមបូម៉ាន់ ។ |
| ក្រូម៉ាទីន | ជាសំណុំនៃម៉ូលេគុល ADN ដែលរុំព័ទ្ធជុំវិញប្រូតេអ៊ីន(អ៊ីស្តូន) ។ ក្រូម៉ាទីនជាក្រូម៉ូសូមរលានៅចន្លោះវគ្គ ។ |
| ក្រូម៉ូសូម | ជាទម្រង់ឆ្មារៗដូចជាសរសៃអំបោះដែលកើតពី ADN និងប្រូតេអ៊ីនហើយផ្ទុកព័ត៌មានសេនេទិច ។ |
| ចំណងប៉ិបទីត | ជាសម្ព័ន្ធគីមី CO – NH ដែលកើតពីបណ្តុំកាបុកស៊ីលនៃអាស៊ីតអាមីនេមួយទៅនឹងបណ្តុំអាមីននៃអាស៊ីតអាមីនេមួយទៀត ។ |
| ចម្រោះក្នុងតម្រងនោម | ការឆ្លងកាត់នៃធាតុខ្លះៗនៃប្លាស្មាក្នុងសរសៃប្លូរចូលក្នុងតម្រងនោម ។ |
| ចំណែកកោសិកា | ជាលំនាំមួយដែលកោសិកាមេមួយចែកខ្លួន ដើម្បីបង្កើតជាកោសិកាកូនពីរ ។ ក្នុងចំណែកកោសិកាមានមីតូសនិងចំណែកស៊ីតូប្លាស ។ |
| ចំណែកស៊ីតូប្លាស | ការចែកស៊ីតូប្លាសជាពីរទៅឲ្យកោសិកាកូន ។ |
| ជម្រាបជ្រើស | ជាលក្ខណៈដែលអនុញ្ញាតិឱ្យសារធាតុមួយចំនួនឆ្លងកាត់បាន ។ |
| នុយក្លេអូភីឡាម៉ង់ | ភីឡាម៉ង់នៃក្រូម៉ាទីនបង្កឡើងដោយម៉ូលេគុល ADNដែលរុំព័ទ្ធលើអ៊ីស្តូន ។ |
| នុយក្លេអូសូម | ទម្រង់បង្កដោយបណ្តុំម៉ូលេគុលប្រូតេអ៊ីនដែលរុំព័ទ្ធដោយ ADN ។ |
| នុយក្លេអូល | ធាតុកោសិកានៅក្នុងណ្វៃយ៉ូ ។ វាផ្សំឡើងដោយ ARN ជាច្រើន ។ |
| តេស្តូស្តេរ៉ូន | អរម៉ូនភេទដែលផលិតដោយពងស្វាសសម្រាប់ជម្រុញអភិវឌ្ឍន៍លក្ខណៈភេទបន្ទាប់និងឲ្យមានបំលែងឯកទេសកោសិកាបន្តពូជ ។ |

| | |
|---|---|
| ទ្រីសូមី | វត្តមានក្រូម៉ូសូមដល់ទៅ3 ក្នុងគូក្រូម៉ូសូមអូម៉ូឡូកណាមួយ ឧ ទ្រីសូមី 21 ។ |
| ណេប្រុង | ឯកតាបញ្ចេញចោលតូចៗរបស់តម្រងនោមដែលច្រោះទឹកនោមពីឈាម ។ |
| បំលែងឯកទេស | ជាដំណើរឯកទេសកម្មរបស់កោសិកាទៅសភាពមួយដែលមានមុខងារជាក់លាក់ ។ |
| បង្កកំណើតកាត់ | ជាការរលាយចូលគ្នារវាងកាម៉េតញីឈ្មោលដែលមាននៅក្នុងឯកត្តៈ ផ្សេងគ្នា ។ |
| បង្កកំណើតនិមិត្ត | ជាការរលាយចូលគ្នារវាងកាម៉េតញីនិងកាម៉េតឈ្មោលដោយមានអន្តរាគមន៍ពីមនុស្ស ។ |
| បេរីស្តាស៊ីស | ជាចលនាកន្ត្រាក់នៃសាច់ដុំបំពង់អាហារ ពោះវៀន ដើម្បីរុញអាហារតាមបណ្តោយបំពង់អាហារ ។ |
| ប្លាស្មូលីស | ជាបាតុភូតអូស្មូស ដែលធ្វើឲ្យកោសិការុក្ខជាតិរួមតូចដោយការបាត់បង់ទឹក ។ |
| បន្ទះកោសិកា | ទម្រង់មានរាងជាសកើតឡើងពីការរលាយចូលគ្នានៃថង់(ថង់នេះកើតឡើងពីឧបករណ៍គុលស៊ី)នៅតំបន់អេក្វាទ័រ ។ បន្ទះនេះធ្វើឱ្យមានការបង្កើតភ្នាសគ្រោងដែលខណ្ឌចែកកោសិកាកូនទាំងពីរនៅពេលចំណែកកោសិកា ។ |
| បន្សាយ | ជាចលនារបស់ម៉ូលេគុល ឬអ៊ីយ៉ុងពីតំបន់ដែលមានកំហាប់សូលុយស្យុងខ្ពស់ទៅតំបន់កំហាប់សូលុយស្យុងទាប ។ |
| បង្ហូរនោម | បំពង់ដឹកនាំទឹកនោមចេញពីប្លោកនោមទៅកាន់ទ្វារនោម ។ ចំពោះបុរសបំពង់នេះក៏មាននាទីដឹកនាំស្តែម៉ាតូស៊ូអ៊ីតផងដែរ ។ |
| ប្រូតូប្លាស | ជាផ្នែកមានជីវិតរបស់កោសិកាដែលមានស៊ីតូប្លាសនិងណ្វៃយ៉ូ ។ |
| ប្រូតេអ៊ីន | សារធាតុសរីរាង្គដែលបង្កឡើងដោយ C–H–O–N ។វាកើតពីអាស៊ីតអាមីនេច្រើនដែលភ្ជាប់គ្នាដោយចំណងប៉ិបទីត ។ វាជាសម្ព័ន្ធកូវ៉ាឡង់ ។ |
| ប៉ូលីប្លូអ៊ីឌី | ការកើនឡើងនៃចំនួនក្រូម៉ូសូមជាពហុគុណនៃ n 3n 4n 5n ... ។ |
| ពហុអាឡែល | សភាពនៃសែនមួយដែលមានអាឡែលច្រើន ។ |
| ភ្នាសអឌ្ឍជ្រាប | ភ្នាសដែលអាចជ្រាបបានតែម៉ូលេគុលតូចៗដូចជាទឹក អ៊ីយ៉ុង ប៉ុន្តែរាំងស្ទះម៉ូលេគុលធំៗ ។ |

| | |
|---|---|
| មហារីក | ជាជំងឺបណ្ដាលមកពីដុំពក ។ ដុំពកនេះកើតឡើងដោយកោសិកាចែកខ្លួនគ្មានកំណត់និងគ្មានការត្រួតពិនិត្យ ។ ជំងឺនេះអាចស្លាប់ បើគ្មានការព្យាបាលទាន់ពេលវេលាទេ ។ |
| មីតូស | ជាប្រភេទមួយនៃចំណែកណៃ្វយ៉ូដោយណៃ្វយ៉ូមេមួយចែកបានណៃ្វយ៉ូកូនពីរដែលមានចំនួននិងរូបរាងក្រូម៉ូសូមដូចទៅនឹងណៃ្វយ៉ូមេ ។ |
| ម៉ូណូសូមី | អវត្តមាននៃក្រូម៉ូសូមមួយក្នុងគូក្រូម៉ូសូមអូម៉ូឡូកណាមួយ គឺនៅក្នុងគូក្រូម៉ូសូមនោះមានក្រូម៉ូសូមតែមួយ ។ |
| មាឌខ្យល់ចរន្ត | ជាមាឌខ្យល់ចេញ ឬចូលក្នុងសួតនៅពេលដង្ហើមចេញឬដង្ហើមចូលធម្មតា (0.5$\ell$) ។ |
| មាឌខ្យល់បង្គ្រប់ | មាឌខ្យល់បន្ថែមចូលក្នុងសួតនៅពេលដង្ហើមចូលបង្ខំ ។ |
| មាឌខ្យល់បម្រុង | មាឌខ្យល់បន្ថែមដែលត្រូវបញ្ចេញពីសួតនៅពេលដង្ហើមចេញបង្ខំ ។ |
| មាឌខ្យល់សល់ | មាឌខ្យល់ដែលមាននៅសល់ក្នុងសួត បន្ទាប់ពីដង្ហើមចេញបង្ខំ ។ មាឌខ្យល់នេះមិនអាចបញ្ចេញពីសួតបានទេ ។ |
| មេតាបូលីស | ជាលំនាំនានារួមមានលំនាំនៃការសំយោគ បំបែកម៉ូលេគុលផ្សេងៗក្នុងសារពាង្គកាយ ។ |
| ម៉ាក្រូម៉ូលេគុល | ជាម៉ូលេគុលដែលបង្កដោយអាតូមច្រើន ។ ឧទាហរណ៍ ប្រូតេអ៊ីនជាម៉ាក្រូម៉ូលេគុល ។ |
| ម៉ូណូសាការីត | ស្ករងាយដែលមិនអាចបំបែកទៅជាម៉ូលេគុលស្ករតូចៗបាន ។ វាជាឯកតាគ្រឹះដែលបង្កើតស្ករស៊ីតធំៗ ។ |
| ម៉ូណូមែ | ជាឯកតាតូចៗដូចគ្នាដែលផ្គុំគ្នាជាប៉ូលីមែ ។ |
| រីបូសូម | ជាគុកោសិកាតូចៗបង្កឡើងពីប្រូតេអ៊ីននិង ARN ។ វាស្ថិតនៅរាយប៉ាយក្នុងស៊ីតូប្លាសនិងភ្ជាប់លើរេទីគុយឡូមអង់ដូប្លាស ។ វាជាកន្លែងសំយោគប្រូតេអ៊ីន ។ |
| រេទីគុយឡូមអង់ដូប្លាស | ជាធាតុកោសិកាមានភ្នាសស្ថិតនៅក្នុងកោសិកាអឺការីយ៉ូត ។ វាមានរាងជាថង់សំប៉ែតផ្គុំគ្នាជាស៊េរី ។ វាមាននាទីក្នុងដំណឹកនាំប្រូតេអ៊ីនដែលសំយោគរួច ។ |

| | |
|---|---|
| លក្ខណៈតពូជជាប់នឹងភេទ | ជាលក្ខណ កំណត់ដោយសែនដែលមាននៅលើក្រូម៉ូសូមភេទ ហើយសម្តែងឡើងដោយទាក់ទងនឹងភេទ ។ |
| លីពីត | ជាសារធាតុសរីរាង្គបង្កឡើងដោយ C–H–O ។ វាកើតពីគ្លីសេរ៉ុលនិងអាស៊ីតខ្លាញ់ ។ |
| សន្ទះទ្រូង | ជាសាច់ដុំដែលខណ្ឌប្រហោងទ្រូងនិងពោះ ។ នៅពេលសន្ទះទ្រូងកន្ត្រាក់ប្រអប់ទ្រូងឡើងប៉ោងដែលធ្វើឲ្យខ្យល់ចូលក្នុងសួត ។ |
| ស្វ័យបង្កកំណើត | ជាការរលាយចូលគ្នានៃកាម៉េតញីឈ្មោលដែលមាននៅក្នុងឯកត្ត តែមួយឬនៅក្នុងផ្កាតែមួយ ។ |
| សំពាធប៉ោងឬដេញ្ញាស្មូលិស | ជាបាតុភូតអូស្មូសដែលធ្វើឲ្យកោសិការីកមាឌដោយការស្រូបទឹកចូលនៃកោសិការុក្ខជាតិ ។ |
| សារធាតុចិញ្ចឹម | ជាសារធាតុដែលបានមកពីការបំបែកអាហារក្នុងប្រដាប់រំលាយអាហារ ហើយអាចជ្រាបចូលក្នុងកោសិកាជ្រាំងពោះវៀន ដើម្បីទ្រទ្រង់ជីវិតសារពាង្គកាយ ។ |
| ស៊ីកូត | កោសិកាមួយ ដែលបានមកពីការរលាយចូលគ្នារវាងកាម៉េតញីនិងកាម៉េតឈ្មោល ។ |
| ស៊ីមអាហារ | ជាអាហារដែលបានរំលាយនៅក្នុងក្រពះនិងពោះវៀន ។ |
| ស្បូន | សរីរាង្គស្ថិតនៅចន្លោះប្រមោយជាឡូប(ដៃស្បូន)និងផ្លូវភេទដែលជាកន្លែងលូតលាស់នៃគភ៌ ។ |
| សែន | អង្កត់ ADN ស្ថិតនៅត្រង់កន្លែងកំណត់មួយនៃក្រូម៉ូសូម ។ វាមានផ្ទុកព័ត៌មានសម្រាប់កំណត់លក្ខណៈមួយរបស់ភាវៈរស់ ។ |
| ស្លេស្មកស្បូន | ស្លេស្មជាតិបាស ផលិតដោយក្រពេញកស្បូន ។ ស្លេស្មនេះត្រូវបានបញ្ចេញយ៉ាងច្រើននៅពេលដំណើរអូវុល ។ក្រៅពីដំណាក់កាលនេះ វាបង្កើតបានជាសំណាញ់ដើម្បីរារាំងមិនឲ្យស្ពែម៉ាតូសូអ៊ីតភាគច្រើនទៅដល់ ។ |
| ឡូគុស | ទីតាំងនៃសែនមួយនៅលើក្រូម៉ូសូម ។ |
| អង់ស៊ីម | ជាប្រភេទប្រូតេអ៊ីនដែលផលិតឡើងដោយកោសិកា ។ វាមានមុខងារជាកាតាលីករតីមី ជីវៈដែលជម្រុញល្បឿនប្រតិកម្មគីមី ។ |

| | |
|---|---|
| **អង្គលឿង** | លទ្ធផលនៃការបំប្លែងផូលីគុលដ៏ក្រាប ក្រោយដំណើរអូវុលឲ្យទៅជាទម្រង់មួយដែលផ្ទុកជាតិពណ៌លឿង ។ អង្គលឿងនេះផលិតអរម៉ូនប្រូសេស្តេរ៉ូន ។ |
| **អាក្រូសូម** | ថង់ដែលស្ថិតនៅផ្នែកខាងលើនៃក្បាលស្ពែម៉ាតូសូអ៊ីត មានផ្ទុកអង់ស៊ីមសម្រាប់រំលាយភ្នាសស៊ីតូប្លាសរបស់អូវ៉ូស៊ីត ។ |
| **អាមីណូអាស៊ីត ឬអាស៊ីតអាមីនេ** | ជាធាតុបង្ករបស់ប្រូតេអ៊ីន ។ វាកើតពីបណ្តុំកាបុកស៊ីល បណ្តុំអាមីន និងរ៉ាឌីកាល់ R ដែលស្ថិតនៅលើអាតូមកាបូនតែមួយ ។ |
| **អាឡែលលប់មិនពេញលេញ** | ជាអាឡែលពីរនៃសែនតែមួយដែលមានសមត្ថភាពស្មើគ្នាមិនលប់លើគ្នាទាំងស្រុងទេ ។ |
| **អាស៊ីតអាមីនេគ្រឹះ** | ជាអាស៊ីតអាមីនេប្រហែល 10 ប្រភេទ ដែលរាងកាយមិនអាចផលិតបាន ។ អាស៊ីតអាមីនេនេះមាននាទីសំខាន់ណាស់ក្នុងសំយោគប្រូតេអ៊ីន ហើយត្រូវផ្តល់ដោយរបបអាហារ ។ |
| **អ៊ីពែតូនិច** | កំហាប់នៃសារធាតុរលាយខ្ពស់ជាងសូលុយស្យុងដែលត្រូវបានប្រៀបធៀប (កោសិកា) ។ |
| **អ៊ីប៉ូតូនិច** | កំហាប់នៃសារធាតុរលាយទាបជាងសូលុយស្យុងដែលត្រូវបានប្រៀបធៀប (កោសិកា) ។ |
| **អ៊ីសូតូនិច** | ពាក្យសម្រាប់រៀបរាប់ពីសូលុយស្យុងពីរដែលមានកំហាប់សារធាតុរលាយស្មើគ្នា ។ |
| **អឹស្ត្រូសែន** | អរម៉ូនមួយប្រភេទ ដែលផលិតដោយអូវែសម្រាប់ជម្រុញអភិវឌ្ឍន៍លក្ខណៈភេទញីបន្ទាប់និងជម្រុញអភិវឌ្ឍន៍ដំណើរបន្តពូជ ។ |
| **អូមេអូស្តាស** | លំនឹងថេរ គឺការរក្សាលំនឹងមជ្ឈដ្ឋានខាងក្នុងឲ្យនៅដដែល ទោះបីជាស្ថានភាពខាងក្រៅផ្លាស់ប្តូរក៏ដោយ ។ |
| **អូស្មូស** | ជាបន្សាយនៃទឹកឆ្លងកាត់ភ្នាសអឌ្ឍជ្រាបពីតំបន់ដែលមានកំហាប់ម៉ូលេគុលទឹកខ្ពស់ទៅតំបន់មានកំហាប់ម៉ូលេគុលទឹកទាប ។ |
| **ឯកទេសកម្មនៃកោសិកា** | ការបំលែងពីកោសិកាដែលមិនទាន់មានឯកទេសទៅជាកោសិកាមានឯកទេស ។ |
| **ឧបករណ៍គុលស៊ី** | ធាតុកោសិកាមានរាងជាថង់សំប៉ែតត្រួតលើគ្នា ។ វាមាននាទីប្រមូលផ្តុំនិងដឹកនាំប្រូតេអ៊ីនដែលសំយោគរួច ។ |